# របត់នយោបាយ

## សីហនុ - លន់ នល់ - ប៉ុល ពត - ហេង សំរិន - ជា ស៊ីម - ហ៊ុន សែន

### ភាគ ៧









ពីឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៧២

# របត់នយោបាយ

សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហេង សំរិន ~ ជា ស៊ីម ~ ហ៊ុន សែន

ភាគ ៧

ហាមថតចម្លង

**ស្នាដៃនេះត្រូវបានចុះបញ្ជីលេខ ® ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។**

**-សហការីពិនិត្យអក្ខរាវិរុទ្ធ៖**

វេជ្ជបណ្ឌិត អ៊ុន សុវណ្ណ

**-ការីកុំព្យូទ័រ**

១. លោក រ៉ាំ សារឿន

២. លោក ឈឹម មករា

៣. លោក ប៉ោ កុសល

៤. លោក ឈឹម ពុទ្ធី

រក្សាសិទ្ធិ© ឈឹម សេរីភួន គ.ស.២០២៣

ISBN-13 : 978-9924-969-808

ឯកសារប្រវត្តិសាស្ត្រ ដែលមានចំណងជើងថា “ របត់នយោបាយ ” ត្រូវបានចង់ក្រង និងបោះពុម្ពជាសៀវភៅចាប់ពីភាគទី១ រហូតដល់ភាគទី៧នេះ ស្របតាមគតិបណ្ឌិតដ៏ថ្លៃថ្លា និងមនសិការប្រវត្តិសាស្ត្រជាតិដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ដែលចង់ឱ្យកូនខ្មែរសម័យបច្ចុប្បន្ន ក៏ដូចជាជំនាន់ក្រោយៗទៀតទុកជាមេរៀន ដើម្បីសិក្សាពិចារណាស្វែងយល់ពីមូលហេតុ ដែលនាំឱ្យខ្មែរមានជម្លោះបាក់បែកគ្នាដោយសារតែមនោគមវិជ្ជានយោបាយ រហូតដល់ក្លាយជាសង្គ្រាមបង្ហូរឈាមខ្មែរ និងខ្មែរព្រោះតែអំណាចរហូតដល់សព្វថ្ងៃ។

ប្រសិនបើគ្មានការជួយឧបត្ថម្ភគាំទ្រពី **សម្តេចក្រឡាហោម ស ខេង** នោះទេ ក៏គ្មានវត្តមានសៀវភៅឯកសារប្រវត្តិសាស្ត្រដ៏ពិស្តារ និងមានសារៈសំខាន់មួយនេះដែរ។

គតិបណ្ឌិត និងមនសិការប្រវត្តិសាស្ត្រដ៏ថ្លៃថ្លារបស់សម្តេចក្រឡាហោម នឹងចារឆ្លាក់នៅក្នុងបេះដូងរបស់កូនខ្មែរគ្រប់ៗជំនាន់។

**ឈឹម សេរីវឌ្ឍន**

# អារម្ភកថា

ក្នុងសៀវភៅ “ របត់នយោបាយភាគទី៧ ” នេះ ប្រិយមិត្តអ្នកអាននឹងបាន ដឹងពីស្ថានការណ៍សឹកសំខាន់ៗ នៃការវាយប្រយុទ្ធគ្នារវាងទាហានរបប សាធារណរដ្ឋខ្មែរ ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង និងបានយល់ ដឹងពីដំណាក់កាល នៃការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបយ្យរបស់ពួកមេដឹកនាំ ខ្មែរក្រហម ដែលបានយកសម្តេចសីហនុ មកធ្វើជាប្រធានរណសិរ្សរួបរួមជាតិ កម្ពុជា ដើម្បីបំភាន់ភ្នែកប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេស ក៏ដូចជានៅលើឆាក អន្តរជាតិក្នុងការតស៊ូដណ្តើមអំណាចរបស់ពួកគេ។

ជាមួយគ្នានេះ ប្រិយមិត្តអ្នកអាននឹងបានយល់ដឹងពីមូលហេតុ និងអាថ៌ កំបាំងសំខាន់ៗដែលធ្វើឱ្យ លន់ នល់, សិរិមតៈ និងអ៊ិន តាំ ដែលជាវរជន ១៨មីនា មានជម្លោះបែកបាក់ប្រេះឆាគ្នា និងធ្វើឱ្យភូមិសាស្ត្រគ្រប់គ្រងរបស់របបសាធារណ រដ្ឋខ្មែរ កាន់តែរួមតូចទៅៗផងដែរ។

បើលោកអ្នកអានសៀវភៅ ឬឯកសារប្រវត្តិសាស្ត្រ ដែលគ្មានលក្ខណៈ វិទ្យាសាស្ត្រ មិនប្រាកដនិយម នឹងធ្វើឱ្យលោកអ្នកវង្វេងប្រវត្តិសាស្ត្រជាមិនខាន។

ថ្ងៃអង្គារ ១៣រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥
**អ្នកសិក្សាស្រាវជ្រាវ**

**ឈឹម សេរីរត្ន**

# មាតិកា


- ៧.១. ស ខេង ចូលរួមចលនាតស៊ូជាមួយរណសិរ្សរួបរួមជាតិកម្ពុជា........១
- ៧.២. ស ខេង ទៅបម្រើការងារនៅអង្គភាពកាសែតពន្លឺប្ញព៌ា............. ១៣
- ៧.៣. ប្អូនប្រុសទី២ ពលីជីវិតនៅក្នុងសមរភូមិព្រៃកកណ្ដៀង............ ១៨
- ៧.៤. បើកវគ្គនៅភូមិភាគបូព៌ា នួន ជា និងអៀង សារី ចូលរួម ............២៨
- ៧.៥. ជួន មុម្ម ចូលរួមក្នុងចលនាតស៊ូនៅប៉េកាំង.......................... ៣៦
- ៧.៦. ក្រោយរដ្ឋប្រហារ ជួន ប្រាសិទ្ធ ចូលរួមចលនាតស៊ូ
  កុម្មុយនិស្តវិញ...........................................................................៥០
- ៧.៧. ជីវភាពគ្រួសារ និងការសិក្សារបស់ ហ៊ុន សែន.........................៥៨
- ៧.៨. ហ៊ុន សែន និងប៊ុន រ៉ានី ចូលព្រៃម៉ាគី ព្រោះសម្ដេចឪ ...............៦៤
- ៧.៩. កាសែតបរទេសថា៖ សម្ដេចសីហនុយកខ្មោច ខៀវ សំផន, ហ៊ូ យន់
  និងហ៊ូ នឹម មកធ្វើជារដ្ឋមន្ត្រី ..................................................៧៩
- ៧.១០. ចៅ សេង និយាយពីការបែកបាក់ក្នុងជួររណសិរ្សរួបរួមជាតិ ... ៩៣
- ៧.១១.សួង ស៊ីគឿន ចូលចិត្តរឿងនយោបាយតាំងពីរៀននៅ
  អនុវិទ្យាល័យ ....................................................................... ១០១
- ៧.១២.ហួត សម្បត្តិ នៅតែស្មោះត្រង់ជាមួយសម្ដេចសីហនុ ........... ១១៨
- ៧.១៣. វ៉ាន់ ពីនី ពីលេខាស្ថានទូត ក្លាយជាអនុរដ្ឋមន្ត្រី
  ក្រសួងការបរទេស ................................................................ ១២៩
- ៧.១៤. រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងរបស់ពួកខ្មែរក្រហម ..........១៣៤
- ៧.១៥. មេដឹកនាំកុម្មុយនិស្តចិន និងវៀតណាមជួយជ្រោមជ្រែង
  សម្ដេចសីហនុ....................................................................... ១៤៤
- ៧.១៦.ប្រធានាធិបតីអាមេរិក ឱ្យកងទ័ពចូលមកកម្ទេចទីតាំង
  ពួកវៀតកុង ១២កន្លែងក្នុងទឹកដីកម្ពុជា .................................. ១៤៨
- ៧.១៧.លន់ នល់ ចាត់ទុកពួកយួនកុម្មុយនិស្តជាទមិឡអន្សត្ថិរិយ.... ១៥៤

- ៧.១៨. ខៀវ សំផន,ហ៊ូ យន់,ហ៊ូ នឹម,ប៉ុក ដឺសកុមារ ទៅជួប ប៉ុល ពត នៅមន្ទីរមជ្ឈិមបក្សក្បែរស្ទឹងជីនិត ............................... ១៥៩
- ៧.១៩. លន់ នល់ កាត់ទោសសម្តេចសីហនុ និងមហេសី ព្រមទាំងស័ក្តិ៥ គុំ សារ៉ាវ៉ាន់ និងចេង ស៊ីយ៉ុមប៊ិន......................... ១៦៤
- ៧.២០.និស្សិតខ្មែរ បែកបាក់គ្នាក្លាយជាសត្រូវស្លាប់រស់.................. ១៧៤
- ៧.២១.លន់ នល់ ឱ្យសភាប្រកាសរបបសាធារណរដ្ឋខ្មែរជាបន្ទាន់.... ១៨៤
- ៧.២២. ប្រតិបត្តិការសឹកចេនឡាទី២...................................... ១៩៧
- ៧.២៣ សុស្តែន មេបញ្ជាការយោធភូមិភាគ២ឡើង ជានាយអគ្គសេនាធិការ ......................................................... ២១៣
- ៧.២៤ ចូលព្រៃដើម្បីធ្វើបដិវត្តន៍ មិនមែនដើម្បីសម្តេចសីហនុ........ ២២៧
- ៧.២៥ លន់ ណុន រៀបចំផែនការកំចាត់ទ្រង់សិរិមតៈ ................. ២៣៥
- ៧.២៦ របប លន់ នល់ រស់បានដោយសារជំនួយអាមេរិក .............២៤៥
- ៧.២៧ កងទ័ពវៀតកុង ចាប់អ្នកការសែតខ្មែរ និងបរទេស ៦នាក់....២៥៦
- ៧.២៨ លន់ នល់ ឡើងជាសេនាប្រមុខ សិស្ស និស្សិត ធ្វើបាតុកម្ម ប្រឆាំងទ្រង់ សិរិមតៈ ..............................................២៦៩
- ៧.២៩ រដ្ឋាភិបាលប្រកាសចាប់ កុយ ប៊ុច និស្សិត និងសិស្សធ្វើបាតុកម្ម..........................................................២៧៨
- ៧.៣០ រដ្ឋធម្មនុញ្ញ នៃរបបសាធារណរដ្ឋខ្មែរ .............................២៨៦

# ៧.១. ស ខេង ចូលរួមចលនាតស៊ូជាមួយរណសិរ្សរួបរួមជាតិកម្ពុជា



នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧០ សាស្ត្រាចារ្យម្នាក់ឈ្មោះ អ៊ឹម ផុន មានចំណេះដឹងខ្ពស់ជាងសាស្ត្រាចារ្យផ្សេងៗទៀត និងមាននិន្នាការទៅរកពួកខ្មែរក្រហមផងនោះ បានបំផុសឱ្យសិស្សធ្វើបាតុកម្មប្រឆាំងនឹងការធ្វើរដ្ឋប្រហាររបស់ លន់ នល់ កាលពីថ្ងៃទី១៨ ខែមីនានោះ។ សាស្ត្រាចារ្យរូបនេះ បានណែនាំឱ្យសិស្សថ្នាក់ទី៣ម្នាក់ឈ្មោះ ឡូយ សុផាត ដែលសាស្ត្រាចារ្យ និងសិស្សទាំងអស់នៅអនុវិទ្យាល័យកំចាយមារ ស្គាល់គាត់គ្រប់ៗគ្នា ព្រោះគាត់ជាប្រធានក្រុមកីឡាបាល់ទះប្រចាំអនុវិទ្យាល័យ និងមានចិត្តក្លាហានជាងគេទៀតនោះ ឱ្យធ្វើជាមេដឹកនាំបាតុកម្ម។ សាស្ត្រាចារ្យ អ៊ឹម ផុន បានលើកហេតុផលប្រាប់

របត់នយោបាយ

ឡូយ សុផាត ថា ការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នាពេលនេះ ច្បាស់ជាមានការជ្រៀតជ្រែកពីពួកបរទេស ហើយប្រទេសជាតិយើងនឹងធ្លាក់ចូលក្នុងភ្លើងសង្គ្រាមជាមិនខាន។

ពេលនោះ ស ខេង ជាសិស្សថ្នាក់ទី៤ និងសិស្សទាំងអស់នៅអនុវិទ្យាល័យកំចាយមារ សរុបប្រមាណជិត២០០នាក់ ក៏បានចូលរួមក្នុងការធ្វើបាតុកម្មនោះដែរ។

ដោយបានដឹងថា សិស្សនៅក្នុងអនុវិទ្យាល័យកំចាយមារ កំពុងរៀបចំហែក្បួនបាតុកម្មចេញមកក្រៅ កម្លាំងទាហាន និងប៉ូលិសជាច្រើន ត្រូវបានគេដឹកតាមរថយន្តឱ្យទប់ស្កាត់នៅរបងខាងមុខ និងខាងក្រោយអនុវិទ្យាល័យ មិនឱ្យហែក្បួនបាតុកម្មចេញជាដាច់ខាត។ ពេលក្រុមបាតុករនៅតែពុះកញ្ជ្រោលចេញមកក្រៅ ក៏មានការបាញ់គំរាមខ្លះៗដែរ។

ដើម្បីធានាសុវត្ថិភាពក្នុងការហែក្បួនបាតុកម្ម ពិសេសដើម្បីកុំឱ្យពួកទាហាន និងប៉ូលិសបាញ់មកលើក្បួនបាតុកម្ម ឡូយ សុផាត បានជ្រើសរើសពួកកូនៗ និងក្មួយៗមន្ត្រីរាជការដែលធ្វើការនៅសាលាអនុខេត្តកំចាយមារ ក្នុងនោះមានដូចជាក្មួយចៅហ្វាយស្រុក, កូនបាឡាត់ស្រុក, កូនមន្ត្រីប៉ូលិសស្រុក និងកូនៗរបស់អ្នកមានឥទ្ធិពលនៅក្នុងស្រុក ជាដើម ឱ្យដើរមុខក្បួនបាតុកម្ម។ ឃើញដូច្នេះ ពេលហែក្បួនបាតុកម្មចេញមកក្រៅរបងអនុវិទ្យាល័យពួកទាហាន និងប៉ូលិសមិនហ៊ានធ្វើអ្វីឡើយ ហើយបើកផ្លូវឱ្យដង្ហែក្បួនតាមសម្រួល។ ឯក្រុមបាតុករវិញ ក៏មិនបានវាយកម្ទេចផុតបំផ្លាញ ឬលួចឆក់ប្លន់ទ្រព្យសម្បត្តិសាធារណៈ និងប្រើអំពើហិង្សាណាមួយដែរ។

ឡូយ សុផាត ដែលបច្ចុប្បន្នជាប្រធានគណៈកម្មការទី៣ នៃរដ្ឋសភាបានរម្លឹកថា ការធ្វើបាតុកម្មនៅពេលនោះ គឺពួកគាត់ប្រឆាំងនឹងសង្គ្រាម ប្រឆាំងនឹងការជ្រៀតជ្រែកពីបរទេស តែមិនច្បាស់ថា ប្រឆាំងខាងណា ហើយគាំទ្រខាងណានោះទេ គ្រាន់តែដឹងតែថា ពួកគាត់នាំគ្នាធ្វើបាតុកម្មនោះ គឺដើម្បីការពារឯករាជ្យជាតិប៉ុណ្ណោះ។

ពេលល្ងាចថ្ងៃដដែលនោះ ចាប់ពីម៉ោង១៨:០០នាទី-១៩:៣០នាទី យ៉េ ស៊ុនឌីជាអភិបាល និងមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងអនុខេត្តកំចាយមារ បានប្រមូលពួក

របត់នយោបាយ
សិស្សៗដែលបាននាំគ្នាធ្វើបាតុកម្មពីព្រឹកនោះ ឱ្យមកចូលរួមប្រជុំនៅសាលាអនុខេត្ត។ តែ ឡូយ សុផាត មិនហ៊ានចូលទៅប្រជុំទេ ព្រោះគាត់លេចមុខខ្លាំងជាងគេក្នុងការដឹកនាំគ្នាធ្វើបាតុកម្ម។ម្យ៉ាងទៀតគាត់ ក៏មានការភ័យខ្លាចដែរ ព្រោះមានគ្រូបង្រៀន២នាក់ ជាឪពុករបស់មិត្តភក្តិរៀនថ្នាក់ជាមួយគាត់ ត្រូវសមត្ថកិច្ចចាប់យកទៅបាត់។គាត់ក៏សម្រេចចិត្តជិះកង់ត្រឡប់ទៅផ្ទះនៅឯភូមិកំណើត ដើម្បីរង់ចាំស្តាប់សភាពការណ៍ស្រុកទេសបន្តទៀត។

នៅពេលព្រលប់ថ្ងៃដដែលនោះ មានសិស្សប្រមាណ១០នាក់ ក្នុងនោះមានយុវសិស្ស ស ខេង ម្នាក់ដែរ ដែលមិនមែនជាមេដឹកនាំបាតុកម្ម ក៏មានចូលរួមនៅក្នុងអង្គប្រជុំជាមួយ យ៉ៃ ស៊ុនឌី ដែរ។

យ៉ៃ ស៊ុនឌី បានណែនាំពន្យល់ពីមូលហេតុដែលរដ្ឋសភាទម្លាក់សម្តេចសីហនុនៅថ្ងៃទី១៨មីនា ដោយចោទថា សម្តេចសីហនុ ជាជនក្បត់ជាតិ ព្រោះព្រះអង្គបានបើកដៃឱ្យពួកយួនវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅតាមបណ្តោយព្រំដែនទឹកដីកម្ពុជា ដើម្បីធ្វើសង្គ្រាមជាមួយពួករដ្ឋការវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក។ ពេលនោះដែរ យ៉ៃ ស៊ុនឌី ក៏បានអំពាវនាវឱ្យសិស្សទាំងអស់ដែលមានវត្តមាននៅក្នុងអង្គប្រជុំនោះ ស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពរដ្ឋាភិបាល ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងពួកយួនវៀតកុង-វៀតណាមខាងជើង ផងដែរ។

ពេលចប់ប្រជុំនៅម៉ោង១៩:៣០នាទី យ៉ៃ ស៊ុនឌី អភិបាលអនុខេត្តកំចាយមារ ក៏បានផ្តល់ប្រាក់ចំនួន៥០០រៀល ឱ្យទៅសិស្សម្នាក់ឈ្មោះ រី រៀននៅថ្នាក់ទី៣ ដើម្បីយកទៅចែកគ្នា។ ពេលចេញពីប្រជុំភ្លាម ដោយសារខ្លាចគេចាប់យកទៅធ្វើទាហានផង សិស្សដែលបានទៅចូលរួមក្នុងអង្គប្រជុំនោះ ក៏ប្រញាប់ចែកផ្លូវគ្នា រៀបចំសម្ភារៈផ្ទាល់ខ្លួនរួចជិះកង់វិលត្រឡប់ទៅភូមិកំណើតវិញទាំងយប់ ដោយមិនហ៊ាននៅរង់ចាំទទួលប្រាក់ចំណែកដែលអភិបាលអនុខេត្តកំចាយមារ យ៉ៃ ស៊ុនឌី ផ្តល់ឱ្យសិស្សថ្នាក់ទី៣ ឈ្មោះ រី ទុកឱ្យយកមកចែកគ្នានោះឡើយ។

របត់នយោបាយ

យ៉ៃ ស៊ុនឌី កើតនៅឆ្នាំ១៩២៧ នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ឪពុកឈ្មោះ យ៉ៃ សុបិន ម្តាយឈ្មោះ និត។ កាលវ័យកុមារ គាត់បានចូលរៀននៅសាលាបឋមសិក្សាក្រុងបាត់ដំបង។ ក្រោយបញ្ចប់ថ្នាក់បឋមសិក្សា គាត់បានបន្តការសិក្សានៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ នៅរាជធានីភ្នំពេញ រួចគាត់បានទៅបន្តសិក្សានៅវិទ្យាល័យសាស៊្សីលូឡូបា នៅទីក្រុងព្រៃនគរបន្តទៀត។ នៅចុងទសវត្សរ៍ឆ្នាំ១៩៤០ គាត់បានទៅសិក្សានៅប្រទេសបារាំង រហូតទទួលបានសញ្ញាបត្របរិញ្ញាច្បាប់ ទើបគាត់វិលត្រឡប់មកបម្រើការងារជាមន្ត្រីរាជការនៅមាតុប្រទេសវិញ ហើយបានរៀបការជាមួយកញ្ញា អែម យ៉ុន។

ក្រោយមកទៀត គាត់បានទៅសិក្សាខាងយោធានៅប្រទេសអាល្លឺម៉ង់។ ពេលត្រឡប់មកវិញ គាត់បានទទួលតំណែងជាមេបញ្ជាការទាហាននៅបន្ទាយភ្នំប្រុសភ្នំស្រី ខេត្តកំពង់ចាម។ បន្ទាប់មក ជាមេបញ្ជាការទាហាន នៅបន្ទាយខេត្តកំពង់ស្ពឺ និងជាមេបញ្ជាការទាហាននៅខេត្តពោធិ៍សាត់។ លុះដល់ឆ្នាំ១៩៦៩ តាមព្រះរាជក្រមលេខ ៤០៤/៦៩ប.ករាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម បានបង្កើតអនុខេត្តកំចាយមារ ដែលរួមមាន៣ស្រុក គឺស្រុកពញាក្រែក, ស្រុកកំចាយមារ និងស្រុកមេសាង។ ទីប្រជុំជនរបស់អនុខេត្តនេះ ស្ថិតនៅក្នុងភូមិដោរ៍ ឃុំជាច ស្រុកកំចាយមារ។ គោលដៅសំខាន់បំផុតនៃការបង្កើតអនុខេត្តកំចាយមារនេះ គឺដើម្បីពង្រឹងសន្តិសុខក្នុងស្រុកទាំងបី។

ពេលនោះ យ៉ៃ ស៊ុនឌី ត្រូវបានតែងតាំងជាអភិបាលអនុខេត្តកំចាយមារ និងជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករង នៃអនុខេត្តនេះផងដែរ។ ក្រោយមក គាត់ត្រូវបានសេនាប្រមុខ លន់ នល់ តែងតាំងឱ្យធ្វើជាមេបញ្ជាការកងរថក្រោះ ក្នុងជួរកងទ័ពនៃរបបសាធារណរដ្ឋខ្មែរ។

ទោះបីពេលនោះ ប្រទេសជាតិកើតមានចលាចលវឹកវរបង្កដាភ្លើងសង្គ្រាមឆាបឆេះឡើង នៅអនុវិទ្យាល័យកំចាយមារ ក៏ដូចជាគ្រឹះស្ថានសិក្សានៅទីតំបន់ជនបទផ្សេងៗជាច្រើនទៀត ត្រូវបានបិទទ្វារក៏ពិតមែន តែយុវជន ស ខេង នៅតែចង់ទៅបន្តការ

របត់នយោបាយ

សិក្សានៅទីរួមខេត្តព្រៃវែង ឬទីក្រុងភ្នំពេញ ឱ្យបានដល់ថ្នាក់ឧត្តមសិក្សាដូចចិត្ត ប៉ងប្រាថ្នាពីមុនមកដែរ តែគាត់គ្មានសាច់ញាតិ មីងមា បងប្អូនណានៅទីនោះ គ្រាន់ស្នាក់អាស្រ័យ ដូច្នេះគាត់គ្មានជម្រើសអ្វីក្រៅតែពីត្រូវបង្ខំចិត្តបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៤ នៅអនុវិទ្យាល័យកំចាយមារ ដែលត្រូវបិទទ្វារនោះឡើយ។ ជាមួយគ្នានោះដែរ គាត់បានពិចារណាថ្លឹងថ្លែងថា តើត្រូវសម្រេចចិត្តចូលធ្វើទាហានតាមការអំពាវនាវរបស់ យ៉ៃ ស៊ុនឌី អភិបាលអនុខេត្តកំចាយមារ? ឬមួយត្រូវរត់ចូលព្រៃម៉ាគីតាមការអំពាវនាវរបស់សម្តេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីប្រឆាំងនឹងពួកមេដឹកនាំធ្វើរដ្ឋប្រហារ លន់ នល់ វិញ? ។ ក្រោយពីធ្វើការពិចារណាយ៉ាងល្អិតល្អន់ និងមើលឃើញអំពីទុក្ខលំបាកវេទនារបស់ប្រជាកសិករទូទៅដូចគ្រួសារគាត់ដែរ គាត់បានសម្រេចចិត្តចូលរួមចលនាតស៊ូជាមួយសម្តេចសីហនុ ដើម្បីរំដោះប្រទេសជាតិ។

ក្នុងខែឧសភា ឆ្នាំ១៩៧០ ស ខេង ក៏បានចូលបម្រើការងារជាស្មៀនរបស់ឪពុកមាគាត់ម្នាក់ឈ្មោះ ស ថុន ត្រូវប្អូនបង្កើតរបស់ឪពុកគាត់ (ឪពុកតែមួយម្តាយទីទៃ) ដែលមានតួនាទីជាសមាជិកគណៈកម្មាធិការឃុំក្របៅ ទទួលបន្ទុកសេដ្ឋកិច្ច នៅក្នុងស្រុកកំចាយមារ តំបន់២០។ ឪពុកមាគាត់ម្នាក់នេះ គឺជាកសិករសុទ្ធសាធពុំបានរៀនសូត្រចេះដឹងជ្រៅជ្រះនោះទេ គឺគ្រាន់តែអាចអាន និងសរសេរអក្សរខ្មែរបានខ្លះៗប៉ុណ្ណោះ។ ភារកិច្ចដំបូងរបស់យុវជន ស ខេង គឺធ្វើដំណើរតាមឪពុកមា ស ថុន ដែលចុះទៅតាមភូមិនានាក្នុងឃុំ ធ្វើការប្រជុំជាមួយប្រជាជន ដើម្បីឃោសនាចលនានយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា បំផុសឱ្យប្រជាជនខិតខំបង្កបង្កើនផល និងបំផុសឱ្យយុវជនចូលបម្រើក្នុងជួរកងទ័ពរំដោះប្រឆាំងនឹងរបប លន់ នល់។

ស ខេង រម្លឹកថា៖ សម័យនោះនៅក្នុងឃុំក្របៅ ក៏ដូចជាឃុំផ្សេងៗទៀតដែរ នៅតាមឃុំនីមួយៗពុំមែនមានស្មៀនម្នាក់ទេ គឺក្នុងចំណោមគណៈកម្មាធិការឃុំក្របៅទាំង៥នាក់ មានស្មៀន១ម្នាក់ ដូច្នេះក្នុងមន្ទីរឃុំក្របៅ មានស្មៀនមួយក្រុមមានគ្នា៥នាក់ ក្នុងនោះ បងប្រុសជីដូនមួយរបស់គាត់ម្នាក់ ជាប្រធានក្រុមឈ្មោះ ដួន ធឿន និងជា

របត់នយោបាយ

ស្មៀនរបស់ ជា ស៊ីម លេខាគណៈកម្មាធិការបក្សឃុំក្របៅ។ ជួន ធឿន ជាអតីតស្មៀននៅសាលាស្រុកកំចាយមារ ជាមន្ត្រីស្ទាត់ជំនាញខាងវាយអង្គុលីលេខផងដែរ។ ក្រោយមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បងប្រុសជីដូនមួយរបស់គាត់ម្នាក់នេះ បានចូលរួមក្នុងចលនាតស៊ូរំដោះសិរ្សរួបរួមជាតិកម្ពុជា។

ពេលបំពេញការងារជាស្មៀនជាមួយគ្នានោះ ស ខេង តែងតែឆក់ឱកាសស្នើសុំឱ្យបងប្រុស ជួន ធឿន ជួយបង្ហាត់បង្រៀនវាយអង្គុលីលេខដើម្បីបង្កើនចំណេះដឹង និងសមត្ថភាពការងារ។ ដោយសារភាពឈ្លាសវៃផងដែរ ត្រឹមតែរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ យុវជន ស ខេង ក៏ចេះវាយអង្គុលីលេខបានជាបណ្តើរៗ។

ចាប់ពីពេលនោះមក ការគ្រប់គ្រងឯកសាររដ្ឋបាល និងឯកសារផ្សេងៗនៅមន្ទីរឃុំ ស ខេង ជាអ្នករ៉ាប់រងតាក់តែង រៀបចំទុកដាក់ និងទទួលខុសត្រូវវាយអង្គុលីលេខទៀតផង។ ដោយសារការងារទាំងនេះ ធ្វើឱ្យគាត់មានការយល់ដឹងពីប្រព័ន្ធរដ្ឋបាល និងគោលនយោបាយ នៅថ្នាក់មូលដ្ឋានបន្តិចម្តងៗចាប់ពីពេលនោះមក។

ដោយមើលឃើញពីសមត្ថភាពការងារ និងសីលធម៌រស់នៅរបស់យុវជន ស ខេង ដែលលេចធ្លោជាងគេក្នុងចំណោមស្មៀនដទៃទៀត នៅក្នុងខែកក្កដា ឆ្នាំ១៩៧១ ហែម បូ លេខាគណៈកម្មាធិការបក្សស្រុកកំចាយមារ បានស្នើសុំយុវជន ស ខេង ឱ្យទៅធ្វើជាស្មៀននៅមន្ទីរស្រុកកំចាយមារ វិញ។ មន្ទីរស្រុកកំចាយមារ នៅពេលនោះ មានទីតាំងស្ថិតនៅក្នុងភូមិក្របៅ និងភូមិអណ្តូងស្អាត ក្នុងឃុំក្របៅ នោះតែម្តង។

នៅពេលបំពេញការងារជាស្មៀន នៅមន្ទីរស្រុកកំចាយមារ កាន់តែធ្វើឱ្យយុវជន ស ខេង មានការរីកចម្រើនទាំងផ្នែកសមត្ថភាព និងយល់ដឹងទាំងលើការងារគ្រប់គ្រងរដ្ឋបាល ការងារសន្តិសុខ និងសភាពការណ៍នយោបាយស្រុកទេសជាលំដាប់។ មិនយូរប៉ុន្មានយុវជន ស ខេង បានចូលជាសម្ព័ន្ធយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) និងត្រូវបានចាត់តាំងឱ្យធ្វើជា អនុប្រធានសមាគមយុវជនស្នេហាជាតិស្រុកកំចាយមារ បន្ថែមលើតួនាទីជាស្មៀនរបស់មន្ទីរស្រុក ថែមទៀត។ នៅពេលនោះ សមាគមយុវជន

របត់នយោបាយ
ស្នេហាជាតិស្រុកកំចាយមារ មានឈ្មោះ អ៊ុន ឈឹម ហៅ ផក់ ជាប្រធាន, ឈ្មោះ វណ្ណៈ ជាអនុប្រធានទី១, ស ខេង ជាអនុប្រធានទី២ និងសមាជិកគណៈកម្មការសមាគម៦ រូបទៀត រួមមាន៖ ឡូយ សុផាត (មេដឹកនាំបាតុកម្មនៅអនុវិទ្យាល័យកំចាយមារ ថ្ងៃ២៣ ខែមីនា ឆ្នាំ១៩៧០), ឈុន ឈន់ (បច្ចុប្បន្នប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ), វណ្ណារ៉ា មកពីស្រុកកញ្ជ្រៀច (ស្លាប់ក្នុងឆ្នាំ១៩៧៨) និងយុវជន៣នាក់ ទៀត។

ក្រោយពីបានទទួលការចាត់តាំង ជាអនុប្រធានទី២ របស់សមាគមយុវជនស្នេហាជាតិមក ស ខេង មិនសូវបានបំពេញការងារនៅមន្ទីរស្រុក ទេ គាត់ និងមិត្តវណ្ណៈ អនុប្រធានទី១ របស់សមាគម ព្រមទាំងសមាជិកមួយចំនួនទៀត ត្រូវថ្នាក់លើចាត់តាំងឱ្យចុះទៅបំពេញភារកិច្ចនៅតាមឃុំទាំង៨ នៅក្នុងស្រុកកំចាយមារ ដែលរួមមាន៖ ឃុំក្របៅ, ឃុំជាច, ឃុំក្រញូង, ឃុំស្មោងខាងជើង, ឃុំស្មោងខាងត្បូង, ឃុំដូនកឹង, ឃុំត្របែក និងឃុំសៀងឃ្វាង។

ពេលចុះទៅបំពេញភារកិច្ចនៅតាមឃុំម្តងៗ ពួកគាត់រួមគ្នាជាមួយនឹងសមាគមនារីស្នេហាជាតិស្រុក ផងដែរ ត្រូវធ្វើដំណើរដោយថ្មើរជើង គឺពុំមានកង់ជិះនោះទេ។ គណៈកម្មការសមាគមនារីស្នេហាជាតិស្រុក ដែលបានចូលរួមដំណើរចុះទៅបំពេញភារកិច្ចនៅតាមឃុំកាលពីពេលនោះ ក៏មាននារីម្នាក់ឈ្មោះ អ៊ំ សំ (ក្រោយមកបានក្លាយជាភរិយារបស់ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ នៃព្រឹទ្ធសភានីតិកាលទី៤)។ ក្រៅពីបំពេញការងារស្នូលជាស្មៀននៅមន្ទីរស្រុក និងជាអនុប្រធានទី២ សមាគមយុវជនស្នេហាជាតិស្រុកកំចាយមារ យុវជន ស ខេង ក៏បានចូលរួមដាំបន្លែបង្ការផ្សេងៗ និងជួយដឹកជញ្ជូនស្បៀងដើម្បីផ្គត់ផ្គង់អង្គភាពផងដែរ។

ស ខេង រម្លឹកបន្តថា៖ ពេលមួយនោះ គាត់បានទៅជួយដឹកអង្ករជាមួយ អ៊ំ យ៉ែម ហៅ សុខ ជាអនុប្រធានមន្ទីរស្រុកកំចាយមារ នៅរោងម៉ាស៊ីនកិនស្រូវ នៅឯភូមិកំចាយមារ ក្នុងឃុំក្រញូង។ កាលនោះ តាមបណ្តោយផ្លូវជាតិលេខ៨ ពីទីតាំងមន្ទីរស្រុក ដែលឋិតនៅក្នុងឃុំក្របៅ ទៅឃុំក្រញូងនោះ មានស្ពានដែកបេឡេមួយប្រវែងប្រហែល២៥ម៉ែត្រ

ត្រូវយន្តហោះអាមេរិក មកទម្លាក់គ្រាប់បែកបណ្ដាលឱ្យ បាក់ស្រុតផុងចំកណ្ដាលក្លាយជារាងអក្សរវ៉េ (V) នោះ គេបានយកបន្ទះក្ដារឈើវែងៗ ដាក់ជាស្ពូ ដើម្បីឱ្យមនុស្សដើរឆ្លងទៅមក។ តែបើអ្នកជិះកង់ ត្រូវចុះបណ្ដើរ ទើបអាចឆ្លងបាន។ ពេលជិះកង់ដឹកអង្ករមួយបាវធំទម្ងន់១០០គីឡូក្រាម មកពីរោងម៉ាស៊ីនកិនស្រូវ នៅឯភូមិកំចាយមារ មកដល់ស្ពាននេះ គាត់ត្រូវទម្លាក់បាវអង្ករទម្ងន់១០០គីឡូក្រាមនោះ ចេញពីលើរានកង់ ហើយលីដើរស្ទួលើស្ពូបន្ទះក្ដារឈើដោយកាន់បង្កាន់ដៃស្ពាន ដើម្បីជួយទប់ខ្លួនឆ្លងទៅដល់ត្រើយម្ខាង រួចលើកបាវអង្ករទម្ងន់១០០គីឡូក្រាមនោះ ដាក់លើរានកង់វិញ។ អ៊ំ យ៉ែម ហៅ សុខ អនុប្រធានមន្ទីរស្រុក ឃើញដូច្នោះ ក៏លាន់មាត់ថា៖យី! ខេងឯងអី ក៏ខ្លាំងម្លេះ?។ ស ខេង កាលនោះមានវ័យ២០ឆ្នាំ ឆ្លើយវិញថា៖ "ខ្ញុំនៅក្មេងខ្លាំងអីចឹងហើយអ៊ំ...!" រួចហើយគាត់ក៏នាំគ្នាដឹកបាវអង្ករបន្តដំណើរទៅដល់មន្ទីរស្រុកវិញដោយសុវត្ថិភាព។

ក្នុងខែតុលា ឆ្នាំ១៩៧១ អង្គការបដិវត្តន៍បានចាត់តាំងបើកវគ្គរៀនសូត្រនយោបាយមួយមានរយៈពេល១ខែ ដើម្បីអប់រំបំពាក់បំប៉នកម្មាភិបាលថ្នាក់ឃុំ និងកម្មាភិបាលថ្នាក់ស្រុកប្រមាណ២០០នាក់។ នេះជាលើកដំបូងហើយ ដែលយុវជន ស ខេង បានចូលរៀនសូត្រវគ្គនយោបាយ។ ខ្លឹមសារនៃវគ្គនយោបាយនោះ គឺរៀនសូត្រពីទស្សនៈសភាពការណ៍កម្ពុជា, ពីបុព្វហេតុនៃការតស៊ូដើម្បីប្រឆាំងនឹងរបប លន់ នល់ និងពីការឈ្លានពានរបស់ចក្រពត្តិអាមេរិក ព្រមទាំងពីបុព្វហេតុនៃការតស៊ូវណ្ណៈប្រឆាំងនឹងរបបសក្តិភូមិ និងពីចលនាតស៊ូរបស់យុវជននៃបណ្ដាប្រទេសនានា នៅលើសាកលលោក។

ជាមួយគ្នានោះ ក៏បានសិក្សារៀនសូត្រពីទស្សនវិជ្ជាបដិច្ចសមុប្បាទ គឺជាធម៌ ឬសភាវៈដែលកើតមានឡើងដោយសារបច្ច័យដែលមានន័យថា អ្វីៗតែងតែមានទំនាស់គ្នា អ្វីៗតែងតែមានការផ្លាស់ប្ដូរ អ្វីៗតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមក, អ្វីៗតែងតែមានការវិវត្តពីតិចទៅច្រើន ពីតូចទៅធំ ឬពីក្មេងទៅចាស់...ជាដើម។

អ្នកឧទ្ទេសនាមឯកសារនយោបាយនៅពេលនោះ មានឈ្មោះ ស៊ុន ហៅ ខឹម

របត់នយោបាយ

លេខាគណៈកម្មាធិការតំបន់២០ និងជា ស៊ីម លេខាគណៈកម្មាធិការស្រុកពញាក្រែក ព្រមទាំងឈ្មោះ ស៊ី មន ជាអតីតទាហានបារាំង នៅខេត្តកំពង់ឆ្នាំង តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៤០ តែក្រោយមកគាត់បានរត់ទៅចូលរួមជាមួយចលនាតស៊ូខ្មែរឥស្សរៈប្រឆាំងនឹងបារាំងវិញ។ ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ គាត់ក៏បានចាកចេញពីមាតុប្រទេស ជាមួយពួកខ្មែរឥស្សរៈប្រមាណជាង១០០០នាក់ទៀត ទៅរស់នៅវៀតណាមភាគខាងជើង។ ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស៊ី មន បានវិលត្រឡប់មកមាតុភូមិវិញ ដើម្បីចូលរួមក្នុងចលនាតស៊ូប្រឆាំងនឹងរបប លន់ នល់ និងចក្រពត្តិអាមេរិក ជាបន្តទៀតក្នុងតួនាទីជាអ្នកបង្ហាត់បង្រៀនឧទ្ទេសនាមឯកសារអប់រំនយោបាយដល់កម្មាភិបាលតំបន់ និងស្រុកនានាក្នុងភូមិភាគបូព៌ា។

តែក្រោយមកដោយសារ ប៉ុល ពត មេដឹកនាំបដិវត្តន៍នៅក្នុងប្រទេសចាត់ទុកថាគាត់ជាពួកក្បាលយួនខ្លួនខ្មែរ ក៏ចាប់យកទៅដាក់គុក គាត់រត់គេចខ្លួន ក៏ត្រូវស្លាប់នៅតាមផ្លូវ។

ក្រោយពេលរៀនចប់ កម្មាភិបាលជាសិក្ខាកាមទាំងអស់ត្រូវសរសេរជីវទស្សន៍ គឺជាការឆ្លុះកញ្ចក់ត្រួតពិនិត្យមើលខ្លួនឯង ដោយលើកឡើងពីចំណុចល្អជាគុណសម្បត្តិ និងចំណុចមិនល្អជាគុណវិបត្តិ រួចធ្វើការប្ដេជ្ញាចិត្តកែប្រែចំណុចមិនល្អនោះ កុំឱ្យកើតមានទៀត ព្រមទាំងបញ្ជាក់ពីគោលជំហរធ្វើបដិវត្តន៍របស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងរឹងមាំថែមទៀតផងដែរ។

ក្រោយពីបញ្ចប់វគ្គនយោបាយរយៈពេលមួយខែនោះមក យុវជន ស ខេង ដែលជាអនុប្រធានទី២ នៃសមាគមយុវជនស្នេហាជាតិស្រុក បានបន្តចុះធ្វើការឃោសនាអប់រំនៅតាមភូមិឃុំ ដើម្បីឱ្យកម្មាភិបាល និងប្រជាជននៅមូលដ្ឋានបានយល់ដឹងពីសភាពការណ៍កម្ពុជា, បុព្វហេតុនៃការតស៊ូដើម្បីប្រឆាំងនឹងរបប លន់ នល់ ប្រឆាំងនឹងចក្រពត្តិអាមេរិក និងបុព្វហេតុនៃការតស៊ូវណ្ណៈជាដើម...។

ចំណែក ឡូយ សុផាត សមាជិកគណៈកម្មាធិការសមាគមយុវជនស្នេហាជាតិស្រុក

របត់នយោបាយ

ក្រោយពីបានរៀនសូត្រវគ្គនយោបាយរយៈពេល១ខែនោះមក ដោយសារមានទស្សនៈមិនសូវចុះសម្រុងនឹងគ្នាជាមួយមិត្តភក្តិនៅក្នុងអង្គភាព ពីបញ្ហាទ្រឹស្តីនៃការធ្វើបដិវត្តន៍តស៊ូវណ្ណៈ និងទ្រឹស្តីនៃការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនៅ ដើមឆ្នាំ១៩៧២ គាត់ក៏បានសួរយោបល់ ស ខេង ថា តើគួរនៅធ្វើជាសមាជិកសមាគមយុវជនស្នេហាជាតិស្រុកបន្តទៀត ឬមួយចេញទៅធ្វើយោធាវិញ? ពេលនោះ ស ខេង ក៏បានឱ្យយោបល់ថា ដើម្បីកុំឱ្យមានបញ្ហាដល់ខ្លួន មិត្តគួរតែទៅធ្វើយោធាវិញ ប្រសើរជាង...។

នៅក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧២ ស ខេង ត្រូវបានគណៈកម្មាធិការបក្សស្រុកវាយតម្លៃថា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលអាចបញ្ចូលជាបក្ខជនត្រៀមបាន។ ពិធីបញ្ចូលជាបក្ខជនត្រៀមនោះ បានធ្វើនៅលើផ្ទះប្រជាជនមួយខ្នងសង់អំពីឈើប្រក់ក្បឿងជាប្រភេទផ្ទះប៉ិតពីរខ្នង ឋិតនៅក្នុងភូមិថ្នល់កែង ឃុំស្មោងខាងជើង (បច្ចុប្បន្នស្ថិតនៅខាងត្បូងសាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ) ដោយមាន អ៊ុន ឈឹម ហៅ ជក់ ប្រធានសមាគមយុវជនស្នេហាជាតិ និងជាបក្ខជនជំនាន់មុនជាអធិបតី។

ចុងក្រោយនៃពិធីបញ្ចូលជាបក្ខជនត្រៀមនោះ គេឱ្យគាត់ប្តេជ្ញាចិត្តស្មោះត្រង់ និងដើរតាមមាគ៌ានយោបាយរបស់បក្ស ស្មោះត្រង់នឹងជាតិមាតុភូមិ ដោយហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាង។ តែពេលនោះ គាត់មិនយល់ថា អ្វីទៅជាបក្ខជនរបស់បក្សកុម្មុយនិស្តឡើយ។ តែយ៉ាងណា នេះអាចចាត់ទុកជាចំណុចចាប់ផ្តើមជីវិតនយោបាយរបស់គាត់ក្នុងវ័យ២១ឆ្នាំ នោះដែរ។

ក្រោយពីបានចូលជាបញ្ចូលជាបក្ខជនត្រៀមមក គណៈកម្មាធិការបក្សស្រុកបានបំពាក់បំប៉នគោលជំហរបដិវត្តន៍ ឧត្តមគតិស្នេហាជាតិ ជាប់ជាប្រចាំ ហើយគាត់ក៏បានព្យាយាមហាត់ពត់លត់ដំកសាងខ្លួននៅក្នុងចលនាតស៊ូឱ្យបានល្អប្រសើរដែរ។

ក្រោយពីឋិតនៅជាបក្ខជនត្រៀមរយៈពេល៦ខែមក ដោយផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខន្តិកៈបក្ស នៅក្នុងខែធ្នូ ឆ្នាំ១៩៧២ គាត់ត្រូវបានគណៈកម្មាធិការបក្សស្រុក ឱ្យចូលជាបក្ខជនពេញសិទ្ធិ។

របត់នយោបាយ

ឈុន ឈន់ (បច្ចុប្បន្នជា ប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ) បានរម្លឹកថា ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដំបូងគាត់បានចូលបម្រើការងាររដ្ឋបាលក្នុងឃុំដាច។ បន្ទាប់មក គាត់មានបំណងចូលធ្វើជាយោធាដែរ ប៉ុន្តែ គណៈកម្មាធិការឃុំដាច បានឃាត់គាត់ឱ្យនៅជួយបម្រើការងារក្នុងឃុំសិន។ លុះដល់ឆ្នាំ១៩៧១ គាត់ត្រូវបានចាត់តាំងឱ្យមកបម្រើការងារនៅមន្ទីរស្រុកកំចាយមារ ជាមួយ ស ខេង ដែរ។ គាត់ជាអ្នកទទួលការងារសរសេរចម្លងឯកសារផ្សេងៗដោយដៃ។ ចំណែក ស ខេង ជាអ្នកវាយអង្គុលីលេខ។

ឈុន ឈន់ រម្លឹកបន្តថា នៅក្នុងខែមីនា ឆ្នាំ១៩៧២ គាត់បានចូលជាបក្ខជនត្រៀម។ ពេលនៅជាបក្ខជនត្រៀមនោះ គាត់បានចូលរួមជាមួយ ស ខេង, ឡូយ សុផាត, អ៊ុន ឈឹម ហៅ ជក់, ប្រាក់ សុវណ្ណ និងជៀម ហ៊ឹម ចុះទៅតាមមូលដ្ឋានភូមិឃុំ ដើម្បីឃោសនាអប់រំឱ្យប្រជាជនយល់ដឹងពីសភាពការណ៍ស្រុកទេស ពីការឈ្លានពានរបស់ចក្រពត្តិអាមេរិក និងពួក លន់ នល់ សិរិមតៈ ដែលបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ចេញពីអំណាចបណ្តាលឱ្យកើតវឹកវរមានសង្គ្រាមពេញផ្ទៃប្រទេស ហើយពួក លន់ នល់ សិរិមតៈ បានឱ្យយន្តហោះអាមេរិក មកទម្លាក់គ្រាប់បែកសម្លាប់ប្រជាជន យុវជន និងកុមារខ្មែររាប់ពាន់រាប់ម៉ឺននាក់...។ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧២ គាត់ត្រូវបានបញ្ចូលជាបេក្ខជនពេញសិទ្ធិ ដែលពេលនោះមាន ជា ស៊ីម ជាលេខាគណៈកម្មាធិការបក្ស និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនឃុំក្របៅ ជាអ្នកឧទ្ទេសនាម។

អ៊ុន ឈឹម ហៅជក់ (អតីតប្រធានសមាគមយុវជនស្នេហាជាតិស្រុកកំចាយមារ) បានរម្លឹកថា ជាមួយនឹងតួនាទីជាប្រធានសមាគមយុវជនស្នេហាជាតិស្រុក គាត់មានតួនាទីជាលេខាសម្ព័ន្ធយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) នៅក្នុងជួរបក្សផងដែរ។ សម័យនោះយុវជនណាដែលត្រូវអង្គការបដិវត្តន៍ បញ្ចូលជាសមាជិកពេញសិទ្ធិរបស់សម្ព័ន្ធយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) លុះត្រាតែយុវជននោះមានគោលជំហរធ្វើបដិវត្តន៍ ដោយស្មោះស្ម័គ្រ និងបញ្ចេញសកម្មភាពជាក់ស្តែងក្នុងចលនាតស៊ូ ពិសេសត្រូវពិនិត្យលើ

របត់នយោបាយ

វណ្ណៈភាព។ បើយុវជនដែលមានវណ្ណៈភាពជាកសិករមាន មុននឹងចូលជាសមាជិកសម្ព័ន្ធយុវកក ត្រូវត្រៀមរយៈពេល៩ខែ។ យុវជនដែលមានវណ្ណៈភាពជាកសិករកណ្ដាល ត្រូវត្រៀមរយៈពេល៦ខែ និងយុវជនដែលមានវណ្ណៈភាពជាកសិករក្រ ត្រូវត្រៀមរយៈពេលតែ៣ខែប៉ុណ្ណោះ។ ការកំណត់រយៈពេលត្រៀមនេះ គឺអាស្រ័យលើគណៈកម្មាធិការបក្សស្រុក ជាអ្នកវាយតម្លៃ និងសម្រេច។



**ទាហានវៀតណាមខាងត្បូង ចូលមកបោសសម្អាត កងទ័ពវៀតកុង នៅស្រុកត្បូងឃ្មុំ និងស្រុកមេមត់ (ថ្ងៃទី១២/០៧/១៩៧០)**

# ៧.២. ស ខេង ទៅបម្រើការងារនៅអង្គភាព កាសែតពន្លឺបូព៌ា




**មន្ទីរនីរសាភូមិភាគ**

នៅចុងខែវិច្ឆកា ឆ្នាំ១៩៧២ សោ ភឹម ជាលេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា (ភូមិភាគ២០៣) បានដាក់ផែនការឱ្យ សុក ខ្នុល ហៅ ពាម ឬហៅ លីន (អតីតនិស្សិតមកពីប្រទេសបារាំង) ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគ និងជាប្រធានមន្ទីរភូមិភាគឱ្យជ្រើសរើសកម្មាភិបាលនៅក្នុងតំបន់២០ ចំនួន៥នាក់ ដើម្បីយកទៅបម្រើការងារនៅអង្គភាពកាសែតពន្លឺបូព៌ា។ ក្រោយពីទទួលផែនការនេះ សុក ខ្នុល ហៅ ពាម ឬហៅ លីន បានទាក់ទងទៅលេខាគណៈកម្មាធិការបក្សតំបន់២០ ឈ្មោះគង់ ជាស៊ិន ហៅស៊ិន ហៅ ខឹម ឱ្យជ្រើសរើសយុវជនដែលមានសមត្ថភាព និងមានកម្រិតវប្បធម៌គ្រាន់បើក្នុងមួយស្រុកម្នាក់។

ពេលនោះ មានយុវជន៥នាក់ត្រូវ បានជ្រើសរើស ក្នុងនោះរួមមាន៖ ១.ស ខេង មកពីស្រុកកំចាយមារ, ២. ទឹម ផន មកពីស្រុកព្រៃវែង, ៣.ជី សាខន មកពីស្រុកមេសាង, ៤.ប៊ុន សុវណ្ណ មកពីស្រុកពញាក្រែក និង៥.ព្រុំ ឈៀង មកពីស្រុកកញ្ជ្រៀច។

របត់នយោបាយ

នៅថ្ងៃអាទិត្យទី៣ ខែធ្នូ ឆ្នាំ១៩៧២ ពួកគាត់ទាំង៥នាក់បានជួបជុំគ្នានៅមន្ទីរឃុំដាច ក្នុងស្រុកកំចាយមារ ហើយ ស៊ុន ហៅ ខឹម លេខាគណៈកម្មាធិការតំបន់២០ បានឱ្យអ្នកបើករថយន្តម្នាក់ឈ្មោះមិត្ត សយ បើករថយន្តហ្ស៊ីបអាជី(Jeep A2) ផលិតនៅសហរដ្ឋអាមេរិក មកដឹកពួកគាត់ទាំង៥នាក់ យកទៅស្នាក់ការនីរសារភូមិភាគ ដែលឋិតនៅអតីតទីរួមស្រុកអូររាំងឪ។ នៅស្នាក់ការសាខានីរសារភូមិភាគនោះ ហេង សំកៃ (បងបង្កើតរបស់ ហេង សំរិន) ជាអ្នកទទួលខុសត្រូវនៅទីនោះ បានរៀបចំបាយទឹក និងឱ្យពួកគាត់សម្រាកនៅទីនោះមួយយប់។ លុះព្រឹកឡើងមានរថយន្តយោធាមួយគ្រឿង ផលិតនៅប្រទេសចិន បានមកដឹកពួកគាត់ទៅតាមផ្លូវចម្ការកៅស៊ូជប់ ឆ្ពោះទៅទិសខាងជើងសំដៅទៅស្នាក់ការនីរសារភូមិភាគមួយទៀត ឋិតនៅក្នុងចម្ការកៅស៊ូត្រពាំងឫស្សី ក្នុងឃុំឈូក ស្រុកក្រូចឆ្មារ។បុគ្គលិកបម្រើការនៅស្នាក់ការនីរសារនោះ ទទួលពួកគាត់យ៉ាងរាក់ទាក់ និងរៀបចំបាយថ្ងៃត្រង់ឱ្យពួកគាត់ហូបជុំគ្នា។

លុះដល់ វេលាម៉ោង៣រសៀល គេបានឱ្យនីរសារម្នាក់ នាំពួកគាត់ពីចម្ការកៅស៊ូត្រពាំងឫស្សី ធ្វើដំណើរឆ្ពោះទៅឃុំរកាខ្នុរ កាត់តាមព្រៃត្រោក ជាព្រៃឫស្សីមានកម្ពស់ពី ១០ម៉ែត្រ ទៅ១៥ម៉ែត្រ។ កន្លែងខ្លះ ពួកគាត់ងើបមើលមេឃមិនឃើញទេ ឃើញតែស្លឹកឫស្សីបែកមែកសាខាគ្របជិតពីលើ ធ្វើឱ្យពួកគាត់មានអារម្មណ៍រំភើបសប្បាយរីករាយម្យ៉ាងដែរ។ រហូតដល់ម៉ោងជិត៧យប់ ទើបទៅដល់ភូមិខ្នុរ (ភូមិទី៧) ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ គេបាននាំពួកគាត់ទៅសម្រាកនៅឈើផ្ទះឈើប្រក់ក្បឿងមួយខ្នង ហើយនីរសារនោះក៏បានវិលត្រឡប់ទៅចម្ការកៅស៊ូត្រពាំងឫស្សី វិញទាំងយប់។

ស ខេង សង្កេតឃើញថា ម្ចាស់ផ្ទះនោះ ឈ្មោះ អ៊ំទ្រី ជាប្រធានគណៈកម្មាធិការបម្រើប្រជាជនឃុំរកាខ្នុរ និងប្រពន្ធគាត់រាក់ទាក់រីករាយជាមួយពួកគាត់ ហើយបានរៀបចំបាយទឹក និងម្ហូបអាហារឆ្ងាញ់ៗមានសាច់មាន់ ត្រី បន្លែ ឱ្យពួកគាត់ទទួលទានមួយថ្ងៃ៣ពេល។ក្រោយពីពួកគាត់ស្នាក់នៅផ្ទះប្រធានឃុំរកាខ្នុរនោះ បានរយៈពេលមួយសប្តាហ៍ ពេលព្រលប់មួយក៏មានយុវជន៥នាក់ ជិះកង់ម្នាក់១គ្រឿងៗ មកទទួលពួកគាត់យក

របត់នយោបាយ
ទៅមន្ទីរកាសែតពន្លឺប្លូ៉ញ។

ដើម្បីជាការតបស្នង សងគុណចំពោះទឹកចិត្តដ៏ថ្លៃថ្លារបស់ម្ចាស់ផ្ទះ ដែលបានរៀបចំបាយទឹក និងម្ហូបឆ្ងាញ់ៗមួយថ្ងៃ៣ពេល រយៈពេលមួយសប្តាហ៍នោះ មុននឹងចេញដំណើរពួកគាត់បាននាំគ្នាលុតជង្គង់ថ្វាយបង្គំ អ៊ំទ្រី និងប្រពន្ធគាត់ជាម្ចាស់ផ្ទះ ក្នុងមនោសញ្ចេតនាដឹងគុណដ៏ជ្រាលជ្រៅ។ អ៊ំទ្រី និងប្រពន្ធក៏បានជូនពរពួកគាត់ថា ទោះទៅដល់ទីណាសូមឱ្យពួកគាត់ជួបតែសេចក្តីសុខផងដែរ។

ក្រុមយុវជនទាំង៥នាក់ បានជិះកង់ដឹកពួកគាត់ទាំង៥នាក់ តាំងពីក្បាលព្រលប់ ពីឃុំកោខ្នុរ ទៅឃុំស្វាយឃ្លាំង ដោយឆ្លងកាត់ឃុំប៉ើស២ និងឃុំប៉ើស១ ដែលចម្ងាយប្រមាណតែ១៣គីឡូម៉ែត្រប៉ុណ្ណោះ ពង្វាងផ្លូវបត់ចុះបត់ឡើងរហូតដល់ម៉ោង៨យប់ទើបទៅដល់ផ្លូវចូលអង្គភាពកាសែតពន្លឺប្លូ៉ញ ដែលនៅក្នុងឃុំស្វាយឃ្លាំង។ ប៉ុន្តែ ពួកគេមិននាំពួកគាត់ចូលតាមផ្លូវខាងមុខទេ គឺពួកគេបង្វែងដានពួកគាត់ទៅហួសអង្គភាពប្រហែលកន្លះគីឡូម៉ែត្រ ទើបវិលត្រឡប់ចូលពីខាងក្រោយអង្គភាពវិញ។ ពួកគាត់ក៏ដឹងដែរថា ពួកគេធ្វើបែបនេះ គឺដើម្បីរក្សាការសម្ងាត់បដិវត្តន៍...។

លុះដល់ព្រឹកឡើងភ្លឺ ស ខេង បានឃើញយុវជនម្នាក់ឈ្មោះ សឿង ហេន ហៅហែ មានស្រុកកំណើតនៅឃុំក្រញូង ក្នុងស្រុកកំចាយមារ ជាមិត្តភក្តិធ្លាប់ស្នាក់នៅផ្ទះជួល (ផ្ទះតាខ្មែរ) នៅផ្សារដោរ៍ កាលនៅរៀនអនុវិទ្យាល័យកំចាយមារ ជាមួយគ្នា។ តែក្រោយពីអនុវិទ្យាល័យកំចាយមារត្រូវ បិទទ្វារដោយសារព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បង្កឱ្យមានភាពវឹកវរ ក៏បែកគ្នាពុំដឹងជាមិត្តភក្តិទៅទីណា?។ គាត់នឹកស្មានថា សឿង ហេន ហៅ ហែ ទៅបន្តការសិក្សានៅក្រុងភ្នំពេញជាមួយមិត្តភក្តិគាត់មួយចំនួនទៀតបាត់ទៅហើយ។ ការពិត សឿង ហេន ហៅ ហែ បានរត់ចូលព្រៃម៉ាគីចូលរួមក្នុងចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជាតាំងពីឆ្នាំ១៩៧០ដូចគាត់ដែរ ស្រាប់តែបែងដន្យ បានមកជួបគ្នានៅអង្គភាពកាសែតពន្លឺប្លូ៉ញនេះ។

សឿង ហេន ហៅ ហែ ត្រូវបាន សុក ខ្នុល ហៅ ពាម ឬលីន សមាជិកគណៈកម្មាធិការ

របត់នយោបាយ

បក្សភូមិភាគ និងជាប្រធានមន្ទីរភូមិភាគ ចាត់តាំងឱ្យធ្វើជាប្រធានអង្គភាពកាសែតពន្លឺបូព៌ា តាំងពីពេលអង្គភាពនេះបង្កើតឡើងដំបូងមកម្ល៉េះ។ ជាមួយគ្នានោះ គាត់ក៏បានជួបមិត្តភក្តិធ្លាប់រៀនសូត្រនៅអនុវិទ្យាល័យកំចាយមារ ជាមួយគ្នា៤នាក់ទៀត គឺ ឯម សំអាន, ឡឹង វិបុល, ឃុត សារ៉ាត និងហោ សេងហួរ ហៅអូន ហួរ ផងដែរ។ ពួកគាត់សប្បាយរីករាយក្រៃលែង ហើយកាន់តែស្រឡាញ់រាប់អានគ្នាលើសកាលនៅសិក្សាទៅទៀត។

ទោះបីវិស័យសារព័ត៌មាន គឺជាការងារថ្មីក៏ពិតមែន តែដោយសារការព្យាយាមអំណត់អត់ធ្មត់ និងមានការជួយបង្ហាត់បង្រៀនបន្ថែមពី សឿង ហេន ហៅហៃ ជាប្រធានអង្គភាពកាសែតពន្លឺបូព៌ា ដែលត្រូវជាមិត្តភក្តិជិតស្និទ្ធផងនោះ មិនយូរប៉ុន្មានយុវជន ស ខេង មិនត្រឹមតែមានសមត្ថភាពក្នុងការសរសេរអត្ថបទ និងចុះយកព័ត៌មាននៅតាមតំបន់ និងតាមស្រុកនានាប៉ុណ្ណោះទេ គឺថែមទាំងមានសមត្ថភាពក្នុងការចារអក្សរលើក្រដាសស្តង់ស៊ីល ដើម្បីធ្វើជាពុម្ពកាសែតទៀតផង។ ការងារមួយនេះតម្រូវឱ្យគាត់មានភាពអំណត់ព្យាយាមប្រិតប្រៀងដូចជាជាងចម្លាក់ ឬជាងគូរគំនូរដែរ។

នៅពេលនោះ អត្ថបទសំខាន់ដែលត្រូវចុះផ្សាយនៅលើទំព័រកាសែតពន្លឺបូព៌ា គឺគោលនយោបាយរបស់បក្ស និងការអប់រំសតិអារម្មណ៍តស៊ូធ្វើបដិវត្តន៍ព្រមទាំងព័ត៌មានពីសមរភូមិជួរមុខ និងព័ត៌មានស្តីពីការងារបង្កបង្កើនផលនៅសមរភូមិក្រោយជាដើម...។

ក្រោយពេលបោះពុម្ពកាសែតមួយលេខៗរួចរាល់ហើយ យុវជន ស ខេង ក៏មានភារកិច្ចដឹកជញ្ជូនកាសែតទាំងអស់នោះ ទៅចែកដល់មន្ទីរតំបន់នានាក្នុងភូមិភាគបូព៌ា ដោយទៅម្តងៗមានរយៈពេលមួយសប្តាហ៍យ៉ាងតិច ហើយគាត់ក៏មានភារកិច្ចត្រូវយកព័ត៌មាន ស្តីពីសកម្មភាពដឹកប្រឡាយលើកទំនប់បង្កបង្កើនផល និងចិញ្ចឹមសត្វនៅតាមមូលដ្ឋាន ដែលគាត់ចុះទៅនោះត្រឡប់មកឱ្យអង្គភាពវិញ ដើម្បីសរសេរតាក់តែងជាអត្ថបទសម្រាប់ចុះផ្សាយនៅលេខក្រោយបន្តទៀតផងដែរ។

ទន្ទឹមនឹងការងារស្នូល ប្រធានអង្គភាពក៏បានចាត់តាំងឱ្យពួកគាត់ទៅដាំពោត និងបន្លែបង្ការផ្សេងៗទៀតនៅលើកោះ និងធ្វើស្រែប្រាំង ដាក់មង ដាក់ឈ្នក់ រកត្រីនៅតាម

របត់នយោបាយ

ដងទន្លេមេគង្គនៅតាមបឹងខាងក្រោយភូមិ នៃឃុំស្វាយឃ្លាំង ដើម្បីផ្គត់ផ្គង់ជីវភាពអង្គភាព ព្រមទាំងនាំគ្នាកាប់ឈើ ច្រូតស្បូវ ដើម្បីសាងសង់អង្គភាពបន្ថែមទៀតផង។

ដំណាក់កាលនោះ ពួកគាត់ធ្វើការគ្មានបានទទួលប្រាក់បៀវត្សអ្វីទាំងអស់ អង្គការបដិវត្តន៍ផ្តល់តែខោ អាវ ក្រមា អំបិល អង្ករខ្លះៗ ព្រមទាំងក្រដាស និងទឹកថ្នាំខ្មៅ ដើម្បីបោះពុម្ពកាសែតតែប៉ុណ្ណោះ។

ក្រៅពីការងារស្នូល ប្រធានអង្គភាពកាសែតពន្លឺបូព៌ា បានបែងចែកកម្លាំង និងប្តូរវេនគ្នាឱ្យទៅធ្វើស្រែប្រាំង នៅខាងក្រោយទីតាំងអង្គភាពមានចម្ងាយប្រមាណ៣គីឡូម៉ែត្រ។ ក្នុងអំឡុងពេលទៅធ្វើស្រែប្រាំងនោះ រយៈពេលបី ឬបួនថ្ងៃម្តង ស ខេង ត្រូវធ្វើដំណើរមកប្រជុំជីវភាពបក្សនៅអង្គភាពរហូតដល់យប់ជ្រៅ ទើបត្រឡប់មកវិញ។

យប់មួយ វេលាម៉ោង១០ នៅពេលប្រជុំជីវភាពបក្សចប់ ស ខេង ក៏ដើរវិលត្រឡប់មកជំរំស្រែប្រាំងវិញតែម្នាក់ឯង។ ពេលនោះស្រាប់តែឮសំឡេងហ្វូងចចកស្រែកលូនៅចម្ងាយប្រហែល១០០ម៉ែត្រពីគាត់ប៉ុណ្ណោះ។ គាត់មានការភិតភ័យយ៉ាងខ្លាំង ពីព្រោះគ្មានកាំបិត ឬពូថៅដើម្បីការពារខ្លួនបន្តិចសោះ ក៏អង្គុយសម្ងំនៅស្ងៀមប្រហែល១ម៉ោង សំឡេងហ្វូងចចកលូកាន់តែរសាត់ទៅឆ្ងាយឮសូរល្វើយៗ ទើបហ៊ានក្រោកដើរទៅមុខទៀតរហូតដល់ម៉ោង១២ពាក់កណ្តាលអធ្រាត្រ បានទៅដល់ជំរំធ្វើស្រែប្រាំងវិញ ខណៈមិត្តរួមអង្គភាពដេកលក់អស់គ្មាននរណាម្នាក់ដឹងឡើយ។ ចាប់ពីពេលនោះមក គាត់លែងហ៊ានដើរយប់ម្នាក់ឯងទៀតហើយ យ៉ាងហោចណាស់ក៏មានគ្នាពីរនាក់ និងមានកាំបិតពូថៅការពារខ្លួនដែរ។

---

របត់នយោបាយ

# ៧.៣. ប្អូនប្រុសទី២ ពលីជីវិត នៅសមរភូមិព្រែកល្ពៀង



**កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា**

មុនព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០ រាល់រដូវធ្វើស្រែម្តាយរបស់ ស ខេង មិនដែលទៅដកស្ទូងទេ គឺនៅតែផ្ទះដាំស្លយកទៅឱ្យឪពុកគាត់ និងកូនៗហូបនៅឯស្រែប៉ុណ្ណោះ។ ខណៈកូនប្រុសៗទាំង៣នាក់ ចេញទៅចូលរួមជាមួយចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជាអស់ នៅសល់តែកូនស្រីៗ ក្នុងរដូវវស្សាឆ្នាំ១៩៧៣ ប្រជាជនក្នុងតំបន់រំដោះនៅធ្វើស្រែជាឯកជនតាមគ្រួសារនៅឡើយ នៅក្នុងឃុំក្រពៅ ក៏ដូចជា នៅក្នុងស្រុកកំចាយមារទាំងមូលដែរ ជួបគ្រោះរាំងស្ងួតគ្មានទឹកធ្វើស្រែ ដូច្នេះឪពុកម្តាយ ស ខេង ត្រូវ បង្ខំចិត្តទៅជួលដីគេនៅវាលគោករមាំង ឃុំព្រាល ស្រុកកញ្ជៀច ដើម្បីធ្វើស្រែ។ លុះដល់ចុងខែវិច្ឆិកា ជារដូវចម្រូត ថ្ងៃមួយឪពុកម្តាយ ស ខេង បរទេះគោទៅដឹកកណ្តាប់ស្រូវនៅវាលគោករមាំង នោះ យកមកបោកបែនឯផ្ទះ នៅភូមិអណ្តូងស្អាត ឃុំក្រពៅ ពេលនោះដោយសាររទេះដាក់ស្រូវច្រើនពេកមិនអាចជិះទាំងអស់គ្នាបាន ម្តាយគាត់ក៏ឡើងបរ

រទេះ ឯឪពុកគាត់ដើរពីក្រោយរទេះ។ ចៃដន្យ ដោយសារមិនសូវស្ទាត់ជំនាញបររទេះផង ពេលបរឡើងភ្លឺស្រែ ស្រាប់តែភ្លូករទេះបណ្តាលឱ្យម្តាយគាត់ធ្លាក់មកដីបាក់ជើងឆ្វេង។

ពេលនោះ ស ខេង កំពុងបំពេញការងារនៅអង្គភាពកាសែតពន្លឺបូព៌ា ឃុំស្វាយឃ្លាំង ក្នុងស្រុកក្រូចឆ្មារ តំបន់២២ បានទទួលដំណឹងនេះតាមរយៈមិត្តភក្តិរួមអង្គភាពដែលចុះទៅចែកកាសែត និងយកព័ត៌មាននៅតំបន់២០។ ពេលទទួលដំណឹងនេះ គាត់មានការព្រួយបារម្ភក្តុកក្តួលក្នុងចិត្ត អាណិតអ្នកមានគុណយ៉ាងខ្លាំង រហូតដល់ដាច់ចិត្តសុំច្បាប់ពីប្រធានអង្គភាពទៅមើលម្តាយ។ ពេលនោះមិត្ត សឿង ហេន ហៅហែ ប្រធានអង្គភាពមិនត្រឹមតែអនុញ្ញាតច្បាប់នោះទេ គឺថែមទាំងឱ្យគាត់យកម៉ូតូម៉ូប៊ីឡែត ១គ្រឿងរបស់អង្គភាព ដើម្បីជិះធ្វើដំណើរទៅមើលម្តាយនៅឯស្រុកកំណើតទៀតផង។



**ឧបាសក ស ប៊ិត**



**ឧបាសិកា ម៉ក់ សែម**

ពេលទៅដល់ផ្ទះភ្លាម គាត់លុតជង្គង់ថ្វាយបង្គំម្តាយទាំងក្តុកក្តួលរំជួលចិត្តអាណិតអ្នកមានគុណមិនគួរណាជួបគ្រោះថ្នាក់បែបនេះ។ តែជាសំណាងល្អពេលនោះមានគ្រូខ្មែរដំបំណានម្នាក់ឈ្មោះ អ៊ំផាន់ បានមកជួយព្យាបាលជើងម្តាយដែលបាក់នោះ។ អ៊ំផាន់ បានយកឈើ្លងមកដុតកម្លោច ហើយបុកលាយជាមួយនឹងទឹកឃ្មុំយកទៅលាបត្រង់ឆ្អឹងជើង

របត់នយោបាយ

បាក់នោះរួចរុំអបទ្រៀសប្ញស្សីពីលើ។ អ៊ំផាន់ជាអតីតប្រធានសហករណ៍លក់ដូរសម័យមុនរដ្ឋប្រហារឆ្នាំ១៩៧០ ជាឪពុករបស់ឈ្មោះ ផាន់ សុខា ជាសិស្សរួមថ្នាក់ និងជាមិត្តភក្តិជិតស្និទ្ធរបស់គាត់ដែរ។

គាត់សុំច្បាប់មកស្រុកសួរសុខទុក្ខម្តាយជាទីស្រឡាញ់ បានតែមួយយប់ប៉ុណ្ណោះស្អែកឡើង ក៏វិលត្រឡប់ទៅអង្គភាពវិញ ទាំងអាឡោះអាល័យ។ ពេលទៅដល់អង្គភាពវិញគាត់តែងតែផ្តាំផ្ញើមិត្តភក្តិ ដែលចុះទៅយកព័ត៌មាននៅតំបន់២០ ឱ្យជួយសួរដំណឹងពីអាការៈបាក់ឆ្អឹងជើងរបស់ម្តាយជានិច្ច។ អ៊ំផាន់ បានជួយព្យាបាលឆ្អឹងជើងរបស់ម្តាយគាត់អស់រយៈពេល៣ខែ ទើបបានជាសះស្បើយ អាចដើរបានដូចដើមវិញ។ ក្រោយពីបានទទួលដំណឹងថា អ្នកមានគុណអាចដើរបានដូចដើមវិញ គាត់មានចិត្តសប្បាយរីករាយយ៉ាងខ្លាំង។

ក្នុងចំណោមបងប្អូនបង្កើតចំនួន៩នាក់ ស ខេង មានតែប្អូនប្រុស២នាក់ ប៉ុណ្ណោះគឺទី១.ឈ្មោះ ស ថន ហៅ ស ថេង (កើតនៅក្នុងឆ្នាំ១៩៥៣) និងទី២.ឈ្មោះ ស បាន (កើតនៅក្នុងឆ្នាំ១៩៥៥)។ យុវជន ស បាន មានកម្ពស់ខ្ពស់ប្រហែល១,៨០ម៉ែត្រ មានរូបរាងស្រស់សង្ហា និងជាមនុស្សក្លាហានឆ្លាតវៃ មានប្រជាប្រិយក្នុងចំណោមអ្នកភូមិទាំងប្រុសស្រី ក្មេងចាស់ ព្រមទាំងឧស្សាហ៍ព្យាយាមក្នុងការរៀនសូត្រ ក៏ដូចជាការងារនៅផ្ទះដែរ។ តែ ស បាន មានចរិតមានះចចេសរឹងរូសបន្តិច ហើយមានតែ ស ខេង ម្នាក់ប៉ុណ្ណោះ ដែលប្អូនប្រុសម្នាក់នេះគោរពស្រឡាញ់ និងស្តាប់បង្គាប់ មិនហ៊ានរឹងរូសជាមួយ...។ នៅដើមឆ្នាំ១៩៧៣ ក្នុងវ័យ១៨ឆ្នាំ ស បាន សម្រេចចិត្តថ្វាយបង្គំលាម្តាយឪពុកចូលបម្រើក្នុងជួរកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា។ ពេលចូលជួរកងទ័ពដំបូងក្រោយពីពិនិត្យលើរូបសម្បត្តិ និងភាពឆ្លាតវៃមក ប្រធានកងវរសេនាធំ ឈ្មោះញ៉ែម ឈឿង ហៅសម្ងាត់ បានចាត់តាំង ស បាន ឱ្យទៅរៀនជំនាញខាងពេទ្យ ប៉ុន្តែដោយមានចរិតក្លាហានអង់អាច គាត់ក៏សុំប្រធានកងវរសេនាធំ ចេញទៅប្រយុទ្ធនៅសមរភូមិមុខ មួយរយៈសិន។



**ស្ពានចាណារាម ខាងជើងទៅរួមស្រុកពាមរក៍**

ក្នុងខែឧសភា ឆ្នាំ១៩៧៣ សមរភូមិព្រៃកណ្ដៀង នៅលើកំណាត់ផ្លូវជាតិលេខ១១ ពីទីរួមខេត្តព្រៃវែង ទៅទីប្រជុំជនអ្នកលឿង មានការប្រយុទ្ធគ្នាស៊ីសាច់ហុតឈាមទាំងយប់ទាំងថ្ងៃរវាងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរបបសាធារណរដ្ឋខ្មែរ។ បើតាមយុទ្ធជនជាមិត្តរួមអង្គភាពបានឱ្យដឹងថា ពេលប្រយុទ្ធស៊ីសាច់ហុតឈាមគ្នា នៅវេលាយប់នោះ ស បាន ក្លាហានពេក គាត់មិនលូនក្រាបទេ គឺគាត់តែងតែងើបឈរបាញ់ដោយគ្មានញញើតអ្វីបន្តិច ស្រាប់តែត្រូវគ្រាប់របស់ទាហាន លន់ នល់ ដែលបាញ់ស្រោចមកបណ្ដាលឱ្យពលីជីវិតនៅលើសមរភូមិក្នុងយប់នោះតែម្ដង។ លុះព្រឹកឡើងភ្លឺសាកសពត្រូវបានយកមកកបញ្ចុះទុកនៅក្នុងបរិវេណវត្តសំរោង ឃុំសំរោង ស្រុកស្វាយអន្ទរ។

ក្រោយពេលទទួលដំណឹងអកុសលនេះ ក្រុមគ្រួសារមានការស្លុតរន្ធត់ស្ដាយស្រណោះ អាឡោះអាល័យពន់ពេក។ ឪពុកគាត់ក៏ប្រញាប់ប្រញាល់ធ្វើដំណើរមកជួបប្រធានកងវរសេនាធំ ឈ្មោះ ញ៉ែម ឈឿង ហៅសម្ងាត់ សុំគាស់យកសាកសពកូនប្រុសមកបូជានៅក្នុងបរិវេណវត្តសំរោងនោះ ដើម្បីយកធាតុទៅធ្វើបុណ្យតាមប្រពៃណីនៅឯស្រុកកំណើត។

របត់នយោបាយ



**ទាហាន លន់ នល់**

ចំណែក ស ខេង ជាបងវិញ រំលងច្រើនថ្ងៃក្រោយមកទើបបានទទួលដំណឹងថា ប្អូនប្រុសឈ្មោះ ស បាន ពលីជីវិតក្នុងពេលប្រយុទ្ធគ្នានៅសមរភូមិព្រែកឈ្លៀង។ ដំណឹងអកុសលនេះ គាត់ដឹងតាមរយៈមិត្តភក្តិរួមការងារម្នាក់ គាត់ក៏សុំអនុញ្ញាតច្បាប់សមមិត្ត សឿង ហេន ហៅហៃ ប្រធានអង្គភាពកាសែតពន្លឺបូព៌ា ដើម្បីធ្វើដំណើរជាមួយមិត្ត ម៉េន ទី ( ទឹម ផន ) ទៅផ្ទះម្ដាយឪពុកនៅស្រុកកំណើត។ ពេលទៅដល់គាត់ បានត្រឹមតែអុជធូបបួងសួងនៅមុខកោដ្ឋដាក់ធាតុ ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ប្អូនប្រុសជាទីស្រឡាញ់ដោយក្ដីអាឡោះអាល័យតែប៉ុណ្ណោះ។

ទឹម ផន (បច្ចុប្បន្នជាសមាជិកព្រឹទ្ធសភា) បានរម្លឹកថា នៅអំឡុងពេលធ្វើការនៅអង្គភាពកាសែតពន្លឺបូព៌ានោះ ដោយសារ ស ខេង មានសមត្ថភាពយល់ដឹងខ្ពស់ និងធ្លាប់រៀននៅអនុវិទ្យាល័យកំចាយមារ ដាមួយនោះប្រធានអង្គភាពឈ្មោះ សឿង ហេន ហៅហៃ ក៏មានទំនុកចិត្ត និងបានប្រគល់ការងារឱ្យ ស ខេង ដឹកនាំមើលការខុសត្រូវការងារទាំងអស់នៅក្នុងអង្គភាព ពេលគាត់អវត្តមានម្ដងៗ។ តែយ៉ាងណាពួកគាត់ទាំង ៥នាក់ (ស ខេង, ម៉េន ទី ហៅ ទឹម ផន, ជី សាខន, ប៊ុន សុវណ្ណ ហៅខុន និងព្រុំ ឈៀង) ជាអ្នកមកពីតំបន់២០ ជាមួយគ្នា ពួកគាត់នៅតែស្រឡាញ់រាប់អាន និងដឹងសុខទុក្ខគ្នាជានិច្ច។

របត់នយោបាយ

ទឹម ផន បានបញ្ជាក់ថា ឈ្មោះដើមរបស់គាត់ គឺ ម៉េន ទី តែមកដល់ឆ្នាំ១៩៧៣ នៅអង្គភាពកាសែតពន្លឺប៉ូព៌ានោះ ស ខេង បានស្នើឱ្យដូរឈ្មោះមកជា ទឹម ផន វិញ ដើម្បីឱ្យសូរសំនៀងជួនគ្នា គឺ ខេង, ខន, ផន, ខុន ។

គាត់នៅចាំឈ្មោះមិត្តភក្តិសហការី ដែលធ្លាប់បម្រើការងារនៅអង្គភាពកាសែតពន្លឺប៉ូព៌ា ជាមួយគ្នានាពេលនោះ មានដូចជា៖ ឯម សំអាន អតីតរដ្ឋលេខាធិការក្រសួងមហាផ្ទៃ(ស្លាប់), មិត្តវ៉ាត (ស្លាប់), មិត្តវិចិត្រ (ស្លាប់), មិត្តវិបុល (ស្លាប់), មិត្តចន្ថា (ស្លាប់), មិត្តស្រេង (ស្លាប់), មិត្តរី (ស្លាប់), មិត្តយ៉ឺន (ស្លាប់), មិត្តរីន(ស្លាប់), មិត្តហួរ, មិត្តរ៉េត (ស្លាប់), មិត្តសុង(ស្លាប់), មិត្តវ៉ុន, មិត្តសំអោក (ស្លាប់), មិត្តធុន (ស្លាប់) មិត្តផល (ស្លាប់), មិត្តស៊ាង, មិត្តពិសិដ្ឋ (ស្លាប់), មិត្តហេង (ស្លាប់), មិត្តរដ្ឋ (ស្លាប់), មិត្តនារី ជួន គឹម (ភរិយាឯកឧត្តមឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ), មិត្តនារី មីន, មិត្តនារី ជួន គឿន, មិត្តនារី ឋាន, មិត្តនារី សុខ នេត, មិត្តនារី ជួន យឹម, មិត្តនារី ស៊ីណា, មិត្តនារី ស៊ីណាត, មិត្តនារី វ៉ាត (ស្លាប់), មិត្តនារី វ៉ាន់ (ស្លាប់), មិត្តនារី វ៉ឺន (ស្លាប់), មិត្តនារី ស៊ាង, មិត្តនារី សារី (ស្លាប់), មិត្តនារី រីន (ស្លាប់), មិត្តនារី ខន (ស្លាប់), មិត្តនារី គឹម អាន (ស្លាប់), មិត្តនារី ភាព (ស្លាប់) និងមិត្តមួយចំនួនទៀតដែលគាត់ភ្លេចឈ្មោះ ព្រោះទើបផ្លាស់ចូលមកថ្មី។

ទឹម ផន បានរម្លឹកបន្តថា អំឡុងខែឧសភា ឆ្នាំ១៩៧៣ នោះ បន្ទាប់ពីបានទទួលដំណឹងថា ប្អូនប្រុសបង្កើតរបស់ ស ខេង ឈ្មោះ ស បាន ពលីជីវិតក្នុងពេលប្រយុទ្ធគ្នានៅសមរភូមិព្រែកណ្ដៀង គាត់បានរួមដំណើរជាមួយ ស ខេង ដើម្បីទៅស្រុកកំណើតរបស់ ស ខេង។ ពេលនោះ ពួកគាត់បានធ្វើដំណើរឆ្លងកាត់ព្រៃចម្ការកៅស៊ូពាមជាំងទួលទ្រា ទៅដល់ភូមិពង្រ ឃុំជីហែ ស្រុកកោះសូទិន ប្រជាជនបានឱ្យថ្នាំខ្លាំងពួកគាត់ម្នាក់ប្រហែល២គីឡូក្រាម ដើម្បីយកទៅជូនឪពុកម្ដាយនៅឯស្រុកកំណើត។ ពេលចេញដំណើរពីស្រុកកោះសូទិនឆ្លងកាត់ស្រុកស៊ីធរកណ្ដាល, ស្រុកកញ្ជៀច ដល់ស្រុកព្រៃវែង (បច្ចុប្បន្ននៅក្នុងស្រុកស្វាយអន្ទរ) ក៏ចូលផ្ទះឪពុកម្ដាយរបស់គាត់ នៅភូមិ

របត់នយោបាយ

ត្រពាំងស្មៅ ឃុំពានរោង ដើម្បីសម្រាកហូបបាយថ្ងៃត្រង់សិន។ លុះដល់វេលារសៀល ថ្ងៃដដែល ទើបបន្តដំណើរឆ្លងកាត់ឃុំជ្រៃ ឃុំដូនកឹង ឃុំស្មោង ឃុំដាច ឃុំក្រញូង រហូតដល់ផ្ទះ ស ខេង នៅភូមិអណ្តូងស្អាត ឃុំក្របៅ។

ពេលនោះ គ្រួសារ ស ខេង នៅជុំគ្នាក្នុងទឹកមុខស្រងូតស្រងាត់ ដោយសារបាត់បង់យុវជន ស បាន ជាទីស្រឡាញ់។ ឪពុករបស់ ស ខេង កើតទុក្ខក្រៀមក្រំបាយមិនបានសម្រាន្តមិនលក់ សូម្បីតែនិយាយក៏ឮខ្សាវៗដែរ។ បងស្រីរបស់ ស ខេង ឈ្មោះ ស ស៊ន់ កើតជំងឺពិសនៅដៃ ធ្វើឱ្យឈឺចុកចាប់ដេកមិនលក់ គិតតែថ្ងូរយំ។ ទោះបីយ៉ាងណាក៏ក្រុមគ្រួសារ ស ខេង មានសន្តានចិត្តធ្វើនំបញ្ចុកឱ្យ គាត់ហូបយ៉ាងឆ្ងាញ់ពិសា។ រសជាតិទឹកសម្លនំបញ្ចុករបស់ម្តាយ ស ខេង ពេលនោះ គាត់មិនអាចបំភ្លេចបានឡើយ។

ក្រោយពេលជួបជុំគ្រួសារ និងអុជធូបគោរពវិញ្ញាណក្ខន្ធប្អូនប្រុស នៅស្រុកកំណើតមក ស ខេង និងទឹម ផន បានធ្វើដំណើរវិលត្រឡប់ទៅអង្គភាពកាសែតពន្លឺប៉ូព៌ា ដោយបានធ្វើដំណើរទៅដល់ទីប្រជុំជនសួង វេលាម៉ោង៣ និង៣០នាទីរសៀល រួចក៏បានបន្តដំណើរតាមផ្លូវចម្ការកៅស៊ូជប់ រហូតទៅដល់ភូមិថ្មពេជ្រ ស្រុកពាមជីលាំង (បច្ចុប្បន្នស្រុកក្រូចឆ្មារ) ម៉ូតូក៏ធ្លាយពោះវៀនកង់ក្រោយ។ ដោយគ្មានមធ្យោបាយអ្វីដើម្បីប៉ះពោះវៀនកង់ដែលធ្លាយនោះ ពួកគាត់បានយកចំបើងមកមូរប៉ុនកដៃញាត់ចូលក្នុងសម្បកកង់ម៉ូតូទាល់តែពេញ រួចឡើងជិះបន្តដំណើរបានចម្ងាយប្រហែល ១គីឡូម៉ែត្រ ខ្នងកង់ម៉ូតូ ក៏កិនរមូរចំបើងខ្ទេចអស់ ក៏ចូលទៅសុំចំបើងអ្នកស្រុកនៅតាមដងផ្លូវមកញ៉ុកបន្ថែមទៀត។ ម្តងនេះ ធ្វើដំណើរបានប្រហែល៥០០ម៉ែត្រ ស្រាប់តែពោះវៀនកង់ម៉ូតូខាងមុខធ្លាយមួយទៀត។ វិធីដោះស្រាយ មានតែញ៉ុកចំបើងដូចកង់ក្រោយដែរ រួចជិះម៉ូតូបន្តដំណើរយឺតៗកាត់ភ្លៀងកំពុងធ្លាក់ខ្លាំងលើផ្លូវរអិលកាត់ភក់ល្បាប់រហូតដល់ម៉ោងប្រហែលម៉ោង១០យប់ ក៏បានទៅដល់មន្ទីរស្រុកក្រូចឆ្មារ គឺនៅសល់តែប្រមាណ៥-៦គីឡូម៉ែត្រប៉ុណ្ណោះ ទៅដល់អង្គភាពវិញ ម៉ូតូក៏អស់សាំងរលីង...។ ម៉ូតូអស់សាំង មេឃក៏ងងឹតខ្លាំង កម្លាំងក៏កាន់តែហត់ហេវ ពេលបណ្តើរម៉ូតូ

ទៅដល់ជិតវត្តចម្ការម្លូ ឃើញផ្ទះអ្នកភូមិមួយមានពន្លឺចង្កៀងប្រេងកាតភ្លឺប្លុងៗ គាត់ក៏ដាច់ចិត្តដើរចូលទៅស្រែកហៅម្ចាស់ផ្ទះថា៖ “ ម៉ែអើយម៉ែ!ៗ ”។ ពេលនោះ អ៊ំស្រីជាម្ចាស់ផ្ទះ អាយុប្រហែលជា៦០ឆ្នាំ បានឆ្លើយមកវិញថា៖ “ នរណាហ្នឹង? ” គាត់ក៏ចូលទៅលុតជង្គង់ថ្វាយបង្គំ ហើយនិយាយថា៖ “ បាទម៉ែ! ពួកខ្ញុំធ្វើការនៅអង្គភាពកាសែតពន្លឺបូព៌ា ពួកខ្ញុំត្រឡប់មកពីខេត្តព្រៃវែង វិញ តែអកុសល ម៉ូតូបែកកង់ទាំងពីរ និងអស់សាំងទៀតហើយមិនទាន់ហូបបាយផង។ ដូចនេះ បានជាដាច់ចិត្តចូលមកជួបម៉ែក្រែងមានសល់បាយកកបាយក្តាំងខ្លះ ខ្ញុំសុំហូបផង ”។ អ៊ំម្ចាស់ផ្ទះតបវិញថា៖ “អត់អីទេកូននៅក្នុងឆ្នាំងមានសល់បាយខ្លះដែរ ហើយម៉ែកំពុងខត្រីសម្រាប់ទុកយកទៅហូបនៅស្រែប្រាំង ចាំបន្តិចទៀតម៉ែខត្រីឆ្អិនហើយ ”។ ចំណែកអ៊ំប្រុសជាប្តីកំពុងសម្រាន្តលង់លក់ ដោយសារគាត់ហត់នឿយការងារស្រែប្រាំងកាលពីថ្ងៃ។

បន្តិចក្រោមក អ៊ំស្រីម្ចាស់ផ្ទះក៏ដួសបាយ និងត្រីខឱ្យពួកគាត់ហូបបាយបណ្តើរ និងសាកសួរពីនេះពីនោះបណ្តើរ “ តើកូនមានស្រុកកំណើតនៅឯណា? ហើយមកធ្វើការនៅអង្គភាពកាសែតពន្លឺបូព៌ា ប៉ុន្មានឆ្នាំហើយ...?”

លុះហូបបាយឆ្អែតរួចរាល់ហើយ ពួកគាត់ក៏ថ្វាយបង្គំលាអ៊ំស្រីម្ចាស់ផ្ទះ បន្តដំណើរទៅមុខទៀត រហូតដល់ម៉ោង១២ពាក់កណ្តាលអធ្រាត្រ ទើបទៅដល់អង្គភាពវិញ។

បាយមួយពេលនេះ ស ខេង ចាត់ទុកជាគុណូបការៈដ៏ធំធេងមួយដែលគាត់មិនអាចបំភ្លេចបាន។ តែគាត់មានការសោកស្តាយដែរ ដោយសារមិនបានសួរឈ្មោះអ៊ំស្រីម្ចាស់ផ្ទះ ក្រែងថ្ងៃក្រោយមានសំណាងល្អ គាត់បានតបស្នងសងគុណអ៊ំស្រីម្ចាស់ផ្ទះម្នាក់នេះវិញ។

នៅក្នុងឃុំស្វាយឃ្លាំង (ស្រុកក្រូចឆ្មារ) នោះ ជាមួយនឹងអនុស្សាវរីយ៍អ៊ំស្រីម្ចាស់ផ្ទះដួសបាយ និងត្រីខឱ្យគាត់ទទួលទាននេះ ក៏មានអនុស្សាវរីយ៍ពីរទៀត ដែលធ្វើឱ្យគាត់ មិនអាចបំភ្លេចបាន គឺទី១. ពេលគាត់ និងមិត្តរួមអង្គភាពត្រូវអង្គការចាត់ឱ្យទៅជួយសែងគ្រាប់កាំភ្លើង ដែលដឹកតាមកាណូតមកពីខេត្តក្រចេះ ឡើងមកលើគោក

របត់នយោបាយ

កាលពីឆ្នាំ១៩៧៣ និងទី២. ពេលគាត់បានមកចូលរៀនសូត្រវគ្គនយោបាយ នៅក្នុងវត្តចម្ការម្លូ កាលពីដើមឆ្នាំ១៩៧៤។

ក្រោយថ្ងៃរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គាត់ក៏បានទៅសួររកអ៊ំស្រីម្ចាស់ផ្ទះជាអ្នកមានគុណនៅក្បែរវត្តចម្ការម្លូ ក្នុងឃុំស្វាយឃ្លាំង នោះដែរ។ តែរកមិនឃើញដោយសារមិនស្គាល់ឈ្មោះអ៊ំស្រីម្ចាស់ផ្ទះនោះ។

ស ខេង ពិនិត្យឃើញថា ប្រជាជននៅស្រុកក្រូចឆ្មារ ពិសេសប្រជាជនដែលរស់នៅក្បែរៗអង្គភាពកាសែតពន្លឺបូព៌ា មានសន្តានចិត្តល្អប្រពៃណាស់។ ពេលពួកគាត់ទៅលេងផ្ទះម្តងៗ ពួកគេតែងតែស្វាគមន៍ ដាក់នំចំណី ផ្លែឈើ ទទួលពួកគាត់ដោយរីករាយរាក់ទាក់បំផុត ហើយតែងផ្តាំប្រាប់ថា បើពួកគាត់ត្រូវការបន្លែ ផ្លែឈើអ្វីកុំខ្លាចចិត្តខ្លាចថ្លើមអី មកបេះយកទៅហូបចុះ។ ក្នុងនោះ មានអ្នកភូមិម្នាក់ឈ្មោះ កិៈ ជ ប្រពន្ធឈ្មោះ ហេង ញិ (ស្លាប់ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩)។ គ្រួសារមួយនេះស្រឡាញ់រាប់អានគាត់ដូចប្អូនបង្កើត។ បងប្រុស កិៈ ជ បងស្រីហេង ញិ មានកូនប្រុសម្នាក់ឈ្មោះ ជ ចាន់ស៊ាង។ ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បងស្រី ហេង ញិ បានទទួលមរណភាព។ ស ខេង ក៏បានយកកូនប្រុសពួកគាត់ឈ្មោះ ជ ចាន់ស៊ាង មកជួយទំនប់បម្រុងឱ្យរៀនសូត្ររហូតដល់ចប់ថ្នាក់បរិញ្ញាបត្រ និងបានចូលក្របខណ្ឌជាមន្ត្រីរាជការ។ បច្ចុប្បន្ន ជ ចាន់ស៊ាង ជាអភិបាលរងខណ្ឌដង្កោ។

កសិករវ័យចំណាស់ ឈ្មោះ កិៈ ជ រស់នៅភូមិទី១ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នៅក្នុងឆ្នាំ២០២២ គាត់មានអាយុ៨៣ឆ្នាំហើយនោះ បានឱ្យដឹងថា រូបគាត់និងប្រពន្ធបានស្គាល់យុវជន ស ខេង នៅពេលមកធ្វើការនៅអង្គភាពកាសែតពន្លឺបូព៌ាដែលមានទីតាំងនៅមិនឆ្ងាយប៉ុន្មានពីផ្ទះរបស់គាត់។ ពេលនោះ គាត់សង្កេតឃើញ ស ខេង ជាមនុស្សចូលចិត្តស្ងប់ស្ងាត់ហ្មត់ចត់ច្បាស់លាស់តែសាមញ្ញមិនប្រកាន់តួនាទីមិនប្រកាន់ថា ជាកម្មាភិបាល ឬប្រជាជននោះទេ ស ខេង ស្រឡាញ់រាប់អានទាំងអស់ជាមួយគ្នានោះ ស ខេង បានចុះជួយបង្ហាត់បង្រៀនបងប្អូនជាអនក្ខរជននៅតាមផ្ទះ ឱ្យ

របត់នយោបាយ

ចេះអាន និងសរសេរអក្សរខ្លះៗ។ ពេលវល់មិនបានមកបង្រៀន ស ខេង ក៏ចាត់ឱ្យក្រុមការងារចុះមកជួយបង្រៀនជំនួសដែរ។

គិ:ជ បន្តថា គាត់ និងប្រពន្ធស្រឡាញ់រាប់អាន ស ខេង ដូចប្អូនបង្កើត។ កាលនោះជាញឹកញាប់ប្រពន្ធគាត់តែងតែយកបាយសម្លទៅឱ្យ ស ខេង ពិសានៅកន្លែងស្នាក់នៅ។ ប៉ុន្តែពេលយកបាយម្ហូបទៅឱ្យនោះ គឺត្រូវដើរពង្វាងផ្លូវជានិច្ច ព្រោះខ្លាចមានគេតាមដាន។ គាត់នៅចាំបានថា មានយប់មួយពេល ស ខេង និងមិត្តភក្តិ៣-៤នាក់ចេញល្បាតនៅក្រៅអង្គភាពតាំងពីព្រលប់ លុះដល់ពាក់កណ្ដាលអធ្រាត្រក៏ឈោងចូលមកលេងផ្ទះគាត់ហើយប្រាប់ថា រមូលពោះណាស់! ភ្លាមនោះ គាត់ក៏ឱ្យប្រពន្ធដាំបាយឱ្យហូប។ ចុងក្រោយ ពេលប្រពន្ធគាត់កំពុងត្បាញក្រមា ស្រាប់តែ ស ខេង និងអ្នករួមការងារ៤នាក់ទៀត បានមកជម្រាបលាគាត់ និងប្រពន្ធថា អង្គភាពកាសែតពន្លឺប៉ុស្ដិ៍ត្រូវរុះរើទៅបោះទីតាំងថ្មីហើយ។ ពេលនោះ ប្រពន្ធគាត់បានកាត់ក្រមាជូនម្នាក់មួយៗដើម្បីទុកជាអនុស្សាវរីយ៍ និងបញ្ជាក់ពីក្ដីស្រឡាញ់រាប់អានគ្នាដូចបងប្អូនបង្កើត។

---

# ៧.៤. បើកវគ្គនៅភូមិភាគបូព៌ា នួន ជា និង អៀង សារី ចូលរួម...



អៀង សារី



នួន ជា

ដើមឆ្នាំ១៩៧៤ គណៈកម្មាធិការបក្សភូមិភាគបូព៌ា បានបើកវគ្គបណ្ដុះបណ្ដាលនយោបាយដល់កម្មាភិបាលស្រុក, តំបន់ និងមន្ទីរជុំវិញភូមិភាគ រយៈពេលមួយខែនៅក្នុងបរិវេណវត្តចម្ការម្លូ (វត្តឥន្ទកោសិយ) ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ តំបន់២២។ ពេលនោះ មិត្ត សឿង ហេន ហៅហៃ, មិត្ត ស ខេង, មិត្ត ឯម សំអាន, មិត្ត វ៉ាត និងមិត្ត សៀម នៅអង្គភាពកាសែតពន្លឺបូព៌ា ត្រូវអង្គការចាត់តាំងឱ្យចូលទៅរៀនក្នុងវគ្គនយោបាយនោះដែរ។ ក្នុងវគ្គបណ្ដុះបណ្ដាលកម្មាភិបាលនោះ មានសិក្ខាកាមចូលរួមប្រមាណ ១០០នាក់ ក្នុងនោះក៏មានមិត្ត សាយ ឈុំ មកពីស្រុកកោះសូទិនម្នាក់ដែរ។ គ្រូឧទ្ទេសនាមឯកសារនយោបាយក្នុងវគ្គសិក្សានោះរួមមាន៖ សុក ខ្នុល ហៅសមមិត្តពាម ឬលីន សមាជិកគណៈកម្មាធិការបក្សភូមិភាគ និងជាប្រធានមន្ទីរភូមិភាគ, សមមិត្ត គឹម

របត់នយោបាយ

ប្រធានយុវជនបដិវត្តន៍ភូមិភាគបូព៌ា និងកម្មាភិបាលភូមិភាគមួយចំនួនទៀត។ ចំណែក សុក សាផុន ហៅសមមិត្ត ភួង អនុលេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា មកបង្រៀនអំពីការគ្រប់គ្រងសេដ្ឋកិច្ច។ មេរៀនសំខាន់ គឺផ្ដោតទៅខ្លឹមសារនៃការតស៊ូវណ្ណៈរបស់កម្មករ និងកសិករ ដើម្បីប្រឆាំងរបបសក្តិភូមិ ពួកកាន់អំណាចប្រតិកិរិយា ពួកចក្រពត្តិអាមេរិក និងបរិវារ។ សមមិត្ត គឹម ប្រធានយុវជនបដិវត្តន៍ភូមិភាគបូព៌ា គ្រូឧទ្ទេសនាមបានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងដំណាក់កាលធ្វើសង្គ្រាមបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ អង្គការយើងយកសម្ដេចសីហនុ ឱ្យធ្វើប្រធានរណសិរ្សរួបរួមជាតិ គឺគ្រាន់តែប្រើឥទ្ធិពល និងប្រជាប្រិយភាពរបស់ព្រះអង្គដើម្បីប្រមូលកម្លាំងមហាជនប្រជាជនឱ្យចូលរួមធ្វើបដិវត្តន៍ និងប្រឆាំង នឹងរបប លន់ នល់ ដែលមានអាមេរិក ជាមេខ្លោងប៉ុណ្ណោះ។

ស ខេង បានរម្លឹកថា៖ ពេលរៀនសូត្រវគ្គនយោបាយនោះ គេបានផ្ដល់ឯកសារផ្សេងទៀតមួយចំនួនដូចជា ឯកសារស្ដីពីតួនាទី និងភារកិច្ចរបស់កម្មករ, កសិករ យុវជនយុវនារី និងបញ្ញវន្ត ក្នុងការតស៊ូធ្វើបដិវត្តន៍ជាដើម។ ចំពោះកម្មវិធីសិក្សាវិញ គឺពេលព្រឹកស្ដាប់បទឧទ្ទេសនាមរបស់គ្រូៗជាកម្មាភិបាលជាន់ខ្ពស់។ ពេលរសៀល ឬជួនកាលពេលយប់ ត្រូវប្រជុំពិភាក្សាតាមក្រុម ដើម្បីស្វែងយល់បន្ថែម និងធ្វើការទិតៀន និងស្វ័យទិតៀន។ ទិតៀន គឺដាក់ខ្លួនឱ្យសមូហភាព (អង្គប្រជុំ) មានមតិលើកឡើងពីគុណសម្បត្តិ គុណវិបត្តិរបស់ខ្លួន និងមានមតិជួយកែលម្អ។ ចំណែកស្វ័យទិតៀន គឺបុគ្គលខ្លួនឯងត្រូវមានមតិលើកឡើងពីគុណសម្បត្តិ និងគុណវិបត្តិរបស់ខ្លួនផ្ទាល់ តើកន្លងមកបានគោរព និងអនុវត្តគោលនយោបាយរបស់បក្ស គោរពការចាត់តាំង គោរពអង្គការវិន័យសីលធម៌រស់នៅ និងបំពេញភារកិច្ចបដិវត្តន៍ជូនអង្គការបានកម្រិតណា? មានអ្វីខ្លះជាគុណសម្បត្តិ និងមានអ្វីខ្លះជាគុណវិបត្តិ? ហើយមានការប្ដេជ្ញាកែប្រែយ៉ាងដូចម្ដេច?។

ក្នុងពេលបើកវគ្គរៀនសូត្រនយោបាយនោះដែរ ថ្ងៃមួយមានអង្គការថ្នាក់លើម្នាក់មកពីទីក្រុងភ្នំពេញ ដែលពួកគាត់ជាសិក្ខាកាមទាំងអស់មិនស្គាល់ថា ជានរណា បានមក

របត់នយោបាយ

ឧទ្ទេសនាមឱ្យពួកគាត់បានយល់ពីគោលនយោបាយរបស់អង្គការបដិវត្តន៍ និងសភាពការណ៍នៅក្នុងប្រទេសអស់រយៈពេលជិត៣ម៉ោង។ ពេលឧទ្ទេសនាមចប់ អង្គការថ្នាក់លើនោះក៏ចេញទៅតាមខាងក្រោយវាំងននវេទិកាកិត្តិយសបាត់ទៅ...។

ក្រោយមក ទើបនៅក្នុងចំណោមសិក្ខាកាមបាននិយាយតៗគ្នាថា អង្គការថ្នាក់លើម្នាក់នោះគឺ នួន ជា អនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស។ បន្ទាប់មកទៀតល្ងាចមួយ ពេលពួកគាត់ជាសិក្ខាកាមមួយក្រុមមានគ្នាប្រមាណ២០នាក់ កំពុងអង្គុយជុំកង់នៅទីធ្លាមួយដើម្បីប្រជុំពិភាក្សាពាក់ព័ន្ធជាមួយឯកសារ ដែលបានរៀនសូត្រហើយនោះ ស្រាប់តែឃើញ អៀង សារី ដើរមកអង្គុយសំណេះសំណាលសួរសុខទុក្ខពួកគាត់ថា មិត្តទាំងអស់មកពីស្រុកណា តំបន់ណាខ្លះ?...ជាដើម ព្រមទាំងបើកទូលាយឱ្យពួកគាត់សួរសំណួរដែលពាក់ព័ន្ធដល់សភាពការណ៍អន្តរជាតិផងដែរ។

ពេលនោះ មិត្ត វ៉ាត ទៅពីអង្គភាពកាសែតពន្លឺបូព៌ាដែរនោះ សួរ អៀង សារី ថា តើមហាបដិវត្តន៍នៅប្រទេសចិន មានការវិវត្តដូចម្តេចដែរ? តែ អៀង សារី មិនឆ្លើយសំណួរនេះទេ ដោយគ្រាន់តែលើកហេតុផលថា៖ រឿងនេះខ្ញុំក៏ក្តាប់មិនសូវបានដែរ ដោយសារខ្ញុំជាបេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិកម្ពុជា មិនសូវបានយកចិត្តទុកដាក់រឿងនេះទេ។ ម្យ៉ាងនេះជាកិច្ចការផ្ទៃក្នុងរបស់មហាមិត្តចិន។ ពួកគាត់យល់ថា តាមពិត មិនមែន អៀង សារី ក្តាប់មិនបានពីការវិវត្តរបស់បដិវត្តន៍នៅប្រទេសចិននោះទេ ប៉ុន្តែ អៀង សារី មិនអាចនិយាយបាន ព្រោះបើនិយាយទៅវាអាចប៉ះពាល់ដល់មេដឹកនាំចិន។ ម្យ៉ាងទៀត ក៏អាចប៉ះពាល់ដល់សតិអារម្មណ៍កម្មាភិបាលតស៊ូនៅក្នុងប្រទេសផងដែរ។

លុះព្រឹកឡើង អៀង សារី ក៏បានចូលមកឧទ្ទេសនាមពីសភាពការណ៍បដិវត្តន៍កម្ពុជា នៅលើឆាកអន្តរជាតិ រយៈពេលប្រហែល២ម៉ោង ដើម្បីឱ្យពួកគាត់ជាសិក្ខាកាមបានជ្រួតជ្រាបផងដែរ។

ចុងក្រោយ គណៈគ្រប់គ្រងវគ្គឱ្យសិក្ខាកាមម្នាក់ៗសរសេរបញ្ជាក់អំពីការយល់

ដឹងរបស់ខ្លួន ក្រោយពីបានសិក្សារៀនសូត្ររយៈពេល១ខែ និងឱ្យធ្វើជីវទស្សន៍ឆ្លុះបញ្ចាំងអំពីសកម្មភាពរបស់ខ្លួនក្នុងចលនាតស៊ូធ្វើបដិវត្តន៍រយៈពេលកន្លងទៅ ដោយតម្រូវឱ្យ សរសេរពីគុណសម្បត្តិ និងគុណវិបត្តិ ព្រមទាំងការប្តេជ្ញាចិត្តផងដែរ។

ស ខេង បញ្ជាក់ថា នៅក្នុងចំណោមសិក្ខាកាមទាំង១០០នាក់នោះ ការយល់ដឹងមិនដូចគ្នាទេ ព្រោះពួកគេចេញមកពីប្រភពផ្សេងៗគ្នាហើយកម្រិតវប្បធម៌ ក៏ខុសគ្នាដែរ ដូច្នេះសិក្ខាកាមអតីតជាសាស្ត្រាចារ្យ ជាគ្រូបង្រៀន ជានិស្សិត ជាសិស្សអាចមានសមត្ថភាពសរសេរជីវទស្សន៍បានល្អក្បោះក្បាយ។ តែសិក្ខាកាមខ្លះមានប្រភពចេញពីវណ្ណៈកសិករក្រ ចេះត្រឹមតែសរសេរ ឬអានអក្សរខ្មែរបន្តិចបន្តួច មិនអាចសរសេរជីវទស្សន៍បានល្អដូចគេ បែរជាគិតតែសញ្ជប់សញ្ជឹងព្រួយបារម្ភខ្លាំងពេក បណ្តាលឱ្យឡប់សតិដើរងើបមើលតែស្លឹកឈើដែលនៅខាងលើ ហើយសើចញញឹមតែម្នាក់ឯងក៏មាន។ ជាក់ស្តែង សិក្ខាកាមម្នាក់ឈ្មោះមិត្ត សឿម មានប្រភពចេញពីវណ្ណៈកសិករក្រ មិនចេះអក្សរ មានស្រុកកំណើតនៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ជាតំបន់ចុងកាត់មាត់ញកប្រែក្លាយជាមនុស្សឡប់សតិនៅចុងបញ្ចប់វគ្គនយោបាយនោះ។

សាយ ឈុំ (អតីតប្រធានព្រឹទ្ធសភា បច្ចុប្បន្នជាឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ) បានបញ្ជាក់ថា៖ គាត់មាននៅសល់ឯកសារមួយបញ្ជាក់ថា គាត់ចូលជាបក្ខជនត្រៀមនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៣។ សម័យនោះ ដើម្បីក្លាយជាបក្ខជនពេញសិទ្ធិរបស់បក្សកុម្មុយនិស្តកម្ពុជា គឺត្រូវតែនៅជាបក្ខជនត្រៀមរយៈពេល៦ខែ ចំពោះអ្នកដែលប្រភពចេញពីវណ្ណៈអនុធនដូចរូបគាត់។ ដូច្នេះបើគិតពីថ្ងៃចូលជាបក្ខជនត្រៀមពីខែមេសា រហូតដល់ចុងខែតុលា ឆ្នាំ១៩៧៣ ទើបគាត់បានចូលជាបក្ខជនពេញសិទ្ធិ។ ពេលនោះ មានតែបក្ខជនពេញសិទ្ធិ ឬជាសមាជិកគណៈកម្មាធិការបក្សស្រុកប៉ុណ្ណោះ ទើបត្រូវបានគេចាត់តាំងឱ្យមករៀនវគ្គអប់រំនយោបាយនេះ។

គាត់នៅចាំបានថា វគ្គរៀនសូត្រនយោបាយនេះ ធ្វើឡើងក្រោយពេលដែលសម្តេចមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា ជាព្រះមាតា ត្រូវបានគេ

របត់នយោបាយ
អនុញ្ញាតឱ្យយាងចាកចេញពីទីក្រុងភ្នំពេញ ទៅព្យាបាលរោគ និងជួបសម្តេចព្រះនរោត្តម សីហនុ នៅក្រុងប៉េកាំង នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៣។ ពេលនោះ គាត់បានស្គាល់ ស ខេង តាមរយៈយុវជនទៅពីអង្គភាពជាមួយគាត់ម្នាក់ឈ្មោះ តន់ ជាអ្នកណែនាំ។ ក្នុងវគ្គរៀនសូត្រវគ្គនយោបាយនោះ មានតែមិត្ត តន់ និងមិត្ត វ៉ាត ដែលមានវ័យក្មេងជាងគេ។ មិត្ត វ៉ាត មកពីអង្គភាពកាសែតពន្លឺបូព៌ាជាមួយ ស ខេង រួមជាមួយមិត្តបីនាក់ផ្សេងទៀត គឺមិត្ត សឿង ហេន ហៅហែ, មិត្តសឿម និងមិត្ត ទឹម ផន។

សាយ ឈុំ បានបន្តថា៖ ពិធីបើកវគ្គអប់រំនយោបាយនោះ សុក ខ្នុល ហៅសម មិត្តពាម ហៅលីន អតីតនិស្សិតមានសញ្ញាបត្រខាងកាត់ដេរ មកពីប្រទេសបារាំង ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគ និងជាប្រធានមន្ទីរភូមិភាគ ជាអធិបតី និងជាគ្រូឧទ្ទេសនាមឯកសារនយោបាយផងដែរ។ សមមិត្ត ភួង អនុលេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា មកបង្រៀនអំពីការគ្រប់គ្រងសេដ្ឋកិច្ច។ ចំណែក នួន ជា អនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស ពេលធ្វើដំណើរឆ្លងកាត់ស្រុកក្រូចឆ្មារតំបន់២២ គាត់ក៏ឆ្លៀតចូលមកវត្តចម្ការម្លូ កន្លែងបើកវគ្គរៀនសូត្រវគ្គនយោបាយនោះ ឧទ្ទេសនាមអំពីគោលនយោបាយរបស់បក្ស ព្រមទាំងការបង្កើតសហករណ៍ និងការបង្កើនផលិតផលកសិកម្ម។ ជាមួយគ្នានោះ អៀង សារី ជាបេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិកម្ពុជា ក៏បានចូលទៅឧទ្ទេសនាម ស្តីពីលទ្ធផលការងារការបរទេស របស់រណសិរ្សរួបជាតិកម្ពុជា ពីស្ថានភាពរបស់អន្តរជាតិដែលមានការពាក់ព័ន្ធជាមួយប្រទេសកម្ពុជា និងបានបើកឱកាសឱ្យសិក្ខាកាមចោទសួរជាសំណួរផ្សេងៗទៀតផង ។ ពេលនោះ មិត្ត វ៉ាត វ័យក្មេងជាងគេមកពីអង្គភាពកាសែតពន្លឺបូព៌ា បានឡើងសួរ២សំណួរ គឺទី១ មិត្ត វ៉ាត សួរថា មូលហេតុអ្វីបានជារបប លន់ នល់ អនុញ្ញាតឱ្យសម្តេចមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (ព្រះមាតាសម្តេចព្រះនរោត្តម សីហនុ) យាងទីក្រុងប៉េកាំង?។ ទី២ តើមហាបដិវត្តន៍នៅប្រទេសចិន មានការវិវត្តដូចម្តេចហើយ?។ សំណួរទី១ អៀង សារី ឆ្លើយថា រឿងរបប លន់ នល់ អនុញ្ញាតឱ្យសម្តេចមហាក្សត្រិយានី ស៊ីសុវត្ថិ

របត់នយោបាយ
កុសុមៈ យ៉ាងទីក្រុងប៉េកាំងនេះ គាត់ក៏មិនដឹងថា មកពីមូលហេតុអ្វីដែរ?។ ចំពោះសំណួរទី២ អៀង សារី ឆ្លើយថា មហាបដិវត្តន៍នៅប្រទេសចិន គឺជាកិច្ចការផ្ទៃក្នុងរបស់មហាមិត្តចិន។ បក្សរបស់យើងមិនជ្រៀតជ្រែករឿងកិច្ចការផ្ទៃក្នុងរបស់មហាមិត្តយើងនោះទេ។

សាយ ឈុំ (អតីតប្រធានព្រឹទ្ធសភា) បានបញ្ជាក់ថា៖ អំឡុងពេលរៀនវគ្គនយោបាយនោះ សិក្ខាកាមទាំងអស់គោរពអង្គការវិន័យតឹងរ៉ឹងណាស់ ពេលរៀនចប់ត្រូវនាំគ្នាមកកន្លែងស្នាក់នៅរៀងៗខ្លួនដោយស្ងាត់ស្ងៀម សូម្បីតែពេលហូបបាយ ក៏មិនសូវហ៊ានជជែកគ្នាផ្តេសផ្តាសដែរ ពោលគឺម្នាក់ៗប្រឹងគោរពអង្គការវិន័យឱ្យបានខ្ជាប់ខ្ជួនបំផុត។ ក្រោយបញ្ចប់វគ្គរៀនសូត្រ គឺសិក្ខាកាមទាំងអស់ត្រូវប្រជុំតាមក្រុម ដើម្បីធ្វើការបូកសរុបលទ្ធផលនៃការរៀនសូត្រ  ទិតៀន និងស្វ័យទិតៀន ព្រមទាំងធ្វើជីវទស្សន៍ផងដែរ។

ចាប់ពីឆ្នាំ១៩៧៣មក ដោយសារមានសមត្ថភាព និងមានប្រៀបក្នុងការធ្វើសង្គ្រាមជាមួយរបបសាធារណរដ្ឋខ្មែរ ដោយឯករាជ្យម្ចាស់ការ អង្គការបដិវត្តន៍ខ្មែរក្រហម បានបណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើង និងជនជាតិវៀតណាម មិនឱ្យមានវត្តមាននៅលើទឹកដីកម្ពុជា ដូចមុនទៀតឡើយ ហើយក៏បានចាប់ផ្តើមអនុវត្តនយោបាយផ្តាច់ការ មកលើប្រជាជនដែលរស់នៅក្នុងតំបន់រំដោះ ដែលពួកគេកាន់កាប់ មិនឱ្យមានការចាយវាយប្រាក់កាស មិនឱ្យមានការរកស៊ីជួញដូរ មិនឱ្យមានទីផ្សារ បំបិទសេរីភាពគ្រប់បែបយ៉ាង និងរើសអើងពូជសាសន៍ផងដែរ។

ពាក់កណ្តាលឆ្នាំ១៩៧៤ ឪពុកម្តាយរបស់មិត្ត សឿង ហេន ហៅហៃ ប្រធានអង្គភាពកាសែតពន្លឺបូព៌ា ព្រមទាំងកូនៗទាំងអស់ បានសម្រេចចិត្តចាកចេញពីទឹកដីកម្ពុជា ទៅរស់នៅប្រទេសវៀតណាមខាងត្បូង។ ឪពុករបស់មិត្ត សឿង ហេន ហៅហៃ ឈ្មោះ សឿង ជាជនជាតិចិន ឯម្តាយគាត់ជាជនជាតិវៀតណាម។ ក្រោយពីបានទទួលដំណឹងមកថា ឪពុកម្តាយគាត់មានបំណង ចាកចេញពីទឹកដីកម្ពុជា ទៅរស់នៅ

របត់នយោបាយ

ប្រទេសវៀតណាមខាងត្បូង មិត្ត សឿង ហេន ហៅហៃ ក៏ហៅ ស ខេង ឱ្យឡើងជិះម៉ូតូម៉ូប៊ីឡែតជាមួយធ្វើដំណើរទៅភូមិកំណើត នៅភូមិកំចាយមារ ឃុំក្រញូង ស្រុកកំចាយមារ ដើម្បីឃាត់ឪពុកម្ដាយ បងប្អូន មិនឱ្យធ្វើដំណើរទៅប្រទេសវៀតណាម។ ពេលទៅដល់ភូមិកំណើត ស្រាប់តែឃើញផ្ទះបិទទ្វារជិតឈឹង ឪពុកម្ដាយបងប្អូនគេបានចេញដំណើរទៅបាត់អស់ តែមានអ្នកភូមិប្រាប់ថា ឪពុកម្ដាយ បងប្អូនគាត់បានធ្វើដំណើរទៅដល់ស្រុករមាសហែក ខេត្តស្វាយរៀង បាត់ហើយ។ ពេលនោះ មិត្ត សឿង ហេន ហៅហៃ និង ស ខេង ក៏ប្រញាប់ប្រញាល់ជិះម៉ូតូបន្តដំណើរក្នុងបំណងទៅតាមដល់ស្រុករមាសហែកទៀត។ លុះមកដល់ភូមិដោរ៍ ( ទីរួមស្រុកកំចាយមារ ) យប់កាន់តែជ្រៅ មានអ្នកភូមិវ័យចំណាស់ធ្លាប់ស្គាល់គ្នាជាកូនចៅចិន និងវៀតណាមដែលមិនព្រមចាកចោលផ្ទះសម្បែង ចេញទៅប្រទេសវៀតណាម ក៏បានឃាត់ឱ្យសម្រាកជាមួយពួកគេនៅភូមិដោរ៍ នោះមួយយប់ ដោយពួកគេបានបបរពងមាន់ដាក់ស្ករត្នោត និងជីរនាងវងឱ្យពួកគាត់ទទួលទានយ៉ាងឆ្ងាញ់ពិសា។

ស ខេង បានរម្លឹកថា ព្រឹកឡើងទើបមិត្ត សឿង ហេន ហៅហៃ និងគាត់បន្តដំណើរទៅមុខទៀត ក៏បានជួបក្រុមគ្រួសារតាសឿង នៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀង។ ពេលនោះ មិត្ត សឿង ហេន ហៅហៃ ក៏បានជួបពិភាក្សាជាមួយឪពុកគេ និងក្រុមគ្រួសារអស់រយៈពេលប្រហែល៣ម៉ោង។ តែគាត់មិនបាននៅក្បែរពួកគេទេ ដោយសារនេះជាបញ្ហាផ្ទាល់ខ្លួនរបស់គ្រួសាររបស់មិត្តសឿង ហេន ហៅហៃ។ ទីបំផុតតាសឿង និងក្រុមគ្រួសារនៅតែសម្រេចចិត្តបន្តដំណើរចូលទៅប្រទេសវៀតណាមទាល់តែបាន ហើយពួកគាត់ទាំង២នាក់ ក៏បានធ្វើដំណើរវិលត្រឡប់មកអង្គភាពកាសែតពន្លឺបូព៌ា នៅស្រុកក្រូចឆ្មារ វិញទាំងស្ដាយស្រណោះ។

ពេលនោះ មិត្តសឿង ហេន ហៅហៃ និងគាត់នៅតែមិនអស់ចិត្ត និងងឿងឆ្ងល់ថា ហេតុអ្វី បានជាតាសឿង នៅតែមានះនាំក្រុមគ្រួសារទៅរស់នៅប្រទេសវៀតណាម ? ។

របត់នយោបាយ

ក្រោយមក ពួកគាត់កោតសរសើរចំពោះតាសឿង ដែលយល់ដឹង និងវិភាគហេតុផលសភាពការណ៍បានត្រឹមត្រូវល្អណាស់ ទើបបានជាគាត់សម្រេចចិត្តនាំប្រពន្ធកូនទៅរស់នៅប្រទេសវៀតណាម បើមិនដូច្នេះទេ ពួកគាត់ច្បាស់ជាត្រូវពួកខ្មែរក្រហមសម្លាប់ផុតពូជជាមិនខាន។








**ជនជាតិវៀតណាម ត្រូវទាហានលន់ នល់
បង្ខំឱ្យចេញពីទឹកដីកម្ពុជា**

---

# ៧.៥. ជួន មុម្ម ចូលរួមក្នុងចលនាតស៊ូ នៅប៉ារាំង



**ពីឆ្វេងទៅស្តាំ ជួន មុម្ម , ស៊ីសុវត្ថិ មេថាវី, ចៅ សេង អ្នកម្នាងម៉ូនិក និងសម្តេចសីហនុ នៅកណ្តាលភ្ញៀវបរទេសពីរនាក់**

ក្រោយពីសម្តេចសីហនុ ឡើងសោយរាជសម្បត្តិក្នុងឆ្នាំ១៩៤១ មិនបាន១ឆ្នាំផង ព្រះអង្គបានប្រព្រឹត្តរឿងស្នេហាផ្តេសផ្តាសជាមួយនាងកាវីរបាំព្រះរាជទ្រព្យម្នាក់ ឈ្មោះ ផាត់ កាញ៉ុល។ នៅក្នុងឆ្នាំ១៩៤២ ជាមួយគ្នានោះដែរ ព្រះអង្គបានប្រព្រឹត្តអំពើរឿងស្នេហាផ្តេសផ្តាសជាមួយព្រះនាង ស៊ីសុវត្ថិ ពង្សសានមុនី ដែលមានវ័យទើបតែ១៣ឆ្នាំកន្លះមួយថែមទៀត។ ព្រះនាង ស៊ីសុវត្ថិ ពង្សសានមុនី ជាបុត្រីរបស់ព្រះបរមសព ព្រះមហាក្សត្រ មុនីវង្ស ដែលត្រូវជាព្រះអយ្យកោរបស់ព្រះអង្គ ពោលគឺព្រះនាងអង្គនេះត្រូវជាម្តាយមីងរបស់ព្រះអង្គតែម្តង។ ទំនាក់ទំនងស្នេហារបស់ព្រះមហាក្សត្រ សីហនុ ជាមួយនាងកាវីរបាំព្រះរាជទ្រព្យឈ្មោះ ផាត់ កាញ៉ុល និងព្រះនាង ស៊ីសុវត្ថិ ពង្សសានមុនី ត្រូវបានពួកមន្ត្រីបារាំង និងពួកគហបតីខ្មែរជាច្រើនប្រឆាំងជំទាស់។ ដូច្នេះ ពួកមន្ត្រីបារាំងខ្លះបាន

របត់នយោបាយ

ទម្លាយរឿងស្នេហាអាស្រូវនេះទៅប្រាប់ឧត្តមនាវី ហ្សង់ ដឺគូ (Jean Decoux) អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន នៅទីក្រុងព្រៃនគរ ឱ្យបានដឹងផងដែរ។ ក្រោយពីបានដឹងរឿងរ៉ាវស្នេហាអាស្រូវនេះ ឧត្តមនាវី ហ្សង់ ដឺគូ មានការខឹងសម្បាយ៉ាងខ្លាំង។ នៅដើមខែមីនា ឆ្នាំ១៩៤៣ ឧត្តមនាវី ហ្សង់ ដឺគូ (Jean Decoux) បានសម្រេចផ្លាស់ប្តូរមន្ត្រីបារាំង ឈ្មោះ ហ្សង់ ដឺឡង់ (Jean Delens) ដែលមកបំពេញតួនាទីជាទេសាភិបាលជាន់ខ្ពស់នៅកម្ពុជា កាលពីចុងឆ្នាំ១៩៤១នោះចេញ ដោយសារទេសាភិបាលជាន់ខ្ពស់រូបនេះមិនមានសមត្ថភាពក្នុងការណែនាំអប់រំព្រះមហាក្សត្រ សីហនុ បណ្តាលឱ្យព្រះអង្គប្រព្រឹត្តអំពើរឿងស្នេហាផ្តេសផ្តាសបែបនេះ។

នៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៤៣ ឧត្តមនាវី ហ្សង់ ដឺគូ (Jean Decoux) អគ្គទេសាភិបាលបារាំង ប្រចាំឥណ្ឌូចិន បានតែងតាំងមន្ត្រីបារាំងថ្មីម្នាក់ឈ្មោះ ហ្សក អាម៉ង់ ឡេអុង ហ្គោដេ (George Armand Leon Gauthier) ឱ្យមកធ្វើជាទេសាភិបាលជាន់ខ្ពស់ជំនួស ហ្សង់ ដឺឡង់ (Jean Delens)។ ពេលនោះ ទេសាភិបាលជាន់ខ្ពស់ ហ្គោដេ (Gauthier) សម្លឹងឃើញកញ្ញា ដួន ជឿម ជាចៅរបស់ឧកញ៉ាចៅហ្វាវាំង ដួន ដែលស័ក្តិសមបំផុតក្នុងការរៀបអភិសេក ជាមហេសីរបស់ព្រះមហាក្សត្រ សីហនុ។ កញ្ញា ដួន ជឿម មានឪពុកឈ្មោះ ដួន ហ៊ល និងម្តាយឈ្មោះ ប៊ុណ្ណ ចន្ទម៉ូលី ។ ប៊ុណ្ណ ចន្ទម៉ូលីនេះ ជាបងបង្កើតរបស់ ប៊ុណ្ណ ចន្ទម៉ុល។ ដួន ហ៊ល និងប៊ុណ្ណ ចន្ទម៉ូលី មានកូន៦នាក់ ១. ដួន ជឿន, ២. ដួន ជឿម (ស្រី), ៣. ដួន ជុំ, ៤.ដួន មុម្ម, ៥.ដួន សោភ័ណ (ស្រី) ស្លាប់ពេលអាយុបាន៤ឆ្នាំ និង៦.ដួន ប្រាសិទ្ធ។

តែទោះបីកញ្ញា ដួន ជឿម ជាកូនស្រីគហបតី និងមានការរៀនសូត្រចេះដឹងខ្ពង់ខ្ពស់យ៉ាងណា ក៏ព្រះមហាក្សត្រ សីហនុ មិនសព្វព្រះទ័យនឹងរូបសម្បត្តិរបស់នាងដើម្បីយកមកធ្វើជាអគ្គមហេសីរបស់ព្រះអង្គដែរ។ តែក្រោយមក កញ្ញា ដួន ជឿម បានរៀបការជាមួយ ឈាន វ៉ែម ដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីអប់រំជាតិ ពីថ្ងៃទី២ ខែមករា ឆ្នាំ១៩៤៨ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៤៨ ។

របត់នយោបាយ

ក្រោយមក ព្រះមហាក្សត្រ សីហនុ ឈ្វេងយល់ថា ការមិនសព្វព្រះទ័យយកកញ្ញា ជួន ជឿម មកធ្វើជាអគ្គមហេសីរបស់ព្រះអង្គនេះ គឺជាការប្រមាថដ៏ធ្ងន់មួយរបស់ព្រះអង្គចំពោះកិត្តិយសក្រុមគ្រួសារត្រកូលជួននេះ ក៏អាចថាបាន ព្រោះដោយសារបញ្ហានេះហើយ ទើបក្រោយមក មានបង និងប្អូនប្រុសៗ របស់កញ្ញា ជួន ជឿម ៣នាក់ គឺជួន ជឿន, ជួន មុម្ម និងជួន ប្រាសិទ្ធ ក៏បានចូលរួមជាមួយពួកមេដឹកនាំខ្មែរក្រហមដើម្បីផ្តួលរំលំព្រះអង្គដែរ។ តែមានប្អូនប្រុសកញ្ញា ជួន ជឿម ម្នាក់ឈ្មោះ ជួន ជុំ មិនបានចូលរួមតស៊ូជាមួយពួកមេដឹកនាំខ្មែរក្រហម ទេ។

ចំពោះការឈ្វេងយល់របស់សម្តេចសីហនុ ដូចខាងលើនេះ ជួន មុម្ម បានធ្វើការបកស្រាយថា កាលនោះ ទោះបីព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ចង់ឱ្យព្រះមហាក្សត្រ សីហនុ រៀបការជាមួយ ជួន ជឿម ជាបងស្រីគាត់យ៉ាងណាក៏ដោយ ក៏គ្រួសារត្រកូលជួន មិនអាចទទួលបានដែរ ព្រោះឧកញ៉ាថៅហ្វាវាំង ជួន ដែលជាជីតារបស់គាត់បានផ្តាំទុកថា បើមានកូនស្រី កុំឱ្យយកប្តីជាស្តេច ឬយកប្តីជាជនជាតិយួន។

ក្រោយពីបង្កើតចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង ថ្ងៃ២៣ មីនា ឆ្នាំ១៩៧០ មក ដំបូងសម្តេចសីហនុ បានផ្ញើសារទូរលេខជាបន្តបន្ទាប់ទៅ ជួន មុម្ម ដែលនៅក្រុងប៉ារីស ឱ្យធ្វើដំណើរទៅក្រុងប៉េកាំង ដើម្បីចូលរួមក្នុងចលនាតស៊ូជាមួយព្រះអង្គ។ បន្ទាប់ពីធ្វើការពិចារណាយ៉ាងល្អិតល្អន់មក គាត់យល់ឃើញថា ពេលនេះមិនអាចនៅឈរឱបដៃនៅស្ងៀមបានទេ គាត់ក៏សម្រេចចិត្តចាកចោលប្រពន្ធ និងកូនៗ ព្រមទាំងបោះបង់ចោល ការងារស្រាវជ្រាវទាំងអស់នៅក្រុងប៉ារីស ធ្វើដំណើរទៅក្រុងប៉េកាំង តាមការអំពាវនាវរបស់សម្តេចសីហនុ។

នៅដើមខែមេសា ឆ្នាំ១៩៧០ ពេលទៅដល់ក្រុងប៉េកាំងភ្លាម ជួន មុម្ម សង្កេតឃើញថា នៅក្នុងរាជដំណាក់សម្តេចសីហនុ ដែលមេដឹកនាំចិនឱ្យស្នាក់នៅនោះ ហាក់ដូចជានាវាមួយកំពុងអណ្តែតនៅក្នុងមហាជលសាមួយគ្មានកោះត្រើយ។ ទោះបីពេលនោះ សម្តេចសីហនុ និងប៉ែន នុត ជាប្រមុខចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា ក៏ពិត

របត់នយោបាយ

មែនតែមិនដឹងអ្នកណាកាន់ចាប៉ី អ្នកណាកាន់ទ្រនោះទេ។ គាត់ឃើញតែមេដឹកនាំចិនដើរគ្រវីក្បាលដកដង្ហើមធំ មិនដឹងពឹងលើបុគ្គលខ្មែរណា ដើម្បីជួយរៀបចំចាត់តាំងរចនាសម្ព័ន្ធដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា ឱ្យបានរឹងមាំ និងមានប្រសិទ្ធភាព ព្រោះមន្ត្រីដែលតាមហែហមអមព្រះរាជដំណើរព្រះអង្គ ចាកចេញពីប្រទេសតាំងពីដើមខែកុម្ភៈមកនោះ ម្នាក់ៗគិតតែព្រួយបារម្ភពីក្រុមគ្រួសារបងប្អូននៅក្នុងប្រទេស មិនដឹងជោគវាសនាទៅជាយ៉ាងណា ដូច្នេះពួកគេចង់តែត្រឡប់ទៅមាតុប្រទេសវិញតែម្យ៉ាងគត់។

ប៉ែន នុត បានឱ្យ ជួន មុម្ម , សារិន ឆាក និងថៅ សេង ចូលទៅប្រជុំពិភាក្សាគ្នាដើម្បីរៀបចំសមាសភាព មេដឹកនាំការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា។ ប៉ុន្តែ ការរៀបចំសមាសភាពសមាជិកការិយាល័យនយោបាយនេះ ធ្វើឱ្យសម្តេចសីហនុ និងប៉ែន នុត មានទំនាស់នឹងគ្នាយ៉ាងខ្លាំង។ សម្តេចសីហនុ ទាមទារឱ្យដាក់ឈ្មោះហួត សម្បត្តិ បញ្ចូលបន្ថែមចូលក្នុងបញ្ជីសមាសភាពសមាជិកការិយាល័យនយោបាយ ដែល ប៉ែន នុត បានព្រាងរួចស្រេចហើយនោះ។ តែ ប៉ែន នុត មិនព្រមបញ្ចូលឈ្មោះ ហួត សម្បត្តិ តាមព្រះទ័យរបស់សម្តេចសីហនុ ទេ ដោយ ប៉ែន នុត យកលេសថា ហួត សម្បត្តិ ជាមនុស្សធ្លាប់ចំណាយថវិការដ្ឋច្រើនពេក នៅពេល ហួត សម្បត្តិ ធ្វើទូតប្រចាំនៅអង្គការសហប្រជាជាតិ នៅក្រុងញូវយ៉ក។ សម្តេចសីហនុ នៅតែទទូចឱ្យដាក់បញ្ចូលឈ្មោះ ហួត សម្បត្តិ នៅក្នុងបញ្ជីសមាសភាពសមាជិកការិយាល័យនយោបាយ។ ទំនាស់នេះបានធ្វើឱ្យរាំងស្ទះដល់ដំណើរការបង្កើតការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា។

ពេលនោះ បក្ស និងរដ្ឋាភិបាលចិន កំពុងមមាញឹកក្នុងការរៀបចំបើកសន្និសីទកំពូលវៀតណាម-កម្ពុជា-លាវ ដើម្បីប្រកាសពីការតស៊ូប្រឆាំងវត្តមានកងទ័ពអាមេរិកនៅឥណ្ឌូចិន ដោយបានអញ្ជើញគ្រប់អង្គទូតនានា មកចូលរួមផងដែរ។ តាមការគ្រោងទុកមេដឹកនាំចិន បានកំណត់ប្រារព្ធបើកសន្និសីទកំពូលនេះ នៅថ្ងៃទី២៤ និង២៥ ខែឧសភា ឆ្នាំ១៩៧០។ ថ្ងៃប្រារព្ធបើកសន្និសីទកំពូលនោះ កាន់តែឈានជិតមកដល់

របត់នយោបាយ
ទៅហើយ មេដឹកនាំចិនក៏បានហៅ ជួន មុម្ម, សារិន ឆាក និងចៅ សេង ទៅជួបពិភាក្សាគ្នា ដើម្បីដោះស្រាយបញ្ហារៀបចំសមាសភាពសមាជិកការិយាល័យនយោបាយ របស់រណសិរ្សរួបរួមជាតិកម្ពុជា ឱ្យបានមុនពេលបើកសន្និសីទកំពូលនោះ។

ជួន មុម្ម, សារិន ឆាក និងចៅ សេង បានឯកភាពគ្នាទាំងបីនាក់ថា មានតែនាំគ្នាទៅជួប ប៉ែន នុត អង្វរឱ្យយល់ព្រមបញ្ចូល ហួត សម្បត្តិ ជាសមាជិកការិយាល័យនយោបាយ តាមការចង់បានរបស់សម្តេចសីហនុ តែប៉ុណ្ណោះ។ ពេលចូលទៅក្នុងបន្ទប់ សារិន ឆាក ដែលធ្លាប់ស្គាល់ជិតស្និទ្ធនឹងភរិយា ប៉ែន នុត ជាអ្នកនិយាយអង្វរ ប៉ែន នុត ចំណែក ជួន មុម្ម និងចៅ សេង អង្គុយចាំស្តាប់ និងងក់ក្បាលបន្ទរ។ យប់ជ្រៅបន្តិចទៅហើយ ទើប ប៉ែន នុត សុខចិត្តយល់ព្រម។ ភ្លាមនោះ ជួន មុម្ម ប្រាប់ សារិន ឆាក និងចៅ សេង ថា ត្រូវតែចូលទៅគាល់ព្រះករុណា ដើម្បីទូលថា សម្តេច ប៉ែន នុត យល់ព្រមហើយ និងយកឯកសារទៅថ្វាយសុំឱ្យព្រះអង្គឡាយព្រះហស្តលេខា។ តែ សារិន ឆាក និងចៅ សេង ឃាត់ថា យប់ជ្រៅណាស់ទៅហើយ មិនហ៊ានចូលគាល់ព្រះអង្គទេ ចាំស្អែកព្រឹកទៅ...?។ ជួន មុម្ម ប្រកែកថា មិនបានទេ ស្អែកព្រឹក គេបើកប្រជុំសន្និសីទកំពូលនោះហើយ សម្តេចសីហនុ និងសម្តេច ប៉ែន នុត ក៏ត្រូវចូលប្រជុំសន្និសីទកំពូលនោះដែរ។ ឯមេដឹកនាំបក្ស និងរដ្ឋាភិបាលចិន ក៏ត្រូវការឯកសារស្តីពីការរៀបចំ សមាសភាពសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា នេះ ជាការបន្ទាន់ដែរ។

មិនបង្អង់យូរ ជួន មុម្ម ក៏នាំសារិន ឆាក និងចៅ សេង ដើរតម្រង់ទៅបន្ទប់រាជដំណាក់ ជាមួយគ្នានោះតែម្តង។ ទៅដល់មុខបន្ទប់រាជដំណាក់ កងអង្គរក្សស្ទុះមកឃាត់ដែរ តែ ជួន មុម្ម ធ្វើមិនដឹង ហើយដើរទៅគោះទ្វារ រួចចូលទៅតែម្តង ។ អ្នកម្នាងម៉ូនិក ជាព្រះជាយាភ្ញាក់ក្រោកឡើង ស្ទុះមកឈរបាំងមុខទ្វារទាំងសម្លៀកបំពាក់ផ្ទំយប់ ហើយរាដៃឃាត់មិនឱ្យចូល។ ជួន មុម្ម និយាយថា សុំចូលគាល់ព្រះករុណា មានការបន្ទាន់ខ្លាំងណាស់ ហើយដើរចូលទៅក្នុង។ សារិន ឆាក និងចៅ សេង ចូលតាមពីក្រោយ ក្រឡេកឃើញ សម្តេចសីហនុ គង់នៅមុខប៊ុយរ៉ូ ក៏នាំគ្នាថ្វាយបង្គំ។ ព្រះអង្គ

របត់នយោបាយ
ទតឃើញហើយ ទ្រង់ញញឹមហាក់យល់ការ។ សារិន ឆាក និងថៅ សេង ទូលថា ប៉ែន នុត យល់ព្រមបញ្ចូល ហួត សម្បត្តិ ជាសមាជិកការិយាល័យនយោបាយហើយ។

សម្តេចសីហនុ ក៏បានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងសមាសភាពសមាជិកការិយាល័យនយោបាយនោះ ដោយព្រះទ័យរីករាយ។ នៅវេលាម៉ោង២ទៀបភ្លឺ ជួន មុម្ម ក៏រត់ទៅជួប ហាន នៀនឡុង មន្ត្រីទំនាក់ទំនងប្រទេសអាស៊ី របស់ក្រសួងការបរទេសចិន ទាំងយប់ ដើម្បីប្រគល់ឯកសារតែងតាំង សមាសភាពសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលសម្តេចសីហនុ បានឡាយព្រះហស្តលេខាជាផ្លូវការហើយនោះ។ តែមន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសចិន ហាន នៀនឡុង ទទួលឯកសារពីដៃ ជួន មុម្ម ទាំងពេលកំពុងស្លៀកខោខ្លីនោះ បានប្រាប់ថា៖ ដោយសារឃើញភាគីកម្ពុជា រៀបចំឯកសារនេះមិនទាន់យើងខ្ញុំបានសម្រេចលើកពេលបើកសន្និសីទកំពូលវៀតណាម-កម្ពុជា-លាវ មួយថ្ងៃទៀត។ ដូច្នេះ ជួន មុម្ម មិនហ៊ានទៅដេកទេ គឺត្រូវរង់ចាំដល់ព្រឹកឡើងភ្លឺ នឹងចូលទៅគាល់ និងទូលព្រះករុណាវិញថា មេដឹកនាំចិន សម្រេចលើកថ្ងៃបើកសន្និសីទកំពូលនោះ មួយថ្ងៃទៀត។ ចំណែក សារិន ឆាក និងថៅ សេង ត្រូវទៅប្រាប់ ប៉ែន នុត ឱ្យបានដឹងពីការលើកពេលប្រជុំកំពូលនេះដែរ។

នៅរសៀលថ្ងៃទី២៤ ខែមេសា ជាថ្ងៃលើកពេលប្រជុំកំពូល ស្រាប់តែ ផាម វ៉ាន់ដុង នាយករដ្ឋមន្ត្រីវៀតណាមខាងជើង ដែលរង់ចាំចូលប្រជុំនៅថ្ងៃស្អែកនោះ បានអញ្ជើញ ជួន មុម្ម ឱ្យទៅជួបសំណេះសំណាលគ្នា។ ដំបូង ជួន មុម្ម នឹកថា រដ្ឋមន្ត្រីវៀតណាមខាងជើងរូបនេះ ប្រហែលចង់និយាយពីបញ្ហាអាថ៌កំបាំងអ្វីជាមួយគាត់ហើយមើល៍ទៅ?។ តែពេលទៅជួបគ្នា ផាម វ៉ាន់ដុង គ្រាន់តែសំណេះសំណាលសួរសុខទុក្ខជាធម្មតា។

ជួន មុម្ម យល់ថា ផាម វ៉ាន់ដុង គ្រាន់តែចង់ដឹងថា គាត់ជានរណាប៉ុណ្ណោះ?។ តែក្រោយមកទៀត នៅពេល ជួន មុម្ម ដង្ហែសម្តេចសីហនុ យាងទៅធ្វើទស្សនកិច្ចនៅក្រុងហាណូយ ឧត្តមសេនីយ៍ វ៉ូ ង្វៀនយ៉ាប់ ចាប់ដៃគាត់ហើយសួរភ្លាមថា នរណាមួយ

របត់នយោបាយ

ឈ្មោះ សារិន ឆាក? គាត់យល់ថា ឧត្តមសេនីយ៍រដ្ឋមន្ត្រីការពារជាតិវៀតណាមរូបនេះ ប្រហែលជាចង់ស្គាល់មុខ សារិន ឆាក ដោយសារ សារិន ឆាក បានសរសេរនិក្ខេបបទមួយស្តីពីបញ្ហាព្រំដែនខ្មែរ-វៀតណាម ដែលធ្វើឱ្យមេដឹកនាំវៀតណាម មានការរង្គាសចិត្តជាខ្លាំង។

សមាសភាពការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា មាន ប៉ែន នុត ជាប្រធាន និងសមាជិក១០រូបរួមមាន ៖ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់, ថៅ សេង, ដួង សំអុល, ហួត សម្បត្តិ, ចាន់ យ៉ូរ៉ាន់, ជា សាន, សារិន ឆាក និងជួន មុម្ម។ សមាជិកការិយាល័យនយោបាយទាំង១០រូបនេះ ជាអ្នកតាក់តែងរៀបចំកម្មវិធី និងគោលនយោបាយសំខាន់ៗរបស់រណសិរ្សរួបរួមជាតិកម្ពុជា។ តាមពិតទៅសម្តេចសីហនុ ត្រូវកាន់តួនាទីជាព្រះប្រធានការិយាល័យនយោបាយ តែព្រះអង្គប្រកែកមិនព្រមទទួល ហើយប្រគល់ឱ្យ ប៉ែន នុត ធ្វើជាប្រធានការិយាល័យនយោបាយជំនួសវិញ។ ក្រោយពីរៀបចំសមាសភាពការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ប៉ែន នុត នៅក្រុងប៉េកាំង និងមេដឹកនាំចលនាតស៊ូនៅក្នុងប្រទេសបានរៀបចំបញ្ជីរាយនាមសមាសភាពគណៈរដ្ឋមន្ត្រីរួបរួមជាតិកម្ពុជា។

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ សមាសភាពរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានប្រកាសជាផ្លូវការ ដោយមាន ប៉ែន នុត (នៅក្រុងប៉េកាំង) ជានាយករដ្ឋមន្ត្រី, ខៀវ សំផន (នៅក្នុងប្រទេស) ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ, សុន សេន (នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីការពារជាតិ, សារិន ឆាក (នៅក្រុងប៉េកាំង) ជារដ្ឋមន្ត្រីការបរទេស, រ៉ាន់ ពិនី (នៅក្រុងប៉េកាំង) ជាអនុរដ្ឋមន្ត្រីការបរទេស, ហ៊ូ យន់ (នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីមហាផ្ទៃ សហករណ៍ និងកំណែទម្រង់សហគមន៍, ហ៊ូ នឹម (នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីក្រសួងឃោសនាការ, ទីវ អុល (នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីក្រសួងឃោសនាការ, ជួន មុម្ម (នៅក្រុងប៉េកាំង) ជារដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, កុយ ធួន (នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឧត្តម

របត់នយោបាយ
សេនីយ៍ ដួង សំអុល ជារដ្ឋមន្ត្រីសម្ភារៈបរិក្ខារ និងសាស្ត្រាវុធ (ពេលនោះ ដួង សំអុល កំពុងសម្រាកព្យាបាលរោគនៅក្នុងមន្ទីរពេទ្យមួយក្នុងក្រុងប៉េកាំង), ជា សាន (នៅក្រុងប៉េកាំង) អតីតឯកអគ្គរាជទូតប្រចាំសហភាពសូវៀត និងជាអ្នកកាន់សាសនាកាតូលិកជារដ្ឋមន្ត្រីយុត្តិធម៌, ថៅ សេង (នៅក្រុងប៉េកាំង) ជារដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស, ជួន ប្រាសិទ្ធ (នៅក្រុងប៉េកាំង) រដ្ឋមន្ត្រីសម្របសម្រួល, តូច គឿន (នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, ជួន ជឿន (នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីសុខាភិបាល, ចាន់ យូរ៉ាន់ (នៅក្រុងប៉េកាំង) ជារដ្ឋមន្ត្រីអប់រំ និងយុវជន, អៀង ធីរិទ្ធ (នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីអប់រំ និងយុវជន, ង៉ោ ហ៊ូ (នៅក្រុងប៉េកាំង) អតីតឧត្តមសេនីយ៍កងទ័ពជើងអាកាស ជារដ្ឋមន្ត្រីសង្គមកិច្ច, សុក ធួក (វន វ៉េត) (នៅក្នុងប្រទេស) អនុរដ្ឋមន្ត្រីសន្តិសុខជាតិ។

ក្រោយពីបានបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មិនបានប៉ុន្មានសប្តាហ៍ផង គាត ឈន់ អតីតរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម ឆ្នាំ១៩៦៨ កំពុងបំពេញបេសកកម្មនៅក្រៅប្រទេស ក៏បាននាំក្រុមគ្រួសារចាកចេញពីការគ្រប់គ្រងរបស់ លន់ នល់ មកសុំចុះចូលជាមួយរណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំងដែរ។ គាត ឈន់ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាលេខាធិការការិយាល័យនយោបាយផងដែរ។

ទាក់ទងដល់ការរៀបចំបញ្ជីរាយនាមសមាសភាពគណៈរដ្ឋមន្ត្រីនេះ ដំបូងពេលទតឃើញមានឈ្មោះ ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ធ្វើឱ្យសម្តេចសីហនុ មានការងឿងឆ្ងល់ជាខ្លាំង ព្រោះមជ្ឈដ្ឋាននានាក្នុងប្រទេសបាននិយាយថា មន្ត្រីល្បីឈ្មោះជាបញ្ញវន្តឆ្វេងនិយមទាំង៣នាក់នេះ ស្លាប់អស់តាំងពីឆ្នាំ១៩៦៧មកម្ល៉េះ?។

ក្រោយពីចុះផ្សាយបញ្ជីរាយនាម សមាសភាពរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះមក មានអ្នកកាសែតបរទេសខ្លះ បានសរសេរជៀមដាមថា នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សម្តេចសីហនុ បានតែងតាំងខ្មោចទាំងបី គឺ ខៀវ សំផន, ហ៊ូ យន់ និង

ហ៊ូ នឹម ឱ្យធ្វើជារដ្ឋមន្ត្រី។ មុនពេល អៀង សារី មកដល់ក្រុងប៉េកាំង សួង ស៊ីគឿន ហៅសមមិត្ត គង់ បានទាមទារឱ្យបង្កើតព្រឹត្តិបត្រមួយទៀត ជាភាសាបារាំង។ តែ ជួន មុម្ម មិនយល់ស្រប ព្រោះឃើញសំណេរព្រឹត្តបត្រជាភាសាខ្មែរមាននិន្នាការលំអៀងទៅខាងសូវៀតពេក ហើយរដ្ឋាភិបាលចិន ក៏ទំនងជាមិនសូវសប្បាយចិត្តនឹងសំណេរនេះដែរ។ លុះពេល អៀង សារី មកដល់ក្រុងប៉េកាំង ក្នុងខែកក្កដា ឆ្នាំ១៩៧១ ភ្លាម ប្រហែលជាមេដឹកនាំចិនប្រាប់ហើយ បានជា អៀង សារី សួររកមុខអ្នកដែលឱ្យចេញព្រឹត្តបត្រនេះ ស្រាប់តែ សួង ស៊ីគឿន បែរទៅជាឆ្លើយដាក់រូបគាត់ថា ជាអ្នកឱ្យចេញព្រឹត្តបត្រនោះទៅវិញ។ គាត់ហាក់ត្រូវគេចាក់មួយកាំបិតចំពីក្រោយខ្នង ផ្ទុយទៅវិញបើកាលនោះ អៀង សារី លើកសរសើរព្រឹត្តបត្រនោះ ប្រហែលជា សួង ស៊ីគឿន ឆ្លើយថា ខ្លួនគេជាអ្នកផ្ដើមធ្វើព្រឹត្តបត្រនេះហើយមើលទៅ?។

ក្រោយមកទៀត អៀង សារី ក៏បានបន្ទុះបង្អាប់ ជួន មុម្ម ថា ខ្លឹមសារកម្មវិធីនយោបាយដែល ជួន មុម្ម ជាអ្នកតាក់តែងឡើងនោះ វាស្រាលពេក។... នេះជាហេតុធ្វើឱ្យមានទំនាស់ជាមួយគ្នាជាបន្តបន្ទាប់។ ក្រោយមកទៀត អៀង សារី ចេះតែជំរុញឱ្យ ជួន មុម្ម ចូលទៅតស៊ូនៅក្នុងប្រទេស តែគាត់ចេះតែប្រកែក ព្រោះមិនទុកចិត្ត អៀង សារី តាំងពីដើមទីមក។

ក្នុងតួនាទីជាសមាជិកការិយាល័យនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួន មុម្ម ត្រូវបាននាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ និងមន្ត្រីការបរទេស ហាន នៀនឡុង បានអញ្ជើញឱ្យទៅជួបដើម្បីពិភាក្សាគ្នាពីបញ្ហាផ្ដល់ជំនួយថវិកាដល់ចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា។

ជូ អេនឡាយ សួរថា តើសមមិត្តត្រូវការជំនួយប៉ុន្មានលានដុល្លារ? គាត់ឆ្លើយថា ៥លានដុល្លារអាមេរិក ជាការគ្រប់គ្រាន់ហើយ។ តែ ជូ អេនឡាយ តបវិញភ្លាមថា ទេ! ១០លានដុល្លារអាមេរិក ទើបសមល្មម...។ ជួន មុម្ម ក៏បានចុះហត្ថលេខាទទួលជំនួយជាថវិកា១០លានដុល្លារអាមេរិក ពីរដ្ឋាភិបាលចិន។ ជួន មុម្ម ក៏ពិចារណាដែរថា ចិន

របត់នយោបាយ
ជួយយើងក្នុងប្រយោជន៍គេដែរ ប៉ុន្តែបើខ្លួនយើងគ្មានកម្លាំង និងរចនាសម្ព័ន្ធដឹកនាំត្រឹមត្រូវទេ ក៏គេជួយយើងមិនកើតដែរ។

ដោយមានជំនួយពីចិនប្រជាមានិត និងមានរចនាសម្ព័ន្ធត្រឹមត្រូវនេះដែរ រណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេចសីហនុ ជាប្រធាន និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមាន ប៉ែន នុត ជានាយករដ្ឋមន្ត្រី មានលទ្ធភាពធ្វើឱ្យបណ្តាប្រទេសជាច្រើនព្រមទាំងអង្គការអន្តរជាតិនានា ពិសេសអង្គការសហប្រជាជាតិ បោះឆ្នោតទទួលស្គាល់ថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជារាជរដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់កម្ពុជា។



**សម្តេចសីហនុ និងចាន់ យូវ៉ាន់**
**(អៀង សារី នៅខាងក្រោយខ្លួនសម្តេចសីហនុ)**

នៅក្នុងឆ្នាំ១៩៧៣ ក្នុងអង្គប្រជុំមួយ អៀង សារី បានបញ្ជាឱ្យរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាឱ្យឈប់សុំអាហារូបករណ៍ពីប្រទេសបារាំង និងប្រទេសផ្សេងៗឱ្យនិស្សិតខ្មែរទៅបន្តការសិក្សាទៀត ព្រោះការតស៊ូនៅក្នុងប្រទេស គេមិនត្រូវការសញ្ញាបត្រទេ

របត់នយោបាយ
គេត្រូវការតែសញ្ញាឃើញតែប៉ុណ្ណោះ។ ឮដូច្នោះ អ្នកខ្លះសើចទះដៃ តែនិស្សិតខ្លះបាន លបសួរយោបល់ ជួន មុម្ម ថា តើយើងត្រូវឈប់រៀនតទៅទៀតឬទេ ? ជួន មុម្ម បាន ឆ្លើយតបទៅវិញថា៖ « ខ្លួនខ្ញុំបានរៀនចប់ហើយ រឿងនេះយកទៅគិតខ្លួនឯងចុះ! »។

ពេលនោះ ទឹកចិត្តអ្នកតស៊ូនៅក្រៅប្រទេសភាគច្រើន គឺយកតាមគំរូរបស់អ្នក តស៊ូនៅក្នុងប្រទេសដែលមានឆន្ទៈប្ដូរផ្ដាច់យកជីវិតទៅតស៊ូដើម្បីបដិវត្តន៍។ ដូច្នេះ ដោយសារតែពាក្យឃោសនាថា ការតស៊ូនៅក្នុងប្រទេស គេមិនត្រូវការសញ្ញាបត្រទេ គេត្រូវការតែសញ្ញាឃើញនោះ និស្សិតនៅបរទេសភាគច្រើនបានសម្រេចចិត្តបោះបង់ ចោលការសិក្សា ហើយស្ម័គ្រចិត្តទៅចូលរួមក្នុងចលនាតស៊ូនៅក្នុងប្រទេសវិញ។

នៅឆ្នាំ១៩៧៣នេះដែរ សឺន សាន បានស្នើសុំ ប៉ែន នុត នាយករដ្ឋមន្ត្រីរាជរដ្ឋា ភិបាលរួបរួមជាតិកម្ពុជា ឱ្យទៅជួបពិភាក្សាគ្នាពីរឿងប្រទេសជាតិនៅក្រុងហុងកុង តែ ជួន មុម្ម បានជម្រាប ប៉ែន នុត ថា៖ សម្ដេច ជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួម ជាតិកម្ពុជា ឯ សឺន សាន ពុំមានមុខតំណែងតួនាទីជាអ្វីទេ បើគាត់ចង់ជួបសម្ដេច ត្រូវ មកជួបនៅក្រុងប៉េកាំង នេះទៅ។ តែយ៉ាងណាក៏ ប៉ែន នុត មិនបានទៅជួប សឺន សាន នៅក្រុងហុងកុង នោះដែរ។

ជួន មុម្ម នៅចាំបានថា ម្ចាស់ក្សត្រីនរោត្តម សុរិយារង្សី ហៅម្ចាស់ប៉ាង ជាបុត្រី សំណព្វរបស់សម្ដេចសីហនុ ស្រឡាញ់រាប់អានគាត់ណាស់។ ពេលណា បានដឹងរឿងអ្វី នៅក្នុងរាជដំណាក់ ម្ចាស់ប៉ាង តែងមកលួចខ្សឹបប្រាប់គាត់ឱ្យបានដឹង។ ម្ល៉ោះហើយ រឿងរ៉ាវទាំងអស់នៅក្នុងរាជដំណាក់ក្នុងសណ្ឋាគារមិត្តភាពនៅក្រុងប៉េកាំង មិនអាច លាក់បាំងគាត់បានទេ។

ថ្ងៃមួយ ក្រុមដែលស្និទ្ធខាង ប៉ែន នុត ខ្លះបានទិតៀនថា អ្នកម្នាង (អ្នកម្នាងម៉ូនិក) ហ៊ានទិញអាវម៉ង់តូរោមសត្វមួយមានតម្លៃថ្លៃសម្បើមណាស់។ ពេលនោះ ក្នុងនាម គាត់ជារដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាប់ពួកគេវិញថា អ្នកម្នាងជាព្រះអគ្គមហេសី ជាតំណាងប្រទេសយើង ចិនគេមិនគិតអំពីការចំណាយប៉ុណ្ណឹងទេ ហើយអ្នកម្នាងយក

របត់នយោបាយ

លុយចិន ទៅទិញរបស់របរចិន លុយនោះវាគង់តែចូលទៅក្នុងថវិកាចិន វិញទេ។

ជួន មុម្ម នៅចាំបានដែរថា ពេលនោះ មានបងប្អូនខ្មែរយើងខ្លះចង់បានរបបគ្រប់គ្រងតាមបែបអាមេរិក បងប្អូនខ្លះទៀតចង់បានរបបគ្រប់គ្រងតាមបែបចិន ឬតាមបែបសូវៀត តែចំពោះគាត់ និងខ្មែរភាគច្រើនបានជ្រើសរើសរបបគ្រប់គ្រងតាមបែបរណសិរ្សរួបរួមជាតិកម្ពុជា។ ជួន មុម្ម យល់ថា ការប្រកាន់និន្នាការឆ្វេង និន្នាការស្តាំ និងនិន្នាការកណ្តាល គឺជាការធម្មតា។ តែគាត់ប្រកាន់ជំហរប្រមូលមិត្តដើម្បីពន្លត់ភ្លើងជម្លោះកុំឱ្យឆាបឆេះផ្ទះរណសិរ្សរួបរួមជាតិ។

នៅក្រុងប៉េកាំង ទុនដោត ស៊ីរិន បានខ្សឹបប្រាប់ មុម្ម ថា អៀង សារី ចេះតែបង្ខំឱ្យគាត់សរសេររបាយការណ៍ស្តីពីកិច្ចប្រជុំផ្សេងៗ តែមិនដែលឃើញ អៀង សារី យកទៅអានម្តងណាសោះ គឺឱ្យសរសេរចោលអត់ប្រយោជន៍។ គាត់ទាំងពីរនាក់ធ្ងល់ណាស់ ចេះតែគ្រវីក្បាលហួសចិត្ត។ ថ្ងៃមួយ អៀង សារី សាកល្បងឱ្យ ជួន មុម្ម បកប្រែអត្ថបទមួយនៅក្នុងសារព័ត៌មានញូវយ៉កថែម មកជាភាសាខ្មែរ តែ ជួន មុម្ម ប្រកែកភ្លាមថា៖ គាត់មិនមែនអ្នកបកប្រែទេ។ អៀង សារី មិនសប្បាយចិត្តចំពោះអ្នកណាដែលហ៊ានប្រកែកតវ៉ានឹងខ្លួន។

ជួន មុម្ម រម្លឹកថា រយៈពេលរស់នៅជាមួយគ្នាបីឆ្នាំនៅក្រុងប៉េកាំង ទំនាក់ទំនងរវាង អៀង សារី និងគាត់ មិនសូវចុះសម្រុងនឹងគ្នាទេ ព្រោះម្នាក់នេះមានទស្សនៈកម្ទេចពួកមន្ត្រីចាស់ៗឱ្យអស់ និងដាក់មនុស្សថ្មី។ ចំណែក ម្នាក់ទៀតមានទស្សនៈចង់ឱ្យខ្មែរទាំងអស់អាចរស់នៅជាមួយគ្នាបាន ទោះបីមានទំនាស់គ្នាខ្លះៗក៏ពិតមែន តែគាត់សង្ឃឹមថា ខ្មែរទាំងអស់នឹងអាចចូលរួមកសាងប្រទេសជាតិបាន ព្រោះពុំមែនមានតែ អៀង សារី ម្នាក់ទេ ជាអ្នកដឹកនាំនោះ។

ជួន មុម្ម បន្តថា ដើមឆ្នាំ១៩៧៣ អាមេរិកាំង និងវៀតណាម ចាប់ធ្វើការចរចាគ្នានៅប៉ារីស ចំពេលសម្តេចសីហនុ មានផែនការសម្ងាត់យាងទៅបំពេញទស្សនកិច្ចក្នុងតំបន់រំដោះនៅក្នុងប្រទេស។ មុនពេលយាងចេញដំណើរ មន្ត្រីការបរទេសចិន ហាន

នៀនឡុង បានប្រគល់ប្រាក់ចំនួន៥លានដុល្លារអាមេរិក នៅចំពោះមុខគាត់។ ក្រដាសប្រាក់ដុល្លារមួយរយៗ ត្រូវបានគេរៀបចងយ៉ាងណែនដាក់ក្នុងសាក់កាដូចំនួន៥។ សូម្បីតែព្រះករុណា សីហនុ ក៏គេមិនឱ្យដឹងដែរ។ និស្សិតខ្មែរ៥នាក់ ដែលស្ម័គ្រចិត្តចូលទៅតស៊ូនៅក្នុងប្រទេសពេលនោះ ត្រូវស្ពាយសាក់កាដូនោះម្នាក់ៗ១លានដុល្លារ ដោយមិនឱ្យដឹងថា នៅក្នុងសាក់កាដូនោះមានអ្វីផង។ ប្រាក់ដុល្លារសម្ងាត់ចំនួន៥លាននេះ មេដឹកនាំបក្ស និងរដ្ឋាភិបាលចិន ផ្ញើឱ្យមេដឹកនាំចលនាតស៊ូនៅក្នុងប្រទេស សម្រាប់យកទៅទិញកាំភ្លើង និងគ្រាប់ ពីពួកទាហាន លន់ នល់។

ឆ្នាំ១៩៧៣ នោះដែរ នៅប៉េកាំង មេដឹកនាំបក្ស និងរដ្ឋាភិបាលចិន តែងអញ្ជើញមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិ ឱ្យទៅទស្សនកិច្ចនៅតាមការដ្ឋាន តាមរោងចក្រផ្សេងៗ និងតាមមហាវិទ្យាល័យរបស់គេផងដែរ។ ពេលនោះ ប្រទេសចិន មិនទាន់បានបញ្ចប់បដិវត្តន៍វប្បធម៌នៅឡើយ។ សិស្សចិនភាគច្រើន ពេលរៀនចប់ថ្នាក់មធ្យមសិក្សា ត្រូវទៅលត់ដំតាមការជ្រើសរើសរៀងៗខ្លួន ដោយខ្លះទៅលត់ដំធ្វើស្រែ រែកភក់ រែកលាមកជាមួយអ្នកស្រែ ខ្លះទៅធ្វើកម្មករក្នុងរោងចក្រ និងខ្លះទៀតទៅបម្រើជាយោធា។

បន្ទាប់ពីលត់ដំបានមួយឆ្នាំឬពីរឆ្នាំ បើគណៈកម្មាធិការបក្សរបស់តំបន់ ឬអង្គភាពនីមួយៗ វាយតម្លៃថា សិស្សនោះធ្វើការលត់ដំបានល្អទើបរដ្ឋអនុញ្ញាតឱ្យទៅប្រឡងយកអាហារូបករណ៍ ចូលសិក្សានៅតាមមហាវិទ្យាល័យផ្សេងៗបន្តទៀត។

ថ្ងៃមួយ មេដឹកនាំចិន បានឱ្យ ជួន មុម្ម ទៅធ្វើទស្សនកិច្ចនៅមហាវិទ្យាល័យមួយ។ នៅក្នុងថ្នាក់រៀនមួយ សាស្ត្រាចារ្យម្នាក់កំពុងមានមតិទិតៀន និងស្វ័យទិតៀននៅមុខសិស្សបួនប្រាំនាក់ តាមរយៈអ្នកបកប្រែ ជួន មុម្ម ក៏ជ្រុលមាត់សួរទៅពួកគេថា៖ បើមានតែកម្មករ និងកសិករ តែគ្មានវិស្វករគ្រប់គ្រាន់ តើត្រូវធ្វើដូចម្តេច? ដើម្បីសាងសង់រោងចក្រ និងកសាងឧស្សាហកម្មបាន? ហើយហេតុអ្វីបានជាមានសិស្សតិចម្ល៉េះ?។ សាស្ត្រាចារ្យម្នាក់នោះប្រាប់ថា ពេលនេះ មានសិស្សតិច ព្រោះសិស្សភាគច្រើនត្រូវចេញទៅលត់ដំខ្លួននៅទីជនបទ។

របត់នយោបាយ

ជួន មុម្ម ជាមនុស្សវិទ្យាសាស្ត្រ ពិតជាដឹងច្បាស់ថា កម្មករអាចធ្វើការនឹងកម្លាំងបាយបានមែនពិត តែបញ្ហាបច្ចេកទេសចាំបាច់គេត្រូវការវិស្វករ ទើបអាចសាងសង់រោងចក្រ និងកសាងឧស្សាហកម្មបាន។

ក្រោយបញ្ចប់ដំណើរទស្សនកិច្ចនៅមហាវិទ្យាល័យនោះ អ្នកបកប្រែច្បាស់ជារាយការណ៍ទៅថ្នាក់លើរបស់គេ។ តាំងពីថ្ងៃនោះមក ពេលបើកអង្គប្រជុំម្តងៗ អៀង សារី តែងលើកឡើងដដែលៗថា៖ « នៅស្រុកខ្មែរគ្មានបញ្ញាជនអីទៀតទេ មានតែកសិករ និងកម្មករទេ ដែលហ៊ានប្តូរស្លាប់រស់ជាមួយបដិវត្តន៍... »។ តែគាត់មិនសូវយល់ន័យពីការលើកឡើងរបស់ អៀង សារី នេះទេ។ រហូតដល់ថ្ងៃមួយ ក្នុងឱកាសជប់លៀងចុងឆ្នាំ ១៩៧៤ ស្រាប់តែនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដើរមកបានគោះកែវស្រាជាមួយគាត់ ហើយនិយាយថា៖ គេរាយការណ៍ប្រាប់ខ្ញុំថា អ្នកឯងជាពួកសេរី...។ ឥឡូវខ្ញុំដឹងច្បាស់ហើយថា អ្នកឯងមិនមែនពួកសេរីទេ ហើយអ្វីដែលអ្នកឯងនិយាយថា ការកសាងឧស្សាហកម្មឱ្យជឿនលឿនគេត្រូវការវិស្វករនោះ គឺពិតប្រាកដណាស់។ ជួន មុម្ម ភ្ញាក់ខ្លួនព្រើត ហើយក៏រំភើបក្នុងចិត្តណាស់ដែរ ព្រោះនាយករដ្ឋមន្ត្រីចិន ដ៏ខ្លាំងពូកែរូបនេះ ហ៊ានទទួលស្គាល់ថា អ្វីដែលគាត់និយាយថា ដើម្បីកសាងឧស្សាហកម្មឱ្យជឿនលឿន គេត្រូវការវិស្វករនោះ គឺជាការពិត ហើយនេះជាការបញ្ជាក់ឱ្យឃើញថា នាយករដ្ឋមន្ត្រីចិន ទទួលស្គាល់ និងឱ្យតម្លៃដល់ ជួន មុម្ម ដែលជាមនុស្សវិទ្យាសាស្ត្រម្នាក់។

# ៧.៦. ក្រោយរដ្ឋប្រហារ ជួន ប្រាសិទ្ធ ចូលរួមចលនាតស៊ូកុម្មុយនិស្តវិញ




**ជួន ប្រាសិទ្ធ**

ជួន ប្រាសិទ្ធ ជាប្អូនពៅរបស់ ជួន មុម្ម គាត់កើតថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៣០ នៅក្រុងភ្នំពេញ ជាចៅរបស់ឧកញ៉ាចៅហ្វាំង ជួន។ ឪពុក ជួន ប្រាសិទ្ធ ឈ្មោះ ជួន ហ៊ល ទៅរៀននៅប្រទេសបារាំង តាំងពីក្មេងវ័យ។ ពេលវិលមកមាតុប្រទេសវិញ ទទួលតំណែងជាអគ្គលេខាធិការរដ្ឋសភា។ ម្តាយឈ្មោះ ប៊ុណ្ណ ចន្ទម៉ូលី ជាបងស្រីរបស់ ប៊ុណ្ណ ចន្ទម៉ុល ជាអ្នកទោសកោះត្រឡាច។



**ជួន ជុំ , ជួន ប្រាសិទ្ធ, ជួន ជឿម, ជូន មុម្ម និងជួន ជឿន**

ជួន ប្រាសិទ្ធ មានបងប្អូន ៦នាក់(ស្រី២ ប្រុស៤៖ ១. ជួន ជឿន ជាវេជ្ជបណ្ឌិត, ២. ជួន ជឿម (ស្រី) ជាភរិយា ឈាន វ៉ម អតីតនាយករដ្ឋមន្ត្រី ពីថ្ងៃទី២ ខែមករា ឆ្នាំ ១៩៤៨ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៤៨, ៣. ជួន ជុំ បណ្ឌិតច្បាប់, ៤.ជួន មុម្ម បណ្ឌិតវិទ្យាសាស្ត្រ, ៥.ជួន សោភ័ណ (ស្រី) ស្លាប់ ពេលអាយុបាន៤ឆ្នាំ និង៦. ជួន ប្រាសិទ្ធ (រូបគាត់ផ្ទាល់)។

ពីឆ្នាំ១៩៣៥ ដល់ឆ្នាំ១៩៤១ គាត់បានចូលរៀនសាលាបឋមសិក្សាបារាំង នៅក្រុងភ្នំពេញ រហូតដល់ប្រឡងចូលថ្នាក់ទី៦ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ឪពុកគាត់ក៏សម្រេចឱ្យទៅសិក្សានៅវិទ្យាល័យសាស្សឺលូ-ឡូបា (Chasseloup-Laubat) នៅក្រុងព្រៃនគរ រៀតណាមខាងត្បូង បន្តទៀត។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៤៤ ដោយក្រុងព្រៃនគរ ត្រូវយន្តហោះអាមេរិក ទម្លាក់គ្រាប់បែកខ្លាំងពេក ឪពុកគាត់ក៏សម្រេចឱ្យផ្លាស់ចេញក្រុងព្រៃនគរ ទៅរៀននៅក្រុងដាឡាត់ វិញ។ លុះដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ពួកហ្វាស៊ីសជប៉ុន ធ្វើរដ្ឋប្រហារដណ្តើមអំណាចពីបារាំង គាត់ត្រូវគេបញ្ជូនឱ្យត្រឡប់មកក្រុង

របត់នយោបាយ

ភ្នំពេញ នៅខែមេសា ឆ្នាំ១៩៤៥ និងបានបន្តការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ រហូតប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) នៅក្នុងខែមិថុនា ឆ្នាំ១៩៤៩។ ក្រោយប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ វរសេនីយ៍បារាំងម្នាក់ ឈ្មោះ ម៉ារ៉េ បានឱ្យគាត់ធ្វើដំណើរកម្សាន្តតាមជើងទឹក ទៅក្រុងម៉ានីល ប្រទេសហ្វីលីពីន និងក្រុងហុងកុង រយៈពេល២ខែ គឺពីខែកក្កដា ដល់ខែសីហា ឆ្នាំ១៩៤៩ ដើម្បីជាការលើកទឹកចិត្ត និងចង់ឱ្យចូលបម្រើការងារជាមន្ត្រីរាជការដូចជីតា និងឪពុកគាត់ផងដែរ។ តែនៅក្នុងខែកញ្ញា ឆ្នាំ១៩៤៩ ឪពុកគាត់បានបញ្ជូនឱ្យទៅបន្តសិក្សានៅប្រទេសបារាំង ដោយទទួល អាហារូបករណ៍ពាក់កណ្ដាល។ នៅទីក្រុងប៉ារីស ដោយមានការភ្ញាក់រឭកខាងស្មារតីស្នេហាជាតិ ក្នុងការតស៊ូប្រឆាំងពួកអាណានិគមនិយមបារាំង ដើម្បីទាមទារឯករាជ្យ និងមានគោលបំណងចង់ឱ្យប្រទេសកម្ពុជា ក្លាយទៅជាប្រទេសសង្គមនិយម នៅក្នុងឆ្នាំ១៩៥១ គាត់បានចូលក្នុងក្រុមម៉ាក្សស៊ីស្ម-លេនីនិស្ម ដែលបានបង្កើតឡើងដោយ អៀង សារី, សាឡុត ស និងសុន សេន។ល។

នៅក្នុងឆ្នាំ១៩៥២ រាជរដ្ឋាភិបាលភ្នំពេញ បានកាត់ផ្ដាច់អាហារូបករណ៍ពាក់កណ្ដាលនោះ ដោយសារគាត់បានធ្វើសកម្មភាពប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា។ នៅឆ្នាំ១៩៥៣ ក្រោមការណែនាំរបស់ អៀង សារី និងសាឡុត ស គាត់បានសម្រេចចូលជាសមាជិកបក្សកុម្មុយនិស្តបារាំង។ នៅឆ្នាំ១៩៥៣ ដដែល បន្ទាប់ពីចូលរួមធ្វើសកម្មភាពប្រឆាំងនឹងសម្ដេចសីហនុ តាមរយៈសមាគមនិស្សិតខ្មែរ គាត់ត្រូវប៉ូលិសបារាំង ចាប់យកទៅឃុំខ្លួនដើម្បីសួរចម្លើយរយៈពេល១ថ្ងៃ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយស្ត្រីជនជាតិបារាំង ឈ្មោះ គ្រីស្ទាន ហ្គូរ៉េ។ មានកូន ៣នាក់ (ស្រី២ ប្រុស១) កូនស្រីច្បងរបស់គាត់កើតនៅក្នុងឆ្នាំ១៩៥៥។

នៅចុងខែធ្នូ ឆ្នាំ១៩៥៥ គាត់ត្រឡប់មកមាតុប្រទេសវិញ និងបានចូលធ្វើការនៅរាជាយស្ម័យយានកម្ពុជា។ ពេលនោះ បក្សបានចាត់តាំងគាត់ឱ្យធ្វើជាលេខាសាខាបក្សនៅរាជាយស្ម័យយាននោះ ដើម្បីអូសទាញអប់រំកម្មករមួយចំនួនជាសម្ងាត់ ឱ្យបានយល់ដឹង

របត់នយោបាយ

ពីចលនាតស៊ូបដិវត្តន៍ និងចូលរួមសរសេរកាសែតអ្នកសង្កេតការណ៍ (Observateur) ជាភាសាបារាំង ផងដែរ។

តាមការស្នើពីក្រសួងសាធារណការ និងដោយមានការអនុញ្ញាតពីបក្សផងដែរ ជួន ប្រាសិទ្ធ បានទៅធ្វើកម្មសិក្សាស្តីពីបញ្ហារថភ្លើងនៅប្រទេសជប៉ុន ពីខែវិច្ឆិកា ឆ្នាំ១៩៥៨ ដល់ខែមេសា ឆ្នាំ១៩៥៩។ ពេលនោះហើយ ដែលគាត់បានទទួលព័ត៌មានអំពីព្រឹត្តិការណ៍ក្បត់របស់ សម សារី និងដាប ឈួន ព្រមទាំងបានដឹងឮអំពីសកម្មភាពរបស់ចារបុរសជប៉ុនម្នាក់ឈ្មោះ តាដាតូម៉ា ដែលបានទាក់ទងក្នុងចំណោមនិស្សិតខ្មែរនៅប្រទេសជប៉ុននោះ។

ក្រោយពេលត្រឡប់មកពីជប៉ុន វិញ ដោយសារចលនាកម្មកររថភ្លើងចេះតែបះបោរងើបឡើងប្រឆាំងតវ៉ា ពិសេសនៅក្នុងខែមិថុនា ឆ្នាំ១៩៦១ សម្តេចសីហនុ បានផ្លាស់គាត់ឱ្យទៅធ្វើការនៅក្រសួងសាធារណការវិញ បក្សក៏បានសម្រេចឱ្យគាត់ផ្តាច់ការទាក់ទងមួយរយៈ។

រហូតដល់ឆ្នាំ១៩៦២ បក្សបានចាត់តាំងគាត់ឱ្យមកធ្វើសកម្មភាពក្នុងចំណោមបញ្ញាជនវិញ និងតាមដានសភាពការណ៍វណ្ណៈកាន់អំណាច និងពួកបរទេស។ ពេលនោះគាត់បានទាក់ទងអតីតវរសេនីយ៍បារាំង ឈ្មោះ ម៉ារ៉េ ដែលធ្លាប់ស្គាល់គ្នាពីមុន ដើម្បីយកព័ត៌មានខ្លះៗ។ តែក្រោយមកទើគាត់ដឹងថា ឈ្មោះ ម៉ារ៉េ នោះ ជាចារបុរសបារាំង បានព្យាយាមយកព័ត៌មានពីគាត់វិញដែរ។ តែយ៉ាងណា គាត់មិនធ្វើឱ្យបែកការណ៍សម្ងាត់ណាមួយជាមួយចារបុរសបារាំងម្នាក់នេះឡើយ។

ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៦៣ លន់ នល់ បានរៀបចំបញ្ជីឈ្មោះពួកឆ្វេងនិយម៣៤នាក់ រួមមាន៖ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, ចៅ សេង, កេង វ៉ាន់សាក់, ទេព ឈីវខេង, សាឡុត ស, អៀង សារី, សុន សេន, គាត ឈន់, ឱក សាគុន និងជួន ប្រាសិទ្ធ...ជាដើម ដើម្បីឱ្យរៀបចំគណៈរដ្ឋមន្ត្រីថ្មីមួយដឹកនាំប្រទេស។ ការរៀបចំបញ្ជីឈ្មោះនេះ ធ្វើឱ្យពួកឆ្វេងនិយម (ពួកកុម្មុយនិស្ត) ជ្រួលច្របល់ ព្រោះគិតថា នេះជាផែនការរបស់

របត់នយោបាយ

លន់ នល់ ប្រមូលពួកគេយកទៅសម្លាប់ចោលតែប៉ុណ្ណោះ។ ដោយសារខ្លាច លន់ នល់ យកទៅសម្លាប់ចោល ជួន ប្រាសិទ្ធ ក៏បានសុំអនុញ្ញាតពីបក្សទៅរស់នៅប្រទេសបារាំង មួយរយៈសិន។ ចំណែក សាឡុត ស, អៀង សារី និងមេដឹកនាំមួយចំនួនទៀត ត្រូវបង្ខំចិត្តនាំគ្នារត់ចូលព្រៃ។

ក្នុងខែមិថុនា ឆ្នាំ១៩៦៣ ជួន ប្រាសិទ្ធ និងកូនស្រីច្បង បានឡើងយន្តហោះចាកចេញពីប្រទេសកម្ពុជា ដោយឈប់សំចតនៅក្រុងប្រាក ( Prague ) សាធារណរដ្ឋឆែក ( Czech Republic ) ជាប្រទេសសង្គមនិយមមួយ ដែលគាត់ចង់ស្គាល់ជាយូរមកហើយ នោះរយៈពេល២ថ្ងៃ ដើម្បីរង់ចាំឡើងយន្តហោះធ្វើដំណើរទៅទីក្រុងប៉ារីស បន្តទៀត។ រហូតដល់ខែធ្នូ ឆ្នាំ១៩៦៣ ប្រពន្ធ និងកូនគាត់២ទៀតបានមករស់នៅជួបជុំគ្នានៅប្រទេសបារាំង។ ឆ្នាំ១៩៦៥ គាត់ចូលធ្វើការនៅក្នុងក្រុមហ៊ុនលក់ប្រេងឥន្ធនៈ។ ឆ្នាំ១៩៦៨ គាត់ចូលធ្វើការនៅអាកាសយានដ្ឋានប៉ារីស។

ជួន ប្រាសិទ្ធ បានរម្លឹកថា រយៈពេលរស់នៅប្រទេសបារាំង ពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៧០ ទោះបី គាត់បានត្រៀមខ្លួនថា ថ្ងៃណាមួយបក្សនឹងប្រគល់ភារកិច្ចអ្វីមួយឱ្យគាត់ក៏ពិតមែន តែឥទ្ធិពលពួកនាយទុនបារាំង បានចូលមកបន្សាបទស្សនៈគោលជំហរបដិវត្តន៍របស់គាត់ ប្រែជាស្រពេចស្រពិល សម្ភារៈគ្របដណ្តប់ខ្លាំង និងឈានទៅសំងំសុខយករួចខ្លួន គិតគូរតែបញ្ហាគ្រួសារប្រពន្ធកូនតែប៉ុណ្ណោះ។ គាត់ដាច់ខ្សែទាក់ទងជាមួយបក្សទាំងស្រុង។ តែទោះបីយ៉ាងនេះក៏ដោយ ក៏គាត់ចូលរួមសកម្មភាពខ្លះៗនៅក្នុងសហភាពនិស្សិតខ្មែរដែរ។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បក្សបានហៅគាត់ឱ្យទៅបម្រើការងាររណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង ប្រទេសចិន តែគាត់មិនបានទៅភ្លាមៗតាមការចាត់តាំងរបស់បក្សទេ គាត់ឱ្យបងប្រុសគាត់ ( ជួន មុម្ម ) ទៅមុន។ មុនពេលបែកឆ្ងាយពីគ្នា ដើម្បីឱ្យគ្រួសារប្រពន្ធកូនមានលំនឹងក្នុងជីវភាពរស់នៅ ប្រាក់កាសនៅក្នុងគណនេយ្យធនាគារទាំងប៉ុន្មាន គាត់បានដាក់ឈ្មោះប្រពន្ធគាត់ និងបានលក់ផ្ទះ

របត់នយោបាយ

ចាស់យកប្រាក់បន្ថែមទៅទិញផ្ទះថ្មីមួយ ដោយសុំខ្ចីប្រាក់ក្រុមហ៊ុនអាកាសយានដ្ឋានប៉ារីស មកបន្ថែមទៀត នៅតែមិនគ្រប់ថ្លៃទិញផ្ទះថ្មីនោះទៀត ខណៈសមាជិករណសិរ្សរួបរួមជាតិកម្ពុជា នៅប៉ារីស មួយចំនួន បានប្រគល់ផ្ទះជាកម្មសិទ្ធិរបស់ពួកគេឱ្យបក្សយកធ្វើជាការិយាល័យ ដើម្បីបម្រើចលនាតស៊ូបដិវត្តន៍។ ពេលនោះ គាត់ពិតជាមានសេចក្តីអៀនខ្មាសបំផុត តែមិនដឹងដោះស្រាយយ៉ាងណា។ ដោយសារបញ្ហាគ្រួសារប្រពន្ធកូននេះ ធ្វើឱ្យគាត់មានការយឺតយ៉ាវ មិនបានចេញដំណើរពីក្រុងប៉ារីសទៅបម្រើការងាររណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង អស់រយៈពេល៣ខែ។

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧០ ជួន ប្រាសិទ្ធ បានធ្វើដំណើរទៅក្រុងប៉េកាំង ដោយឆ្លងកាត់តាមទីក្រុងមូស្គូ សហភាពសូវៀត។ ពេលឈប់សំចតនៅក្រុងមូស្គូ ជា សាន ឯកអគ្គរាជទូតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បាននាំគាត់ និងចៅ សេង ទៅជួបអ្នកដឹកនាំអង្គការសន្តិភាព ដែលជាអង្គការមហាជនរបស់សហភាពសូវៀត។ ពេលនោះ ជា សាន និងចៅ សេង ជាអ្នកឡើងថ្លែងការណ៍ ចំណែករូបគាត់មិនមានតួនាទីអ្វីទេ។

ជួន ប្រាសិទ្ធ បានឱ្យដឹងថា ពេលទៅដល់ទីក្រុងប៉េកាំង ទិសដៅបឋមរបស់គាត់គឺទាក់ទងជាមួយបក្សឡើងវិញដើម្បីរាយការណ៍ជូនបក្ស និងអនុវត្តតាមការណែនាំរបស់បក្ស។ តែមិនមានឱកាសសោះ ដោយសារដាច់ឆ្ងាយពីការអប់រំរបស់បក្ស និងនៅជាប់កម្អែលឥទ្ធិពលនាយទុនបារាំង ធ្វើឱ្យទស្សនៈគោលជំហរបដិវត្តន៍របស់គាត់នៅទន់ខ្សោយ និងមានការលំបាកច្រើនក្នុងការអនុវត្តមាគ៌ារបស់បក្ស។ នៅទីក្រុងប៉េកាំង សម្តេចសីហនុ និងប៉ែន នុត បានចាត់តាំងគាត់ឱ្យធ្វើជារដ្ឋមន្ត្រីសម្របសម្រួល ទទួលបន្ទុកទាក់ទងក្នុងប្រទេស។ សមមិត្ត គាត ឈន់ ក៏ត្រូវចាត់តាំងជារដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី។ ការចាត់តាំងនេះ មិនមែនមកពីគាត់ស្នើសុំនោះទេ គឺសម្តេចសីហនុ និងប៉ែន នុត ចង់ប្រមូលកម្លាំង(បញ្ញាជន)ឱ្យមកនៅខាងពួកគេ ដោយមិនទាន់ដឹងថា គាត់មានការទាក់ទងផ្ទៃក្នុងបក្សយ៉ាងណានោះទេ ហើយពួកគេក៏មិនដឹងច្បាស់ថា គាត់ជាស្អីដែរ?។ ពួកគេគ្រាន់តែដឹងថា គាត់មានវណ្ណៈដូចពួកគេប៉ុណ្ណោះ។ ចំណែកគាត់វិញ នៅពេល

របត់នយោបាយ
នោះ ទិសដៅធំជាងគេ គឺឱ្យតែបានប្រាក់ខែ ដើម្បីចិញ្ចឹមគ្រួសារនៅប្រទេសបារាំង។ ឯតួនាទីមុខមាត់បុណ្យស័ក្តិមិនជាសំខាន់ទេ។ តែថ្នាក់ដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជាចាស់ៗទាំងអស់ មិនសប្បាយចិត្តពីការតែងតាំងគាត់ឱ្យធ្វើជារដ្ឋមន្ត្រីសម្របសម្រួលនោះទេ ព្រោះពួកនេះគិតថា គាត់ជាអ្នកប្រឆាំងនឹងផលប្រយោជន៍វណ្ណៈគេ ក្បត់វណ្ណៈគេ ជាអ្នករារាំងមិនឱ្យពួកគេឡើងកាន់អំណាច ឬមិនឱ្យពួកគេចរចាជាមួយចក្រពត្តិអាមេរិក ព្រមទាំងចោទប្រកាន់ថា គាត់ជាខ្ញុំបម្រើបារាំងដោយសារគាត់មានប្រពន្ធជាជនជាតិបារាំង។

ចុងខែកក្កដា ឆ្នាំ១៩៧០ គាត់បានធ្វើដំណើរទៅក្រុងហាណូយ ជាមួយ ថៅ សេង តាមសេចក្តីអញ្ជើញរបស់រដ្ឋាភិបាលវៀតណាម។ មុនពេលឡើងយន្តហោះមិត្តចិនម្នាក់បានមកប្រាប់គាត់ថា មានគេចង់ជួប។ ពេលនោះ គាត់បានជួបមិត្តវ័ត្ន សាមឿន (ជាកម្មាភិបាលជាន់ខ្ពស់របស់បក្ស) ត្រូវឡើងយន្តហោះទៅក្រុងហាណូយដែរ តែជិះក្នុងបន្ទប់អ្នកបើកបរ។ មិត្តវ័ត្ន សាមឿន ប្រាប់គាត់ឱ្យប្រុងប្រយ័ត្ន ធ្វើយ៉ាងណាកុំឱ្យ ថៅ សេង ចាប់អារម្មណ៍ពីទំនាក់ទំនងសម្ងាត់រវាងគាត់ និងបក្ស។

ពេលទៅដល់ក្រុងហាណូយ គាត់បានជួបពិភាក្សាគ្នាជាមួយមិត្តវ័ត្ន សាមឿន អស់ពេលច្រើនម៉ោង ជាសម្ងាត់ម្តងទៀត។ គាត់សួរបញ្ជាក់ មិត្តវ័ត្ន សាមឿន ថា តើនយោបាយបក្សយើង និងបក្សវៀតណាម ឯកភាពគ្នាទេ? មិត្តវ័ត្ន សាមឿន បញ្ជាក់ថា ប្រហែលអាចទុកចិត្តគ្នាទៅវិញទៅមកបាន។

នៅហាណូយនោះហើយ ដែលគាត់បានហាមាត់ខ្ចីប្រាក់វៀតណាម ធ្វើមួយចំនួនទៅឱ្យសហភាពនិស្សិតខ្មែរ ដើម្បីធ្វើសកម្មភាពនៅប្រទេសបារាំង និងមួយចំនួនទៀតដើម្បីយកទៅដោះស្រាយបញ្ហាជំពាក់ប្រាក់គេ ទិញផ្ទះថ្មីនៅក្រុងប៉ារីស។ បញ្ហាខ្ចីប្រាក់វៀតណាមនេះ គាត់ដឹងខ្លួនថា ជាកំហុសធំណាស់ មួយជីវិតនេះគាត់មិនអាចបំភ្លេចបានឡើយ នឹកឃើញពេលណា គាត់មានការសោកស្តាយតូចចិត្ត និងឈឺចាប់បំផុត។ នេះមកពីគាត់គ្មានបទពិសោធខាងនយោបាយ គ្មានមោទនភាពជាតិ និងគ្មានទស្សនៈ

របត់នយោបាយ

អន្តរជាតិនិយមត្រឹមត្រូវ។

ជួន ប្រាសិទ្ធ រម្លឹកថា ក្នុងរយៈមួយ១ឆ្នាំដំបូង គាត់មិនទាន់ស្គាល់វៀតណាមច្បាស់ទេ។ គាត់ស្មានតែវៀតណាម ស្មោះនឹងកម្ពុជា គោរពកម្ពុជា។ ក្នុងស្មារតីយល់ច្រឡំនេះហើយ បានជាគាត់ធ្វើសេចក្ដីរាយការណ៍ អំពីសភាពការណ៍ផ្ទៃក្នុងបក្សកម្ពុជាជាចំហតាមរយៈវៀតណាម ឱ្យគេដឹងចំណុចខ្សោយរបស់បក្សកម្ពុជា ទាំងអស់។ ពេលនោះ វៀតណាម ក៏ចង់អូសទាញគាត់ឱ្យបម្រើនយោបាយគេដែរ ព្រោះគេស្គាល់ចំណុចខ្សោយរបស់គាត់ ដែលរស់នៅប្រទេសបារាំង។

រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧១ ទើបគាត់បានជួបតំណាងបក្ស (អៀង សារី) ឡើងវិញ នៅក្រុងហាណូយ គាត់មានការសប្បាយរីករាយបំផុត។ ដោយមានការអប់រំណែនាំជាប់ពីតំណាងបក្ស (អៀង សារី) គាត់បានលះបង់ជាបណ្ដើរៗ នូវកម្មសិទ្ធិបុគ្គល និងកម្មសិទ្ធិឯកជនដទៃទៀត ហើយបានភ្ជាប់ខ្លួនទៅនឹងបក្ស និងចលនាបដិវត្តន៍ ឡើងវិញ។ ដោយយល់ជ្រួតជ្រាបពីមាគ៌ានយោបាយ និងក្ដាប់បាននូវធាតុជាជនកុម្មុយនិស្ត និងបានកសាងខ្លួនជាជនកុម្មុយនិស្តបានមួយកម្រិត ហើយបក្សក៏មានការទុកចិត្តមកលើគាត់ជាបន្តបន្ទាប់។ ក្រោយពីបានចូលក្នុងចលនាបដិវត្តន៍ឡើងវិញ នាំឱ្យជីវិតគាត់មានន័យ មានខ្លឹមសារឡើងវិញ។

---

# ៧.៧. ជីវភាពគ្រួសារ និងការសិក្សា របស់ ហ៊ុន សែន



**ឧបាសក ហ៊ុន នាង  និងឧបាសិកា ឌី ប៉ុក**

ឧបាសក ហ៊ុន នាង កើតនៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ១៩២៣ នៅភូមិពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ក្នុងឆ្នាំ១៩៤១ គាត់បួសជាព្រះសង្ឃ ហើយបានមកគង់នៅវត្តឧណ្ណាលោម ដើម្បីសិក្សារៀនសូត្រ។ ក្នុងឆ្នាំ១៩៤២ ក្រោយពីបារាំងចាប់អាចារ្យ ហែម ចៀវ យកទៅដាក់គុកកោះត្រឡាចក៏កើតមានចលនាតស៊ូពាសពេញផ្ទៃប្រទេសគាត់បានលាចាកសិក្ខាបទ និងបានចូលរួមជាមួយនឹងចលនាតស៊ូខ្មែរឥស្សរៈដើម្បីរំដោះប្រទេស ពីពួកអាណានិគមនិយមបារាំងនឹងគេដែរ។ នៅក្នុងឆ្នាំ ១៩៤៧ គាត់បានរៀបការជាមួយក្រមុំឈ្មោះ ឌី ប៉ុក កើតនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩១៩ នៅភូមិដីដុះ ក្នុងឃុំ-ស្រុកជាមួយគ្នា។

ក្រោយមក គាត់មានការខកចិត្តយ៉ាងខ្លាំង ព្រោះមានពួកខ្មែរឥស្សរៈមួយក្រុម

របត់នយោបាយ
ផ្សេងទៀត បានចូលមកចាប់ម្តាយក្មេកគាត់យកទៅជំរិតទារប្រាក់ជាច្រើន។ ដើម្បីជួយជីវិតម្តាយក្មេកគាត់ និងប្រពន្ធត្រូវបង្ខំចិត្តលក់ទ្រព្យសម្បត្តិមានតម្លៃទាំងអស់របស់ខ្លួនដើម្បីយកប្រាក់ទៅលោះម្តាយក្មេកយកមកវិញ។ ដោយសារតែមានចលនាឥស្សរៈមួយចំនួនបន្លំធ្វើសកម្មភាព ចាប់ជំរិត លួចប្លន់ មាស ប្រាក់ ទ្រព្យសម្បត្តិប្រជារាស្ត្រដូច្នេះហើយទើបសម័យនោះមានពាក្យគន្លាស់មួយ អ្នកស្រុកតែងនិយាយថា ឥស្សរ៉ាចៈ ពាក្យគន្លាស់ប្រែត្រឡប់មកវិញថា ឥស្សរៈចោរ។

ក្រោយពីក្រុមគ្រួសាររងគ្រោះដោយសារការចាប់ជំរិតនោះ គាត់មានការឈឺចាប់ និងបានស្ម័គ្រចិត្តចូលធ្វើជាកងជីវពល និងបាននាំពួកទាហានខ្មែរទៅវាយកម្ទេចពួកឥស្សរ៉ាចៈ(ឥស្សរៈចោរ) នោះវិញផងដែរ។ នៅពេលប្រទេសកម្ពុជា ទទួលបានឯករាជ្យនាឆ្នាំ១៩៥៣ ហ៊ុន នាង ត្រូវបានតែងតាំងជាប្រធានកងជីវពលឃុំពាមកោះស្នា។

ពួកគាត់មានកូន៦នាក់៖ ទី១-ឈ្មោះ ហ៊ុន ឡុងសាន ហៅ ហ៊ុន សាន (ប្រុស) កើតនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៤៨ នៅភូមិពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់។ បានរៀបការជាមួយក្រមុំឈ្មោះ ច្រឹង គឹមហេន នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧២ និងមានកូនចំនួន៥នាក់ (ប្រុស២, ស្រី៣)។ ទី២-ឈ្មោះ ហ៊ុន ឡុងសេង ហៅ ហ៊ុន ណេង (ប្រុស) កើតនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៥០ នៅភូមិពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងក្រមុំឈ្មោះ លាង វួចឆេង នៅឆ្នាំ១៩៧១ និងមានកូនចំនួន៦នាក់ (ប្រុស៣ ស្រី៣)។ ទី៣-ឈ្មោះ ហ៊ុន ប៊ុនណាល់ ហៅ ហ៊ុន សែន (ប្រុស) ,៤-ឈ្មោះ ហ៊ុន សេងនី (ស្រី), ទី៥-ឈ្មោះ ហ៊ុន ស៊ីណាត (ស្រី) និងទី៦-ឈ្មោះ ហ៊ុន ប៊ុនធឿន (ស្រី)។

ហ៊ុន ប៊ុនណាល់ កើតនៅយប់ថ្ងៃអង្គារ ពេលព្រះចន្ទពេញបូណ៌មី ខែស្រាពណ៍ ឆ្នាំរោង ចត្វាស័ក ព.ស ២៤៩៦ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៥២ ក្រោមដំបូលផ្ទះសង់ពីឈើ៣ខ្នងជាលំនៅឋានដ៏សែនសុខសាន្តមួយ នៅភូមិពាមក្រៅ ឃុំពាមកោះស្នា

របត់នយោបាយ



សាស្រ្តាចារ្យវិទ្យាល័យឥន្ទ្រទេវី ឆ្នាំ១៩៦៦

ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ យាយខាងម្ដាយ គាត់តែងតែធ្វើជាឆ្មបរាល់ការសម្រាលកូន ទាំងអស់នៅក្នុងគ្រួសារ។ ពេលកើតមកដំបូង ដោយសារប្រុសទី៣នេះ មានសម្បុរស ហើយថ្ពោសមានសាច់ទ្រលុកទ្រលន់ឡើងកាណាល់ៗ ធ្វើឱ្យអ្នកភូមិនាំគ្នាខ្នាញ់ ស្រឡាញ់ចង់តែប្រលែងលេងនោះ ហើយក៏ចង់ដាក់ឈ្មោះកូន មានសំនៀងដូន ជាមួយនឹងឈ្មោះគាត់ (នាង) ផងដែរ ឪពុកក៏បានសម្រេចដាក់ឈ្មោះកូនទី៣ថា ណាល់ គឺ ហ៊ុន ប៊ុនណាល់។ បើតាមជំនឿរបស់ ជនជាតិខ្មែរតាំងពីបុរាណមក ក្មេងដែលកើតមកចំឆ្នាំរោង ពិសេសថ្ងៃអង្គារដូច្នេះ គេចាត់ទុកជាក្មេងមានះរឹងរូសខ្លាំងណាស់។ តែផ្ទុយទៅវិញ ប៊ុនណាល់ ជាក្មេងស្លូតបូត ឈ្លាសវៃ និងចូលចិត្តការសិក្សារៀនសូត្រ តែរាងក្រមិចក្រមើមបន្តិច។

សិក្សា១៩៥៩-៦០ កុមារ ហ៊ុន ប៊ុនណាល់ បានចូលរៀនថ្នាក់ទី១២ (ស្មើថ្នាក់ទី១បច្ចុប្បន្ន) នៅសាលាបឋមសិក្សាពាមកោះស្នា រហូតដល់ថ្នាក់ទី៧ (ស្មើថ្នាក់ទី៦បច្ចុប្បន្ន)។ ក្រោយបញ្ចប់ការសិក្សានៅសាលាបឋមសិក្សាពាមកោះស្នា ក្នុងឆ្នាំសិក្សា១៩៦៤-៦៥។ ទន្ទឹមនឹងជីវភាពគ្រួសារកាន់តែជួបការលំបាក នៅរដូវវស្សាឆ្នាំ១៩៦៥ ទឹកទន្លេមេគង្គឡើងធំ ជន់លិចផលដំណាំគ្រួសារ ដែលជិតបានទទួលផលទៅហើយនោះ ឪពុកគាត់បានសម្រេចចិត្តនាំកូនច្បងទាំង២នាក់ គឺ ហ៊ុន សាន និងហ៊ុន ណេង ទៅធ្វើស្រែប្រាំង នៅភូមិទួលសំបួរ ក្រែងបានស្រូវមកចិញ្ចឹមកូនបន្តទៀត ដោយទុកប្រពន្ធឱ្យនៅផ្ទះមើលថែកូនស្រីតូចៗ និងដាំដំណាំបន្តិចបន្តួច។ តែម្ដាយគាត់ប្រកែក

របត់នយោបាយ

ថា បើទៅណាត្រូវតែទៅទាំងអស់គ្នា។ តែទោះ បីជីវភាពគ្រួសារកាន់តែជួបការលំបាកយ៉ាងណាក៏ដោយ ក៏ម្ដាយឪពុកគាត់ត្រូវតែបញ្ជូន ប៊ុនណាល់ ឱ្យទៅបន្តការសិក្សានៅទីក្រុងភ្នំពេញ តាមបំណប្រាថ្នារបស់គេដែរ។

ក្នុងត្រីមាសទី៣ ឆ្នាំ១៩៦៥ នោះដែរ ក្នុងវ័យជំទង់ ហ៊ុន ប៊ុនណាល់ ត្រូវឃ្លាតចេញពីឪពុកម្ដាយបងប្អូន និងផ្ទះសម្បែងដោយក្ដីអាឡោះអាល័យបំផុត។ គេបានធ្វើដំណើរតាមកប៉ាល់ពីកំពង់ចាម ដោយមានអង្ករ១កញ្ចប់តូច និងប្រាក់១២រៀល (ស្មើនឹង៣៤សេនដុល្លារអាមេរិកកាលសម័យនោះ) និងសម្លៀកបំពាក់តែមួយចង្កេះនៅជាប់នឹងខ្លួនប៉ុណ្ណោះ។ រហូតដល់ម៉ោង៣ទៀបភ្លឺ កប៉ាល់ក៏បានចូលចតនៅកំពង់ផែភ្នំពេញ អ្នកដំណើរទាំងអស់នាំគ្នាឡើងគោក។

ដោយសារពូជាអ្នកជាក់ស៊ីក្លូទារថ្លៃ៣រៀល ប៊ុនណាល់ ក៏សម្រេចចិត្តធ្វើដំណើរដោយថ្មើរជើង និងដើរបណ្ដើរសួរគេបណ្ដើរដើម្បីរកផ្លូវទៅវត្តនាគវ័ន ក្នុងសង្កាត់លេខ២។

គាត់បានស្នាក់នៅកុដិជាមួយនឹងព្រះសង្ឃព្រះនាម គីម ប្រែង និងបានដាក់ពាក្យចូលរៀនថ្នាក់ទី៦ទំនើប (ស្មើនឹងថ្នាក់ទី៧ សម័យបច្ចុប្បន្ន) នៅវិទ្យាល័យឥន្ទ្រទេវី។ ដើម្បីបានចូលសិក្សាដំបូងនៅវិទ្យាល័យឥន្ទ្រទេវីនោះ សិស្សគ្រប់គ្នាត្រូវបង់ប្រាក់ចំនួន១,៨០០រៀល គឺជាទឹកប្រាក់ច្រើនណាស់ សម្រាប់សិស្សជាកូនអ្នកក្រ។ ចាប់ពីពេលនោះមក គាត់ក៏បានដូរឈ្មោះ ហ៊ុន ប៊ុនណាល់ មកជា ហ៊ុន សែន វិញ។

អំឡុងពេលស្នាក់នៅរៀនសូត្រក្នុងវត្តនោះ ហ៊ុន សែន និងក្មេងវត្តដទៃទៀតត្រូវក្រោកពីដំណេកនៅម៉ោង៤ទៀបភ្លឺ រៀបចំដាំបបរប្រគេនព្រះសង្ឃ ដោយដាំបបរបណ្ដើរ អានមេរៀនបណ្ដើរ និងជួយបោសសម្អាតស្លឹកឈើក្នុងទីធ្លាវត្ត ដែលមានដើមឈើធំៗ២ដើមឱ្យស្អាត និងធ្វើការងារផ្សេងៗទៀត មុននឹងចេញទៅសិក្សា។ ពេលណាព្រះសង្ឃចេញមកឃើញមានសំរាមស្លឹកឈើតែបន្តិច គាត់នឹងទទួលទណ្ឌកម្មជាមិនខាន។ បើថ្ងៃណាសាលាត្រូវឈប់សម្រាកមិនជាបញ្ហាប៉ុន្មានទេ តែបើប៉ះចំថ្ងៃត្រូវសិក្សាគាត់ត្រូវសូមអនុញ្ញាតពីគ្រូចេញមុនម៉ោង ដើម្បីដើរយួរចានស្រាក់តាមក្រោយព្រះសង្ឃ

ចេញទៅបិណ្ឌបាតចង្ហាន់តាមផ្ទះអ្នកស្រុក។ ពេលព្រះសង្ឃឆាន់រួច ទើបពួកគាត់ជាក្មេងវត្ត មានសិទ្ធិចូលទៅទទួលទានម្ហូបអាហារដែលនៅសេសសល់។ តែព្រះសង្ឃខ្លះឆាន់បណ្ដើរ នាំគ្នាជជែកលេងសើចបណ្ដើរ ប្រើពេលយូរ មិនខ្វល់ពីក្រពះពួកគាត់ជាក្មេងវត្តកំពុងកូរពោះស្រេកឃ្លាននោះទេ។ ពេលខ្លះទម្រាំពួកគាត់ទទួលទានបាយរួច ចង់ហួសម៉ោងទៅរៀន ក៏មានដែរ។ នៅពេលល្ងាច ពួកគាត់ត្រូវទៅរែកទឹកនៅឯផ្លូវកម្ពុជាក្រោមឯណោះ មកដាក់ពាងនៅក្នុងវត្ត រហូតដល់ម៉ោង៧យប់ទើបពេញពាង ហើយត្រូវនាំគ្នាសូត្រធម៌បន្តទៀត មិនសូវមានពេលរៀនសូត្រប៉ុន្មានទេ។

តែបើសល់ពេលទំនេរខ្លះពីការងារក្នុងវត្ត និងការរៀនសូត្រ យុវជន ហ៊ុន សែន តែងតែឆ្លៀតតែងនិពន្ធ សរសេរកំណាព្យ ពិសេសរៀនលេងអុកចត្រង្គ។ គាត់ចូលចិត្តល្បែងមួយនេះខ្លាំងណាស់ ព្រោះគិតថា វាអាចជួយបង្កើនប្រាជ្ញាដើម្បីដោះស្រាយបញ្ហា ឬឧបសគ្គផ្សេងៗបាន។ គាត់មិនចូលចិត្តសេពគប់ជាមួយ ពួកកូនអ្នកមាន កូនអ្នកធំ ដែលជាមនុស្សប្រទ្បើសបើសព្រហើនកោងកាច អសីលធម៌ និងគេចវេះសាលានោះឡើយ ។



**វត្តនាគវ័ន ពេលបុណ្យបញ្ចុះខណ្ឌសីមា ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៦៨**

របត់នយោបាយ

ក្នុងឆ្នាំ១៩៦៩ មានព្រឹត្តិការណ៍គួរឱ្យភ័យខ្លាចមួយបានកើតឡើងនៅក្នុងជម្រកដ៏សុខសាន្តរបស់យុវជនជាក្មេងវត្តនាគវ៉ន។ ថ្ងៃមួយ ស្ងាត់ៗ ស្រាប់តែមានប៉ូលិសប្រដាប់អាវុធមួយក្រុម បានសម្រុកចូលមកចាប់មនុស្សមួយចំនួនចងស្លាបសេក ដោយចោទថា ជាពួកខ្មែរក្រហមប្រឆាំងនឹងរាជរដ្ឋាភិបាល។ ក្នុងចំណោមនោះ មានយុវជនម្នាក់ឈ្មោះ នីវ គាន ជាបងជីដូនមួយរបស់គាត់ផងដែរ។

ដោយមានការភិតភ័យខ្លាំងពេកយុវជន ហ៊ុន សែន ដែលពេលនោះមានវ័យ ១៧ឆ្នាំរូបរាងខ្ពស់សង្ហាក៏បង្ខំចិត្តបោះបង់ចោលការសិក្សានៅវិទ្យាល័យឥន្ទ្រទេវី ហើយក៏បានចាកចេញពីវត្តនាគវ៉ន នាទីក្រុងភ្នំពេញ ធ្វើដំណើរទៅរស់នៅជួបជុំជាមួយម្តាយឪពុកបងប្អូន សំងំប្រកបរបរធ្វើស្រែចម្ការជាធម្មតាវិញ។

# ៧.៨. ហ៊ុន សែន និងប៊ុន រ៉ានី ចូលព្រៃម៉ាគី ព្រោះសម្តេចឪ



**ហ៊ុន សែន និងមេបញ្ជាការគាត់**

លុះមកដល់ខែមករា ឆ្នាំ១៩៧០ បងជីដូនមួយរបស់គាត់ឈ្មោះ នីវ គាន ក៏ត្រូវបានដោះលែងមកវិញ បន្ទាប់ពីសួរចម្លើយទៅដឹងច្បាស់ថា គេមិនមានជាប់ពាក់ព័ន្ធនឹងចលនាតស៊ូណាមួយដែលប្រឆាំងនឹងរាជរដ្ឋាភិបាលទេ។ ក្រោយពីទទួលដំណឹងល្អនេះ យុវជន ហ៊ុន សែន ក៏មានបំណងវិលត្រឡប់មកបន្តការសិក្សានៅវិទ្យាល័យឥន្ទ្រទេវី វិញដែរ តែជ្រុលពេលទៅហើយ ព្រោះនៅថ្ងៃពុធ ទី១៨ ខែមីនា ឆ្នាំដដែលនោះ ឧត្តមសេនីយ៍ លន់ នល់ និងទ្រង់ សិរិមតៈ ដឹកនាំធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ

របត់នយោបាយ

ចេញពីអំណាច បណ្តាលឱ្យប្រទេសជាតិកើតវឹកវរចលាចល ពិសេសប្រជារាស្ត្រនៅខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង និងតាកែវ នាំគ្នាហែក្បួនបាតុកម្មក្នុងបំណងចូលមកទីក្រុងភ្នំពេញ ដើម្បីទាមទារឱ្យយកសម្តេចឪ មកដឹកនាំប្រទេសវិញ។ តែត្រូវឧត្តមសេនីយ៍ លន់ នល់ និងទ្រង់ សិរិមតៈ បញ្ជាឱ្យពួកទាហានបង្ក្រាបបាញ់សម្លាប់គ្មានត្រាប្រណី ហើយភ្លើងសង្គ្រាមក៏ចាប់ផ្តើមឆាបឆេះចាប់ពីពេលនោះមកដែរ។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ដោយមានមេដឹកនាំវៀតណាមខាងជើង និងចិនប្រជាមានិតជួយជ្រោមជ្រែងផង នៅទីក្រុងប៉េកាំង សម្តេចសីហនុ បានសហការជាមួយពួកមេដឹកនាំខ្មែរក្រហម បង្កើតរណសិរ្សតស៊ូមួយឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា និងបានប្រកាសអំពាវនាវឱ្យប្រជារាស្ត្រខ្មែរទាំងស្រីប្រុសក្មេងចាស់ឈប់បះបោរធ្វើបាតុកម្មប្រឆាំងនឹងពួកក្បត់ លន់ នល់ និងសិរិមតៈ តទៅទៀត ព្រោះមិនបានទទួលផលអ្វីក្រៅតែពួកគេបាញ់សម្លាប់តែប៉ុណ្ណោះ ដូច្នេះត្រូវនាំគ្នារត់ចូលព្រៃម៉ាគី កាន់អាវុធធ្វើសង្គ្រាម តស៊ូវិញ ទើបអាចផ្តួលរម្លំរបបក្បត់ លន់ នល់ និងសិរិមតៈ ដោយជោគជ័យ។ ចំណែកឧត្តមសេនីយ៍ លន់ នល់ ក៏បានប្រកាសអំពាវនាវប្រជារាស្ត្រ ពិសេសពួកយុវជនឱ្យចូលបម្រើក្នុងជួរកងទ័ព ដើម្បីវាយបណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើង ឱ្យចេញពីទឹកដីខ្មែរវិញដែរ។

ក្រោយពីបានពិចារណាយ៉ាងល្អិតល្អន់មកយុវជន ហ៊ុន សែន សម្រេចចិត្តចូលព្រៃម៉ាគី តាមការអំពាវនាវរបស់សម្តេចសីហនុ ដែលប្រជារាស្ត្រខ្មែរភាគច្រើនលើសលប់ស្រឡាញ់គាំទ្រ និងដង្ហែតាម។ ឪពុកគាត់ក៏យល់ព្រម ព្រោះការសម្រេចចិត្តនេះ ក៏ស្របនឹងបំណងប្រាថ្នារបស់លោកដែរ ហើយមុននេះប្រហែលមួយសប្តាហ៍ ឪពុករបស់គាត់ក៏បានលួចបង្ហាត់បង្រៀនបងប្រុសគាត់ទាំង២នាក់ គឺ ហ៊ុន សាន និងហ៊ុន ណេងឱ្យចេះពីរបៀបតស៊ូរស់នៅនៅក្នុងព្រៃផងដែរ។

នៅថ្ងៃអង្គារ ទី៤ ខែមេសា ឆ្នាំ១៩៧០ មានយុវជនយុវនារីប្រមាណជាង៣០០នាក់ក្នុងនោះក៏មានយុវជន ហ៊ុន សែន ម្នាក់ដែរ បានស្ម័គ្រចិត្តនាំគ្នាចូលព្រៃម៉ាគី ជាមួល

របត់នយោបាយ

ដ្ឋានចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា ស្ថិតនៅស្រុកមេមត់ ដើម្បីរួមចំណែករំដោះប្រទេសជាតិ តាមការអំពាវនាវរបស់សម្តេចសីហនុ ដោយគ្មានរួញរា។ ក្រោយមកប្អូនស្រីរបស់គាត់២នាក់ទៀត ក៏បានសម្រេចចិត្តចូលព្រៃម៉ាគី ដើម្បីរួមចំណែកតស៊ូរំដោះប្រទេសជាតិដែរ។

នៅពេលចុះឈ្មោះចូលបម្រើជាយោធាតំបន់២១ ក្នុងភូមិភាគបូព៌ា ដំបូង ហ៊ុន សែន បានដូរឈ្មោះមកជា ហ៊ុន សម្រេច និងបានដូរកាលបរិច្ឆេទថ្ងៃកំណើតរបស់គាត់ពីថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៥២ មកជាថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៥២ វិញ ក្នុងគោលបំណងលាក់អត្តសញ្ញាណដើមនេះ ព្រោះមិនទាន់ដឹងច្បាស់ថា សភាពការណ៍នយោបាយអាចផ្លាស់ប្តូរប្រែប្រួលទៅជាយ៉ាងណាទៀតនោះទេ?។ មូលហេតុដែលធ្វើឱ្យគាត់ដូរឈ្មោះពី ហ៊ុន សែន មកជាឈ្មោះជា ហ៊ុន សម្រេច នេះ គឺដោយសារគាត់ប៉ងប្រាថ្នាថា ក្រោយពីពេលចូលបម្រើជាយោធានោះមក គាត់ធ្វើអ្វីៗនឹងបានសម្រេចជោគជ័យដូចបំណងជាមិនខាន។

បន្ទាប់ពីទទួលការហ្វឹកហ្វឺនកងទ័ពបាន២សប្តាហ៍ ដោយសារការឈ្លាសវៃ និងអង់អាចក្លាហាន និងមានកម្រិតវប្បធម៌ខ្ពស់គួរសមដែរ ហ៊ុន សម្រេច ត្រូវបានចាត់តាំងឱ្យធ្វើជាមេបញ្ជាការកងអនុសេនាតូច មានយុទ្ធជន៣៦នាក់ ក្នុងនោះភាគច្រើនជាជនជាតិភាគតិចស្ទៀងមិនចេះអក្សរ ឬចេះតិចតួចប៉ុណ្ណោះ។ ពេលនោះដែរ គាត់ក៏ឆ្លៀតឱកាសបង្រៀនអក្សរខ្មែរ និងលេខដល់យុទ្ធជននៅក្នុងកងអនុសេនាតូចរបស់គាត់ និងយុទ្ធជននៅក្នុងកងផ្សេងទៀតដែលបោះជំរំនៅជិតគ្នានោះផងដែរ។ ហេតុដូច្នេះហើយទើបយុទ្ធជនមួយចំនួនតែងតែហៅគាត់ថា លោកគ្រូៗ។

ក្រោយពីត្រូវបានចាត់តាំង ជាប្រធានកងអនុសេនាតូច បានតែពីរថ្ងៃប៉ុណ្ណោះ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧០ កងអនុសេនាតូចរបស់ ហ៊ុន សម្រេច បានទទួលបញ្ជាឱ្យចូលរួមសហការជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ទៅវាយដណ្តើមយកទីរួមស្រុកស្នួល (ខេត្តក្រចេះ) ពីការគ្រប់គ្រងរបស់ លន់ នល់ មេដឹកនាំរដ្ឋប្រហារ។

របត់នយោបាយ

ព្រឹកថ្ងៃទី២២ ខែមេសា កងអនុសេនាតូចរបស់គាត់ និងកងទ័ពវៀតកុង-វៀតណាមខាងជើង បានឡោមព័ទ្ធទាហាន លន់ នល់ និងស្រែកបញ្ចុះបញ្ចូលតាមឧគ្ឃោសនសព្ទឱ្យពួកគេដាក់អាវុធចុះ និងព្រមចុះចូល ដោយគ្មានការវាយប្រយុទ្ធគ្នាអ្វីធំដុំឡើយ។






**រថក្រោះអាមេរិក ចូលកម្ទេចទីរួមស្រុកស្នួល ខេត្តក្រចេះ**

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧០ កម្លាំងចម្រុះរបស់កងទ័ពសហរដ្ឋអាមេរិក និងកងទ័ពនៃសាធារណរដ្ឋវៀតណាមខាងត្បូង បានសហការគ្នាបើកប្រតិបត្តិការសឹកមួយចូលមកវាយប្រហារកងទ័ពវៀតកុង-វៀតណាមខាងជើង និងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា នៅក្នុងស្រុកមេមត់ខេត្តកំពង់ចាម និងស្រុកស្នួល ខេត្តក្រចេះ។

នៅសមរភូមិស្រុកស្នួល ដោយសារកងអនុសេនាតូចរបស់ ហ៊ុន សម្រេច ជាកងទ័ពថ្មី និងមានគ្នាតិចផងនោះ ត្រូវទាហានអាមេរិក ដែលមានទ្រង់ទ្រាយធំ រួមមានរថក្រោះ និងយន្តហោះផង វាយឱ្យរត់ខ្ចាត់ខ្ចាយ ខ្លះត្រូវស្លាប់ ខ្លះរត់ទៅផ្ទះសម្បែងវិញ។ កងអនុសេនាតូចរបស់គាត់ ដែលពីដំបូងមានគ្នាចំនួន៤៨នាក់ ក្រោយពីបរាជ័យក្នុងការប្រយុទ្ធជាមួយកងទ័ពអាមេរិកនោះមក នៅតែចំនួន១៦នាក់ប៉ុណ្ណោះ ក៏ត្រូវរំលាយ និងបញ្ចូលជាអង្គភាពថ្មីមួយទៀត។

បន្ទាប់មក ហ៊ុន សម្រេច ត្រូវថ្នាក់លើបញ្ជូនឱ្យទៅហ្វឹកហ្វឺននៅសាលាកងទ័ពពិសេសមួយ ក្នុងព្រៃជ្រៅ។ ក្រោយពីហ្វឹកហ្វឺនរៀនសូត្រអស់រយៈពេលមួយឆ្នាំមក

របត់នយោបាយ
គាត់ត្រូវបានចាត់តាំងជាមេបញ្ជាការកងអនុសេនាធំ ដែលមានយុទ្ធជន១៣០នាក់។

ហ៊ុន សែន បានរម្លឹកថា៖ កាលជំនាន់ទៅហ្វឹកហ្វឺននៅសាលាកងទ័ពពិសេសក្នុងព្រៃជ្រៅនោះ ពួកគាត់ជាកម្មាភិបាលយោធាមានគ្នាទាំងអស់ចំនួន៧៨នាក់ កាលជំនាន់នោះ។ រហូតមកដល់ឆ្នាំ១៩៧៩ ក្នុងចំណោមមិត្តរួមជំនាន់ជាមួយគាត់ទាំង៧៨នាក់នោះ នៅសល់តែគាត់ម្នាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតជាមួយនឹងពិការភាពផងដែរ។

ក្នុងនាមជាមេបញ្ជាការយោធាម្នាក់ ហ៊ុន សម្រេច បានណែនាំបង្ហាត់បង្រៀនយុទ្ធជនឱ្យចេះក្បួនយុទ្ធសាស្ត្រ ឱ្យចេះមើលផែនទី ចេះប្រើត្រីវិស័យ និងកែវយឺត។ ដោយសារមានសមត្ថភាពខាងជំនាញចារកម្ម និងដឹកនាំយុទ្ធជនវាយប្រយុទ្ធនៅក្នុងសមរភូមិទទួលបានជោគជ័យជាបន្តបន្ទាប់នោះ។ នៅឆ្នាំ១៩៧៤ គាត់ត្រូវបានថ្នាក់លើដំឡើងតួនាទីទៅជាមេបញ្ជាការកងវរសេនាតូច ដែលមានយុទ្ធជនចំនួន៥០០នាក់ ហើយគាត់ក៏បានដូរឈ្មោះពី ហ៊ុន សម្រេច មកជាឈ្មោះ ហ៊ុន សែន ដូចកាលនៅរៀនវិទ្យាល័យឥន្ទ្រទេវី វិញដែរ។

ហ៊ុន សែន បានរម្លឹកថា៖ ការពិតគាត់ស្អប់ខ្មែរក្រហម តាំងតែពីសម្តេចសីហនុនៅកាន់អំណាចម្ល៉េះ។ តែគាត់ចូលរួមចលនាតស៊ូនៅព្រៃម៉ាគី ដោយសារ៖ មូលហេតុទី១. អាមេរិក បានបញ្ជូនកងទ័ពចូលទឹកដីកម្ពុជា? វាជាការឈ្លានពានរបស់ប្រទេសក្រៅមួយចូលក្នុងប្រទេសកំពុងមានសន្តិភាព។ មូលហេតុទី២. សេចក្តីអំពាវនាវរបស់សម្តេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។ យុវវ័យភាគច្រើនបាននាំគ្នាសម្រុកទៅចូលរួមចលនាតស៊ូនៅព្រៃម៉ាគី ដើម្បីឱ្យសម្តេចសីហនុយាងមកកាន់អំណាចវិញ។ តែពួកគាត់បានចូលក្នុងសំណាញ់ខ្មែរក្រហមដោយមិនដឹងខ្លួន។ នៅក្នុងឆ្នាំ១៩៧៤ នោះទើបគាត់ដឹងច្បាស់ថា សម្តេចសីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាពិតមែនតែពួកមេខ្មែរក្រហមជាអ្នកដឹកនាំចាត់ចែងអ្វីៗទាំងអស់។



**កងទ័ពវៀតណាមខាងត្បូង ដកថយពីផ្លូវជាតិលេខ៧៣ ភូមិកំពង់រាំង ស្រុកតំបែរ**

ហ៊ុន សែន រម្លឹកបន្តថា៖ ពេលធ្វើសង្គ្រាមនោះ នៅទីក្រុងភ្នំពេញ គាត់មានញាតិសន្តានម្នាក់ឈ្មោះ នូ ថូ មានឋានន្តរសក្តិជាឧត្តមសេនីយ៍ទោ (ផ្កាយពីរ)បានព្យាយាមឱ្យគ្នាគេ មកលួចទាក់ទងគាត់ ឱ្យនាំយុទ្ធជនទាំងអស់របស់គាត់ ទៅចុះចូលជាមួយរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ ជាថ្នូរនឹងការផ្តល់ឋានន្តរសក្តិជាវរសេនីយឯក ទៀតផង តែគាត់បដិសេធ។

ប៊ុន រ៉ានី កើតនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៥៤ នៅភូមិរកាខ្នុរ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម នៅក្នុងគ្រួសារកសិករមួយមានឪពុកឈ្មោះ លីន គ្រី និងម្តាយឈ្មោះ ប៊ុន ស៊ាងលី ព្រមទាំងមានបងប្អូនបង្កើតចំនួន៥នាក់។ គ្រួសារកសិករខ្មែរកាត់ចិនមួយនេះ រស់នៅដោយសុខដុមដោយសារភោគផលបានមកពីដីស្រែចម្ការសម្បូរជីជាតិ។

ក្រោយពីមានព្រឹត្តិការណ៍រដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនាឆ្នាំ១៩៧០ ក្នុងវ័យ១៦ឆ្នាំ ប៊ុន រ៉ានី បានសម្រេចចិត្តបោះបង់ការសិក្សាត្រឹមថ្នាក់មធ្យមសិក្សា ស្ម័គ្រចិត្តចូលព្រៃម៉ាគីដើម្បីរួមចំណែកតស៊ូរំដោះ ប្រទេសជាតិ ពីរបបរបស់ លន់ នល់ ដោយមិនឱ្យម្តាយឪពុកក្រុមគ្រួសារដឹងឡើយ ព្រោះខ្លាចម្តាយឪពុកឃាត់ឃាំងរារាំងបំណងមួយនេះ ហើយ

របត់នយោបាយ
ក៏ស្របពេលដែលយុវជន ហ៊ុន សែន មានវ័យ១៨ឆ្នាំ មិនដែលស្គាល់គ្នាសោះ សម្រេចចិត្តចូលព្រៃម៉ាគី តាមការអំពាវនាវរបស់សម្ដេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ពីក្រុងប៉េកាំង ប្រទេសចិន នោះដែរ។

ពេលនោះ មានយុវជនយុវនារី និងបុរសវ័យកណ្ដាលច្រើនណាស់មកពីឃុំកោឌ្ឋរ សម្រេចចិត្តចូលព្រៃម៉ាគីផងដែរ។ តែក្នុងចំណោមនោះ មានតែយុវនារី ប៊ុន រ៉ានី និងយុវនារី ជាមិត្តភក្តិម្នាក់ទៀត មកពីភូមិជាមួយគ្នា ដែលមិនប្រាប់ឪពុកម្ដាយឱ្យបានដឹងថាពួកគាត់សម្រេចចិត្តចូលព្រៃម៉ាគី តាមការអំពាវនាវរបស់សម្ដេចសីហនុ ហើយ។

មួយថ្ងៃបន្ទាប់មកទៀត ទើបឪពុកម្ដាយ ប៊ុន រ៉ានី បានដឹងដំណឹងនេះ ក៏នាំគ្នាតាមរកនាង តែពួកគាត់ មិនអាចទៅដល់កន្លែងដែលនាងកំពុងប្រមូលផ្ដុំគ្នានោះទេ ពីព្រោះទីតាំងនោះឋិតនៅក្នុងព្រៃជ្រៅ។

ដំបូង ប៊ុន រ៉ានី ក៏ដូចអ្នកស្ម័គ្រចិត្តតស៊ូក្នុងព្រៃម៉ាគីផ្សេងៗទៀតដែរ បានទទួលការស្វាគមន៍ ពីសំណាក់កម្មាភិបាលជាតំណាងរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំតំបន់ និងត្រូវបានសាកសួរពីគោលបំណងចង់រៀនសូត្រហ្វឹកហ្វឺន មុខជំនាញណាមួយដើម្បីបំពេញភារកិច្ចរួមចំណែកតស៊ូរំដោះប្រទេសជាតិ?

ពេលនោះ ប៊ុន រ៉ានី បានជ្រើសយកការហ្វឹកហ្វឺនរៀនសូត្រមុខជំនាញខាងសុខាភិបាល។ វេជ្ជបណ្ឌិតមួយចំនួនដែលបានរត់ចេញពីក្រុងភ្នំពេញ ទៅចូលព្រៃម៉ាគីដែរនោះ បានបង្ហាត់បង្រៀនពួកនារីៗ ជាសិក្ខាកាមទាំងអស់ពីទ្រឹស្ដីវិជ្ជាពេទ្យ និងការអនុវត្តជាក់ស្ដែងពីរបៀបចាក់ថ្នាំ ពីរបៀបផ្សំថ្នាំ ការព្យាបាល ការថែទាំអ្នកជំងឺ អ្នករបួស... ជាដើម។ ជាមួយគ្នានោះ នាងក៏ទទួលបានការបង្ហាត់បង្រៀនធ្វើជាឆ្មបទៀតផង។

ក្រោយពីទទួលការបណ្ដុះបណ្ដាលហ្វឹកហ្វឺនអស់ប្រាំមួយខែ ប៊ុន រ៉ានី និងមិត្តភក្តិរួមវគ្គសិក្សាទាំងអស់បានក្លាយជាបុគ្គលិកពេទ្យ គ្រប់ៗគ្នា។

នាងត្រូវបានគេបញ្ជូនឱ្យត្រឡប់ទៅបម្រើការងារជាបុគ្គលិកពេទ្យ នៅមន្ទីរពេទ្យមួយ ដែលនៅក្បែរមាត់ទន្លេមេគង្គ ក្នុងស្រុកក្រូចឆ្មារ ជាស្រុកកំណើតរបស់នាង។

របត់នយោបាយ

គ្រាដំបូងកម្មាភិបាល ជាអ្នកគ្រប់គ្រងមន្ទីរពេទ្យនោះ យកចិត្តទុកដាក់ចំពោះនាងណាស់ ហើយតែងតែហៅនាងថា៖ “ កូនស្រីៗ ” ។

មិនយូរប៉ុន្មាន នៅក្នុងតំបន់រំដោះ ស្ត្រីៗទាំងអស់ ដែលទុកសក់វែងមិនថា ក្មេង ឬចាស់នោះទេ អង្គការជាមេដឹកនាំចលនាតស៊ូតម្រូវឱ្យកាត់សក់ខ្លីនៅត្រឹមកញ្ចឹងក គ្រប់ៗគ្នា ហើយទាំងយោធា បុគ្គលិកគ្រប់ក្រសួងមន្ទីរ កម្មាភិបាលគ្រប់ជាន់ថ្នាក់ គ្មានអ្នកណាម្នាក់ទទួលបានប្រាក់បៀវត្សនោះទេ។ ពិសេស សូម្បីតែសុំច្បាប់ មកសួរសុខទុក្ខម្តាយឪពុកពីរបីថ្ងៃ ក៏មិនអនុញ្ញាតឱ្យដែរ។

ក្រោយពីបំពេញតួនាទីជាបុគ្គលិកពេទ្យ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានសីលធម៌ល្អ អស់រយៈពេល៤ឆ្នាំមក ប៊ុន រ៉ានី ត្រូវបានចាត់តាំងជាប្រធានមន្ទីរពេទ្យនៅស្រុកក្រូចឆ្មារ នោះ។

មន្ទីរពេទ្យនេះទទួលព្យាបាលយុទ្ធជនរងរបួសរាប់រយនាក់ ដែលបញ្ជូនមកពីសមរភូមិមុខ។ ប៊ុន រ៉ានី មិនដែលគិតពីតួនាទី ជាប្រធានមន្ទីរពេទ្យ នោះទេ នាងបានចូលរួមជាមួយបុគ្គលិកគ្រប់ផ្នែក គ្រប់ជំនាញ ព្យាបាលយុទ្ធជន ដែលរងរបួសទាំងថ្ងៃទាំងយប់ដោយយកចិត្តទុកដាក់បំផុត និងគ្មានខ្លាចនឿយហត់ឡើយ ព្រោះពួកគេក្លាហាន ហ៊ានប្តូរជីវិតនៅក្នុងសមរភូមិ ហើយគាត់មានទឹកចិត្តស្រឡាញ់ ចូលចិត្តកងទ័ពតាំងពីគាត់នៅតូចមកផងដែរ។ ដើមឆ្នាំ១៩៧៤ ក្រោយពី ប៊ុន រ៉ានី ត្រូវបានចាត់តាំងជាប្រធានមន្ទីរពេទ្យហើយ ហ៊ុន សែន ជាមេបញ្ជាការកងវរសេនាតូចអង្គភាពពិសេស មកយុទ្ធជនរបស់ ហ៊ុន សែន មួយចំនួន ទៅសម្រាកព្យាបាលមុខរបួស នៅមន្ទីរពេទ្យដែលមាន ប៊ុន រ៉ានី ជាប្រធាននោះ ពួកគេចេះតែនិយាយចំអែចំអន់ផ្លូផ្លងថា សមមិត្តមេបញ្ជាការរបស់ពួកគេ ស័ក្តិសមគ្នា ជាមួយនឹងសមមិត្តនារី ប្រធានមន្ទីរពេទ្យនេះខ្លាំងណាស់ ហើយពួកគេបាននិយាយប្រតិដ្ឋប្រាប់ ប៊ុន រ៉ានី ថា ហ៊ុន សែន មេបញ្ជាការរបស់ពួកគេ សូមផ្ញើក្តីនឹករលឹករបស់គាត់ មកជូនសមមិត្តនារី ប្រធានមន្ទីរពេទ្យដ៏ស្រស់ស្អាតនេះផងដែរ។ លើសពីនេះទៅទៀត យុទ្ធជនរបស់ ហ៊ុន សែន មួយ

របត់នយោបាយ

ចំនួនបាននិយាយថា នៅពេលណាចប់សង្គ្រាមពួកគេចង់ឱ្យគាត់រៀបការជាមួយ ប៊ុន រ៉ានី ទៀតផង។ ចំណែកនារីៗ ជាបុគ្គលិកពេទ្យដែល ប៊ុន រ៉ានី ចាត់បញ្ជូនពីមន្ទីរពេទ្យ ឱ្យទៅព្យាបាលជំងឺ និងមុខរបួសស្រាលៗយុទ្ធជននៅសមរភូមិ ក្រោមបញ្ជាការ ហ៊ុន សែន ក៏ចេះតែនិយាយផ្លូផ្លុងថា មេបញ្ជាការ និងសមមិត្តនារីប្រធានមន្ទីរពេទ្យ ពិតជាសមគ្នាមែន ហើយអ្នកខ្លះនិយាយចេញតែពីមាត់ខ្លួនឯងប្រាប់ ហ៊ុន សែន ថា ប៊ុន រ៉ានី ផ្តាំឱ្យពួកគេសួរសុខទុក្ខគាត់ទៀតផង។ តែការពិត ហ៊ុន សែន ក៏ដូចជា ប៊ុន រ៉ានី ដែរ កុំថា ឡើយដល់ទៅមានមនោសញ្ចេតនាស្នេហានឹងគ្នា សូម្បីតែមុខ ក៏មិនដែលបានឃើញគ្នាម្តងណាឡើយ។ ហ៊ុន សែន គ្រាន់តែដឹងថា ប្រធានមន្ទីរពេទ្យនៅស្រុកក្រូចឆ្មារនោះឈ្មោះ ប៊ុន រ៉ានី ដែលល្បីថា មានរូបសម្ផស្សស្រស់ស្អាតសាច់សខ្ចី។

ហ៊ុន សែន ចេះតែឆ្ងល់ថា ចុះហេតុដូចម្តេចបានជាយុទ្ធជនរបស់គាត់នាំគ្នាប្រតិដ្ឋរឿងស្នេហារបស់គាត់ទាំង២នាក់បែបនេះទៅវិញ។ គាត់ជាមេបញ្ជាការដឹងច្បាស់ថា ការផ្លូផ្លុងរឿងស្នេហានេះ គឺខុសវិន័យអង្គការ និងសីលធម៌បដិវត្តន៍។ រឿងនេះធ្វើឱ្យគាត់មានការធុញថប់នៅក្នុងអារម្មណ៍ ចង់ដឹងថា តើរឿងនេះមកពីមូលហេតុអ្វី? គាត់ចង់ទៅជួបនារីឈ្មោះ ប៊ុន រ៉ានី នោះ ដើម្បីដោះស្រាយគ្នាធ្វើយ៉ាងណាកុំឱ្យមានបញ្ហាផ្លូផ្លុងនោះបន្តទៀត តែគាត់មិនទាន់មានពេលគ្រប់គ្រាន់។ ខណៈនោះដែរ ប្អូនស្រីបង្កើតម្នាក់របស់គាត់ ដែលជាយោធានៅក្នុងតំបន់រំដោះដែរនោះ បានហៅនារីម្នាក់នៅអង្គភាពជាមួយគ្នានោះថា សោៗ (បងថ្លៃស្រី)។តែគាត់មិនដែលស្គាល់នារីម្នាក់នោះទេ។

ហ៊ុន សែន ក៏បានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅ ប៊ុន រ៉ានី សុំជួបដើម្បីដោះស្រាយការយល់ច្រឡំកន្លងមក។

មុនថ្ងៃបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៤ នោះពីរបីថ្ងៃ ហ៊ុន សែន បានស្នើមេបញ្ជាការរបស់គាត់ ឱ្យជូនទៅជួប ប៊ុន រ៉ានី ជាប្រធានមន្ទីរពេទ្យនៅស្រុកក្រូចឆ្មារ ដើម្បីឱ្យមេបញ្ជាការរបស់គាត់ធ្វើជាសាក្សីផង និងដើម្បីងាយបានជួបគ្នាជាមួយ ប៊ុន រ៉ានី ផង។

របត់នយោបាយ

ពេលធ្វើដំណើរដល់មន្ទីរពេទ្យ ពួកគាត់ទាំងពីរនាក់រង់ចាំនៅមុខអគារមន្ទីរពេទ្យ។ ពេលនោះមេបញ្ជាការគាត់ ក៏ឆ្លៀតឱកាសចេញទៅរកជួបសួរសុខទុក្ខប្រធានភូមិមួយនៅក្បែរមន្ទីរពេទ្យនោះ ដែលធ្លាប់ស្គាល់គ្នាពីមុនមក ដោយទុកឱ្យ ហ៊ុន សែន នៅរង់ចាំនៅមុខអគារមន្ទីរពេទ្យ នោះតែម្នាក់ឯង។ ពេលនោះគាត់មិនដែលស្គាល់ ប៊ុន រ៉ានី ទេ ហើយ ប៊ុន រ៉ានី ក៏មិនដែលស្គាល់គាត់ដែរ។ តែ ហ៊ុន សែន គិតក្នុងចិត្តថា បើសិនជា រ៉ានី មានរូបស្អាត និងចរិយាសម្បត្តិល្អ ដូចគេតែងតែសរសើរមែននោះ គឺគាត់ស្រឡាញ់ ហើយស្នើសុំរៀបការតែម្តង។ គាត់បានចូលទៅក្នុងមន្ទីរពេទ្យ ហើយសួរនារីដ៏ស្រស់ស្អាតម្នាក់កំពុងតែរៀបចំគ្រឿងបរិក្ខារពេទ្យថា តើនារីឈ្មោះ រ៉ានី នៅកន្លែងណា? នារីដ៏ស្រស់ស្អាតម្នាក់នោះក៏មិនស្គាល់មេបញ្ជាការ ហ៊ុន សែន ជានរណាដែរ ឆ្លើយកុហកយ៉ាងសោះអង្គើយ និងមិនខ្វីទាំងមើលមុខផងថា រ៉ានី ចេញទៅដងទឹកបាត់ហើយ...។ បន្តិចក្រោយមកទើបគាត់ដឹងថា នារីដ៏ស្រស់ស្អាតដែលគាត់សួររក រ៉ានី នោះ គឺជាប្រធានមន្ទីរពេទ្យ ឈ្មោះ ប៊ុន រ៉ានី។

យប់នោះ នៅក្នុងមន្ទីរពេទ្យ ការជួបពិភាក្សាគ្នា ដើម្បីបញ្ចប់ការយល់ច្រឡំពីបញ្ហារឿងផ្ទូផ្តងស្នេហារវាង ហ៊ុន សែន និងប៊ុន រ៉ានី ត្រូវបានធ្វើឡើងក្រោមពន្លឺភ្លើងចង្កៀងខ្លាញ់ត្រីភ្លឺប្លុងៗ។ ភាគីខាងនារី មានគ្នា៣នាក់ ចំណែកឯភាគីខាងយុវជនមានគ្នា២នាក់។ ពេលចាប់ផ្តើមសាកសួរគ្នារកមូលហេតុ ដែលនាំឱ្យមានការភាន់ច្រឡំដោយសារពួកយុទ្ធជននាំគ្នាចំអែចំអន់ផ្ទូផ្តងពីរឿងស្នេហានោះ ហ៊ុន សែន តែងតែលួចគយគន់រូបសម្ផស្សដ៏ស្រស់ស្អាតរបស់មិត្តនារី ប៊ុន រ៉ានី ក្នុងសម្លៀកបំពាក់សំពត់ខ្មៅអាវខ្មៅ សក់ខ្លីត្រឹមកញ្ចឹងក សាច់សចាំងនឹងពន្លឺចង្កៀងខ្លាញ់ត្រីទៀតនោះ គាត់បានសុំទោសជំនួសយុទ្ធជនរបស់គាត់ដែលបាននាំគ្នាចំអែចំអន់ផ្ទូផ្តងពីរឿងស្នេហា ដែលជាការមិនសមរម្យខុសអង្គការវិន័យ និងសីលធម៌បដិវត្តន៍នោះ។ បន្ទាប់មក ហ៊ុន សែន ក៏ឈប់និយាយពីរឿងចំអែចំអន់ផ្ទូផ្តងស្នេហា នោះបន្តទៀត ហើយប្តូរប្រធានបទភ្លាមៗបែរមកនិយាយពីសភាពការណ៍ក្នុងសមរភូមិវិញ។ ទីបំផុត គាត់បានស្នើសុំរាប់អាន

របត់នយោបាយ
ប៊ុន រ៉ានី ជាមិត្តរួមចលនាតស៊ូជាមួយគ្នា ដោយភាតរបដិវត្តន៍។ ចំណែក ប៊ុន រ៉ានី ក៏មិនបដិសេធនឹងសំណើនេះដែរ។

ពេលជួបគ្នាគ្រាដំបូង ហ៊ុន សែន ជាមេបញ្ជាការ ធ្លាប់មានតែមានជ័យជម្នះនៅលើសមរភូមិនោះ ដឹងខ្លួនថា ពេលនោះបេះដូងគាត់ពិតជាចុះចាញ់នឹងសម្រស់របស់ ប៊ុន រ៉ានី ហើយមិនខុសពីគំនិតដែលគាត់បានគិតទុកមុនពេលជួបគ្នានោះថា បើ រ៉ានី មានរូបស្អាត និងចរិយាសម្បត្តិល្អ គឺគាត់ស្រឡាញ់ និងស្នើសុំរៀបការតែម្តង។ យប់នោះជាអំណោយផលល្អដែរ ដែល ហ៊ុន សែន និងមេបញ្ជាការរបស់គាត់ មិនអាចធ្វើដំណើរទាំងយប់វិលត្រឡប់ទៅកាន់អង្គភាពវិញបាន។ ពួកគាត់ត្រូវសម្រាកនៅមន្ទីរពេទ្យនោះមួយយប់។

ខ្យល់អាកាសមាត់ទន្លេត្រជាក់ខ្លាំង ប៊ុន រ៉ានី បានយកខ្នើយ និងភួយពណ៌ផ្កាឈូករបស់គាត់ព្រមទាំងខ្នើយ  និងភួយពណ៌ខៀវរបស់បុគ្គលិកគាត់ម្នាក់ទៅប្រគល់ឱ្យភ្ញៀវទាំង២នាក់ ដណ្តប់ដើម្បីឱ្យបាត់រងា ដោយមិនបានចាប់អារម្មណ៍ ថា ហ៊ុន សែន និងមេបញ្ជាការរបស់គាត់យកភួយណាមួយនោះទេ។ ចៃដន្យ អាចថា ជានិស្ស័យស្នេហ៍ ហ៊ុន សែន បានជ្រើសរើសយកភួយពណ៌ផ្កាឈូក ជាកម្មសិទ្ធិរបស់ ប៊ុន រ៉ានី ដែលតែងតែដណ្តប់លើទ្រូងជារៀងរាល់រាត្រីនោះ មកដណ្តប់លើទ្រូងគាត់។

ព្រឹកឡើងភ្លឺ ហ៊ុន សែន និងមេបញ្ជាការរបស់គាត់ ក៏បានលានារី ជាប្រធានមន្ទីរពេទ្យដ៏ស្រស់ស្អាត និងបុគ្គលិកពេទ្យ វិលត្រឡប់ទៅបំពេញភារកិច្ច នៅឯសមរភូមិវិញ។ ទោះបីបែកឆ្ងាយពីគ្នាអស់រយៈពេលរាប់ខែ តែ ហ៊ុន សែន នៅតែនឹកអាល័យដល់ថ្ងៃជួបគ្នាគ្រាដំបូង ហើយនៅតែប៉ងប្រាថ្នាចង់ជួប ប៊ុន រ៉ានី ជាថ្មីម្តងទៀត។

នៅរដូវវស្សា ក្នុងឆ្នាំ១៩៧៤ ដដែលនោះ ជាចៃដន្យ នៅពេលដែលគាត់ធ្វើដំណើរដោយជិះកង់ជាមួយមិត្ត៣នាក់ទៀត ទៅសួរសុខទុក្ខយុទ្ធជនរបស់គាត់មួយចំនួនមានជំងឺគ្រុនចាញ់ និងត្រូវបញ្ជូនឱ្យមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ស្រាប់តែគាត់ប្រទះឃើញ ប៊ុន រ៉ានី និងបុគ្គលិកពេទ្យមួយក្រុម

កំពុងព្យាបាលជំងឺគ្រុនចាញ់ឱ្យយុទ្ធជនរបស់គាត់ ដោយយកចិត្តទុកដាក់បំផុត។

ប៊ុន រ៉ានី និងបុគ្គលិកពេទ្យមួយក្រុមនោះ ត្រូវបានគេបញ្ជូនតាមរថយន្តមួយគ្រឿងពីមន្ទីរពេទ្យ នៅស្រុកក្រូចឆ្មារ ឱ្យមកជួយព្យាបាលពួកយុទ្ធជន ដែលមានជំងឺគ្រុនចាញ់មកសម្រាកព្យាបាលមន្ទីរពេទ្យ ឃុំពាមជីលាំង នោះ។

ដោយក្ដីរីករាយ និងដើម្បីបាននៅជិតនាង គាត់បានប្រមែប្រមូលមិត្តភក្ដិរបស់គាត់ ហើយអញ្ជើញ ប៊ុន រ៉ានី និងមិត្តនារីៗជាបុគ្គលិកពេទ្យជុំគ្នាទទួលទានអាហារមួយពេល។ ហ៊ុន សែន សប្បាយចិត្តជាពន់ពេកនៅពេលបានទទួលទានអាហារជុំគ្នាជាមួយនារីដែលជាទីប៉ងប្រាថ្នារបស់ខ្លួន។ ពេលនោះ មិត្តភក្ដិរបស់គាត់ខ្លះនៅតែចំអែចំអន់ផ្លូផ្លង ថា ពួកគាត់ទាំង២នាក់ ពិតជាស័ក្ដិសមជាគូអនាគត ដូចកាលមុនពេលពួកគាត់បានជួបគ្នាគ្រាដំបូងដែរ។ ពាក្យចំអែចំអន់ផ្លូផ្លងនេះធ្វើឱ្យគាត់រំភើបរីករាយក្នុងចិត្តណាស់ តែគាត់ ក៏មានក្ដីបារម្ភថា ការចំអែចំអន់ផ្លូផ្លងរឿងស្នេហានេះ គឺខុសនឹងអង្គការ វិន័យ និងខុសពីសីលធម៌បដិវត្តន៍ ហើយគាត់ ក៏មិនដឹងធ្វើដូចម្ដេចឱ្យមិត្តភក្ដិរបស់គាត់ឈប់និយាយចំអែចំអន់ផ្លូផ្លងបែបនេះទៀតដែរ។ ដើម្បីចៀសវាងកុំឱ្យមានការប្រកាន់ថាខុសសីលធម៌ ដោយសារមានស្នេហាលាក់បាំងពីភ្នែកអង្គការបដិវត្តន៍ ហ៊ុន សែន វ័យ២២ឆ្នាំ បានស្នើសុំរៀបការជាមួយ ប៊ុន រ៉ានី វ័យ២០ឆ្នាំ ជាផ្លូវការតែម្ដង។

គាត់បានស្នើសុំរៀបការច្រើនលើកច្រើនសា តែថ្នាក់លើគាត់បានប្រាប់ថា អង្គការបានកំណត់ហើយថា បើចង់រៀបការទាល់តែកម្មាភិបាល ឬយុទ្ធជននោះមានអាយុ៣០ឆ្នាំ ឬជាយុទ្ធជនពិការទើបអង្គការអនុញ្ញាត។ ពិសេស ត្រូវរង់ចាំកងទ័ពបដិវត្តន៍វាយដណ្ដើមបានទីក្រុងភ្នំពេញ ទទួលបានជោគជ័យលើរបបសាធារណរដ្ឋខ្មែរទាំងស្រុងសិន។ ព្រដូច្នេះ ធ្វើឱ្យអស់សង្ឃឹមយ៉ាងខ្លាំងមិនដឹងថា តើពេលណាគាត់នឹងបានរៀបការជាមួយ ប៊ុន រ៉ានី យុវនារីជាទីស្រឡាញ់បំផុតរបស់គាត់?។

ទោះបីមេបញ្ជាការរបស់ ហ៊ុន សែន ប្រាប់ថា បើកម្មាភិបាល ឬយុទ្ធជនណាចង់រៀបការទាល់តែមានអាយុ៣០ឆ្នាំ ឬជាយុទ្ធជនពិការ ពិសេសត្រូវរង់ចាំកងទ័ពបដិវត្តន៍

របត់នយោបាយ

វាយដណ្ដើមបានទីក្រុងភ្នំពេញ ទើបអង្គការអនុញ្ញាត ក៏ពិតមែន តែ ប៊ុន រ៉ានី វិលត្រឡប់មកពីព្យាបាលជំងឺគ្រុនចាញ់ឱ្យពួកយុទ្ធជននៅមន្ទីរពេទ្យ ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ មកដល់ទៅមន្ទីរពេទ្យស្រុកក្រូចឆ្មារ វិញ មានមិត្តភក្តិម្នាក់លួចខ្សឹបថា អង្គការមានគម្រោងឱ្យនាងរៀបការជាមួយកម្មាភិបាលម្នាក់ ជាប្រធានរោងពុម្ពក្នុងរយៈពេលយ៉ាងយូរ៣ថ្ងៃទៀត។ គ្រាន់តែឮដូច្នេះ ប៊ុន រ៉ានី ក៏ដើរទៅរកគណៈកម្មាធិការស្រុក ដែលមានគម្រោងឱ្យគាត់រៀបការនោះ ហើយប្រាប់ថា គាត់មិនរៀបការជាមួយកម្មាភិបាល ជាប្រធានរោងពុម្ពទេ ឱ្យគេរៀបការជាមួយនារីផ្សេងទៅ...។

ក្រោយពី ប៊ុន រ៉ានី បដិសេធមិនព្រមរៀបការជាមួយកម្មាភិបាល ជាប្រធានរោងពុម្ពនោះ ធ្វើឱ្យកម្មាភិបាលមួយចំនួននៅក្នុងជួរគណៈកម្មាធិការស្រុក មានការខឹងសម្បាយ៉ាងខ្លាំងរហូតដល់ពួកគេឈប់និយាយស្តីរកនាងទៀតផង។

ជាមួយគ្នានោះ យុវជនជាប្រធានរោងពុម្ពដែលជាអ្នកស្នើសុំរៀបការជាមួយគាត់នោះក៏បានបង្ហាញឱ្យឃើញពីអាកប្បកិរិយាខឹងសម្បា និងគុំកួនផងដែរ។

ចំណែក ហ៊ុន សែន វិញ មិនយូរប៉ុន្មាន មេបញ្ជាការរបស់គាត់បានហៅឱ្យគាត់មកជួប ហើយប្រាប់គាត់ឱ្យបំភ្លេច ប៊ុន រ៉ានី ចោលទៅ ព្រោះនាងបានរៀបការជាមួយបុរសផ្សេងទៀតហើយ។ គ្រាន់តែឮដំណឹងនេះភ្លាម ធ្វើឱ្យគាត់ធ្លាក់ថ្លើមក្នុក ឈឺចាប់ដែរ តែគាត់ព្យាយាមទប់អារម្មណ៍ឱ្យស្ងប់ស្ងៀម។ មិនគួរណា ប៊ុន រ៉ានី ដាច់ចិត្តទៅរៀបការជាមួយគេផ្សេងធ្វើឱ្យគាត់អាម៉ាស់មុខដូច្នេះទេ ព្រោះនរណាៗក៏គេដឹងរឿងស្នេហារបស់គាត់ដែរ។

ប៉ុន្មានថ្ងៃក្រោយមក ហ៊ុន សែន គិតថា មិនអាចទទួលយកការបាត់បង់កិត្តិយសបែបនេះបានទេ ពិសេសដើម្បីកុំឱ្យចាញ់ចិត្ត ប៊ុន រ៉ានី ដែលដាច់ចិត្តរៀបការជាមួយគេផ្សេង គាត់ក៏បានស្នើសុំរៀបការជាមួយនារីម្នាក់ ដែលនៅជិតអង្គភាពមន្ទីរពេទ្យរបស់ប៊ុន រ៉ានី ដែរ។ តែមិត្តភក្តិម្នាក់បានមកស្តីបន្ទោសគាត់ថា ម៉េចក៏ឯងធ្វើបែបនេះ ប៊ុន រ៉ានី មិនបានរៀបការជាមួយនរណាផ្សេងនោះទេ មានគេស្នើសុំរៀបការជាមួយនាងពិតមែន

តែនាងបដិសេធ ហើយនាងនៅតែរង់ចាំឯង...។ ពេលដឹងការពិត គាត់ក៏ដកចិត្តលែងស្នើសុំរៀបការជាមួយនារីម្នាក់ដែលនៅជិតអង្គភាពមន្ទីរពេទ្យរបស់ ប៊ុន វ៉ានី នោះទៀត ហើយគាត់បានផ្ដាំផ្ញើមិត្តភក្ដិម្នាក់នោះឱ្យសុំទោសចំពោះ ប៊ុន វ៉ានី ជំនួសគាត់ផង។

ចាប់ពីពេលនោះមក ទើបគាត់ដឹងថា មេបញ្ជាការគាត់បានប្រើល្បិចឱ្យគាត់បំភ្លេច ប៊ុន វ៉ានី ដោយភូតកុហកគាត់ថា នាងបានរៀបការជាមួយបុរសផ្សេងនោះ ឱ្យគាត់រៀបការជាមួយនារីម្នាក់ទៀត ដែលមានអាយុចាស់ជាងគាត់ដល់ទៅ១២ឆ្នាំ មកធ្វើប្រពន្ធ។

នារីម្នាក់វ័យ៣២ឆ្នាំនោះ ជាអតីតសាស្ត្រាចារ្យ ធ្លាប់មានការផ្គូផ្គងឱ្យរៀបការជាមួយមេបញ្ជាការជាន់ខ្ពស់ តែម្នាក់ផ្សេងទៀតដែរ ត្រូវអាក់ខានទៅវិញ។ ពេលនោះ ហ៊ុន សែន បដិសេធទាំងប្រថុយប្រថាន ព្រោះការមិនគោរពតាមការចាត់តាំងរបស់អង្គការបែបនេះអាចចាត់ទុកថា មិនដើរតាម ឬមិនស្មោះត្រង់ជាមួយអង្គការ ក៏អាចថាបាន។ ក្រោយមក នៅឆ្នាំ១៩៧៦នារីវ័យចំណាស់ម្នាក់នោះ ក្លាយជាសមាជិកសភាប្រជាជនរបស់របបកម្ពុជាប្រជាធិបតេយ្យ។

ក្រោយពីមេបញ្ជាការគាត់ ស្នើឱ្យគាត់រៀបការជាមួយនារីវ័យ៣២ឆ្នាំ និងជាអតីតសាស្ត្រាចារ្យនោះ មិនបានសម្រេចដូចបំណងមក មេបញ្ជាការគាត់ឈ្មោះ សឿង បានបញ្ចុះបញ្ចូល និងជំរុញឱ្យគាត់រៀបការជាមួយកូនស្រីរបស់ខ្លួនម្ដងវិញ។ ម្ដងនេះ វាកាន់តែពិបាកបដិសេធជាងមុនទៅទៀត ព្រោះវាមិនមែនធម្មតាទេ មេដឹកនាំម្នាក់ដែលគាត់តែងតែគោរព និងធ្វើតាមបញ្ជាគ្រប់យ៉ាងនោះ ពេលចង់ឱ្យគាត់រៀបការជាមួយកូនស្រីរបស់ខ្លួន គឺចាត់ទុកជាការផ្ដល់កិត្តិយសដ៏ថ្លៃថ្លាមួយចំពោះគាត់ តែបើគាត់ប្រកែកវិញនោះ ក៏អាចចាត់ថា ជាការប្រមាថមួយដែរ។ ដើម្បីដោះស្រាយបញ្ហានេះ មធ្យោបាយដែលល្អបំផុតមានតែមួយគត់ គឺគាត់ប្រាប់ទៅមេបញ្ជាការនោះដោយរាបសាទន់ភ្លន់ថា គាត់ចាត់ទុកមេបញ្ជាការនោះ ដូចជាឪពុកបង្កើត។ ចំណែកកូនស្រីដែលមេបញ្ជាការ ចង់ឱ្យគាត់រៀបការជាមួយនោះ ក៏គាត់ចាត់ទុកដូចជាប្អូនស្រីបង្កើតរបស់គាត់ដែរ ដូច្នោះគាត់មិនអាចរៀបការជាមួយប្អូនស្រីរបស់ខ្លួនឯងបានទេ។ មេបញ្ជាការ

របត់នយោបាយ
របស់គាត់ស្តាប់ហេតុផលនេះហើយ ក៏នៅស្ងៀមលែងនិយាយពីរឿងរៀបការនោះទៀត។




**បន្ទាយទាហានលន់ នល់ នៅស្រុកពញាក្រែក ត្រូវកងទ័ពរំដោះវាយកម្ទេច**

---

# ៧.៩. កាសែតបរទេសថា៖ សម្តេចសីហនុ យកខ្មោច ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម មកធ្វើជារដ្ឋមន្ត្រី

  

ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧០ វេលាម៉ោង៨យប់ សម្តេចសីហនុ និងជាយា បានយាងចេញពីព្រះរាជដំណាក់ ដើម្បីទៅអាកាសយានដ្ឋានពោធិ៍ចិនតុង ឡើងយន្តហោះចេញទៅក្រៅប្រទេស ជាមួយរាជវង្ស និងឥស្សរជនមួយចំនួន ដូចជា នុត ឈឿម ចាងហ្វាងកាសែតសុជីវធម៌ ផងដែរ។ ក្រោយពីចំណាយពេលហោះហើរអស់រយៈពេលជាច្រើនម៉ោងមក យន្តហោះបានចុះចតនៅអាកាសយានដ្ឋានក្រុងរ៉ូម ប្រទេសអ៊ីតាលី សម្តេចសីហនុ និងជាយា ព្រមទាំងអ្នករួមដំណើរទាំងអស់ បានចុះពីលើយន្តហោះ ហើយឡើងរថយន្ត ដើម្បីបន្តដំណើរទៅកាន់រាជដំណាក់តូចមួយ របស់ព្រះអង្គឈ្មោះមូហ្សាំង ស្ថិតនៅមាត់សមុទ្រ កូត ដាហ្សៀ ដោយមានឥស្សរជនខ្មែរ ដូចជានាយករដ្ឋមន្ត្រី លន់ នល់, ញឹក ជូឡុង (មន្ត្រីជាន់ខ្ពស់ចូលនិវត្តន៍), តូច គីម រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, យ៉ែម សារុង មន្ត្រីជាន់ខ្ពស់នៃធនាគារជាតិកម្ពុជា, សុន វើនសៃ ឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសបារាំង និងអាណិកជនខ្មែរនៅប្រទេសបារាំងជាច្រើនទៀត បាននាំគ្នាមកថ្វាយបង្គំព្រះអង្គ ដោយក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត។

នៅថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧០ សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋបានយាងដល់

របត់នយោបាយ

ព្រះរាជដំណាក់ ព្រះអង្គនៅក្រុងមូហ្សាំង (Mougins) នៃប្រទេសបារាំង ខណៈ លន់ នល់ ជានាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ មកសម្រាកព្យាបាលមុខរបួសបាក់ឆ្អឹងជងកាំបិតដោយសារគ្រោះថ្នាក់ចរាចរណ៍ក៏បានមកសំណាក់នៅផ្ទះក្មួយរបស់គាត់ ដែលស្ថិតនៅសង្កាត់អ៊ីស៊ីទ្បេម៉ូលីណូ(Issy-Les-Mo lineaux)ជាយក្រុងប៉ារីស ផងដែរ។

នុត ឈឿម ចាងហ្វាងកាសែតសុជីវធម៌ ដែលអមព្រះរាជដំណើរសម្តេចសីហនុទៅប្រទេសបារាំង ដែរនោះ បានអះអាងថា ថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៧០ សម្តេចសីហនុសព្វព្រះទ័យឱ្យ លន់ នល់ ចូលគាល់។ តែមិនដឹងថា មានបញ្ហាអ្វីនោះទេ?។ លុះស្អែកឡើងថ្ងៃទី០៩ មករា គាត់បានទៅជួប លន់ នល់ នៅផ្ទះក្មួយរបស់ លន់ នល់ នោះ។

ដោយសារធ្លាប់ស្គាល់ច្បាស់ថា នុត ឈឿម មិនមែនត្រឹមតែជាចាងហ្វាងកាសែតសុជីវធម៌ប៉ុណ្ណោះទេ គឺជាសមាជិកបរះរាជរដ្ឋាភិបាល មានតួនាទីតាមដានសកម្មភាពអំពើពុករលួយរបស់មន្ត្រីធំៗផងនោះ ម្ល៉ោះហើយពេលបានជួបគ្នាម្តងៗ លន់ នល់ តែងហៅ នុត ឈឿម ថា៖ “ លោកបរះៗ ” ។ នុត ឈឿម សួរ លន់ នល់ ថា៖ “ លោកធំអញ្ជើញចូលគាល់ព្រះករុណា មានការអ្វីជាធំដុំឬ? ”។ លន់ នល់ តបទាំងញញឹមថា៖ “ គ្មានការអ្វីធំដុំទេ តែសម្តេចបានមានព្រះបន្ទូលថា មុននឹងស្តេចយាងត្រឡប់ទៅកាន់ទីក្រុងភ្នំពេញ វិញ ព្រះអង្គសព្វព្រះទ័យឱ្យខ្ញុំដង្ហែព្រះអង្គទៅធ្វើព្រះរាជទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសឆេកូស្លូវ៉ាគី, យូហ្គោស្លាវី, សហភាពសូវៀត និងប្រជាមានិតចិន ដែរ ”។ តែព្រះអង្គមានព្រះបន្ទូលរអ៊ូរទាំថា៖ “ សមាជិករាជរដ្ឋាភិបាលរបស់ឯកឧត្តម បានធ្វើទុក្ខបុកម្នេញខ្ញុំខ្លាំងណាស់ ” ពិសេសគឺទ្រង់ សិរិមតៈ បានចេញប្រកាសមួយថា៖ “ ចាប់ពីថ្ងៃនេះ មន្ត្រីថ្នាក់ណាក៏ដោយ ឬឥស្សរជនណាក៏ដោយ បើចង់ចូលគាល់ខ្ញុំ ត្រូវតែសុំការអនុញ្ញាតពីទ្រង់ជាមុនសិន ”។ ព្រះអង្គមានបន្ទូលទៀតថា៖ “ ការប្រកាសបែបនេះ ខ្ញុំយល់ថា ទ្រង់ សិរិមតៈ នៅតែមានគំនិតគុំកួនខ្ញុំ ”។ តែរឿងនេះមិនជាធំដុំទេ ព្រោះខ្ញុំមានជំនឿថា “ ពេលសហជីវិននាយករដ្ឋមន្ត្រី (លន់ នល់) ត្រឡប់ទៅប្រទេសវិញ សហជីវិនប្រាកដជារៀបចំសណ្តាប់ធ្នាប់នៅក្នុងរាជរដ្ឋាភិបាលរបស់សហជីវិន ឱ្យបានល្អឡើងវិញជាមិនខាន ”។

របត់នយោបាយ

លុះស្អែកឡើង ថ្ងៃទី១០ ខែកុម្ភៈ សម្តេចសីហនុ ក៏បានឱ្យ លន់ នល់ ចូលមកគាល់ម្តងទៀត។ ពេលនោះ ព្រះអង្គមានបន្ទូលថា៖ “ ខ្ញុំសូមសហជីវិនអញ្ជើញត្រឡប់ទៅក្រុងភ្នំពេញ មុនចុះ មិនបាច់នៅចាំដង្ហែខ្ញុំទៅធ្វើទស្សនកិច្ចប្រទេសឆេកូស្លូវ៉ាគី, យូហ្គោស្លាវី, សហភាពសូវៀត និងប្រជាមានិតចិន ដូចខ្ញុំបានជម្រាបសហជីវិនកាលពីម្សិលមិញនោះទេ ព្រោះសភាពការណ៍នៅក្នុងប្រទេសយើងមិនសូវល្អទេ ម៉្យាងរូបខ្ញុំជាប្រមុខរដ្ឋក៏នៅក្រៅប្រទេស ឯកឧត្តមជានាយករដ្ឋមន្ត្រី ក៏នៅក្រៅប្រទេសដែរ។ ហេតុនេះខ្ញុំសូមឯកឧត្តមអញ្ជើញទៅមុនចុះ ដើម្បីរៀបចំសភាពការណ៍ក្នុងប្រទេសឱ្យបានស្រួលបួលឡើងវិញ ”។ លន់ នល់ គោរពតាមព្រះរាជបញ្ជា និងសន្យាថា គាត់នឹងវិលត្រឡប់ទៅមាតុប្រទេសវិញ ក្នុងពេលឆាប់ៗខាងមុខនេះ។ ពេល លន់ នល់ ត្រឡប់មកដល់ផ្ទះក្មួយរបស់គាត់វិញ នុត ឈឿម ក៏បានទៅជួប លន់ នល់ ម្តងទៀត ដើម្បីសាកសួរពីខ្លឹមសារនៃការចូលគាល់ជាលើកទី២នេះ។

លុះដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧០ នៅចំណតអាកាសយានដ្ឋានអ័រលី (Orly) គេឃើញវត្តមាន ញឹក ជូឡុង, សុន វើនសៃ ឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសបារាំង, នុត ឈឿម ព្រមទាំងឥស្សរជន និងនិស្សិតខ្មែរជាច្រើនបានមករង់ចាំជូនដំណើរនាយករដ្ឋមន្ត្រី លន់ នល់ ឡើងយន្តហោះវិលត្រឡប់ទៅមាតុប្រទេសវិញ។

នុត ឈឿម បានឱ្យដឹងថា ពេល លន់ នល់ ទៅដល់ចំណតអាកាសយានដ្ឋានពោធិ៍ចិនតុងមានឥស្សរជនខ្មែរ និងបរទេសជាច្រើននាក់រង់ចាំទទួលស្វាគមន៍។ តែដោយសារសុខភាពមិនសូវល្អ លន់ នល់ បានចាប់ដៃភ្ញៀវកិត្តិយសខ្លះប៉ុណ្ណោះ រួចក៏ឡើងរថយន្តទៅគេហដ្ឋាននៅឯទំនប់ទឹក ក្បែរផ្សារដើមថ្កូវ តែម្តង។

ចាប់ពីថ្ងៃ លន់ នល់ ទៅដល់មាតុប្រទេសវិញ បុគ្គលិកជាអ្នកស៊ើបការណ៍កាសែតសុជីវធម៌ក្រុងភ្នំពេញ តែងតែផ្តល់ព័ត៌មានពីសភាពការណ៍ប្រែប្រួលរបស់ប្រទេសជាតិមកឱ្យ នុត ឈឿម ជាចាងហ្វាងនៅប្រទេសបារាំងជាញឹកញាប់។ នុត ឈឿម វាយតម្លៃថា សភាពការណ៍ប្រទេសជាតិនឹងមានការប្រែប្រួលជាមិនខាន។

ប្រភពផ្តល់ព័ត៌មានពីក្នុងប្រទេសបានឱ្យដឹងថា ពេលនាយករដ្ឋមន្ត្រី លន់ នល់

ចូលទៅដល់ក្នុងគេហដ្ឋាន អនុសេនីយ៍ទោ លន់ ណុន និងបក្សពួកគាត់ ២-៣ទៀត សុំជួបពិភាក្សាការងារសំខាន់មួយ។ តែប្រហែល លន់ នល់ បានដឹងពីបំណងរបស់ប្អូនប្រុសជាមុន ក៏ប្រាប់ថា ចាំពេលក្រោយទៅ។ ក្រោយ លន់ នល់ ទៅដល់មាតុប្រទេសវិញបាន៤ថ្ងៃ នុត ឈឿម ក៏បានសម្រេចចិត្តចាកចេញពីប្រទេសបារាំង ទៅកាន់ទីក្រុងហុងកុង ដើម្បីងាយស្រួលតាមដានសភាពការណ៍នៅក្នុងប្រទេសបន្តទៀត។

ក្រោយពេលមកដល់មាតុប្រទេសវិញបានប៉ុន្មានថ្ងៃ លន់ នល់ ក៏បានស្លៀកពាក់ឯកសណ្ឋានទាហានចេញដំណើរទៅពិនិត្យសភាពការណ៍នៅតាមបណ្ដោយព្រំដែនខាងកើត ពិសេសចង់ដឹងពីកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលចូលមកបោះទីតាំងនៅទីនោះ។

នៅព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មវាយកម្ទេចស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង (វៀតកុង) និងស្ថានទូតវៀតណាមខាងជើង នៅទីក្រុងភ្នំពេញ។ ប្រភពមួយបានអះអាងថា អនុសេនីយ៍ទោ នល់ ណុន ប្អូនប្រុសរបស់ឧត្ដមសេនីយ៍ឯក លន់ នល់ ជាអ្នករៀបចំឱ្យមានបាតុកម្មនេះ។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧០ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ បានប្រកាសឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដកចេញពីទឹកដីកម្ពុជា ឱ្យអស់ឱ្យបានត្រឹមថ្ងៃទី១៥ ខែមីនា ពោលគឺទុករយៈពេលឱ្យតែ៣ថ្ងៃប៉ុណ្ណោះ និងបានបដិសេធលែងទទួលស្គាល់កិច្ចព្រមព្រៀងស្ដីពីការដឹកជញ្ជូនអាវុធទៅឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង តាមច្រកទ្វារកំពង់ផែក្រុងព្រះសីហនុទៀតផង។

ជាមួយគ្នានោះឧត្ដមសេនីយ៍ឯក លន់ នល់ នាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ បានផ្ញើលិខិតមួយច្បាប់ទៅថ្វាយសម្ដេចសីហនុ ជាព្រះប្រមុខរដ្ឋ នៅឯក្រុងប៉ារីស ដើម្បីសុំព្រះរាជអនុញ្ញាតជ្រើសរើសកងទ័ពចំនួន១០,០០០នាក់ (មួយម៉ឺន) ដើម្បីការពារព្រំដែនខ្មែរ-វៀតណាមផង និងបណ្ដេញកងទ័ពវៀតកុង-វៀតណាមខាងជើងឱ្យចេញពីទឹកដីខ្មែរផង។ តែសម្ដេចសីហនុ ឆ្លើយតបវិញថា៖ “ កងទ័ពអាមេរិក នៅ

របត់នយោបាយ
ក្នុងប្រទេសវៀតណាម ដល់ទៅ៥០០,០០០នាក់ (ហាសិបម៉ឺននាក់) នៅតែច្បាំងមិនឈ្នះកងទ័ពវៀតកុង-វៀតណាមខាងជើង តើយើងជ្រើសរើសទាហាន១០,០០០នាក់ (មួយម៉ឺននាក់) យកមកធ្វើអី? ម្យ៉ាងទៀត តើយើងបានប្រាក់បៀវត្ស និងអាវុធមកពីណា? តែទោះជាយ៉ាងណា ព្រះអង្គទុកបញ្ហានេះជូនរាជរដ្ឋាភិបាលស្រោចស្រង់ជាតិពិចារណា ដោះស្រាយចុះ"។

នុត ឈឿម បានបញ្ជាក់ថា ក្រោយពេលធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ ណុន ជាប្អូន លន់ នល់ បានបញ្ជាឱ្យកងប៉ូលិស និងកងរាជអាវុធហត្ថ ដើរឆែកឆេរភូមិគ្រឹះរបស់ឥស្សរជនណាដែលជាមនុស្សជិតស្និទ្ធនឹងសម្ដេចសីហនុ ព្រមទាំងបានឆែកឆេរទីស្នាក់ការ ហើយចាប់ខ្លួននិពន្ធនាយក និងបុគ្គលិកកាសែតសុជីវធម៌ផងដែរ ខណៈ នុត ឈឿម ជាចាងហ្វាងកំពុងនៅឯបរទេស។

បន្ទាប់ពីបានដឹងថា រដ្ឋាភិបាលក្រុងប៉េកាំង ប្រកាសគាំទ្រឱ្យសម្ដេចសីហនុបង្កើតរណសិរ្សរួបរួមជាតិម្ពុជា រដ្ឋាភិបាល លន់ នល់ បានចេញបញ្ជាមិនឱ្យ កង ម៉ៅចាវ ជាឯកអគ្គរដ្ឋទូតចិនប្រចាំប្រទេសកម្ពុជា និងបុគ្គលិកស្ថានទូតទាំងអស់ ចេញពីស្ថានទូតជាដាច់ខាត។ ចំណែក រដ្ឋាភិបាលចិនក៏បានឃាត់ ណៃ វ៉ាឡង់តាំង ឯកអគ្គរាជទូតខ្មែរ ប្រចាំក្រុងប៉េកាំង មិនឱ្យចាកចេញពីស្ថានទូតដែរ។ រយៈអស់ជិតមួយខែ ទើបមានការសម្របសម្រួលគ្នា ឱ្យឯកអគ្គរដ្ឋទូត និងបុគ្គលិកស្ថានប្រទេសទាំងពីរ មន្ត្រីទូតចិនប្រចាំប្រទេសកម្ពុជា និងចិន ចេញដំណើរវិលត្រឡប់ទៅកាន់ប្រទេសរៀងៗខ្លួនក្នុងម៉ោងនិងថ្ងៃតែមួយ។

ចាប់តាំងពីសម្ដេច ប្រកាសបង្កើតចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា មកមានឥស្សរជន និងនិស្សិតមកពីសហភាពសូវៀត និងប្រទេសបារាំង ស្ម័គ្រចិត្តមកចូលរួមក្នុងចលនាតស៊ូនោះរាប់រយនាក់។ ប៉ុន្តែ ពួកខ្មែរក្រហមជាតំណាងរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំប្រទេសបារាំង ភាគច្រើនជ្រើសរើសតែឥស្សរជន និងនិស្សិតណាដែលមាននិន្នាការទៅរកលទ្ធិកុម្មុយនិស្តតែប៉ុណ្ណោះ។ នៅក្រុងប៉េកាំង រដ្ឋាភិបាលចិន

របត់នយោបាយ

បានបែងចែកឥស្សរជន និងនិស្សិតខ្មែរជា២ក្រុម គឺក្រុមដែលគេចាត់ទុកជាពួកសីហនុនិយម ត្រូវស្នាក់នៅក្នុងបរិវេណរាជដំណាក់សម្ដេចសីហនុ។ ឯមួយក្រុមទៀតជាក្រុមខ្មែរក្រហម គេឱ្យស្នាក់នៅក្នុងសណ្ឋាគារមិត្តភាពមានច្រើនបន្ទប់។

នុត ឈឿម ដែលពេលនោះសម្ដេចសីហនុ បានតែងតាំងជាអនុព័ន្ធសារព័ត៌មានរបស់ព្រះអង្គបានឱ្យដឹងថា៖ ថ្ងៃមួយ មន្ត្រីក្រសួងការបរទេសចិន បានរៀបចំបញ្ចាំងខ្សែភាពយន្តឯកសារមួយស្ដីពីរឿង “ ជម្លោះព្រំប្រទល់ដែនចិន-សូវៀត ” ជូនឥស្សរជន និងនិស្សិតជាអ្នកតស៊ូខ្មែរទាំងអស់ទស្សនាកម្សាន្ត។ ពេលនោះ មាននិស្សិតខ្លះមាននិន្នាការទៅរកសូវៀត មិនចង់ទៅមើលខ្សែភាពយន្តនោះ ពួកគេក៏រអ៊ូរទាំថា ខ្សែភាពយន្តនោះមិនមែនជារឿងរ៉ាវរបស់ខ្មែរយើងទេ គឺជារឿងជម្លោះរវាងចិន និងសូវៀត ទេតើ!។ ក៏ប៉ុន្តែមានឥស្សរជន និងនិស្សិតខ្លះទៀតមាននិន្នាការទៅរកចិន បានជំរុញថា ត្រូវតែគោរពតាមការអញ្ជើញពីមន្ត្រីចិន ជាម្ចាស់ផ្ទះ។ ដោយសាររឿងទៅទស្សនាខ្សែភាពយន្តនោះ បណ្ដាលឱ្យមានជម្លោះ ឈ្លោះប្រកែកគ្នារហូតដល់មានការប្រើអំពើហិង្សាដាក់គ្នាទៀតផង។ ឃើញដូច្នេះ មន្ត្រីក្រសួងការបរទេសចិន ក៏សម្រេចលុបចោលកម្មវិធីបញ្ចាំងខ្សែភាពយន្តនោះវិញ។

បើតាម នុត ឈឿម បានឱ្យដឹងថា ក្រោយពេលបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានឈ្មោះ ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ, ហ៊ូ យន់ ជារដ្ឋមន្ត្រីមហាផ្ទៃ សហករណ៍ និងកំណែទម្រង់សហគមន៍, ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ មក សូម្បីតែសម្ដេចសីហនុ ក៏មានការងឿងឆ្ងល់ដែរ។ ថ្ងៃមួយ ព្រះអង្គបានសួរទៅ កែរ មាស ជានាយកខុទ្ទកាល័យរបស់ព្រះអង្គ ដើម្បីចង់ដឹងការពិតថា រដ្ឋមន្ត្រីទាំងបីរូបនេះនៅមានជីវិត ឬស្លាប់បាត់ទៅហើយ?។

កែរ មាស បានទូលព្រះអង្គរបៀបកំប្លុកកំប្លែងថា៖ “ កាលទូលបង្គំនៅជាចាងហ្វាងពិធីការក្នុងព្រះបរមរាជវាំងនៅក្នុងប្រទេស នរណាៗក៏និយាយថា ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ស្លាប់ហើយដែរ។ ទូលបង្គំក៏ងឿងឆ្ងល់ដែរថា តើហេតុដូចម្ដេចបាន

ជាអង្គការក្នុងប្រទេសផ្ញើឈ្មោះអ្នកទាំង៣នាក់នេះមកថ្វាយព្រះអង្គឱ្យដាក់ជាសមាជិករាជរដ្ឋាភិបាលរួបរួមជាតិ? ”។ សម្ដេចសីហនុ មានបន្ទូលតបទៅវិញថា៖ “ ជាការពិតណាស់ ពួកគេគួរតែផ្ញើព័ស្តុតាងអ្វីមួយដើម្បីឱ្យខ្ញុំឃើញច្បាស់ថា ពួកគាត់ទាំង៣នាក់នេះប្រាកដជានៅរស់ប្រាកដមែន ”។ ប៉ុន្តែរហូតមកដល់ពេលនេះ ខ្ញុំគ្មានបានទទួលព័ស្តុតាងអ្វីទាំងអស់ ធ្វើឱ្យខ្ញុំមានការលំបាកក្នុងការឆ្លើយតបទៅពួកកាសែត ដែលចេះតែមសួរញ៉ាំញីខ្ញុំជារៀងរាល់ថ្ងៃពីរឿងពួកគាត់ទាំង៣នាក់នេះ។

នុត ឈឿម អនុព័ន្ធសារព័ត៌មានរបស់សម្ដេច សីហនុ បានឱ្យដឹងថា នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ១៩៧១ អង្គការតស៊ូក្នុងប្រទេសបានបញ្ជូន អៀង សារី ដែលកំពុងបំពេញភារកិច្ចនៅក្រុងហាណូយ ឱ្យមកធ្វើការនៅអមសម្ដេចសីហនុ នៅទីក្រុងប៉េកាំង ក្នុងឋានៈជាតំណាងជាន់ខ្ពស់របស់អង្គការតស៊ូក្នុងប្រទេស។

ពេលមកដល់ក្រុងប៉េកាំងភ្លាម អៀង សារី ក៏បានចូលគាល់សម្ដេចសីហនុ ជាប្រធានរណសិរ្ស ព្រមទាំងបានយករូបថតជាច្រើនសន្លឹកមកថ្វាយ សម្ដេច ក្នុងនោះក៏មានទាំងរូបថត ខៀវ សំផន, ហ៊ូ យន់, និង ហ៊ូ នឹម ផងដែរ។ លុះដល់ អៀង សារី ចេញពីរាជដំណាក់ត្រឡប់ទៅវិញ សម្ដេចបានបង្ហាញរូបអ្នកទាំងបីនេះឱ្យ កែវ មាស ដែលពេលនោះ គាត់មានឋានៈជាឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងប៉េកាំង ដើម្បីពិនិត្យមើលឱ្យច្បាស់ ព្រមទាំងមានបន្ទូលថា៖ “ លោកមាសឯងឃើញទេ អស់លោកទាំងបីនាក់នេះ ពិតជានៅរស់នៅឡើយទេតើ! អៀង សារី ទើបយករូបថតនេះជាព័ស្តុតាងមកឱ្យខ្ញុំមើលអម្បាញ់មិញនេះ ”។

កែវ មាស ដែលធ្លាប់តែនិយាយកំប្លុកកំប្លែងជាមួយសម្ដេច ក៏បានឆ្លើយតបទៅព្រះអង្គវិញថា៖ “តាមយោបល់ស្ដួចស្ដើងរបស់ទូលបង្គំ រូបថតទាំងបីនាក់ ដែលគេយកមកថ្វាយព្រះអង្គនេះ ប្រហែលសុទ្ធតែជារូបក្លែងក្លាយទេ។ រូបក្បាលទាំងបី ប្រាកដជាក្បាលរបស់ ខៀវ សំផន, ហ៊ូ យន់, និង ហ៊ូ នឹម នោះមែន! តែចំណែកដងខ្លួនវិញសង្ស័យសុទ្ធតែជាដងខ្លួនពួកយួនវៀតកុងទាំងអស់ហ្នឹង...”។ ការសន្ទនាបានចប់ត្រឹម

របត់នយោបាយ
នេះ ដោយសម្ដេចសីហនុ អត់មានព្រះបន្ទូលតបអ្វីទាំងអស់។

លុះដល់យប់មួយ ក្នុងពិធីជប់លៀងរៀបចំកីឡាវាយសី នៅក្នុងរាជដំណាក់ ដោយមានវត្តមាន ប៉ែន នុត នាយករដ្ឋមន្ត្រី និងអៀង សារី ជាតំណាងជាន់ខ្ពស់របស់អង្គការតស៊ូក្នុងប្រទេស ព្រមទាំងសមាជិករាជរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា និងសមាជិកការិយាល័យនយោបាយទាំងអស់ ស្រាប់តែសម្ដេចសីហនុ មានបន្ទូលខ្លាំងៗថា៖ “ រឿងពាក្យចចាមអារ៉ាមដែលថា ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ត្រូវគេសម្លាប់តាំងពីឆ្នាំ១៩៦៧ គឺនៅក្នុងរបបសង្គមរាស្ត្រនិយម ដែលមានរូបខ្ញុំជាអ្នកដឹកនាំនោះ ខ្ញុំបានសាកសួរ កែវ មាស ជានាយកខុទ្ទកាល័យរបស់ខ្ញុំថា តើព័ត៌មាននេះ ពិតឬមិនពិត? កែវ មាស បានឆ្លើយតបមកខ្ញុំថា ប្រហែលជាការពិតមែនហើយ។ រួចគាត់និយាយបន្ថែមទៀតថា រូបថតដែល អៀង សារី យកមកបង្ហាញខ្ញុំនោះ គឺជារូបថតក្លែងក្លាយទេ។ រូបក្បាលខាងលើជាមុខរបស់ ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ពិតមែន តែដងខ្លួនពួកគាត់ជាដងខ្លួនពួកយួនវៀតកុង ”។ បន្ទាប់មកទៀត សម្ដេចសីហនុ បន្ទូលថា៖ “ ខ្ញុំសូមប្ដឹង កែវ មាស ទៅរាជរដ្ឋាភិបាល និងការិយាល័យនយោបាយ ដែលហ៊ានចោទប្រកាន់ថា ខៀវ សំផន, ហ៊ូ យន់, និងហ៊ូ នឹម ត្រូវបានគេសម្លាប់កាលឆ្នាំ១៩៦៧ គឺនៅក្នុងសម័យសង្គមរាស្ត្រនិយម ដែលមានខ្ញុំជាដឹកនាំប្រទេស ”។

ក្រោយពីសម្ដេចសីហនុ មានបន្ទូលថា ប្ដឹង កែវ មាស ដូច្នេះ ប៉ែន នុត ប្រធានការិយាល័យនយោបាយមិនបង្អង់យូរ បានប្រាប់ឱ្យ អៀង សារី ចាត់ការតាមបណ្ដឹងរបស់ព្រះអង្គភ្លាមមួយរំពេច។

វេលាម៉ោង១០យប់ថ្ងៃដដែលនោះ កម្មាភិបាលនៅក្រោមបង្គាប់ អៀង សារី ចំនួន៤នាក់ បានទៅហៅ កែវ មាស នាយកខុទ្ទកាល័យរបស់ព្រះអង្គ នៅក្នុងទីលានកីឡាវាយសីឱ្យចេញមកក្រៅ ហើយឱ្យដើរតាមពួកគេដើម្បីទៅជួប អៀង សារី ដែលកំពុងអង្គុយរង់ចាំនៅក្នុងស្ថានទូតខ្មែរ រួចស្រេចទៅហើយនោះ។

បន្ទាប់ពីប្រាប់នូវទោសកំហុសរបស់ កែវ មាស មក អៀង សារី ក៏បានប្រាប់

របត់នយោបាយ
កែរ មាស ថា៖ ខ្ញុំសូមបញ្ចប់ភារកិច្ច និងតួនាទីជាឯកអគ្គរាជទូតរបស់លោក ចាប់ពីពេលនេះតទៅ និងសូមអញ្ជើញលោកចេញពីស្ថានទូត ទៅរស់នៅក្នុងសណ្ឋាគារមិត្តភាពវិញ។ បន្ទាប់មក កម្មាភិបាលនៅក្រោមបង្គាប់ អៀង សារី ទាំង៤នាក់ ក៏នាំ កែរ មាស ឡើងរថយន្ត ដឹកយកទៅសណ្ឋាគារមិត្តភាព។ លុះទៅដល់សណ្ឋាគារមិត្តភាព គេបានយក កែរ មាស ទៅសួរចម្លើយទាំងយប់ រហូតទៅដល់ម៉ោងជិត៦ភ្លឺ ទើបគេយកទៅដាក់ក្នុងបន្ទប់មួយចាក់សោពីក្រៅ ដោយមានអ្នកយាម២នាក់ប្រចាំការនៅមាត់បន្ទប់។ ពេលនោះ កែរ មាស មិនត្រូវបានគេអនុញ្ញាតឱ្យទៅទទួលទានបាយនៅខាងក្រៅដូចគេដូចឯងទេ គឺគេលើកបាយ និងសម្លទៅឱ្យគាត់ទទួលទានម្នាក់ឯងនៅក្នុងបន្ទប់ឃុំខ្លួននោះតែម្តង។ មិនយូរប៉ុន្មាន អៀង សារី តំណាងជាន់ខ្ពស់របស់អង្គការតស៊ូក្នុងប្រទេសដ៏មានអំណាច បានប្រកាសតែងតាំងជនកម្មុយនិស្តម្នាក់ឈ្មោះ តូច ខាំឿន ជាអតីតប្រធាននិស្សិតខ្មែរ នៅប្រទេសបារាំង ឱ្យធ្វើជាឯកអគ្គរាជទូតខ្មែរ ប្រចាំក្រុងប៉េកាំងជំនួស កែរ មាស។

ប៉ុន្តែរយៈពេលជិតមួយខែក្រោយមក សម្តេចសីហនុ ហាក់ដូចជាមានព្រះទ័យអាណិតអាសូរដល់ កែរ មាស ដែលធ្លាប់ជាចាងហ្វាងពិធីការក្នុងព្រះបរមរាជវាំងស្មោះត្រង់ចំពោះព្រះអង្គ និងព្រះរាជបល្ល័ង្កតាំងពីដើមមកនោះ ព្រះអង្គក៏បានបញ្ជាឱ្យ អៀង សារី ស្នើសុំទៅការិយាល័យនយោបាយ ឱ្យដោះលែង កែរ មាស ឱ្យត្រឡប់មករស់នៅក្នុងរាជដំណាក់ព្រះអង្គវិញ ដោយមិនឱ្យមានតួនាទីអ្វីទៀតឡើយ។ លុះដល់ឆ្នាំ១៩៧៣ កែរ មាស មានភារកិច្ចថ្មីមួយ គឺជាអ្នកថែរក្សាជំងឺព្រះមហាក្សត្រិយានីស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន ជាព្រះមាតា ដែលទើបតែទទួលបានការអនុញ្ញាតឱ្យយាងមកពីប្រទេសម្ពុជា មករស់នៅជាមួយសម្តេចសីហនុ ជាបុត្រានៅទីក្រុងប៉េកាំង។

នុត ឈឿម បានរៀបរាប់បន្តថា ចាប់តាំងពី អៀង សារី មកធ្វើការអមសម្តេចសីហនុ នៅប៉េកាំង មន្ត្រីរណសិរ្សរួបរួមជាតិ ជាង២០០នាក់ (ពីររយនាក់) ចាប់ផ្តើមបែងចែកបក្សពួកជា ២ចំណែក គឺ១. ជាពួកសីហនុនិយម និងមួយចំណែកទៀតជា

កុម្មុយនិស្តនិយម ស្តាប់តែបញ្ជា អៀង សារី ម្នាក់ប៉ុណ្ណោះ។ ជាមួយគ្នានោះ ក្នុងការសន្ទនាគ្នា អៀង សារី តំណាងអង្គការ ឱ្យផ្លាស់ប្តូរពាក្យពេចន៍មួយចំនួន ឧទាហរណ៍ កន្លងទៅធ្លាប់ហៅគ្នាថា “លោក” ត្រូវប្តូរហៅគ្នាជា “ មិត្ត ” វិញ សូម្បីតែរវាងកូន និង ឪពុកម្តាយ ក៏ត្រូវហៅគ្នាជាមិត្តដែរ។

ក្មេងៗទាំងអស់ ទោះបីជាមានឪពុកម្តាយនៅជាមួយក៏ដោយ ក៏ត្រូវចាត់ទុកជាកូនរបស់អង្គការទាំងអស់ ហើយគេបានបង្ហាត់បង្រៀនក្មេងៗទាំងនោះ ឱ្យចេះយកការណ៍ពីឪពុកម្តាយឯងទៅប្រាប់អង្គការទៀតផង។ ចំណែកមន្ត្រីខ្លះដែលធ្លាប់ជាមនុស្សសីហនុនិយម ក៏បាក់ស្បាតភ័យខ្លាចអំណាច អៀង សារី ដែរ។ បើពួកសីហនុនិយម ណាមិនគោរពកោតខ្លាចទេ អៀង សារី នឹងបំបែកចេញពីក្រុងប៉េកាំង ឱ្យទៅតស៊ូនៅក្នុងប្រទេស ដោយយកលេសថា អង្គការនៅក្នុងប្រទេសត្រូវការជាចាំបាច់។ ក្នុងនោះ មានបញ្ញវន្តម្នាក់ឈ្មោះ លី អុន មកពីប្រទេសបារាំង ជាមនុស្សស្មោះត្រង់ប្តូរផ្តាច់បំផុតជាមួយសម្តេចសីហនុ ត្រូវបាន អៀង សារី ចុចឈ្មោះឱ្យចេញពីប៉េកាំង ទៅតស៊ូនៅក្នុងប្រទេសវិញ។ ថ្ងៃមួយ ក្រោយពេលបានទទួលលិខិតបង្គាប់ការពី គាត ឈន់ ជារដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្លៀតឱកាសសម្តេចសីហនុ នៅក្នុងដំណាក់កំពុងរៀបចំចេញទៅលេងកីឡាវាយសី លី អុន ក៏បានចូលទៅថ្វាយបង្គំលាដោយបានសម្រក់ទឹកភ្នែកនៅលើបាទាព្រះអង្គ ព្រោះគាត់ដឹងខ្លួនថា គាត់ចៀសមិនផុតពីសេចក្តីស្លាប់ទេ។

កាលនោះបញ្ញវន្តភាគច្រើន ដែលត្រូវគេបញ្ជូនចេញពីប៉េកាំង ឱ្យទៅតស៊ូក្នុងតំបន់រំដោះ ក្នុងប្រទេសកម្ពុជា មិនសូវបានមកដល់គោលដៅទេ ព្រោះដំណើរពីក្រុងប៉េកាំង ទៅដល់ប្រទេសកម្ពុជា ត្រូវដើរឆ្លងកាត់តាមផ្លូវលំ ហូ ជីមិញ មានការលំបាកក្រៃលែង និងមានជំងឺឈឺស្លាប់តាមផ្លូវ។ ចំណែក នុត ឈឿម អនុព័ន្ធសារព័ត៌មានរបស់ព្រះអង្គ ក៏បានទទួលលិខិតបង្គាប់ការឱ្យចូលទៅតស៊ូនៅក្នុងប្រទេសពី គាត ឈន់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែរ តែគាត់បានយកសំបុត្រនេះទៅជូន

របត់នយោបាយ

អ្នកម្នាង (អ្នកម្នាងម៉ូនិក) ដើម្បីសុំព្រះរាជអន្តរាគមន៍ពីសម្ដេចសីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។ បន្ទាប់មក ព្រះអង្គក៏បានអញ្ជើញ គាត ឈន់ ចូលគាល់ រួចមានព្រះបន្ទូលប្រាប់ គាត ឈន់ ថា៖ “ ខ្ញុំសូមទុកលោក នុត ឈឿម ឱ្យនៅបម្រើខ្ញុំសិន… សូមឯកឧត្ដមទៅប្រាប់ឯកឧត្ដម អៀង សារី ផង ”។ ដោយសារព្រះរាជអន្តរាគមន៍នេះហើយ ដែលធ្វើឱ្យគាត់នៅរស់រានមានជីវិតមកដល់សព្វថ្ងៃនេះ។

នុត ឈឿម រម្លឹកទៀតថា ពេលនោះ គាត ឈន់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីព្យាយាមធ្វើយ៉ាងណាឱ្យ អៀង សារី ជឿទុកចិត្តគាត់ ដោយគាត់តែងនិយាយពាក្យដៀមដាមថា៖ “ ធ្វើកុង្ស៊ីយ៍កាលក្នុងរបបសង្គមរាស្ត្រនិយមរបស់សម្ដេចសីហនុ គ្មានអំណាចទេ! គ្រប់កុង្ស៊ីយ៍មិនហ៊ានសម្រេចការអ្វី ក្រៅតែពីរង់ចាំភ្លើងខៀវពីចម្ការមន (សម្ដេចព្រះប្រមុខរដ្ឋ) ឱ្យបញ្ជាមក ទើបអាចធ្វើអ្វីបាន! ”។

ដើម្បីបន្សាបឥទ្ធិពល និងព្រះកិត្តិនាមរបស់សម្ដេចសីហនុ ថ្ងៃមួយ អៀង សារី បានចូលគាល់ សម្ដេច ដើម្បីស្នើសុំឱ្យឈប់ប្រើពាក្យ “ សីហនុនិយម ” នៅក្នុងចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា តទៅទៀត ព្រះអង្គក៏យល់ព្រមតាមការស្នើសុំនោះដែរ។

ចាប់ពីពេលនោះមក ពួកសីហនុនិយមភាគច្រើន ក៏បាក់បបខ្លបខ្លាចអំណាចរបស់ អៀង សារី ក្លាយខ្លួនទៅជាពួកខ្មែរក្រហម ពួកកុម្មុយនិស្ត ដូចអ្នកតស៊ូនៅក្នុងប្រទេសដែរ។ ស្ទើរតែរៀងរាល់ថ្ងៃ ចាប់តាំងពីរដ្ឋមន្ត្រី រហូតមកដល់ថ្នាក់ក្រោម អៀង សារី តម្រូវឱ្យចូលរៀនទ្រឹស្ដីលទ្ធិកុម្មុយនិស្ត និងប្រជុំស្វ័យទិតៀន និងទិតៀនគ្នាទៅវិញទៅមក។ ពេលខ្លះ អៀង សារី ប្រាប់ថា គាត់ត្រូវចូលទៅក្នុងតំបន់រំដោះបួនដប់ថ្ងៃ។ តែ នុត ឈឿម អះអាងថា ការពិត គាត់គ្មានទៅតំបន់រំដោះឯណាទេ គឺគាត់ទៅតែត្រឹមក្រុងហាណូយ ដើម្បីយកឯកសារផ្សេងៗទៀត យកមកបង្រៀនអ្នកតស៊ូនៅក្រុងប៉េកាំងនោះតែបុណ្ណោះ។

ចាប់ពីពេល អៀង សារី មកធ្វើការជាតំណាងអង្គការនៅក្នុងប្រទេស មកធ្វើការ

របត់នយោបាយ
ជិតសម្តេចសីហនុ ពេលណាមក សម្តេចសីហនុ មិនសូវបានទទួលភ្ញៀវបរទេសមកពីខាងលោកសេរីទេ ទោះបីពួកគេបានដាក់ចុតហ្មាយ សូមចូលគាល់ព្រះអង្គយ៉ាងណាក្តី។ ដោយឡែក រាជរដ្ឋាភិបាលចិន ហាក់ដូចជាមានការសប្បាយចិត្តជាងពេលមុនណាស់ និងបានយកចិត្តផ្គាប់ផ្គុនព្រះអង្គ មិនឱ្យព្រួយព្រះទ័យ ឬខ្វះខាតអ្វីឡើយ។ សូម្បីតែរឿងប្រាក់កាសក៏រដ្ឋាភិបាលចិន បើកគណនេយ្យមួយដាក់ព្រះនាមព្រះអង្គក្នុងធនាគារទុកសម្រាប់ថ្វាយព្រះអង្គចាយវាយតាមសព្វព្រះទ័យ។

នុត ឈឿម អនុព័ន្ធសារព័ត៌មានរបស់ព្រះអង្គបានឱ្យដឹងថា ពេលសម្តេចសីហនុយាងទៅធ្វើព្រះរាជទស្សនកិច្ចនៅបរទេសម្តងៗ បក្ស និងរដ្ឋាភិបាលចិន បានថ្វាយព្រះទីនាំងអាកាសយានធំៗប្រភេទ បូអ៊ីង ៧០៧ (Boeing 707) ជូនកាល ១គ្រឿង ជូនកាល ២គ្រឿង ហើយទ្រង់ ស៊ីសុវត្ថិ មេថាវី (ប្អូនរបស់ទ្រង់ ស៊ីសុវត្ថិ សិរិមតៈ) ជានាយកខុទ្ទកាល័យរបស់ព្រះអង្គ មានសិទ្ធិចុះហត្ថលេខាលើមូលប្បទានបត្រទៅបើកប្រាក់ពីធនាគារ សម្រាប់យកទៅចំណាយផ្សេងៗ ពេលព្រះអង្គយាងទៅធ្វើព្រះរាជទស្សនកិច្ចនៅបរទេសនោះទៀតផង។

នុត ឈឿម បានធ្វើការវាយតម្លៃថា មុនពេល អៀង សារី មករស់នៅក្រុងប៉េកាំង ពួកខ្មែរសីហនុនិយម មានប្រមាណ៩០ភាគរយ។ តែក្រោយពេល អៀង សារី មកដល់មិនបាន១ឆ្នាំផង ពួកខ្មែរសីហនុនិយម បានថយចុះនៅត្រឹម៣០ភាគរយ ឯ ៧០ភាគរយទៀត ត្រូវតែចេះអែបអបខ្លបខ្លាច អៀង សារី ដែរ សូម្បីតែ ប៉ែន នុត ជានាយករដ្ឋមន្ត្រីបង្រួបបង្រួមជាតិកម្ពុជា និងជាប្រធានការិយាល័យនយោបាយផងដែរនោះ ក៏ចេះប្រើស្នៀតដិះទូក២ដែរ។ នៅចំពោះព្រះភក្ត្រសម្តេចសីហនុ ប្រធានរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ប៉ែន នុត នៅតែប្រើពាក្យសម្តីទន់ភ្លន់ និងគោរពព្រះអង្គដូចពេលមុនៗដែរ។ តែបើនៅជាមួយ អៀង សារី វិញ ប៉ែន នុត បញ្ចេញអាកប្បកិរិយាផ្សេង ធ្វើដូចមិនសូវចូលចិត្តព្រះអង្គ ហើយកោតសរសើរ អៀង សារី មិនដាច់ពីមាត់ទៀតផង។

ប្រឈមនឹងស្ថានភាពបែបនេះ ធ្វើឱ្យឥស្សរជនរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា

របត់នយោបាយ
នៅក្រុងប៉េកាំង មួយចំនួនដែលត្រូវតែងតាំងជាឯកអគ្គរាជទូតខ្មែរនៅឯបរទេស ក្នុងនោះរួមមាន ជា សាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចេញទៅធ្វើជាឯកអគ្គរាជទូតប្រចាំសហភាពសូវៀត នៅក្រុងមូស្គូ, ហួត សម្បត្តិ រដ្ឋមន្ត្រីក្រសួងសាធារណការ ទៅធ្វើជាឯកអគ្គរាជទូត នៅប្រទេសយូហ្គោស្លាវី, ងួន ពីទូរ៉េត ចេញទៅធ្វើជាឯកអគ្គរាជទូតនៅប្រទេសម៉ូរីតានី។ ហោ ណាំហុង ចេញទៅធ្វើជាឯកអគ្គរាជទូតនៅប្រទេសគុយបា។ ទ្រង់ ស៊ីសុវត្ថិ មេថាវី ជានាយកខុទ្ទកាល័យសម្តេចសីហនុ ត្រូវចេញទៅធ្វើជាឯកអគ្គរាជទូតនៅប្រទេស អាល្លឺម៉ង់ខាងកើតក៏យាងចេញទៅបាត់ដែរ។ តែមុននឹងយាងចេញពីក្រុងប៉េកាំង ទៅកាន់តំណែងថ្មីនៅប្រទេសអាល្លឺម៉ង់ខាងកើត ទ្រង់មានព្រះបន្ទូលមកកាន់ នុត ឈឿម ថា " ឈឿមឯងឃើញទេ អៀង សារី កំពុងតែធ្វើនយោបាយដឹកនាំប្រទេសយើងទៅរកលទ្ធិកម្មុយនិស្តផ្តាច់ការហើយ ត្រូវតែប្រយ័ត្ន!..."។

ចំណែក ថៅ សេង រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដែលត្រូវចេញទៅបំពេញការងារនៅក្រុងប៉ារីស ប្រទេសបារាំងវិញនោះ បានលួចខ្សឹបប្រាប់ នុត ឈឿម ជាមនុស្សស្គាល់គ្នាច្បាស់នោះថា៖ ខ្ញុំមិនចង់រស់នៅក្បែរ អៀង សារី ទៀតទេ ព្រោះគាត់ស្អប់មនុស្សនេះណាស់។ ដូច ឈឿមឯងធ្លាប់ស្គាល់ខ្ញុំស្រាប់ហើយ កាលពីមុនឆ្នាំ ១៩៧០ ពួកបញ្ញវន្តខាងឆ្វេងទាំងអស់ បានចាត់ទុកខ្ញុំជាមគ្គទេសក៍របស់ពួកគេ តែពេលឥឡូវនេះ ខ្ញុំក្លាយជាសត្រូវពួកគេ ដោយសារការឃោសនារបស់ អៀង សារី ព្រោះតែខ្ញុំនៅស្រឡាញ់ និងនៅតែគាំទ្រព្រះរាជនយោបាយសម្តេច...។ ខ្ញុំអត់ខ្លាចពួកអស់នេះទេ ព្រោះខ្ញុំមានសញ្ជាតិជាខ្មែរផង និងសញ្ជាតិបារាំងផង។ បើពួកគេមិនចង់ឱ្យខ្ញុំនៅបម្រើសម្តេចទេ ខ្ញុំវិលត្រឡប់ទៅប្រទេសបារាំងវិញ ក៏បានដែរ។ នៅក្រុងប៉េកាំង ថៅ សេង និងអៀង សារី មិនដែលនិយាយរកគ្នាម្តងណាទេ តែ អៀង សារី មិនអាចធ្វើអ្វី ថៅ សេង បាន ព្រោះ ថៅ សេង មានសញ្ជាតិបារាំងផង និងលិខិតឆ្លងដែនចេញពីបារាំងផង។

ចាប់ពីឆ្នាំ១៩៧៣ មក បក្ស និងរដ្ឋាភិបាលចិន តែងតែយកចិត្ត និងគាំទ្រ អៀង សារី

និងបក្សពួក ដែលរស់នៅក្នុងសណ្ឋាគារមិត្តភាព។ រីឯខ្មែរសីហានុនិយម ដែលរស់នៅក្នុងរាជដំណាក់វិញ ក្រៅពីសម្តេចសីហនុ អ្នកម្នាង និងព្រះញាតិវង្សមួយចំនួន បក្ស និងរដ្ឋាភិបាលចិន មិនសូវជារវីរវល់ជាមួយប៉ុន្មានទេ! ដោយពេលខ្លះបានលួចហៅពួកសីហនុនិយមថា ពួកអស់នេះសុទ្ធតែជាពួកដេកចាំតែស៊ី។



**សម្តេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ជួបជាមួយ**

**ម៉ៅ សេទុង នៅប៉េកាំង ឆ្នាំ១៩៧០**

---

# ៧.១០. ចៅ សេង និយាយពីការបែកបាក់ក្នុងជួររណសិរ្សរួបរួមជាតិ




ចៅ សេង កើតថ្ងៃទី១៥ ខែមករា ឆ្នាំ១៩២៨ (ខែបុស្ស ឆ្នាំរោង) នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក កម្ពុជាក្រោម។ ជាប្អូនជីដូនមួយរបស់ ចៅ សែនកុសល ឈុំ។ ឪពុកគាត់កើតនៅក្នុងឆ្នាំ១៩០១។ ចំណែកម្តាយគាត់ស្លាប់នៅក្នុងឆ្នាំ១៩៥៣ គឺពេលគាត់កំពុងរៀនសូត្រនៅប្រទេសបារាំង។

ចៅ សេង បានឱ្យដឹងថា គាត់មានបងប្អូន ៦នាក់(ប្រុស៥ ស្រី១) ក្នុងនោះ គាត់ជាកូនច្បងគេ។ ប្អូនប្រុសទី១ មានមុខរបរជាទាហាន ស្លាប់ដោយសារមានជំងឺ នៅក្នុងឆ្នាំ១៩៦៧។ ប្អូនប្រុសទី២ មានមុខរបរជាពេទ្យសត្វ ចេញពីភ្នំពេញ ទៅរស់នៅប្រទេសបារាំង នៅឆ្នាំ១៩៧៣ មានប្រពន្ធជាជនជាតិបារាំង។ ប្អូនទី៣ មិនដឹងថារស់ឬស្លាប់បាត់ដំណឹងយូរហើយ។ តែប្រហែលរស់នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក។

របត់នយោបាយ
ប្អូនប្រុសទី៤ ធ្វើពេទ្យធ្មេញ មានប្រពន្ធជាជនជាតិបារាំង និងរស់នៅប្រទេសបារាំង ក៏មានគ្រួសារបោរាំង ដែរ។ ប្អូនទី៥ ជាប្អូនពៅ (ស្រី) រស់នៅភ្នំពេញ ធ្វើជាមន្ត្រីតូចតាច។

លុះដល់វ័យ ១២ឆ្នាំ គាត់ក៏បានចេញពីស្រុកកំណើត នៅកម្ពុជាក្រោម មកស្នាក់នៅជាមួយបងជីដូនមួយឈ្មោះ ថៅ សែនកុសល ឈុំ និងបានចូលរៀនសូត្រនៅសាលាបឋមសិក្សាទីរួមខេត្តកំពត។ បន្ទាប់មក បងជីដូនមួយនោះ បានឡើងជាភូឈ្មួយខេត្តកំពង់ស្ពឺ គាត់ក៏បានមករៀនសាលាបឋមសិក្សានៅខេត្តកំពង់ស្ពឺ បន្តទៀត។ ដោយសារប្រឡងសញ្ញាបត្រថ្នាក់សាលាបឋមសិក្សាចេះតែធ្លាក់ នៅឆ្នាំ១៩៤៤ គាត់ក៏បានទៅស្នាក់នៅវត្តបទុមវតី ដើម្បីសិក្សានៅសាលាមីស្ស (Ecole Miche) ជាសាលាឈ្នួលនៅភ្នំពេញ ម្តងវិញ។ លុះដល់ឆ្នាំ១៩៤៥ ក៏បានប្រឡងជាប់សញ្ញាបត្រថ្នាក់បឋមសិក្សា ហើយបានចូលរៀនសាលាគរុវិជ្ជា។

ក្រោយរៀនចប់សាលាគរុវិជ្ជា នៅឆ្នាំ១៩៤៩ គាត់បានទទួលអាហារូបករណ៍បានទៅបន្តការរៀនសូត្រនៅសាលាគរុវិជ្ជា នៅទីក្រុងម៉ុងប៉ុល្លីយេ៉ (Montpellier) ប្រទេសបារាំង។

នៅក្នុងឆ្នាំ១៩៥៣ គាត់បានទាក់ស្នេហាជានិស្សិតម្នាក់រៀនជាមួយគ្នា ឈ្មោះ មូនិក សេញី (Mounique Segny) កើតថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៣០ នៅលីយើរ៉ង់លែសបេស៊្បីយេ “ Lieuran-Lès-Bégiers ” ជាកូនទោល ក្នុងគ្រួសារកសិករមួយជាអ្នកដាំទំពាំងបាយជូរ។ ពួកគាត់បានរៀបការជាមួយគ្នានៅក្នុងខែតុលាឆ្នាំ១៩៥៣។ ប្រពន្ធគាត់ក៏ជាសមាជិកនៃចលនាយុវជនយុវនារីកុម្មុយនិស្តបារាំង ប៉ុន្តែដល់ពេលមានកូនក៏បានចេញពីចលនានោះនៅឆ្នាំ១៩៥៥។ ឪពុកក្មេកគាត់បានចូលតស៊ូក្នុងពេលធ្វើសង្គ្រាមជាមួយកងទ័ពអាល្លឺម៉ង់ កាលសម័យសង្គ្រាមលោកលើកទី២ និងបានមកធ្វើជាកសិករដាំទំពាំងបាយជូរ នៅស្រុកកំណើត ពីឆ្នាំ១៩៤៥ រហូតដល់គាត់ស្លាប់នៅឆ្នាំ១៩៧៣។ ចំណែកម្តាយក្មេកគាត់ស្លាប់តាំងពីឆ្នាំ១៩៥៧មកម្ល៉េះ។

នៅក្នុងខែមករា ឆ្នាំ១៩៥៤ គាត់បានកូនស្រីទី១។ នៅក្នុងខែមីនា ឆ្នាំ១៩៥៥

របត់នយោបាយ

គាត់បានកូនស្រីមួយទៀត ជាកូនទី២។ លុះដល់យុវវ័យ កូនស្រី២នាក់ នេះមានគ្រួសារជានិស្សិតដូចគ្នា ក្នុងនោះម្នាក់ជាជនជាតិបារាំង និងម្នាក់ទៀតជាជនជាតិគូវ៉ែត (Kuwait)។ ឪពុកម្ដាយកូនប្រសាទាំង ២នាក់នេះសុទ្ធតែជាពួកនាយទុន។ លុះរៀនចប់នៅសាលាគរុវិជ្ជា គាត់ក៏បានបន្តការសិក្សានៅមហាវិទ្យាល័យអក្សរសាស្ត្រ នៅទីក្រុងម៉ុងប៉ឺល្លីយេ៉ (Montpellier) ដដែលនោះ រហូតទទួលបានសញ្ញាបត្របរិញ្ញាអក្សរសាស្ត្រនៅឆ្នាំ១៩៥៦។ ក្នុងចំណោមនិស្សិតខ្មែរ នៅក្រុងម៉ុងប៉ឺល្លីយេ៉ (Montpellier) ប្រទេសបារាំង គាត់បានទាក់ទងរាប់អានគ្នាជាមួយ អ៊ុច វ៉ែន, ប៉ុក ដឹសកុមារ, សុត និងនារីម្នាក់ឈ្មោះ ចែម សម្ងាត់។ ក្រោយមក ឈ្មោះ សុត នោះបានក្លាយជាកូនប្រសារបស់ទ្រង់ សិរិមតៈ។ ចំណែកនិស្សិតបរទេសវិញ គាត់ទាក់ទងរាប់អានគ្នាតែជាមួយនិស្សិតចម្រើន និងនិស្សិតកុម្មុយនិស្ត ដែលជាអ្នកប្រឆាំងនឹងរបបអាណានិគមនិយមតែប៉ុណ្ណោះ។

នៅចុងឆ្នាំ១៩៥៦ គាត់បាននាំប្រពន្ធ និងកូនស្រីទាំង២ ត្រឡប់មកមាតុភូមិវិញ ហើយបានចូលបម្រើការងារជាសាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ពីឆ្នាំសិក្សា ១៩៥៦-៥៧ និងបានទាក់ទងរាប់អានគ្នាជាមួយ អ៊ុច វ៉ែន និងប៉ុក ដឹសកុមារ បន្តទៀតរហូតមក។ នៅក្នុងឆ្នាំ១៩៥៧ ឪពុកគាត់បាននាំប្អូនៗគាត់រត់ចេញពីស្រុកកំណើត ស្រុកស្វាយទង ខេត្តមាត់ជ្រូក កម្ពុជាក្រោម មករស់នៅទីក្រុងភ្នំពេញ។

ពេលមករស់នៅក្រុងភ្នំពេញ ឪពុកដែលមានវ័យចាស់ជរា និងប្អូនៗទាំង៥នេះ គាត់ជាអ្នករ៉ាប់រងចិញ្ចឹម និងឱ្យបានសិក្សារៀនសូត្រគ្រប់ៗគ្នា។

ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៥៧ គាត់ចូលជាសមាជិកចលនាសង្គមរាស្ត្រនិយម។ ក្នុងខែឧសភា ឆ្នាំ១៩៥៧ ត្រូវបានតែងតាំងជានាយកផ្នែកកិច្ចការនយោបាយទីស្ដីការនាយករដ្ឋមន្ត្រី។ ខែកញ្ញា ឆ្នាំ១៩៥៧ ដដែល ជាអគ្គលេខាធិការទីស្ដីការនាយករដ្ឋមន្ត្រីនាយកគ្រប់គ្រងទូទៅ។ ឆ្នាំ១៩៥៨ ជាតំណាងរាស្ត្រមណ្ឌលភ្នំពេញ។ ក្នុងរាជរដ្ឋាភិបាលទី១០ ដែលមាន ប៉ែន នុត ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី២២ ខែមករា ដល់ថ្ងៃទី២៩

ខែមេសា ឆ្នាំ១៩៥៨) ចៅ សេង ជាអនុរដ្ឋលេខាធិការសិក្សាធិការជាតិ ទទួលបន្ទុកផ្នែកសិក្សាសាធារណៈ កីឡា និងយុវជន។


ចៅ សេង ក្នុងពិធីសមាជជាតិឆ្នាំ១៩៦៧

ក្នុងរាជរដ្ឋាភិបាលទី១១ ដែលមាន ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៨) ជារដ្ឋលេខាធិការក្រសួងសិក្សាធិការជាតិ។ ក្នុងរាជរដ្ឋាភិបាលទី១២ ដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៨ ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៥៩) ជារដ្ឋលេខាធិការក្រសួងសិក្សាធិការជាតិ។

ក្នុងរាជរដ្ឋាភិបាលទី១៣ ដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៥៩ ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៩) ជារដ្ឋលេខាធិការក្រសួងអប់រំជាតិ វិចិត្រសិល្បៈ កីឡា និងយុវជន។ ក្នុងរាជរដ្ឋាភិបាលទី១៥ ដែលមាន ផូ ព្រឿង ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៦០ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦១) ជារដ្ឋមន្ត្រីក្រសួងឃោសនាការជាតិ។ ក្នុងរាជរដ្ឋាភិបាលទី១៦ ដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦១ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៦១) ជារដ្ឋមន្ត្រីព័ត៌មាន។ ក្នុងរាជរដ្ឋាភិបាលទី១៧ ដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៦១ ដល់ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៦២) ជារដ្ឋមន្ត្រីទទួលបន្ទុកឃោសនាការ។ នៅឆ្នាំ១៩៦២ ជាប់ឆ្នោតជាតំណាងរាស្ត្រមណ្ឌលភ្នំពេញ ជាថ្មីម្តងទៀត។ ក្នុងរាជរដ្ឋាភិបាលទី១៩ ដែលមានទ្រង់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៦២ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦៤) ជារដ្ឋមន្ត្រីកសិកម្ម។ ពីឆ្នាំ១៩៥៧មក គាត់មានទំនាក់ទំនងការងារជាមួយ ប៉ែន នុត, ស៊ឹម វ៉ា, សាន យុន នៅពេលដែលអ្នកទាំង៣នាក់នេះ កាន់តំណែងជានាយករដ្ឋមន្ត្រី។ ជាមួយគ្នានោះ គាត់ក៏

របត់នយោបាយ

មានទំនាក់ទំនងជាមួយ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ជាមិត្តភក្តិធ្លាប់រៀននៅប្រទេសបារាំង ជាមួយគ្នា និងក្នុងក្របខ័ណ្ឌជាសមាជិករង្វង់សភាផងដែរ។

ពីខែមករា ឆ្នាំ១៩៦៥ ដល់ខែតុលា ឆ្នាំ១៩៦៦ ជានាយកខុទ្ទកាល័យនៃព្រះប្រមុខរដ្ឋ (សម្តេចសីហនុ) ព្រមទាំងជានិពន្ធនាយកទស្សនាវដ្តីជាភាសាបារាំង កាំប៊ូហ្ស៊ា (KAMBUJA), ឡឺសង្គម(LE SANGKUM), រ៉េអាល់លីតេ កាំបូហ្សៀន (RÉALITÉS CAMBODGIENNES ), ទស្សនាវដ្តីអ្នកជាតិនិយម និងកាសែតឡាដេប៉េស ជាមួយគ្នា អ៊ុច វ៉ែន, ប៉ុក ដឹសកុមារ, រស់ ដេទ្វោ, សូ ណែម, ទេព ឆៀងខែង និងបញ្ញវន្តជំនាន់ក្រោយឈ្មោះ ភោគ ឆាយ ផងដែរ។ នៅឆ្នាំ ១៩៦៦ គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយ ខែក វ៉ាន់ឌី និងសៀន អាន ធ្វើការនៅផ្សាររដ្ឋ។

ពីខែវិច្ឆិកា ឆ្នាំ១៩៦៦ ដល់ខែកញ្ញា ឆ្នាំ១៩៦៧ គាត់ត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សារាជបល្ល័ង្គ។ ក្នុងរាជរដ្ឋាភិបាលទី២៣ ដែលមានសម្តេចសីហនុជានាយករដ្ឋមន្ត្រី (ពីថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៧ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៦៨) ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៦៨ ចៅ សេង ត្រូវបានសម្តេចសីហនុ និងលន់ នល់ ចោទប្រកាន់ថា គាត់ជាប់ពាក់ព័ន្ធជាមួយចលនាតស៊ូរបស់ពួកបះបោរខ្មែរក្រហម។ ដូច្នេះ គាត់ក៏បានបង្ខំចិត្តនាំប្រពន្ធកូនត្រឡប់ទៅរស់នៅប្រទេសបារាំង ជាស្រុកកំណើតរបស់ប្រពន្ធគាត់វិញ។

ក្រោយពេលទៅដល់ប្រទេសបារាំងវិញ គាត់ប្រកបមុខរបរជាអ្នកធ្វើចម្ការជីវភាពជួបការលំបាក មិនអាចរកប្រាក់ចិញ្ចឹមប្រពន្ធ និងកូនស្រីទាំង៤នាក់។

បានគ្រប់គ្រាន់ នៅដើមឆ្នាំ១៩៦៩ គាត់ក៏បានទៅខ្ចីប្រាក់ធនាគារ ដើម្បីពង្រីកដីចម្ការដាំទំពាំងបាយជូរបានជិត២០ហិកតារ។ តែមិនយូរប៉ុន្មាន ដោយសារបញ្ហាជំពាក់ប្រាក់កាសច្រើនពេក ហើយគ្រួសារគាត់មិនអាចរ៉ាប់រងបាន គាត់ក៏សម្រេចចិត្តលក់ចម្ការទំពាំងបាយជូរនោះទៅឱ្យរដ្ឋ ដោយទុកតែចម្ការទំពាំងបាយជូរប្រហែល ១០ហិកតារ ជាកេរតំណែលពីឪពុកក្មេកដែលស្លាប់ទៅហើយ។

របត់នយោបាយ

ក្រោយពីលក់ចម្ការទំពាំងបាយជូរនោះ គាត់ក៏បានព្យាយាមរត់ឯកសារ ចូលសញ្ជាតិជាតិបារាំង ដើម្បីបានចូលជាក្របខ័ណ្ឌសាស្ត្រាចារ្យបារាំង នៅមហាវិទ្យាល័យប៉េពីញ៉ុង។ ជាមួយគ្នានោះ គាត់ក៏បានបន្តការរៀនសូត្របន្តទៀត រហូតបានប្រឡងជាប់សញ្ញាបត្របណ្ឌិតផ្នែកគរុកោសល្យ នៅឆ្នាំ១៩៧០។

ចៅ សេង បានរម្លឹកថា ក្រោយរដ្ឋប្រហារនៅទីក្រុងភ្នំពេញ មួយថ្ងៃ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧០ ឯកអគ្គរដ្ឋទូតបារាំង ប្រចាំក្រុងប៉េកាំង ឈ្មោះម៉ាណាក់ ( Mana'ch ) សុំចូលគាល់សម្ដេចសីហនុ ដើម្បីស្នើសុំព្រះអង្គ កុំឱ្យបង្កើតចលនាតស៊ូអ្វីទាំងអស់។ ជាថ្នូរមកវិញ រដ្ឋាភិបាលបារាំងនឹងទទួលរ៉ាប់រងទាំងអស់ក្នុងជីវភាពរស់នៅរបស់សម្ដេច និងរាជវង្ស ព្រមទាំងអ្នកអមដំណើរមកជាមួយទាំងអស់។ តែការស្នើសុំនេះ មិនបានជោគជ័យឡើយ។ ដោយមានការជំរុញពីសំណាក់មេដឹកនាំចិន និងមេដឹកនាំវៀតណាមខាងជើង នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្ដេចសីហនុ បានយល់ព្រមបង្កើតចលនាតស៊ូមួយមានឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា។ ទោះបីរណសិរ្សរួបរួមជាតិកម្ពុជា មិនទាន់បង្កើតកម្មវិធីគោលនយោបាយអ្វីក៏ពិតមែន ក៏ព្រះអង្គបានប្រកាសអំពាវនាវឱ្យបងប្អូនកូនចៅជនរួមជាតិទាំងនៅក្នុងប្រទេស និងនិស្សិតបញ្ញវន្តខ្មែរក្រៅប្រទេសនាំគ្នាចូលព្រៃម៉ាគី មកចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីតស៊ូរំដោះប្រទេសពីពួកក្បត់ លន់ នល់ ដែលជាអាយ៉ងចក្រពត្តិអាមេរិក។ ពេលនោះ ទីស្នាក់ការរណសិរ្សរួបរួមជាតិកម្ពុជា ស្ថិតនៅសណ្ឋាគារមិត្តភាព ក្រុងប៉េកាំង ប្រទេសចិន មានឥស្សរជនខ្មែរប្រមាណ៥០នាក់ ប៉ុណ្ណោះ។ ពេលនោះ ចិនចំណាយថវិកាយ៉ាងច្រើនឱ្យចៅ សេង ដែលកំពុងរស់នៅក្រុងបារីស ប្រទេសបារាំង រៀបចំរចនាសម្ព័ន្ធដឹកនាំចលនាតស៊ូមួយនៅក្រៅប្រទេស។ នៅពាក់កណ្ដាល ខែមេសា ឆ្នាំ១៩៧០ ទើប ចៅ សេង ទៅធ្វើការជាមួយសម្ដេចសីហនុ និងប៉ែន នុត នៅទីស្នាក់ការរណសិរ្សរួបរួមជាតិកម្ពុជា ស្ថិតនៅក្រុងប៉េកាំង។

ចៅ សេង បានរម្លឹកថា មុនពេលបើកសន្និសីទកំពូលលើកទី២ របស់ប្រជាជន

របត់នយោបាយ

ឥណ្ឌូចិន នៅខេត្តគ័ងទុង ប្រទេសចិន ថ្ងៃទី២៤ និង២៥ ខែមេសា ឆ្នាំ១៩៧០ សម្ដេចសីហនុ និងប៉ែន នុត ចាប់ផ្ដើមមានទំនាស់នឹងគ្នាដោយសារបញ្ហាតែងតាំងសមាសភាពការិយាល័យនយោបាយរណសិរ្សរួបរួមជាតិកម្ពុជាចំនួន៥រូប គឺ ប៉ែន នុត ជាប្រធាន, ខៀវ សំផន, ចៅ សេង, ជួន មុម្ម និងសារិន ឆាក ជាសមាជិក។ សម្ដេចសីហនុស្នើសុំឱ្យដាក់ ហួត សម្បត្តិ ម្នាក់ទៀតជាសមាជិកការិយាល័យនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា តែ ប៉ែន នុត បដិសេធ។ ទំនាស់នេះមិនត្រឹមតែធ្វើឱ្យរាំងស្ទះដល់ដំណើរការបង្កើតការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាប៉ុណ្ណោះទេ គឺធ្វើឱ្យរាំងស្ទះដល់ការបើកសន្និសីទកំពូលលើកទី២ របស់ប្រជាជនឥណ្ឌូចិន (កម្ពុជា វៀតណាម លាវ) នៅខេត្តគ័ងទុង នោះទៀតផង។ ប៉ែន នុត ខឹងនឹងសម្ដេចសីហនុហើយរអ៊ូរទាំថា ការដឹកនាំរបៀបចាស់របស់សម្ដេចសីហនុ នៅតែដដែល។ នៅពេលគណៈប្រតិភូវៀតណាម លាវ មកដល់ខេត្តគ័ងទុង សន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិន ចាប់ផ្ដើមបើកទៅហើយ ប៉ែន នុត ធ្វើពុតជាឈឺ មិនទៅប្រជុំតាមកម្មវិធីដែលបានគ្រោងទុក។ ទាល់តែ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ជួយសម្រុះសម្រួលដោះស្រាយ ទើបសម្ដេចសីហនុ និងប៉ែន នុត ឈប់មានទំនាស់នឹងគ្នា។

ចុងខែមេសា ចៅ សេង បានត្រឡប់ទៅធ្វើជាតំណាងរណសិរ្សរួបរួមជាតិកម្ពុជាមួយរយៈ ទើបគាត់មកធ្វើការនៅក្រុងប៉េកាំងវិញ។ ពេលនោះ គាត់សង្កេតឃើញថាក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង មានការបែងចែកជា ៣ពួក គឺទី១.ពួកសម្ដេចសីហនុ ដែលមាន ហួត សម្បត្តិ, កែវ មាស, ពុង ប៉េងចេង និងកូន កែវ មាស ឈ្មោះ កែវ ឈៀង(កូន កែវ មាស)។ ពួកនេះជាអ្នកចាក់រុកធ្មឹះឆ្កៀល ធ្វើយ៉ាងណាឱ្យសម្ដេចសីហនុ មានទំនាស់ជាមួយមេដឹកនាំខ្មែរក្រហម ពិសេស អៀង សារី តំណាងអង្គការតស៊ូនៅក្នុងប្រទេស។

ទី២.គឺពួក ប៉ែន នុត ដែលមាន សារិន ឆាក, វ៉ាន់ ពីនី, ជា សាន, ចាន់ យូរ៉ាន់... ជាពួកបត់បែនតាមសភាពការណ៍ជាក់ស្ដែង ដើម្បីផលប្រយោជន៍ពួកគេ។

របត់នយោបាយ

ទី៣.គឺពួកចម្រើន ដែលមាន ជួន មុម្ម, ជួន ប្រាសិទ្ធ, គាត ឈន់ និងថៅ សេង ជាដើម...។ ពួកនេះបានភ្ជាប់ខ្លួននឹងចលនាតស៊ូក្នុងប្រទេសតាមការណែនាំរបស់ អៀង សារី ជាតំណាងអង្គការតស៊ូនៅក្នុងប្រទេស។

ទំនាស់បែកបាក់ផ្ទៃក្នុងរណសិរ្សរួបរួមជាតិកម្ពុជា នៅក្រៅប្រទេសរបស់បក្ខពួកទាំង៣ក្រុមនេះ គឺបញ្ហាមុខមាត់ បុណ្យស័ក្តិ ប្រាក់កាស តែងតាំងទូត បុគ្គលិកទូត។ តែបើគ្មាន អៀង សារី ជាតំណាងអង្គការតស៊ូនៅក្នុងប្រទេស ទៅធ្វើការនៅក្រុងប៉េកាំង ណែនាំអប់រំបំពាក់បំប៉នកំណត់មាគ៌ានយោបាយជាយុទ្ធសាស្ត្រ យុទ្ធវិធីនោះទេ រណសិរ្សរួបរួមជាតិនៅខាងក្រៅប្រទេស ក៏គ្មានន័យអ្វីដែរ។



**សម្តេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងប៉ែន នុត ទស្សនារោងចក្រ នៅក្រុងប៉េកាំង ឆ្នាំ១៩៧០**

# ៧.១១.សួង ស៊ីគឿន ចូលចិត្តរឿងនយោបាយ តាំងពីរៀននៅអនុវិទ្យាល័យ



សួង ស៊ីគឿន កើតនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៣៧ នៅភូមិជ្រោយអំពិល ឃុំចំបក់ ស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ ជនជាតិខ្មែរ។ ឪពុកឈ្មោះ នូ កាន កើតនៅភូមិឫស្សីកែវ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ វណ្ណៈភាពកសិករថ្នាក់កណ្តាល។ ឪពុករបស់គាត់បានស្លាប់នៅក្នុងឆ្នាំ១៩៣៧ នៅពេល សួង ស៊ីគឿន ទើបតែអាយុ៣ខែ។ ក្រោយពីឪពុកគាត់ស្លាប់ទៅ ពីមួយឆ្នាំទៅមួយឆ្នាំ ជីវភាពរស់នៅរបស់គ្រួសារគាត់ចេះតែចុះដុនដាបទៅៗ ម្តាយត្រូវខ្ចីបុលប្រាក់គេ ដើម្បីចិញ្ចឹមជីវិតផង និងដើម្បីផ្គត់ផ្គង់ឱ្យគាត់

រៀនសូត្រផង។ មិនតែប៉ុណ្ណោះ មានពួកចោរព្រៃជាដៃជើងបារាំង និងពួកទាហានចុះរាតត្បាតរំអែង្គាស ព្រមទាំងទារពន្ធសព្វសារពើ មានទាំងវិភាគទានសម្រាប់កំចាត់អសន្តិសុខ។ នៅឆ្នាំ១៩៤៥ ពេលពួកយោធានិយមជប៉ុន ចូលឈ្លានពានប្រទេសកម្ពុជា ប្រជាជននៅក្នុងភូមិគាត់ដាច់បាយរយៈពេល៦ខែ ហូបតែក្ដួច និងពោត ហើយត្រូវពួកហ្វាស៊ីសជប៉ុន កែនយកទៅធ្វើបន្ទាយនៅទីរួមខេត្តក្រចេះ កើតជំងឺអាសន្នរោគស្លាប់អស់ជាច្រើននាក់។

ជីតាខាងឪពុកគាត់ ឈ្មោះ តាសួង ធ្វើអាចារ្យវត្ត។ ម្ដាយគាត់ ឈ្មោះ នូ រ៉េន នៅភូមិជ្រោយអំពិល ឃុំចំបក់ ស្រុកព្រែកប្រសព្វ។ ជីតាខាងម្ដាយ ឈ្មោះ តានូ ជាភ្នាក់ងាររដ្ឋអំណាចសក្ដិភូមិ ជំនាន់នោះ គេហៅគាត់ថា បាឡាត់នូៗ។ បងបង្អស់របស់ម្ដាយគាត់ឈ្មោះ នូ ឈុំ ជាមេឃុំចំបក់ ក្នុងស្រុកព្រែកប្រសព្វ។ បន្ទាប់ពីជប៉ុនបរាជ័យមានកើតចលនាចោរព្រៃ ដែលបង្កបង្កើតអសន្តិសុខ នៅពេញស្រុកភូមិគាត់។ ក្នុងរយៈពេលនេះ បងប្រុសម្ដាយគាត់ម្នាក់ និងប្អូនប្រុសឪពុកគាត់ម្នាក់ ត្រូវពួកចោរព្រៃចាប់យកទៅសម្លាប់ចោល។ ឆ្នាំ១៩៤៥ ពេលចូលរៀនសាលាជាលើកដំបូង គាត់ចាប់អារម្មណ៍ខ្លះៗពីបញ្ហាជាតិ និងអំពីការជិះជាន់របស់ពួកអាណានិគមនិយមបារាំង តាមរយៈការឃោសនារបស់ពួកឈ្មួញកប្បាស ជាភ្នាក់ងារពួកប្រជាធិបតេយ្យ ដែលចុះពីទន្លេតូចព្រែកចង្ក្រាន មកដល់ភូមិស្រុករបស់គាត់។

នៅឆ្នាំ១៩៤៧ គាត់បានទៅរៀនសាលាបឋមសិក្សានៅទីរួមស្រុកឆ្លូង ត្រូវពួកគ្រូបង្រៀនចាត់តាំងបានចូលជាក្រុមឃោសនាចល័ត សម្រាប់អង្គាសប្រាក់ឱ្យគណបក្សប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៤៩ គាត់បានឡើងមករៀននៅអនុវិទ្យាល័យសីហនុ នៅក្រុងកំពង់ចាម។ ចាប់ពីពេលនោះមក គាត់បានចូលរួមសកម្មភាព ក្នុងគណបក្សប្រជាធិបតេយ្យ ដោយម្យ៉ាងគាត់យល់ថា គណបក្សនេះជាអ្នកស្នេហាជាតិ និងជាអ្នកស្អាតស្អំ គាត់គោរពស្រឡាញ់ទ្រង់ យុត្តិវង្ស និងអៀវ កើស។ ម្យ៉ាងទៀតគាត់យល់ថាបក្សនេះប្រឆាំងនឹងរបបរាជាធិបតេយ្យ ដែលគាត់ស្អប់ខ្ពើម ព្រោះរបបរាជាធិបតេយ្យ

របត់នយោបាយ

ទទួលឥទ្ធិពលពីពួកអាណានិគមនិយមបារាំង។ នៅឆ្នាំ១៩៥១ គាត់បានចូលរួមយ៉ាងសកម្មក្នុងការធ្វើកូដកម្មប្រឆាំងរបបអាណានិគមនិយម និងរបបរាជាធិបតេយ្យជាបន្តបន្ទាប់នៅក្រុងកំពង់ចាម។ នៅឆ្នាំ១៩៥២ គាត់បានចូលរួមធ្វើបាតុកម្មពីរលើក និងត្រូវពួកប៉ូលិស និងទាហានមកបង្ក្រាបយ៉ាងសាហាវបំផុតនៅក្រុងកំពង់ចាម។

អំឡុងពេលកំពុងសិក្សានៅអនុវិទ្យាល័យសីហនុ នៅក្រុងកំពង់ចាម ក្នុងឆ្នាំ១៩៥២ ជាញឹកញាប់ ពេលយប់គាត់តែងឆ្លៀតឱកាសទៅលេងនៅទីក្រុងភ្នំពេញ ដោយស្នាក់នៅផ្ទះឪពុកធំម្នាក់ ដែលត្រូវជាបងរបស់ម្ដាយគាត់។ ចាប់ពីពេលនោះមក គាត់ក៏បានទទួលឥទ្ធិពលពីពួកប្រជាចលនាឥស្សរៈរួមខ្មែរបម្រើជាតិរបស់ សឺង ង៉ុកថាញ់ ផងដែរ។ ដោយគាត់យល់ច្រឡំថា ក្រុម សឺង ង៉ុកថាញ់ នេះជាក្រុមម៉ាក្សនិយមចង់ឱ្យប្រទេសយើងទៅសង្គមនិយមដែរ តែឯករាជ្យពីយួន។ លុះដល់ប្រាស្រ័យទាក់ទងជាមួយពួកនេះទៅ ឃើញថា ពួកវាវាយបំបែកផ្ទៃក្នុងជាតិឯង វាយប្រហារពួកបញ្ញាជនចម្រើន និងក្រុមប្រជាជន តែពួកវាមិនវាយចក្រពត្តិអាមេរិកទេ ដោយយកលេសថា បើវាយអាមេរិកខ្លាចអាមេរិក បែរទៅជួយសង្គមរាស្ត្រនិយមវិញ។ ម្យ៉ាងទៀត ដោយឃើញថា អ្នកដឹកនាំក្រុមនេះ ដូចជា ហង្ស ធុនហាក់ និងគាំ រ៉េត ជាដើម ជាពួកពាលាអាវាសែ និងគ្មានសមត្ថភាព។ ហង្ស ធុនហាក់ និងគាំ រ៉េត លើកតម្កើង សឺង ង៉ុកថាញ់ និងអៀ ស៊ីចូវ ដូចជាព្រះ។ ពួកវាមិនដែលនិយាយពីវីរភាពរបស់មហាជន និងប្រជាជនឡើយ។ នេះជាទស្សនៈរបៀបហ្វាស៊ីស មើលងាយមហាជន ប្រជាជន។ ចំពោះបញ្ហាសាមគ្គីភាពក្នុងប្រជាជាតិ គាត់ឃើញពួកអ្នកចម្រើន (ពួកកុម្មុយនិស្តនិយម) មានទស្សនៈទូលាយ មិនចង្អៀតចង្អល់ មានមាគ៌ា ជាយុទ្ធវិធីប្រមូលកម្លាំងឱ្យបានច្រើនជាអតិបរមា ហើយមិនចេះតែវាយខ្មាំងទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ប៉ាតណាប៉ាតណីនោះទេ។ ពួកអ្នកចម្រើន (ពួកកុម្មុយនិស្តនិយម) បានឃើញគ្រោះអាសន្ននៃចក្រពត្តិអាមេរិក ដែលត្រូវតែប្រមូលកម្លាំងប្រជាជាតិទាំងមូល ដើម្បីទប់ទល់។ ឯពួកប្រជាចលនា (ប្រជាចលនាឥស្សរៈរួមខ្មែរបម្រើជាតិរបស់ សឺង ង៉ុកថាញ់) វិញ វាមិនដែលនិយាយថា

របត់នយោបាយ
សហរដ្ឋអាមេរិក ជាគ្រោះថ្នាក់ដល់ប្រជាជាតិយើងទេ។ វាយកបញ្ហារបបគ្រប់គ្រងប្រទេសតាមបែបរាជាណាចក្រ ឬសាធារណរដ្ឋ មកធ្វើជាកម្មវត្ថុឃោសនារបស់វា។ មួយវិញទៀត វាប្រមាថមើលងាយប្រជាជនយើង ពិសេសកសិករក្រីក្រថា មិនងាយភ្ញាក់រលឹកទេ ឱ្យសីហនុ អូសទាញបាន។ ក្រៅពីនេះពួកវាហ្វាស៊ីសណាស់ អ្នកណាមានមតិមិនដូចវា វាដាក់ផ្លាកថា ជាខ្ញុំកញ្ជះយួនភ្លាម។

សួង ស៊ីគឿន បានរម្លឹកថា នៅក្នុងខែធ្នូ ឆ្នាំ១៩៥៣ សម្តេចសីហនុ យាងទៅក្រុងកំពង់ចាម ដើម្បីបញ្ចប់យុទ្ធនាការឃោសនាបោកប្រាស់ថា បានទាមទារឯករាជ្យពីបារាំង ក្នុងឱកាសនោះ ក្រុមប្រជាចលនាបានរៀបចំផែនការសម្លាប់ សីហនុ។ ពួកវាបានចាត់តាំងក្រុមភេរវកម្មប្រដាប់អាវុធ ដោយជ្រើសរើស ក្នុងចំណោមសិស្សវិទ្យាល័យកំពង់ចាម។ គាត់មិនបានចូលជាសមាជិកក្រុមនេះទេ តែក្រុមនេះបានចាត់តាំងឱ្យគាត់ដើរបោះខិត្តប័ណ្ណប្រឆាំងនឹងសីហនុ នៅក្នុងពេលយប់។ រយៈពេលពីរបីថ្ងៃ មុនពេលសម្តេចសីហនុ យាងទៅដល់ក្រុងកំពង់ចាម ក្រុមភេរវកម្មនេះបានហៅគ្នាវាមកជុំគ្នាផឹកស៊ីនិយាយឡូឡា ហើយយកកាំភ្លើងទៅបាញ់សត្វ ពេលសម្រាកថ្ងៃត្រង់ក្នុងសាលា នាំឱ្យបែកការណ៍ដល់ភ្នាក់ងារគិញ ដែលជាសិស្សដូចគ្នា។ ក្រុមនេះត្រូវប៉ូលិសចាប់បានទាំងអស់ មុនពេលសម្តេចសីហនុ យាងទៅដល់ក្រុងកំពង់ចាម ១ថ្ងៃ។ គាត់ក៏មានឈ្មោះនៅក្នុងបញ្ជីដែលត្រូវចាប់ខ្លួនដែរ។ នៅពេលយប់ ពួកប៉ូលិសចូលទៅដល់អន្តេវាសិកដ្ឋាននៅក្នុងវិទ្យាល័យកំពង់ចាម ដើម្បីឆែកឆេររកអាវុធ គាត់ក៏បានរត់គេចខ្លួនចេញពីវិទ្យាល័យ។ លុះព្រឹកឡើង គាត់ក៏ឡើងជិះកប៉ាល់ដឹកធ្យូង មកលាក់ខ្លួននៅក្រុងភ្នំពេញ ដោយបានស្នាក់នៅជាមួយឪពុកមាជីដូនមួយគាត់ម្នាក់ ដែលធ្លាប់បួសរៀនជាមួយ សឺង ង៉ុកមិញ។ ៦ខែក្រោយមក ឪពុកមាជីដូនមួយនោះបានបបួលគាត់ឱ្យទៅចូលរួមតស៊ូជាមួយក្រុម នរោត្តម ចន្ទរង្សី និងចាន់ តោត្រេស នៅខេត្តកំពង់ស្ពឺ។ តែមិនយូរប៉ុន្មាន ចន្ទរង្សី ក៏បានដាក់អាវុធ ចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្តេចសីហនុ។

របត់នយោបាយ

ក្នុងរយៈពេលរស់នៅជាមួយក្រុមចន្ទរង្សីនេះ គាត់គ្មានភារកិច្ចអ្វីទេ គឺរស់នៅក្នុងសភាពរង់ចាំលទ្ធផលនៃកិច្ចប្រជុំក្រុងហ្សឺណែវ ប៉ុណ្ណោះ។ ពេលនោះ គាត់ក៏បានស្គាល់ស័ក្តិ៣ជប៉ុនម្នាក់ ឈ្មោះ តាដាគូម៉ា (TADAKUMA) ដែលជាទីប្រឹក្សារបស់ ចន្ទរង្សី។

ពេលក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ទើបគាត់ដឹងថា ស័ក្តិ៣ជប៉ុនម្នាក់នោះជាមេចារកម្មរបស់ជប៉ុន និងជាភ្នាក់ងារសេអ៊ីអារបស់អាមេរិក។ ក្រោយលទ្ធផលនៃកិច្ចប្រជុំក្រុងហ្សឺណែវ គាត់បានចាកចេញពីចលនាតស៊ូចន្ទរង្សី ទៅធ្វើជាសមាជិកសកម្មនៃបក្សប្រជាធិបតេយ្យ និងក្រុមប្រជាជន ក្នុងសម័យបោះឆ្នោត ឆ្នាំ១៩៥៥។

នៅក្នុងឆ្នាំ១៩៥៥នោះ ឪពុកធំឈ្មោះ នូ ឈុំ ដែលបានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្ររបស់គណបក្សសេរីភាព ដែលមាន សុស្តែន ហ្វែរណង់ដេស ជាមេខ្លោងតាំងពីឆ្នាំ១៩៤៧មក បានឈរឈ្មោះជាថ្មីម្តងទៀត។ ពេលនោះ ឪពុកធំម្នាក់នេះបានក្លាយជាគូបដិបក្ខជាមួយគាត់ ព្រោះគាត់ជាសមាជិកសកម្មនៃបក្សប្រជាធិបតេយ្យ និងក្រុមប្រជាជន។

សួង ស៊ីគឿន បានរម្លឹកថា នៅពាក់កណ្តាលឆ្នាំ១៩៥៦ ដោយចង់ភ្ជាប់ខ្លួនទៅចលនាចម្រើនចលនាសង្គមនិយម ហើយចង់រៀនសូត្រទ្រឹស្តីម៉ាក្ស-ឡេនីន គាត់សុំ មិត្ត សុក ខ្នុល ចូលជាសមាជិកក្នុងក្រុមម៉ាក្សនិយមខ្មែរដែរ។ តែលើកទី១ មិត្ត សុក ខ្នុល ហៅពាម ថា មិនដឹងទេ? លុះសុំចូលលើកទី២ មិត្ត សុក ខ្នុល ក៏នៅតែឆ្លើយថា មិនដឹងដដែល (ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៨ សុក ខ្នុល ហៅសមមិត្ត ពាម ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគបូព៌ា និងជាប្រធានមន្ទីរភូមិភាគបូព៌ា)។ ប៉ុន្តែ ប៉ុន្មានថ្ងៃក្រោយមក អៀង សារី បានមកលេង និងសួរសុខទុក្ខគាត់ ហើយបានស្នើឱ្យគាត់ជួយសរសេរអត្ថបទ « នាទីអន្តរជាតិ » សម្រាប់កាសែតឯកភាព ដែលមាន ពឹង សយ ជាចាងហ្វាង។

មួយរយៈក្រោយមក អៀង សារី បានប្រាប់គាត់ឱ្យទៅប្រជុំនៅផ្ទះឈ្មោះ វ៉ង់ (អ៊ំ ណេង) មានឋានៈជាជនបង្គោល នៅពេលយប់។ ពេលទៅដល់ផ្ទះនោះ គាត់ឃើញមានឈ្មោះ នុត ប៉ាណារ៉ា, តាក ហេង, ហ៊ូ យន់ និងវ៉ង់ ជាម្ចាស់ផ្ទះ។ ក្រុមគាត់ទាំង៥នាក់

របត់នយោបាយ
ក៏បានចូលរួមប្រជុំជាមួយគ្នារាល់អាទិត្យ ដោយមានឈ្មោះ ហ៊ូ យន់ ជាប្រធាន ហើយពេលខ្លះក៏មាន អៀង សារី ចូលរួមដែរ។ បន្ទាប់មក ក្រុមនេះក៏បែកគ្នា ហើយគាត់ចូលមកប្រជុំជាមួយក្រុមថ្មីមួយទៀតនៅសាលាចម្រើនវិជ្ជា វិញ។ ក្រុមថ្មីរបស់គាត់នោះរួមមាន៖ នុត ប៉ាណារ៉ា, ស៊ាត ឆៃ (ហៅទុំ) ណៃ សារ៉ាន់ (ម៉ែន សាន ហៅយ៉ា) ដោយមាន អៀង សារី ជាប្រធានប្រជុំ។ ពេលនោះ គាត់ទទួលភារកិច្ចទាក់ទងយកការណ៍ពី គាំ រ៉េត ទៅរាយការណ៍ឱ្យ អៀង សារី រាល់អាទិត្យ។ គាត់បន្តបង្រៀននៅសាលាចម្រើនវិជ្ជា និងបន្តរួមសកម្មភាពបដិវត្តន៍រហូតដល់ថ្ងៃ១៧ ខែតុលា ឆ្នាំ១៩៥៧ គាត់បានទទួលអាហារូបករណ៍ ទៅរៀនវិជ្ជាបច្ចេកទេសទូរគមនាគមន៍ខាងយន្តហោះ នៅទីក្រុងប៉ារីស ដោយសារមានការជ្រោមជ្រែងពីឪពុកមាគាត់ម្នាក់ឈ្មោះ អ៊ុល ចុន ដែលពេលនោះរស់នៅទីស្នាក់ការសមាគមអតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ជាមួយគាត់។ គោលបំណងទៅរៀននេះ គឺដើម្បីចង់រៀនសូត្រពីទ្រឹស្ដីម៉ាក្ស-ឡេនីន និងស្គាល់ចលនាបដិវត្តន៍ និងកុម្មុយនិស្តនៅអឺរ៉ុប ពិសេសនៅប្រទេសបារាំង។ ម្យ៉ាងគាត់ក៏ចង់ស្គាល់ និងចូលរួមសកម្មភាពជាមួយនិស្សិត និងបញ្ញាជនម៉ាក្សនិយមកម្ពុជា នៅប្រទេសបារាំង នោះដែរ។ ឪពុកមាគាត់ឈ្មោះ អ៊ុល ចុន ខំរកប្រាក់កាសទិញខោអាវឱ្យគាត់ទៅរៀននៅប្រទេសបារាំង។ មុននឹងចេញដំណើរ អៀង សារី បានហៅនិសិស្សិតទាំងអស់ដែលត្រូវទៅរៀននៅប្រទេសបារាំង  ទៅលេងផ្ទះដើម្បីណែនាំ និងផ្ដាំផ្ញើពីបញ្ហារស់នៅ ពីបញ្ហាទិសដៅដែលត្រូវទៅបន្តវិជ្ជានេះ ព្រមទាំងបញ្ហារួមកម្លាំងនិស្សិតស្នេហាជាតិទាំងអស់ ប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវារ។ បន្ទាប់មក ក៏មានរៀបចំពិធីជប់លៀងមួយ ដោយមាន សុន សេន និងហ៊ូ យន់ ចូលរួមដែរ ហើយ ហ៊ូ យន់ ក៏បានឱ្យលុយគាត់ ៥០០រៀល។

លុះដល់ថ្ងៃចេញដំណើរ អៀង សារី បានប្រគល់ឯកសារសម្ងាត់មួយឱ្យគាត់យកទៅប្រគល់ឱ្យ ខៀវ សំផន នៅក្រុងប៉ារីស ដោយផ្ទាល់ដៃ។ ឯកសារសម្ងាត់នោះ គាត់បានយកទៅឱ្យ ខៀវ សំផន ដោយផ្ទាល់ដៃនៅមន្ទីរពេទ្យបុរីអន្តរជាតិ ក្រុងប៉ារីស ខណៈខៀវ សំផន ចូលសម្រាកនៅមន្ទីរពេទ្យនោះបានមួយថ្ងៃ ក្រោយគាត់ទៅដល់ប្រទេស

បារាំង។ ពីរ-បីថ្ងៃក្រោយមក ខៀវ សំផន បានប្រាប់គាត់ថា គាត់ត្រូវបានទទួលស្គាល់ជាសមាជិកមណ្ឌលម៉ាក្ស-ឡេនីន នៅប្រទេសបារាំង តាមសំណូមពររបស់គាត់ហើយ។ ពេលនោះ គណៈកម្មការដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន រួមមាន ខៀវ សំផន, ជួន មុម្ម, អ៊ិន សំបុក, និងអ៊ិន សូកាន (នៅធ្វើការក្រុងឡីយ៉ុង)។ ជាមួយគ្នានេះ គាត់ក៏បានចូលជាសមាជិកសកម្មនៃសមាគមសហភាពនិស្សិតខ្មែរផងដែរ។ ភារកិច្ចរបស់គាត់ គឺឃោសនាកៀងគរនិស្សិត និងកម្មសិក្សាការីកម្ពុជា ឱ្យឃើញពីគ្រោះអាសន្ននៃចក្រពត្តិអាមេរិក និងពួកប្រតិកិរិយាក្នុងប្រទេសជាដៃជើងវា រួមមាន សម សារី, ម៉ៅ សាយ, លន់ នល់ និងញឹក ជូឡុង។ ជាមួយនេះ គាត់ធ្វើយ៉ាងណាឱ្យពួកគេមកចូលរួមសកម្មភាព ឬចូលជាសមាជិកសមាគមសហភាពនិស្សិតខ្មែរ ទៀតផង។

សួង ស៊ីគឿន បានរម្លឹកបន្តថា ក្នុងអំឡុងឆ្នាំ១៩៥៧ និង ឆ្នាំ១៩៥៨ គាត់ទទួលឥទ្ធិពលពីការអប់រំរបស់ ខៀវ សំផន ច្រើនណាស់ ព្រោះ ខៀវ សំផន យកចិត្តទុកដាក់អប់រំគាត់ផ្ទាល់។ គាត់បានរៀនសូត្រពី ខៀវ សំផន នូវស្មារតីលះបង់ទ្រាំទ្រការលំបាកឈឺថ្កាត់ និងដាក់ខ្លួនក្នុងមហាជន។ ចុងឆ្នាំ១៩៥៨ ខៀវ សំផន ក៏បានត្រឡប់មកមាតុប្រទេសវិញ។ ជួន មុម្ម ជាអ្នកទទួលខុសត្រូវគណៈកម្មការដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន បន្ត។ នៅឆ្នាំ១៩៥៨នោះដែរ គាត់បានចូលជាសមាជិកនៃបក្សកុម្មុយនិស្តបារាំង និងបានប្រឡងជាប់បាសូទី២ (បាក់ឌុប) នៅក្រុងប៉ារីស។ ពេលនោះដែរ គាត់ក៏បានរួមចំណែកសរសេរ និងបោះពុម្ពផ្សាយទស្សនាវដ្តីសម្ងាត់មួយ ឈ្មោះ «រស្មី»។

ឆ្នាំ១៩៥៩ នោះដែរ សួង ស៊ីគឿន បានទៅចូលរួមមហោស្រពរបស់យុវជន និងនិស្សិតនៅទីក្រុងវីយែន ប្រទេសអូទ្រីស ក្នុងនាមសមាជិកគណៈប្រតិភូសហភាពនិស្សិតខ្មែរ ដោយមាន អ៊ិន សូកាន ជាអ្នកដឹកនាំ។ ពេលនោះ ក៏មានប្រតិភូយុវជនរាជសង្គមរាស្ត្រនិយមខ្មែរ មកពីប្រទេសកម្ពុជា ដឹកនាំដោយ យឹម ឌិត ទៅចូលរួមមហោស្រពរបស់យុវជន និងនិស្សិតនោះដែរ។ គណៈប្រតិភូសហភាពនិស្សិតខ្មែរ និងគណៈប្រតិភូយុវជនរាជសង្គមរាស្ត្រនិយមខ្មែរ បានរួមបញ្ចូលគ្នាជាគណៈប្រតិភូកម្ពុជា

របត់នយោបាយ

តែមួយ ដឹកនាំដោយ យឹម ឱត និងមាន អ៊ិន សូកាន ជាទីប្រឹក្សា។ ក្រោយពីបានទៅចូលរួមមហោស្រពនេះ អ៊ិន សូកាន និងគាត់ ក៏បានទៅចូលរួមមហាសន្និបាតសហភាពអន្តរជាតិ នៅទីក្រុងប្រាក ប្រទេសឆេកូស្លូវ៉ាគី។ នៅឱកាសនោះ ទំនាស់រវាងចិន និងពួកសេរីវ៉ េ ចាប់ផ្ដើមខ្លះៗហើយ។ ចុងឆ្នាំ១៩៥៩ ក្រោយពី អ៊ិន សូកាន ត្រឡប់មកមាតុប្រទេសវិញ គាត់ត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មការ ដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន ជាមួយ ជួន មុម្ម, ទុន ជោតស៊ីរិន និងតូច ខាំឌឿន។

នៅឆ្នាំ១៩៦០ ក្រោយពីសន្និសីទសកលលោកនៃបក្សកុម្មុយនិស្ត និងបក្សពលករចំនួន៨១ នៅមូស្គូ មណ្ឌលម៉ាក្ស-ឡេនីន បានបើកវគ្គសិក្សារៀនសូត្រឯកសារសេចក្ដីថ្លែងការណ៍នៃសន្និសីទនេះ។

ក្នុងឆ្នាំ១៩៦២ មណ្ឌលម៉ាក្ស-ឡេនីន បានឱ្យគាត់ដឹកនាំគណៈប្រតិភូសហភាពនិស្សិតខ្មែរ ដែលបានទៅចូលរួមមហោស្រពសកលលោកនៃយុវជន និងនិស្សិត នៅក្រុងហែលស៊ីនគី ប្រទេសហ្វាំងឡង់។ បន្ទាប់មក គាត់បានទៅចូលរួមមហាសន្និបាតសហព័ន្ធសកលលោកនៃយុវជនប្រជាធិបតេយ្យនៅក្រុងវ៉ាស្សូវី ប្រទេសប៉ូឡូញ។

ពេលនោះ ក្នុងសុន្ទរកថារបស់គណៈប្រតិភូសហភាពនិស្សិតខ្មែរ បានសរសេរថា៖ « ពិសោធន៍នៅកម្ពុជា បង្ហាញថា ការរួមរស់ដោយសន្តិភាព គឺជាការអនុគ្រោះដល់ការតស៊ូរបស់ប្រជាជនប្រឆាំងអំពើជ្រៀតជ្រែក វិទ្ធង្សនា និងឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារ ដើម្បីឯករាជ្យ សន្តិភាព អព្យាក្រឹត និងដើម្បីកែប្រែជីវភាពប្រជាជន » ដែលនេះជាការឆ្លុះបញ្ចាំងនូវទស្សនៈសេរីវ៉េដែលទាក់ទិននឹងបញ្ហាកម្ពុជា។

ចាប់ពីឆ្នាំ១៩៦៣មក គាត់កាន់តែមានទស្សនៈគាំទ្រលទ្ធិសេរីវ៉េនិយម រហូតដល់ស្នើឱ្យគណៈកម្មការដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន សរសេរលិខិតមួយផ្ញើទៅគាំទ្រគោលជំហរសូវៀត ដែលប្រឆាំងនឹងចិន។ តែសមាជិកមណ្ឌលម៉ាក្ស-ឡេនីន ភាគច្រើន មិនយល់ស្របតាមគាត់ឡើយ។

ដោយមានទំនាស់ជាបុគ្គលផង និងទំនាស់ក្នុងការដឹកនាំផង ក្នុងនោះទំនាស់

ខ្លាំងជាងគេ គឺនៅក្នុងឆ្នាំ១៩៦២ ពេលទៅចូលរួមមហាសន្និបាតសហភាពអន្តរជាតិនិស្សិតនៅក្រុងមូស្គូ តូច ខាំឡឿន ប្រធានសហភាពនិស្សិតខ្មែរ បានសម្រេចបញ្ចូលសហភាពនិស្សិតខ្មែរនេះ ជាសមាជិកសហភាពអន្តរជាតិនិស្សិតនោះ ដោយគ្មានសួរយោបល់ពីសមូហភាពដឹកនាំ។ ទំនាស់មួយទៀត គឺ នៅក្នុងឆ្នាំ១៩៦៥ ទុន ជោតស៊ីរិន ទៅសម្រាកក្នុងមន្ទីរពេទ្យនៅតំបន់ខាងត្បូងប្រទេសបារាំង ស្រាប់តែគេចូលធ្វើការក្នុងវិទ្យាស្ថានស្រាវជ្រាវរបស់បារាំង ដោយគ្មានប្រាប់គណៈកម្មការដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន បន្តិចសោះ។ គាត់យល់ថា ការប្រព្រឹត្តិបែបនេះ គឺជាការរំលោភលើលក្ខការណ៍ចាត់តាំងរបស់មណ្ឌលម៉ាក្ស-ឡេនីន។ តែ ជួន មុម្ម មិនបានចាត់វិធានការអ្វីបន្តិចសោះ ចំពោះ ទុន ជោតស៊ីរិន។ គាត់មិនឯកភាពលើអាកប្បកិរិយាសម្រុះសម្រួលរបស់ ជួន មុម្ម នោះទេ។ នៅឆ្នាំ១៩៦៦ ដោយសារទំនាស់ទាំងអស់នេះ គាត់បានសុំលាចេញពីជួរដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន។ ដូច្នេះ គណៈកម្មការដឹកនាំមណ្ឌលម៉ាក្ស-ឡេនីន នៅសល់តែ ជួន មុម្ម, ទុន ជោតស៊ីរិន និងតូច ខាំឡឿន ប៉ុណ្ណោះ។

សួង ស៊ីគឿន បានរម្លឹកថា ពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៦ ជារយៈកាលដែលឥទ្ធិពលសេរីនិយមមកគ្របដណ្តប់ ធ្វើឱ្យទស្សនៈ និងគោលជំហរចំពោះខ្មាំងជាចក្រពត្តិ និងខ្មាំងវណ្ណៈប្រឫកប្រឫល់។ ពេលនោះ គាត់យល់ឃើញថា ចក្រពត្តិអាមេរិក និងបរិវារ គឺពួក ម៉ៅ សាយ, លន់ នល់ និងញឹក ជូឡុង នៅតែជាសត្រូវស្លាប់រស់របស់ប្រជាជាតិ និងប្រជាជនខ្មែរ។ តែមាគ៌ាដោះស្រាយទំនាស់ស្លាប់រស់នេះ នៅតែមិនច្បាស់លាស់។ គាត់គិតថា សីហនុ គ្មានសមត្ថភាពដឹកនាំប្រទេសឡើយ គឺមានតែបក្សម៉ាក្ស-ឡេនីនទេ អាចដឹកនាំប្រទេសបាន។ ប៉ុន្តែបញ្ហាទំនាស់ជាមួយចក្រពត្តិ និងបរិវារផ្ទៃក្នុង អាចដោះស្រាយបានដោយជំរុញរដ្ឋអំណាចសីហនុ ឱ្យទប់ទល់ និងប្រឆាំងឧបាយកលជ្រៀតជ្រែកឈ្លានពាន និងវិទ្ធង្សនារបស់ចក្រពត្តិអាមេរិក និងពួកអាក្បត់ជាបរិវារ។

សួង ស៊ីគឿន បានរម្លឹកបន្ថែមថា នៅក្នុងឆ្នាំ១៩៦២ គាត់មិនបានអាន មិនបានដឹងពីទស្សនៈ និងគោលជំហររបស់បក្សឡើយ។ ការពិត ឯកសារជាទស្សនៈ និង

របត់នយោបាយ

គោលជំហររបស់បក្ស បក្សបានផ្ញើទៅឱ្យគាត់បានអានបានដឹងដែរ តែពេលនោះ ជួន មុម្ម អ្នកទទួលខុសត្រូវមណ្ឌលម៉ាក្ស-ឡេនីន មិនបានផ្សព្វផ្សាយឱ្យគាត់បានដឹង និងបានយល់ទេ។ ពេលខ្លះ គាត់ភ្លាប់បានថា បក្សបានផ្ញើឯកសារនោះ ទៅឱ្យមណ្ឌល ម៉ាក្ស-ឡេនីន ដែរ តែ ជួន មុម្ម ច្រើនប្រាប់ថា ឯកសារទាំងនោះជាសំបុត្រផ្ទាល់ខ្លួន...។

នៅខែមេសា ឆ្នាំ១៩៦៣ បងៗអ្នកដឹកនាំ បាននាំគ្នារត់ចូលព្រៃទៅបន្តដឹកនាំ ការតស៊ូនៅមូលដ្ឋានជនបទ។ ព្រឹត្តិការណ៍នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែល មានអត្ថន័យ ជាយុទ្ធសាស្ត្រជ្រាលជ្រៅណាស់ ចំពោះអនាគតប្រទេសជាតិយើង អនាគតបដិវត្តន៍កម្ពុជាយើង។ ដំបូង គាត់ភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍នេះខ្លាំងណាស់ ព្រោះពេលនោះចលនាមហាជនប្រឆាំងចក្រពត្តិអាមេរិក កាន់តែសន្ធោសន្ធៅ សីហនុ ក៏បានប្រកាសឈប់ទទួលជំនួយចក្រពត្តិអាមេរិក។ គាត់យល់ថា បងៗអ្នកដឹកនាំ នាំ គ្នារត់ចូលព្រៃបែបនេះ មិនសមស្របទេ ព្រោះមហាជនមិនយល់ ពីមូលហេតុអ្វីបានជា សីហនុ កំពុងវាយចក្រពត្តិអាមេរិក បងៗអ្នកដឹកនាំបែរជារត់ចោល សីហនុ ទុកឱ្យ សីហនុ នៅឯកោ ខណៈខ្មាំងកំពុងវាយប្រហារទៅវិញ។

ក្នុងឆ្នាំ១៩៦៥ ហាក់ ស៊ាងឡាយនី និស្សិតខ្មែររៀននៅក្រុងមូស្គូ បានទៅដល់ ប្រទេសបារាំង និងនៅក្នុងឆ្នាំ១៩៦៦ ទៅម្តងទៀត។ ទាំងពីរលើកនេះ គាត់មិនបាន ទាក់ទងធ្វើការជាមួយទេ តែ ហាក់ ស៊ាងឡាយនី បានជួបទាក់ទងធ្វើការជាមួយ តូច ខាំឿន ជាប្រធានសហភាពនិស្សិតខ្មែរ ហើយជួបទាក់ទងធ្វើការជាសម្ងាត់ជា ច្រើនជាមួយ ជួន មុម្ម ជាអ្នកទទួលខុសត្រូវមណ្ឌលម៉ាក្ស-ឡេនីន ពិសេសពេលជួបគ្នា នៅក្នុងខែកក្កដា ឆ្នាំ១៩៦៦។ ភាគច្រើន ហាក់ ស៊ាងឡាយនី តែងលើកឡើងពីបញ្ហា បង្កើតសហព័ន្ធនិស្សិតកម្ពុជា នៅអឺរ៉ុប។ ក្នុងឆ្នាំ១៩៦៧ ផ្ទុះព្រឹត្តិការណ៍នៅសំឡូត គាត់ឃើញច្បាស់ថា នេះជាស្នាដៃពួកបរិវារខ្ញុំកញ្ជះចក្រពត្តិអាមេរិក ដែលមានពួក សីហនុ ជាអ្នកចូលដៃរាតត្បាតកាប់សម្លាប់ប្រជាជនស្លូតត្រង់ យុទ្ធជន យុទ្ធនារី និងកម្មាភិបាល បដិវត្តន៍។ ពេលនោះគាត់ក៏បានសរសេរអត្ថបទថ្កោលទោសអំពើហ្វាស៊ីស របស់វណ្ណៈ

របត់នយោបាយ

កាន់អំណាចចុះផ្សាយនៅក្នុងព្រឹត្តិបត្រប្រចាំត្រីមាសរបស់សហភាពនិស្សិតខ្មែរ ដែរ។

សភាពការណ៍នេះ បានជះឥទ្ធិពលមកដល់អាណិកជនកម្ពុជា នៅប្រទេសបារាំង។ យុវជនស្នេហាជាតិមិនទុកចិត្តលើមណ្ឌលម៉ាក្ស-ឡេនីន ព្រោះប្រកាន់ជំហរទៅរកសូវៀត និងនិយមវៀតណាម។ ទំនាស់ផ្ទៃក្នុងកាន់តែខ្លាំង គ្មានអ្នកណាស្ដាប់អ្នកណា ចំពោះខ្លួនគាត់ផ្ទាល់ លែងមានទស្សនៈបដិវត្តន៍ គិតវិលវល់តែបញ្ហាការងារផ្ទាល់ខ្លួន ដោយបានរៀបចំគ្រួសារ (ការប្រពន្ធ) ជាជនជាតិបារាំង ធ្វើគ្រូបង្រៀនបឋមសិក្សា នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ដែលពេលនោះ គាត់មានអាយុ ៣០ឆ្នាំ និងប្រពន្ធមានអាយុ ២០ឆ្នាំ។

នៅក្នុងឆ្នាំ១៩៦៨ ឈ្មោះ រឿង ម៉ាច ជានិស្សិតខ្មែរនៅសហភាពសូវៀត បានធ្វើដំណើរមកប្រទេសបារាំង ក៏បានផ្ញើសៀវភៅទិតៀនចំពោះចលនាសង្គមនិយមព្រះពុទ្ធសាសនារបស់ សីហនុ និងខិត្តប័ណ្ណ ដែលមានចុះហត្ថលេខាថា៖ “បក្សកុម្មុយនិស្តខ្មែរ” សរសេរដោយក្រុមនិស្សិតខ្មែរ ជាពួកសេរីនិយមនៅសហភាពសូវៀត តាមប៉ុស្តិ៍ប្រៃសណីយ៍មកឱ្យសហភាពនិស្សិតខ្មែរ ដើម្បីយកមកផ្សព្វផ្សាយ នៅប្រទេសបារាំង។ ក្រៅពីមកផ្សព្វផ្សាយឯកសារនេះ គាត់មិនបានដឹងថា ឈ្មោះ រឿង ម៉ាច មកប្រទេសបារាំង ក្នុងទិសដៅអ្វីទៀតទេ?។

សួង ស៊ីគឿន បានសង្កេតឃើញថា ក្នុងអំឡុងចុងទស្សវត្សរ៍ឆ្នាំ១៩៦០ មណ្ឌលម៉ាក្ស-ឡេនីន មានការទាក់ទងកាន់តែជិតស្និទ្ធជាមួយនិស្សិតចម្រើនយួន ពិសេស ដួន មុម្ម និងង្វៀង ខាច់វៀន ជាប្រធានសហភាពនិស្សិតវៀតណាម នៅប្រទេសបារាំង។ សមាជិកមណ្ឌលម៉ាក្ស-ឡេនីន ភាគច្រើនបានលង់ខ្លួនចូលទៅក្នុងទស្សនៈសហព័ន្ធឥណ្ឌូចិន ដោយយល់ច្រឡំថា យួនវាគ្មានមហិច្ឆតាលេបទឹកដីខ្មែរយើងទេ ព្រោះយួនក៏ធ្វើបដិវត្តន៍ ហើយយើងក៏ធ្វើបដិវត្តន៍ដូចគ្នា គឺទាក់ទងគ្នាដោយស្មើភាព គោរពគ្នាទៅវិញទៅមក និងជួយឧបត្ថម្ភគ្នាជាបងប្អូនក្នុងគ្រួសារតែមួយ។

នៅឆ្នាំ១៩៦៩ តូច ខាំឿន បានលាឈប់ពីប្រធានសហភាពនិស្សិតខ្មែរ ទោះបីគណៈកម្មាធិការមណ្ឌលម៉ាក្ស-ឡេនីន មិនយល់ព្រមក៏ដោយ។ គណៈកម្មាធិការមណ្ឌល

របត់នយោបាយ

បានស្នើឱ្យ ទុន ជោតស៊ីរិន ធ្វើជាប្រធាន តែឈ្មោះនេះប្រកែក។ គណៈកម្មាធិការមណ្ឌល ក៏បានតែងតាំងឱ្យគាត់ធ្វើជាប្រធានសហភាពនិស្សិតខ្មែរ ចាប់ពីពេលនោះមក។

ក្រោយមានរដ្ឋប្រហារនៅក្រុងភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងនាមប្រធានសហភាពនិស្សិតខ្មែរ គាត់បានឡើងថ្កោលទោសចំពោះមេដឹកនាំរដ្ឋប្រហារនោះ នៅក្នុងអង្គមិទ្ទីងរបស់អាណិកជនកម្ពុជានៅប្រទេសបារាំង ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧០។

នៅដើមខែឧសភា ១៩៧០ មហាសន្និបាតនៃសហភាពនិស្សិតខ្មែរ បានជ្រើសរើសគាត់ឱ្យធ្វើជាប្រធានសហភាពនិស្សិតខ្មែរ ជាថ្មីម្តងទៀត។ ប៉ុន្តែសមាជិកមួយចំនួនជាបក្ខពួក អ៊ិន សូភាព (ហៅមី) បានជំទាស់ ព្រោះពួកគេចាត់ទុកគាត់ថា ជាពួកសេរីនិយម ហើយនាំគ្នាដើរចេញពីអង្គប្រជុំ។ ជាមួយគ្នានោះ ពួក សារិន ឆាក និងវ៉ាន់ ពីនី ក៏ជំទាស់ដែរ។




**មិទ្ទីងរបស់រណសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសបារាំង ឆ្នាំ១៩៧០**

ក្រោយសន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិនលើកទី២ ថ្ងៃទី២៤ និ២៥ ខែមេសា ឆ្នាំ១៩៧០ កម្ពុជា វៀតណាម ឡាវ ប្រកាសរួបរួមសាមគ្គីគ្នាប្រឆាំងការឈ្លានពានរបស់ចក្រពត្តិអាមេរិកមក នៅថ្ងៃទី១២ ឧសភា ១៩៧០ សមាគមនិស្សិតខ្មែរ យួន និងឡាវ

របត់នយោបាយ

នៅក្រុងប៉ារីស បានរៀបចំធ្វើមិទ្ទីងរួមគ្នាមួយ ដើម្បីអបអរសាទរ និងគាំទ្រសន្និសីទកំពូលនេះ ដោយគាត់ត្រូវបានជ្រើសតាំងជាប្រធានអធិបតីនៃមិទ្ទីងនោះ។

នៅថ្ងៃ១៥ខែ ឧសភា ឆ្នាំ១៩៧០ គាត់បានធ្វើដំណើរមកទីក្រុងប៉េកាំង ដើម្បីពាំនាំនូវការគាំទ្ររបស់សហភាពនិស្សិតខ្មែរ ជូនដល់រណសិរ្សរួបរួមជាតិកម្ពុជា និងដើម្បីពិនិត្យមើលសភាពការណ៍ជាក់ស្តែងនៅក្រុងប៉េកាំង ផងដែរ។

ពេលយន្តហោះឈប់សំចតនៅក្រុងមូស្គូ គាត់បានសម្រាក២ថ្ងៃនៅក្នុងស្ថានទូតកម្ពុជាប្រចាំសហភាពសូវៀត ដែលពេលនោះ ជា សាន ជាឯកអគ្គរាជទូត។ ក្នុងពេលស្នាក់អាស្រ័យនៅមូស្គូនេះ ក្នុងឋានៈជាប្រធានសហភាពនិស្សិតខ្មែរ គាត់បានសុំជួបសមាគមនិស្សិតសូវៀត ដើម្បីឧទ្ទេសនាមពីសភាពការណ៍នៅប្រទេសកម្ពុជាក្រោយរដ្ឋប្រហារ និងពីបញ្ហាដែលកងទ័ពចក្រពត្តិអាមេរិក និងបរិវារកំពុងចូលមកឈ្លានពានប្រទេសកម្ពុជា។ គាត់ក៏បានស្នើសុំឱ្យពួកនិស្សិតសូវៀត ជួយគាំទ្រដល់បុព្វហេតុនៃការតស៊ូប្រជាជនកម្ពុជា ហើយសូមឱ្យរដ្ឋាភិបាលសូវៀត ទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ផងដែរ។ តែពួកនិស្សិតសូវៀត ធ្វើសោះអង្គើយ ពួកគេគ្រាន់តែឆ្លើយយ៉ាងខ្លីថា៖ បញ្ហាកម្ពុជា សមាគមនិស្សិតសូវៀត គាំទ្រតាមគោលជំហររបស់រដ្ឋាភិបាលសូវៀត។ រដ្ឋាភិបាលសូវៀត គាំទ្ររដ្ឋាភិបាលខ្មែរណា សមាគមនិស្សិតសូវៀត គាំទ្ររដ្ឋាភិបាលខ្មែរនោះ។ ឮដូច្នេះ គាត់ក៏បានដើរចេញ ដោយអាក់អន់ចិត្តយ៉ាងខ្លាំង ព្រោះដឹងថា រដ្ឋាភិបាលសូវៀត មិនទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទេ។ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧០ គាត់បានទៅដល់ក្រុងប៉េកាំង។ តែគាត់មិនបានទទួលតំណែងអ្វីទេ គាត់ជួយធ្វើការគេងណោះបន្តិចឯណោះបន្តិច។

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧០ គាត់បានចូលជាសមាជិកគណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អមដំណើរ សីហនុ ទៅធ្វើទស្សនកិច្ចនៅក្រុងហាណូយ។ គាត់រំភើបនឹងដំណើរទស្សនកិច្ចនេះណាស់ ព្រោះពេលឃើញប្រទេសវៀតណាម ហាក់ដូចជាឃើញប្រទេសខ្លួនឯងអ៊ីចឹង។ ប៉ុន្តែ

របត់នយោបាយ
គាត់ចាប់អារម្មណ៍ថា ពិធីដែលវៀតណាមទទួលស្វាគមន៍ សីហនុ គឺដូចពីសម័យសង្គមចាស់ ដោយចាក់ភ្លេងលេងសិល្បៈកម្ពុជា តាមចំណូលចិត្តរបស់ សីហនុ គ្មានបទភ្លេងសិល្បៈបដិវត្តន៍អីបន្តិចទេ។ ម្យ៉ាងទៀត ពួកកម្មាភិបាលវៀតណាម ដែលមកជួយសម្រួលការងារដល់គណៈប្រតិភូកម្ពុជា គ្មានទស្សនៈបដិវត្តន៍ទេ ពួកគេចូលចិត្តនិយាយពីនារីៗ ពីចម្រៀងប្រទេសខាងលិច មានប្រទេស អ៊ីតាលី ឬបារាំង ជាដើម។

ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧០ គណៈប្រតិភូកម្ពុជា ត្រឡប់មកក្រុងប៉េកាំង វិញ។ ក្រោយពីស្នាក់នៅក្រុងប៉េកាំង បានមួយរយៈ គាត់សម្រេចថា នឹងចូលបម្រើការងាររណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង តែម្តង។ តែគាត់បានសុំអនុញ្ញាតពីថ្នាក់ដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា ទៅយកប្រពន្ធពីប្រទេសបារាំង មករស់ជាមួយគ្នានៅក្រុងប៉េកាំង ដែរ។ គាត់ និងប្រពន្ធបានមកដល់ប្រទេសចិននៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧០។ ដោយមានគំនិតផ្តួចផ្តើមខ្លួនឯងផង និងដោយមានការគាំទ្រពីសមាជិករណសិរ្សក្មេងៗផង គាត់ក៏បានចាប់ផ្តើមសរសេរ និងបោះពុម្ពព្រឹត្តិបត្ររណសិរ្សរួបរួមជាតិកម្ពុជា ដោយចេញផ្សាយក្នុងមួយអាទិត្យម្តង។ បន្ទាប់មក ក៏មានបង្កើតជាការិយាល័យឃោសនាការមួយអមការិយាល័យនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា។ ចាប់ពីពេលនោះមក ក៏ចាក់ផ្សាយអត្ថបទវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា ក្នុងចំណោមអាណិកជនកម្ពុជា នៅបរទេស។ គាត់ធ្វើការនេះ រហូតដល់ឈានដល់បង្កើតទីភ្នាក់ងារសារព័ត៌មានកម្ពុជា “ អា.កា.អ៊ី ” នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧០។

រយៈកាលស្នាក់នៅប្រទេសចិន មុនជួបបក្ស(អៀង សារី) ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧០ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧១ គាត់នៅតែមានគោលជំហរ និងមានទស្សនៈសេរីរើជាមូលដ្ឋាន។ តែគាត់បានប្តេជ្ញាចិត្តមកចូលរួមក្នុងការតស៊ូប្រឆាំងការឈ្លានពានចក្រពត្តិអាមេរិក នៅក្រុងប៉េកាំង ដោយមិនត្រឡប់ទៅប្រទេសបារាំងវិញទេ។ ម្យ៉ាងទៀត គាត់ក៏មានទស្សនៈថា ក្នុងការធ្វើសង្គ្រាមរំដោះជាតិនេះ ពួកវណ្ណៈកាន់អំណាចមុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលមាន សីហនុ និងប៉ែន នុត

របត់នយោបាយ
ជាតំណាង មិនអាចដឹកនាំប្រទេសជាតិបានជាដាច់ខាត ហើយគាត់បានប្រកែកមិនព្រមធ្វើអនុរដ្ឋលេខាធិការ ក្រសួងឃោសនាការ តាមការស្នើសុំរបស់ ជួន មុម្ម និងប៉ែន នុត ហើយគាត់បានប្រកែកមិនព្រមទៅធ្វើទូតនៅស៊ីលី និងគុយបា តាមការស្នើសុំរបស់ សារិន ឆាក។ ពេលនោះ គាត់បានតស៊ូមតិស្តីពីរបៀបរបបធ្វើការពីសង្គមចាស់ ដែលពោរពេញដោយគំនិតបក្ខពួកនិយម គ្មានប្រជាធិបតេយ្យ។

ក្នុងខែកញ្ញា ឆ្នាំ១៩៧១ អៀង សារី តំណាងបក្សក្នុងប្រទេស បានអញ្ជើញមកដល់ក្រុងប៉េកាំង ហើយបានបើកវគ្គអប់រំរៀនសូត្រដល់សមាជិករណសិរ្សរួបរួមជាតិកម្ពុជាទាំងអស់។ ក្នុងវគ្គអប់រំរៀនសូត្រនោះ អៀង សារី បានផ្សព្វផ្សាយ និងបំពាក់បំប៉ននូវទស្សនៈ និងគោលជំហរជាមូលដ្ឋានក្នុងការកិច្ចធ្វើសង្គ្រាមបដិវត្តន៍រំដោះជាតិ រំដោះប្រជាជន។ ជាពិសេស បានអប់រំគោលជំហរឯករាជ្យ ម្ចាស់ការខ្លួនទីពឹងខ្លួន ពីគោលជំហរតស៊ូ យូរអង្វែង ទ្រាំទ្រការលំបាកវេទនាគ្រប់បែបយ៉ាង មិនសម្រុះសម្រួលមិនរាថយ និងបានវែកញែកយ៉ាងច្បាស់ពីព្រំដែនរវាងមិត្ត និងសត្រូវ ទាំងផ្ទៃក្នុងប្រទេសជាតិទាំងលើឆាកអន្តរជាតិ។

តាមរយៈវគ្គអប់រំរៀនសូត្រនេះ ធ្វើឱ្យគាត់យល់ច្បាស់ពីមាគ៌ារបស់អង្គការបដិវត្តន៍ និងបោះបង់ចោលនូវគំនិតសេរីនិយមរបស់គាត់ដែលមានពីមុនមក ជាពិសេស បានដឹងច្បាស់ពីយុទ្ធសាស្ត្ររបស់សហភាពសូវៀត ដែលប្រឆាំងនឹងចលនាបដិវត្តន៍ដឹកនាំដោយបក្សកុម្មុយនិស្តកម្ពុជា កាលពីពេលកន្លងមក។ ជាមួយគ្នានោះ គាត់បានធ្វើស្វ័យទិតៀន អំពីអាកប្បកិរិយាអមិត្ត របស់គាត់ដែលប្រឆាំងនឹងចិន ក្នុងរយៈកាលកន្លងមកផងដែរ។

ដោយសារការសន្តោសប្រណីរបស់បក្ស រួមផ្សំនឹងឧត្តមគតិរបស់ខ្លួនដែលមានតាំងពីយុវវ័យផង ចាប់ពីពេលនោះមក គាត់ប្តេជ្ញាលះបង់អ្វីៗទាំងអស់ ដើម្បីបម្រើប្រជាជាតិ បម្រើប្រជាជន បម្រើបក្ស វណ្ណៈកម្មករកម្ពុជា ជារៀងរហូត។

នៅថ្ងៃ៣០ ខែតុលា ឆ្នាំ១៩៧១ គាត់មាននមហាកិត្តិយសបំផុត ដោយបានអង្គការ

របត់នយោបាយ

បដិវត្តន៍បញ្ចូលជាបក្ខជននៃបក្សកុម្មុយនិស្តកម្ពុជា ដ៏មហាក្លីស្វាង ដោយមាន អៀង សារី ជាគណៈអធិបតីក្នុងពិធីបញ្ចូលជាបក្ខជននោះ និងមាន ជួន ប្រាសិទ្ធ និងគាត ឈន់ ជាអ្នកឧទ្ទេសនាម។

ក្រោយពីបានចូលបក្ខជនមក គាត់បានបំពេញភារកិច្ចជាជំនួយការរបស់គណៈប្រតិភូបក្សកុម្មុយនិស្តកម្ពុជា ដឹកនាំដោយ អៀង សារី និងខៀវ សំផន ទៅធ្វើទស្សនកិច្ចនៅប្រទេសអាស៊ី អឺរ៉ុប និងអាហ្វ្រិក មួយចំនួន។

ដោយចង់លត់ដំកសាងខ្លួនក្នុងចលនាតស៊ូជាក់ស្តែង ដើម្បីឱ្យស័ក្តិសមជាបក្ខជននៃបក្សកុម្មុយនិស្តកម្ពុជា និងដើម្បីបម្រើបក្សឱ្យកាន់តែខ្លាំងក្លា និងមានប្រសិទ្ធភាព នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៤ អង្គការបដិវត្តន៍ក៏បានអនុញ្ញាតឱ្យគាត់ចូលមកក្នុងប្រទេស ជាមួយគណៈប្រតិភូមួយក្រុម។

ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៧៤មក គាត់មានតួនាទីជាអ្នកដកស្រង់ព័ត៌មានសង្ខេបប្រចាំថ្ងៃតាមវិទ្យុជាតិ និងតាមវិទ្យុអន្តរជាតិនៅក្នុងមន្ទីរតំណាងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជានៅបរទេស ដែលមាន អៀង សារី ជាប្រធាន។

ចាប់ពីដើមឆ្នាំ១៩៧៥ គាត់ចាប់ផ្តើមមានមនោសញ្ចេតនាស្នេហាជាមួយនារីម្នាក់ជាសមាជិកសម្ព័ន្ធយុវកកធ្វើការក្នុងក្រុមអានអត្ថបទ នៅវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា។ គាត់បានរាយការណ៍ពីបញ្ហានេះជម្រាបបង វ៉ា ជាប្រធានវិទ្យុសំឡេងរណសិរ្ស និងស្នើសុំរៀបចំគ្រួសារជាមួយនារីនោះ ហើយលែងគ្រួសារនៅប្រទេសបារាំង។ ព្រោះគាត់យល់ដោយអត្តនោម័តថា អង្គការបក្សបានជំរុញឱ្យបក្ខជនណាដែលមានប្រពន្ធជាជនបរទេស ត្រូវតែលែងលះប្រពន្ធនោះចោល ដើម្បីរៀបចំប្រពន្ធជាជនជាតិខ្មែរមានវណ្ណភាពជាកម្មករ ឬកសិករវិញ។ ចំណែកនារីជាសាមីខ្លួនធ្វើការក្នុងក្រុមអានអត្ថបទវិទ្យុនោះ នាងក៏មានការខ្វល់ខ្វាយនឹកអាណិត ដល់វាសនាអនាគតរបស់កូនស្រីរបស់គាត់ទាំងពីរនាក់ដែរ ហើយនាងគិតថា បើគាត់ហ៊ានលែងលះប្រពន្ធទី១នោះ ទៅថ្ងៃក្រោយក៏គាត់ហ៊ានលែងលះប្រពន្ធទី២ទៀតដែរ។ ប៉ុន្តែ

របត់នយោបាយ

បំណាងលែងលះប្រពន្ធនេះ ត្រូវបានគេរិះគន់ថា គ្រាន់តែជាការកែលម្អប្រវត្តិរូបមិនឱ្យជាប់ពាក់ព័ន្ធគ្រួសារជាជនបរទេស ក្នុងបំណងស្វែងរកតួនាទី និងឋានៈក្នុងជួរបដិវត្តន៍ប៉ុណ្ណោះ។



**សម្ដេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា**
**យាងទៅចិន ឆ្នាំ១៩៧០**

---

# ៧.១២.ហ្វូត សម្បត្តិ នៅតែស្មោះត្រង់ជាមួយសម្តេចសីហនុ



ហ្វូត សម្បត្តិ កើតថ្ងៃទី២៩ ខែកមរា ឆ្នាំ១៩២៨ នៅក្រុងភ្នំពេញ។ ឪពុកឈ្មោះ ណៃ ហ្វូត ជាគ្រូពេទ្យ ម្តាយឈ្មោះ តាន់ គួចគាវ។ ពីឆ្នាំ១៩៣៧ ដល់១៩៤០ ហ្វូត សម្បត្តិ បានចូលរៀននៅសាលាបឋមសិក្សាក្នុងទីរួមខេត្តបាត់ដំបង។ ពីឆ្នាំ១៩៤០ ដល់ឆ្នាំ១៩៤២ បានទៅរៀននៅសាលាបឋមសិក្សានៅក្នុងទីរួមខេត្តខេត្តព្រៃវែង បន្តទៀត។ ពីឆ្នាំ១៩៤២ ដល់ឆ្នាំ១៩៤៨ បានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ នៅក្នុងខែតុលា ឆ្នាំ១៩៤៥ ពួកអាណានិគមបារាំង ចូលមកគ្រប់គ្រងប្រទេសកម្ពុជាវិញ បានបងប្រុសគាត់ម្នាក់ ឈ្មោះ ហ្វូត សុវណ្ណ លេខាធិការផ្ទាល់របស់នាយករដ្ឋមន្ត្រី សឺង ង៉ុកថាញ់ ត្រូវពួកបារាំង ចាប់យកទៅដាក់ក្នុងទីឃុំឃាំង ធ្វើទារុណកម្មរហូតដល់ស្លាប់។

របត់នយោបាយ

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤៩ ហួត សម្បត្តិ បានចេញទៅរៀននៅប្រទេសបារាំង ដោយមានគោលបំណងចង់រៀនសូត្របន្តទៀតផង និងស្វែងយល់ពីចលនាបណ្តេញអាណានិគមនិយមបារាំង ចេញឱ្យអស់ពីកម្ពុជា ដើម្បីបន្តវេនតស៊ូពីបងប្រុសរបស់គាត់ ដែលត្រូវពួកបារាំងចាប់យកទៅ ធ្វើទារុណកម្មរហូតដល់ស្លាប់នោះផងដែរ។

ពេលទៅដល់ប្រទេសបារាំង គាត់បានទៅរក ឌុក រ៉ាស៊ី ដែលធ្លាប់ជាមិត្តភក្តិរបស់បងប្រុសគាត់ឈ្មោះ ហួត សុវណ្ណ នោះ។ បន្ទាប់មក ឌុក រ៉ាស៊ី ក៏បាននាំគាត់ទៅជួបសម សារី និងម៉ៅ សាយ ដែលពីមុនមកពុំធ្លាប់ស្គាល់គ្នាសោះ។

នៅក្នុងឆ្នាំ១៩៥០ ដោយចង់ចូលរួមក្នុងចលនាបណ្តេញអាណានិគមនិយមបារាំងឱ្យចេញពីប្រទេសកម្ពុជា ហួត សម្បត្តិ បានទៅជួបសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តបារាំង ២នាក់ ម្នាក់ឈ្មោះ សាក់ ដុយក្លូ និងម្នាក់ទៀតឈ្មោះ អង់ដ្រេម៉ាទី។ តែជនជាតិបារាំងទាំង២នាក់នេះ បានឱ្យគាត់ទៅជួបតំណាងបក្សកុម្មុយនិស្តឥណ្ឌូចិននៅប្រទេសបារាំង ដែលកំពុងធ្វើសង្គ្រាមវាយបណ្តេញពួកអាណានិគមនិយមបារាំងឱ្យចេញពីទឹកដីកម្ពុជា វៀតណាម និងលាវ។ ពេលនោះ សម សារី និង ម៉ៅ សាយ ប្រាប់គាត់ថា៖ “ មានតែផ្លូវមួយគត់ គឺចូលជាមួយអាមេរិក ពីព្រោះមានតែអាមេរិកទេដែលអាចបង្ខំឱ្យបារាំង ផ្តល់ឯករាជ្យមកដល់កម្ពុជាបាន។ ចំណែកពួកកុម្មុយនិស្ត គ្មានលទ្ធភាពនឹងបណ្តេញបារាំង បានទេ។ សម សារី, ម៉ៅ សាយ និងឌុក រ៉ាស៊ី គឺជាអ្នកប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត មិនឱ្យចូលស្រុកខ្មែរជាដាច់ខាត ”។

នៅឆ្នាំ១៩៥០ ហួត សម្បត្តិ បានធ្វើសំបុត្រមួយផ្ញើតាមអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលមកប្រជុំនៅទីក្រុងប៉ារីស ទៅឱ្យរដ្ឋមន្ត្រីការបរទេសអាមេរិក ដើម្បីឱ្យបានដឹងថា ប្រជាជនខ្មែរទូទៅចង់បានឯករាជ្យ និងបណ្តេញអាណានិគមនិយមបារាំង ចេញពីប្រទេសកម្ពុជា ប៉ុន្តែរដ្ឋមន្ត្រីអាមេរិករូបនោះ មិនបានឆ្លើយតបមកគាត់វិញទេ។

របត់នយោបាយ

ចាប់តាំងពីឆ្នាំ១៩៥២ ហួត សម្បត្តិ ជួយធ្វើការឱ្យនាយករដ្ឋមន្ត្រី ប៉ែន នុត ជាអ្នកទិញកាសែតបារាំង យកមកអាន ហើយកាត់យកអត្ថបទសំខាន់ទាំងឡាយណាដែលទាក់ទងដល់ប្រទេសកម្ពុជា ដែលចុះផ្សាយនៅលើទំព័រកាសែតបារាំងទាំងនោះ ផ្ញើមកឱ្យ ប៉ែន នុត នៅក្រុងភ្នំពេញ ក្នុងមួយសប្តាហ៍ម្តង។ ចំណែកនាយករដ្ឋមន្ត្រី ប៉ែន នុត ក៏តែងតែផ្ញើប្រាក់ជារៀងរាល់ខែ សម្រាប់ឱ្យគាត់សម្រាប់ទិញកាសែតបារាំង និងសម្រាប់ថ្លៃផ្ញើអត្ថបទកាសែតតាមប្រអប់សំបុត្រ។ ជាមួយគ្នានោះ យូរៗម្តង ប៉ែន នុត បានផ្ញើប្រាក់ឱ្យគាត់សម្រាប់ចាយវាយផ្ទាល់ខ្លួនផងដែរ។

នៅក្នុងឆ្នាំ១៩៥៣ ហួត សម្បត្តិ បានដកខ្លួនចេញពីសមាគមខ្មែរនៅស្រុកបារាំង ព្រោះយល់ឃើញថា សមាគមនេះបានធ្វើសកម្មភាពបំបែកបំបាក់និស្សិត និងអាណិកជនខ្មែរ នៅស្រុកបារាំង កាន់តែខ្លាំងឡើងៗ។ នៅក្នុងឆ្នាំ១៩៥៤ នាយករដ្ឋមន្ត្រី ប៉ែន នុត ឱ្យគាត់តាមដានលទ្ធផលនៃកិច្ចប្រជុំសន្និសីទក្រុងហ្សឺណែវ តាមរយៈការចុះផ្សាយរបស់កាសែតនៅក្រុងប៉ារីស ប្រទេសបារាំង។ នៅចុងឆ្នាំ១៩៥៤ និងដើមឆ្នាំ១៩៥៥ ពេលមានសន្និសីទសេដ្ឋកិច្ចមួយដែលមានប្រទេស៤ ចូលរួមគឺ ខ្មែរ វៀតណាមខាងត្បូង ឡាវ និងបារាំង នៅទីក្រុងប៉ារីស នាយករដ្ឋមន្ត្រី ប៉ែន នុត បានតែងតាំងគាត់ឱ្យធ្វើជាសមាជិកនៃគណៈប្រតិភូខ្មែរទទួលភារកិច្ចទាក់ទងនឹងអ្នកកាសែត។

លុះដល់ខែមីនា ឆ្នាំ១៩៥៥ ហួត សម្បត្តិ បានត្រឡប់មកប្រទេសខ្មែរវិញ ចំពេលសហរដ្ឋអាមេរិក កំពុងតែធ្វើសកម្មភាពអូសទាញប្រទេសខ្មែរ ឱ្យចូលជាសមាជិកអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ (SEATO = សេអាតូ)។ នៅក្នុងអំឡុងពីខែតុលា ឆ្នាំ១៩៥៥ ដល់ខែមករា ឆ្នាំ១៩៥៦ គាត់ត្រូវបានសម្តេចសីហនុ តែងតាំងជារដ្ឋលេខាធិការក្រសួងអប់រំជាតិ (ពេលនោះ សម្តេចសីហនុ ជានាយករដ្ឋមន្ត្រី និងសម សារី ជាឧបនាយករដ្ឋមន្ត្រី)។ ពីខែមីនា ឆ្នាំ១៩៥៦ ដល់ខែមេសា ឆ្នាំ១៩៥៦ គាត់ត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងអប់រំជាតិ វិចិត្រសិល្បៈ យុវជន និងកីឡា។

ពីខែកញ្ញា ឆ្នាំ១៩៥៦ ដល់ខែតុលា ឆ្នាំ១៩៥៦ គាត់ត្រូវបានតែងតាំងជា

របត់នយោបាយ
រដ្ឋលេខាធិការក្រសួងអប់រំជាតិ វិចិត្រសិល្បៈ យុវជន និងកីឡា។ ពីខែតុលា ឆ្នាំ១៩៥៦ ដល់ខែមករា ឆ្នាំ១៩៥៧ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីហិរញ្ញវត្ថុ ផែនការ និងឧស្សាហកម្ម។ ក្នុងពេលនោះដែរ ហួត សម្បត្តិ, សម សារី និងម៉ៅ សាយ ដែលធ្លាប់ស្រឡាញ់រាប់អានគ្នាកាលរៀននៅប្រទេសបារាំង មានជម្លោះបាក់បែកគ្នា ដោយសារសម សារី និងម៉ៅ សាយ ចោទគាត់ថាជាជនពុករលួយ។ ពីខែមករា ឆ្នាំ១៩៥៧ ដល់ខែមេសា ឆ្នាំ១៩៥៧ គាត់ត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងព័ត៌មាន និងការងារ។

អំឡុងពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៧នោះដែរ ទីប្រឹក្សាស្ថានទូតអាមេរិកម្នាក់ឈ្មោះ ម៉ាទីន ហេត្ស ជាញឹកញាប់បានមកទាក់ទងសួរនាំគាត់អំពីស្ថានការណ៍នយោបាយក្នុងប្រទេសខ្មែរ។ ប៉ុន្តែ ក្រោយពី ចប់ភារកិច្ចចាកចេញពីក្រុងភ្នំពេញ វិលត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ទីប្រឹក្សាស្ថានទូតអាមេរិកម្នាក់នោះ បានសរសេរសៀវភៅមួយ មានខ្លឹមសារវាយប្រហាររិះគន់ធ្ងន់ៗ ទៅលើសម្តេចសីហនុ ធ្វើឱ្យព្រះអង្គពិរោធយ៉ាងខ្លាំង។

ចាប់ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៦២ ហួត សម្បត្តិ ឈប់ធ្វើការនៅក្នុងជួររាជរដ្ឋាភិបាលទៅឈរឈ្មោះបោះឆ្នោតធ្វើជាតំណាងរាស្ត្រមណ្ឌលមួយក្នុងខេត្តស្វាយរៀង។ ដើមឆ្នាំ១៩៥៧ សម សារី ត្រូវចេញទៅធ្វើឯកអគ្គរាជទូតនៅប្រទេសអង់គ្លេស ចំណែក ម៉ៅ សាយ ត្រូវបាន ហួត សម្បត្តិ រួមចំណែកទម្លាក់ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងផែនការ។

ប៉ុន្តែ ពីខែសីហា ឆ្នាំ១៩៦២ ដល់ខែតុលា ឆ្នាំ១៩៦២ ហួត សម្បត្តិ បានចូលមកបម្រើការងារក្នុងជួររាជរដ្ឋាភិបាលវិញ ជារដ្ឋមន្ត្រីក្រសួងការបរទេស និងទេសចរណ៍ គឺចំពេលដែលប្រទេសកម្ពុជា បានសម្រេចចិត្តប្តឹងរដ្ឋាភិបាលវៀតណាមខាងត្បូង និងអាមេរិក ទៅអង្គការសហប្រជាជាតិ ដែលបានឱ្យកងទ័ពរបស់ពួកគេ ចូលមករំលោភឈ្លានពានប្រទេសកម្ពុជា។ ពេលនោះ ហួត សម្បត្តិ ត្រូវបានបញ្ជូនទៅអង្គការសហប្រជាជាតិ ដើម្បីប្តឹងបកអាក្រាត និងបានស្នើសុំឱ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ផ្តន្ទាទោស សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង។ ជាមួយគ្នានោះ

របត់នយោបាយ
គាត់បានទាក់ទងជាមួយអគ្គលេខាធិការនៃបក្សកុម្មុយនិស្តឥណ្ឌូនេស៊ី ឈ្មោះ អាជិត។ នៅឆ្នាំ១៩៦៣ គាត់បានទៅជួប ហូ ជីមិញ និងផាមវ៉ាន់ដុង នៅទីក្រុងហាណូយ ផងដែរ។

ឆ្នាំ១៩៦៥ ប្រទេសកម្ពុជា បានផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង។ ប៉ុន្តែមុននឹងផ្តាច់ទំនាក់ទំនងការទូតនេះ តំណាងរាស្ត្រអាមេរិក ម្នាក់ ឈ្មោះ ម៉ៃ មេនហ្វៀល បានមកជួបជាមួយ ហួត សម្បត្តិ ជារដ្ឋមន្ត្រីក្រសួងការបរទេស ដើម្បីដោះស្រាយបញ្ហាផ្តាច់ទំនាក់ទំនងការទូតនេះដែរ។ ប៉ុន្តែ ហួត សម្បត្តិ មិនព្រមដោះស្រាយ។ ក្រោយពីផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក មក ហួត សម្បត្តិ បានទទួលបញ្ជាពីរាជរដ្ឋាភិបាលភ្នំពេញ ឱ្យបំផុសមហាជនអាមេរិក ជួយគាំទ្រដល់ប្រជាជនកម្ពុជា និងប្រឆាំងនឹងការឈ្លានពានរបស់សហរដ្ឋអាមេរិក។

ចាប់ពីឆ្នាំ១៩៦៥មក ហួត សម្បត្តិ ត្រូវបានតែងតាំងជាតំណាងប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ។ នៅក្នុងឆ្នាំ១៩៦៩ ទំនាក់ទំនងការទូតរវាងកម្ពុជា និងសហរដ្ឋអាមេរិក ក៏បានចាប់ផ្តើមកើតមានជាថ្មីឡើងវិញ។ នេះជារឿងមួយដែលធ្វើឱ្យ ហួត សម្បត្តិ ពិបាកធ្វើការនៅឯអង្គការសហប្រជាជាតិ ដោយសាររាជរដ្ឋាភិបាលភ្នំពេញ បញ្ឈប់ឱ្យថ្កោលទោសចំពោះសហរដ្ឋអាមេរិក។

ក្រោយសម្តេចសីហនុ ប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ហួត សម្បត្តិ បានសម្រេចចិត្តបោះបង់តំណែងតំណាងប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ធ្វើដំណើរពីទីក្រុងញូវយ៉ក សហរដ្ឋមេរិក ទៅកាន់ទីក្រុងប៉េកាំង ដើម្បីទៅចូលរួមក្នុងចលនាតស៊ូវាយផ្តួលរម្លំពួកមេដឹកនាំរដ្ឋប្រហារ លន់ នល់ និងសិរិមតៈ។ ពេលនោះ ដោយសារគ្មានប្រាក់គ្រប់គ្រាន់ ដើម្បីទិញសំបុត្រយន្តហោះសម្រាប់គ្រួសាររបស់គាត់ចំនួន១២នាក់ ប្រពន្ធរបស់គាត់ក៏បានយកទ្រព្យសម្បត្តិរបស់ខ្លួនលក់ដើម្បីយកប្រាក់ទៅទិញសំបុត្រយន្តហោះ។ ប៉ុន្តែប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិនោះ នៅតែមិនគ្រប់ថ្លៃទិញសំបុត្រយន្តហោះទៀត ហួត សម្បត្តិ ក៏បាន

ទៅខ្ចីប្រាក់ពី អ៊ូ ថាន់ អគ្គលេខានៃអង្គការសហប្រជាជាតិ។ ប៉ុន្តែ អ៊ូ ថាន់ ប្រាប់គាត់ថា មិនហ៊ានយកប្រាក់របស់អង្គការសហប្រជាជាតិឱ្យខ្ចីទេ គាត់ក៏បានទៅខ្ចីប្រាក់ពីសង្ឃកាតូលិកជាជនជាតិបារាំងមួយរូប ព្រះនាម ពែរ ហ្វូតាំង បានចំនួន៤០០០ដុល្លារសហរដ្ឋអាមេរិក ដើម្បីបង្គ្រប់ថ្លៃទិញសំបុត្រយន្តហោះ ធ្វើដំណើរពីទីក្រុងញូវយ៉កមកទីក្រុងមូស្គូ មួយរយៈខ្លីដោយមានរដ្ឋាភិបាលចិន ជាអ្នកជួយចេញថ្លៃហូបចុក និងស្នាក់នៅ។ បន្ទាប់មក រដ្ឋាភិបាលចិន បានជួយចេញថ្លៃសំបុត្រយន្តហោះ ដើម្បីធ្វើដំណើរពីទីក្រុងមូស្គូ មកទៅទីក្រុងប៉េកាំង បន្តទៀត។

ពេលទៅដល់ទីក្រុងប៉េកាំង សម្តេចសីហនុ និងប៉ែន នុត មានការថ្នាំងថ្នាក់ជាមួយគ្នា ដោយសារសម្តេចសីហនុ ចង់ឱ្យគាត់ចូលជាសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា តែ ប៉ែន នុត មិនព្រម។ ទីបំផុត ដោយមានការសម្របសម្រួលគ្នា ហួត សម្បត្តិ ត្រូវបានតែងតាំងជាសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា មាន ប៉ែន នុត ជាប្រធាន និងសមាជិក១០រូប រួមមាន៖ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់, ថៅ សេង, ដួង សំអុល, ហួត សម្បត្តិ, ចាន់ យូរ៉ាន់, ជា សាន សារិន ឆាក និងជួន មុម្ម។

ហួត សម្បត្តិ បានរម្លឹកថា នៅក្នុងខែសីហា ឆ្នាំ១៩៧០ សៀន អាន ឯកអគ្គរាជទូតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅក្រុងហាណូយ បានទូរសព្ទមករាជរដ្ឋាភិបាលនៅប៉េកាំង ថា ឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញប្រចាំកម្ពុជា ឈ្មោះ បាវ សូវស្គី ស្នើសុំចូលគាល់សម្តេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។ បីថ្ងៃក្រោយមក ពេលដែលឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញ មកដល់ប៉េកាំង ប៉ែន នុត បានចាត់ឱ្យគាត់ទៅទទួលនៅចំណតអាកាសយានដ្ឋាន និងជូនទៅជួបសម្តេចសីហនុ នៅមាត់សមុទ្រភាគខាងជើងប្រទេសចិនឈ្មោះ “ ពេតាហេ ” ដែលព្រះអង្គ និងមហេសី កំពុងទៅសម្រាកលម្ហែព្រះកាយនៅទីនោះ។ ពេលកំពុងធ្វើដំណើរតាមផ្លូវ ឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញ ឈ្មោះ បាវ សូវស្គី ប្រាប់គាត់ថា នៅក្រុងភ្នំពេញ ឥស្សរជនមួយក្រុម រួមមាន៖ សម្តេចសង្ឃគណៈ

របត់នយោបាយ
មហានិកាយ ហួត តាត, សឺន សាន, ចេង ហេង, នរោត្តម កន្តុល, អ៊ុំង ហុងសាធ ជាដើម និងបញ្ញាជនប្រហែល៣០០នាក់ទៀត កំពុងរៀបចំបង្កើតកម្លាំងទី៣មួយផ្សេងទៀត ដែលមិនចូលដៃចូលជើងជាមួយ លន់ នល់ ហើយក៏មិនចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា របស់សម្តេចសីហនុ ដែរ។ ការបង្កើតកម្លាំងទី៣នេះ ក្នុងទិសដៅចង់បញ្ឈប់សង្គ្រាម និងបង្រួបបង្រួមគ្នាឡើងវិញ។

ដើម្បីអនុវត្តគោលបំណងនេះ ពួកគេតម្រូវឱ្យសម្តេចសីហនុ និងលន់ នល់ ដើរចេញពីឆាកនយោបាយកម្ពុជា សិន ហើយពួកគេនឹងរៀបចំធ្វើជាប្រជាមតិមួយនៅក្រោមការទទួលខុសត្រូវរបស់អង្គការអន្តរជាតិ ដើម្បីប្រជារាស្ត្រខ្មែរបោះឆ្នោតជ្រើសរើសសម្តេចសីហនុ ឬលន់ នល់ ជាមេដឹកនាំប្រទេស។ ប្រសិនបើប្រជារាស្ត្រខ្មែរភាគច្រើនបោះឆ្នោតគាំទ្រសម្តេចសីហនុ ឱ្យធ្វើជាមេដឹកនាំប្រទេស លន់ នល់ ត្រូវដើរចេញពីកម្ពុជា ហើយផ្ទុយទៅវិញ ប្រសិនបើប្រជារាស្ត្រខ្មែរភាគច្រើនបោះឆ្នោតគាំទ្រ លន់ នល់ ឱ្យធ្វើជាមេដឹកនាំប្រទេស សម្តេចសីហនុ ក៏ត្រូវតែលែងចូលប្រទេសដែរ។

ប៉ុន្តែក្រោយពីបានស្តាប់ហើយ គាត់មិនបានឆ្លើយតបថាយ៉ាងណានោះទេចំពោះបញ្ហាបង្កើតកម្លាំងទី៣នេះទេ តែគាត់បានសួរឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញ ឈ្មោះ បាវ សូវស្គី ថាតើពេលណា ទើបប្រទេសប៉ូឡូញ ទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយបិទស្ថានទូតរបស់ប៉ូឡូញ នៅក្រុងភ្នំពេញ? ភ្លាមនោះ បាវ សូវស្គី បានឆ្លើយថា គាត់មិនត្រឡប់ទៅក្រុងភ្នំពេញ វិញទៀតទេ។ ចំណែកឯការទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឬមិនទទួលស្គាល់យ៉ាងណានោះ គាត់នឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋាភិបាលគាត់។

តែពេលចូលគាល់សម្តេចសីហនុ នៅសណ្ឋាគារនាមាត់សមុទ្រនោះ បាវ សូវស្គី មិនបានលើកយកបញ្ហាបង្កើតកម្លាំងទី៣នោះ មកពិភាក្សាជាមួយព្រះអង្គទេ។ ហួត សម្បត្តិ បានធ្វើសេចក្តីរាយការណ៍ អំពីបញ្ហារៀបចំបង្កើតកម្លាំងទី៣ ដូចដែលឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញ បាននិយាយប្រាប់គាត់នោះ ថ្វាយសម្តេចសីហនុ តែព្រះអង្គមិនយល់

ស្របតាមគំនិតរបស់កម្លាំងទី៣ នោះឡើយ។ នៅពេលត្រឡប់មកប៉េកាំងវិញ គាត់បានយកបញ្ហាបង្កើតកម្លាំងទី៣នោះ ទៅប្រាប់ ប៉ែន នុត បន្តទៀតដែរ។

ហួត សម្បត្តិ បានរម្លឹកបន្តថា នៅក្នុងឆ្នាំ១៩៧១ ពេលគាត់ទៅបំពេញទស្សនកិច្ចនៅប្រទេសយូហ្គោស្លាវី អូរ៉ាលិច អនុរដ្ឋមន្ត្រីក្រសួងការបរទេសយូហ្គោស្លាវី បានប្រាប់គាត់ថា តាមសេចក្ដីរាយការណ៍ ដែលគាត់បានទទួលបានពីទូតយូហ្គោស្លាវី ប្រចាំនៅប្រទេសបារាំង បានឱ្យដឹងថា មេដឹកនាំបារាំង បានចូលដៃ ចូលជើងនៅក្នុងការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នោះដែរ។

នៅក្នុងឆ្នាំ១៩៧១នោះដែរ ប៉ែន នុត បានឱ្យ សារិន ឆាក រដ្ឋមន្ត្រីការបរទេស និងចាន់ យូរ៉ាន់ សមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជាទៅជួប សឺន សាន នៅក្រុងប៉ារីស តែគាត់មិនដឹងថា មានបញ្ហាអ្វីនោះទេ។ លុះក្រោយមកទៀត ទើបគាត់បានដឹងថា សឺន សាន ចង់បំបែក ប៉ែន នុត ចេញពីរណសិរ្សរួបរួមជាតិកម្ពុជា តាមគំនិត និងទិសដៅរបស់រដ្ឋាភិបាលបារាំង និងសហភាពសូវៀត។ ទោះជាយ៉ាងណាក្ដី ដោយមានការលើកទឹកចិត្តពី ជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន និងប៉ែន នុត គាត់នៅតែស្មោះស្ម័គ្រជាមួយសម្ដេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជារហូតមក....។

ហួត សម្បត្តិ បានអះអាងថា កម្លាំងទី៣ ជាគ្រោងការរបស់បារាំង និងសហភាពសូវៀត ដែលភ័យខ្លាចសម្ដេចសីហនុ គ្មានអំណាចអ្វីទៀត ហើយរដ្ឋអំណាចទាំងអស់ត្រូវធ្លាក់ទៅលើដៃអ្នកបដិវត្តកម្ពុជាខ្មែរក្រហម ដែលពលីជីវិតច្រើនជាងគេ នៅក្នុងការតស៊ូធ្វើសង្គ្រាមផ្ដួលរម្លំរបប លន់ នល់។

ហួត សម្បត្តិ បានបញ្ជាក់ថា នៅឆ្នាំ១៩៧១ អង្គការបដិវត្តន៍នៅក្នុងប្រទេសបានផ្ញើរូបថត ខៀវ សំផន, ហ៊ូ នឹម និងហ៊ូ យន់ ពីតំបន់រំដោះមកក្រុងប៉េកាំង ដើម្បីឱ្យរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា យកទៅឃោសនាផ្សព្វផ្សាយ និងបង្ហាញឱ្យអន្តរជាតិឃើញថា ប្រជាជន និងកងទ័ពអង្គការបដិវត្តន៍កម្ពុជា បានប្រយុទ្ធតស៊ូធ្វើសង្គ្រាមផ្ដួល

របត់នយោបាយ

រម្លំរបប លន់ នល់ ទទួលបានជោគជ័យជាបន្តបន្ទាប់ ហើយការធ្វើសង្គ្រាមនេះ មិនមែនជាសង្គ្រាមឈ្លានពានរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង ដូចការឃោសនារបស់បនក្បត់ លន់ នល់ នោះទេ។

នៅក្នុងឆ្នាំ១៩៧១នោះដែរ ក្នុងជួរថ្នាក់ដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានការបែកបាក់ សង្ស័យ និងមានការចោទប្រកាន់គ្នាទៅវិញទៅមក។ តែក្រោយពេល អៀង សារី ទៅធ្វើជាតំណាងរបស់អង្គការបដិវត្តន៍នៅក្រុងប៉េកាំងនោះ ក៏បានរៀបចំបើកវគ្គអប់រំរៀនសូត្រ ទើបថ្នាក់ដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានរបៀបរៀបរយឡើងវិញ ហើយការងារគ្រប់យ៉ាងក៏ចម្រើនផងដែរ។

ហួត សម្បត្តិ បានបញ្ជាក់បន្តថា នៅឆ្នាំ១៩៧២ ក្រោយពីយាងត្រឡប់មកពីបំពេញទស្សនកិច្ចជាលើកដំបូង នៅតាមបណ្ដាប្រទេសជាមិត្តមួយចំនួននៅអឺរ៉ុប អាស៊ី និងអាហ្វ្រិក មកដល់ទីក្រុងប៉េកាំង វិញ សម្ដេចសីហនុ បានប្រកាសសុំលាលែងពីតំណែងជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ដោយសារគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចេះតែជំទាស់នឹងនយោបាយរបស់ព្រះអង្គ។ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧២ គាត់បានរៀបចំធ្វើពិធីតាំងរូបថតជាច្រើនសន្លឹក ស្ដីពីសកម្មភាពតស៊ូរបស់ប្រជាជន និងកងទ័ពបដិវត្តន៍កំពុងប្រយុទ្ធតស៊ូក្នុងការធ្វើសង្គ្រាមផ្ដួលរម្លំរបប លន់ នល់ ដែលអង្គការបដិវត្តន៍នៅក្នុងប្រទេសផ្ញើមកឱ្យ។ ក្នុងពេលនោះដែរ ក៏មានអតីតគ្រូបង្រៀនភាសាអង់គ្លេសម្នាក់នៅខេត្តសៀមរាប ជាជនជាតិអាមេរិក ឈ្មោះ អឺតហ្គ័រ កូទីយេ ដែលធ្លាប់ទាក់ទងគ្នាជាមួយគាត់តាំងពីឆ្នាំ១៩៦៨ កាលគាត់នៅជាតំណាងប្រទេសកម្ពុជា នៅអង្គការសហប្រជាជាតិនោះ បានទៅដើរកម្សាន្តនៅប្រទេសយូហ្គោស្លាវី គាត់ក៏បានអញ្ជើញ អឺតហ្គ័រ កូទីយេ ឱ្យមកទស្សនាការពិព័រណ៍រូបថតនោះដែរ ដើម្បីស្នើឱ្យ អឺតហ្គ័រ កូទីយេ ជួយទាក់ទងពលរដ្ឋអាមេរិក ជាអ្នកស្នេហាសន្តិភាព ឱ្យជួយផ្សាយពីការរងទុក្ខវេទនា និងការតស៊ូរបស់ប្រជាជនកម្ពុជា ដូចបានឃើញនៅក្នុងការតាំង

របត់នយោបាយ

ពិព័រណ៍រូបថតនោះ នៅពេល អ៊ឹតហ្គ័រ កូទីយេ ត្រឡប់ទៅដល់អាមេរិក វិញ។ ឆ្លៀតពេលនោះ គាត់ក៏បានផ្ញើប្រាក់ចំនួន៤០០០ដុល្លារអាមេរិក តាមរយៈ អ៊ឹតហ្គ័រ កូទីយេ ដើម្បីសងទៅសង្ឃកាតូលិកជាជនជាតិបារាំង ព្រះនាម ពែរ ហ្វូតាំង ដែលគាត់បានខ្ចីទិញសំបុត្រយន្តហោះពីក្រុងញូវយ៉ក ទៅក្រុងមូស្គូ នោះវិញ។

ហួត សម្បត្តិ បានបញ្ជាក់បន្តទៀតថា នៅដើមឆ្នាំ១៩៧៣ ខណៈសហរដ្ឋអាមេរិក កំពុងចរចាជាមួយមេដឹកនាំវៀតកុង-វៀតណាមខាងជើង មេដឹកនាំប្រទេសជាមិត្តមួយចំនួន ដូចជា ប្រទេសម៉ូរីតានី, អាល់ហ្សេរី និងរ៉ូម៉ានី មានបំណងចង់ឱ្យសម្តេចសីហនុ ជួបចរចាជាមួយ លន់ នល់ ដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជាដែរ។ តែសម្តេចសីហនុ ចង់ជួបចរចាជាមួយ ហង់រី គីហ្ស៊ីងហ្គ័រ រដ្ឋមន្ត្រីការបរទេសអាមេរិក ដែលមកជួបចរចាគ្នាជាមួយ ម៉ៅ សេទុង និងជូ អេនឡាយ នៅក្រុងប៉េកាំង នោះទៅវិញ។ តែយ៉ាងណា អង្គការបដិវត្តន៍នៅក្នុងប្រទេស មិនអនុញ្ញាតឱ្យសម្តេចជួបចរចាជាមួយ ហង់រី គីហ្ស៊ីងហ្គ័រ ជាដាច់ខាត ដូច្នេះ សម្តេច ក៏បានសុំលាលែងពីប្រធានរណសិរ្សរួបរួមជាតិកម្ពុជាម្តងទៀត។

ពេលឃើញសភាពមិនសូវល្អយ៉ាងដូច្នេះ គាត់ក៏បានស្នើសុំលាឈប់ពីតំណែងជាសមាជិកការិយាល័យនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា ហើយស្នើឱ្យរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្រគល់អំណាចទាំងស្រុង ទៅឱ្យអង្គការបដិវត្តន៍នៅក្នុងប្រទេសជាអ្នកដឹកនាំវិញម្តង ពីព្រោះគាត់ដឹងច្បាស់ថា អង្គការបដិវត្តន៍នៅក្នុងប្រទេស ប្រាកដជាមិនព្រមចរចាជាមួយ លន់ នល់ ជាដាច់ខាត គឺស្របនឹងគោលជំហររបស់គាត់ដែរ។

ហួត សម្បត្តិ បានបញ្ជាក់ដែរថា ក្រោយពីយាងមកបំពេញទស្សនកិច្ចនៅតំបន់រំដោះក្នុងប្រទស ចាប់ពីដើមខែមីនា ឆ្នាំ១៩៧៣ ដល់សប្តាហ៍ទី១ នៃខែមសា ឆ្នាំ ១៩៧៣ ពេលវិលត្រឡប់ទៅដល់ទីក្រុងប៉េកាំងវិញ សម្តេចសីហនុ បានជួបជាមួយនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ សុំឱ្យនាយករដ្ឋមន្ត្រីចិនរូបនេះ ជួយនិយាយជាមួយ ហង់រី គីហ្ស៊ីងហ្គ័រ រដ្ឋមន្ត្រីការបរទេសអាមេរិក ជួយធ្វើអន្តរាគមន៍យ៉ាងណា ដើម្បីឱ្យ

របត់នយោបាយ

លន់ នល់ អនុញ្ញាតឱ្យព្រះមាតា ស៊ីសុវត្ថិ កុសុមៈ របស់ព្រះអង្គបានចេញពីប្រទេសកម្ពុជា មកកាន់ប្រទេសចិន ដើម្បីព្យាបាលជំងឺមហារីក និងបានរស់នៅជាមួយព្រះអង្គនៅក្រុងប៉េកាំង ផងដែរ។ ហង់រី គីហ្ស៊ីងហ្គ័រ រដ្ឋមន្ត្រីការបរទេសអាមេរិក ក៏យល់ព្រមតាមសំណើនេះ ហើយបានប្រាប់ឱ្យ លន់ នល់ ដោះលែងព្រះមាតារបស់ព្រះអង្គពីការឃុំឃាំងក្នុងផ្ទះ ហើយអនុញ្ញាតឱ្យម្ចាស់ក្សត្រី ស៊ីសុវត្ថិ កុសុមៈ ព្រមទាំងរាជវង្សជាបុត្រាបុត្រីចៅៗរបស់ព្រះអង្គ និងអ្នកបម្រើមួយចំនួនទៀត បានចាកចេញពីប្រទេសកម្ពុជា មកកាន់ប្រទេសចិន តាមការស្នើសុំរបស់សម្តេចសីហនុ។

នៅឆ្នាំ១៩៧៤ សម្តេចសីហនុ សុំលាលែងពីតំណែងម្តងទៀត ប៉ុន្តែ គាត់ពុំបានដឹងអំពីមូលហេតុយ៉ាងណានោះឡើយ។ តែ ជូ អេនឡាយ បានជួយសម្រុះសម្រួលឱ្យព្រះអង្គសុខចិត្តយល់ព្រមបន្តបេសកកម្មជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា រហូតដល់ទទួលបានជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

# ៧.១៣. វ៉ាន់ ពីនី ពីលេខាស្ថានទូត ក្លាយជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស



**ហួត សម្បត្តិ និងវ៉ាន់ ពីនី** (កាន់បាច់ផ្កា) **ពេលទៅដល់ប្រទេសអាល់បានី**

វ៉ាន់ ពីនី កើតនៅឆ្នាំ១៩៤០ ក្នុងភូមិស្វាយពល ឃុំស្វាយពល ស្រុកពារាំង ខេត្តព្រៃវែង។ ឪពុកឈ្មោះ វ៉ាន់ ប៊ុនថាន់ ជាអភិបាលស្រុក (ស្លាប់ដើមឆ្នាំ១៩៧៤)។ ម្ដាយឈ្មោះ រស់ បូផា មុនឆ្នាំ១៩៧៥ រស់នៅភ្នំពេញ។ ក្នុងចំណោមបងប្អូន៩នាក់ ស្រី៤នាក់ ប្រុស៥នាក់ ពីនី ជាកូនទី៣។ ប្រពន្ធរបស់ ពីនី ឈ្មោះ កួន វឡ្លាណា។

ក្នុងឆ្នាំ១៩៥៦ វ៉ាន់ ពីនី បានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ នៅឆ្នាំ ១៩៦១ គាត់ប្រឡងជាប់ចូលរៀនមហាវិទ្យាល័យច្បាប់។ ក្នុងពេលកំពុងរៀននៅមហាវិទ្យាល័យច្បាប់នោះ គាត់ឆ្លៀតបង្រៀននៅសាលាឯកជនខេមរា ដែលមាន ភោគ ឆាយ ជាចាងហ្វាង និងសាលាចម្រើនវិជ្ជា។ នៅសាលាឯកជនខេមរា គាត់បានស្គាល់ លៀវ ជានអ៊ឹម ជាមនុស្សបង្កប់របស់ លន់ ណុន (ប្អូនប្រុសរបស់ លន់ នល់) និង សោម សារី គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ។ ២នាក់នេះ បានអូសទាញគាត់ឱ្យចូលរួមជាមួយចលនាឥស្សរៈរួមខ្មែរបម្រើជាតិ (ដឹកនាំដោយ សឺង ង៉ុកថាញ់) និងបានណែនាំគាត់ឱ្យស្គាល់ ហង្ស ធុនហាក់ (សាស្ត្រាចារ្យសាលាល្ខោនជាតិ) ឧក ប៉ាស៊ី (ចាងហ្វាងមហាវិទ្យាល័យច្បាប់ ក្រោយមកផ្លាស់ទៅធ្វើអគ្គរដ្ឋទូតនៅប្រទេសអង់គ្លេស) អ៊ឹង ម៉ឹង,

របត់នយោបាយ
ថៅ បាន, ឃី តាំងលឹម និងសុន ចាន់។ ក្រោពីនោះ គាត់ឆ្លៀតសរសេរអត្ថបទឱ្យកាសែតឡាដេប៉េស។

នៅចុងឆ្នាំ១៩៦២ ពីនី ត្រូវបានជនជាតិបារាំងពីរនាក់ គឺឈ្មោះ រ៉ូប្លូ និងគួរ ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ ព្រមមទាំង សារិន ឆាក ឱ្យចូលបម្រើការងារក្រៅក្របខ័ណ្ឌរដ្ឋ នៅមហាវិទ្យាល័យច្បាប់ ដោយបានទទួលប្រាក់បៀវត្ស៦០០០រៀលក្នុងមួយខែ។

នៅខែមីនា ឆ្នាំ១៩៦៣ គាត់ប្រឡងជាប់បានចូលរៀននៅសាលាភូមិន្ទរដ្ឋបាល ប៉ុន្តែគាត់នៅតែបន្តធ្វើកិច្ចការនៅមហាវិទ្យាល័យច្បាប់ដដែល។ នៅមហាវិទ្យាល័យច្បាប់ មនុស្សសំខាន់ៗដែលគាត់គិតថា ជាពួកចម្រើននិយម រួមមាន ហ៊ូ យន់, ហូ នឹម, អ៊ុច វ៉ែន និងភោគ ឆាយ។ ចំណែកមិត្តភក្តិជិតស្និទ្ធរបស់គាត់មាន៤នាក់ រួមមាន អាំង ប៊ុនថៃ, ហ៊ូ ប៊ុនឡាយ, ម៉ៅ ផាត់ និងសាយ បូរី។

ឆ្នាំ១៩៦៤ គាត់ចូលរួមជាមួយ ភោគ ឆាយ, ទូន សុខផល្លា, ឈុន សុខងួន និង ប៉ុក កាណែល បង្កើតសមាគមទូទៅនៃនិស្សិតខ្មែរ( AGEK = Association Generale des Etudiants Khmers) នៅភ្នំពេញ។ សមាជិកសមាគមបានបោះឆ្នោតជ្រើសតាំង ភោគ ឆាយ ជាប្រធាន និងរូបគាត់ជាអនុប្រធានសមាគម។ សមាគមទូទៅនៃនិស្សិតខ្មែរមានការទាក់ទងជាហូរហែជាមួយស្ថានទូតចិន នៅភ្នំពេញ។ សមាគមនេះបានយកឯកសារពីប្រទេសចិន និងសៀវភៅឯកសារជាស្នាដៃនិពន្ធរបស់ ម៉ៅ សេទុង ទៅដាក់នៅបន្ទប់អានរបស់សមាគម។ ពេលនោះ អ្នកដែលចេញមុខធ្វើសកម្មភាពបដិវត្តន៍ខ្លាំងជាងគេ គឺ ភោគ ឆាយ, ទូន សុខផល្លា និង ឈុន សុខងួន។

ខែ៤ ឆ្នាំ១៩៦៥ គាត់បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យភូមិន្ទរដ្ឋបាល និងបានចូលប្រើការងារជាក្របខ័ណ្ឌរដ្ឋនៅក្រសួងការបរទេស ផ្នែកនយោបាយ។

ខែតុលា ឆ្នាំ១៩៦៦ ក្រោយពេល ភោគ ឆាយ ត្រូវបានតែងតាំងជាអគ្គនាយកក្រុមហ៊ុនសូណាព្រីម ភោគ ឆាយ បានហៅគាត់ឱ្យទៅធ្វើការជាមួយនៅក្រុមហ៊ុន

របត់នយោបាយ

សូណាព្រីមនោះដែរ តែគាត់ត្រូវចេញទៅធ្វើកម្មសិក្សានៅប្រទេសបារាំង។ ទម្រាំគាត់ត្រឡប់មកពីប្រទេសបារាំងវិញ នៅក្នុងខែ៤ ឆ្នាំ១៩៦៧ ភោគ ឆាយ បានលាឈប់ពីអគ្គនាយកក្រុមហ៊ុនសូណាព្រីមនោះទៅហើយ។ នៅក្នុងខែ៨ ឆ្នាំ១៩៦៨ គាត់ត្រូវបានតែងតាំងឱ្យទៅធ្វើលេខាស្ថានទូតខ្មែរ ប្រចាំនៅប្រទេសបារាំង។

ក្រោយពីមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ វ៉ាន់ ពីនី បានចូលរួមក្នុងចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា ដែលបង្កើតឡើងដោយសម្តេចសីហនុ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០។ គាត់ត្រូវបានតែងតាំង ជាអនុប្រធានតំណាងរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំនៅប្រទេសបារាំង ខណៈ ចាន់ យូរ៉ាន់ ជាប្រធាន និងអ៊ិន សុភាព ជាអគ្គលេខា។ រណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំនៅប្រទេសបារាំង ទើបតែដំណើរការបានមួយរយៈខ្លី ស្រាប់តែ ឱក សាគុន មកបង្ហាញក្រឹត្យតែងតាំងពីក្រុងប៉េកាំង ដែលបញ្ជាក់ថា ខ្លួនគេត្រូវបានតែងតាំងជាតំណាងរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំនៅប្រទេសបារាំងវិញម្តង។ ដូច្នេះ នៅពាក់កណ្តាលខែតុលា ឆ្នាំ១៩៧០ គាត់បានចេញពីក្រុងប៉ារីសទៅទទួលតួនាទីជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស នៅស្នាក់ការរណសិរ្សរួបរួមជាតិកម្ពុជា នៅទីក្រុងប៉េកាំង។ នៅទីក្រុងប៉េកាំង គាត់បានទាក់ទង កែវ មាស ជាមនុស្សជំនិតរបស់សម្តេចសីហនុ និងជាឯកអគ្គរាជទូតរាជរដ្ឋាភិបាលរួបរួមជាតិ ប្រចាំនៅទីក្រុងប៉េកាំង និងមានការទាក់ទងជាមួយទូតបរទេសជាច្រើនផងដែរ។

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧១ អៀង សារី បានមកបំពេញការងារជាតំណាងអង្គការបដិវត្តន៍ នៅទីក្រុងប៉េកាំង។

វ៉ាន់ ពីនី បានរម្លឹកថា លុះដល់ខែតុលា ឆ្នាំ១៩៧១ អៀង សារី បានបើកវគ្គអប់រំរៀនសូត្រដល់សមាជិករណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង ជាលើកដំបូង ដោយយកឯកសារនយោបាយរបស់អង្គការបដិវត្តន៍ពីក្នុងប្រទេស មកអប់រំបង្ហាត់បង្រៀន និងមានការឆ្លងជីវទស្សន៍នៅចុងវគ្គអប់រំរៀនសូត្រនោះ ផងដែរ។ បន្ទាប់ពីចប់វគ្គអប់រំរៀនសូត្រនោះ អៀង សារី បានណែនាំឱ្យបង្កើតគណៈកម្មាធិការរណសិរ្សរួបរួមជាតិ

កម្ពុជាមួយ ប្រចាំនៅទីក្រុងប៉េកាំង ដើម្បីអប់រំមហាជន និងដោះស្រាយគ្រប់បញ្ហាទាំងអស់ដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌរណសិរ្សរួបរួមជាតិកម្ពុជា មួយប្រចាំនៅទីក្រុងប៉េកាំងនោះ។ ពេលនោះ គាត់ថា ការអប់រំមហាជន និងការដោះស្រាយគ្រប់បញ្ហាទាំងអស់ ដែលកើតមានឡើង នៅទីក្រុងប៉េកាំងនោះ គួរតែទុកឱ្យក្រសួងការបរទេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាអ្នកទទួលខុសត្រូវ ដូចពីមុនដដែលទៅ...។ ប៉ុន្តែការជំទាស់របស់គាត់មិនត្រឹមតែមិនបានសម្រេចនោះទេ លុះដល់ឆ្នាំ១៩៧២ គាត់ និងមិត្តភក្តិមួយចំនួន ដូចជា យុគ ចាន់ថា ត្រូវ អៀង សារី ផ្លាស់ទៅធ្វើទូតនៅប្រទេសតង់សានី។ ប៉ែន ញ៉ាច ទៅធ្វើទូតនៅប្រទេសអេហ្ស៊ីប។ ង៉ោ តាំងទីគា ធ្វើការនៅក្រុងប៉េកាំង បានមួយរយៈក៏ផ្លាស់ទៅប្រទេសរ៉ូម៉ានី។ អ៊ិត ហេង ត្រូវទៅបន្តវិជ្ជាពេទ្យនៅប្រទេសរ៉ូម៉ានី។ ស្វាយ បូរី, គាំ លឿងហាក់ និងលឿន ហុងសួ មកធ្វើការនៅក្រសួងការបរទេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំង។ ហេង ពេជ និងអ៊ី ម៉ុង គាត់ត្រូវចូលទៅតស៊ូនៅតំបន់រំដោះក្នុងប្រទេស។ ចំណែក ទេព សំអាន ដែលទើបតែចូលមកទីក្រុងប៉េកាំង បានមួយរយៈខ្លីក៏ត្រូវផ្លាស់ទៅប្រទេសអាល់ហ្សេរី វិញដែរ។ នៅចុងឆ្នាំ១៩៧២ អង្គការបដិវត្តន៍នៅក្នុងប្រទេស ស្នើសុំសម្តេចសីហនុ និងប៉ែន នុត ឱ្យតែងតាំង អៀង សារី ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ពេលនោះសារិន ឆាក បានផ្តល់យោបល់ទៅសម្តេចសីហនុ និងប៉ែន នុត កុំឱ្យតែងតាំង អៀង សារី ជាឧបនាយករដ្ឋមន្ត្រី តាមការស្នើសុំរបស់អង្គការបដិវត្តន៍នៅក្នុងប្រទេសឱ្យសោះ។ ដូច្នេះ ការតែងតាំង អៀង សារី ជាឧបនាយករដ្ឋមន្ត្រី ក៏បានផ្អាកទៅវិញ។

វ៉ាន់ ពីនី បានរម្លឹកបន្តថា ឆ្នាំ១៩៧៣ បន្ទាប់ពីវិលត្រឡប់ពីទស្សនកិច្ចតំបន់រំដោះនៅក្នុងប្រទេសកម្ពុជាវិញ សម្តេចសីហនុ ឈ្វេងយល់ថា អង្គការបដិវត្តន៍នៅក្នុងប្រទេស បានយកចិត្តទុកដាក់ជាមួយព្រះអង្គយ៉ាងពេញទំហឹង ហេតុនេះព្រះអង្គមិនចង់ឱ្យមាននរណាម្នាក់មកធ្វើជាតំណាង ឬធ្វើជាស្ពានរវាងព្រះអង្គ និងអង្គការបដិវត្តន៍នៅក្នុងប្រទេសទេ។ មិនតែប៉ុណ្ណោះ ព្រះអង្គមិនចង់ឱ្យ អៀង សារី មានវត្តមាននៅជិត

របត់នយោបាយ
ព្រះអង្គនៅទីក្រុងប៉េកាំង ផងដែរ។ ដូច្នេះ នៅចុងឆ្នាំ ១៩៧៣ អៀង សារី ក៏វិលត្រឡប់ចូលតំបន់រំដោះនៅក្នុងប្រទេសកម្ពុជា វិញ។

នៅដើមឆ្នាំ១៩៧៤ អង្គការបដិវត្តន៍នៅក្នុងប្រទេស បានស្នើសុំផ្លាស់ប្តូរតែងតាំងសមាសភាពរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាថ្មីមួយ ដែលភាគច្រើនជាអ្នកកំពុងតស៊ូនៅក្នុងប្រទេស និងសុំផ្ទេរ ចាន់ យូរ៉ាន់ និងហួត សម្បត្តិ ឱ្យទៅធ្វើការនៅក្នុងប្រទេសវិញ។ ពេលនោះ គាត ឈន់ បានយកសំណើពីអង្គការបដិវត្តន៍ នៅក្នុងប្រទេសទៅថ្វាយសម្តេចសីហនុ និងជូនប៉ែន នុត នៅខេត្តគ័ងទុង ដើម្បីឡាយព្រះហស្តលេខា និងចុះហត្ថលេខា ចេញក្រឹត្យជាផ្លូវការ។ ការស្នើសុំផ្លាស់ប្តូរតែងតាំងនេះគាត់ (វ៉ាន់ ពីនី) សារភាពថា ដោយសំអាងថា ដួន មុម្ម, ដួន ប្រាសិទ្ធ និង គាត ឈន់ ជារដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅទីក្រុងប៉េកាំង ក៏មិនទាន់បានទៅតស៊ូនៅក្នុងប្រទេសនៅឡើយដែរ គាត់បានស្នើឱ្យ ពុង ប៉េងចេង ជួយនិយាយបញ្ចុះបញ្ចូលសម្តេចសីហនុធ្វើយ៉ាងណាកុំឱ្យព្រះអង្គឡាយព្រះហស្តលេខា លើក្រឹត្យតែងតាំងរាជរដ្ឋាភិបាលថ្មីនោះឱ្យសោះ។ ដោយសារបញ្ហានេះ នាំឱ្យមានទំនាស់យ៉ាងខ្លាំងនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងប៉េកាំង។ រហូតដល់ខែ៤ ឆ្នាំ១៩៧៤ ខៀវ សំផន និងអៀង សារី ដឹកនាំគណៈប្រតិភូទៅទីក្រុងប៉េកាំង ដើម្បីចរចាសម្រុះសម្រួលទើបរឿងនេះបានស្ងប់ស្ងាត់វិញ។

នៅក្នុងខែតុលា ឆ្នាំ១៩៧៤ អៀង សារី ដឹកនាំគណៈប្រតិភូសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយទៅបំពេញទស្សកិច្ចនៅទីក្រុងប៉េកាំង ក្នុងទិសដៅសុំជំនួយយោធា និងសេដ្ឋកិច្ច ពីមេដឹកនាំចិន ក្នុងនោះក៏មានការទាក់ទងសុំបោះពុម្ពក្រដាសប្រាក់ សម្រាប់ចាយវាយក្នុងតំបន់រំដោះរបស់រណសិរ្សរួបរួមជាតិកម្ពុជា ផងដែរ។

# ៧.១៤. រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង របស់ពួកខ្មែរក្រហម



**មេដឹកនាំកំពូល និងសំខាន់ៗ របស់បក្សកុម្មុយនិស្តកម្ពុជា**

ពេលនោះ ពួកមេខ្មែរក្រហម បានធ្វើការបែងចែករចនាសម្ព័ន្ធដឹកនាំប្រទេស មានថ្នាក់មជ្ឈិម, ថ្នាក់ភូមិភាគ, ថ្នាក់តំបន់, ថ្នាក់ស្រុក និងថ្នាក់សង្កាត់ “ ឃុំ ” ដោយមិនមានថ្នាក់ខេត្ត ដូចរដ្ឋបាល លន់ នល់ និងដូចរដ្ឋបាលកាលសម័យសង្គមរាស្ត្រនិយមទេ។

នង សួន ធ្លាប់ជាសមាជិកបម្រុងគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ កាលពីសម័យតស៊ូប្រឆាំងនឹងបារាំង ហើយនៅក្នុងសម័យសង្គមរាស្ត្រនិយម ជាមេដឹកនាំគណបក្សប្រជាជន ចេញមុខប្រឆាំងនឹងសម្តេចសីហនុ ត្រូវតុលាការសឹកកាត់ទោសប្រហារជីវិត ក្នុងខែឧសភា ឆ្នាំ១៩៦២។ តែក្រោយមក ត្រូវបានសម្តេចសីហនុបន្ធូរបន្ថយទោសឱ្យមកនៅត្រឹមជាប់គុកអស់មួយជីវិតនោះ ត្រូវបាន លន់ នល់ មេ

របត់នយោបាយ

ដឹកនាំរដ្ឋប្រហារដោះលែងឱ្យមានសេរីភាពវិញ ក្នុងខែមេសា ឆ្នាំ១៩៧០ គាត់ក៏បានរត់ចេញពីទីក្រុងភ្នំពេញ ទៅចូលរួមតស៊ូបន្តទៀត នៅតំបន់រំដោះនាភូមិភាគនិរតី។

ក្រោយពីខិតខំលត់ដំកសាងខ្លួន ក្នុងចលនាតស៊ូ នៅរលាក់កងជើង, តាសាយ, ខ្លុងអាយ និងតោងម៉ោង ក្នុងខេត្តកំពង់ស្ពឺ រយៈពេល៥ខែមក នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧០ នង សួន ត្រូវបានចាត់តាំងជាលេខាគណៈកម្មាធិការបក្សតំបន់៣១ របស់ភូមិភាគនិរតី។

ចាប់ពីចុងខែមីនា ឆ្នាំ១៩៧០ មក តំបន់២៥នេះ ស្ថិតនៅក្រោមការដឹកនាំដោយកម្មាភិបាលជាជនជាតិវៀតណាមម្នាក់ ឈ្មោះ ហាយ ផាយ តែប្រើឈ្មោះខ្មែរថា ទេព ផាន។ លុះដល់ចុងខែធ្នូ ឆ្នាំ១៩៧០ ឈ្មោះ ហាយ ផាយ ហៅទេព ផាន ត្រូវដកចេញ និងឱ្យវិលត្រឡប់ទៅខេត្តអាងយ៉ាង វៀតណាមខាងត្បូងវិញ មានអតីតខ្មែរវេស្សរៈវៀតមិញមកពីក្រុងហាណូយ ៨នាក់ ក្នុងនោះមានម្នាក់ ឈ្មោះ សូ ពុំ ត្រូវបានចាត់តាំងជាលេខាគណៈកម្មាធិការបក្សតំបន់២៥ និងម្នាក់ទៀត ជាអ្នកតស៊ូមកពីក្រុងហាណូយដែរ ឈ្មោះ សៀន សាន ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានយោធាតំបន់។

ជាមួយគ្នានោះដែរ ក៏មានបញ្ញវន្ត (សាស្ត្រាចារ្យ និងគ្រូបង្រៀន) ជាអ្នកតស៊ូនៅក្នុងស្រុកប្រមាណ២០នាក់ទៀត ត្រូវបានចាត់តាំង ជាកម្មាភិបាលសំខាន់ៗ នៅក្នុងតំបន់២៥ នេះដែរ ដូចជា សុខ ប៊ុតចំរើន ជាអតីតអ្នករៀបចំម៉ាស៊ីនបោះពុម្ពរបស់កាសែតប្រជាជននៅទីក្រុងភ្នំពេញ កាលពីចុងទសវត្សរ៍ឆ្នាំ១៩៥០ ជាមួយ នង សួន ដែលកាលនោះជាចាងហ្វាងកាសែតប្រជាជន។

សុខ ប៊ុតចំរើន ចូលប្រឡូកក្នុងចលនាតស៊ូដំបូង ក៏ដោយសារមានការអប់រំណែនាំពី នង សួន។ សុខ ប៊ុតចំរើន ក៏ជាមនុស្សជិតស្និទ្ធជាមួយ កែវ មាស និងជូ ជេត (ហៅសមមិត្ត ស៊ី លេខាបក្សភូមិភាគបស្ចិម) ផងដែរ។ ឯឈ្មោះ សុខ ជាអតីតគ្រូបង្រៀនម្នាក់បានចូលរួមក្នុងចលនាបដិវត្តន៍ក្នុងឆ្នាំ១៩៥៩ តាមរយៈ ណៃ សារ៉ាន់ (សមមិត្ត យ៉ា លេខាបក្សភូមិភាគឦសាន)។ ចំណែក ហួត ស៊ី ចូលរួមតស៊ូធ្វើបដិវត្តន៍

របត់នយោបាយ

ក្នុងឆ្នាំ១៩៦៧ តាមរយៈ សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា។

អ្នកទាំង៣នាក់ នេះ ( ចំរើន, សុខ និងសី ) ត្រូវបានគេរាយការណ៍ថា មានជម្លោះយ៉ាងស្រួចស្រាវជាមួយកម្មាភិបាលម្នាក់ទៀត ឈ្មោះ គៀត ដែលជាខ្សែរយៈរបស់ថ្នាក់ដឹកនាំមជ្ឈិមបក្ស តែគេមិនបានដឹងថា ទំនាស់នោះកើតឡើងដោយសារបញ្ហាអ្វីទេ។ តែក្រោយមក ឈ្មោះ គៀត ត្រូវគេសម្លាប់ចោល ហើយមានគេរាយការណ៍ទៅមជ្ឈិមបក្សថា អ្នកទាំង៣នាក់នេះ ( ចំរើន, សុខ និងសី ) រួមគ្នាសម្លាប់ឈ្មោះ គៀត នោះ។

ក្រោយពេលវាយដណ្ដើមកាន់កាប់ស្រុកជាច្រើន នៅជុំវិញទីក្រុងភ្នំពេញ មកនៅដើមឆ្នាំ១៩៧១ គណៈកម្មាធិការមជ្ឈិមបក្ស ដែលគេហៅថា អង្គការថ្នាក់លើ បានបង្កើតភូមិភាគថ្មីមួយ ហៅថាភូមិភាគពិសេស មានឈ្មោះសម្ងាត់ថា ភូមិភាគ៣០៥ មានទីតាំងភូមិសាស្ត្រនៅខាងលិច និងខាងត្បូងទីក្រុងភ្នំពេញ។ វន វ៉េត ត្រូវបានចាត់តាំងឱ្យធ្វើជាលេខាគណៈកម្មាធិការបក្សភូមិភាគពិសេស ដែលបានបង្កើតថ្មីនោះ នង សួន ជាលេខាគណៈកម្មាធិការបក្សតំបន់៣១ និងចេង អន ត្រូវបានចាត់តាំងជាលេខាគណៈកម្មាធិការបក្សតំបន់១៥។

វន វ៉េត បានចាត់តាំងអតីតពួកបញ្ញវន្ត ដែលចេញមកទីក្រុងភ្នំពេញ ឱ្យកាន់តំណែងសំខាន់ៗ ដូចជា រស់ ជេទ្វោ ហៅជាតិ ជាប្រធានមន្ទីរភូមិភាគ, សៀង ប៉ោសែ ហៅនាគ ជាប្រធានមន្ទីរសេដ្ឋកិច្ចភូមិភាគ និងជី គឹមអាន ជាប្រធានមន្ទីរឃោសនាការ និង បោះពុម្ពផ្សាយ។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៧១ វន វ៉េត បានដក នង សួន ជាលេខាគណៈកម្មាធិការបក្សតំបន់៣១ ឱ្យមកស្នាក់នៅមន្ទីរភូមិភាគពិសេស រយៈពេល៣សប្ដាហ៍ដើម្បីអប់រំបំពាក់បំប៉នគោលជំហរឱ្យ នង សួន បានយល់ពីផែនការឈ្លានពានវាតទី និងពីល្បិចកលរបស់ពួកវៀតកុង-វៀតណាមខាងជើង ក្នុងពេលធ្វើសង្គ្រាមផ្ដួលរម្លំរបបលន់ នល់ នោះ។

របត់នយោបាយ



នង សួន

វន វ៉េត ក៏បានប្រាប់ នង សួន ដែរ ថា អង្គការបានផ្លាស់គាត់ចេញពីលេខាគណៈកម្មាធិការបក្សតំបន់៣១ ឱ្យនៅធ្វើជាលេខាគណៈកម្មាធិការបក្សតំបន់២៥វិញ ព្រមទាំងតម្លើងឋានៈ គាត់ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគពិសេសផងដែរ។

វន វ៉េត បានបញ្ជាក់ប្រាប់ នង សួន ថា នៅតំបន់២៥ នោះ មានកម្មាភិបាល៣នាក់ គឺ ចំរើន, សុខ និងសី ជាមនុស្សជិតស្និទ្ធនឹងវៀតណាម និងបានសម្លាប់កម្មាភិបាលម្នាក់ឈ្មោះ គៀត ជាកម្មាភិបាលជិតស្និទ្ធនឹងគណៈមជ្ឈិមបក្ស។ តែទោះបីយ៉ាងណា កុំធ្វើសកម្មភាពអ្វីដែលធ្វើឱ្យកម្មាភិបាលនៅទីនោះ មានសតិអារម្មណ៍ដល់កាប្រឹងប្រែងក្នុងការធ្វើសង្គ្រាមឱ្យសោះ គឺត្រូវរកវិធីអូសទាញពួកគេសិន ហើយប្រុងប្រយ័ត្នកុំឱ្យពួកវៀតណាមអូសទាញពួកគេបានឱ្យសោះ។ ដោយឡែក ចំពោះកងទ័ពវៀតណាម ដែលនៅទីនោះ យើងត្រូវបំផុសប្រជាជនឱ្យចេញមុខបះបោរប្រឆាំងតាមគ្រប់រូបភាព។ ប្រសិនបើអាចចៀសវាងបាន កុំប្រើអាវុធឱ្យសោះ យើងត្រូវប្រើនយោបាយប្រសើរជាង។

ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧១ នង សួន បានធ្វើដំណើរជាមួយនីរសា និងអង្គរក្ស១២នាក់ទៀត ទៅដល់មន្ទីរតំបន់២៥។ សូ ពុំ ដែលកំពុងកាន់តំណែងលេខាគណៈកម្មាធិការបក្សតំបន់២៥នោះ មានការងឿងឆ្ងល់យ៉ាងខ្លាំង។ ៣ថ្ងៃក្រោយមក នង សួន ក៏បានប្រាប់ទៅឈ្មោះ សុខ ជាប្រធានសន្តិសុខតំបន់នោះថា គាត់ត្រូវបានអង្គការចាត់តាំងឱ្យមកធ្វើជាលេខាគណៈកម្មាធិការបក្សតំបន់២៥នេះ។ ពេលនោះ សុខ និងកម្មាភិបាលជាច្រើនទៀតបានជំទាស់នឹងវិធីចាត់តាំងនោះ ដោយយល់ថា ទោះបី

របត់នយោបាយ

គណៈកម្មាធិការមជ្ឈិមមិនបានចុះមកធ្វើពិធីប្រកាសចាត់តាំងជាផ្លូវការឱ្យ នង សួន មកធ្វើជាលេខាគណៈកម្មាធិការបក្សតំបន់២៥ នេះក៏ដោយ យ៉ាងហោចណាស់ក៏មានមេដឹកនាំថ្នាក់ភូមិភាគមកជាអធិបតីដែរ មិនត្រូវឱ្យ នង សួន មកប្រកាសដោយខ្លួនឯងបែបនេះឡើយ។

សូ ពុំ និងពួកកម្មាភិបាល ជាសមមិត្តរបស់គាត់ មិនព្រមចាកចេញពីតំបន់២៥ ដើម្បីប្រគល់អំណាចឱ្យ នង សួន ដោយងាយៗឡើយ ដោយចាំគាត់រាយការណ៍ទៅ សោ ភឹម ជាលេខាបក្សភូមិភាគបូព៌ា ឱ្យបានដឹងពីរឿងនេះ និងបានស្នើឱ្យ នង សួន ចាកចេញទៅវិញសិន។ ប៉ុន្តែ នង សួន មិនព្រមចេញទៅណាតាមការស្នើសុំនោះឡើយ។

អំឡុងពេលមិនព្រមចាកចេញនោះ នង សួន បានឆ្លៀតឱកាសទាក់ទាញប្រធានសន្តិសុខតំបន់ ឈ្មោះ សុខ ឱ្យមកនៅខាងគាត់។ ចំណែកកម្មាភិបាលជាអតីតគ្រូបង្រៀនជាង១០នាក់ នៅតែស្មោះត្រង់នឹង សូ ពុំ ដដែល។ ប៉ុន្តែ នង សួន មានប្រជាប្រិយភាពជាង សូ ពុំ ព្រោះគាត់ធ្លាប់ល្បីឈ្មោះនៅតំបន់នោះ តាំងពីសម័យតស៊ូប្រឆាំងនឹងបារាំង ជាមួយ ពុត ឆាយ និងងិន ហោ មកម្ល៉េះ។ ដូច្នេះ មិនយូរប៉ុន្មានកម្មាភិបាលមួយចំនួនដែលធ្លាប់តែស្មោះត្រង់នឹង សូ ពុំ បានផ្លាស់ប្ដូរចិត្តទៅនៅខាង នង សួន វិញ ដូចជាប្រធានសន្តិសុខតំបន់ ឈ្មោះ សុខ ដែរ ហើយចាប់ផ្ដើមលួចហៅ សូ ពុំ និងកម្មាភិបាលដែលនៅតែស្មោះត្រង់ជាមួយ សូ ពុំ ថាជាពួកខ្មែរពាក់ដួន (យួន) ទៀតផង។

បន្ទាប់មកទៀត កម្មាភិបាល ២នាក់ទៀត គឺ ចំរើន និងសី ដែល វន វ៉េត បានប្រាប់ នង សួន ថា ជាជនក្បត់ ឱ្យ នង សួន មានការប្រុងប្រយ័ត្ននោះ ក៏បានសម្រេចដើរចេញពី សូ ពុំ មកធ្វើការងារជាមួយ នង សួន ដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ នង សួន នៅតែរក្សាទំនាក់ទំនងល្អជាមួយ សូ ពុំ ជាធម្មតា។

ពេលនោះដែរ នង សួន ក៏បានឆ្លៀត ឱកាសទៅជួបសមមិត្ត ឈូក (សួស នៅ) ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគបូព៌ា និងជាលេខាគណៈកម្មាធិការបក្សតំបន់២៤

របត់នយោបាយ

ដែលនៅត្រើយខាងកើតទន្លេមេគុងក្រោមនោះ បាន២-៣លើកដែរ។

ក្រោយពីទៅនៅជាមួយ នង សួន មិនបានប៉ុន្មានសប្ដាហ៍ផង ប្រធានសន្តិសុខតំបន់ ឈ្មោះ សុខ ក៏បានសម្ដែងឱ្យ នង សួន ឃើញនូវសកម្មភាពស្អប់ខ្ពើមប្រឆាំងនឹងពួកវៀតណាម របស់ខ្លួនកាន់តែខ្លាំងឡើងៗ បើទោះជាពេលនោះ កងទ័ពវៀតកុង និងកងទ័ពខ្មែរ កំពុងសហការគ្នាយ៉ាងជិតស្និទ្ធនៅលើសមរភូមិក៏ដោយ។

មិនតែប៉ុណ្ណោះ នៅដើមឆ្នាំ១៩៧២ ក្រោយពីឮដំណឹងថា សុខ មានបំណងចង់កម្ទេចអ្នកដែលស្មោះត្រង់នឹងខ្លួន សូ ពុំ ក៏បានជិះម៉ូតូទៅជួប សុខ ដើម្បីសម្របសម្រួលកុំឱ្យមានបញ្ហាបង្ហូរឈាមគ្នា។

ដើម្បីបន្ធូរភាពតានតឹង នង សួន ក៏បានព្យាយាមស្នើសុំឱ្យ សូ ពុំ ទទួលតំណែងជាអនុលេខាបក្សតំបន់២៥ នោះដែរ ដើម្បីបង្រួបបង្រួមគ្នា និងបញ្ចប់បញ្ហា។ ប៉ុន្តែ សូ ពុំ មិនព្រម។

រហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧២ ដោយមានការសម្របសម្រួលពី សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា សូ ពុំ ក៏បានសម្រេចចិត្តឆ្លងទន្លេមេគង្គទៅតំបន់២៤ បាត់ទៅ ហើយ នង សួន ក៏បានកាន់តំណែងជាលេខាគណៈកម្មាធិការបក្សតំបន់២៥ នៅក្រោមការគ្រប់គ្រងរបស់ភូមិភាគពិសេស ដោយគ្មានបញ្ហាចម្រូងចម្រាសអ្វីទៀតឡើយ។ ក្រោយពី សូ ពុំ ចាកចេញទៅបាត់ នង សួន ក៏បានចាត់តាំងឱ្យ ចំរើន ឡើងជាអនុលេខាគណៈកម្មាធិការបក្សតំបន់២៥ ទទួលបន្ទុកជាប្រធានសេដ្ឋកិច្ច។ ឯ សុខ និងសី ក៏បានឡើងជាសមាជិកគណៈកម្មាធិការបក្សតំបន់២៥ ដែរ។ ចំណែកឯកម្មាភិបាលជាអ្នកតស៊ូមកពីក្រុងហាណូយ ៦នាក់ទៀត ក៏នៅបន្តការងារជាមួយ នង សួន ជាធម្មតា។

នៅពេលចាប់ផ្ដើមតស៊ូធ្វើសង្គ្រាមពីឆ្នាំ១៩៧០មកដល់ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានបែងចែកទឹកដីដែលពួកគេគ្រប់គ្រងជា ៦ភូមិភាគ រួមមាន៖

១. ភូមិភាគបូព៌ា ឬភូមិភាគ២០៣ មាន សោ ភឹម ជាលេខាគណៈកម្មាធិការបក្ស

ភូមិភាគ។ ភូមិភាគបូព៌ា រួមមានខេត្តព្រៃវែងទាំងមូល, ខេត្តស្វាយរៀងទាំងមូល, បណ្តាស្រុកទាំងឡាយរបស់ខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយខាងកើតទន្លេមេកុង, ស្រុកឆ្លូង របស់ខេត្តក្រចេះ និងស្រុកបីទៀតក្នុងខេត្តកណ្តាល គឺស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងស្រុកមុខកំពូល។ ភូមិភាគនេះចែកចេញជា ៥តំបន់ គឺតំបន់២០, តំបន់២១, តំបន់២២, តំបន់២៣, តំបន់២៤ និងតំបន់២៥ ដែលត្រូវកាត់ឱ្យភូមិភាគពិសេសក្នុងឆ្នាំ១៩៧១។

២. ភូមិភាគឦសាន ឬភូមិភាគ១០៨ មាន ណៃ សារ៉ាន់ ហៅយ៉ា ជាលេខាគណៈកម្មាធិការបក្សភូមិភាគ។ ភូមិភាគឦសាន រួមមាន៖ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ទាំងមូល។ ភូមិភាគនេះ បែងចែកជា ៤តំបន់ គឺតំបន់១០១, តំបន់១០២, តំបន់១០៤ និងតំបន់១០៧។

៣.ភូមិភាគឧត្តរ ឬភូមិភាគ៣០៣ មាន កុយ ធួន ហៅសមមិត្តធុច ឬឃួន ជាលេខាគណៈកម្មាធិការបក្សភូមិភាគ, ឈូក ឆាង ហៅ ជ ឆាន ហៅសមមិត្ត ស្រេង ជាអនុលេខាបក្ស និងកែ ពក ជាប្រធានយោធា។ ភូមិភាគឧត្តរ រួមមាន៖ ខេត្តកំពង់ធំទាំងមូល, បណ្តាស្រុកទាំងឡាយរបស់ខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គលើ និងស្រុកព្រែកប្រសព្វ ដែលកាត់យកពីខេត្តក្រចេះ។ ភូមិភាគនេះចែកចេញជា៣តំបន់ គឺតំបន់៤១, តំបន់៤២ និងតំបន់៤៣។

៤.ភូមិភាគពាយ័ព្យ ឬភូមិភាគ៥៦០ មាន មូល សម្បត្តិ ហៅរស់ ញឹម ហៅកៅអតីតអ្នកតស៊ូជំនាន់ខ្មែរ-វៀតមិញ ជាលេខាគណៈកម្មាធិការបក្សភូមិភាគ និងគង់ សុផល ហៅកឺ ជាអតីតគ្រូបង្រៀននៅភ្នំពេញ ជាអនុលេខាគណៈកម្មាធិការបក្សភូមិភាគ និងជាប្រធានយោធាភូមិភាគ។ គង់ សុផល ហៅសមមិត្ត កឺ ចូលធ្វើបដិវត្តន៍តាមរយៈ វន វ៉េត កាលពីឆ្នាំ១៩៦១។ ភូមិភាគពាយ័ព្យ រួមមាន៖ ខេត្តពោធិ៍សាត់ និងបាត់ដំបង។ ភូមិភាគនេះចែកចេញជា៧តំបន់ គឺតំបន់១, តំបន់២, តំបន់៣, តំបន់៤, តំបន់៥, តំបន់៦ និងតំបន់៧។

របត់នយោបាយ

៥.ភូមិភាគនិរតី ឬភូមិភាគ៤០៥ មាន ឈិត ជឿន ហៅ ម៉ុក ជាលេខាគណៈកម្មាធិការបក្សភូមិភាគ។ ភូមិភាគនិរតី រួមមាន៖ ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកោះកុង កំពង់សោម និងស្រុកមួយចំនួនរបស់ខេត្តកណ្តាល។ ភូមិភាគនេះចែកចេញជា ៨តំបន់ គឺ តំបន់៣៣, តំបន់៣៥, តំបន់៣១, តំបន់៣២, តំបន់៣៧, តំបន់១១, តំបន់១៥ និងតំបន់១៣។ កាលដើមទសវត្សរ៍ ឆ្នាំ១៩៦០ គឺនៅក្នុងសម័យតស៊ូនយោបាយរួមផ្សំអាវុធនោះ ឈ្មោះ ម៉ា ម៉ង់ ហៅញឹម ជាលេខាគណៈកម្មាធិការបក្សភូមិភាគនិរតី។ ប្រភពព័ត៌មានមួយបានឱ្យដឹងថា ឈ្មោះ ម៉ា ម៉ង់ ហៅ ញឹម នេះក៏បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៦៨ ដោយមិនដឹងថា ត្រូវប៉ូលិស ឬទាហានរដ្ឋាភិបាលសម្តេចសីហនុ សម្លាប់ ឬយ៉ាងណាទេ? តែបើតាម កាំង ហ្កេចអ៊ាវ ហៅ ឌុច បានបញ្ជាក់ថា ឈ្មោះ ម៉ា ម៉ង់ ជាលេខាគណៈកម្មាធិការបក្សភូមិភាគនិរតីនោះ ត្រូវបាត់បង់ជីវិតនៅលើភ្នំឱរ៉ាល់ នៅក្នុងឆ្នាំ១៩៦៨ ដោយសារពេទ្យចាក់ថ្នាំច្រឡំ។

នៅក្នុងសង្គ្រាមដែលចាប់ផ្តើមក្រោយរដ្ឋប្រហារ ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ឈិត ជឿន ឬតាម៉ុក ជាលេខាគណៈកម្មាធិការបក្សភូមិភាគ ទទួលបន្ទុកការងារយោធា និងសន្តិសុខ។ ឯ ជូ ជេត ហៅសមមិត្ត ស៊ី ជាអនុលេខាគណៈកម្មាធិការបក្សភូមិភាគ និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនភូមិភាគ ទទួលបន្ទុកកិច្ចការនយោបាយ និងរដ្ឋបាល។

ចំណែក ប្រាសិទ្ធ ហៅ តាចុង លេខាគណៈកម្មាធិការបក្សតំបន់១១ (ខេត្តកោះកុង) និងសង្ហា ហឿន ជាអតីត មេខ្មែរឥស្សរៈល្បីឈ្មោះនៅខេត្តកំពង់ស្ពឺ ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគ។

ធុច រិន ហៅ ឱក គ្រិន អតីតសាស្រ្តាចារ្យបរិញ្ញាបត្រផ្នែកអក្សរសាស្រ្ត មនុស្សសាស្រ្ត នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាលេខាគណៈកម្មាធិការសម្ព័ន្ធយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) និងជាប្រធានវប្បធម៌ភូមិភាគផងដែរ។ នៅចុងឆ្នាំ១៩៧០ តាម៉ុក លេខាគណៈកម្មាធិការបក្សភូមិភាគ ចាប់ផ្តើមមានទំនាស់ជាមួយ ជូ ជេត អនុលេខា

របត់នយោបាយ

គណៈកម្មាធិការបក្សភូមិភាគ និងប្រាសិទ្ធ ហៅ តាចុង កាន់តែតានតឹងឡើងៗ។

នៅក្នុងដើមឆ្នាំ១៩៧១ ក្នុងនាមតំណាងថ្នាក់ដឹកនាំគណៈកម្មាធិការមជ្ឈិមបក្ស វន វ៉េត បានចុះទៅធ្វើការនៅមន្ទីរភូមិភាគនិរតី។ ពេលនោះ តាម៉ុក មិននៅក្នុងមន្ទីរភូមិភាគទេ ព្រោះគាត់ត្រូវចុះជាប់នៅសមរភូមិមុខ។ នៅមន្ទីរភូមិភាគនិរតី វន វ៉េត បានជួបតែ ជូ ជេត ហៅ ស៊ី និងប្រាសិទ្ធ ហៅតា ចុង ព្រមទាំងកម្មាភិបាលជំនួយការ៣នាក់ ទៀត គឺក្រូច, ហុក និងគង់។ ជូ ជេត និងប្រាសិទ្ធ បានរាយការណ៍ពីបញ្ហាជម្លោះរបស់ពួកគាត់ជាមួយតាម៉ុក ឱ្យ វន វ៉េត បានដឹង។ ជម្លោះរវាងតាម៉ុក និងជូ ជេត ហៅ ស៊ី មិនសូវខ្លាំងក្លាប៉ុន្មានទេ។ អ្នកដែលមានជម្លោះខ្លាំងជាងគេ ជាមួយ តាម៉ុក គឺ ប្រាសិទ្ធ ហៅ តាចុង។

វន វ៉េត បានព្យាយាមណែនាំ ជូ ជេត និងប្រាសិទ្ធ ឱ្យរម្ងាប់ទំនាស់ជាមួយ តាម៉ុក និងចង់ឱ្យក្រុម ជូ ជេត និងក្រុម តាម៉ុក រួបរួមសាមគ្គីគ្នាឡើងវិញ ព្រោះរូបគាត់ផ្ទាល់ក៏ជាមិត្តភក្តិជាមួយតាម៉ុក តាំងពីយូរមកហើយ។ ជូ ជេត យល់ព្រមតាមការណែនាំរបស់ វន វ៉េត។ ប៉ុន្តែ ប្រាសិទ្ធ នៅតែមិនអាចផ្សះផ្សាជាមួយតាម៉ុក ដដែល។

ឯភូមិភាគពិសេសបានបង្កើតឡើងនៅដើមឆ្នាំ១៩៧១ ក្នុងបំណងវាយដណ្តើមយកទីក្រុងភ្នំពេញឱ្យបានឆាប់រហ័ស។ ភូមិភាគពិសេសនេះ ត្រូវកាត់យកតំបន់១៥ និងតំបន់៣១របស់ភូមិភាគនិរតី។ លុះដល់ពាក់កណ្តាល ឆ្នាំ១៩៧១ បានកាត់យកតំបន់២៥ របស់ភូមិភាគបូព៌ា មួយទៀត។

ក្រៅពីភូមិភាគទាំង៦ ខាងលើនេះ មេដឹកនាំខ្មែរក្រហម ក៏បានបង្កើតឱ្យមានតំបន់ស្វយ័ត ឬហៅថា តំបន់ឯករាជ្យ ចំនួន៤ទៀតផងដែរ គឺតំបន់៥០៥ (ខេត្តក្រចេះ), តំបន់១០៥ (ខេត្តមណ្ឌលគីរី) តំបន់១០៦ (ខេត្តសៀមរាប និងឧត្តរមានជ័យ) និងតំបន់១០៣ (ខេត្តព្រះវិហារ និងស្រុកមួយចំនួននៃខេត្តស្ទឹងត្រែង ដែលស្ថិតនៅខាងលិចទន្លេមេគង្គ)។ តំបន់ទាំង៣នេះ មិនឋិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគណាមួយឡើយ គឺគណៈកម្មាធិការមជ្ឈិមបក្ស ជាអ្នកគ្រប់គ្រងផ្ទាល់តែម្តង។




**ផែនទីសម័យកម្ពុជាប្រជាធិបតេយ្យ**

---

# ៧.១៥. មេដឹកនាំកុម្មុយនិស្តចិន និងវៀតណាម ជួយជ្រោមជ្រែងសម្តេចសីហនុ




**សម្តេចសីហនុ និងម៉ៅ សេទុង  សម្តេចសីហនុ និងផាម វ៉ាន់ដុង**

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧០ សម្តេចសីហនុ អមព្រះរាជដំណើរដោយអ្នកម្នាងម៉ូនិក ជាមហេសី និងប៉ែន នុត នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រមទាំងមន្ត្រីមួយចំនួនទៀត បានយាងទៅបំពេញទស្សនកិច្ចជាផ្លូវការនៅប្រទេសវៀតណាមខាងជើង ដូចការគ្រោងទុក។

ប្រធានាធិបតី តុង ដុកថាំង និងនាយករដ្ឋមន្ត្រី ផាម វ៉ាន់ដុង បានរៀបចំពិធីទទួលស្វាគមន៍សម្តេចសីហនុ យ៉ាងអធិកអធមបំផុត។ ព្រះអង្គ និងមេដឹកនាំវៀតណាមខាងជើង បានពិភាក្សា និងឯកភាពគ្នាយ៉ាងប្តូរផ្តាច់ក្នុងការរួបរួមគ្នាដើម្បីវាយផ្តួលរម្លំរបបរដ្ឋប្រហាររបស់ លន់ នល់ និងវាយបណ្តេញពួកចក្រពត្តិអាមេរិក និងកងទ័ពរដ្ឋការវៀតណាមខាងត្បូង ឱ្យចេញពីទឹកដីកម្ពុជា ផងដែរ។

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧០ តំណាងរណសិរ្សរួបរួមជាតិកម្ពុជា និងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង (វៀតកុង) បានជួបពិភាក្សាគ្នានៅទីក្រុងប៉ារីស ដើម្បីបញ្ជាក់ពីគោលដៅរួមនៃការតស៊ូរបស់ភាគីទាំង២ ជាថ្មីម្តងទៀត។




**សម្ដេចសីហនុ និងគីម អ៊ីលស៊ុង នៅក្រុងព្យុងយ៉ាង**

ល្ងាចថ្ងៃអាទិត្យ ទី១៤ ខែមិថុនា ឆ្នាំ១៩៧០ សម្ដេចសីហនុ បានធ្វើដំណើរតាមរថភ្លើងពិសេស ពីក្រុងប៉េកាំង ទៅប្រទេសកូរ៉េខាងជើង តាមការយាងរបស់សេនាប្រមុខ គីម អ៊ីលស៊ុង។ មេដឹកនាំចិន បានរៀបចំពិធីជូនព្រះរាជដំណើរយ៉ាងអធិកអធមបំផុត។ ឯកអគ្គរដ្ឋទូតបារាំង និងភារធារីសហភាពសូវៀត នៅក្រុងប៉េកាំង ក៏មានវត្តមានក្នុងពិធីជូនព្រះរាជដំណើរនោះដែរ។

ក្រៅពីប្រទេសកូរ៉េខាងជើង សម្ដេចសីហនុ ក៏គ្រោងយាងទៅបំពេញទស្សនកិច្ចនៅប្រទេសអ៊ីរ៉ាក់ តាមការយាងរបស់ប្រធានាធិបតី អាម៉េដហាស្សាន់ ផងដែរ។

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧០ នៅក្នុងជំនួបមួយនៅទីក្រុងប៉េកាំង នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានថ្លែងប្រាប់លោកស្រី ង្វៀង ធីប៊ីញ រដ្ឋមន្ត្រីការបរទេសវៀតណាមខាងជើង ថា៖ កាលសម័យសង្គ្រាមកូរ៉េ  នៅពេលអាមេរិក ចាប់ផ្ដើមធ្វើសង្គ្រាមឈ្លានពានមកលើប្រទេសចិន ទើបនឹងរំដោះបាន យើងខ្ញុំបានប្រយុទ្ធតស៊ូយ៉ាងប្លូរផ្ដាច់ ហើយសមមិត្តប្រធាន ម៉ៅ បានព្រមានទៅអាមេរិក វិញថា នៅពេលណាអ្នកឯងចូលមកដល់ទន្លេយ៉ាលូ យើងគ្មានធ្វើអ្វី ក្រៅពីការវាយបកទៅវិញនោះឡើយ ហើយបើយើងមិនគាំទ្រកូរ៉េខាងជើង ទេ កូរ៉េខាងជើង នឹងត្រូវធ្លាក់ក្នុងកណ្ដាប់ដៃអាមេរិក បាត់ទៅហើយ។

របត់នយោបាយ

តែពេលនោះ យើងក៏មិនដឹងច្បាស់ពីលទ្ធផលនៃការធ្វើអន្តរាគមន៍របស់យើងដែរ។ ប៉ុន្តែ សមមិត្តប្រធាន ម៉ៅ បាននិយាយថា ប្រជាជនចិន មានសិទ្ធិគាំទ្រប្រជាជនកូរ៉េ ហើយ ប្រសិនបើគេរុញច្រានយើង យើងក៏អាចវាយបកទៅវិញ។

ផូ អេនឡាយ បញ្ជាក់ថា មុនដំបូង យើងវាយកងទ័ពអាយ៉ង (ជៀង កាយជៀក)។ លុះដល់សង្គ្រាមលោកលើកទី២ ចាប់ផ្តើម យើងត្រូវប្រឈមមុខជាមួយនឹងកងទ័ព អាមេរិក ទៀត។ ក្រោយពីបើកការប្រយុទ្ធគ្នាបាន ២-៣លើកមក យើងដឹងថា អាមេរិក មិនសូវខ្លាំងប៉ុន្មានទេ។ តើវាមិនមែនជាការពិតទេឬ ដែលថា សមមិត្តមានបទពិសោធ ពីភាពទន់ខ្សោយទៅរកភាពខ្លាំង ហើយសមមិត្តបាន និងកំពុងប្រយុទ្ធក្នុងសង្គ្រាមមួយ ដែលមានទំហំធំជាងសង្គ្រាមនៅកូរ៉េ ទៅទៀតនោះ?។ នេះជាការពិត ដូចដែលសម មិត្តប្រធាន ម៉ៅ បានថ្លែងការណ៍ កាលពីថ្ងៃទី២៥ ខែឧសភា ថា៖ “ វាមិនមែនឱ្យតែ ប្រទេសតូចតាច សុទ្ធតែខ្លាចប្រទេសជាមហាអំណាចនោះទេ ”។ ពេលខ្លះ ប្រទេសជាម ហាអំណាច ក៏អាចខ្លាចប្រទេសតូចតាចដែរ។ ចិនជាប្រទេសធំមួយ តែក្នុងសង្គ្រាមកូរ៉េ ចិនជាប្រទេស ទន់ខ្សោយ។ ប៉ុន្តែ យើងហ៊ានកាន់អាវុធ ដើម្បីប្រយុទ្ធតតាំង។ នៅ ទីបំផុត យើងមានលទ្ធភាពប្រើប្រាស់សង្គ្រាមបដិវត្តន៍មួយដើម្បីផ្ទាញ់សង្គ្រាមឈ្លានពាន។



**ង្វៀន ធីប៊ីញ រដ្ឋមន្ត្រីការបរទេសវៀតណាមខាងជើង** (ឆ្នាំ១៩៦៨)

របត់នយោបាយ

ជូ អេនឡាយ បញ្ជាក់ប្រាប់ ង្វៀង ធីប៊ីញ បន្តទៀតថា សង្គ្រាមនៅវៀតណាម កាន់តែបញ្ជាក់ច្បាស់ថែមទៀត ពីចំណុចខាងលើនេះ។ ឥឡូវសង្គ្រាមវៀតណាម បាន រីករាលដាលដល់ប្រទេសកម្ពុជា និងឥណ្ឌូចិនទាំងមូលហើយ។ តែនេះ មិនមែន សមមិត្ត ហើយក៏មិនមែនសម្តេចសីហនុ ឬមួយក៏ប្រទេសចិនដែរ ដែលជាអ្នកបង្កើត ផែនការពង្រីកសង្គ្រាមនេះ គឺសហរដ្ឋអាមេរិក ដែលជាអ្នកធ្វើដូច្នេះ។ ល្អហើយ! ទុក ឱ្យសង្គ្រាមវារីករាលដាលតាមដំណើរវាទៅចុះ។ កាលពីមុនសង្គ្រាមមានតែតំបន់មួយ ចំនួនដែលនៅខាងកើតទន្លេមេគង្គជាទីជម្រករបស់កងទ័ពសមមិត្តប៉ុណ្ណោះ។ ឥឡូវនេះ ប្រទេសកម្ពុជាទាំងមូល និងឥណ្ឌូចិនទាំងមូលបានក្លាយជាជម្រករបស់កងទ័ពសម មិត្ត។ ទាំងអស់ នេះមិនទាន់និយាយដល់ជម្រកធំមួយទៀត នៅក្នុងប្រទេសចិនផង។

# ៧.១៦.ប្រធានាធិបតីអាមេរិក ឱ្យកងទ័ពចូលមកកម្ទេចទីតាំងពួកវៀតកុង ១២កន្លែងក្នុងទឹកដីកម្ពុជា




**ប្រធានាធិបតីអាមេរិក រីឆាដ និចសុន**

ក្រោយពីបញ្ជាឱ្យកងទ័ពអាមេរិក និងវៀតណាមខាងត្បូង ចូលលុកលុយប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៣០ ខែមេសា អស់រយៈពេលជិត២ខែមក ប្រធានាធិបតីនិចសុន បានប្រកាសជាសាធារណៈថា នឹងដកកងទ័ពអាមេរិក ចេញពីកម្ពុជាវិញ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧០ និងបានថ្លែងតាមកញ្ចក់ទូរទស្សន៍ថា យើងបានបើកប្រតិបត្តិការសឹកចំនួន១០កន្លែង ដើម្បីវាយប្រហារទៅលើមូលដ្ឋានពិសេសរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង ចំនួន១២កន្លែង ពិសេសនៅតំបន់ផ្លែសន្ទូច (ក្រែកមេមត់ ខេត្តកំពង់ចាម) និងតំបន់ចំពុះទា (ខេត្តស្វាយរៀង) ដោយមានកងទ័ពអាមេរិកចូលរួមចំនួន៣២០០០នាក់ និងកងទ័ពវៀតណាមខាងត្បូង ចំនួន៤៨០០០នាក់។ មកដល់ថ្ងៃនេះ កងទ័ពអាមេរិកទាំងអស់ រាប់ទាំងបុគ្គលិកផ្គត់ផ្គង់ផ្នែកព័ស្តុភារ និងទីប្រឹក្សា

របត់នយោបាយ
ព្រមទាំងកងទ័ពវៀតណាមខាងត្បូងមួយភាគ ត្រូវបានដកថយពីកម្ពុជា វិញហើយ។

និចសុន បន្តថា ការឆ្លើយតបតាមផ្លូវយោធារបស់យើងចំពោះការបង្កើនសកម្មភាពរបស់ពួកសត្រូវ គឺជាប្រតិបត្តិការសឹក ដែលមានរយៈពេល និងគោលដៅកំណត់ ច្បាស់លាស់។ យើងបានកំណត់ចម្ងាយ២១ម៉ៃល៍ពីព្រំដែន សម្រាប់កងទ័ពជើងគោកយើងបើកការវាយលុកចូលទៅក្នុងទឹកដីប្រទេសកម្ពុជា។

យោងតាមរបាយការណ៍ចុងក្រោយពីសមរភូមិប្រយុទ្ធបានឱ្យដឹងថា កងទ័ពយើងរឹបអូសកាំភ្លើងដៃពីពួកសត្រូវបានចំនួន២២៨៩២ដើម។ កាំភ្លើងទាំងនេះអាចយកទៅបំពាក់ឱ្យកងទ័ពថ្មើរជើងវៀតកុង-វៀតណាមខាងជើង បានចំនួន៧៤កងវរសេនាតូច។ កាំភ្លើងធំចំនួន២៥០៩ដើម ដែលអាចយកទៅបំពាក់កងទ័ពថ្មើរជើងវៀតកុង-វៀតណាមខាងជើង បានចំនួន២៤កងវរសេនាតូច និងគ្រាប់ចំនួន១៤លានគ្រាប់ គឺស្មើនឹងចំនួនគ្រាប់ដែលពួកសត្រូវបានបាញ់នៅសមរភូមិវៀតណាមខាងត្បូងកាលពីមួយឆ្នាំកន្លងមក។

ជាមួយគ្នានោះ កងទ័ពយើងរឹបអូសបានអង្ករចំនួន ៧០០០តោន ដែលអាចចិញ្ចឹមពួកសត្រូវទាំងអស់ដែលកំពុងប្រយុទ្ធនៅវៀតណាមខាងត្បូង បានរយៈពេល៤ខែ។ គ្រាប់កាំភ្លើងត្បាល់មិនដាក់ថយ និងកាំជ្រួចរ៉ុក្កែតចំនួន១៤៣០០០គ្រាប់ ដែលពួកសត្រូវអាចប្រើប្រាស់សម្រាប់បាញ់ចូលទីក្រុង និងមូលដ្ឋានកងទ័ពយើង រួមទាំងកងទ័ពសម្ព័ន្ធមិត្តនៅវៀតណាមខាងត្បូង បានក្នុងរយៈពេល១៤ខែ, គ្រាប់កាំភ្លើងបាញ់យន្តហោះចំនួន១៩៩៥៥២គ្រាប់, មីនចំនួន ៥៤៨២គ្រាប់, គ្រាប់បែកដៃចំនួន៦២០២២គ្រាប់, រំសេវផ្ទុះចំនួន៤១តោន, រំសេវដាក់ក្នុងថង់១០០២ថង់, រថយន្ត៤៣៥គ្រឿង, បំផ្លាញលេណដ្ឋានចំនួន ១១៦៨៨កន្លែង និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតជាច្រើន។ ពួកសត្រូវ ១១៣៤៩នាក់ត្រូវបានសម្លាប់ និងចាប់បានជាឈ្លើយសឹកចំនួន ២៣២៨នាក់។

និចសុន ថ្លែងបន្តទៀតថា យើងមានចំណាត់ការជាបន្ទាន់ ដើម្បីកាត់បន្ថយ

របត់នយោបាយ

អត្រាស្លាប់ និងរងរបួសរបស់កងទ័ពយើង រួមទាំងបញ្ហាសន្តិសុខនៅវៀតណាមខាងត្បូង។ យើងបានធ្វើឱ្យសត្រូវស្លាប់ និងរបួសព្រមទាំងខាតបង់សម្ភារៈ ដ៏ច្រើនសន្ធឹកសន្ធាប់។ យើងបានបំផ្លាញជម្រកដ៏រឹងមាំរបស់សត្រូវ (វៀតកុង-វៀតណាមខាងជើង) ទាំងឡាយនៅលើទឹកដីកម្ពុជា ដែលពួកវាធ្វើជាទីតាំងដ៏រឹងមាំរយៈពេល៥ឆ្នាំកន្លងមកហើយ។ យើងបានកាត់ផ្តាច់ការផ្គត់ផ្គង់របស់សត្រូវតាមផ្លូវសមុទ្រទាំងស្រុង ដែលកាលពីឆ្នាំ១៩៦៩ ស្បៀងអាហារ អាវុធ គ្រាប់រំសេវ ត្រូវផ្តល់ឱ្យពួកវៀតកុង-វៀតណាមខាងជើង តាមច្រកសមុទ្រកំពង់ផែកំពង់សោម។ ប្រតិបត្តិការបោសសម្អាតមូលដ្ឋានវៀតណាមកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជា ស្ថិតនៅក្រោមបញ្ជារបស់ឧត្តមសេនីយ៍ត្រៃតុន អាប្រាហាម ជាមេបញ្ជាការកងទ័ពអាមេរិក ប្រចាំនៅវៀតណាមខាងត្បូង។

ប្រធានាធិបតីអាមេរិក បានថ្លែងបន្តថា នៅក្នុងខែមិថុនា ឆ្នាំ១៩៦៩ យើងបានប្រកាសដកកងទ័ពចំនួន២៥០០០នាក់ ចេញពីវៀតណាមខាងត្បូង ដែលពេលនេះពួកគេបានមកដល់ផ្ទះសម្បែងវិញអស់ហើយ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៩ យើងបានប្រកាសដកកងទ័ពចំនួន៣៥០០០នាក់ទៀត ពេលនេះពួកគេបានមកជួបជុំក្រុមគ្រួសារអស់ហើយដែរ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៩ ដដែលនោះ យើងបានប្រកាសដកកងទ័ព៥០០០០នាក់ទៀត ហើយពួកគេនឹងមកដល់សហរដ្ឋអាមេរិកវិញ នៅក្នុងនិទាឃរដូវឆ្នាំនេះ (ឆ្នាំ១៩៧០)។

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧០ យើងបានប្រកាសដកកងទ័ពជាលើកទី៤ ចំនួន១៥០០០០នាក់។ ការបញ្ចប់ប្រតិបត្តិសឹកជើងគោករបស់កងទ័ពអាមេរិក នៅក្នុងប្រទេសកម្ពុជា នៅពេលនេះ ក៏ស្ថិតនៅក្នុងផែនការបញ្ចប់សង្គ្រាមនៅវៀតណាមខាងត្បូង និងដើម្បីស្វែងរកសន្តិភាពដែលប្រជាពលរដ្ឋអាមេរិក កំពុងចង់បាននោះដែរ។

ប្រធានាធិបតីអាមេរិក បានបញ្ជាក់ថា គោលនយោបាយសំខាន់របស់យើងសម្រាប់កម្ពុជា មាន៧ចំណុចគឺ៖

១-មិនឱ្យមានកងទ័ពជើងគោករបស់អាមេរិកណាម្នាក់ ស្ថិតនៅក្នុងប្រទេសកម្ពុជា

របត់នយោបាយ
ឡើយ លើកលែងតែមន្ត្រីស្ថានទូតរបស់យើងនៅទីក្រុងភ្នំពេញ។

២- មិនឱ្យមានទីប្រឹក្សាយោធាអាមេរិក នៅក្នុងកងទ័ពរបស់កម្ពុជា។

៣- តាមការយល់ព្រមពីរដ្ឋាភិបាលកម្ពុជា យើងនឹងដឹកនាំប្រតិបត្តិការតាមផ្លូវអាកាស ដើម្បីរារាំងការដឹកជញ្ជូនកងទ័ព និងសម្ភារបរិក្ខារផ្សេងរបស់ពួកសត្រូវ ដែលឆ្លងកាត់តាមទឹកដីកម្ពុជា ចូលទៅប្រទេសវៀតណាមខាងត្បូង ដើម្បីធ្វើសង្គ្រាមនៅវៀតណាមខាងត្បូង បន្តទៀត។ យើងធ្វើដូច្នេះ ក៏ដើម្បីការពារកងទ័ពរបស់យើងដែលកំពុងឈរជើងនៅវៀតណាមខាងត្បូង ផងដែរ។

៤- យើងនឹងប្រគល់អាវុធយុទ្ធភណ្ឌ និងគ្រឿងសម្ភារៈផ្សេងៗទៀត ដែលយើងរឹបអូសបានពីពួកសត្រូវនៅលើទឹកដីកម្ពុជា ទៅឱ្យរដ្ឋាភិបាលកម្ពុជា ដើម្បីជួយកម្ពុជាក្នុងការការពារអព្យាក្រឹតភាព និងឯករាជ្យភាពរបស់ខ្លួន។

៥- យើងនឹងផ្តល់ជំនួយយោធាទៅឱ្យរដ្ឋាភិបាលកម្ពុជា ជាគ្រឿងអាវុធ និងសម្ភារៈសាមញ្ញៗ ដែលសមស្របនឹងលក្ខណៈកងទ័ពរបស់គេ។ មកដល់ថ្ងៃនេះ យើងបានផ្តល់អាវុធ និងសម្ភារសឹកទាំងអស់នោះ ពិសេស គឺអាវុធធុនស្រាល, កាំភ្លើងត្បាល់, រថយន្ត, គ្រឿងបន្លាស់, យន្តហោះ, គ្រឿងបរិក្ខារសម្រាប់ទូរគមនាគមន៍ និងថ្នាំពេទ្យ ដែលសរុបជាទឹកប្រាក់មានចំនួន៥លានដុល្លារ។

៦- យើងនឹងស្នើសុំប្រទេសផ្សេងៗទៀតនៅក្នុងភូមិភាគអាស៊ី ឱ្យជួយផ្តល់ការគាំទ្រខាងផ្លូវទូត ចំពោះឯករាជ្យភាព និងអព្យាក្រឹតភាពរបស់កម្ពុជា ផងដែរ។

៧- យើងជួយជំរុញ និងគាំទ្រការខិតខំប្រឹងប្រែងរបស់ប្រទេសតតិយលោកមួយចំនួនដែលមានបំណង ជួយផ្តល់សម្ភារសឹកដើម្បីទៅជួយកម្ពុជា។ យើងសូមអបអរសាទរចំពោះការខិតខំប្រឹងប្រែងរបស់ប្រជាជាតិទាំងឡាយនៅអាស៊ី ក្នុងការជួយកម្ពុជាឱ្យរក្សាការពារអព្យាក្រឹតភាព និងឯករាជ្យភាពរបស់ខ្លួន។

ចុងក្រោយ ប្រធានាធិបតី និចសុន បានសង្កត់ធ្ងន់ថា៖ ខ្ញុំជឿជាក់ថា គោលការណ៍សំខាន់ពីរនឹងគ្របដណ្តប់ លើសកម្មភាពទាំងឡាយ របស់ប្រជាជាតិនៅអាស៊ីក្នុងការ

របត់នយោបាយ

ជួយដល់កម្ពុជានោះ គឺ៖ ទី១ ប្រជាជាតិទាំងអស់នោះ នឹងឆ្លើយតបតាមការស្នើសុំ និងធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលកម្ពុជា និងទី២ ប្រជាជាតិទាំងនោះនឹងមិនចាំបាច់ចំណាយកម្លាំងយោធាសម្រាប់កិច្ចការពាររបស់ខ្លួនដោយផ្ទាល់ទេ។ ការពិតវាជាការរួមចំណែកដល់បញ្ហាការពារសន្តិសុខផ្ទាល់របស់ខ្លួនផងដែរ ព្រោះប្រជាជាតិទាំងនោះជាប់ទាក់ទងនឹងព្រឹត្តិការណ៍នៅកម្ពុជា ដែរ។ ទាក់ទងដល់ការដកកងទ័ពអាមេរិក ចេញពីទឹកដីកម្ពុជារបស់ប្រធានាធិបតី និចសុន ដូចខាងលើនេះ សម្តេចសីហនុបានថ្លែងថា មុនការប្រកាសដកកងទ័ពចេញពីកម្ពុជានោះ អាមេរិកបានបង្កើនការទម្លាក់គ្រាប់បែកតាមយន្តហោះបេ៥២ទ្វេដង ហើយថា ការដកកងទ័ពនេះ គឺគ្រាន់តែជាការបំភាន់ភ្នែកប្រជាពលរដ្ឋអាមេរិក តែប៉ុណ្ណោះ។ ការពិត អាមេរិក មានតែចង់ដាក់នឹមអាណានិគម និងសម្លាប់រង្គាលមកលើប្រជាជនកម្ពុជា។





**ង្វៀង វ៉ាន់ធីវ និងរីឆាដ និចសុន, និចសុន មកសួរសុខទុក្ខកងទ័ពអាមេរិក**

ជាមួយគ្នានោះ សម្តេចសីហនុ បានអះអាងថា រណសិរ្សរួបរួមជាតិ និងកងទ័ពរំដោះរបស់ព្រះអង្គ បានវាយដណ្តើមកាន់កាប់ ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តស្ទឹងត្រែង, ខេត្តក្រចេះ និងខេត្តព្រះវិហារ បានទាំងស្រុង ហើយខេត្តផ្សេងៗទៀត ក៏កងទ័ពរបស់ព្រះអង្គវាយដណ្តើមបានស្ទើរតែទាំងស្រុង។ ផ្លូវជាតិទាំងអស់ ព្រមទាំងផ្លូវរថភ្លើងផងក៏ត្រូវកាត់ផ្តាច់ផងដែរ។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧០ ប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀង វ៉ាន់ធីវ បានប្រកាសតាមកញ្ចក់ទូរទស្សន៍ និងវិទ្យុថា កងទ័ពវៀតណាមខាងត្បូង បានត្រៀម

របត់នយោបាយ
ខ្លួនជាស្រេចហើយ ក្នុងការឆ្លើយតបតាមសំណូមពររបស់រដ្ឋាភិបាលកម្ពុជា។ តែតាមការពិត ពេលនោះកងទ័ពវៀតណាមខាងត្បូង កំពុងបើកការលុកលុយស្ទើរពេញផ្ទៃប្រទេសកម្ពុជា ទៅហើយ។



7-6-1970 – Thủ tướng Lon Nol (1913 - 1985) đón Phó tổng thống Nguyễn Cao Kỳ thăm Phnom Penh, Campuchia. Đi phía sau Phó Tổng thống Nguyễn Cao Kỳ là Tướng Nguyễn Văn Vỹ, Bộ trưởng Quốc phòng và Ngoại trưởng Trần Văn Lắm

**លន់ នល់ និងង្វៀន កាវគី អនុប្រធានាធិបតីវៀតណាមខាងត្បូង ឆ្នាំ១៩៧០**

______________________

# ៧.១៧.លន់ នល់ ចាត់ទុកពួកយួនកុម្មុយនិស្ត ជាទមិឡអន្សតិរ្ថិយ




**ឧត្តមសេនីយ៍ លន់ នល់ ក្នុងពិធីសាសនាមួយ**

នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានថ្លែងសារមួយផ្សាយតាមវិទ្យុជាតិថា៖ “ខ្ញុំសូមធ្វើការអំពាវនាវទៅកាន់ជនរួមជាតិទាំងអស់របស់យើងដែលជាពុទ្ធសាសនិកថា ព្រះពុទ្ធសាសនា ត្រូវមានចិរវេលា៥០០០ឆ្នាំ”។ បច្ចុប្បន្ននេះយើងទើបតែស្ថិតក្នុងឆ្នាំ២៥០០នៃពុទ្ធសករាជប៉ុណ្ណោះ ពោលគឺបានពាក់កណ្ដាលសាសនាហើយដូច្នេះ នៅពាក់កណ្ដាលសាសនាទៀតយើងនឹងរឹតតែរុងរឿងថ្កុំថ្កើងថែមទៀត។ តាមពុទ្ធទំនាយ សង្គ្រាមដែលរាតត្បាតនៅពេលនេះ គឺជាសង្គ្រាមសាសនា។ ពុទ្ធសាសនាសម្អាងលើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងជឿជាក់លើអំពើល្អ និងអំពើអាក្រក់។ ពួកអ្នកទាំងឡាយ ដែលធ្វើអំពើល្អនឹងបានទទួលផលល្អ ពួកអ្នកទាំងឡាយ

របត់នយោបាយ
ដែលធ្វើអំពើអាក្រក់ នឹងបានទទួលផលអាក្រក់។ តាមពុទ្ធទំនាយ ដែលបានទស្សន៍ទាយទុកតាំងពីយូរយារមកហើយបានឱ្យដឹងថា នឹងមានកើតសង្គ្រាមនៅពាក់កណ្ដាលសាសនានេះ ហើយនឹងមានប្រាសាទមាសប្រាសាទប្រាក់ ផុសនៅចំទន្លេមុខ៤ " ទន្លេចតុម្មុខ "។

សង្គ្រាមនោះ ជាសង្គ្រាមបង្ហូរឈាមរវាងពួកទមិឡឥតសាសនា និងពួកអ្នកជឿជាក់សាសនានៅត្រង់ទន្លេមុខ៤, ស្ដេចពាលមួយអង្គរត់កៀសខ្លួន, ផ្កាយដុះកន្ទុយលេចឡើងនៅក្នុងផ្ទៃមេឃ ជាដើម ដែលទាំងអស់នេះជាប្រផ្នូលឱ្យដឹងពីការកើតមានឧបទ្រពចង្រៃដល់ប្រទេសជាតិ។ ប៉ុន្តែ បន្ទាប់ពីសង្គ្រាមចប់ទៅ ប្រជាពលរដ្ឋខ្មែរនឹងបានសម្បូររុងរឿងដូចៗគ្នា ហើយប្រទេសកម្ពុជា នឹងក្លាយទៅជាសាធារណរដ្ឋមួយដែលអ្នកកាន់អំណាចត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ តាមបែបលទ្ធិប្រជាធិបតេយ្យ ហើយមេដឹកនាំកំពូលរបស់ប្រទេសយើងនឹងត្រូវលែងហៅថា ព្រះមហាក្សត្រទៀតហើយ គឺហៅថាប្រធានាធិបតីនៃសាធារណរដ្ឋវិញ។ ប្រធានាធិបតីនេះនឹងត្រូវបោះឆ្នោតជ្រើសរើសសម្រាប់អាណត្តិ៥ឆ្នាំម្ដង។ ប្រជាពលរដ្ឋកម្ពុជាទាំងអស់អាចឈរឈ្មោះឱ្យគេបោះឆ្នោតដោយស្មើមុខគ្នាក្នុងបរិយាកាសសន្តិភាពមួយ និងដោយគ្មានការបង្ខិតបង្ខំ។

លុះដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានថ្លែងសារតាមវិទ្យុជាតិជាថ្មីម្ដងទៀតថា៖ " យើងទាំងអស់គ្នាជាខ្មែរ " ជនជាតិខ្មែរសុទ្ធតែជាកូនចៅពូជអ្នកចម្បាំងពោរពេញដោយសេចក្ដីក្លាហានក្នុងការប្រយុទ្ធ ហើយមិនដែលរាថយនៅចំពោះមុខសត្រូវរបស់ខ្លួនសោះឡើយ។ ជនជាតិខ្មែរបានបូជាជីវិត ដើម្បីជាតិមាតុភូមិ។ ជនជាតិខ្មែរ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាដ៏មុតមាំ ចេះបែងចែកដាច់ស្រឡះរវាងអំពើល្អ និងអំពើអាក្រក់។ ដូច្នេះ ដើម្បីការពារប្រទេសរបស់យើងឱ្យស្ថិតនៅក្នុងឯករាជ្យភាព ប្រជាពលរដ្ឋរបស់យើងនៅគ្រប់ទិសទី ត្រូវតែចូលរួមកាត់ផ្ដាច់ការផ្គត់ផ្គង់ស្បៀងទាំងអស់ពីពួកវៀតកុង-វៀតណាមខាងជើង, ត្រូវតែដណ្ដើមអាវុធរបស់ពួកវាយកមកប្រគល់ឱ្យកងទ័ពខេមរជាតិ ហើយបើសិនជាកាលៈទេសៈចាំបាច់ ត្រូវ

របត់នយោបាយ

កៀសខ្លួនមកនៅខាងក្រោយទីតាំងឈរជើងរបស់កងទ័ពខេមរជាតិយើង។

ម៉្យាងទៀត នៅពេលណាជនរួមជាតិរបស់យើង ទទួលរងគ្រោះដោយសារការរំលោភបំពានទោះពីសំណាក់ទាហានផ្ទាល់របស់យើងក្តី ឬពីសំណាក់ទាហានមិត្តយើងក្តី (វៀតណាមខាងត្បូង) ត្រូវតែរាយការណ៍ពីការប្រព្រឹត្តិអំពើផ្តេសផ្តាសទាំងនោះមកអាជ្ញាធររបស់យើង ដើម្បីឱ្យចាត់វិធានការដាក់ទណ្ឌកម្មទៅតាមការប្រព្រឹត្តិនោះ។

នៅអមបណ្តាកងឯកភាពប្រយុទ្ធនីមួយៗរបស់យើងមានទីប្រឹក្សាជំនាញម្នាក់មានតួនាទីជាអ្នកបម្រើ និងការពារផលប្រយោជន៍ប្រជាពលរដ្ឋយើង ជាអ្នកចាំទទួលពាក្យបណ្តឹងទាំងអស់ពីជនរួមជាតិ។

ម៉្យាងទៀត យើងសូមអំពាវនាវឱ្យជនរួមជាតិយើងទាំងអស់នាំគ្នាចូលធ្វើទាហានឱ្យបានច្រើន។ វាប្រាកដណាស់ ដែលថា នៅពេលដែលចំនួនទាហានរបស់យើងកើនឡើងកាន់តែច្រើន និងសមត្ថភាពប្រយុទ្ធរបស់ទាហានយើងរឹតតែប្រសើរជាងមុននោះកងទ័ពយើងនឹងក្លាយទៅជាកងទ័ពពូកែជាងគេបំផុត។ សត្រូវក៏លែងហ៊ានប្រយុទ្ធជាមួយយើងទៀតដែរ។

នៅពេលបានចូលធ្វើទាហាន បណ្តាជនរួមជាតិរបស់យើងទាំងនោះនឹងបានទទួលផលប្រយោជន៍រៀនវិជ្ជាមន្តអាគម ដែលបន្សល់ទុកដោយបុព្វបុរសយើងនឹងធ្វើឱ្យយើងបញ្ចៀសគ្រាប់កាំភ្លើងសត្រូវបាន ហើយអាចយកឈ្នះសត្រូវបានដោយងាយ។

ជាមួយគ្នានោះ លន់ នល់ ក៏បានហៅពួកវៀតកុង-វៀតណាមខាងជើងថា ជាពួកទមិឡ(ថ្មិល) អត់សាសនាផងដែរ។

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ឧត្តមសេនីយ៍ លន់ នល់ ខាងលើនេះមក សមាជិករដ្ឋាភិបាលភាគច្រើន ពិសេសពួកនិស្សិតយល់ថា សេចក្តីថ្លែងការណ៍បែបនេះអាចធ្វើឱ្យប្រទេសកម្ពុជាបាត់បង់កិត្តិយសកេរ្តិ៍ឈ្មោះដោយសារបញ្ហាជឿលើមន្តអាគមនេះ។ ពួកអ្នកឯកទេសស៊ីវិល និងយោធាអាមេរិក បានបង្ហាញនូវការព្រួយបារម្ភរបស់គេ ចំពោះជំនឿលើមន្តអាគម និងអបិយជំនឿហួសហេតុរបស់មេដឹកនាំ

ខ្មែរម្នាក់នេះ ហើយបានសុំឱ្យរដ្ឋាភិបាលអាមេរិក មានការប្រុងប្រយ័ត្នក្នុងការផ្គត់ផ្គង់អាវុធ និងសម្ភារសឹកមកឱ្យរដ្ឋាភិបាលខ្មែរផងដែរ។




ផ្ទាំងគំនូរ ពួកទមិឡឥតសាសនា

នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានប្រកាសឱ្យដឹងថា ពលទាហានរបស់គាត់ បានកើនឡើងដល់ចំនួន១៣៨០០០នាក់ ហើយថា គាត់នឹងបង្កើនពលទាហានរបស់គាត់យ៉ាងតិច ឱ្យបានដល់ចំនួន២១០០០០នាក់ដែរ។

លន់ នល់ បន្តថា៖ ពួកវៀតកុង-វៀតណាមខាងជើង បានរិះរកគ្រប់មធ្យោបាយនៅតាមសមរភូមិនានា ដើម្បីបន្សាបសេចក្ដីក្លាហាន និងបន្ទន់ចិត្តរបស់ពលទាហានគាត់ ដោយឱ្យស្រីៗជាពូកវៀតកុង ស្រាតននលនៅខ្សែត្រៀមជួរមុខរបស់ពួកគេ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏កងទ័ពគាត់ធ្វើឱ្យពួកវៀតកុង-វៀតណាមខាងជើង បរាជ័យគ្រប់សមរភូមិដែរ ហើយចុងបញ្ចប់នៃសង្គ្រាមសាសនានេះ កងទ័ពគាត់នឹងទទួលបានជ័យជម្នះជាស្ថាពរមិនខាន។

លន់ នល់ បញ្ជាក់ថា ដើម្បីទទួលបានជ័យជម្នះជាស្ថាពរលើគូសត្រូវ គាត់មានមធ្យោបាយច្រើនណាស់ ដូចជាការបំផ្លាញសត្រូវដោយសកម្មភាពកងទ័ព, សកម្មភាពសាសនា, សកម្មភាពចិត្តសាស្ត្រ, សកម្មភាពសេដ្ឋកិច្ច, សកម្មភាពសង្គម, សកម្មភាពនយោបាយ និងសកម្មភាពផ្សេងៗទៀត។

ជាមួយមធ្យោបាយយកជ័យជម្នះលើពួកវៀតកុង-វៀតណាមខាងជើង ទាំងប៉ុន្មានខាងលើនេះ គាត់ក៏សង្ឃឹមជឿជាក់ទៅលើមន្តអាគមមួយផ្នែកធំផងដែរ។

លន់ នល់ បានបញ្ជាឱ្យពលទាហានរបស់គាត់ យកដីខ្សាច់ដែលបានសូត្រមន្តអាគមបញ្ចូលសិល្ប៍រួចហើយនោះ ដាក់ក្នុងឧទ្ធម្ភាគចក្រ ហោះប្រទក្សិណជុំវិញខ្សែក្រវាត់ការពារទីក្រុងភ្នំពេញ បាចរាយដីខ្សាច់នោះមកចុះក្រោម ធ្វើជាខ្សែសីមា

របត់នយោបាយ ដើម្បីការពារមិនឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកវាយប្រហារដណ្តើមយកទីក្រុងភ្នំពេញ បានទៀតផង។





**សេនាប្រមុខលន់ នល់**

———————————

# ៧.១៨. ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, ប៉ុក ដឺសកុមារ ទៅជួប ប៉ុល ពត នៅមន្ទីរមជ្ឈិមបក្សក្បែរស្ទឹងជីនិត



**ប៉ុក ដឺសកុមារ, ហ៊ូ យន់, ខៀវ សំផន, ហ៊ូ នឹម និងទិវ អុល**

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧០ កាសែតឡឺមុងដ៍ របស់បារាំង បានដកស្រង់ការចុះផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មានចិនថ្មី ថា ពួកតស៊ូកុម្មុយនិស្តថៃម៉ៅនិយម បានប្រកាសតាមសំឡេងវិទ្យុប្រជាជនថៃ ថា ប្រជាជន ថៃនឹងរួបរួមជាមួយប្រជាជនកម្ពុជា លាវ និងវៀតណាម កាន់តែជិតស្និទ្ធថែមទៀត ក្នុងការតស៊ូធ្វើបដិវត្តន៍ ពិសេសការតស៊ូតបតនឹងការបង្ក្រាបយ៉ាងសាហាវឃោរឃៅរបស់រដ្ឋាភិបាលឧត្តមសេនីយ៍ ថ្នម គិតទិខៈចន ដែលជាបរិវាររបស់អាមេរិក និងដឹកនាំធ្វើសង្គ្រាមប្រជាជនយូរអង្វែង រហូតផ្តួលរំលំរបបគ្រប់គ្រងប្រតិកិរិយារបស់បនក្បត់ ថ្នម គិតទិខៈចន នេះ ព្រមទាំងកម្ចាត់ពួកចោរឈ្លានពានអាមេរិក ឱ្យអស់ទាំងស្រុងពីលើទឹកដីថៃ។ ជាមួយគ្នានោះ

របត់នយោបាយ

វិទ្យុប្រជាជនថៃបានផ្សាយរម្លឹកឡើងវិញពីខ្លឹមសារនៃសេចក្ដីប្រកាសរបស់មេដឹកនាំចលនាកុម្មុយនិស្ដថៃ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧០ ដែលបានប្រកាសគាំទ្រសេចក្ដីអំពាវនាវរបស់ប្រធាន ម៉ៅ សុំឱ្យចលនាបដិវត្តន៍សាកលលោកគាំទ្រដល់ការតស៊ូរបស់ប្រជាជនកម្ពុជា ផងដែរ។

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧១ កាសែតឡឺម៉ុងដ៍ដដែល បានចុះផ្សាយដោយយោងទៅតាមពាក្យចចាមអារ៉ាមថា បណ្ដាញពួកកុម្មុយនិស្ដមកពីប្រទេសកម្ពុជា បានជ្រៀតចូលទៅដល់ភាគឦសាននៃប្រទេសថៃហើយ។ បណ្ដាញពួកកុម្មុយនិស្ដមកពីប្រទេសកម្ពុជា ដែលគេសង្ស័យថា ជាជនជាតិវៀតណាមនោះ បានចូលទឹកដីថៃ ជាសម្ងាត់ទៅជ្រើសរើសពួកយុវជន នៅក្នុងតំបន់សហគមន៍មួយចំនួន ដែលមានជនជាតិវៀតណាម រស់នៅដ៏ច្រើនកុះករ ដើម្បីយកទៅបង្ហាត់បង្រៀនពីបច្ចេកទេសធ្វើទ័ព្វង្សនានៅក្នុងព្រៃ។

តំបន់សហគមន៍ ដែលជនជាតិវៀតណាមរស់នៅច្រើនជាងគេនោះ មានដូចជានៅខេត្តអ៊ុដនថានី និងខេត្តណៈខនផ្នុម ជាសម្បុកចាស់របស់ ហូ ជីមិញ ជាមេដឹកនាំចលនាតស៊ូកុម្មុយនិស្តវៀតណាម កាលពី៣០-៤០ឆ្នាំមុន។ ក្រោយមក កន្លែងនោះបានក្លាយទៅជាមូលដ្ឋានកងទ័ពអាកាសរបស់អាមេរិក។

កាលក្នុងសម័យតស៊ូប្រឆាំងនឹងបារាំង នាយករដ្ឋមន្ត្រីថៃ ឈ្មោះ ព្រីឌី ផ្នុមយ៉ុង្គ ជាអ្នកបង្កើតចលនាតស៊ូខ្មែរសេរីៈនៅភាគខាងលិចប្រទេសកម្ពុជា ក៏ធ្លាប់ទាក់ទងជាមួយ ហូ ជីមិញ ដែលមកស្នាក់នៅតំបន់នោះដែរ។ មុននឹងបានឡើងធ្វើជានាយករដ្ឋមន្ត្រី ព្រីឌី ផ្នុមយ៉ុង្គ ជាមនុស្សមានជំហរអព្យាក្រឹតនិយម បានដឹកនាំចលនាប្រឆាំងនឹងកងទ័ពជប៉ុន ដែលចូលមកក្នុងទឹកដីនៃប្រទេសថៃ។

នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៤៥ ក្រោយពីពួកយោធាធ្វើរដ្ឋប្រហារទម្លាក់គាត់ចេញពីអំណាច ព្រីឌី ផ្នុមយ៉ុង្គ បាននិរទេសខ្លួនទៅរស់នៅប្រទេសចិន។ តាំងពីពេលនោះមក ចលនាតស៊ូរបស់ពួកកុម្មុយនិស្តថៃ ក៏កើតមានឡើង ពិសេសនៅភាគឦសាន

របត់នយោបាយ

ប្រទេសថៃ ដោយមានមេដឹកនាំចិន ជាអ្នកជួយឧបត្ថម្ភគាំទ្រដូចនៅប្រទេសកម្ពុជា វៀតណាម និងលាវ ដែរ។

តាមរយៈប្រទេសលាវ មេដឹកនាំចិន បានបង្កើតបណ្តាញទូរគមនាគមន៍មួយ ដើម្បីសម្រួលដល់ការធ្វើទំនាក់ទំនងជាមួយពួកកុម្មុយនិស្តថៃ។

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧០ សម្តេចសីហនុ យាងទៅដល់ប្រទេសកូរ៉េខាងជើង។ នៅក្នុងពិធីជប់លៀងជាកិត្តិយសមួយថ្វាយព្រះអង្គ ប្រធានាធិបតី គីម អ៊ីលស៊ុង ក៏បានអំពាវនាវឱ្យបណ្តាប្រជាជាតិនៅអាស៊ី បង្កើតរណសិរ្សរួមគ្នាមួយ ដើម្បីប្រឆាំងនឹងអាមេរិក។

គីម អ៊ីលស៊ុង បានប្រកាសថា រណសិរ្សរួមនេះ មានការចូលរួមពីប្រទេសចិន, កូរ៉េខាងជើង, កម្ពុជា, លាវ និងវៀតណាម ដើម្បីតបតនឹងសម្ព័ន្ធភាពយោធាប្រឆាំងកុម្មុយនិស្តមួយ ដែលរួមមាន សហរដ្ឋអាមេរិក, កូរ៉េខាងត្បូង, កោះតៃវ៉ាន់, វៀតណាមខាងត្បូង, ថៃ និងជប៉ុន។

ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧០ លន់ នល់ បានប្រកាសធ្វើកំណែនទាហានទៅលើប្រជាពលរដ្ឋខ្មែរ ប្រុស-ស្រី ទាំងឡាយណា ដែលមានអាយុចាប់ពី១៨ឆ្នាំ ដល់៦០ឆ្នាំ។ ប៉ុន្តែ កំណែនកងទ័ពនេះ អនុវត្តបានតែនៅទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួនប៉ុណ្ណោះ ព្រោះតំបន់ភាគច្រើនលើសលប់ ត្រូវកាន់កាប់ដោយកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរក្រហម ដែលគេហៅថាតំបន់រំដោះ និងតំបន់មួយចំនួនទៀត ជាតំបន់ប្រទាញប្រទង់គ្នា។ ក្រោយពីមិនសូវមានអ្នកស្ម័គ្រចិត្តចូលជាទាហាន នៅតាមវិថីនានា យុវជនជាច្រើន ដែលពុំមែនជាសិស្ស និស្សិត ឬមន្ត្រីរដ្ឋការ ត្រូវគេចាប់ដាក់លើរថយន្តយកទៅបង្ខំឱ្យបម្រើក្នុងជួរទាហាន។

នៅដើមខែមិថុនា ឆ្នាំ១៩៧០ មេដឹកនាំកំពូលរបស់ពួកខ្មែរក្រហម បានផ្លាស់ប្តូរទីតាំងមន្ទីរគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ពីភូមិភាគឦសានមកតាំងនៅក្បែរមាត់ស្ទឹងជីនិត ត្រង់ព្រំប្រទល់ខេត្តកំពង់ធំ និងកំពង់ចាម ជាទឹកដីនៃភូមិភាគឧត្តរ

របត់នយោបាយ

ដែលមាន កុយ ធួន ជាលេខាគណៈកម្មាធិការបក្សភូមិភាគ។

ចុងខែមិថុនា ឆ្នាំ១៩៧០ វន វ៉េត ក៏បានទៅជួប ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និងប៉ុក ជឹសកុមារ ដែលបានទៅលាក់ខ្លួននៅភ្នំឱរ៉ាល់ តាំងពីឆ្នាំ១៩៦៧ នោះ។ ពេលជួបនិយាយគ្នាមិនទាន់បានមួយម៉ោងផង ក៏មាននីរសារម្នាក់បានយកសំបុត្រមួយមកឱ្យ ដោយក្នុងសំបុត្រនោះ បានសរសេររបៀបចេញបញ្ជាថា ឱ្យ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និងប៉ុក ជឹសកុមារ ធ្វើដំណើរចុះពីភ្នំឱ រ៉ាល់ទៅភ្នំពិស នៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដើម្បីត្រៀមខ្លួនធ្វើដំណើរទៅជួបអង្គការថ្នាក់លើ។

ពេលនោះ វន វ៉េត ក៏បានរួមដំណើរជាមួយ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និង ប៉ុក ជឹសកុមារ ព្រមទាំងកម្មាភិបាលមួយចំនួនទៀត ធ្វើដំណើរចុះពីលើភ្នំឱរ៉ាល់ ទៅភ្នំពិសតាមបញ្ជារបស់អង្គការ ដោយមិនហ៊ានបង្អែបង្អង់ឡើយ។

ទៅដល់ភ្នំពិសសម្រាកជុំគ្នាបាន២-៣ថ្ងៃ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និង ប៉ុក ជឹសកុមារ ក៏បានបែកគ្នាពី វន វ៉េត ដើម្បីបន្តដំណើរទៅជួបអង្គការនៅមន្ទីរគណៈមជ្ឈិមបក្ស ដែលស្ថិតនៅក្បែរមាត់ស្ទឹងជីនិត ក្នុងស្រុកស្ទឹងត្រង់តំបន់៤២ ភូមិភាគឧត្តរ។

បន្ទាប់មកទៀត ពួកនីរសារក៏បាននាំពួកបញ្ញវន្តទាំង៤នាក់នេះ ជិះទូកកាត់ផ្ទៃទឹកបឹងទន្លេសាបដ៏ធំល្វឹងល្វើយ រួចហើយបត់ចូលតាមដងស្ទឹងជីនិត (មុំស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង) សំដៅទៅមន្ទីរគណៈមជ្ឈិមបក្សដែលនៅមាត់ស្ទឹងជីនិត ត្រង់ព្រំប្រទល់ខេត្តកំពង់ធំ និងកំពង់ចាម ដើម្បីជួបមេដឹកនាំកំពូល។

ខៀវ សំផន បានរម្លឹកថា ពេលនោះ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង! ព្រោះពួកគាត់មិននឹកស្មានថា សាឡុត ស និងនួន ជា ជាមេដឹកនាំកំពូលបក្សកុម្មុយនិស្តកម្ពុជាដូច្នេះឡើយ។ តាំងពីដើមមក គាត់នឹកស្មានថា អៀង សារី ឯណោះទេ ជាមេដឹកនាំកំពូល ព្រោះធ្លាប់ឃើញ អៀង សារី ធ្វើសកម្មភាពឃោសនាតស៊ូដោយចេញមុខ ហើយពួកបញ្ញវន្តភាគច្រើនស្គាល់ អៀង សារី ជាងគេ។ ពេលទៅសិក្សានៅប្រទេសបារាំង គាត់ក៏ធ្លាប់បានចូលទៅស្តាប់ អៀង សារី មានមតិនៅក្នុងអង្គប្រជុំដែរ។

របត់នយោបាយ

ខៀវ សំផន បញ្ជាក់ថា ថ្វីដ្បិតតែគាត់ធ្លាប់សិក្សានៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ជាមួយ សាឡុត ស ក៏ពិតមែន ប៉ុន្តែក្រោយពីបញ្ចប់ការសិក្សានៅវិទ្យាល័យនោះមក គាត់មិនដែលបានជួប សាឡុត ស ម្តងណាទេ ហើយ សាឡុត ស ក៏មិនដែលលេចមុខលេចមាត់ និងល្បីឈ្មោះថា ជាមេដឹកនាំខ្មែរក្រហម នោះដែរ។

ដំណាក់កាលនៃការធ្វើសង្គ្រាមក្នុងឆ្នាំ១៩៧០ នោះ ខៀវ សំផន យល់ថា សម្តេចសីហនុ បានប្រកាសយកគោលនយោបាយអព្យាក្រឹត ដើម្បីបញ្ចៀសភ្លើងសង្គ្រាមបានរយៈពេល១៥ឆ្នាំដែរ (ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០)។ ប៉ុន្តែទោះបីព្រះអង្គខិតខំយ៉ាងណា ក៏បានត្រឹមតែពន្យារពេលនៃគ្រោះមហន្តរាយនោះតែប៉ុណ្ណោះ ព្រោះព្យុះសង្ឃរានៃសង្គ្រាមត្រជាក់ និងសង្គ្រាមនៅវៀតណាម វាបក់បោកខ្លាំងលើសពីកម្លាំងរបស់ព្រះអង្គ និងប្រជាជាតិខ្មែរទៅទៀត។

ពេលនោះមហាអំណាចធំៗ ជាគូសត្រូវនឹងគ្នាក្នុងសង្គ្រាមវៀតណាម ក៏បាននាំគ្នាចូលមកធ្វើសង្គ្រាមនៅលើទឹកដីកម្ពុជា ដ៏តូច ដោយគ្មាននរណាទប់បានឡើយ។

ខៀវ សំផន បន្តថា ប្រឈមមុខនឹងគ្រោះអាសន្ននេះ ខ្មែរយើងស្ទើរតែទាំងអស់ ទាំងនៅជនបទ ទាំងនៅទីក្រុង ទាំងបញ្ញវន្ត ទាំងឥស្សរជន ទាំងនិស្សិតនៅក្រៅប្រទេស បានរួបរួមគ្នាធ្វើការតស៊ូសង្គ្រោះជាតិ ដែលពេលនោះកម្លាំងដើរតួសំខាន់មាន ២ គឺ៖ ទី១. បក្សកុម្មុយនិស្តកម្ពុជា ដែលមានកម្លាំងអាចប្រយុទ្ធបាននៅនឹងកន្លែងតែម្តង។ ទី២. គឺសម្តេចសីហនុ ដែលមានឥទ្ធិពលទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ ហើយកម្លាំងទាំង២នេះ មិនអាចអត់កម្លាំងណាមួយបានឡើយ។ ប៉ុន្តែសួរថា តើសម្តេចសីហនុ អាចរួបរួមជាមួយមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា បានទេ? ច្បាស់ជាមិនបានឡើយ។ ដូច្នេះ គេត្រូវការគាត់ឱ្យដើរតួនាទីជាស្ពាន ដោយសារឋានៈសង្គមរបស់គាត់ ហើយគាត់ក៏ធ្លាប់មានប្រជាប្រិយភាពនៅក្នុងប្រទេស គេក៏ឱ្យគាត់ចេញមុខដើរតួជាមេដឹកនាំសំខាន់ម្នាក់របស់កម្លាំងតស៊ូនៅក្នុងប្រទេស តែប៉ុណ្ណោះ។

# ៧.១៩. លន់ នល់ កាត់ទោសសម្តេចសីហនុ និងមហេសី ព្រមទាំងស័ក្តិ៥ គុំ សារ៉ាវ៉ាន់ និងចេង ស៊ីយ៉ុមប៊ិន



**សិរិមតៈ**, **ចេង ហេង**, **លន់ នល់**
**និងឧត្តមសេនីយ៍យួនខាងត្បូង** ( **ពីឆ្វេងទៅស្តាំ** )

នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៧០ នៅទីក្រុងប៉េកាំង សម្តេចសីហនុ បានថ្លែងប្រាប់អ្នកយកព័ត៌មានកាសែតអាអេហ្វប៉េ( AFP )របស់បារាំងថា មេដឹកនាំកូរ៉េខាងជើងបានទូលព្រះអង្គថា កូរ៉េខាងជើង បានត្រៀមខ្លួនជាស្រេចហើយ ឱ្យតែមានការស្នើសុំពីព្រះអង្គតែមួយម៉ាត់ កូរ៉េខាងជើងនឹងបញ្ជូនកងទ័ពរបស់ខ្លួនឱ្យមកជួយការពារប្រទេសកម្ពុជា ភ្លាម ។ ប៉ុន្តែ បើព្រះអង្គមិនត្រូវការកម្លាំងកងទ័ពទេ ព្រះអង្គនឹងទទួលបាននូវ

របត់នយោបាយ

ជំនួយសំខាន់ផ្សេងៗទៀត។

សម្តេចបន្តថា អាវុធយុទ្ធភណ្ឌទាំងឡាយ និងសម្ភារយោធាផ្សេងៗទៀត ព្រមទាំងថ្នាំពេទ្យផងដែរ ដែលកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ប្រើប្រាស់ក្នុងការធ្វើសង្គ្រាមនោះ គឺចិន និងកូរ៉េខាងជើងជាអ្នកផ្តល់ឱ្យ។ ទោះបីយើងចោទជាបញ្ហាដឹកជញ្ជូនខ្លះៗ ក៏យើងនៅតែដឹកជញ្ជូនបានដែរ។ ចំណែក ពួកវៀតកុង-ពួកវៀតណាមខាងជើងជាអ្នកជួយបង្ហាត់ក្បួនយុទ្ធសាស្ត្រដល់កងទ័ព រណសិរ្សរួបរួមជាតិកម្ពុជា គ្រូធំរបស់យើង គឺកងទ័ពឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប់។

ជាការពិតហើយដែលថា មានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅលើទឹកដីកម្ពុជា។ ប៉ុន្តែមិនត្រូវមានការភ្ញាក់ផ្អើលទេ គឺប្រជាជនឥណ្ឌូចិន កំពុងរួបរួមគ្នាធ្វើសង្គ្រាមប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវារតែប៉ុណ្ណោះ។

សម្តេចបញ្ជាក់ថា នៅវៀតណាមខាងត្បូង ពួកអាមេរិកបានលុបបំបាត់ខ្សែបន្ទាត់ព្រំដែន ហើយពួកវាបានធ្វើឱ្យសង្គ្រាមនៅវៀតណាម រីករាលដាលទៅជាសង្គ្រាមពេញឥណ្ឌូចិនទាំងមូល ប៉ុន្តែនៅកម្ពុជា ក៏មានចលនាតស៊ូដែរ ព្រះអង្គមិនទុកឱ្យពួកវៀតកុង-វៀតណាមខាងជើង ជាអ្នករំដោះប្រទេសព្រះអង្គតែម្នាក់ឯងទេ។ ប្រជាជនកម្ពុជា បានត្រៀមខ្លួនរំដោះប្រទេសដោយខ្លួនឯង ហើយការវាយលុកដ៏ធំមួយរបស់ប្រជាជនកម្ពុជា នឹងធ្វើឡើងនៅរដូវក្តៅខាងមុខនេះ។

សម្តេចសីហនុ បញ្ជាក់បន្ថែមថា៖ សីហនុ នៅតែជាសីហនុដដែល។ ខ្ញុំមិនអាចក្លាយទៅជាជនកុម្មុយនិស្តបានទេ ហើយខ្ញុំនឹងមិនបោះបង់នូវពាក្យសម្តីដែលខ្ញុំបាននិយាយរួចហើយដែរ។ ខ្ញុំមិនចូលទៅខាងអាមេរិក ហើយខ្ញុំក៏មិនចូលទៅខាងកុម្មុយនិស្តដែរ ព្រោះទាំង២ហ្នឹង វាជាគ្រោះថ្នាក់ដូចតែគ្នា។ ប៉ុន្តែ លន់ នល់ ជាអ្នកបង្ខំខ្ញុំឱ្យជ្រើសរើស១ ក្នុងចំណោមជម្រើសទាំង២នេះ។ ខ្ញុំដឹងថា ក្រោយពេលប្រទេសត្រូវបានរំដោះរួចនឹងមានបញ្ហារវាងពួកកុម្មុយនិស្ត និងពួកមិនមែនកុម្មុយនិស្ត ដែលពេលនេះកំពុងតែនៅក្នុងរណសិរ្សរួបរួមជាតិជាមួយគ្នា។ តែបើសួរថា តើរណសិរ្សរួបរួមជាតិ




សម្តេចសីហនុ

នេះ អាចបិតថេរយូរអង្វែងឬទេ? ខ្ញុំក៏មិនដឹងដែរ។ ប៉ុន្តែយ៉ាងណា ខ្ញុំមិនចង់មានបញ្ហាជាមួយពួកកុម្មុយនិស្តទេ។ ក្រោយពេលប្រទេស ត្រូវបានរំដោះនោះ បញ្ហាសំខាន់គឺអនាគតរបស់យុវជនជំនាន់ក្រោយ។ ប៉ុន្តែសម្រាប់ខ្ញុំ ក្រោយពេលប្រទេសបានរំដោះហើយ ខ្ញុំនឹងដកខ្លួនថយទៅ រស់នៅឯមូហ្សាំង (Mougins) ដែលនៅភាគខាងត្បូងប្រទេសបារាំង វិញ។

ពេលនោះដែរ ជួន មុម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលរួបរួមជាតិ បានបញ្ចប់ដំណើរទស្សនកិច្ចនៅទីក្រុងមូស្គូ ដោយគាត់បានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះមេដឹកនាំសហភាពសូវៀត ដែលបានផ្តល់ជំនួយជាច្រើនដល់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ដែលកំពុងតស៊ូប្រយុទ្ធជាមួយពួកចក្រពត្តិអាមេរិក និងរបបអាយ៉ងនៅក្រុងភ្នំពេញ។

ចំណែកនៅទីក្រុងភ្នំពេញវិញ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៧០ តុលាការសឹកបានបើកសវនាការកាត់ទោស សម្តេចសីហនុ កំបាំងមុខ ដោយដកហូតសញ្ជាតិជាខ្មែរ និងរឹបអូសយកទ្រព្យសម្បត្តិរបស់ព្រះអង្គទាំងអស់ ហើយសម្រេចផ្តន្ទាទោសប្រហារជីវិតព្រះអង្គ ដោយជាប់ចោទពីបទអនុញ្ញាតឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើងចូលមកបោះទីតាំងនៅលើទឹកដីកម្ពុជា, ឱ្យកងទ័ពបរទេសនេះ ចូលមកឈ្លានពានប្រទេសកម្ពុជា, ផ្តល់គ្រឿងអាវុធ ស្បៀងអាហារ និងថ្នាំពេទ្យឱ្យពួកវៀតកុង-វៀតណាមខាងជើង, ញុះញង់ឱ្យប្រជារាស្ត្រខ្មែរចូលដៃជាមួយសត្រូវបរទេស, រំលោភរដ្ឋធម្មនុញ្ញ ព្រមទាំងបំផ្លិចបំផ្លាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ជាតិទៀតផង។ នៅក្នុងសវនាការនោះដែរ សាក្សីជាច្រើនក៏បានឡើងចោទប្រកាន់ថា សម្តេចសីហនុ បានប្រើប្រាស់ថវិកា

របត់នយោបាយ

ជាតិខ្ជះខ្ជាយ និងបម្រើតែផលប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ។

តែយ៉ាងណា ក្រោយថ្ងៃធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្ដេចសីហនុ បានធ្វើការបកស្រាយបំភ្លឺពីក្រុងប៉េកាំង រួចមកថា ព្រះអង្គមិនដែលបានទទួលប្រាក់កម្រៃពីការបើកកាស៊ីណូ នៅភ្នំពេញនោះទេ ហើយព្រះអង្គក៏មិនបានចាយវាយថវិការដ្ឋខ្ជះខ្ជាយដែរ។ ព្រះអង្គក៏មិនដែលទទួលសំណូក ឬប្រាក់ទឹកតែក្នុងការតែងតាំងមន្ត្រីជាន់ខ្ពស់ ឬដកយកថវិកាជាតិមកធ្វើមានបានផ្ទាល់ខ្លួនដែរ។ ជាមួយគ្នានោះ ព្រះអង្គពុំដែលមានគណនីធនាគារផ្ទាល់ខ្លួន ទាំងនៅក្នុងប្រទេស និងក្រៅប្រទេសម្ដងណាឡើយ។ សូម្បីតែរថយន្ត ឬផ្ទះសម្បែងផ្ទាល់ខ្លួនក៏ព្រះអង្គគ្មានដែរ ក្រៅតែភូមិគ្រឹះមួយនៅប្រទេសបារាំង ហើយភូមិគ្រឹះនេះ ក៏ពុំមែនជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គដែរ គឺជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រប្រទេសកម្ពុជា ប៉ុណ្ណោះ។

ចំពោះករណីដែលចោទថា ព្រះអង្គលួចបន្លំបេឡាសាធារណៈនោះ ព្រះអង្គមានសៀវភៅកត់ត្រាការចំណូលចំណាយទាំងអស់ សូម្បីមួយកាក់មួយសេនក៏មានមន្ត្រីហិរញ្ញិកកត់ត្រាដែរ ហើយរាល់ចលនទ្រព្យ និងអចលនទ្រព្យទាំងអស់ ដែលប្រមូលទៅដាក់ក្នុងបេឡាសាធារណៈនោះ សុទ្ធតែមានចុះបញ្ជីទុកជាសម្បត្តិរដ្ឋទាំងអស់។

ពេលកំពុងគង់នៅក្រៅប្រទេស ព្រះអង្គគ្មានទ្រព្យសម្បត្តិអ្វីឡើយ ហើយពេលនេះ ជីវភាពរស់នៅរបស់ព្រះអង្គ គឺដោយសារទឹកចិត្តដ៏សប្បុរសរបស់រដ្ឋាភិបាលចិន និងសហភាពសូវៀត ដែលជួយផ្ដត់ផ្គង់គ្រប់បែបយ៉ាងចំពោះព្រះអង្គ, មហេសី និងបរិពាររបស់ព្រះអង្គផងដែរ។ ពេលព្រះអង្គត្រូវស្នាក់នៅក្រុងប៉េកាំងក្តី ក្រុងមូស្គូក្តី រដ្ឋាភិបាលប្រទេសទាំងពីរនេះ ជាអ្នករ៉ាប់រងចំណាយគ្រប់បែបយ៉ាង។

ប្រតិកម្មទៅនឹងការកាត់ទោសប្រហារជីវិត របស់តុលាការសឹកនៅក្រុងភ្នំពេញ ថ្ងៃទី០៥ ខែកក្កដានោះ សម្ដេចសីហនុ ប្រកាសតបវិញថា នៅពេលអនាគតដ៏ខ្លីខាងមុខនេះ បនក្បត់ លន់ នល់, សិរិមតៈ និងបក្ខពួកមួយចំនួនទៀត នឹងត្រូវកាត់ទោសដោយតុលាការប្រជាជនជាមិនខាន។

របត់នយោបាយ

ក្រោយពីការកាត់ទោសប្រហារជីវិតសម្តេចសីហនុ បានជាងមួយខែមក នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧០ តុលាការសឹកនៅទីក្រុងភ្នំពេញ ក៏បានបន្តបើកសវនាការកំបាំងមុខ ដោយផ្តន្ទាទោសអ្នកម្នាង ម៉ូនិក ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ផងដែរ។

ក្រោយពីកាសែតឡឺម៉ុងដ៍របស់បារាំង ចុះផ្សាយនូវសេចក្តីថ្លែងការណ៍របស់អ្នកកាន់សាសនាគ្រិស្ត និងក្រុមគ្រូពេទ្យវៀតណាម ដែលរស់នៅប្រទេសបារាំង ប្រឆាំងនឹងនយោបាយឈ្លានពានរបស់អាមេរិកនៅលើឥណ្ឌូចិនកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧០មក នៅថ្ងៃទី០៣ ខែសីហា ក្រុមវេជ្ជបណ្ឌិតខ្មែរចំនួន៥៣នាក់ ដែលជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យវេជ្ជសាស្ត្រ នាទីក្រុងភ្នំពេញ បាននាំគ្នាចុះហត្ថលេខាលើលិខិតមួយផ្ញើទៅការិយាល័យនិពន្ធកាសែតឡឺម៉ុងដ៍ មានខ្លឹមសារថា៖ កាលពី១៦ឆ្នាំមុន ប្រសិនបើ សីហនុ ព្យាយាមអនុវត្តគោលការណ៍សំខាន់ៗ នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ឱ្យបានត្រឹមត្រូវមែននោះ ប្រទេសកម្ពុជា អាចស្ថិតនៅជាប្រទេសអព្យាក្រឹត និងឯករាជ្យរៀងរហូតមកជាមិនខាន។ ប៉ុន្តែជាអកុសល តាំងពីមានសន្និសីទនោះមក ប្រជាពលរដ្ឋខ្មែរនៅតែបន្តរស់ក្នុងភាពជាអ្នករងគ្រោះ ព្រោះតែ សីហនុ ក្បត់ឆន្ទៈប្រជាពលរដ្ឋខ្លួនឯង ហើយក្នុងរយៈពេល២-៣ឆ្នាំចុងក្រោយកន្លងមកនេះ ប្រជាពលរដ្ឋខ្មែរ បានបាត់បង់សិទ្ធិសេរីភាព ដោយសារអំណាចផ្តាច់ការ និងការកេងប្រវ័ញ្ចរបស់សីហនុ និងប្រពន្ធ ព្រមទាំងមនុស្សជិតស្និទ្ធ២-៣នាក់ទៀត។

សីហនុ បានរំលោភបំពានលើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ដោយអនុញ្ញាតឱ្យកងទ័ពវៀតកុង-យួនខាងជើងមកតាំងមូលដ្ឋានទ័ពនៅតាមបណ្តោយព្រំដែនខ្មែរ និងយួនខាងត្បូង។

ខ្លឹមសារក្នុងលិខិតនោះបន្តថា ក្រោយថ្ងៃទី១៨ ខែមីនា ប្រជាពលរដ្ឋខ្មែរបានស្នើសុំជាផ្លូវការឱ្យកងទ័ពបរទេសទាំងអស់ចាកចេញពីលើទឹកដីរបស់ខ្លួន។ ជាការឆ្លើយតបនឹងការស្នើសុំនេះ ពួកវៀតកុង-យួនខាងជើង បែរជាធ្វើសកម្មភាពឈ្លានពានចេញពីជម្រករបស់ពួកគេ ដែលរីករាលដាលពាសពេញប្រទេសកម្ពុជា ដោយយកលេសថា

ជួយធ្វើសង្គ្រាមដណ្តើមអំណាចយកទៅឱ្យ សម្តេចសីហនុ វិញ។

លិខិតនោះបានបញ្ជាក់ដែរថា យើងមិនដែលឃើញមានការបំផ្លាញផ្ទះសម្បែង, គិលានដ្ឋាន, មន្ទីរពេទ្យ, សាលារៀន, សាកលវិទ្យាល័យរបស់យើង ដោយសារគ្រាប់រ៉ុក្កែតរបស់កងទ័ពអាមេរិក ហើយយើងក៏មិនដែលឃើញកងទ័ពអាមេរិក សម្លាប់ស្ត្រី និងកុមារខ្មែរ ក៏ដូចជាសម្លាប់បុព្វជិតខាងកាតូលិក, ព្រះសង្ឃខាងព្រះពុទ្ធសាសនា, ឬក៏សម្លាប់អ្នករងរបួសណាម្នាក់នោះដែរ ប៉ុន្តែផ្ទុយទៅវិញ ជាញឹកញាប់គេឃើញតែពួកវៀតកុង-យួនខាងជើងទេ ដែលជាអ្នកសម្លាប់អ្នកទាំងអស់នោះ។

គិតចាប់ពីសប្តាហ៍ទី៣ នៃខែមីនា ដល់ចុងខែមិថុនា ឆ្នាំ១៩៧០ កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបានប្រកាសថា នឹងវាយផ្តួលរម្លំរបបក្បត់ លន់ នល់ ក្នុងរយៈពេលខ្លី ដើម្បីយកអំណាចប្រគល់ឱ្យ សម្តេចសីហនុ វិញនោះ ផ្លូវជាតិសំខាន់ៗ រួមមានផ្លូវជាតិលេខ១, ផ្លូវជាតិលេខ២, ផ្លូវជាតិលេខ៣, ផ្លូវជាតិលេខ៤, ផ្លូវជាតិលេខ៥, និងផ្លូវជាតិលេខ៦ ព្រមទាំងផ្លូវរថភ្លើងផងដែរ ត្រូវបានកងទ័ពវៀតកុង-វៀតណាមខាងជើងកាត់ផ្តាច់ស្ទើរតែទាំងស្រុង។



**ស្ពានស្ទឹងស្លូត នៅផ្លូវជាតិលេខ១ ត្រូវបានកងទ័ពវៀតកុង កាត់ផ្តាច់ទាំងស្រុង**

របត់នយោបាយ

កំពង់ផែក្រុងកំពង់សោម លែងមានសកម្មភាពលើកដាក់ទំនិញ ហើយទីក្រុងភ្នំពេញ ក៏រងនូវការគំរាមកំហែង ពីសំណាក់កងទ័ពវៀតកុង-វៀតណាមខាងជើង ដែរ។ ប៉ុន្តែ ដោយសារមានអន្តរាគមន៍ពីកងទ័ពវៀតណាមខាងត្បូង និងពួកទាហានកន្សែងស (ទាហានខ្មែរកម្ពុជាក្រោម) ព្រមទាំងមានអន្តរាគមន៍ ពីកងអាកាសចរណ៍យោធាអាមេរិកផងនោះ ធ្វើឱ្យទាហានរដ្ឋាភិបាល លន់ នល់ មានលំនឹងបន្តិចឡើងវិញ។



**រថយន្តអ្នកដំណើរនៅផ្លូវជាតិលេខ៤ ត្រូវកងទ័ពវៀតកុងស្ទាក់បាញ់កម្ទេច**

មកដល់ខែកញ្ញា ពួកគេអាចមានលទ្ធភាពអាចទប់ស្កាត់ មិនឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង វាយសម្រុកដណ្តើមយកទីតាំងរបស់ពួកគេបានដោយងាយៗ ដូចមុនៗទៀតឡើយ។

នៅទីក្រុងភ្នំពេញ នៅមុខអគារសាធារណៈ អគារទីស្តីការក្រសួងនានា និងកន្លែងសំខាន់ៗទៀត សុទ្ធតែមានការសាងសង់ប៉ុស្តិ៍ប៉មយាមកាម និងដាក់បាវខ្សាច់ និងស្រាស់បន្លាលួសព័ទ្ធជុំវិញ។

នៅតាមវិទ្យាល័យ និងមហាវិទ្យាល័យ សិស្ស និស្សិតទាំងអស់នៅទីក្រុងភ្នំពេញ

របត់នយោបាយ
មានកាតព្វកិច្ចហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ និងត្រូវបញ្ចូលជាកងកុម្ម៉ង់ដូ ដើម្បីយាមកាមការពារវិទ្យាល័យ និងមហាវិទ្យាល័យរៀងៗខ្លួន។

សិស្សវិទ្យាល័យនៅតាមខេត្ត ក៏យ៉ាងដូច្នេះដែរ ត្រូវបានបញ្ចូលជាកងកុម្ម៉ង់ដូ ហើយពេលខ្លះ ត្រូវចេញប្រយុទ្ធជាកម្លាំងជំនួយរបស់ទាហានរដ្ឋាភិបាលផងដែរ។

ចំណែកពួកទាហានកន្សែងស ឬហៅថា ពួកម៉ៃហ្វក ជាទាហានខ្មែរកម្ពុជាក្រោម ដែលទីប្រឹក្សាយោធាអាមេរិក នៅប្រទេសវៀតណាមខាងត្បូង ត្រូវបានបញ្ជូនមកឱ្យជួយទប់ទល់ ដើម្បីការពារទីក្រុងភ្នំពេញនោះ ភាគច្រើននៅពេលយប់ ពួកគេមានវត្តមាននៅក្នុងវង្គសាលរាំវែក និងនៅក្នុងហាងផឹកស៊ីទៅវិញ។ ជួនកាល ពួកនេះផឹកស្រវឹងបង្កជម្លោះជាមួយនឹងទាហានកងទ័ពឆត្រយោង ដែលល្បីថា សុទ្ធតែជាពួកទាហានខ្លាំងពូកែដូចគ្នា។ លុះកម្លាំងកងអាវុធហត្ថ (PM) ចូលទៅធ្វើអន្តរាគមន៍ ក៏មានការបាញ់ប្រហារគ្នាជាមួយកម្លាំងកងអាវុធហត្ថ (PM) នោះទៀតផង។

នៅដើមខែឧសភា ឆ្នាំ ១៩៧០ ក្រុងកែប (ខេត្តកំពត) ត្រូវបានកងទ័ពវៀតកុង-វៀតណាមខាងជើង វាយដណ្ដើមចូលកាន់កាប់ទាំងស្រុង។



**ក្រុងកែប ត្រូវបានពួកខ្មែរក្រហមចូលកាន់កាប់ទាំងស្រុង នៅពាក់កណ្ដាលឆ្នាំ១៩៧០**

របត់នយោបាយ

ទាហានជើងទឹករដ្ឋាភិបាលក៏បានបាញ់កាំភ្លើងប្លោងជ្រំ ទៅលើទីក្រុងនេះសព្វទីកន្លែង ដើម្បីជួយអន្តរាគមន៍ទាហានថ្មើរជើង បើកប្រតិបត្តិការសឹកដណ្តើមទីក្រុងនេះមកវិញដែរ តែមិនអាចដណ្តើមបាន។ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧០ កងទ័ពវៀតណាមខាងត្បូង ជាសម្ព័ន្ធមិត្តបានចូលមកជួយវាយដណ្តើមយកទីក្រុងកែប ពីកងទ័ពវៀតកុង-វៀតណាមខាងជើង បានមកវិញ។

វរសេនីយ៍ទោ តុំ សារ៉ាវ៉ាន់ ជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹកខេត្តកំពត ក៏ត្រូវបានតុលាការសឹកកាត់ទោសប្រហារជីវិត ពីបទចោទប្រកាន់ថា គាត់បានបើកដៃឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង វាយដណ្តើមយកក្រុងកែប ដោយមិនបានបញ្ជាកូនទាហានរបស់ខ្លួនឱ្យធ្វើការប្រយុទ្ធទប់ទល់អ្វីបន្តិចឡើយ។




**ក្រុងក្រចេះ ត្រូវបានរំដោះ ក្នុងខែមីនា ១៩៧០**




**ចេង ស៊ីយ៉ុមប៊ិន ពេលចូលមន្ទីរស.២១**

ពេលនោះ កងទ័ពវៀតកុង-វៀតណាមខាងជើង បានបង្ខំចិត្តដកថយពីទីក្រុងកែបវិញ ចម្ងាយប្រហែល៣០គីឡូម៉ែត្រ។ ប៉ុន្តែ មកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៣ កងទ័ពវៀតកុង-វៀតណាមខាងជើង ក៏វាយដណ្តើមយកទីក្រុងកែប ពីទាហានរដ្ឋាភិបាល

របត់នយោបាយ
បានជាថ្មីម្តងទៀត ហើយកងទ័ពខ្មែរក្រហម ក៏បានចូលមកតាមក្រោយ ដើម្បីគ្រប់គ្រងទីក្រុងកែបនេះ ជាតំបន់រំដោះចាប់ពីពេលនោះមក។

ជាមួយគ្នានោះដែរ វរសេនីយ៍ឯក ចេង ស៊ីយ៉ុមប៊ិន ជាអភិបាលខេត្តក្រចេះ និងជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹកខេត្តក្រចេះ ក៏ត្រូវតុលាការសឹកផ្តន្ទាទោសឱ្យជាប់ពន្ធនាគារជាច្រើនឆ្នាំ ដោយសារតែគាត់បណ្តោយឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង វាយដណ្តើមយកទីរួមខេត្តក្រចេះ ដោយគ្មានការប្រយុទ្ធទប់ទល់ដូចវរសេនីយ៍ទោ គុំ សារ៉ាវ៉ាន់ នៅខេត្តកំពត នោះដែរ។ ប៉ុន្តែមិនយូរប៉ុន្មានវរសេនីយ៍ឯក ចេង ស៊ីយ៉ុមប៊ិន ជាអភិបាលខេត្តក្រចេះ និងជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹកខេត្តក្រចេះ បានលួចរត់ចេញពីពន្ធនាគារនៅក្នុងភ្នំពេញ ចេញជាមួយប្រពន្ធទៅរស់នៅក្នុងតំបន់រំដោះ ក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការបក្សភូមិភាគពិសេស។ ក្រោយពួកខ្មែរក្រហមវាយរំដោះបានទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បើតាមឯកសារដែលបានបន្សល់ទុកបានបញ្ជាក់ច្បាស់ថា គាត់ត្រូវពួកខ្មែរក្រហមបានចាប់គាត់ពីខេត្តព្រះវិហារមកដាក់នៅមន្ទីរស.២១ (គុកទួលស្លែង) មួយរយៈ ទើបសម្លាប់ចោលនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

---

# ៧.២០.និស្សិតខ្មែរ នៅប្រទេសបារាំង បែកបាក់គ្នា ក្លាយជាសត្រូវស្លាប់រស់



**សម្ដេចសីហនុ ជាមួយនិស្សិតខ្មែរនៅប្រទេសបារាំង**

សមាគមនិស្សិតខ្មែរនៅប្រទេសបារាំង ត្រូវបានបង្កើតឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៤៦ ដោយពុំមាននិន្នាការនយោបាយអ្វី ក្រៅតែពីការចង់បានឯករាជ្យពីបារាំងនោះឡើយ ហើយសមាគមនេះក៏ធ្វើឱ្យរដ្ឋាភិបាលបារាំង មានការធុញទ្រាន់ខ្លាំងណាស់ដែរ។ នៅពេលបង្កើតសមាគមនិស្សិតខ្មែរជាលើកដំបូងនោះ និស្សិតជាតិនិយមម្នាក់ឈ្មោះ អៀ ស៊ីចូវ ជាប្រធានសមាគម និងនិស្សិតម្នាក់ទៀតឈ្មោះ យ៉ែម សារ៉ុង អ្នកប្រជាធិបតេយ្យនិយមកណ្ដាល ជាអគ្គលេខាធិការ។ សមាគមនិស្សិតខ្មែរនេះមានសម្ដេចសីហនុ ជាព្រះប្រធានកិត្តិយសផងដែរ។ សមាគមនិស្សិតខ្មែរមានទីស្នាក់ការនៅអគារឥណ្ឌូចិន ដែលស្ថិតនៅក្នុងបរិវេណសាកលវិទ្យាល័យក្រុងប៉ារីស បានចេញផ្សាយព្រឹត្តិបត្រមួយឈ្មោះ ព្រឹត្តិបត្រខេមរនិស្សិត ចេញផ្សាយក្នុងរយៈពេល៦ខែ ១លេខ ដោយចុះផ្សាយអត្ថបទស្ដីពី សេដ្ឋកិច្ច, ប្រវត្តិសាស្ត្រ, សិល្បៈខ្មែរ និងព័ត៌មានបរទេសខ្លះៗប៉ុណ្ណោះ ដោយមិនចុះផ្សាយអ្វី ដែលទាក់ទិនដល់រឿងនយោបាយឡើយ។

ដោយសារមានការបែកបាក់សាមគ្គីផ្ទៃក្នុងខ្លះៗនោះ នៅក្នុងសន្និបាតរបស់សមាគមនិស្សិតខ្មែរនាថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៥០ អៀ ស៊ីចូវ ប្រធានសមាគមបាន

របត់នយោបាយ

ណែនាំឱ្យសមាជិកទាំងអស់យកចិត្តទុកដាក់ក្នុងការរក្សាសាមគ្គីភាព និងឯកភាពផ្ទៃក្នុងរបស់សមាគមដែលសមាជិកទាំងអស់រួមគ្នាជាអ្នកបង្កើតនោះ ហើយត្រូវប្រកាន់ឫកពាឱ្យបានល្អក្នុងទំនាក់ទំនងមិត្តភក្តិទាំងអស់នៅក្នុងសមាគម ដោយប្រកាន់យកការអត់ឱន ប្រឆាំងនឹងការព្យាបាទឈ្នានីស និងប្រកាន់យកការយោគយល់ ប្រឆាំងនឹងការមិនយោគយល់គ្នា។

ជាមួយគ្នានោះ អៀ ស៊ីចូវ ក៏បានក្រើនរម្លឹកដល់សមាជិកទាំងអស់ឱ្យបង្កើនការខិតខំប្រឹងប្រែងក្នុងការសិក្សា ធ្វើយ៉ាងណាឱ្យបានទទួលលទ្ធផលល្អ ដើម្បីឱ្យស័ក្តិសមនឹងការលះបង់គាំទ្ររបស់រាជរដ្ឋាភិបាលខ្មែរ នៅឯក្នុងប្រទេសដែលបានបញ្ជូនសមាជិកសមាគមទាំងអស់ឱ្យមកសិក្សានៅប្រទេសបារាំង នេះផងដែរ។

នៅចុងឆ្នាំ១៩៥០ ក្រោយពីពួកនិស្សិតមួយចំនួនបានទៅបន្តការសិក្សានៅទីក្រុងប៉ារីស មានគំនិតចង់ក្លាយខ្លួន ជាអ្នកនយោបាយមក ការបែកបាក់នៅក្នុងចំណោមនិស្សិតខ្មែរ ក៏ចាប់ផ្តើមកើតមានឡើង។

សាឡុត ស និងអៀង សារី បានបោះបង់ការរៀនសូត្រមួយផ្នែកធំដើម្បីយកពេលវេលាទៅគិតគូរពីរឿងនយោបាយ និងបានបង្កើតក្លឹបមួយមានឈ្មោះថា ក្លឹបម៉ាក្សស៊ីស (Maxism) ដើម្បីសិក្សា និងស្រាវជ្រាវទ្រឹស្តីនៃលទ្ធិកុម្មុយនិស្ត។ សាឡុត ស បានអានសៀវភៅមួយ មានចំណងជើងថា សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តដែលជាស្នាដៃ និពន្ធរបស់កាល់ម៉ាក្ស ហើយ អៀង សារី ក៏បានចេះចាំទ្រឹស្តីកុម្មុយនិស្តចាប់ពីពេលនោះមកដែរ។

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៥០ សមាគមនិស្សិតខ្មែរបានបើកសន្និបាតបោះឆ្នោតជ្រើសតាំង វណ្ណ ម៉ូលីវណ្ណ ឱ្យឡើងជាប្រធានសមាគមជំនួស អៀ ស៊ីចូវ ដែលត្រូវបញ្ចប់ការសិក្សា និងវិលត្រលប់មកមាតុប្រទេសវិញ។ វណ្ណ ម៉ូលីវណ្ណ ជានិស្សិតផ្នែកស្ថាបត្យកម្មនៅមហាវិទ្យាល័យវិចិត្រសិល្បៈ ត្រូវបាននិស្សិតភាគច្រើនទទួលស្គាល់ថាជាអ្នកនិយម កណ្តាល និងជាអ្នកចេះយោគយល់អធ្យាស្រ័យគ្នា។

វណ្ណ ម៉ូលីវណ្ណ ធ្វើជាប្រធានសមាគមនិស្សិតខ្មែរ (AEK) នេះ បានតែមួយឆ្នាំ

របត់នយោបាយ

ក៏មានការផ្លាស់ប្តូរសមាសភាពថ្មី។ នៅក្នុងឆ្នាំ១៩៥១ ហ៊ូ យន់ ត្រូវបានតែងតាំងធ្វើជាប្រធានសមាគមជំនួស វណ្ណ ម៉ូលីវណ្ណ ហើយមាននិស្សិតមកពីក្លឹបម៉ាក្សស៊ីស មួយចំនួន ក៏បានចូលជាសមាជិកគណៈកម្មាធិការនាយកសមាគមនេះផងដែរ។



**វណ្ណ ម៉ូលីវណ្ណ និងភរិយាជាជនជាតិបារាំង ជាមួយសម្តេចសីហនុ**

ចាប់ពីពេលនោះមក សមាគមនិស្សិតខ្មែរ (AEK) មានសមាសភាពចម្រុះ៣និន្នាការ គឺក្រុមទី១ ក្រុមមាននិន្នាការកណ្តាលនិយម ដូចជា៖ វណ្ណ ម៉ូលីវណ្ណ, យ៉ែម សារ៉ុង, ហង្ស ធុនហាក់, តាន់ គឹមហួន ជាដើម។ ក្រុមទី២ ក្រុមមាននិន្នាការសេរីនិយម រួមមាន៖ ម៉ៅ សាយ, សម សារី, លី ជិនលី, ឌុក រ៉ាស៊ី , ឡុង ប៉ែត, ព្រុំ ថុស ជាដើម និងទី៣ ក្រុមម៉ាក្សស៊ីសនិយម រួមមាន៖ ហ៊ូ យន់, អៀង សារី, សាឡុត ស និងកេង វ៉ាន់សាក់ ជាដើម ហើយភាគច្រើន ពួកនេះក៏បានចូលជាសមាជិកបក្សកុម្មុយនិស្តបារាំង ផងដែរ។

ក្រោយពួកនិស្សិតឆ្វេងនិយម ឡើងមកដឹកនាំសមាគមនិស្សិតខ្មែរ (AEK) នោះមក ពួកនិស្សិតស្តាំនិយម ក៏បានបំបែកខ្លួនចេញទៅបង្កើតសមាគមថ្មីមួយទៀត គឺសមាគមមិត្តភាពកម្ពុជា ដោយមាន ម៉ៅ សាយ ជាប្រធាន។ បន្ទាប់មកមាន ឌុក រ៉ាស៊ី ជាប្រធានបន្តមកទៀត។

សមាគមមិត្តភាពកម្ពុជា ទទួលបានមូលនិធិពីសម្តេចសីហនុ មានសមាជិក

របត់នយោបាយ

ប្រមាណពី៣០ទៅ៤០នាក់នោះ ចង់ឱ្យប្រទេសជាតិមានការរីកចម្រើន តាមបែបលទ្ធិប្រជាធិបតេយ្យមួយ ស្ថិតនៅក្រោមការដឹកនាំរបស់សម្តេចសីហនុ ហើយសមាជិកក្នុងសមាគមនេះមិនចូលចិត្តសមាជិកសហភាពនិស្សិតខ្មែរដែលមាននិន្នាការទៅរកកុម្មុយនិស្តនោះទេ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ នៅប្រទេសបារាំងនោះដែរ ដោយមានឧត្តមសេនីយ៍ ញឹក ជូឡុង ជាអ្នកជួយឧបត្ថម្ភគាំទ្រ ក៏មាននិស្សិតខ្មែរមួយចំនួនតូច បានបង្កើតសមាគមមួយទៀតឈ្មោះថា សមាគមខ្មែរ (AK) មាននិន្នាការគាំទ្រនយោបាយរបស់សម្តេចសីហនុ។ សមាគមខ្មែរនេះមាន ចៅ សេងអ៊ួ ជាប្រធាន។ ឯសមាជិកគណៈកម្មាធិការនាយក រួមមាន ឌី ប៉ែលឡែន, រ៉ូហ្សេ កុសល, សាមែ ផល្គុន និងស្រី ប៉ុង។

ដោយសារសមាគមមិត្តភាពកម្ពុជា និងសមាគមខ្មែរ នៅប្រទេសបារាំង មានគោលជំហរគាំទ្រនយោបាយរបស់ចលនាសង្គមរាស្ត្រនិយមដូចគ្នានោះ នៅក្នុងខែមករា ឆ្នាំ១៩៦១ សម្តេចសីហនុ ក៏បានស្នើសុំឱ្យសមាគមទាំង២នេះ រួមបញ្ចូលបញ្ចូលគ្នាបង្កើតជាសហគមន៍មួយមានឈ្មោះថា សហគមន៍និស្សិតខ្មែរឯនាយសមុទ្រ តែម្តងទៅ។ សហគមន៍និស្សិតខ្មែរឯនាយសមុទ្រនោះ មាន ជា សេងថៃ ជាប្រធានគណៈកម្មាធិការនាយក, ឡុង ប៉ែត, អ៊ុយ ផាត់ណា, ហ៊ូ ស៊ីអ៊ុយ, បូរ៉ាមី ជូឡុង, នុត ណារ៉ាង និងចម្រើន សំអឿន ជាវេជ្ជបណ្ឌិតជំនាញជំងឺវិកលចរិត ជាសមាជិក។ ជាមួយគ្នានោះ សហគមន៍និស្សិតខ្មែរឯនាយសមុទ្រ ក៏បានចេញផ្សាយព្រឹត្តិបត្ររបស់ខ្លួនមួយដែរ ដោយផ្តោតការយកចិត្តទុកដាក់ការផ្សព្វផ្សាយពីវប្បធម៌ខ្មែរច្រើនជាង បញ្ហានយោបាយ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៦៤ ក្នុងព្រះរាជដំណើរឆ្លងកាត់ទីក្រុងប៉ារីស សម្តេចសីហនុ បានឆ្លៀតឱកាសយាងចូលប្រជុំជាមួយនិស្សិត ដែលនៅក្នុងអគារស្នាក់នៅរបស់និស្សិតខ្មែរដែលដាក់ឈ្មោះជាភាសាបារាំងថា ប៉ាវីយ៉ុង ឌុយ កាំបូត (Pavillon du Cambodge) ឬផ្ទះខ្មែរ ដោយព្រះអង្គបានបង្ហើបឱ្យដឹងពីព្រះទ័យចង់ឱ្យសហភាពនិស្សិតខ្មែរ និងសហគមន៍និស្សិតខ្មែរឯនាយសមុទ្រ រួបរួមឯកភាពគ្នាជាធ្លុងមួយ បង្កើតជាសមាគមមួយថ្មីទៀត ដើម្បីកុំឱ្យនិស្សិតខ្មែរទាំង២ក្រុមនេះមានការបែកបាក់ និងបង្កជម្លោះនឹង

គ្នាទៀត។ ពេលនោះ សហភាពនិស្សិតខ្មែរ ក៏បានសម្តែងនូវការគាំទ្រចំពោះសម្តេច សីហនុ ដែលមានព្រះទ័យចង់បង្រួបបង្រួមក្រុមនិស្សិតទាំង២ក្រុមនេះដែរ។ ប៉ុន្តែ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៦៥ ជាថ្ងៃដែលត្រូវរំលាយខ្លួនដើម្បីរួបរួមប្រកាសបង្កើត សមាគមថ្មីឈ្មោះថា សមាគមទូទៅនៃជនជាតិខ្មែរ នៅប្រទេសបារាំង “ A G C A F ” នោះស្រាប់តែ សហភាពនិស្សិតខ្មែរបែរជាមិនព្រមរំលាយខ្លួនឯងទៅវិញ។ តែទោះបីយ៉ាងណា ក៏សមាគមទូទៅនៃជនជាតិខ្មែរនៅប្រទេសបារាំង “ A G C A F ” ត្រូវបាន បង្កើតឡើងស្របតាមបំណងរបស់សម្តេចសីហនុ ដោយមាន សាង ហាក់ ជាប្រធាន សមាគមនេះ។ ទោះបីពុំមាននិស្សិត ដែលមាននិន្នាការឆ្វេងនិយមចូលជាសមាជិក របស់សមាគមទូទៅនៃជនជាតិខ្មែរនៅប្រទេសបារាំង “ A G C A F ” ក៏ពិតមែន ក៏មាន ពួកនិស្សិតដែលមានគំនិតចម្រើននិយមជាច្រើន ទោះបីចង់ ឬមិនចង់ ក៏បាននាំគ្នាចូល ជាសមាជិករបស់សមាគមនេះដែរ ព្រោះបើមិនចូលជាសមាជិករបស់សមាគមនេះទេ ក៏មិនងាយនឹងទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សារបស់ខ្លួនទៅឆ្នាំក្រោយៗ ទៀតបានដែរ។

ពេលនោះដែរ សារិន ឆាក ដែលពួកនិស្សិតគ្រប់និន្នាការចាត់ទុកជាមនុស្ស ប្រកបដោយគុណធម៌ សុចរិត យុត្តិធម៌នោះ ជាប្រធានគ្រប់គ្រងអគារស្នាក់នៅរបស់ ពួកនិស្សិតខ្មែរ ដែលហៅថា ប៉ាវីយ៉ុង ឌុយ កាំបូត ( Pavillon du Cambodge ) ឬផ្ទះខ្មែរ តែងតែយកចិត្តទុកដាក់ពីបញ្ហាសុខមាលភាព និងជួយទំនុកបម្រុងដល់ការសិក្សារបស់ ពួកនិស្សិតខ្មែរទាំងអស់ ដោយមិនប្រកាន់និន្នាការអ្វីឡើយ។

ដោយសារ សារិន ឆាក និងសាង ហាក់ ជាមនុស្សកណ្តាលនិយមដូចគ្នា ហើយ មិត្តភក្តិពួកគាត់មួយចំនួនទៀត សុទ្ធតែជាមនុស្សដែលមាននិន្នាការកណ្តាលនិយមដែរ នោះ ពួកគាត់ទាំងអស់ក៏បានក្លាយជាក្រុមកណ្តាលនិយមមួយនៅក្នុងសមាគមទូទៅ នៃជនជាតិខ្មែរនៅប្រទេសបារាំង។ តែក្នុងសមាគមនោះ ក៏មានក្រុមស្តាំនិយមមួយ ក្រុមដែរ ដែលមាន ឡុង ប៉ែត ជាបង្គោល និងឈៀង គីមស្មួរ ជាជំនួយការ។

ចំណែកនៅក្នុងប្រទេសវិញ ចាប់តាំងពីឆ្នាំ១៩៤៩មក វិទ្យាល័យព្រះស៊ីសុវត្ថិ បាន

របត់នយោបាយ

ក្លាយទៅជាមជ្ឈមណ្ឌលនយោបាយ ដ៏ស្រើបស្រាលមួយរបស់ពួកសិស្ស ដែលមានគំនិតចម្រើននិយម។ រហូតមកដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៥ ពួកឆ្វេងនិយមបានបង្កើតសមាគមមួយ ឈ្មោះសមាគមទូទៅនៃនិស្សិតខ្មែរមាន ភោគ ឆាយ ជាប្រធាន និងមានសិស្ស និស្សិតមកពីសាកលវិទ្យាល័យប្រជារាស្ត្រ (សាលាបច្ចេកទេស), វិទ្យាស្ថានគរុកោសល្យ ពិសេស សិស្សមកពីវិទ្យាល័យឯកជនកម្ពុជបុត្រ និងចម្រើនវិជ្ជា ដែលជាសម្បុកពួកខ្មែរក្រហម បាននាំគ្នាមកចូលជាសមាជិក។ ប៉ុន្តែចាប់ពីឆ្នាំ១៩៦៧ មក មេដឹកនាំសមាគមនេះជាច្រើនរូប ដែលជាពួកឆ្វេងនិយម ក្នុងនោះមានសាស្ត្រាចារ្យ ទីវ អុល ជាសមាជិកគណៈកម្មាធិការនាយក ក៏បាននាំគ្នារត់ចូលព្រៃ តស៊ូជាមួយពួកមេដឹកនាំខ្មែរក្រហមជាបន្តបន្ទាប់។

នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ដោយសារសមាគមទូទៅនៃនិស្សិតខ្មែរបានក្លាយទៅជាសម្បុកនៃលទ្ធិកុម្មុយនិស្តដ៏ធំមួយនោះ សម្តេចសីហនុ ក៏បានប្រកាសរំលាយសមាគមនេះចោល រួចហើយព្រះអង្គបានបង្កើតសមាគមថ្មីមួយទៀត គឺសមាគមនិស្សិតកម្ពុជា ជំនួសវិញ។

មុនមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នៅទីក្រុងប៉ារីស ប្រទេសបារាំង មានសមាគមខ្មែរ២ គឺសហភាពនិស្សិតខ្មែរ និងសមាគមជនជាតិខ្មែរនៅប្រទេសបារាំង។ និស្សិតទាំងឡាយដែលចូលជាសមាជិកសហភាពនិស្សិតខ្មែរ សុទ្ធសឹងតែជានិស្សិតឆ្វេងនិយម មានគំនិតជាកុម្មុយនិស្តក្រហមឆ្អិនឆ្អៅ។

ចំណែក សមាជិកសមាគមជនជាតិខ្មែរនៅប្រទេសបារាំង មិនត្រឹមតែជាអ្នកគាំទ្រចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ទេ គឺថែមទាំងមិនចូលចិត្តពួកនិស្សិតជាសមាជិកសហភាពនិស្សិតខ្មែរ នោះទៀតផង។ ប៉ុន្តែពេលនោះ ក៏មាននិស្សិតខ្លះ ជាអ្នកកណ្តាលនិយម មិនចង់ចូលខាងណាទាំងអស់ តែពួកគេត្រូវបង្ខំចិត្តចូលជាសមាជិករបស់សមាគមជនជាតិខ្មែរនៅប្រទេសបារាំង គឺដើម្បីរក្សាអាហារូបករណ៍របស់ ពួកគេឱ្យបានរៀនចប់ចុងចប់ដើមប៉ុណ្ណោះ។ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពួកស្តាំនិយម នៅក្នុងសមាគមជនជាតិខ្មែរ រួមមាន៖ ឡុង ប៉ែត និងពួក

ប្រឆាំងលទ្ធិកុម្មុយនិស្តដាច់ខាតមួយចំនួនទៀត បាននាំគ្នាចាកចេញពីសមាគមជនជាតិខ្មែរ នៅប្រទេសបារាំង ទៅបង្កើតសមាគមថ្មីមួយទៀត ឈ្មោះសមាគមអ្នកស្នេហាជាតិខ្មែរនៅឯបរទេស មាននិន្នាការគាំទ្ររដ្ឋាភិបាល លន់ នល់។

ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧០ សមាគមជនជាតិខ្មែរនៅប្រទេសបារាំងដែលគាំទ្រសម្តេចសីហនុ បានចុះផ្សាយសេចក្តីថ្លែងការណ៍របស់ខ្លួនមួយនៅលើទំព័រកាសែតឡឺម៉ុងដ៍ ដោយបានធ្វើការបរិហារពីនយោបាយពួកចក្រពត្តិនិយមគ្រប់ប្រភេទ ពិសេសលទ្ធិវាតទីនិយមរបស់អាមេរិក និងធ្វើការថ្កោលទោសពួកក្បត់ លន់ នល់ ដែលជាអ្នកនាំភ្លើងសង្គ្រាមឱ្យឆាបឆេះប្រទេសកម្ពុជា ផងដែរ។

ជាមួយគ្នានោះ សហភាពនិស្សិតខ្មែរ បានចេញសេចក្តីថ្លែងការណ៍គាំទ្រចំពោះចលនាតស៊ូរណសិរ្សរួបរួមជាតិកម្ពុជា ដែលបានសហការគ្នាជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ដើម្បីធ្វើសង្គ្រាមប្រឆាំងជាមួយពួកអាមេរិក និងបនក្បត់ លន់ នល់ សិរិមតៈ ជាបរិវារផងដែរ។

តែមិនយូរប៉ុន្មាន ដោយសារមានការបែកបាក់ផ្ទៃក្នុង កាន់តែខ្លាំងឡើងៗរវាងសមាជិកដែលគាំទ្រសម្តេចសីហនុ និងពួកស្តាំនិយមមួយចំនួនទៀត ធ្វើឱ្យប្រធានសមាគម និងសមាជិកសំខាន់ៗជាច្រើនទៀត នៅក្នុងសមាគមជនជាតិខ្មែរនៅប្រទេសបារាំង នាំគ្នាលាឈប់អស់។ ឯសមាគមអ្នកស្នេហាជាតិខ្មែរ នៅប្រទេសបារាំង ដែលឡុង ប៉ែត បង្កើតឡើងនោះ ក៏គ្មានសកម្មភាពអ្វីគួរឱ្យកត់សម្គាល់ដែរ ហើយមិនយូរប៉ុន្មានសមាគមនេះ ក៏រលាយបាត់ទៅ។

ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧០ សហភាពនិស្សិតខ្មែរ បានប្រារព្ធធ្វើមហាសន្និបាតរបស់ខ្លួន ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយកថ្មី។ សមាជិកជាអ្នកមានគំនិតជឿនលឿន ចង់ដាក់បញ្ចូលបេក្ខភាពជានិស្សិតជំនាន់ក្រោយ ដើម្បីឱ្យឈរឈ្មោះដែរ ប៉ុន្តែដោយសារតែគណៈកម្មាធិការនាយកចាស់មិនឱ្យដាក់បញ្ចូលអ្នកថ្មី បណ្តាលឱ្យសមាជិកដែលមានគំនិតជឿនលឿន ប្រមាណ៣០នាក់ មានការអាក់អន់ចិត្ត ក៏បាននាំគ្នាដើរចេញពីសហភាពនិស្សិតខ្មែរ នេះវិញ។ ក្នុងអំឡុងពេលនោះដែរ សហភាពយុវ

របត់នយោបាយ

ជនខ្មែរ នៅសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ក៏ត្រូវបាក់បែកចែកផ្លូវគ្នាជា២ដែរ គឺ មួយក្រុមគាំទ្រពួកមេដឹកនាំធ្វើរដ្ឋប្រហារនៅទីក្រុងភ្នំពេញ និងមួយក្រុមទៀត គាំទ្រពួក កុម្មុយនិស្តខ្មែរក្រហម ហើយសមាជិកនៃសហភាពយុវជនខ្មែរទាំង២ក្រុម ដែលពីមុន មកធ្លាប់ជាមិត្តសម្លាញ់នឹងគ្នា ក៏បានក្លាយជាគូសត្រូវទៅវិញ។



**សម្តេចសីហនុ ជួបនិស្សិតខ្មែរ នៅទីក្រុងប៉ារីស**

នៅទីក្រុងប៉ារីស រណសិរ្សរួបរួមជាតិកម្ពុជា បានបង្កើតសាខារបស់ខ្លួនមួយ ដោយ បានប្រមែប្រមូលពួកអ្នកដែលមានគំនិតស្អប់ខ្ពើមសហរដ្ឋអាមេរិក និងពួកនិស្សិត ឆ្វេងនិយម បង្កើតគណៈកម្មាធិការមួយឱ្យឈ្មោះថា គណៈកម្មាធិការស្នេហាជាតិខ្មែរ។

ក្រោយមកគណៈកម្មាធិការនេះ ក៏បានផ្ញើលិខិតមួយទៅថ្វាយសម្តេចសីហនុ នៅឯទីក្រុងប៉េកាំង ដើម្បីសម្តែងការគាំទ្រពេញទំហឹងចំពោះព្រះអង្គ ដែលបានបង្កើត រណសិរ្សរួបរួមជាតិកម្ពុជា នាថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០នោះ។

នៅចុងឆ្នាំ១៩៧១ អៀង សារី បានស្នើសុំសមាគមនិស្សិតឆ្វេងនិយមទាំងអស់ ដែលកំពុងសិក្សានៅក្រៅប្រទេស ឱ្យចាត់បញ្ជូនតំណាងរបស់ខ្លួន ដើម្បីមកចូលរួម សិក្ខាសាលាមួយនៅទីក្រុងប៉េកាំង។

វត្តមាននៅក្នុងសិក្ខាសាលានោះ គេឃើញមាននិស្សិតឆ្វេងនិយម មកពីប្រទេស

របត់នយោបាយ

យូហ្គោស្លាវី មានតំណាងចំនួន២នាក់, មកពីប្រទេសឆេកូស្លូវ៉ាគីចំនួន១នាក់, មកពីសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ចំនួន២នាក់, មកពីប្រទេសបារាំង ចំនួន៣នាក់, មកពីសហភាពសូវៀត ចំនួន២នាក់ និងមកពីប្រទេសកូរ៉េខាងជើង ចំនួន៤នាក់។

ក្នុងសិក្ខាសាលាដែលប្រារព្ធធ្វើឡើង នៅទីក្រុងប៉េកាំង រយៈពេល ៨ថ្ងៃនោះ អៀង សារី បានឧទ្ទេសនាមអំពីសភាពការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជា, ពីការតស៊ូរបស់វណ្ណៈកសិករ, ពីកម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់លើឯកសារ ស្តីពីការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ និងពីការកសាងជំហរបដិវត្តន៍របស់ពួកនិស្សិតបញ្ញវន្តខ្មែរ ផងដែរ។

ជាមួយគ្នានោះដែរ អៀង សារី ក៏បានលើកឡើងថា ការបង្កើតឱ្យមានសមាគមនិស្សិតខ្មែរច្រើន នៅតាមបណ្តាប្រទេសនីមួយៗបែបនេះ គឺជាការផ្តល់ផលប្រយោជន៍ដល់ពួកស្តាំនិយមដោយមិនដឹងខ្លួន ហើយថា ការបាក់បែកផ្ទៃក្នុងរបស់សមាគមនិស្សិតខ្មែរ នៅប្រទេសបារាំងកន្លងមក គឺជាលទ្ធផលនយោបាយបំបែកបំបាក់របស់រដ្ឋាភិបាលបារាំង តែប៉ុណ្ណោះ។

ក្រោយពីបញ្ចប់សិក្ខាសាលានៅទីក្រុងប៉េកាំង នោះមក សហព័ន្ធពន្លឺយុវជនខ្មែរនៅអឺរ៉ុប ត្រូវរំលាយចោល ដោយទុកឱ្យ ចាន់ យូរ៉ាន់ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងអប់រំរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាអ្នកសម្រេចចិត្តផ្សេងៗ ចំពោះបញ្ហាគ្រប់បែបយ៉ាងដែលទាក់ទងនឹងនិស្សិតខ្មែរនៅអឺរ៉ុបនោះ។ អ៊ិន សូកាន តំណាងរណសិរ្សរួបរួមជាតិកម្ពុជា និងឱក សាគុន តំណាងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក៏ត្រូវបានបញ្ជូនឱ្យទៅជួយរៀបចំសមាគមនិស្សិតនៅប្រទេសបារាំង ដើម្បីឱ្យមានឯកភាពគ្នាឡើងវិញ។

តាមការណែនាំរបស់ អៀង សារី សហភាពនិស្សិតខ្មែរ និងសហភាពជាតិនៃនិស្សិតខ្មែរ បានរំលាយខ្លួនចូលមកជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសបារាំង ដែលទើបបង្កើតថ្មី ហើយសមាជិកសមាគមខ្មែរ នៅប្រទេសបារាំង ដែលសមាជិកមានប្រមាណតែ៥-៦នាក់ប៉ុណ្ណោះ ក៏ស្ម័គ្រចិត្តទៅចូលរួម ជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសបារាំង នោះដែរ។

របត់នយោបាយ

ដំបូងនិស្សិតមួយចំនួន ដែលមិនចូលចិត្តលទ្ធិកុម្មុយនិស្ត ក៏មិនសូវទុកចិត្តពួកមេដឹកនាំខ្មែរក្រហមប៉ុន្មានដែរ។ ប៉ុន្តែពេលពួកនិស្សិតនិយមកណ្ដាល លើកឡើងពីគុណសម្បត្តិរបស់ ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ពួកនិស្សិតដែលមិនសូវចូលចិត្តពួកកុម្មុយនិស្តមួយចំនួន ក៏យល់ព្រមចូលជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជានោះដែរ។ នៅក្នុងជួរសមាជិករណសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសបារាំងនោះ ក្រៅពីសមាសភាពនិស្សិតឆ្វេងនិយម ក៏មានសមាសភាពពួកនិស្សិត សីហនុនិយម ជាច្រើនផងដែរ។

ពេលនោះ មានតែសមាគមទូទៅរបស់ជនរួមជាតិខ្មែរនៅប្រទេសបារាំងទេ ដែលមិនព្រមចូលជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា។ ប៉ុន្តែមិនយូរប៉ុន្មាន សមាគមនេះក៏ចាប់ផ្ដើមមានការរង្គោះរង្គើបែកបាក់ផ្ទៃក្នុងជាបណ្ដើរៗ។

ពួកនិស្សិតជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជាប្រមាណ៣៥០នាក់ តែងមកប្រជុំគ្នាស្ទើររៀងរាល់ថ្ងៃសៅរ៍ នៅទីលានបាសីឡូន (Barcelone) និងនៅអាក់គុយអឺ (Arcueil) ដែលជាទីស្នាក់ការរបស់គណៈកម្មការស្នេហាជាតិខ្មែរ នៅបរទេស។

មេដឹកនាំពួកកុម្មុយនិស្តនៅទីនោះ ពិសេស អ៊ិន សូកាន ជាអ្នកដឹកនាំអង្គប្រជុំ និងធ្វើការពិភាក្សាគ្នាពីអំពើអាក្រក់របស់ពួកក្បត់ លន់ នល់ និងសហរដ្ឋអាមេរិក ជាមេខ្លោង ហើយឱ្យជឿជាក់លើជ័យជម្នះ របស់រណសិរ្សរួបរួមជាតិកម្ពុជា នៅពេលខាងមុខ។

ជាមួយគ្នានោះ អ៊ិន សូកាន ក៏បានដឹកនាំអង្គប្រជុំឱ្យពិភាក្សាគ្នាពីមនសិការភ្ញាក់រលឹកធ្វើបដិវត្តន៍របស់ប្រជាជនកម្ពុជា និងពីការចូលរួមរបស់បញ្ញវន្តក្នុងការធ្វើបដិវត្តន៍ផងដែរ។

---

# ៧.២១.លន់ នល់ ឱ្យសភាប្រកាស របបសាធារណរដ្ឋខ្មែរជាបន្ទាន់



**លន់ នល់, សិរិមតៈ និងចេង ហេង ក្នុងថ្ងៃប្រកាស របបសាធារណរដ្ឋខ្មែរ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០**

ក្រោយពេល សម្តេចសីហនុ ចាកចេញទៅព្យាបាលព្រះរោគនៅប្រទេសបារាំង ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧០ តាមមាត្រា២២ នៃរដ្ឋធម្មនុញ្ញ ចេង ហេង ជាប្រធានរដ្ឋសភាត្រូវឡើងជាប្រមុខរដ្ឋស្តីទី។ ចំណែក អ៊ិន តាំ ត្រូវបានតែងតាំងជាប្រធានសភាស្តីទី។ អ៊ិន តាំ រម្លឹកថា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧០ រដ្ឋសភាបានអនុម័តដោយលើកដៃ ឱ្យរូបគាត់ជាសមាជិកសភាឡើងជាអនុប្រធានទី១នៃរដ្ឋសភាជំនួស កែវ សាន ដែលបានលាឈប់។ នៅពេលប្រជុំសភាទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០នោះ គាត់មិនបានដឹងផែនការសម្ងាត់អ្វីទេ។ គាត់ជាប់ពាក់ព័ន្ធរដ្ឋប្រហារនេះ ដោយសារតែគាត់មានតំណែងជាប្រធានរដ្ឋសភាស្តីទី និងចេង ហេង មានតំណែងជាប្រមុខរដ្ឋស្តីទីតែប៉ុណ្ណោះ។

ក្រោយពីទម្លាក់សម្តេចសីហនុចេញពីអំណាចនៅថ្ងៃទី១៨ មីនា ទីស្តីការគណៈ

របត់នយោបាយ
រដ្ឋមន្ត្រីបានចេញសារាចរមួយ បង្គាប់ឱ្យដកព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រិយានី កុសុមៈ ចេញពីបន្ទប់ការិយាល័យនៅគ្រប់ក្រសួង ស្ថាប័ន និងចេញពីថ្នាក់រៀននៅគ្រប់គ្រឹះស្ថានសិក្សា ព្រមទាំងបំបាត់លែងឱ្យមានទង់ព្រះរាជសង្ហារ (ទង់ព្រះមហាក្សត្រ)។

បាវចនាព្រះរាជាណាចក្រកម្ពុជា ពីមុន គឺ ជាតិ សាសនា ព្រះមហាក្សត្រ ក៏ត្រូវលុបបំបាត់ពាក្យថា ព្រះមហាក្សត្រចោល ទុកតែពាក្យជាតិ សាសនា ប៉ុណ្ណោះ។

ជាមួយគ្នានោះ មន្ត្រីធ្វើការនៅក្នុងព្រះបរមរាជវាំង និងកងរក្សាព្រះអង្គ (ទាហានវាំង) ទាំងអស់ ក៏ត្រូវរំសាយចោល ឱ្យទៅបម្រើការងារនៅតាមស្ថាប័នក្រសួងផ្សេងទៀត។ នៅទីបំផុត ព្រះមហាក្សត្រិយានី កុសុមៈ ត្រូវបានគេបណ្តេញលែងឱ្យគង់នៅក្នុងព្រះបរមរាជវាំងដែរ។

នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧០ អេម៉ូរី ស្វង់ ឯកអគ្គរដ្ឋទូតរបស់សហរដ្ឋអាមេរិក បានមកបំពេញតួនាទីរបស់ខ្លួន នៅទីក្រុងភ្នំពេញ ក្រោយពីទំនាក់ទំនងការទូតរវាងប្រទេសទាំង២ ត្រូវបានកាត់ផ្តាច់អស់រយៈពេល៥ឆ្នាំមក។

ដើម្បីគោរពតាមពាក្យសន្យារបស់ លន់ នល់ ជាមួយសិស្សនិស្សិតបញ្ញវន្ត នៅក្នុងឱកាសចូលរួមជាអធិបតី ក្នុងពិធីព្យុហយាត្រាមហាសាមគ្គីជាតិ នៅពហុកីឡដ្ឋានជាតិអូឡាំពិក កាលពីខែមេសាកន្លងមក ដែលថា គាត់នឹងបង្កើតរបបសាធារណរដ្ឋនិយមនៅកម្ពុជា នាពេលឆាប់ៗខាងមុខនេះ។

តាមគម្រោងដែលបានគ្រោងទុក នៅចុងខែកញ្ញា ចេង ហេង ត្រូវទៅប្រជុំនៅអង្គការសហប្រជាជាតិ ក្នុងនាមជា ប្រមុខរដ្ឋនៃប្រទេសកម្ពុជា និងត្រូវជួបពិភាក្សាជាមួយប្រធានាធិបតីអាមេរិក និចសុន ផងដែរ។ គាត់ត្រូវចាកចេញពីប្រទេសនៅថ្ងៃទី៩ ខែតុលា និងត្រូវទៅចុះសំចតនៅប្រទេសជប៉ុនមួយរយៈ។ នៅពេលឈប់សំចតនោះ ចេង ហេង ក៏ត្រូវបានព្រះចៅអធិរាជជប៉ុន អនុញ្ញាតឱ្យចូលបង្គំគាល់ និងសម្តែងការគួរសមក្នុងឋានៈគាត់ជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា ផងដែរ។

គម្រោងដែល ចេង ហេង ត្រូវចេញទៅប្រជុំនៅអង្គការសហប្រជាជាតិនេះ ធ្វើឱ្យ

របត់នយោបាយ

មានការច្រណែន លាយឡំនឹងការមិនទុកចិត្តពីសំណាក់នាយករដ្ឋមន្ត្រី លន់ នល់ និង ឧបនាយករដ្ឋមន្ត្រី សិរិមតៈ ព្រោះ ចេង ហេង ជាកូនចិញ្ចឹមរបស់ ប៉ែន នុត នាយករដ្ឋមន្ត្រីរដ្ឋាភិបាលរួបរួមជាតិ របស់សម្ដេចសីហនុ នៅក្រុងប៉េកាំង។ លន់ នល់ និងសិរិមតៈ ខ្លាច ចេង ហេង ឆ្លៀតឱកាសជួបទាក់ទងជាមួយ សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេស នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ដូច្នេះ ទ្រង់សិរិមតៈ ចង់ឱ្យ លន់ នល់ ជានាយករដ្ឋមន្ត្រីទៅប្រជុំនៅអង្គការសហប្រជាជាតិ វិញ។

ដោយសារបញ្ហានេះស្មុគស្មាញមិនអាចដោះស្រាយបាន លន់ នល់ និងសិរិមតៈ បានហៅ អ៊ិន តាំ ពីខេត្តកំពង់ចាម ឱ្យមកជួយនិយាយសម្របសម្រួលជាមួយ ចេង ហេង។

សិរិមតៈ បាននិយាយប្រាប់ អ៊ិន តាំ ថា ពេលនេះគួរឱ្យ លន់ នល់ ចេញទៅបង្ហាញមុខមាត់ ដើម្បីឱ្យពិភពលោកបានស្គាល់ផង ហើយឱ្យ អ៊ិន តាំ ទៅជួយនិយាយបញ្ចុះបញ្ចូល ចេង ហេង ព្រោះជាមនុស្សជិតស្និទ្ធធ្លាប់ធ្វើតំណាងរាស្ត្រជាមួយគ្នាយូរឆ្នាំហើយ។ តែនៅពេល អ៊ិន តាំ ទៅជួប ចេង ហេង គាត់ប្រកែកញ៉ាញថា ម្ដងនេះ ធ្វើអីគាត់ក៏ធ្វើចុះ គាត់មិនឱ្យគេជិះជាន់គាត់តាមអំពើចិត្តទៀតទេ។ គាត់មិនព្រមទេ ព្រោះកម្មវិធីនេះត្រូវបានប្រធានាធិបតីអាមេរិក និចសុន យល់ព្រមរួចស្រេចទៅហើយ។

អ៊ិន តាំ ក៏មិនហ៊ាននិយាយបញ្ចុះបញ្ចូល ចេង ហេង តទៅទៀតដែរ ហើយគាត់ក៏ត្រេកអរដែរ បើ ចេង ហេង នៅតែប្រកាន់ជំហររឹងមាំដូច្នេះ គាត់នឹងជួយទប់។ អ៊ិន តាំ ក៏បានទៅប្រាប់ទ្រង់ សិរិមតៈ វិញ ដោយសង្កត់ធ្ងន់ថា កម្មវិធីនេះត្រូវបានសេតវិមានរបស់អាមេរិក យល់ព្រមហើយ មិនអាចផ្លាស់ប្ដូរបានទេ។

ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧០ អ៊ុង ស៊ីម ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា និងអ៊ិន តាំ ប្រធានរដ្ឋសភា ត្រូវបានគេអញ្ជើញឱ្យទៅជួបពិភាក្សាគ្នាជាមួយ លន់ នល់ នៅទីស្ដីការក្រសួងការពារជាតិ វេលាម៉ោង៩ព្រឹក។ ពេលទៅដល់ទីស្ដីការក្រសួងការពារជាតិគាត់ទាំងពីរនាក់ ត្រូវគេនាំចូលទៅក្នុងការិយាល័យរបស់ លន់ នល់ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ។ ពេលនោះឃើញ លន់ នល់ និងសិរិមតៈ

របត់នយោបាយ

ស្មៀកពាក់សណ្ឋានជាឧត្តមសេនីយ៍ឯក និងឧត្តមសេនីយ៍ទោ អង្គុយរង់ចាំគាត់ជាស្រេច។



**សិរិមតៈ និងលន់ នល់**

បន្ទាប់មក ពួកគាត់បានអង្គុយទល់មុខគ្នាពីរនាក់ម្ខាង ដើម្បីពិភាក្សាគ្នា។ លន់ នល់ និយាយថា យើងសូមឱ្យឯកឧត្តមទាំងពីរនាក់ ជួយរៀបចំពិធីប្រកាសរបបសាធារណរដ្ឋខ្មែរឱ្យយើង។ អ៊ិន តាំ សួរថា តើត្រូវប្រកាសនៅពេលណា? លន់ នល់ ឆ្លើយថា ប្រកាសពេលឆាប់ៗនេះ ព្រោះមានយុវជនច្រើនណាស់ ដែលស្លាប់នៅសមរភូមិមុខ ដូចជា សមរភូមិកោះធំ ជាដើម ពួកគេចង់ស្លាប់នៅក្រោមទង់សាធារណរដ្ឋខ្មែរ។

អ៊ិន តាំ សួរថា ចុះ ចេង ហេង ជាប្រមុខរដ្ឋត្រូវទៅប្រជុំនៅអង្គការសហប្រជាជាតិ នៅថ្ងៃទី៩ តុលា ខាងមុខនេះ តើគិតយ៉ាងម៉េច?។ លន់ នល់ ប្រាប់ថា ត្រូវចាត់ការរឿងនេះភ្លាមៗទៅ ព្រោះបើមានរឿងអ្វីកើតឡើង យើងមិនទទួលខុសត្រូវឡើយ។

ក្រោយពី លន់ នល់ ទទូចចង់ឱ្យរៀបចំពិធីប្រកាសរបបសាធារណរដ្ឋខ្មែរ ឆាប់ៗនោះមក អ៊ិន តាំ និងអ៊ុង ស៊ីម ក៏យករឿងនេះទៅពិភាក្សាជាមួយ ចេង ហេង ជាប្រមុខរដ្ឋ ដើម្បីសុំការផ្តល់យោបល់សម្រេច។

ចេង ហេង ក៏ប្រាប់ អ៊ិន តាំ និងអ៊ុង ស៊ីម ថា គន់ វិច រដ្ឋមន្ត្រីក្រសួងការបរទេស

របត់នយោបាយ

ដែលកំពុងដឹកនាំគណៈប្រតិភូរដ្ឋាភិបាល ទៅប្រជុំនៅអង្គការសហប្រជាជាតិ បានផ្ញើសារទូរលេខមួយមកប្រាប់គាត់ថា កុំប្រញាប់ប្រញាល់ធ្វើពិធីប្រកាសរបបសាធារណរដ្ឋខ្មែរធ្វើអ្វី ព្រោះបើយើងប្រកាសប្រទេស ជាសាធារណរដ្ឋនៅពេលនេះ វាអាចឱ្យមានបញ្ហាសើរើអាសនៈខ្មែរយើងនៅអង្គការសហប្រជាជាតិ។ ម្យ៉ាងទៀត ពេលនេះអង្គការសហប្រជាជាតិ ក៏បានទទួលស្គាល់រដ្ឋាភិបាលថ្មីយើងហើយដែរ។

អ៊ិន តាំ បញ្ជាក់ប្រាប់ ចេង ហេង ថា ទោះយ៉ាងណា លន់ នល់ និងសិរិមតៈ ហាក់ដូចជាបង្ខំពួកយើងឱ្យធ្វើពិធីប្រកាសរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃទី៩ ខែតុលា ខាងមុខនេះ ដោយគ្មានតថ្លៃអ្វីបានឡើយ។ ដូច្នេះ គួរផ្ញើសារទូរលេខទៅសួរយោបល់ គន់ វិច រដ្ឋមន្ត្រីក្រសួងការបរទេស និងយឹម ទិត ជាទីប្រឹក្សារដ្ឋាភិបាល ដែលកំពុងប្រជុំនៅអង្គការសហប្រជាជាតិ សិន។ បន្តិចក្រោយមក គន់ វិច និងយឹម ទិត បានឆ្លើយមកវិញថា ធ្វើក៏បាន មិនធ្វើក៏បាន។ ដូច្នេះ ចេង ហេង ក៏បានយល់ព្រមឱ្យធ្វើពិធីប្រកាសរបបសាធារណរដ្ឋខ្មែរតាមការចង់បានរបស់ លន់ នល់ និងសិរិមតៈ។

អ៊ិន តាំ សួរ ចេង ហេង ថា មុននឹងធ្វើពិធីប្រកាសរបបសាធារណរដ្ឋខ្មែរ ត្រូវធ្វើរដ្ឋធម្មនុញ្ញថ្មីសិន ឬមួយត្រូវប្រើរដ្ឋធម្មនុញ្ញចាស់? ចេង ហេង ប្រាប់ថា រឿងនេះត្រូវប្រជុំពិភាក្សាជាមួយអ្នកជំនាញច្បាប់នៅរដ្ឋសភា និងនៅក្រុមប្រឹក្សាព្រះរាជាណាចក្រ ព្រមទាំងអ្នកច្បាប់ល្បីៗដូចជា ភឹង គុន ជាដើមសិន។

នៅថ្ងៃទី៥ ខែតុលា ក្នុងពេលប្រជុំពិភាក្សាគ្នា ភឹង គុន ឱ្យយោបល់ថា ត្រូវតែធ្វើរដ្ឋធម្មនុញ្ញថ្មីសិន ទើបអាចប្រកាសសាធារណរដ្ឋ បាន។ ចំណែក ឧក ប៉ាស៊ី វិញ ឱ្យយោបល់ថា យើងធ្វើរដ្ឋធម្មនុញ្ញថ្មីបណ្តើរៗ ហើយប្រើរដ្ឋធម្មនុញ្ញចាស់ សិនទៅ លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងគោលការណ៍របស់របបសាធារណរដ្ឋ។

ដោយសារមានមតិមិនស្របគ្នា ចេង ហេង បានឱ្យអ្នកច្បាប់របស់រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអ្នកច្បាប់ល្បីៗប្រជុំពិភាក្សាគ្នា និងបោះឆ្នោតសម្រេចថា ត្រូវតែធ្វើរដ្ឋធម្មនុញ្ញថ្មីសិន ទើបប្រកាសរបបសាធារណរដ្ឋជាក្រោយ ឬ

របត់នយោបាយ

ត្រូវប្រកាសរបបសាធារណរដ្ឋ ដោយប្រើរដ្ឋធម្មនុញ្ញចាស់សិន រួចធ្វើរដ្ឋធម្មនុញ្ញថ្មីជាក្រោយ ? ។






**ភឹង គុន** **ឌុក រ៉ាស៊ី** **ហង្ស ធុនហាក់** **យ៉ែម សំបូរ**

លទ្ធផលនៃការបោះឆ្នោតគឺ មតិរបស់ ឌុក រ៉ាស៊ី ដែលបានលើកឡើងថា ត្រូវប្រកាសរបបសាធារណរដ្ឋ ដោយប្រើរដ្ឋធម្មនុញ្ញចាស់សិននោះ ទទួលការគាំទ្រ១៩សំឡេង។ ចំណែក មតិរបស់ ភឹង គុន ដែលបានលើកឡើងថា ត្រូវធ្វើរដ្ឋធម្មនុញ្ញថ្មីសិនទើបប្រកាសរបបសាធារណរដ្ឋជាក្រោយ ទទួលការគាំទ្រ១៨សំឡេង។ តែពេលនោះភឹង គុន មិនបានបោះឆ្នោតគាំទ្រមតិខ្លួនឯងទេ ដោយគាត់លើកហេតុផលថា គាត់ជាអ្នកបច្ចេកទេស គ្រាន់តែឱ្យយោបល់អង្គប្រជុំប៉ុណ្ណោះ គាត់មិនមែនជាទទួលខុសត្រូវក្នុងរឿងនេះទេ។ ទីបំផុត ចេង ហេង ក្នុងនាមជាប្រមុខរដ្ឋ ក៏សម្រេចយកយោបល់របស់ ឌុក រ៉ាស៊ី ទុកជាបានការ។

នៅថ្ងៃទី៧ ខែតុលា រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា បើកកិច្ចប្រជុំពិភាក្សាស្តីពីការបង្កើតរបបសាធារណរដ្ឋខ្មែរ ដោយតម្កល់ទុករដ្ឋធម្មនុញ្ញចាស់សិន។ តែពេលនោះ ក៏មានការខ្វែងយោបល់គ្នា ស្តីពីការបង្កើតទង់ជាតិនៃសាធារណរដ្ឋខ្មែរ។ យ៉ែម សំបូរ រដ្ឋមន្ត្រីទំនាក់ទំនងសភាទាំងពីរ បានបង្ហាញគំរូទង់ជាតិ ដែលរដ្ឋាភិបាលបានធ្វើរួចហើយ មកបង្ហាញអង្គប្រជុំ។ គំរូទង់ជាតិនោះមានទម្រង់ និងពណ៌ដូចទង់ជាតិវៀតកុង ស្ទើរទាំងស្រុង គ្រាន់តែទង់ជាតិវៀតកុង មានផ្កាយតែមួយ ឯទង់ជាតិសាធារណរដ្ឋខ្មែរ មានផ្កាយបី។ មតិភាគច្រើនសុំឱ្យ ដាក់រូបប្រាសាទអង្គរ នៅចំ

របត់នយោបាយ
កណ្តាលទង់ជាតិ នោះ តែ យ៉ែម សំបូរ លើកឡើងថា ការដាក់រូបប្រាសាទអង្គរ គឺហួសសម័យទៅហើយ គួរដាក់រូបផ្កាយបី វិញ។ សមាជិកអង្គប្រជុំភាគច្រើន មិនព្រមទទួលយកគំរូទង់ជាតិរបស់រដ្ឋាភិបាល ឡើយ។ សូម្បី ហង្ស ធុនហាក់ ក្នុងនាម ជាអ្នកបច្ចេកទេស ដែលរដ្ឋាភិបាល ឱ្យមកជួយ យ៉ែម សំបូរ នៅក្នុងអង្គប្រជុំពិភាក្សាគ្នានោះ ក៏បានតវ៉ាដែរថា បើមិនដាក់រូបសញ្ញាប្រាសាទអង្គរ ទេ គាត់នឹងដើរចេញពីរដ្ឋសភា ភ្លាម។ ដូច្នេះ សូម្បីតែតំណាងរដ្ឋាភិបាល ក៏ខ្វែងយោបល់គ្នាដែរ ធ្វើឱ្យការពិភាក្សាគ្នាកាន់មានភាពស្វិតស្វាញតានតឹង ថែមទៀត ដោយមតិខ្លះថា ដាក់រូបផ្កាយបី មតិខ្លះទៀតថាដាក់រូបប្រាសាទអង្គរ។ ការជជែកតវ៉ាគ្នា ស្តីពីការបង្កើតទង់ជាតិនៃសាធារណរដ្ឋខ្មែរ បានអូសបន្លាយរហូតដល់ម៉ោង២រំលងអធ្រាត្រ នៅតែមិនមានការឯកភាពគ្នាទៀត រដ្ឋាភិបាលក៏បាននិមន្តព្រះភិក្ខុ ប៉ាង ខាត់ និងអ៊ឹង ក្រពុំផ្កា ឱ្យមកជួយរកដំណោះស្រាយ។ អ៊ឹង ក្រពុំផ្កា បានឱ្យយោបល់ថា ដើម្បីបញ្ចប់ការចម្រូងចម្រាសគ្នា គួរដាក់ឱ្យមានរូបប្រាសាទអង្គរ ផង និងឱ្យមានរូបផ្កាយបី ផង។ គាត់បានពន្យល់អត្ថន័យថា ផ្កាយបី ជាផ្កាយ ដែលជារបស់ លន់ នល់ ផង, ផ្កាយបី ជាតំណាងឱ្យព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ផង, ផ្កាយបី ជាតំណាងឱ្យអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ផងដែរ។



**ព្រះភិក្ខុប៉ាង ខាត់**



**ទង់ជាតិនៃរបបសាធារណរដ្ឋខ្មែរ**

របត់នយោបាយ

អង្គប្រជុំក៏បានឯកភាពគ្នាតាមការលើកឡើងរបស់ អ៊ឹង ក្រពុំផ្កា និងបានអនុម័តជាឯកច្ឆន្ទនូវច្បាប់ថ្មីមួយ ស្ដីពីការបង្កើតរបបសាធារណរដ្ឋខ្មែរ ហើយបានបញ្ចប់កិច្ចប្រជុំនៅវេលាម៉ោង៣ទៀបភ្លឺ។

បន្ទាប់មក ចេង ហេង ក្នុងនាមប្រមុខរដ្ឋ ក៏បានចុះហត្ថលេខាលើក្រមលេខ ៤៤២/៧០ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧០ ស្ដីពីការប្រកាសបង្កើតរបបសាធារណរដ្ឋខ្មែរ មាន៤មាត្រា៖

**មាត្រា១៖** ប្រទេសកម្ពុជា ជាសាធារណរដ្ឋមួយ និងមិនអាចបែងចែកបាន។ សាធារណរដ្ឋនេះ មានឈ្មោះជាផ្លូវការថា “ សាធារណរដ្ឋខ្មែរ ”។ ការប្រកាសរបបសាធារណរដ្ឋខ្មែរ នេះ នឹងធ្វើឡើងនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧០ វេលាម៉ោង៧ព្រឹក ដោយសភាទាំង២ ក្នុងនាមប្រជាជាតិខ្មែរ តាមរយៈរបស់ប្រធានសភាជាតិ។

**មាត្រា២៖** ដោយរង់ចាំរៀបចំដំណើរការដំបូងរបស់របបសាធារណរដ្ឋ និងការអនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលអនុលោមតាមទម្រង់របបសាធារណរដ្ឋនិយម រដ្ឋធម្មនុញ្ញបច្ចុប្បន្ន (រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មុនថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០) ត្រូវអនុញ្ញាតឱ្យប្រើប្រាស់បន្តទៅទៀត លើកលែងតែបទប្បញ្ញត្តិផ្សេងៗ ដែលផ្ទុយនឹងស្មារតី និងទម្រង់នៃរបបសាធារណរដ្ឋនិយម។

**មាត្រា៣៖** រាល់ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ជាពិសេសបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដែលផ្ដល់ ឬទទួលស្គាល់បុព្វសិទ្ធិផ្សេងៗតាំងពីកំណើតមក ដែលផ្ទុយនឹងគោលការណ៍ស្មើភាពគ្នា របស់ប្រជាពលរដ្ឋ នៅចំពោះមុខច្បាប់ត្រូវចាត់ទុកថា ជាបទប្បញ្ញត្តិ ដែលគ្មានតម្លៃ និងមោឃៈ។

**មាត្រា៤៖** លោក ចេង ហេង ប្រមុខរដ្ឋបច្ចុប្បន្ន ត្រូវបន្តមុខតំណែង ជាប្រមុខរដ្ឋហូតដល់មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ។

ភ្លាមៗនោះ វណ្ណ ម៉ូលីវណ្ណ ក៏បានឱ្យគេរៀបចំសង់ស្តូបតំណាងរបបសាធារណរដ្ឋខ្មែរមួយនៅចំកណ្តាលទីធ្លាសួនច្បារមុខប្រាសាទចន្ទឆាយា ដើម្បីប្រារព្ធពិធីប្រកាស

របត់នយោបាយ
របបសាធារណរដ្ឋខ្មែរ។ ប៉ុន្តែ ការសាងសង់ស្តូបនោះ បានធ្វើឡើងតាំងពីព្រឹកថ្ងៃទី៨ ខែតុលា រហូតដល់វេលារំលងអធ្រាត្រ ឈានចូលដល់ថ្ងៃទី៩ ខែតុលា នៅតែមិនទាន់រួចរាល់ជាស្ថាពរទៀត។

លុះព្រឹកឡើង ដល់ពេលប្រារព្ធពិធី ស៊ីម៉ងត៍មិនទាន់ស្ងួតធ្វើឱ្យស្តូបនោះ មើលទៅឃើញរាងទ្រេតបន្តិច ក៏មានអ្នកខ្លះខ្សឹបខ្សៀវគ្នាថា របបសាធារណរដ្ឋខ្មែរ នេះ អាយុមិនវែងទេ នឹងត្រូវដួលរលំជាមិនខាន។

នៅថ្ងៃសុក្រ ទី៩ ខែតុលា ឆ្នាំ១៩៧០ លន់ នល់ បានសម្រេចធ្វើពិធីប្រកាសបង្កើតរបបសាធារណរដ្ឋខ្មែរ ជាផ្លូវការ ប្តូរផ្លាស់របបគ្រប់គ្រងតាមបែបរាជានិយមផ្តាច់ការមកជារបបគ្រប់គ្រង តាមបែបលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស វិញ។

ពិធីជាប្រវត្តិសាស្ត្រនេះ បានប្រារព្ធឡើងនៅចំកណ្តាលទីធ្លាសួនច្បារមុខប្រាសាទចន្ទឆាយា ដោយមានការចូលរួមពីសំណាក់ទាហាន ព្រះសង្ឃ មន្ត្រីរដ្ឋការ សិស្ស និស្សិតយ៉ាងច្រើនកុះករ ព្រមទាំងអង្គទូតនានាជាច្រើនទៀត។ ប៉ុន្តែ គេពុំបានឃើញវត្តមានរបស់ឯកអគ្គរដ្ឋទូតបារាំង, ឥណ្ឌា, សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមចូលរួមឡើយ។

អ៊ិន តាំ បានឡើងថ្លែងសុន្ទរកថា ប្រកាសបង្កើតរបបសាធារណរដ្ឋខ្មែរ មានខ្លឹមសារថា៖

- ដោយពិនិត្យឃើញថា អំពើអាក្រក់ច្រើនអនេករបស់របបរាជាធិបតេយ្យ ដែលប្រឆាំងនឹងភាពជឿនលឿន។
- ដោយអនុលោមតាមគោលការណ៍ទាំងឡាយនៃរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋទាំងអស់មានសិទ្ធិចាត់ចែងដោយខ្លួនឯង។
- ដោយអនុលោមតាម ឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលបង្ហាញឡើងតាមរយៈ មហាព្យុហយាត្រាមហាសាមគ្គីជាតិ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧០ និងញត្តិផ្សេងៗ ដែលផ្ញើមកពីគ្រប់ស្រទាប់វណ្ណៈសង្គមទាំងអស់។

របត់នយោបាយ
- ដោយយល់ឃើញថា ប្រជាពលរដ្ឋខ្មែរ បានយកចិត្តទុកដាក់នឹងបាវចនា សេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និងសុភមង្គល។
- ដោយសម្អាងលើក្រមលេខ៤៤២ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៧០ យើង អ៊ិន តាំ ប្រធានរដ្ឋសភានៃប្រទេសកម្ពុជា តាងនាមឱ្យប្រជាជាតិទាំងមូល ខ្ញុំសូមប្រកាសជាឱឡារិក នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧០ នេះ និងចាប់ពីម៉ោងនេះ តទៅ ថា ប្រទេសកម្ពុជា ជាសាធារណរដ្ឋទី១ និងមិនអាចបំបែកបាន មានឈ្មោះ ជាផ្លូវការថា៖ “ សាធារណរដ្ឋខ្មែរ ”។





**ពិធីកាត់ខ្សែបូសម្ពោធស្ថាបនាសាធារណរដ្ឋខ្មែរថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧០**

បន្ទាប់មក លន់ នល់ អមដំណើរដោយ សិរិមតៈ និងអ៊ិន តាំ បានធ្វើដំណើរមកបង្ហូតទង់ជាតិនៃរបបសាធារណរដ្ឋខ្មែរ ដោយមានបទចម្រៀងជាតិថ្មី មានខ្លឹមសារថា៖ “ ជនជាតិខ្មែរ ល្បីពូកែមួយក្នុងលោក មានជ័យជោគ កសាងប្រាសាទសិលា អារ្យធម៌ខ្ពស់បវរជាតិសាសនា កេរ្តិ៍ដូនតាទុកលើភពផែនដី។ ខ្មែរក្រោកឡើង ខ្មែរក្រោកឡើង ខ្មែរក្រោកឡើង តស៊ូតម្កើងសាធារណរដ្ឋ ខ្ទាំងរំលោភ ខ្មែរប្រយុទ្ធ មិនតក់ស្លុត យកជ័យបំផុតជូនជាតិខេមរា ឯករាជ្យភ្លឺថ្លា ជាមហាប្រទេសតទៅ... ” បទគោរពទង់ជាតិនេះត្រូវបានបង្កើតឡើង ជំនួសបទភ្លេង និងចម្រៀងជាតិចាស់ ដែលចាប់ផ្ដើមដំបូងថា៖ “ សូមពួកទេព្តា រក្សាមហាក្សត្រយើងឱ្យបានរុងរឿង ជោគជ័យមង្គល... ”វិញ។

របត់នយោបាយ

អ៊ិន តាំ បានរម្លឹកថា នៅថ្ងៃសុក្រទី៩ ខែតុលា ឆ្នាំ១៩៧០ ជាថ្ងៃប្រារព្ធពិធីប្រកាសរបបសាធារណរដ្ឋខ្មែរ ជាផ្លូវការនោះ ចេង ហេង ជាប្រមុខរដ្ឋ ត្រូវទៅចូលរួមប្រជុំនៅអង្គការសហប្រជាជាតិ រូបគាត់ជាប្រធានសភា ត្រូវឡើងជាប្រមុខរដ្ឋស្តីទី។ តែដោយសារ ចេង ហេង ភ័យខ្លាច ពេលគាត់អវត្តមានក្នុងប្រទេស ឧត្តមសេនីយ៍ លន់ នល់ និងសិរិមតៈ ប្រើស្មៀតធ្វើរដ្ឋប្រហារទម្លាក់គាត់ចេញពីតំណែងប្រមុខរដ្ឋ ដូចសម្តេចសីហនុ ដែរនោះ ចេង ហេង ក៏រង់ចាំចូលរួមធ្វើពិធីប្រកាសរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃសុក្រទី៩ ខែតុលា ឱ្យរួចរាល់សិន ទើបគាត់ចេញដំណើរទៅចូលរួមប្រជុំនៅអង្គការសហប្រជាជាតិ។

ក្រោយពេលបង្ហូតទង់ជាតិរបបសាធារណរដ្ឋខ្មែររួច ដើម្បីលួងចិត្ត លន់ នល់ សភាទាំងពីរក៏បានស្នើសុំឱ្យ ចេង ហេង ចេញក្រឹត្យ ដំឡើងឋានន្តរសក្តិឧត្តមសេនីយ៍ឯក លន់ នល់ ជានាយឧត្តមសេនីយ៍ (ផ្កាយ៤) និងចេញក្រឹត្យ ដំឡើងឋានន្តរសក្តិជូនឧត្តមសេនីយ៍ទោ សិរិមតៈ ជាឧត្តសេនីយ៍ឯក (ផ្កាយបី)។ តែពេលនោះ ទោះបីមាន ចេង ហេង ជាប្រមុខរដ្ឋស្តីទី ក៏ដោយ ក៏ លន់ លន់ មិនឱ្យនរណាម្នាក់បំពាក់ឋានន្តរសក្តិផ្កាយ៤ នោះ ឱ្យគាត់ទេ គឺគាត់លើកពាក់ដោយខ្លួនឯង។



**ឧត្តមសេនីយ៍ឯក លន់ នល់ ត្រូវបានដំឡើងឋានន្តរសក្តិ**
**ជានាយឧត្តមសេនីយ៍**

របត់នយោបាយ

ក្រោយពី ចេង ហេង ចេញទៅប្រជុំ នៅអង្គការសហប្រជាជាតិ មក អ៊ិន តាំ ត្រូវឡើងជាប្រមុខរដ្ឋស្តីទី រហូតដល់ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧០ ទើប ចេង ហេង វិលត្រលប់មកមាតុប្រទេស វិញ។

នៅក្នុងអំឡុងពេលទៅប្រជុំន នៅអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉កនោះ ចេង ហេង ក៏បានជួបពិភាក្សាការងារ ជាមួយប្រធានាធិបតីអាមេរិក និចសុន នៅថ្ងៃទី២២ ខែតុលា ផងដែរ។

ក្រោយពីធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មក គ្រឹះស្ថានសិក្សា, សាលាបឋមសិក្សា, អនុវិទ្យាល័យ, វិទ្យាល័យ, មហាវិទ្យាល័យ, មហាវិថី, មន្ទីរពេទ្យ និងសមិទ្ធផលអ្វីៗទាំងអស់ ដែលពីមុនមានដាក់ព្រះនាមអតីតព្រះមហាក្សត្រ និងរាជវង្សទាំងអស់ នៅតាមបណ្តាខេត្តនានា ពិសេសនៅទីក្រុងភ្នំពេញ ត្រូវប្តូរផ្លាស់ឈ្មោះថ្មី ដូចជា សាកលវិទ្យាល័យភូមិន្ទសង្គមរាស្ត្រនិយម ត្រូវដូរឈ្មោះ ជាសាកលវិទ្យាល័យភ្នំពេញ, វិទ្យាល័យព្រះស៊ីសុវត្ថិ ត្រូវដូរឈ្មោះថា វិទ្យាល័យភ្នំដូនពេញ ក្រោយថ្ងៃប្រកាសសាធារណរដ្ឋ ដូរទៅជា វិទ្យាល័យ ៩ តុលា ១៩៧០, វិទ្យាល័យព្រះយុគន្ធរ ត្រូវដូរឈ្មោះថា វិទ្យាល័យ១៨ មីនា១៩៧០ រួចដូរទៅជា វិទ្យាល័យកែវ សង់គីម ឆ្នាំ១៩៧៤។ វិទ្យាល័យឥន្ទ្រទេវី ត្រូវដូរឈ្មោះទៅជា វិទ្យាល័យទួលគោក, វិទ្យាល័យហរិរក្សរាមា (រៀនភាសាអង់គ្លេស នៅជាប់របងមហាវិទ្យាល័យច្បាប់) ដូរទៅជាវិទ្យាល័យបឹងត្របែក, វិទ្យាល័យម៉ូនិក-សីហនុ (នៅប៉ែកខាងត្បូងវិទ្យាល័យហរិរក្សរាមា) ដូរទៅជាវិទ្យាល័យក្បាលថ្នល់, វិទ្យាល័យសង្គមរាស្ត្រនិយម (នៅក្បែរបង្គោលអង់តែនទូរទស្សន៍ទួលគោក) ដូរទៅជា វិទ្យាល័យបឹងកក់, មហាវិថីព្រះនរោត្តម ត្រូវដូរឈ្មោះថាមហាវិថី៩តុលា១៩៧០, មហាវិថីព្រះសីហនុ ត្រូវដូរឈ្មោះថាមហាវិថី១៨មីនា១៩៧០, មហាវិថីព្រះមុនីវង្ស ត្រូវដូរឈ្មោះថា មហាវិថីប្រជាធិបតេយ្យ ជាមួយគ្នានោះ កងយោធពលខេមរភូមិន្ទ ក៏ត្រូវដូរឈ្មោះថា កងយោធពលខេមរជាតិ ឬកងទ័ពជាតិ ដែលហៅកាត់ថា ក.ទ.ជ ពួកមន្ត្រីរាជការ ត្រូវហៅថា មន្ត្រីរដ្ឋការវិញ...។ និយាយរួម អ្វីៗទាំងអស់

របត់នយោបាយ

ដែលពាក់ព័ន្ធនឹងរបបរាជានិយម គឺរបបសាធារណរដ្ឋខ្មែរ ចាត់ទុកថាជារបបសក្តិភូមិ ជិះជាន់ ដូចពួកមេខ្មែរក្រហម ដែរនោះ ត្រូវលុបបំបាត់លែងឱ្យប្រើតទៅទៀត។





**ពិធីប្រកាសរបបសាធារណរដ្ឋខ្មែរ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧0**

# ៧.២២. ប្រតិបត្តិការសឹកចេនឡាទី២



## យន្តហោះអាមេរិក ទម្លាក់គ្រាប់បែកតាមបណ្តោយផ្លូវជាតិលេខ៦ ក្បែរទីប្រជុំជនស្គន់

ក្រោយពេលកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរក្រហម វាយកាត់ផ្តាច់ផ្លូវជាតិលេខ៦ ចូលមកដល់ទីប្រជុំជនតាំងគោក, ទីរួមស្រុកបារាយណ៍ និងភ្នំសន្ទុកមក នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ឯក លន់ នល់ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ និងឧត្តមសេនីយ៍ សក់ ស៊ុតសាខន (សិស្សនាយទាហានជំនាន់ទី១) ជានាយអគ្គសេនាធិការ បានបញ្ជាឱ្យបើកប្រតិបត្តិការសឹកចេនឡាទី១ បើកផ្លូវជាតិលេខ៦ ដើម្បីតភ្ជាប់ផ្លូវគមនាគមន៍ ពីទីក្រុងភ្នំពេញ ទៅទីរួមកំពង់ធំ ឡើងវិញ។ វរសេនីយ៍ អ៊ំ សាវុធ ជាមេបញ្ជាការនៃប្រតិបត្តិការសឹកនេះ បានយកប្រជុំជនស្គន់ ធ្វើជាទីបញ្ជាការ។ មុនពេលមានព្រឹត្តិការរដ្ឋប្រហារឆ្នាំថ្ងៃ១៨ ខែមីនា វរសេនីយ៍ អ៊ំ សាវុធ នេះ ត្រូវបានសម្តេចសីហនុ ត្រាស់បង្គាប់ឱ្យទទួលបេសកកម្មបេសកកម្មពិសេសមួយ គឺធ្វើទំនាក់ទំនងសម្ងាត់ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលចូលមកបោះទីតាំង

របត់នយោបាយ

នៅក្នុងទឹកដីខ្មែរ។

ក្នុងប្រតិបត្តិការសឹកនេះ នាយអគ្គសេនាធិការ សក់ ស៊ុតសាខន ប្រើកម្លាំងទាហានប្រមាណ១០០០០នាក់។ ចំណែកខាងខ្មាំង ត្រូវបានរាយការណ៍ថាមានកងទ័ពវៀតកុង-វៀតណាមខាងជើង ប្រមាណ៥០០០នាក់ និងមានកងទ័ពខ្មែរក្រហមចូលរួមរាប់ពាន់នាក់ទៀត។ ប្រតិបត្តិការសឹកចេនឡាទី១ ចែកចេញជាពីរមុខព្រួញ គឺមុខព្រួញទី១ ចាប់ផ្តើមវាយបើកផ្លូវជាតិលេខ៦ ពីទីរួមប្រជុំជនស្គន់ឆ្ពោះ ទៅទីប្រជុំជនកំពង់ថ្ម ដោយត្រូវឆ្លងកាត់ឃុំសំពងជ័យ (ស្រុកព្រៃឈរ ខេត្តកំពង់ចាម) ស្រុកតាំងគោក និងស្រុកបារាយណ៍។

ចំណែកមុខព្រួញទី២ ផ្លូវជាតិលេខ៧១ ចាប់ផ្តើមវាយចេញពីផ្លូវបំបែកត្រើង (មណ្ឌលព្យាបាលរោគឃ្លង់) ក្នុងភូមិខែលជ័យ(ឃុំអូរស្វាយ ស្រុកកំពង់សៀម ខេត្តកំពង់ចាម) ឆ្លងកាត់ស្រុកចម្ការលើ ចម្ការកៅស៊ូចម្ការអណ្តូង ទៅចាប់ដៃគ្នាជាមួយមុខព្រួញទី១ នៅទីប្រជុំជន កំពង់ថ្ម ផ្លូវជាតិលេខ៦។

ពេលចាប់ផ្តើមបើកប្រតិបត្តិការសឹកដំបូង មុខព្រួញទី១ ត្រូវចេញពីទីប្រជុំជនស្គន់តាមផ្លូវជាតិលេខ៦ វាយដណ្តើមយកបានទីប្រជុំជនតាំងគោក មកវិញ។ ក្រោយពីប្រយុទ្ធគ្នាអស់រយៈពេល៥៧ម៉ោង នៅថ្ងៃសុក្រទី២៩ ខែកញ្ញា ឆ្នាំ១៩៧០ ទាហាន លន់ នល់ បានវាយរំដោះទីប្រជុំជនតាំងគោក និងរំដោះបានប្រជាពលរដ្ឋជាច្រើនគ្រួសារមកវិញ។ ក្នុងអំឡុងពេលប្រយុទ្ធគ្នាយ៉ាងខ្លាំងនោះ ទាហាន លន់ នល់ បានរាយការណ៍ថា ពួកគេបានសម្លាប់ពួកវៀតកុង-វៀតណាមខាងជើង ជិត២០០នាក់ និងបាញ់ឱ្យរងរបួសជាច្រើននាក់ទៀត ព្រមទាំងបានរឹបអូសអាវុធយុទ្ធភណ្ឌមួយចំនួនទៀត។

ទាហាន លន់ នល់ ដាក់តាំងបង្ហាញអាវុធយុទ្ធភណ្ឌដែលវាយដណ្តើមបានពីកងទ័ពវៀតកុង នៅតាំងគោក ថ្ងៃទី២៩កញ្ញា ១៩៧០ នោះ។ រីឯមុខព្រួញទី២ ចេញពីផ្លូវបំបែកត្រើង តាមផ្លូវជាតិលេខ៧១ បានវាយរុលទៅមុខឆ្លងកាត់ឃុំបុសខ្នុរ ឃុំតាអុង ឃុំស្វាយទាប រហូតដល់ទីប្រជុំជនស្រុកចម្ការលើ ក៏ត្រូវកងឯកភាពតូចៗខ្លះនៃកងពលធំ

របត់នយោបាយ
លេខ៩ របស់កងទ័ពវៀតកុង-វៀតណាមខាងជើង វាយប្រយុទ្ធទប់ទល់ឱ្យនៅទើវត្រឹម ចម្ការកៅស៊ូចម្ការអណ្តូង មិនអាចរុលទៅមុខទៀតបាន។

នៅក្នុងអំឡុងពេលបើកប្រតិបត្តិការសឹកចេនឡាទី១នោះ កងទ័ពវៀតកុង-វៀតណាមខាងជើង មិនត្រឹមតែទប់ទល់ជាមួយទាហាន លន់ នល់ នៅផ្លូវជាតិលេខ៦នោះទេ គឺចាប់ពីថ្ងៃដែល លន់ នល់ ប្រកាសបង្កើតរបបសាធារណរដ្ឋខ្មែរថ្ងៃទី៩ ខែតុលា មក ពួកគេបានបង្កើនការវាយប្រហារទៅលើទីតាំងទាហាន លន់ នល់ នៅតាមផ្លូវជាតិលេខ៧ គឺនៅក្នុងភូមិសាស្ត្រស្រុកព្រៃឈរ ក្នុងគោលដៅវាយដណ្តើមយក ទីក្រុងកំពង់ចាម ទៀតផង។




**យុទ្ធនារីកងទ័ពប៉ារ៉ា ចូលរួមក្នុងប្រតិបត្តិការសឹកចេនឡាទី១ នៅតាំងគោក**

ជាមួយគ្នានោះ កងទ័ពវៀតកុង-វៀតណាមខាងជើង ក៏បានបើកការវាយប្រហារ កាត់ផ្តាច់ផ្លូវជាតិលេខ៤ ពីភ្នំពេញទៅក្រុងកំពង់សោម ផងដែរ។

មិនតែប៉ុណ្ណោះ នៅយប់ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧១ កងទ័ពដាក់កុង (កងកុម្ម៉ង់ដូពិសេសរបស់វៀតកុង-វៀតណាមខាងជើង) មានចំនួនប្រហែល១០០នាក់ បានលបចូលមកវាយប្រហារលើអាកាសយានដ្ឋានពោធិ៍ចិនតុង និងមូលដ្ឋានកងទ័ពអាកាសរបស់ លន់ នល់ ដែលនៅជាយទីក្រុងភ្នំពេញ ដោយបានកម្ទេចយន្តហោះស៊ីវិល

របត់នយោបាយ
និងយន្តហោះយោធាខូចខាតស្ទើរតែទាំងអស់។ នៅពេលស្ថានការណ៍សឹកកាន់តែធ្លាក់ដុនដាបទៅៗ បែបនេះ ទាហាន លន់ នល់ ជាច្រើនវរសេនាតូច ត្រូវដកពីប្រតិបត្តិការសឹកចេនឡាទី១ នៅផ្លូវជាតិលេខ៦នោះ យកទៅការពារនៅខ្សែក្រវាត់ទីក្រុងភ្នំពេញវិញ ធ្វើឱ្យប្រតិបត្តិការសឹកចេនឡាទី១ ត្រូវបរាជ័យទាំងស្រុង។ មិនតែប៉ុណ្ណោះ វរសេនីយ៍ទោ អ៊ំ សាវុធ មេបញ្ជាការកងពលតូចលេខ១ (1BIC) នៅបន្ទាយស្លឹក ជាប់របងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក៏ត្រូវក្រឡាប់រថយន្ត ស្លាប់នៅពេលប្រតិបត្តិការសឹកចេនឡាទី១ នោះថែមទៀត។

ក្រោយវរសេនីយ៍ទោ អ៊ំ សាវុធ ស្លាប់ទៅ កងពលតូចលេខ១របស់គាត់ត្រូវបានប្តូរឈ្មោះទៅជាកងពលតូចលេខ៨០ និងមានវរសេនីយ៍ឯក ហង់ យីវ ជាមេបញ្ជាការ។

ពេលនោះ រដ្ឋសភាមានគម្រោងកោះអញ្ជើញនាយឧត្តមសេនីយ៍ លន់ នល់ ក្នុងឋានៈ ជារដ្ឋមន្ត្រីការពារជាតិ ឱ្យមកបំភ្លឺនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧១ ពីបញ្ហាយុទ្ធសាស្ត្រនៃការធ្វើសង្គ្រាមទប់ទល់ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង និងចង់ដឹងពីមូលហេតុអ្វី បានជាទាហាននៃរបបសាធារណរដ្ឋខ្មែរ ចេះតែបរាជ័យនៅគ្រប់សមរភូមិ?។



**កងទ័ពរំដោះផឹកទឹកសម្បថចុះចូលជាមួយទាហាន លន់ នល់**

របត់នយោបាយ

តែយ៉ាងណា នៅខេត្តកំពង់ចាម មេបញ្ជាការកងទ័ពខ្មែរក្រហម ឈ្មោះសុខ លួន បាននាំកងទ័ពរបស់ខ្លួនចំនួន៣២១នាក់ មកចុះចូលជាមួយកងទ័ពរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ នៅថ្ងៃទី៩ខែកុម្ភៈ ឆ្នាំ១៩៧១ នៅទីប្រជុំជនព្រៃទទឹង ស្រុកព្រៃឈរ មេបញ្ជាការ ឈ្មោះសុខ លួន និងកងទ័ពរបស់ខ្លួនចំនួន៣២១នាក់ បានធ្វើសច្ចាប្រណិធាន ផឹកទឹកសម្បថថា ស្មោះត្រង់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។

ប៉ុន្តែ ចៃដន្យនៅក្នុងយប់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧១ ឧត្តមសេនីយ៍ លន់ នល់ មានគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាល ស្លាប់មួយចំហៀងខ្លួន ត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យនាទីក្រុងហូណូលូលូ សហរដ្ឋអាមេរិក អស់រយៈពេលប្រមាណ៣ខែ នៅតែមិនអាចដើរបានដូចដើមវិញ។ រហូតដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧១ ទើបនាយឧត្តមសេនីយ៍ លន់ នល់ វិលត្រឡប់ពីសហរដ្ឋអាមេរិក វិញ។




**លន់ នល់ ដាច់សរសៃឈាមក្នុងខួរក្បាល ស្លាប់មួយចំហៀងខ្លួន**

ពេលមកដល់មាតុប្រទេសភ្លាម ដោយមានឧត្តមសេនីយ៍ សក់ ស៊ុតសាខន នាយអគ្គសេនាធិការ ជាជំនួយការផង គាត់ក៏បានរៀបចំបើកប្រតិបត្តិការសឹកធំមួយទៀត ក្នុងបំណងបើកផ្លូវជាតិលេខ៦ ពីទីរួមប្រជុំជនស្គន់ ឆ្ពោះទៅទីរួមខេត្តកំពង់ធំ ឱ្យទាល់តែបាន ដោយឱ្យឈ្មោះប្រតិបត្តិការសឹកនោះថា ប្រតិបត្តិការសឹកចេនឡាទី២

របត់នយោបាយ

ដោយមានកម្លាំងទាហានសរុបជាង ១ម៉ឺននាក់ ចូលរួម និងបានតែងតាំងឧត្តមសេនីយ៍ ហ៊ូ ហង់ស៊ីន សិស្សនាយទាហានជំនាន់ទី១ មកពីប្រទេសបារាំងដែរ ជាមេបញ្ជាការ។

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧១ បញ្ជាការដ្ឋានរបស់កងទ័ពកន្សែងស ខ្មែរកម្ពុជាក្រោម (ម៉ៃហ្វក) នៅក្នុងបុរីកីឡាប៉ែកខាងជើង អគារជាឃ្លាំងគ្រាប់នៅជាន់ផ្ទាល់ដី ត្រូវឆេះ និងផ្ទុះបាក់ដួលរលំរាបដល់ដី ធ្វើឱ្យកក្រើកទីក្រុងភ្នំពេញ ។




**ទិដ្ឋភាព ផ្ទុះឃ្លាំងគ្រាប់ នៅបុរីកីឡា**

ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧១ ទាហាន លន់ នល់ ចាប់ផ្តើមបើកការវាយប្រហារដណ្តើមបានទីប្រជុំជនតាំងគោក, ទីប្រជុំជនស្រុកបារាយណ៍រហូតដល់ទីប្រជុំជនកំពង់ថ្មដោយជោគជ័យ។

នៅថ្ងៃទី២ ខែកញ្ញា កងពលតូចលេខ៥ ដែលវាយចេញពីទីរួមខេត្តកំពង់ធំ ក៏វាយដណ្តើមបានផ្លូវជាតិលេខ៦ ត្រង់ភ្នំសន្ទុក មកវិញ។ ពេលនោះ កងទ័ពវៀតកុង-វៀតណាមខាងជើង ក៏ព្យាយាមតស៊ូដណ្តើមយកភ្នំសន្ទុក វិញដែរ។ នៅថ្ងៃទី២០ ខែកញ្ញា ទាហាន លន់ នល់ បានវាយរំដោះបានទីប្រជុំជនតាំងក្រសាំង មកវិញជាបន្តទៀត។



**ទីប្រជុំជនស្គន់ នៅផ្លូវជាតិលេខ៦ ពេលបើកប្រត្តិការសឹកចេនឡាទី២**

នៅថ្ងៃទី៥ ខែតុលា ដោយសារនៅសមរភូមិភ្នំសន្ទុក កងទ័ពវៀតកុង-វៀតណាមខាងជើង បើកការវាយប្រហារតបតវិញខ្លាំងពេក អគ្គសេនាធិការដ្ឋាននៅភ្នំពេញ បានបញ្ជូនទាហានបន្ថែមចំនួន៣កងពលតូចទៀត ដើម្បីវាយកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនៅក្រាញននៀលតបតនៅលើផ្លូវជាតិលេខ៦ ត្រង់ចំណុចភ្នំសន្ទុកនោះដែរ តែវាយមិនខ្ចាត់ទាល់តែសោះ។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧១ អគ្គសេនាធិការដ្ឋាននៅភ្នំពេញ បានប្តូរយុទ្ធសាស្រ្តថ្មី ដោយដឹកជញ្ជូនទាហានកងពលតូចលេខ៨តាមឧទ្ធម្ភាគចក្រជាច្រើនគ្រឿង យកទៅដាក់នៅទិសអាគ្នេយ៍នៃភ្នំសន្ទុក ជាចំណុចខ្សោយរបស់ខ្មាំង។ ការប្រយុទ្ធគ្នាពេលនោះ មានការស្វិតស្វាញស៊ីសាច់ហុតឈាមគ្នាហូតឈានដល់មានការប្រយុទ្ធខ្លួនទល់នឹងខ្លួន ទើបទាហាន លន់ នល់ វាយរំដោះបានភ្នំសន្ទុក ទាំងស្រុង ហើយផ្លូវជាតិជាតិលេខ៦ ពីរដ្ឋធានីភ្នំពេញ ទៅទីរួមខេត្តកំពង់ធំ អាចធ្វើចរាចរណ៍ឡើងវិញបានខ្លះៗ។

ក្រោយពីទទួលជ័យជម្នះនេះ នាយឧត្តមសេនីយ៍ លន់ នល់ ក៏បានអនុញ្ញាតឱ្យរៀបចំពិធីបុណ្យរយៈពេលបីថ្ងៃបីយប់ ដើម្បីអបអរសាទរជោគជ័យនៅសមរភូមិផ្លូវជាតិ

របត់នយោបាយ
លេខ៦ នោះដែរ។ ប៉ុន្តែ នៅយប់ទី៣ នៃថ្ងៃបញ្ចប់ពិធីបុណ្យជ័យជម្នះនោះ កងពលធំលេខ៩ កងទ័ពភូមិភាគលេខ២០៥ និងកងទ័ពភូមិភាគលេខ២០៧ របស់កងទ័ពវៀតកុង-វៀតណាមខាងជើង បានរួមសហការគ្នាជាមួយកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា (ខ្មែរក្រហម) បើកការវាយប្រហារទីតាំងទាហាន លន់ នល់ ទាំងប៉ុន្មាន ដែលទើបតែដណ្តើមបាននៅតាមផ្លូវជាតិលេខ៦ ពីទីរួមប្រជុំជនជុំស្គន់ ឆ្ពោះទៅទីរួមខេត្តកំពង់ធំព្រមៗគ្នា។ កងពលធំលេខ៩ របស់វៀតកុង-វៀតណាមខាងជើង ដែលមានទីតាំងនៅចម្ការកៅស៊ូចម្ការអណ្តូង បានបើកការវាយប្រហារមកលើកងវរសេនាតូចលេខ៣៧៦ របស់ទាហាន លន់ នល់ នៅទ្រៀល ស្ថិតនៅចន្លោះទីប្រជុំជនតាំងគោក និងរំលង។ តែក្នុងរយៈពេលខ្លីប៉ុណ្ណោះ កងទ័ពវៀតកុង-វៀតណាមខាងជើង បានវាយដណ្តើមបានទីប្រជុំជនទ្រៀល ទាំងស្រុង ហើយមានតែទាហាន លន់ នល់ ២០នាក់ប៉ុណ្ណោះ ដែលអាចរត់រួច មកដល់ទីតាំងរបស់ពួកគេនៅទីប្រជុំជនស្រុកបារាយណ៍។

ពេលនោះដែរ នៅទីប្រជុំជនរំលង កងទ័ពវៀតកុង-វៀតណាមខាងជើង ក៏បានធ្វើការឡោមព័ទ្ធទាហាននៃកងវរសេនាតូចលេខ១៤ ដែលឈរជើងការពារនៅស្ពានដែក និងទីបញ្ជាការកងពលតូចលេខ៤៦ ដោយមានកងកាំភ្លើងធំ១០៥មិល្លីម៉ែត្រ មួយកងតូចផង។ នៅយប់ថ្ងៃទី២៨ ខែតុលា ទីតាំងទាហាន លន់ នល់ នៅភូមិដំរីស្លាប់ ឃុំស្រឡៅ ទទួលរងនូវការវាយប្រហារដោយគ្រាប់បែកគីមី (Gaz Shells) របស់កងទ័ពវៀតកុង-វៀតណាមខាងជើង ទាហាន លន់ នល់ ត្រូវបង្ខំចិត្តដកថយទៅនៅភូមិគ្រើល ជាទីបញ្ជាការរបស់វរសេនាតូចលេខ១១៨ និងកងរសេនាតូចលេខ២១១។ ប៉ុន្តែ នៅថ្ងៃទី២៩ ខែតុលា កងទ័ពវៀតកុង-វៀតណាមខាងជើង ក៏បានតាមវាយប្រហារទៅលើទាហាន លន់ នល់ ដែលដកថយទៅនៅភូមិគ្រើល នោះបន្តទៀត ធ្វើឱ្យពួកគេបង្ខំចិត្តដកថយ មកនៅទីរួមស្រុកតាំងគោក ជាបន្តទៀត។ រយៈពេលតែ២ថ្ងៃប៉ុណ្ណោះ ទាហាន លន់ នល់ ត្រូវបាត់បង់ទីតាំងសំខាន់ៗ ២កន្លែង គឺទីតាំងដំរីស្លាប់ និងទីតាំងគ្រើល។




**ទាហាន លន់ នល់ ពេលបើកប្រតិការសឹកចេនឡាទី២**

ប្រឈមមុខនឹងការបរាជ័យដ៏អាម៉ាស់នេះ ឧត្តមសេនីយ៍ ហ៊ូ ហង់ស៊ីន មេបញ្ជាការប្រតិបត្តិការសឹកចេនឡាទី២ បានរៀបចំយុទ្ធសាស្ត្រថ្មី ដោយបានបញ្ជាឱ្យកងពលតូចលេខ៦១ និងកងវរសេនាតូចលេខ៤២៤ នៃកងពលតូចលេខ៦២ ដែលឈរជើងនៅភូមិគិរីអណ្តែត ចេញមកវាយកងទ័ពវៀតកុង-វៀតណាមខាងជើង ដើម្បីដណ្តើមយកទីតាំងនៅភូមិទ្រៀល នោះមកវិញ ហើយបញ្ជាឱ្យកងពលតូចលេខ២២២ និងវរសេនាតូចលេខ៣៧៧ មកជួយការពារនៅទីប្រជុំជនតាំងគោក ផងដែរ។

រយៈពេលតែ៤ថ្ងៃប៉ុណ្ណោះ គឺពីថ្ងៃទី២៨ដល់ថ្ងៃទី៣១ ខែតុលា ទាហាន លន់ នល់ ដែលបើកប្រតិបត្តិការចេនឡាទី២ ត្រូវស្លាប់ប្រមាណ៤០០នាក់ គឺក្នុងមួយថ្ងៃៗត្រូវស្លាប់ប្រមាណ១០០នាក់។ ចំណែកអ្នករងរបួសរាប់រយនាក់ទៀត ត្រូវបានឧទ្ធម្ភាគចក្រមកដឹកជញ្ជូនទៅកាន់មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ មិនទាន់ ក៏ត្រូវបាត់បង់ជីវិតជាបន្តបន្ទាប់។

របត់នយោបាយ

ដើមខែវិច្ឆិកា ឆ្នាំ១៩៧១ នៅសមរភូមិផ្លូវជាតិលេខ៦ ពីទីប្រជុំជនស្គន់ ទៅទីប្រជុំជនកំពង់ថ្ម ទីតាំងទាហាន លន់ នល់ ទាំងប៉ុន្មាន ត្រូវកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរក្រហម ឡោមព័ទ្ធទាំងអស់ ហើយមានភ្លៀងធ្លាក់ច្រើនផង ធ្វើឱ្យកងទ័ពអាកាសនៅទីក្រុងភ្នំពេញ មានការលំបាកមកជួយធ្វើអន្តរាគមន៍ បណ្ដាលឱ្យដាច់ស្បៀង និងគ្រាប់រំសេវ។ ពួកទាហាន លន់ នល់ ដែលឈរជើងនៅទីប្រជុំជនរំលង និងទ្រៀល មិនអាចស៊ូទ្រាំបានតទៀត ក៏បង្ខំចិត្តទម្លាក់អាវុធចុះចាញ់។

កងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរក្រហម ក៏បានបញ្ជាឱ្យពួកទាហាន លន់ នល់ ដែលទម្លាក់អាវុធចុះចាញ់នោះ បន្លំធ្វើជាសុំអន្តរាគមន៍ពីកងទ័ពអាកាសនៅភ្នំពេញ មកទម្លាក់គ្រាប់បែកលើទីតាំងទាហាន លន់ នល់ គ្នាឯង បណ្ដាលឱ្យស្លាប់ជាច្រើននាក់ទៀត។

ដើម្បីដណ្ដើមទីតាំងរបស់ខ្លួនមកវិញ អគ្គសេនាធិការដ្ឋាននៅទីក្រុងភ្នំពេញ បានបន្ថែមកម្លាំងថ្មើរជើង ដោយមានជំនួយពីកងទ័ពអាកាស ផងដែរ។ តែដោយសារកាំភ្លើងធំរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបាញ់ចេញពីចម្ការកៅស៊ូចម្ការអណ្ដូង ច្រើនពេក ទាហាន លន់ នល់ គ្មានលទ្ធភាពវាយដណ្ដើមយកទីតាំងរបស់ខ្លួនណាមួយបានមកវិញឡើយ។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧១ យន្តហោះបេ៥២ (B-52) របស់កងទ័ពអាកាសអាមេរិក បានចូលមកធ្វើអន្តរាគមន៍ ជួយទម្លាក់គ្រាប់បែកលើទីតាំងកងកាំភ្លើងធំរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង នៅចម្ការកៅស៊ូចម្ការអណ្ដូង ដែរ ក៏នៅតែមិនអាចទប់ទល់បាន។

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧១ កងទ័ពវៀតកុង-វៀតណាមខាងជើង បានប្រើកាំភ្លើងប្លោងទំហំ៥៧ និង៧៥មិល្លីម៉ែត្រ និងកាំភ្លើងអ៊ែរប៉េដេ (RPD-2) បាញ់ទៅលើរថក្រោះទាហាន លន់ នល់ វាយដណ្ដើមបានទីតាំងនៅភូមិបាខម (ឃុំសំពងជ័យ) ដែលនៅជិតបង្កើយនឹងទីប្រជុំជនស្គន់។

នៅទីបំផុត ទីប្រជុំជនស្គន់ ដែលជាទីបញ្ជាការរបស់ប្រតិបត្តិការសឹកចេនឡាទី២

របត់នយោបាយ

ត្រូវកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរក្រហមឡោមព័ទ្ធ និងវាយដណ្តើមបានទៀត។ អង្គភាពទាហាន លន់ នល់ ខ្លះគ្មានជម្រើសអ្វីក្រៅពីទម្លាក់អាវុធចុះចាញ់ និងអង្គភាពខ្លះទៀតតស៊ូវាយបើកផ្លូវឈាម ប្តូរស្លាប់រស់ ដើម្បីរត់ទៅចូលក្នុងទឹកដីដែលពួកខ្លួនកាន់កាប់វិញ។

បរាជ័យនៃប្រតិបត្តិការសឹកចេនឡាទី២ ធ្វើឱ្យទាហាន លន់ នល់ ចំនួន១០កងវរសេនាតូច និងសម្ភារសឹក១ភាគ៣ នៃសម្ភារសឹករបស់របបសាធារណរដ្ឋខ្មែរទាំងមូលត្រូវបាត់បង់។ ទាហាន លន់ នល់ ដែលត្រូវស្លាប់ និងបាត់ខ្លួនក្នុងប្រតិបត្តិការសឹកចេនឡាទី២ មានចំនួនប្រមាណ១២០០នាក់។ ចំណែកប្រជាជនដែលរស់នៅក្នុងភូមិសាស្រ្តវាយប្រយុទ្ធគ្នានោះ ក៏ត្រូវស្លាប់ច្រើនណាស់ដែរ តែគេមិនដឹងថា មានចំនួនពិតប្រាកដប៉ុន្មាន។



**ប្រតិបត្តិការសឹកចេនឡាទី២ នៅផ្លូវជាតិលេខ៦ កងទ័ពវៀតកុងផ្តាច់ស្ពានគ្រស់ ជាលើកទី២**

បន្ទាប់ពីបរាជ័យប្រតិបត្តិការសឹកចេនឡាទី២ នោះមក ដោយពិនិត្យឃើញថា នាយឧត្តមសេនីយ៍ លន់ នល់ នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ មានជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ស្លាប់មួយចំហៀងខ្លួន តាំងពីខែកុម្ភៈ ឆ្នាំ១៩៧១ មក ដូច្នេះគាត់អាចបាត់បង់ប្រាជ្ញាស្មារតី និងសមត្ថភាពប្រហែលជាង៥០ភាគរយ ទៅហើយនោះ ទ្រង់ សិរិមតៈ បានសុំឱ្យការិយាល័យស្ថានទូតអាមេរិក ប្រចាំប្រទេសកម្ពុជា ឈ្មោះ អេម៉ូរី ស្វាំង

របត់នយោបាយ

(Emory Swank) ជួបពិភាក្សាគ្នាជាមួយ លន់ នល់ ដើម្បីជ្រើសរើសនាយទាហានជាន់ខ្ពស់មានសមត្ថភាពណាម្នាក់ផ្សេងទៀត មកតែងតាំងជានាយអគ្គសេនាធិការកងយោធពលខេមរជាតិ ជំនួសឧត្តមសេនីយ៍ សក់ ស៊ុតសាខន ដើម្បីស្តារស្ថានការណ៍សឹកឡើងវិញ។

លន់ នល់ ចូលបម្រើការងារដំបូង នៅក្នុងក្របខ័ណ្ឌស៊ីវិលជាចៅក្រម។ បន្ទាប់មក គាត់បានឡើងជាចៅហ្វាយស្រុក និងចៅហ្វាយខេត្តជាបន្តបន្ទាប់។ តែនៅពេលសម្តេចសីហនុ ធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង ពីឆ្នាំ១៩៥២ មក គាត់បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ព និងបានទទួលឋានន្តរសក្តិជាវរសេនីយ៍ត្រី។



**ភារធារីអាមេរិក អេម៉ូរី ស្វាំង ជាមួយ លន់ នល់ និងចេង ហេង នៅចម្ការមន**



**ឧត្តមសេនីយ៍សុស្តែន**

ក្រោយប្រទេសកម្ពុជា បានទទួលឯករាជ្យមក លន់ នល់ ត្រូវបានតែងតាំង ជានាយអគ្គសេនាធិការកងទ័ពនៅឆ្នាំ១៩៥៥ ហើយក្រោយមក ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជានាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នៅឆ្នាំ១៩៦០។ តែយ៉ាងណា ក៏គាត់មិនបានចូលសិក្សានៅក្នុងសាលាយោធាម្តងណាឡើយ។ ពេលនោះ គាត់បានយកសុស្តែន ហ្វែរណង់ដេស ដែលជាសិស្សនាយទាហានជំនាន់ទី២ ធ្លាប់ទៅរៀននៅសាលាយោធានៅប្រទេសបារាំង មកធ្វើជាជំនួយការរបស់គាត់។

នៅពេលភារធារីស្ថានទូតអាមេរិក អេម៉ូរី ស្វាំង ( Emory Swank) ស្នើសុំឱ្យតែងតាំងនាយទាហានជាន់ខ្ពស់ណាម្នាក់ មានសមត្ថភាពអាចឡើងជានាយអគ្គសេនា

របត់នយោបាយ

ធិការកងយោធពលខេមរដាតិ ជំនួសឧត្តមសេនីយ៍ សក់ ស៊ុតសាខន នោះ លន់ នល់ ក៏បានយល់ព្រមដែរ ហើយបានជ្រើសរើសបេក្ខជនពីរនាក់ គឺឧត្តមសេនីយ៍ ឋាប្បនា ធិន្ន ជាសិស្សនាយទាហានជំនាន់ទី១ នៅប្រទេសបារាំង និងឧត្តមសេនីយ៍ សុស្តែន ហ្វែរណង់ដេស ជាសិស្សនាយទាហានជំនាន់ទី២ នៅប្រទេសបារាំង ដើម្បីតែងតាំងម្នាក់ជានាយអគ្គសេនាធិការកងយោធពលខេមរដាតិ។

ក្រោយពីបានពិនិត្យពិចារណាពីគុណសម្បត្តិ និងសមត្ថភាពយុទ្ធសាស្ត្របច្ចេកទេសយោធាមក ភារធារីអាមេរិក និងលន់ នល់ បានឯកភាពគ្នាតែងតាំងឧត្តមសេនីយ៍ សុស្តែន ជានាយអគ្គសេនាធិការកងយោធពលខេមរដាតិ ចាប់ពីពេលនោះមក។



**ទាហានប៉ារ៉ា ក្នុងប្រតិបត្តិការសឹករាហ៊ូ**

ក្រៅពីប្រតិបត្តិការសឹកចេនឡាទី១ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ អគ្គសេនាធិការកងទ័ពនៃរបបសាធារណរដ្ឋខ្មែរ ក៏បានបើកប្រតិបត្តិការសឹកមួយទៀត ឈ្មោះប្រតិបត្តិការសឹករាហ៊ូ ដើម្បីបោសសម្អាតកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរក្រហម ដែលចូលមករាតត្បាតកាន់កាប់នៅឃុំព្រៃកតាមាក់, ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល រហូតដល់កំពង់ចម្លងកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែងផងដែរ។

នៅចុងខែកក្កដា ឆ្នាំ១៩៧១ ទាហានសាធារណរដ្ឋខ្មែរ បានបើកប្រតិបត្តិការសឹកមួយទៀត ហៅថាប្រតិបត្តិការសឹកកង្រី នៅត្រង់ចំណុចប្រសព្វខេត្ត៣ គឺខេត្តកំពង់ឆ្នាំង

របត់នយោបាយ

ខេត្តកំពង់ធំ និងខេត្តកំពង់ចាម ដើម្បីកាត់ផ្តាច់ផ្លូវដឹកជញ្ជូនចុះឡើងរបស់ខ្មែរក្រហម និងកងទ័ពវៀតកុង-វៀតណាមខាងជើង ពីស្រុកចម្ការលើ ទៅភ្នំគិរីរម្យ និងបើកផ្លូវជាតិលេខ៥ ផងដែរ។

ប្រតិបត្តិការសឹកកន្រ្តើនេះ មានកងទ័ពជើងទឹក និងជើងអាកាសខ្មែរ ព្រមទាំងកងទ័ពវៀតណាមខាងត្បូង ជាសម្ព័ន្ធមិត្តចូលរួមដែរ ដោយមានការប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ, ស៊ីសាច់ហុតឈាមបំផុត នៅត្រង់ភូមិព្រៃគ្រី ភូមិរពេត និងភូមិព្រីងជ្រុំ តាមបណ្តោយផ្លូវជាតិលេខ៥ ក្នុងស្រុកកំពង់ត្រឡាច។ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧១ ទាហានសាធារណរដ្ឋខ្មែរ ក៏បានបើកប្រតិបត្តិការសឹកអគ្គីនេត្រមហាបដិវត្តន៍ ដើម្បីបើកផ្លូវជាតិលេខ៣ និងវាយដណ្តើមយកភូមិជាច្រើន ដែលនៅតាមបណ្តោយផ្លូវជាតិលេខ៣ នោះមកកាន់កាប់វិញ។

ដោយឡែកផ្លូវជាតិលេខ៤ ដែលជាសរសៃឈាមដឹកជញ្ជូនសំខាន់បំផុត របស់របបសាធារណរដ្ឋខ្មែរ ពីកំពង់ផែក្រុងកំពង់សោម មកកាន់ទីក្រុងភ្នំពេញ ក៏មានការបើកប្រតិបត្តិការសឹកជាញឹកញាប់ដែរ។ នៅចុងឆ្នាំ១៩៧០ ទាហានរបបសាធារណរដ្ឋខ្មែរ ដែលមានទីតាំងនៅទីប្រជុំជនវាលរេញ បានបើកប្រតិបត្តិការសឹក បោសសម្អាតកងទ័ពវៀតកុង-វៀតណាមខាងជើង នៅជិតកំពង់សីលា ក្រោមបញ្ជាការរបស់វរសេនីយ៍ការ ប៊ុននី។ ប៉ុន្តែ ត្រូវកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលមានបទពិសោធ និងអាវុធទំនើបៗនោះ វាយឱ្យបាក់ទ័ពរត់ថយក្រោយវិញអស់។

បន្ទាប់មក ទាហានសាធារណរដ្ឋខ្មែរ ចំនួន៥កងវរសេនាតូច ក្រោមបញ្ជាការរបស់វរសេនីយ៍ ថាច់ រ៉េង បានបើកប្រតិបត្តិការសឹកចេញពីមូលដ្ឋានកងទ័ពជើងទឹកនៅរាម វាយបើកផ្លូវជាតិលេខ៤ ឡើងទៅចាប់ដៃគ្នាជាមួយ ទាហានសាធារណរដ្ឋខ្មែរ នៅបន្ទាយកំពង់សីលា ដែលស្ថិតនៅក្រោមបញ្ជាការរបស់វរសេនីយ៍ អ៊ុង ញ៉ច។ ប៉ុន្តែក្រោយមកទៀត ទាហានសាធារណរដ្ឋខ្មែរ នៅបន្ទាយកំពង់សីលានោះ ត្រូវពួកខ្មែរក្រហមនាំគ្នាឡោមព័ទ្ធជុំជិតអស់ ហើយពុំមានអង្គភាពណាផ្សេងទៀតជួយធ្វើអន្តរាគមន៍បានឡើយ ព្រោះទីតាំងនោះស្ថិតនៅឆ្ងាយដាច់ពីគេពេក។

របត់នយោបាយ



**កងទ័ព និងឧទ្ធម្ភាគចក្រវៀតណាមខាងត្បូង នៅផ្លូវជាតិលេខ៤**

ពេលនោះ ទាហាននៅបន្ទាយកំពង់សីលា ត្រូវដាច់ស្បៀងរកអ្វីទទួលទានមិនបាន ព្រោះត្រូវស្ថិតនៅតែក្នុងបន្ទាយ ដែលរុំព័ទ្ធដោយរបងបន្លាលួសជាច្រើនជាន់។ ឯការទម្លាក់ស្បៀងតាមយន្តហោះ ក៏មានការលំបាកខ្លាំងដែរ ព្រោះបើយន្តហោះ ហោះទាបពេកត្រូវកងទ័ពខ្មែរក្រហម បាញ់រះ អាចគ្រោះថ្នាក់ជាមិនខាន។ ដូច្នេះយន្តហោះដែលត្រូវទៅទម្លាក់ស្បៀងឱ្យទាហាន នៅបន្ទាយកំពង់សីលា ត្រូវហោះខ្ពស់ ទើបទម្លាក់ស្បៀងនោះ។ ប៉ុន្តែការទម្លាក់ស្បៀងខ្ពស់ពេកនោះ ត្រូវខ្យល់បក់ផាត់ឆត្រយោងស្បៀងឱ្យធ្លាក់ទៅខាងក្រៅបន្ទាយ ដូចទម្លាក់ស្បៀងឱ្យកងទ័ពខ្មែរក្រហម ដែលកំពុងឡោមព័ទ្ធជុំវិញបន្ទាយនោះទៅវិញ។

កងទ័ពខ្មែរក្រហម បានឡោមព័ទ្ធបន្ទាយកំពង់សីលា ជុំវិញក៏ពិតមែន តែក៏មិនអាចវាយចូលទៅក្នុងបន្ទាយនោះបានដែរ ដោយបានត្រឹមតែធ្វើការឡោមព័ទ្ធប៉ុណ្ណោះ។ ឯទាហានដែលនៅក្នុងបន្ទាយនោះ ក៏មិនព្រមលើកទង់ស ចុះចាញ់ពួកខ្មែរក្រហម ដោយងាយៗនោះដែរ។

សម័យនោះ ក៏ល្បីថា ទាហាននៅបន្ទាយកំពង់សីលានោះ ស៊ីសាច់សាកសពគ្នាឯង ដោយសារតែការស្រេកឃ្លាន ដាច់ស្បៀងខ្លាំងពេក។

រហូតដល់ឆ្នាំ១៩៧៤ អគ្គសេនាធិការកងទ័ពនៅក្រុងភ្នំពេញ បានដាក់បទបញ្ជាឱ្យទាហាននៅបន្ទាយកំពង់សីលានោះ វាយបើកផ្លូវឈាមរំដោះខ្លួនចេញពីបន្ទាយ ទោះបី

ស្លាប់ប៉ុន្មាន រស់ប៉ុន្មានក៏ដោយ ព្រោះបើស៊ូទ្រាំនៅតែក្នុងបន្ទាយតទៅទៀត ពិតជាត្រូវស្លាប់ដោយដាច់ពោះទាំងអស់គ្នាជាមិនខាន។

ដោយមានជំនួយពីកងឧទ្ធម្ភាគចក្រផងដែរ ទាហាននៅបន្ទាយកំពង់សីលា បានសម្រុកវាយបើកផ្លូវឈាម ដោះខ្លួនចេញពីបន្ទាយ ដោយត្រូវប្រយុទ្ធតបតជាមួយកងទ័ពខ្មែរក្រហម តាមបណ្ដោយផ្លូវជាតិលេខ៤ បណ្ដាលឱ្យស្លាប់អស់ជាច្រើនទម្រាំមកដល់ទីរួមខេត្តកំពង់ស្ពឺ។

ពេលនោះ ទ្រង់នរោត្ដម ចន្ទរង្សី អតីតមេខ្មែរសេរីបានឡើងឋានៈ ជាមេបញ្ជាការយោធភូមិភាគទី២ និងជាអភិបាលខេត្តកំពង់ស្ពឺ ហើយក៏ជាមេបញ្ជាការកងពលថ្មើរជើងលេខ១៣ ផងដែ ចេះប្រើសង្គ្រាមចិត្តសាស្ត្រធ្វើឱ្យប្រជាពលរដ្ឋ នៅក្នុងខេត្តកំពង់ស្ពឺ ស្រឡាញ់រាប់អានពលទាហានរបស់ទ្រង់ មិនដូចនៅតាមខេត្ត និងកងពលមួយចំនួនទៀត ឆ្លៀតឱកាសយកទ្រព្យសម្បត្តិ និងធ្វើឱ្យប្រជាពលរដ្ឋមានការឈឺចាប់ឡើយ។

---

# ៧.២៣ សុស្តែន មេបញ្ជាការយោធភូមិភាគ២ ឡើងជានាយអគ្គសេនាធិការ




**ឧត្តមសេនីយ៍ត្រី សុស្តែន**

ក្នុងឆ្នាំ១៩៩៧ ពេលធ្វើដំណើរពីប្រទេសបារាំង ទៅចូលរួមពិធីបុណ្យសពប្អូន នៅទីក្រុងឡុងប៊ិច សហរដ្ឋអាមេរិក ក្នុងបទសម្ភាសន៍ ជាមួយទូរទស្សន៍ខ្មែរ អេប៊ីស៊ី (Khmer ABC TV) សុស្តែន ហៅ្វរណង់ដេស វ័យ៧៤ឆ្នាំ អតីតនាយអគ្គសេនាធិការ កងទ័ពរបបសាធារណរដ្ឋខ្មែរ ដែលបានទៅរស់នៅប្រទេសបារាំង តាំងពីដើមឆ្នាំ១៩៧៥ នោះបានថ្លែងបញ្ជាក់ថា ការពិតរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មិនមែនជា ល្បិចនយោបាយរបស់សម្តេចសីហនុ និងលន់ នល់ ដើម្បីដេញកងទ័ពយួនវៀតកុង ដូចមជ្ឈដ្ឋានមួយចំនួនបានលើកឡើងនោះទេ។ អ្នកនិយាយយ៉ាងហ្នឹង គឺអ្នកនោះមិន ដែលធ្លាប់បម្រើសម្តេចសីហនុ ឬមិនដែលស្គាល់សម្តេចសីហនុ ថាយ៉ាងណាទេ?។ សម្តេចសីហនុ មិនដែលទុកចិត្តអ្នកណាទេ សូម្បីតែសម្តេច ប៉ែន នុត និងកូនៗលោក

របត់នយោបាយ
ក៏លោកអត់ទុកចិត្តផង លោកមិនទុកចិត្តអ្នកណាទាំងអស់ លោកទុកចិត្ត និងសង្ឃឹមតែលើបរទេស បើមិនយួន ក៏ចិន...។ អ៊ីចឹងបានន័យថា រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មិនមែនជាល្បិចនយោបាយរបស់សម្តេចសីហនុ និងលន់ នល់ ដើម្បីដេញកងទ័ពយួនវៀតកុង ឱ្យចាកចេញពីទឹកដីខ្មែរនោះទេ។ មិនមែនដាច់ខាត រហូតដល់សព្វថ្ងៃសម្តេចនៅតែខឹង និងជេរ លន់ នល់ និងសិរីមតៈទៀត ដូចអស់លោកធ្លាប់បានឮហើយ។ គ្មានការត្រូវរ៉ូវគ្នារវាងសម្តេចសីហនុ និងលន់ នល់ ទាល់តែសោះ គឺគ្មានទេ។ ការទម្លាក់សម្តេចសីហនុ មកពីព្រះអង្គឯង មិនព្រមវិលត្រឡប់ចូលក្នុងប្រទេសវិញ ដើម្បីជួយរៀបចំឱ្យមានការរៀបរយឡើងវិញ នៅពេលដែលប្រទេសកំពុងមានចលាចល។

រដ្ឋសភាមិនបានរៀបចំគម្រោង ធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គទាល់តែសោះ ព្រោះសម្តេចព្រះមហាក្សត្រិយានី បានហៅខ្ញុំទៅជួបលើកចុងក្រោយបំផុត ព្រះអង្គបានសួរខ្ញុំថា៖ “ មើល! សហជីវិន សុស្តែន លោកមានដឹងថា គេមានគម្រោងការចង់ទៅចាប់បុត្រា សីហនុទេ? ខ្ញុំក៏ទូលព្រះអង្គវិញថា ក្រាបទូល គឺអត់មាននរណាចង់ទៅចាប់សម្តេចទេ។ សព្វថ្ងៃនេះ ក្រសួងសន្តិសុខជាតិចាប់អារម្មណ៍ធំបំផុត គឺការបះបោររបស់ប្រជារាស្ត្រនៅទល់ដែន និងការបះបោររំដើបរំជួលនៅក្រុងភ្នំពេញ ធ្វើបាតុកម្មបណ្តេញកងទ័ពយួនពួកវៀតកុង ឱ្យចេញពីទឹកដីខ្មែរតែប៉ុណ្ណោះ ”។ សណ្តាប់ហើយ សម្តេចព្រះមហាក្សត្រិយានី ទុកភារកិច្ចហ្នឹងឱ្យនាយករដ្ឋមន្ត្រី និងរដ្ឋសភា ឱ្យចាត់ចែងដើម្បីយាងសម្តេចសីហនុ ចូលមកប្រទេសវិញ តែព្រះអង្គមិនព្រមយាងមក ទាំងអស់គ្នាក៏ទាល់តម្រិះ។

ចំពោះសំណួរ ដែលបានសួរថា មុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ តើការទំនាក់ទំនងរវាងគាត់ជាមួយនឹង អ៊ំ ម៉ាន្នូរិន ជាបងថ្លៃរបស់សម្តេចសីហនុ យ៉ាងដូចម្តេចដែរ? សុស្តែន ហ្វែរណង់ដេស បានឱ្យដឹងថា៖ “ បាទ! អ៊ំ ម៉ាន្នូរិន និងខ្ញុំជាមិត្តភក្តិជិតស្និទ្ធជាទីបំផុត ជានាយទាហានរួមជំនាន់ជាមួយគ្នា ហើយស្រឡាញ់គ្នាលើសពីមិត្តភក្តិទៅទៀត គឺស្រឡាញ់រាប់អានគ្នាទុកដូចជាបងប្អូន ”។ បើចេញទៅទី

ណាមាន អ៊ំ ម៉ាន់នូរិន ទីនោះក៏មាន សុស្តែនដែរ គឺស្រឡាញ់រាប់អានគ្នាជិតស្និទ្ធណាស់។ ក្រោយ ថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា លន់ នល់ បានបញ្ជាឱ្យគេចាប់ អ៊ំ ម៉ាន់នូរិន, ហ៊ុល ឃុន, ក្រូច សម្រេច និងផេង ផាន់អ៊ី ជាដើម សុទ្ធតែត្រូវបានចោទប្រកាន់ថា៖ “ ជាអ្នកអែបអបសម្តេចសីហនុ និងព្រះបរមរាជវាំង យកទៅឃុំឃាំងនៅក្នុងគុក។ ចំណែកខ្ញុំ គេថាជាអ្នកអែបអបសម្តេចសីហនុ និងព្រះបរមរាជវាំង ក៏មិនខុសដែរ ព្រោះខ្ញុំក៏ធ្លាប់ចេញចូលព្រះបរមរាជវាំងញឹកញាប់ដែរ ប៉ុន្តែ លន់ នល់ នៅតែទុកចិត្តខ្ញុំ... ”។

ចំពោះសំណួរមួយទៀតជាពាក្យចចាមអារ៉ាម ដែលថា មុនពេលធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០នោះ ឧត្តមសេនីយ៍ លន់ នល់ ចង់ចូលទៅគាល់ព្រះមហាក្សត្រិយានី នៅក្នុងព្រះបរមរាជវាំង តែ សុស្តែន ហ្វែរណង់ដេស ប្រាប់ លន់ នល់ ថា កុំចូលក្នុងព្រះបរមរាជវាំងឱ្យសោះ បើហ៊ានចូល គឺគេចាប់ខ្លួនហើយ។ តើរឿងហ្នឹងជាការពិតទេ? សុស្តែន ហ្វែរណង់ដេស បញ្ជាក់ថា៖ “ រឿងនេះមិនពិតទាល់តែសោះ ព្រោះដូចខ្ញុំបានជម្រាបពីមុនមកហើយថា គឺ លន់ នល់ ទេ ដែលជាអ្នកប្រើខ្ញុំជារដ្ឋមន្ត្រីខាងគិញ ជាតំណាងរូបគាត់ជានាយករដ្ឋមន្ត្រី មិនមែនដោយសារ លន់ នល់ ដឹងថា ខ្ញុំជាមនុស្សជិតស្និទ្ធជាមួយនឹងព្រះបរមរាជវាំង ទើបគាត់ឱ្យខ្ញុំចូលទៅគាល់ព្រះមហាក្សត្រិយានី ដើម្បីទូលថ្វាយពីសភាពការណ៍អាក្រក់ ដែលកើតមានទាំងប៉ុន្មានឱ្យព្រះអង្គបានជ្រាបនោះទេ ”។

ចំពោះសំណួរដែលសួរថា កាលជំនាន់រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម អ្នកណាក៏ដឹងថា សុស្តែន ហ្វែរណង់ដេស ជាអ្នករាជានិយមដែរ ព្រោះជាមនុស្សជិតស្និទ្ធជាមួយសម្តេចសីហនុ និងព្រះបរមរាជវាំង?

សុស្តែន ហ្វែរណង់ដេស បានរម្លឹកថា រឿងហ្នឹងក៏មានគេច្រឡំដែរ។ ដើមឆ្នាំ១៩៦៨ ក្រោយពេលដក គូ រុន ចេញពីតំណែងរដ្ឋលេខាក្រសួងសន្តិសុខជាតិ មានមន្ត្រីជាច្រើននាំគ្នារត់ការ ចង់បានតំណែងនេះខ្លាំងណាស់ ព្រោះជាកន្លែងខ្លាញ់។ ខ្ញុំអត់ដឹងខ្លួនទេ

របត់នយោបាយ គ្រាន់តែដឹងថា គណៈរដ្ឋមន្ត្រីនឹងមានការផ្លាស់ប្តូរ។ ពេលនោះ ខ្ញុំត្រូវទៅបំពេញបេសកកម្ម៣ថ្ងៃ នៅខេត្តស្វាយរៀង ដើម្បីដឹកនាំរៀបចំកម្លាំងការពារសន្តិសុខថ្វាយសម្តេចសីហនុ មុនព្រះអង្គយាងទៅសម្ពោធសមិទ្ធផលនៅក្រុងស្វាយរៀង។



**កាំភ្លើងត្រៀមបាញ់យន្តហោះក្នុងឱកាសការពារសម្តេចសីហនុ នៅខេត្តស្វាយរៀង ឆ្នាំ១៩៦៨**

មុនពេលព្រះអង្គយាងទៅមួយថ្ងៃ ពួកមន្ត្រីកុម្មុយនិស្តធំៗជាច្រើននៅក្រុងភ្នំពេញ នាំគ្នាធ្វើដំណើរជាបន្តបន្ទាប់ ទៅសម្រាកនៅក្រុងស្វាយរៀង មួយយប់ ដើម្បីរង់ចាំទទួលស្វាគមន៍ព្រះរាជដំណើររបស់ព្រះអង្គនៅព្រឹកស្អែក។ យប់នោះ អ៊ឹង ហុងសាធ (ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកមហាផ្ទៃ សន្តិសុខ ការពារលើផ្ទៃប្រទេស ធម្មការ និងទំនាក់ទំនងជាមួយសភា) និងគូ រុន ដែលទៅរង់ចាំទទួលស្វាគមន៍ ព្រះរាជដំណើររបស់ព្រះអង្គដែរ បានមកចាប់ដៃខ្ញុំ ហើយនិយាយថា អើ! សុំសរសើរលោក សុស្តែន។ ខ្ញុំថា សរសើររឿងអីហ្នឹង? ពួកគាត់ប្រាប់ថា លោក សុស្តែនឯង បានឡើងជាកុម្មុយនិស្ត ហើយ អត់ដឹងខ្លួនទេឬ?។ ព្រឹកឡើង ពេលព្រះករុណាយាងចុះពីឧទ្ធម្ភាគចក្រ ខ្ញុំទៅថ្វាយបង្គំ ស្រាប់តែ ព្រះអង្គប្រាប់ថា ក្រោយចប់ពិធីសម្ពោធសមិទ្ធផលនៅក្រុងស្វាយរៀង នេះត្រូវត្រឡប់ទៅភ្នំពេញវិញភ្លាម ដើម្បីទទួលតំណែងជារដ្ឋលេខាក្រសួងសន្តិសុខជាតិ។

របត់នយោបាយ

ខ្ញុំគិតថា ការដែលសម្តេចតែងតាំងខ្ញុំជាមេគិញនេះ គឺទី១. មកពីខ្ញុំជាមនុស្សជំនិតជាមួយព្រះអង្គម្នាក់ដែរ ហើយមានកេរ្តិ៍ឈ្មោះជាអ្នកតស៊ូការពារទល់ដែនគ្រប់កន្លែងទាំងអស់។ ទី២. មកពីព្រះអង្គជឿមកលើកេរ្តិ៍ឈ្មោះ និងកិត្តិនាមរបស់ខ្ញុំ ព្រមទាំងឪពុកខ្ញុំដែលធ្លាប់បានបម្រើក្នុងព្រះបរមរាជវាំង ជាចាងហ្វាងទទួលបណ្តឹងពីប្រជារាស្ត្រយកមកថ្វាយ ដើម្បីឱ្យព្រះអង្គបើកពិធីជំនុំជម្រះរកយុត្តិធម៌ និងធ្លាប់ធ្វើតំណាងរាស្ត្រព្រមទាំងធ្វើកុង្សីយ៍ផងដែរ។ កេរ្តិ៍ឈ្មោះពូជពង្សខ្ញុំ នៅក្នុងព្រះបរមរាជវាំង នរណាក៏ដឹងដែរ គឺបម្រើព្រះអង្គ (សម្តេចសីហនុ) ដោយទៀងត្រង់ជាទីបំផុត...។

មកដល់ត្រឹមនេះ អ្នកសម្ភាសបាននិយាយឱគាត់ថា ដល់ពេលធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ លោកក៏ទៀងត្រង់ជាទីបំផុតជាមួយឧត្តមសេនីយ៍ នល់ នល់ ដែរ?។ សុស្តែន ហ្វែរណង់ដេស តបវិញភ្លាមថា ខ្ញុំទៀងត្រង់ទាំងអស់ឱ្យតែអ្នកនោះជាចៅហ្វាយខ្ញុំ។ ដោយសារខ្ញុំបានរៀនសូត្រខាងទ្រឹស្តីវិជ្ជាសឹក សំខាន់បំផុតគេបង្រៀនឱ្យចេះគោរពចៅហ្វាយនាយ ឱ្យចេះធ្វើតាមបញ្ជារបស់ចៅហ្វាយនាយ។ តាំងពីដើមមកខ្ញុំប្រកាន់យកគោលការណ៍ និងទ្រឹស្តីនេះមកអនុវត្ត រហូតដល់បានឡើងបុណ្យសក្តិជាបន្តបន្ទាប់។

ដោយឡែក ចំពោះប្រតិបត្តិការសឹកចេនឡាទី១ និងទី២ នៅផ្លូវជាតិលេខ៦នាឆ្នាំ១៩៧០ និងឆ្នាំ១៩៧១ សុស្តែន ហ្វែរណង់ដេស បានឱ្យដឹងថា កាលនោះឧត្តមសេនីយ៍ សក់ ស៊ុតសាខន ជានាយអគ្គសេនាធិការកងយោធពលខេមរជាតិ ចំណែកគាត់នៅជាមេបញ្ជាការយោធភូមិភាគទី២។ ការបើកប្រតិបត្តិការសឹកចេនឡាទី១ និងទី២នៅផ្លូវជាតិលេខ៦នោះ ទាហានសាធារណរដ្ឋចំនួន២កងពល មានគ្នា១៦០០០នាក់ត្រូវពួកយួនវៀតកុង មកពីថ្មពេជ្រ មកពីចម្ការកៅស៊ូចម្ការអណ្តូង វាយឱ្យបាក់ទ័ពបាត់បង់ទាំងកាំភ្លើងធំ និងរថក្រោះជាច្រើនគ្រឿង។ នេះគឺជាការចាញ់សង្គ្រាមមួយយ៉ាងអាម៉ាស់បំផុតរបស់អាមេរិកាំង ផងដែរ។ ទីប្រឹក្សាយោធាអាមេរិកាំង មកតវ៉ាជាមួយ លន់ នល់ ថា លោកឯងឱ្យអគ្គសេនាធិការដឹកនាំកងទ័ពរបៀបនេះធ្វើឱ្យខូច

ខាតផលប្រយោជន៍ប្រទេសជាតិរបស់លោកឯងសម្បើមណាស់ ដូច្នេះត្រូវតែដក សក់-ស៊ុតសាខន ចេញពីតំណែងនាយអគ្គសេនាធិការ។ តាមវិន័យសឹកឧត្តមសេនីយ៍ សក់-ស៊ុតសាខន ត្រូវមានទោស។ តែ លន់ នល់ អត់ឱនទោស ហើយបំបិទរឿងបរាជ័យនេះចោល ដោយគ្រាន់តែដកឧត្តមសេនីយ៍ សក់ ស៊ុតសាខន ចេញពីតំណែងនាយអគ្គសេនាធិការ ហើយរកឧត្តមសេនីយ៍ណាម្នាក់ទៀតមកដាក់ជំនួសប៉ុណ្ណោះ។ ទីប្រឹក្សាយោធាអាមេរិក និងលន់ នល់ ផ្គូផ្គងចុះឡើងៗ ក៏បានសម្រេចជ្រើសរើសគាត់ដែលពេលនោះជាមេបញ្ជាការយោធភូមិភាគទី២ ដែលមានបទពិសោធ និងសមត្ថភាពក្នុងការដឹកនាំបញ្ជាកងទ័ព ទទួលបានជោគជ័យជាបន្តបន្ទាប់ ឱ្យឡើងជានាយអគ្គសេនាធិការ។




## សុស្តែន ចុះបញ្ជាតាមសមរភូមិ

សុស្តែន ហ្វែរណង់ដេស បានអះអាងថា គាត់មានសមត្ថភាពក្នុងការដឹកនាំបញ្ជាកងទ័ព ដោយសារគាត់បានរៀនសូត្រ ចេញពីសាលាចម្បាំងបារាំង ហើយបានដកស្រង់ពិសោធន៍ពីពួកមេទ័ពបារាំង កាលធ្វើសង្គ្រាមជាមួយពួកអាល្លឺម៉ង់ និងមើលសៀវភៅចិន ដែលនិយាយពីមេទ័ពចិន ដឹកនាំកងទ័ពទាំងម៉ឺនៗ ទាំងសែនៗ ពេលចេញទៅច្បាំងម្តងៗ។ កាល សក់ ស៊ុតសាខន នៅជានាយអគ្គសេនាធិការ នៅសមរភូមិភ្នំប្រសិទ្ធ៍ សក់ ស៊ុតសាខន យកទាហានទៅដាក់លើកំពូលភ្នំ។មិនយូរប៉ុន្មាន ពួកវៀតកុងលើកទ័ពមកវាយយកភ្នំប្រសិទ្ធ៍បានទាំងស្រុង។ ពីលើកំពូលភ្នំ ពួកវាអាចមើលឃើញភូមិសាស្ត្រទីក្រុងភ្នំពេញ វាក៏បាញ់កាំភ្លើងធ្លោង (១២២ម.ម) ចូលទីក្រុងភ្នំពេញ ជារៀងរាល់ថ្ងៃ។ តែក្រោយពីគាត់ត្រូវបានតែងតាំង ជានាយអគ្គសេនាធិការភ្លាម គាត់

របត់នយោបាយ
បានទាក់ទងទីប្រឹក្សាអាមេរិក សុំអន្តរាគមន៍ជើងអាកាស ដើម្បីវាយយកភ្នំប្រសិទ្ធិ៍ មកវិញ។ ដំបូង គាត់បញ្ជាឱ្យកងពលវាយដេញពួកវាដែលនៅតាមជើងភ្នំ ឱ្យរត់ឡើងលើកំពូលភ្នំទៅជុំគ្នាទាំងអស់ រួចហើយ ហៅយន្តហោះអាមេរិក ឱ្យមកទម្លាក់គ្រាប់បែកពីលើ ដោយបើកផ្លូវមួយចំហៀងឱ្យពួកវារត់ចុះមកក្រោម និងត្រៀមកម្លាំងចាំបាញ់កម្ទេចពួកវា អស់ជាងមួយកងពល។

សុស្តែនអះអាងបន្តថា កាលនៅជាមេបញ្ជាការយោធភូមិភាគទី២ ក្រោយពួកវៀតកុង និងពួកខ្មែរក្រហម វាយដណ្តើមបានទីរួមខេត្តកំពត បានតែ៣ថ្ងៃ គាត់ក៏បានបញ្ជាទាហាន ឱ្យវាយដណ្តើមទីរួមខេត្តកំពត បានមកវិញតែក្នុងរយៈពេលតែ២៤ម៉ោងប៉ុណ្ណោះ។

ចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧១ នាយអគ្គសេនាធិការកងយោធពលខេមរជាតិ បានបញ្ជាឱ្យបើកប្រតិបត្តិការសឹកមួយឱ្យឈ្មោះថា ប្រតិបត្តិការសឹកអគ្គីនេត្រមហាបដិវត្ត ដើម្បីបើកផ្លូវជាតិលេខ៣ ពីទីប្រជុំជនត្រាំខ្នារ ទៅកាន់ទីប្រជុំជនអង្គតាសោម និងភូមិសាស្រ្តមួយចំនួនទៀត ដែលនៅតាមកំណាត់ផ្លូវជាតិលេខ៤១។ អង្គភាពដែលត្រូវចូលរួម ក្នុងប្រតិបត្តិការសឹកអគ្គីនេត្រមហាបដិវត្តនេះ រួមមាន៖ កងវរសេនាតូចលេខ២០០, កងវរសេនាតូចលេខ២០១, កងវរសេនាតូចលេខ២០២, កងវរសេនាតូចលេខ២០៣ និងកងវរសេនាតូចលេខ២០៤ នៃកងពលតូចលេខ១៥ ដែលមានវរសេនីយ៍ឯក លន់ ណុន ជាមេបញ្ជាការ សហការជាមួយកងពលតូចថ្មើរជើងលេខ២១, កងពលតូចឆត្រយោងលេខ១ និងកងពលតូចរថក្រោះរថពាសដែក ដែលមានវរសេនីយ៍ឯក ដែង ឡៃយ៉ុម ជាមេបញ្ជាការ ព្រមទាំងមានការគាំទ្រពីសំណាក់យន្តហោះចម្បាំងរបស់សហរដ្ឋអាមេរិក ទៀតផង។

ក្រោយពីប្រតិបត្តិការសឹកអគ្គីនេត្រមហាបដិវត្ត វាយបើកផ្លូវជាតិលេខ៣ ពីទីប្រជុំជនត្រាំខ្នារ ទៅដល់ទីប្រជុំជនអង្គតាសោម ទទួលបានជោគជ័យ សេនាប្រមុខ លន់ នល់ បានទៅធ្វើជាអធិបតីក្នុងពិធីអបអរសាទរជ័យជម្នះនោះ នៅទីប្រជុំជនត្រាំខ្នារ

របត់នយោបាយ

បើទោះបីពេលនោះទីតាំងភ្នំស្រង់ (ខេត្តកំពង់ស្ពឺ) ត្រូវបានកងពលធំថ្មើរជើងលេខ១ របស់កងទ័ពវៀតកុង ដណ្តើមយកបានទៅវិញក៏ដោយ។




**សមរភូមិត្រាំខ្នារ**



**ទាហានលន់ នល់ សែងអ្នករបួស នៅសមរភូមិភ្នំស្រង់**

សុស្តែន ហ្វៃរណង់ដេស បានអះអាងទៀតថា លន់ ណុន ប្អូនសេនាប្រមុខ លន់ នល់ ជាមេទាហានស្រករក្រោយ និងថ្នាក់ក្រោម មានឋានៈត្រឹមតែជាមេបញ្ជាការកងពលប៉ុណ្ណោះ តែចង់មកត្រួតត្រាលើគាត់ ជានាយអគ្គសេនាធិការកងទ័ពជាតិទៅវិញ។ ស្អីបន្តិចក៏ លន់ ណុន បង្កទំនាស់ជាមួយគាត់ដែរ តែគាត់មិនព្រមចាញ់...។ លន់ ណុន មិនហ៊ានខ្លាំងជាមួយគាត់ទេ តែក៏ស្អប់គាត់ណាស់ដែរ។ គាត់មិនអនុញ្ញាតឱ្យ លន់ ណុន ធ្វើអ្វីតាមអំពើចិត្តនោះទេ។ គាត់បានហៅ លន់ ណុន មកព្រមាន រហូតដល់ចង្អុលមុខថា ប្រយ័ត្នណា! បងខ្លួនទេជាសេនាប្រមុខ មិនមែនខ្លួនឯងជាសេនាប្រមុខទេ ដូច្នេះត្រូវតែគោរពថ្នាក់ដឹកនាំឯទៀតៗផង។

ទាក់ទងដល់រឿង លន់ ណុន អាងខ្លួនជាប្អូនប្រុសបង្កើតរបស់សេនាប្រមុខ លន់ នល់ នេះ មានប្រភពមួយបានបង្ហើបឱ្យដឹងថា តាំងពីមុនមានព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០ លន់ ណុន មានរឿងអាស្រូវផ្លូវភេទមួយ ដោយគាត់បានស្រឡាញ់ និងទិញទឹកចិត្តនាង កែវ មន្ថា ជាប្រពន្ធតារាចម្រៀងបទធ្វីស ឈ្មោះ ជុំ កែម យកទៅជាប្រពន្ធចុងរបស់គាត់។ រហូតដល់ឆ្នាំ១៩៧១ ក្នុងពិធីប្រឡងចម្រៀងសម័យនៅវាល

របត់នយោបាយ

ព្រះមេរុ បេក្ខនារីឈ្មោះ ហៃម សុវណ្ណ បានលើកយកបទចម្រៀងមួយបទ គឺបទចំអកនាងល្ងេងមកច្រៀង។

បទចំអកនាងល្ងេង មានខ្លឹមដើមទាំងស្រុងថា៖ ១. ភ្លេងលេងបើកវាំងនន អើយព្រលឹងបងអ្ហើយ ធ្វើមុខញញឹម ភ្លេងលេងបើកវាំងននអើយ ត្រលុងបងអ្ហើយ សុំប្រពន្ធគេផ្ញឹម ខំមកដេកសង្ស៊ឹមអើយ ត្រលុងបងអ្ហើយ សង្ស៊ឹមមេឃា ខំមកដេកសង្ស៊ឹមអើយ ត្រលុងបងអ្ហើយ សង្ស៊ឹមមេឃា។ ២. កោតតែចិត្តខ្លាំងណាស់អើយ មិនគួរមុខក្រាស់ស្រលាញ់ប្រពន្ធគេ កោតតែចិត្តខ្លាំងណាស់អើយ គ្មានអៀនគ្មានខ្មាស ស្រលាញ់ប្រពន្ធគេ ខ្វះអីស្រីទំនេរអើយ ស្រលាញ់ប្រពន្ធគេ ឱ្យអាប់យសស័ក្តិ ខ្វះអីស្រីទំនេរអើយ ស្រលាញ់ប្រពន្ធគេ ឱ្យអាប់យសស័ក្តិ។ ៣. ស្តាយអំណាចស្តុកស្តម្ភអើយ តែមើលមុខចំមុខឡើងកំពឹងពឹង ស្តាយអំណាចស្តុកស្តម្ភអើយ តែមើលមុខចំ មុខឡើងកំពឹងពឹងក្បាលពោះដូចហ៊ីង ត្រលុងបងអ្ហើយ គេស្មុគ្រម្តេចកើត ក្បាលពោះដូចហ៊ីង ត្រលុងបងអ្ហើយ គេស្មុគ្រម្តេចកើត។ ៤. ភ្លេងលេងបើកវាំងនន អើយ ត្រលូបងអ្ហើយ គួរតែស្លាប់ទៅ ភ្លេងលេងបើកវាំងននអើយ ត្រលូបងអ្ហើយ គួរតែស្លាប់ទៅ ខំត្រដររស់នៅអើយ ត្រលូបងអ្ហើយ នាំឱ្យអាស្រូវកេរ្តិ៍ ខំត្រដររស់នៅអើយ ត្រលូបងអ្ហើយ នាំឱ្យអាស្រូវកេរ្តិ៍។

បទចម្រៀងនេះ ត្រូវបានមជ្ឈដ្ឋានជាច្រើនយល់ថា ជាការច្រៀងដៀមដាមដាក់ផ្លែដាក់ផ្កាឱ្យ លន់ ណុន ដែលមានកិត្តិយសបុណ្យស័ក្តិខ្ពង់ខ្ពស់ល្អពេក បែរជាមកលួចប្រពន្ធ ជុំ កែម ទៅវិញ។

ជាមួយគ្នានោះ គេបានចោទប្រកាន់ថា លន់ ណុន បានបង្កើតកម្លាំងពិសេសមួយក្រុម ដើម្បីកម្ចាត់អ្នកនយោបាយ ឬឥស្សរជនណាដែលហ៊ានប្រឆាំងជាមួយគាត់ និងអ្នកកាសែតណាដែលហ៊ានចុះផ្សាយអត្ថបទប៉ះពាល់ដល់កត្តិយសរបស់គាត់។

លន់ ណុន ធ្លាប់បញ្ជាឱ្យកម្លាំងប៉េអឹម ទៅឡោមព័ទ្ធទីស្នាក់ការកាសែតនគរធំ ដែលមាន សុទ្ធ ប៉ូលីន ជាចាងហ្វាង និងកាសែតកោះសន្តិភាព ដែលមាន ថុង អ៊ុយប៉ាង ជានិពន្ធនាយក ដោយសារតែកាសែតទាំង២នេះ ហ៊ានចុះផ្សាយអត្ថបទប៉ះពាល់ដល់

របត់នយោបាយ

កត្តិយសរបស់គាត់ ។

ការសែតសង្កេតការណ៍ថ្មី និងកាសែតប្រយោជន៍ខ្មែរ ក៏បានចុះផ្សាយរឿង លន់ ណុន សម្លុតគម្រាមមន្ត្រីធនាគារជាតិ នៅពេលគាត់ទៅបើកប្រាក់ចំនួនជាងមួយលានរៀល តែបើកបានតែជាងប្រាំពាន់រៀលប៉ុណ្ណោះ ដោយពេលនោះ ខាងធនាគារជាតិខ្វះសាច់ប្រាក់ ។

ការរៀបចំអង្គភាពកងទ័ពសម័យសាធារណរដ្ឋខ្មែរ មានពីរវគ្គ គឺដំបូង លន់ នល់ សូមឱ្យពួកទីប្រឹក្សាយោធាអាមេរិក មកពីក្រុងព្រៃនគរ មកជួយរៀបចំអ្នកស្ម័គ្រចិត្តចូលបម្រើកងទ័ព ជាកងអនុសេនាតូច កងអនុសេនាធំ កងវរសេនាតូច រួចហើយហ្វឹកហាត់កាន់កាំភ្លើងតែ២៤ម៉ោង ក៏ចេញទប់ទល់ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលមានច្រើនកងពល ។ ដោយសារកងទ័ពសម័យសាធារណរដ្ឋខ្មែរ បង្កើតឡើងភ្លាមៗ គ្មានសមត្ថភាព គ្មានបទពិសោធខាងចម្បាំងរាំងជល់ ដល់ប៉ះចំកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលមានគ្នាច្រើន មានអាវុធសម្បូរបែប និងមានបទពិសោធជោគជាំនោះ កងទ័ពសម័យសាធារណរដ្ឋខ្មែរ មិនហ៊ានវាយលុកទៅលើពួកវាទេ គ្រាន់តែវាយទប់ទល់ប៉ុណ្ណោះ ។ ពេលនោះដែរ ទីប្រឹក្សាយោធាអាមេរិក ក៏បានបញ្ជូនពួកទាហានម៉ៃហ្វក (ទាហានខ្មែរកម្ពុជាក្រោម) ដែលអាមេរិក បង្កើតឡើង នៅប្រទេសវៀតណាមខាងត្បូង ឱ្យមកជួយវាយទប់ទល់ ។ ជាមួយគ្នានោះ លន់ នល់ ក៏បានបញ្ជូននាយទាហាន ជាច្រើនទៀត ឱ្យទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ នៅប្រទេសសៀម ប្រទេសឥណ្ឌូនេស៊ី រហូតដល់សហរដ្ឋអាមេរិក ផងដែរ ។ ការប្រើយុទ្ធសាស្ត្រគ្រាន់តែវាយទប់ទល់នោះ គឺដើម្បីយកឱកាសបែងចែកកម្លាំងបណ្តាក់គ្នា ម្តងមួយកងពលៗ ឱ្យទៅរៀនក្បួនយុទ្ធសាស្ត្រ នៅប្រទសយួនខាងត្បូង ទីប្រឹក្សាយោធាអាមេរិក ជាគ្រូបង្ហាត់បង្រៀន ក្នុងមួយវគ្គៗមានរយៈពេល២ខែ ។ ក្រោយពេលរៀនចប់ ត្រូវបំពាក់អាវុធទំនើបៗ ហើយវិលមកមាតុប្រទេសវិញភ្លាម ដើម្បីវាយកម្ទាត់កងទ័ពវៀតកុង-វៀតណាមខាងជើង ទទួលបានជោគជ័យប្រសើរជាងកាលធ្វើសង្គ្រាមដំបូងទី ។




**វរសេនីយ៍ឯក លន់ ណុន មេបញ្ជាការកងពលលេខ១៥**

កាលនោះ ក្រោយពីបានទៅហាត់រៀនក្បួនយុទ្ធសាស្ត្រនៅប្រទេសវៀតណាម ខាងត្បូង មកឧត្តមសេនីយ៍ គីង ម៉េង ខ្លាំងពូកែណាស់ គាត់ដឹកនាំទាហានទៅវាយដណ្ដើមរោងចក្រផលិតស៊ីម៉ងត៍ចក្រីទីង នៅខេត្តកំពត ពីកងទ័ពវៀតកុង-វៀតណាមខាងជើង តែក្នុងរយៈពេល២៤ម៉ោងប៉ុណ្ណោះ ទាហានគាត់ដណ្ដើមបានដោយជោគជ័យ។

ចំពោះការចោទប្រកាន់ថា ដោយសារចង់បានកេរ្តិ៍ឈ្មោះខ្លួនឯង ឧត្តមសេនីយ៍ លន់ នល់ និងសុស្ដែន បានបញ្ជាឱ្យពួកទាហានម៉ៃហ្វក (ទាហានខ្មែរកម្ពុជាក្រោម) ដែលអាមេរិក បង្កើតឡើងនៅប្រទេសវៀតណាមខាងត្បូងនោះ ឱ្យទៅប្រយុទ្ធលើសមរភូមិ ទោះស្លាប់អស់ប៉ុន្មានក៏ស្លាប់ទៅ... តើនេះជាការពិតទេ?។

សុស្ដែន ហ្វៀរណង់ដេស បានធ្វើការបកស្រាយថា ការចេញច្បាំងមិនមែនជាការដើរកម្សាន្តធម្មតាទេ បើយើងបាញ់ទៅខ្មាំង វាបាញ់មកវិញ។ តែបើយើងមិនចេញទៅច្បាំង អាហ្នឹងខ្មាំងវាមកយកទីតាំងយើងតែម្ដង។ ធម្មតាការប្រយុទ្ធគ្នានៅលើសមរភូមិមានតែស្លាប់ និងរបួសតិចឬច្រើន និងរត់ចោលជួរ។





## កងទ័ពម៉ៃហ្វក មកពីកម្ពុជាក្រោម

អ្វីដែលបានចោទថា គាត់បញ្ជាឱ្យពួកទាហានម៉ៃហ្វក (ទាហានខ្មែរកម្ពុជាក្រោម) ទៅស្លាប់អស់ប៉ុន្មាន ក៏ស្លាប់ទៅនោះ គឺមិនពិតទាល់តែសោះ ពីព្រោះនៅអគ្គសេនាធិការដ្ឋានមានប្លង់ចម្បាំង មានក្បួនយុទ្ធសាស្ត្រត្រឹមត្រូវ។ សមរភូមិណាដែលយើងខ្វះកម្លាំងទ័ព យើងសុំទាហានម៉ៃហ្វក ឱ្យមកជួយ។ សមរភូមិណាដែលយើងអាចទប់ទល់បានដោយខ្លួនឯង យើងមិនសុំទាហានម៉ៃហ្វក ឱ្យមកជួយទេ។ ពេលនោះ កងទ័ពសាធារណរដ្ឋខ្មែរ មានចំនួន២០០ពាន់នាក់ ទាំងជើងទឹក, ជើងអាកាស និងជើងគោក បំពាក់សម្ភារសឹកគ្រប់គ្រាន់។

ចំពោះការចោទប្រកាន់ពីរឿងពុករលួយ ទាហានមានតែឈ្មោះនៅក្នុងបញ្ជីនោះ អតីតនាយអគ្គសេនាធិការ សុស្ដែន ហ្វែរណង់ដេស បានបំភ្លឺថា រឿងហ្នឹងមានការយល់ច្រឡំច្រើនណាស់ សូមជ្រាបថា៖ “ ទ័ពដល់ទៅ២០០ពាន់នាក់ ដែលបញ្ជូនឱ្យទៅច្បាំងនោះ គេមើលមិនឃើញអ្នករងរបួសដែលដឹកយកទៅដាក់មន្ទីរពេទ្យទាហានផង មន្ទីរពេទ្យស៊ីវិលផង ដាក់គ្លីនិកឯកជនផង ដាក់កន្លែងសម្រាលកូនទៀត គឺដាក់គ្រប់កន្លែងទាំងអស់ ហើយនៅក្នុងមួយថ្ងៃៗ មានទាហានស្លាប់យ៉ាងហោចណាស់ ក៏ជាង ១០០នាក់ដែរ។ ទាហានក្នុងមួយវរសេនាតូចត្រូវមាន៥០០នាក់ តែជួនកាលវាមិនមានដល់៥០០នាក់ទេ ព្រោះចេញច្បាំងមួយសាៗ ត្រូវស្លាប់អស់១០០ឬ៥០នាក់ ភ្លាមៗ

របត់នយោបាយ

តែម្តង បើអ្នករងរបួសត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ និយាយបែបហ្នឹង មិនមែនថា៖ អត់អំពើពុករលួយទេ គឺប្រាកដជាមានអំពើពុករលួយ។ តែអាមេរិក គេឱ្យលុយយើង គេមិនធ្លូតទេ គេពិនិត្យតាមដាន គេដឹង គេមកប្រាប់យើងថា៖ ប្រយ័ត្ននៅខេត្តបាត់ដំបង មានមេទាហានម្នាក់ឈ្មោះ យិន ខេង និងម្នាក់ទៀត ឈ្មោះ ផល សុខន ជាអ្នកបើកប្រាក់ខែបានកិបកេងយកប្រាក់ខែ ទាហានច្រើនលានរៀល ”។ ក្រោយពីទទួលដំណឹងនេះគាត់បានបញ្ជាឱ្យទៅចាប់មេទាហាន ជាអ្នកបើកប្រាក់ខែទាំង២នាក់នោះ យកមកបកស័ក្តិ និងដាក់គុកភ្លាមៗតែម្តង ហើយគាត់សូមឱ្យពួកទីប្រឹក្សាយោធាអាមេរិក ជួយទៅចាត់ចែងរឿងបើកប្រាក់ខែទាហាននៅខេត្តបាត់ដំបង ឱ្យបានត្រឹមត្រូវឡើងវិញ។



**វរសេនីយ៍ត្រី គឹម កេត ត្រូវបកស័ក្តិមកពលទោ ពីបទផ្គត់ផ្គង់អាវុធ និងផែនការសឹកឱ្យខ្មាំង**

របត់នយោបាយ

ពេលនោះដែរ ក៏មានកាសែតបរទេស ពិសេសកាសែតអាមេរិក បានចុះផ្សាយថា៖ ពួកមេទាហានសាធារណរដ្ឋខ្មែរ ក្នុងនោះ ក៏មានរូបគាត់ផងដែរ ដៃម្ខាងវាយ ដៃម្ខាងទៀតលក់អាវុធឱ្យខ្មាំង។ គាត់ក៏បានស្នើសុំឱ្យពួកទីប្រឹក្សាយោធាអាមេរិក ទៅជួយស៊ើបអង្កេតរឿងហ្នឹង ដែរ។ លុះស៊ើបអង្កេតទៅ ដឹងថា៖ នៅតាមអង្គភាពជាច្រើន មានកូនទាហានខ្លះ ខ្វះលុយចាយ ក៏លួចលក់កាំភ្លើងទៅឱ្យពួកខ្មែរក្រហម និងយួនវៀតកុងមួយដើមពីរពិតមែន។ តែសរុបទៅ ការលក់កាំភ្លើងនោះ មានកាន់តែច្រើន។ រឿងលក់កាំភ្លើងនេះ នៅតាមព្រំដែនខាងលិច ក៏មានលក់ឱ្យពួកសៀម ដែរ។ តែគាត់គិតថា នេះជាសង្គ្រាមចិត្តសាស្ត្ររបស់ពួកខ្មែរក្រហម និងយួនវៀតកុង ព្រោះក្រោយពីទិញបានកាំភ្លើង២០ឬ៣០ដើម ពួកវាហៅអ្នកកាសែតអាមេរិក ឱ្យមកថតរូបយកទៅចុះផ្សាយដោយប្រាប់ថា៖ អ្នកឯងទៅជួយអីខ្មែរ មើលទៅសុទ្ធតែកាំភ្លើង អ្នកឯងទាំងអស់ ក្នុងបំណង កុំឱ្យអាមេរិក ផ្តល់ជំនួយដល់របបសាធារណរដ្ឋខ្មែរ បន្តទៀត។ គាត់បានប្រាប់ទៅពួកទីប្រឹក្សាយោធាអាមេរិក ថា៖ ពួកវាទិញកាំភ្លើងពីយើងបាន២០ឬ៣០ដើម យកទៅឱ្យពួកកាសែតចុះផ្សាយ គឺពួកខ្មាំងគ្រាន់តែចង់សំអុយយើងប៉ុណ្ណោះ។ អ្នកឯងកុំគិតអារឿងតូចតាចហ្នឹងពេក សំខាន់ត្រូវជួយគិតពីរឿងវាយបកទៅពួកវាវិញ។

---

# ៧.២៤ ចូលព្រៃដើម្បីធ្វើបដិវត្តន៍ មិនមែនដើម្បីសម្តេចសីហនុ




## អ្នកបដិវត្តន៍ក្រហមឆ្អិនឆ្អៅចូលព្រៃមិនមែនដើម្បីសម្តេចសីហនុ

ទាក់ទិនដល់ការតស៊ូប្រយុទ្ធជាមួយទាហាននៃរបបសាធារណរដ្ឋខ្មែរ ក្នុងអំឡុងឆ្នាំ១៩៧១ ខៀវ សំផន ដែលបានមកស្នាក់នៅ និងធ្វើការនៅមន្ទីរគណៈមជ្ឈិមបក្សជាមួយ សាឡុត ស និងនួន ជា នៅក្បែរមាត់ស្ទឹងជីនិត។ កាលនោះ ពេល សាឡុត ស និងនួន ជា ចេញពីមន្ទីរគណៈមជ្ឈិមបក្ស ទៅធ្វើការតាមមូលដ្ឋាន គាត់ក៏ត្រូវបានមេដឹកនាំទាំង២នាក់នេះ អនុញ្ញាតឱ្យទៅជាមួយដែរ។ គាត់ឃើញផ្ទាល់ភ្នែកនូវជួរកង់២ខ្សែវែងដាច់កន្ទុយភ្នែក មានចម្ងាយរាប់រយគីឡូម៉ែត្រនៅតំបន់ទន្លេសាប ខាងត្បូងខេត្តសៀមរាប និងខេត្តកំពង់ធំ កំពុងធ្វើដំណើរឆ្ពោះទៅស្រុកស្ទឹងត្រង់។ ជួរកង់២ខ្សែវែងដាច់កន្ទុយភ្នែកនេះ ធ្វើដំណើរបញ្ច្រាសទិសគ្នា គឺជួរកង់ខ្សែទី១ ធ្វើដំណើរពីភូមិភាគពាយ័ព្យ ដឹកបារអង្ករ ត្រីងៀត ត្រីឆ្អើរ

របត់នយោបាយ

និងប៊ីដុងសាំង សំដៅទៅស្រុកស្ទឹងត្រង់ (ខេត្តកំពង់ចាម) ហើយជួរកង់ខ្សែទី២ ធ្វើដំណើរបញ្ច្រាសទិសគ្នាមកពីស្រុកស្ទឹងត្រង់ សំដៅទៅភូមិភាគពាយ័ព្យ វិញ តែមិនសូវឃើញមានដឹកអ្វីសំខាន់ទេ។ ពេលនោះ សាឡុត ស, នួន ជា និងគាត់ (ខៀវ សំផន) បាននាំគ្នាជិះម៉ូតូកណ្ដាល ជួរកង់ទាំង២ខ្សែនេះ ដោយប្រុងប្រយ័ត្នមិនឱ្យប៉ះពារ ជាមួយកង់ទាំង២ខ្សែនេះឡើយ។

សកម្មភាពទាំងនេះធ្វើឱ្យ ខៀវ សំផន នឹកឃើញដល់ជួរកង់ជាខ្សែៗ ដែលដឹកជញ្ជូនស្បៀងអាហារ និងគ្រាប់រំសេវទៅផ្គត់ផ្គង់ដល់កងទ័ពវៀតមិញ វាយប្រហារកងទ័ពបារាំង នៅសមរភូមិឌៀនបៀនភូ កាលឆ្នាំ១៩៥៤ នោះដែរ។ ប៉ុន្តែ ខុសគ្នា ពេលនោះ មនុស្សប្រុសស្រីដែលកំពុងដឹកជញ្ជូន តាមកង់នោះសុទ្ធតែជាជនជាតិខ្មែរ ហើយពួកគេអាចជិះកង់ទាំងអស់នោះបាន ដោយមិនបាច់ដើរបណ្ដើរ និងរុញកង់ឡើងភ្នំចុះភ្នំ ដូចនៅប្រទេសវៀតណាម នោះទេ។ ពេលនោះ សាឡុត ស និងនួន ជា និយាយមកកាន់ ខៀវ សំផន ថា សមមិត្តឃើញទេ គឺពួកគេទេ ដែលជាម្ចាស់ប្រទេស ជាបដិវត្តន៍ពិតប្រាកដ...។




**កងដឹកជញ្ជូនវៀតមិញ កាលសម័យធ្វើសង្គ្រាមបណ្ដេញបារាំង**

របត់នយោបាយ

នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ កងទ័ពស្រួចរបស់ខ្មែរក្រហម ក្រោមផ្លាករណសិរ្សរួបរួមជាតិកម្ពុជា បានកើនឡើងទៅដល់២០កងវរសេនាតូច និង៥វរសេនាតូចទៀត ជាអង្គភាពចម្រុះខ្មែរ-វៀតណាម។ ក្រៅពីកងទ័ពស្រួច នៅតាមភូមិភាគនីមួយៗ ពួកខ្មែរក្រហម បានកសាងកងទ័ពតំបន់ កងទ័ពស្រុក និងកងឈ្លបប្រមាណ៦០០០នាក់ទៀត។

នៅចុងឆ្នាំ១៩៧០ កងទ័ពខ្មែរក្រហម បានកើនចំនួនដល់ប្រមាណ១៥០០០នាក់ថែមទៀត ខណៈដែលកងទ័ពវៀតកុង-វៀតណាមខាងជើង មានចំនួន៤០០០០នាក់ ហើយកងទ័ពរដ្ឋការវៀតណាមខាងត្បូង ដែលចូលមកក្នុងទឹកដីកម្ពុជា ក៏មានចំនួនប្រហាក់ប្រហែលគ្នានេះដែរ។

តែបើតាមរបាការណ៍របស់ភ្នាក់ងារសម្ងាត់សេអ៊ីអា ឈ្មោះ សាម អាដាម ( Same A Dams) បានឱ្យដឹងថា៖ នៅដើមឆ្នាំ១៩៧១ កងទ័ពរៀបរយខ្មែរក្រហម មានតែចំនួន២កងពលតូចប៉ុណ្ណោះ។ ប៉ុន្តែ ពួកខ្មែរក្រហម បានអួតអាងថា៖ ពួកគេមានកងទ័ពរៀបរយ និងកងឈ្លបដល់ទៅ១២៥០០០នាក់ ឯណោះ។ ចំណែកភ្នាក់ងារសម្ងាត់របស់ក្រសួងការពារជាតិអាមេរិក បានរាយការណ៍ថា៖ ពួកខ្មែរក្រហម ដែលទទួលការគាំទ្រពីសំណាក់ប្រជាកសិករខ្មែរ ព្រមទាំងពួកអាណិកជនចិន និងវៀតណាម ផងដែរនោះ បានគ្រប់គ្រងប្រជាជនកម្ពុជា ពី២ ទៅ៣លាននាក់ ក្នុងចំណោមប្រជាជនកម្ពុជាសរុបប្រមាណ៧លាននាក់ ហើយស្ទើរតែគ្រប់តំបន់ដែលរំដោះបាន ពួកវៀតកុង-វៀតណាមខាងជើង យល់ព្រមឱ្យពួកខ្មែរក្រហម ធ្វើជាអ្នកដឹកនាំគ្រប់គ្រងតាមការទាមទាររបស់ពួកគេ។ នៅក្នុងតំបន់ ដែលទើបនឹងរំដោះបាននោះ សុទ្ធតែជាតំបន់ជនបទស្រុកស្រែចម្ការ ពួកខ្មែរក្រហម បានកំណត់យកវណ្ណៈកសិករ និងពួកអនុជនធ្វើជាកម្លាំងបង្អែករបស់បដិវត្តន៍។ ជាមួយគ្នានោះ ពួកគេ ក៏បានសម្លាប់អតីតពួកមន្ត្រីរាជការពិសេសមន្ត្រីប៉ូលិស ទាហាន ជាបន្តបន្ទាប់ដែរ។ ប៉ុន្តែជាទូទៅ ពួកគេយកគំរូល្អពីសីលធម៌បដិវត្តន៍របស់ពួកវៀតកុង-វៀតណាមខាងជើង ដោយព្យាយាមយកចិត្តយកថ្លើមប្រជាកសិករ ពេលទំនេរ ពួកគេជួយធ្វើស្រែចម្ការប្រជាជន និងមិនធ្វើសកម្មភាពណា

របត់នយោបាយ

ដែលធ្វើឱ្យប្រជាកសិករ ថ្នាំងថ្នាក់ មិនពេញចិត្តនោះឡើយ។

នៅដើមឆ្នាំ១៩៧១ ពួកមេដឹកនាំខ្មែរក្រហមបានដាក់ចេញនូវយុទ្ធសាស្ត្រនៃការធ្វើបដិវត្តន៍ក្នុងដំណាក់កាល ប្រជាជាតិប្រជាធិបតេយ្យ ដោយចាត់ទុកថា ការតស៊ូរបស់បដិវត្តន៍របស់ពួកគេ ជាការតស៊ូយូរអង្វែងត្រូវឆ្លងកាត់នូវដំណាក់កាលលំបាកលំបិន, ស្មុគស្មាញ, បត់បែន និងត្រូវឈរលើគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ដើម្បីឈានទៅរក ការដណ្តើមជ័យជម្នះ ជាចុងក្រោយ។ ប្រសិនបើ មិនយកគោលជំហរធ្វើបដិវត្តន៍ដោយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួននេះទេ ដោយគិតតែពឹងពាក់អ្នកដទៃនោះ ការធ្វើបដិវត្តន៍របស់ពួកគេ មិនអាចឈានទៅរកជ័យជម្នះបានឡើយ ហើយពួកគេមុខជាជួបការលំបាកទៅអនាគតទៀតផង។



**យុវជន យុវនារីជាកូនចៅប្រជាកសិករស្ម័គ្រចិត្ត ចូលធ្វើបដិវត្តន៍នៅភូមិភាគបូព៌ា**

ពួកគេបានអប់រំសតិអារម្មណ៍កម្មាភិបាលគ្រប់លំដាប់ថ្នាក់ ឱ្យមានទស្សនៈបដិវត្តន៍គ្រប់ជ្រុងជ្រោយ និងអនុវត្តតាមមាគ៌ាយុទ្ធសាស្ត្រធ្វើបដិវត្តន៍ក្នុងដំណាក់កាលប្រជាជាតិប្រជាធិបតេយ្យនេះ ឱ្យបានដាច់ខាត។

របត់នយោបាយ

ពួកខ្មែរក្រហម បានចាត់ទុកថា ប្រទេសកម្ពុជា ជាប្រទេសពាក់កណ្តាលអាណានិគមផង និងពាក់កណ្តាលសក្តិភូមិផង ហើយធ្វើការបែងចែកវណ្ណៈ នៅក្នុងសង្គមកម្ពុជា ជា៥វណ្ណៈគឺ៖ វណ្ណៈសក្តិភូមិ, វណ្ណៈនាយទុន, វណ្ណៈអនុធន, វណ្ណៈកម្មករ, និងវណ្ណៈកសិករ។ ការបែងចែកវណ្ណៈ ក្នុងសង្គមកម្ពុជា របស់ពួកមេដឹកនាំខ្មែរក្រហម នេះ គឺយកគំរូតាមការបែងចែកវណ្ណៈ របស់បក្សកុម្មុយនិស្តចិន កាលពីសម័យតស៊ូធ្វើបដិវត្តន៍នៅប្រទេសចិន ដូចគ្នាបេះបិទតែម្តង។ ពួកខ្មែរក្រហម បានឃោសនាអប់រំពន្យល់ប្រជាកសិករ ដោយសង្កត់ធ្ងន់ពីការជិះជាន់សង្កត់សង្កិនកេងប្រវ័ញ្ចរបស់ ពួកសក្តិភូមិម្ចាស់ដី ពិសេសអប់រំឱ្យកម្មាភិបាល យុទ្ធជន និងប្រជាជន ដែលនៅក្នុងតំបន់រំដោះ ឱ្យហៅថ្នាក់ដឹកនាំគណៈកម្មាធិការមជ្ឈិមបក្ស ជាថ្នាក់ដឹកនាំកំពូលរបស់ពួកគេ ពិសេស ប៉ុល ពត ថា “ អង្គការ ” ជាអ្នកមានអំណាចកំពូលក្នុងដឹកនាំចលនាតស៊ូបដិវត្តន៍ និងដឹកនាំធ្វើសង្គ្រាមរំដោះប្រជាជន។

បើយោងតាមឯកសារនយោបាយមួយ មានចំណងជើងថា៖ នរណាជាអ្នកដឹកនាំសង្គ្រាមប្រជាជន? ដែលទំនង ជាចង់និយាយពីសម្តេចសីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា បានសរសេរថា៖ វណ្ណៈកេងប្រវ័ញ្ចតែងតែប្រឆាំងជានិច្ច ចំពោះសង្គ្រាមប្រជាជន។ ពួកគេជាសត្រូវស្លាប់រស់របស់សង្គ្រាមប្រជាជន ពួកគេពុំមែនជាអ្នកដឹកនាំសង្គ្រាមប្រជាជន ពិតប្រាកដឡើយ។ ផ្ទុយទៅវិញ បើពួកគេមកចូលរួមដឹកនាំសង្គ្រាមប្រជាជននោះ គឺគ្រាន់តែជាវិធីបោកប្រាស់របស់ពួកគេ ដើម្បីសម្លាប់ប្រជាជន និងបន្តការជិះជាន់កេងប្រវ័ញ្ចប្រជាជន បន្តទៀតតែប៉ុណ្ណោះ។ ដូច្នេះ អ្នកដឹកនាំសង្គ្រាមប្រជាជនពិតប្រាកដ គឺមានតែវណ្ណៈ ដែលត្រូវគេជិះជាន់ ព្រមទាំងជាអ្នកមានកំហឹងយ៉ាងស្រួចស្រាវ និងជាអ្នកដាច់ខាតក្នុងការធ្វើសង្គ្រាម ដើម្បីលុបបំបាត់វណ្ណៈជិះជាន់ លុបបំបាត់ពួកចក្រពត្តិនិយម ពួកសក្តិភូមិនិយម និងពួកនាយទុនប្រតិកិរិយា។ វណ្ណៈនោះ គឺគ្មានវណ្ណៈណាក្រៅ ពីវណ្ណៈកម្មាជីព (កម្មករ) ឡើយ ហើយអង្គការខ្ពស់បំផុត អគ្គបញ្ជាការ និងកម្លាំងឈានមុខរបស់វណ្ណៈកម្មាជីពនេះ គឺមានតែបក្ស

របត់នយោបាយ
របស់វណ្ណៈកម្មាជីព ដែលឈរលើទ្រឹស្តីម៉ាក្ស-ឡេនីន ដ៏ភ្លឺស្វាង មានគោលនយោបាយបម្រើផលប្រយោជន៍វណ្ណៈកសិករ និងប្រទេសជាតិ។

ក្រោយពីការប្រកាសអំពាវនាវរបស់សម្តេចសីហនុ ឱ្យប្រជារាស្ត្ររបស់ព្រះអង្គ ងើបបះបោររត់ចូលព្រៃម៉ាគី ដើម្បីតស៊ូធ្វើសង្គ្រាមផ្តួលរម្លំបនក្បត់ លន់ នល់ សិរិមតៈ នោះមក ប្រជារាស្ត្រខ្មែរជាច្រើន ពិសេសស្រទាប់យុវជន បាននាំគ្នារត់ចូលព្រៃតាមការអំពាវនាវរបស់ព្រះអង្គ ក្នុងគោលបំណងធ្វើសង្គ្រាម ដើម្បីយកព្រះអង្គមកដឹកនាំប្រទេសដូចដើមវិញ ហើយពួកមេដឹកនាំខ្មែរក្រហម ក៏បានឃោសនាបោកប្រាស់ប្រជាជនថា ធ្វើសង្គ្រាមដើម្បីយកសម្តេចសីហនុ មកដឹកនាំប្រទេសវិញដែរ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧១មក នៅក្នុងវគ្គរៀនសូត្រនយោបាយនានា ពួកមេខ្មែរក្រហម បានលើកយកឯកសារមួយដែលមានចំណងជើងថា៖ ហេតុអ្វីបានជា យើងចូលបម្រើបដិវត្តន៍? មកឱ្យកម្មាភិបាល និងយុទ្ធជននៃកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា រៀនសូត្រ និងឱ្យធ្វើជីវទស្សន៍ពាក់ព័ន្ធនឹងសំណួរនេះ។

វាប្រាកដណាស់ថា៖ គ្មានចម្លើយណាមួយ ដែលពួកគេត្រូវឆ្លើយថា ចូលបម្រើបដិវត្តន៍ដើម្បីឱ្យសម្តេចសីហនុ បានវិលត្រលប់មកដឹកនាំប្រទេសវិញ ដូចកាលពីមុនឆ្នាំ១៩៧០ នោះទៀតទេ។ ផ្ទុយទៅវិញ គឺមានតែចម្លើយដែលថា យើងចូលបម្រើបដិវត្តន៍ដើម្បីលុបបំបាត់វណ្ណៈសក្តិភូមិ វណ្ណៈជិះជាន់ និងវណ្ណៈកេងប្រវ័ញ្ចផ្សេងៗទៀតតែប៉ុណ្ណោះ។

នៅខែកក្កដា ឆ្នាំ១៩៧១ មេដឹកនាំខ្មែរក្រហម បានប្រារព្ធធ្វើសន្និបាតគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា នៅមន្ទីរមជ្ឈិមបក្ស ដែលស្ថិតនៅក្បែរមាត់ស្ទឹងជីនិត ក្នុងឃុំដងក្តារ ស្រុកស្ទឹងត្រង់ តំបន់៤២ ភូមិភាគឧត្តរ (ត្រង់ព្រំប្រទល់ខេត្តកំពង់ធំ និងកំពង់ចាម)។

កម្មាភិបាលជាន់ខ្ពស់ដែលចូលរួមក្នុងសន្និបាតនោះ មានជាង៦០នាក់ រួមមានទាំងមេដឹកនាំកំពូលៗដូចជា សាឡុត ស លេខាគណៈមជ្ឈិមបក្ស, នួន ជា អនុលេខា

មជ្ឈិមបក្ស, ស៊ុន សេន សមាជិកគណៈមជ្ឈិមបក្ស, វន វេត លេខាបក្សភូមិភាគពិសេសទើបបង្កើតថ្មី, សោ ភឹម លេខាបក្សភូមិភាគបូព៌ា, ណៃ សារ៉ាន់ លេខាបក្សភូមិភាគឦសាន, កុយ ធួន លេខាបក្សភូមិភាគឧត្តរ, តាម៉ុក លេខាបក្សភូមិភាគនិរតី, មូល សម្បត្តិ លេខាបក្សភូមិភាគពាយ័ព្យ ព្រមទាំងអនុលេខាបក្សភូមិភាគ, និងកម្មាភិបាលជាន់ខ្ពស់ជាអ្នកតស៊ូ មកពីក្រុងហាណូយ មួយចំនួនទៀតដូចជា កែវ មាស ជាដើម។ អៀង សារី មិនមានវត្តមាននៅក្នុងសន្និបាតនោះទេ ព្រោះជាប់រវល់បំពេញភារកិច្ចនៅក្រៅប្រទេស។

ក្នុងសន្និបាតនោះ បក្សកុម្មុយនិស្តកម្ពុជាបានសម្រេចទិសដៅ នយោបាយ និងផែនការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពិសេសយុទ្ធនាការបើកការវាយប្រហារទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ និងពិនិត្យលក្ខន្តិកៈបក្សផងដែរ។ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា បានលើកឡើង ពីមាគ៌ាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ និងការធ្វើសហករណ៍ភាវូបនីយកម្មដីធ្លី, ការជម្លៀសប្រជាជនចេញ ពេលវាយដណ្ដើមបានទីប្រជុំជនណាមួយពីពួកទាហាន លន់ នល់ និងបង្ខំកងទ័ពវៀតកុង-វៀតណាមខាងជើងឱ្យដកថយចេញពីទឹកដីកម្ពុជា វិញផងដែរ។

សោ ភឹម លេខាបក្សភូមិភាគបូព៌ា ជាអតីតសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន កំពុងសហការយ៉ាងជិតស្និទ្ធជាមួយពួកវៀតកុង-វៀតណាមខាងជើង នៅភូមិភាគបូព៌ា មិនឯកភាពក្នុងការវាយបណ្ដេញកងទ័ពវៀតកុង-វៀតណាមខាងជើងទេ គាត់សុំឱ្យប្រើមធ្យោបាយដោយសន្តិវិធីវិញ។

ជាមួយគ្នានេះដែរ ណៃ សារ៉ាន់ លេខាភូមិភាគឦសាន និងកុយ ធួន លេខាបក្សភូមិភាគឧត្តរ បានជំទាស់នឹងការធ្វើសហករណ៍ភាវូបនីយកម្មនោះ។ ពួកគាត់ស្នើសុំឱ្យមានត្រឹមតែក្រុមប្រវាស់ដៃក្នុងការធ្វើស្រែចម្ការ ប៉ុណ្ណោះ។

ចំពោះនយោបាយក្រៅប្រទេសវិញ មហាសន្និបាតបក្សបានសម្រេចថា ទំនាក់ទំនងជាមួយប្រទេសដទៃត្រូវធ្វើឡើង ដោយឈរលើមូលដ្ឋានស្មើភាព និងមិនជ្រៀតជ្រែកដល់កិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក ហើយថា រវាងបក្សកម្ពុជា និងបក្សវៀតណាម

របត់នយោបាយ

(វៀតណាមកុម្មុយនិស្ត) ពុំមានទំនាស់ទេ គ្រាន់តែមានការខ្វែងគំនិតគ្នាខ្លះៗ និងតាមដានគ្នាទៅវិញទៅមកប៉ុណ្ណោះ។



**មហាសន្និបាតគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ខែកក្កដា ឆ្នាំ១៩៧១**

ក្នុងមហាសន្និបាត ដែលមេខ្មែរក្រហម ចាត់ទុកថា មហាសន្និបាតលើកទី៣ របស់បក្សកុម្មុយនិស្តកម្ពុជា នោះ ខៀវ សំផន ត្រូវបានបញ្ចូលជាសមាជិកបម្រុងរបស់គណៈកម្មាធិការមជ្ឈិមបក្ស។ ក្រោយពីសន្និបាតនោះមក មានគណៈប្រតិភូផ្លូវការមួយរបស់អាណិកជនចិន ដែលរស់នៅប្រទេសវៀតណាមខាងជើង បានសុំជួបទាក់ទងក្នុងគោលបំណងស្នើសុំមកដឹកនាំគ្រប់គ្រងអាណិកជនចិន នៅក្នុងប្រទេសកម្ពុជា ដោយផ្ទាល់។ តែមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា មិនអនុញ្ញាតឱ្យជួបព្រោះយល់ថា ប្រសិនបើអនុញ្ញាតឱ្យគណៈប្រតិភូចិន នោះ មកគ្រប់គ្រងអាណិកជនចិន នៅក្នុងប្រទេសកម្ពុជា ដោយផ្ទាល់ តាមការស្នើសុំរបស់គេនោះ បានន័យថា បក្សកុម្មុយនិស្តកម្ពុជា មិនមែនជាម្ចាស់ប្រទេសទេ។ សំខាន់ជាងនេះទៅទៀត មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ដឹងច្បាស់ថា គណៈប្រតិភូចិន នោះ មានពួកវៀតណាម ជាអ្នកនៅពីក្រោយខ្នង។

# ៧.២៥ លន់ ណុន រៀបចំផែនការកំចាត់ ទ្រង់សិរិមតៈ



**ទ្រង់សិរិមតៈ និងប្រធានាធិបតីអាមេរិក រីឆាដ និចសុន**

ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានសម្រេចបើកយុទ្ធនាការធ្វើសង្គ្រាមចិត្តសាស្ត្រនៅទូទាំងប្រទេស ដោយប្រមូលសមាជិកសភា សាស្ត្រាចារ្យ និស្សិត បញ្ញវន្ត គ្រូបង្រៀន បង្កើតជាគណៈកម្មការរាប់រយក្រុមឱ្យចុះទៅឃោសនាប្រាប់ប្រជាពលរដ្ឋខ្មែរឱ្យយល់ពីមូលហេតុនៃការទម្លាក់សម្តេចសីហនុ គឺដោយសារព្រះអង្គលក់ជាតិលក់ទឹកដីឱ្យយួនវៀតកុង។ ក្នុងពេលនោះដែរ វរសេនីយ៍ត្រី លន់ ណុន ក៏បានបង្កើត គណៈកម្មការពិសេសមួយ ដាក់ឈ្មោះថា គណៈកម្មការសម្របសម្រួលក្រសួងការពារជាតិ ដែលមានអំណាចធំជាងអគ្គសេនាធិការ និងរដ្ឋាភិបាលទៅទៀត។ គណៈកម្មការសម្របសម្រួលនេះ ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ឧត្តមសេនីយ៍ លន់ នល់ និងមានទីស្នាក់ការនៅក្នុងអគាររបស់សេនាធិការដ្ឋានកងទ័ពអាកាស ដែលនៅទល់មុខអគ្គសេនាធិកាដ្ឋាន (EMG) តាមបណ្តោយមហាវិថីព្រះនរោត្តម នោះដែរ។

របត់នយោបាយ
តែពីរបីខែក្រោយមក ទីស្នាក់ការរបស់គណៈកម្មការនេះ បានផ្លាស់ប្តូរទៅនៅផ្ទះវីឡាថ្មីសន្លាងមួយ ជាកម្មសិទ្ធិរបស់លោក-យាយ ប៉ុម ពាង មាតាក្មេករបស់សម្តេចសីហនុ ដែលស្ថិតនៅសង្កាត់ទឹកល្អក់ វិញ។

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧១ នាយឧត្តមសេនីយ៍ លន់ នល់ ជួបគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាល ត្រូវស្លាប់មួយចំហៀងខ្លួន។ ពេលនោះ បើទោះបីគាត់មានការងាររមមាញឹក និងសំខាន់ៗ យ៉ាងណាក៏ដោយ ក៏ត្រូវចេញទៅព្យាបាលជំងឺ នៅកោះហាវ៉ៃ សហរដ្ឋអាមេរិក មួយរយៈដែរ។ ប្រជាពលរដ្ឋភាគច្រើនដែលនៅតែជឿជាក់ស្មោះស្ម័គ្រលើសម្តេចសីហនុ បាននាំគ្នានិយាយផ្ទន្ទាថា ការស្លាប់មួយចំហៀងខ្លួនរបស់ លន់ នល់ នេះ គឺដោយសារមកពីគាត់ចាញ់សម្បថ និងមានបាបកម្ម ដែលគាត់ក្បត់សម្តេចសីហនុ ធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាច កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

ពេល លន់ នល់ ចេញទៅព្យាបាលជំងឺ នៅកោះហាវ៉ៃ ដោយមានការភ័យខ្លាចទ្រង់ស៊ីសុវត្ថិ សិរិមតៈ ឧបនាយករដ្ឋមន្ត្រី ក្តោបក្តាប់អំណាចតែម្នាក់ឯង និងដឹកនាំប្រទេសឱ្យវិលទៅរករបបរាជានិយមវិញនោះ លន់ ណុន ដែលមិនត្រឹមតែស្អប់ខ្ពើមសម្តេចសីហនុ និងរបបរាជានិយមទេ សូម្បីតែទ្រង់ សិរិមតៈ ដែលជារាជវង្សសំខាន់ម្នាក់ក្នុងការ ផ្តួលរម្លំសម្តេចសីហនុ ក៏គាត់មិនចូលចិត្តដែរនោះ គាត់បានប្រើល្បិចកលជាច្រើនក្នុងបំណងកម្ចាត់ទ្រង់ សិរិមតៈ ចេញពីអំណាច។

លន់ ណុន បានបញ្ជាឱ្យ ថាច់ ជា ជានាយកវិទ្យាល័យភ្នំដូនពេញ ដែលមានដើមកំណើតនៅកម្ពុជាក្រោម ប្រមែប្រមូលបងប្អូនខ្មែរកម្ពុជាក្រោម និងខ្មែរកណ្តាលបង្កើតជាកងពលតូចថ្មើរជើងមួយ និងបានផ្តល់ឋានន្តរសក្តិឱ្យ ថាច់ ជា ជាវរសេនីយ៍ត្រី។ បន្ទាប់មកទៀត ជាវរសេនីយ៍ទោ រហូតក្លាយជារដ្ឋមន្ត្រីក្រសួងអប់រំ និងវប្បធម៌ នៅក្នុងឆ្នាំ១៩៧២។

នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៧១ លន់ ណុន បានបើកអង្គប្រជុំពិសេសមួយដោយបានអញ្ជើញបក្ខពួកមិត្តភក្តិជិតស្និទ្ធរបស់គាត់ជាមន្ត្រីទាហាន ស៊ីវិលជាច្រើននាក់

របត់នយោបាយ

ព្រមទាំងព្រះសង្ឃច្រើនរូបផងដែរ មករួមប្រជុំនៅទីស្នាក់ការគណៈកម្មាធិការ សម្របសម្រួលរបស់ក្រសួងការពារជាតិ ក្នុងគោលបំណង រកមធ្យោបាយការពាររបបសាធារណរដ្ឋខ្មែរឱ្យបានគង់វង្ស និងប្រឆាំងទ្រង់ សិរិមតៈ ដែលគាត់យល់ថា ទ្រង់មានបំណងចង់ស្តារឱ្យមានរបបរាជានិយមឡើងវិញ។



**ថាច់ ឋា**

ដើម្បីបង្ហាញឱ្យឃើញថា ខ្លួនជាអ្នកប្តូរផ្តាច់ក្នុងការការពាររបបសាធារណរដ្ឋខ្មែរនោះ គណៈកម្មាធិការសម្របសម្រួលរបស់ក្រសួងការពារជាតិនេះ បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាដូរឈ្មោះខ្លួនឯង មកជាគណៈកម្មាធិការបដិវត្តន៍វិញ ហើយទីបំផុត ពួកគេបានឯកភាពគ្នាដូរឈ្មោះមកជា គណៈកម្មាធិការសាធារណរដ្ឋបន្តទៀត។

ស្អែកឡើង ថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧១ គណៈកម្មាធិការសាធារណរដ្ឋនេះបានបើកអង្គប្រជុំនៅទីស្នាក់ការរបស់ខ្លួនបន្តទៀត ប៉ុន្តែ វត្តមានអ្នកចូលរួមត្រូវថយចុះ ក្នុងនោះ អ៉ំ ស៊ឹម រដ្ឋមន្ត្រីក្រសួងគមនាគមន៍, ហង្ស ធុនហាក់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សហគមន៍, ឆន សុខុម រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ព្រមទាំងនាយទាហានជាន់ខ្ពស់កងទ័ព

របត់នយោបាយ
ជើងគោក ជើងទឹក និងជើងអាកាសមួយចំនួនទៀត ក៏លែងមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ដោយមិនដឹងមូលហេតុអ្វីពិតប្រាកដ។

គណៈកម្មាធិការសាធារណរដ្ឋនេះ បានជ្រើសតាំងព្រះភិក្ខុធម្មបាល ខៀវ ជុំ ជាអតីតអ្នកតស៊ូខ្មែរសេរីនៅភ្នំដងរែក ជាមនុស្សជិតស្និទ្ធជាមួយ សឺង ង៉ុកថាញ់ ឱ្យធ្វើជាប្រធានគណៈកម្មាធិការសាធារណរដ្ឋ។ ចំណែក លន់ ណុន ត្រូវបានជ្រើសតាំងជាអនុប្រធាន។

គណៈកម្មាធិការសាធារណរដ្ឋនេះ មានភារកិច្ច៤យ៉ាង គឺ៖ ទី១-តាក់តែងកម្មវិធីនយោបាយមួយ, ទី២-កំណត់សកម្មភាពរបស់គណៈកម្មាធិការនេះ ឱ្យបានច្បាស់លាស់, ទី៣-រៀបចំសមាសភាពគណៈកម្មាធិការកណ្តាលមួយ និងសមាសភាពអនុគណៈកម្មាធិការជំនាញផ្សេងៗ ស្ថិតនៅក្រោមការដឹកនាំ របស់គណៈកម្មាធិការ កណ្តាលនោះ និងទី៤-តាក់តែងកម្មវិធីនយោបាយសំខាន់ៗនៅពេលខាងមុខ គឺ៖

ក- កម្ចាត់ឃ្លួនឈ្លានពាន និងអ្នកចូលដៃជើងពួកវា។

ខ- លុបបំបាត់អំពើពុករលួយ អំពើអយុត្តិធម៌ និងសកម្មភាពវិទ្ធង្សនាផ្សេងៗ ក្នុងគោលបំណងស្តាររបបប្រជាធិបតេយ្យ។

គ- បញ្ចប់រាល់សកម្មភាពអនាធិបតេយ្យ។

ឃ-ពង្រឹង និងធ្វើរបបសាធារណរដ្ឋខ្មែរ ឱ្យកាន់តែមានភាពល្អប្រសើរឡើង។

ង- រៀបចំសេដ្ឋកិច្ចជាតិឱ្យរីកចម្រើន ដើម្បីលើកស្ទួយកម្រិតជីវភាពរបស់ពលរដ្ឋឱ្យបានល្អជាងមុន។

ច- ចាត់ចែងបង្កើតការអប់រំឱ្យប្រជាពលរដ្ឋយល់ដឹង ពីរបបសាធារណរដ្ឋនិយមរហូតដល់ពួកគេក្លាយជាកម្លាំងរបស់សាធារណរដ្ឋខ្មែរ។

ឆ- ពង្រីកទំនាក់ទំនងការទូតនៅលើឆាកអន្តរជាតិឱ្យបានខ្លាំងក្លា។

បន្ទាប់មកទៀត នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៧១ លន់ ណុន ក្នុងនាមគណៈកម្មាធិការសាធារណរដ្ឋ បានរៀបចំគណៈប្រតិភូមួយក្រុម រួមមានភិក្ខុធម្មបាល ខៀវ ជុំ, ប៊ុណ្ណ ចន្ទម៉ុល អតីតអ្នកទោសនៅគុកកោះត្រឡាច, វរសេនីយ៍ទោ ថាច់ ជា និងសន ថាត

ជាតំណាងសិស្ស និស្សិត បញ្ញវន្តខ្មែរ ដើម្បីយកសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការសាធារណរដ្ឋ ដែលទើបនឹងបង្កើតឡើងនោះ ទៅជូនទ្រង់សិរិមតៈ ជានាយករដ្ឋមន្ត្រីស្តីទី។

ទ្រង់សិរិមតៈ ទទួលជួបគណៈប្រតិភូគណៈកម្មាធិការសាធារណរដ្ឋ និងបានពិនិត្យមើលលិខិតថ្លែងការណ៍នោះ តាំងពីដើមរហូតដល់ចប់ផងដែរ។ ប៉ុន្តែ ទ្រង់មិននិយាយអ្វីទាំងអស់ ក្រៅតែពីចារនៅលើគែមលិខិតថ្លែងការណ៍នោះ ដោយដាក់ជាសំណួរថា តើសមាសភាពគណៈកម្មាធិការសាធារណរដ្ឋនេះជាអ្វីទៅ? ហើយគេចាត់ចែងរៀបចំបោះឆ្នោតតាមរបៀបណា? ម្យ៉ាងទៀតសួរថា តើគណៈកម្មាធិការសាធារណរដ្ឋនេះ មានតួនាទីអ្វីទៅលើស្ថាប័នទាំងអស់ ដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ននេះ? រួចហើយទ្រង់បានប្រគល់ លិខិតថ្លែងការណ៍នោះទៅឱ្យគណៈកម្មាធិការសាធារណរដ្ឋ យកត្រឡប់ទៅវិញ។



**ភិក្ខុធម្មបាល ខៀវ ជុំ** (**រូបថត កាលប្រជុំខែតុលា ឆ្នាំ១៩៧១**)

ស្អែកឡើង វេលាម៉ោង១១ព្រឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧១ លន់ ណុន បានកោះប្រជុំគណៈកម្មាធិការសាធារណរដ្ឋ ដើម្បីពិភាក្សាគ្នារៀបចំការឆ្លើយតបទៅនឹងសំណួរដែលទ្រង់ សិរិមតៈ បានចារនៅលើគែមលិខិតនោះវិញ។

គណៈកម្មាធិការសាធារណរដ្ឋ បានឯកភាពគ្នារៀបចំពង្រាងចម្លើយមួយ ដើម្បីឆ្លើយតបទៅទ្រង់ សិរិមតៈ វិញ មានខ្លឹមសារថា៖ ទី១-គណៈកម្មាធិការសាធារណរដ្ឋ គឺ

ជាអង្គការជាន់ខ្ពស់មួយ ដែលគ្មានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ក៏ពិតមែន ប៉ុន្តែ វាជាកម្លាំងគ្រឹះសម្រាប់ចាត់ចែងរៀបចំប្រទេសជាតិ ឱ្យមានដំណើរការស្របតាមរបៀបរបបសាធារណរដ្ឋនិយម និងទី២-គណៈកម្មាធិការសាធារណរដ្ឋ មានសិទ្ធិដាក់ចេញនូវគោលការណ៍ សេចក្តីថ្លែងការណ៍ និងការសម្រេចចិត្តផ្សេងៗដោយផ្ទាល់ទៅលើស្ថាប័នរដ្ឋទាំងអស់ ហើយស្ថាប័នទាំងនោះត្រូវតែអនុវត្តតាម។

ទោះបីការឆ្លើយតបដូចខាងលើនេះ ហាក់ដូចជាការគំរាមកំហែងមួយក៏ពិតមែន ក៏ទ្រង់ សិរិមតៈ នៅតែរក្សាភាពស្ងៀមស្ងាត់ មិនមានប្រតិកម្មតបតវិញបន្តិចឡើយ ព្រោះទ្រង់យល់ថា វាជារឿងអត់បានការ។ តែយ៉ាងណា ក៏ទ្រង់មានការប្រុងប្រយ័ត្ន និងតាមដានសកម្មភាពរបស់ លន់ ណុន បន្តទៀតដែរ។



**វរសេនីយ៍ទោ លន់ ណុន មេបញ្ជាការកងពលតូចថ្មើរជើងលេខ១៥**

នៅក្នុងខែមីនា ឆ្នាំ១៩៧១ ដោយឃើញពីទុក្ខវេទនាដែលបង្កឡើងដោយភ្លើងសង្គ្រាមបង្ហូរឈាមខ្មែរគ្នាឯង កាន់តែមានសភាពសាហាវឡើងៗ ពួកបញ្ញវន្តមួយក្រុមជាអតីតនិស្សិតនៅសាលាភូមិន្ទរដ្ឋបាល បានស្រុះស្រួលគ្នាបង្កើតសមាគមមួយឱ្យឈ្មោះថា សម្ព័ន្ធភាពដើម្បីសន្តិភាព ក្នុងគោលបំណងធ្វើការសម្របសម្រួលជាមួយពួកសីហនុនិយម ពួកសាធារណរដ្ឋនិយម និងពួកខ្មែរក្រហម ដើម្បីរកដំណោះស្រាយធ្វើ

របត់នយោបាយ

ឱ្យប្រទេសជាតិមានសុខសន្តិភាពឡើងវិញ។ តែយ៉ាងណា ការបង្កើតសម្ព័ន្ធភាពដើម្បីសន្តិភាពនេះ ក៏មានការយល់ព្រមពីទ្រង់ ស៊ីសុវត្ថិ សិរិមតៈ នាយករដ្ឋមន្ត្រីស្តីទី ខណៈដែល លន់ នល់ ត្រូវចេញទៅព្យាបាលជំងឺស្លាប់មួយចំហៀងខ្លួន នៅសហរដ្ឋអាមេរិកផងដែរ។

ក្រោយបង្កើតសមាជិកសម្ព័ន្ធភាពដើម្បីសន្តិភាព មានមតិមួយចំនួនបានឱ្យដឹងថា សឺង ង៉ុកថាញ់ បានសាកល្បងអូសទាញសម្ព័ន្ធភាពនេះ ដើម្បីទាញយកផលប្រយោជន៍ខាងនយោបាយទៅវិញ។ តែសម្ពន្ធ័ភាពមួយនេះ មិនយល់ព្រមតាមការអូសទាញរបស់សឺង ង៉ុកថាញ់ ឡើយ។ តែមិនយូរប៉ុន្មាន មិនទាន់បានលទ្ធផលអ្វី ស្តីពីការស្វែងរកសន្តិភាពនោះផង សម្ព័ន្ធភាពដើម្បីសន្តិភាពនោះ ក៏ត្រូវរំលាយចោលវិញ ដោយសារមានរឿងអាស្រូវពីបញ្ហាប្រាក់កាស។ ការពិតទៅ តាំងពីភ្លើងសង្គ្រាមឆាបឆេះ ប្រទេសកម្ពុជាពីដំបូងមកម្ល៉េះ ប្រទេសបារាំង បានព្យាយាមធ្វើមេអណ្តើក ឱ្យមានការជួបចរចាគ្នារវាងសម្តេចសីហនុ និងលន់ នល់ ដើម្បីរកដំណោះស្រាយសន្តិភាពឡើងវិញដែរ ប៉ុន្តែសម្តេចសីហនុ បានបដិសេធថា មិនចរចាជាដាច់ខាត។

នៅក្នុងឆ្នាំ១៩៧១នោះដែរ សឺន សាន អតីតប្រធានសភា និងជាឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីតាំងពីសម័យអាណានិគមបារាំង មកនោះ គាត់នៅតែបន្តទំនាក់ទំនងជាមួយ ប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលកំពុងស្ថិតនៅទីក្រុងប៉េកាំង ប្រទេសចិន បន្តទៀត ក្នុងគោលបំណងចង់ឱ្យសម្តេចសីហនុ និងលន់ នល់ ធ្វើការចរចាគ្នា ដើម្បីបញ្ចប់សង្គ្រាមវិនាសកម្មនៅក្នុងប្រទេសដែរ។

ចំណែកទ្រង់ ស៊ីសុវត្ថិ សិរិមតៈ វិញ ក៏បានរៀបចំធ្វើការសម្របសម្រួលយាងសម្តេចសីហនុ ឱ្យវិញត្រលប់មកមាតុប្រទេសវិញដែរ ប៉ុន្តែទ្រង់បានដាក់លក្ខខណ្ឌ មិនឱ្យសម្តេចសីហនុ ធ្វើនយោបាយបន្តទៀតជាដាច់ខាត។

ទន្ទឹមនោះ ពួកមេខ្មែរក្រហម ដែលជាអ្នកដឹកនាំការតស៊ូនៅក្នុងប្រទេស ក៏មិនអនុញ្ញាត ឱ្យព្រះអង្គធ្វើអ្វី ស្រេចតែព្រះទ័យរបស់ព្រះអង្គ ក្នុងការទាក់ទងចរចាជាមួយមេដឹកនាំរបបសាធារណរដ្ឋខ្មែរ នោះដែរ។

របត់នយោបាយ

នៅថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧១ លន់ នល់ ក៏បានវិលត្រលប់មកពីព្យាបាលជំងឺនៅសហរដ្ឋអាមេរិក មកដល់មាតុប្រទេសវិញ តែគាត់មិនបានចាប់អារម្មណ៍នឹងការបង្កើតគណៈកម្មាធិការសាធារណរដ្ឋរបស់ លន់ ណុន ជាប្អូនគាត់នោះទេ។ ផ្ទុយទៅវិញ គាត់បានយកចិត្តទុកដាក់ពិនិត្យ ពង្រាងរដ្ឋធម្មនុញ្ញថ្មីនៃរបបសាធារណរដ្ឋខ្មែរ ដែលតាក់តែងឡើងដោយគណៈកម្មាធិការមួយ ដឹកនាំដោយ អ៊ឹង ម៉ឹង អស់រយៈពេលច្រើនខែមកហើយ។ ដោយសារមិនសូវពេញចិត្តនឹងពង្រាងរដ្ឋធម្មនុញ្ញថ្មីនោះ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៧១ លន់ នល់ បានបង្កើតគណៈកម្មាធិការចម្រុះមួយទៀត ដើម្បីតាក់តែងពង្រាងរដ្ឋធម្មនុញ្ញថ្មីមួយផ្សេងទៀត។

សមាសភាពគណៈកម្មាធិការចម្រុះថ្មីនោះ មានសមាជិក១៥រូប រួមមាន៖ ឡុង បូរ៉េត, អាំង ប៊ុនថៃ, ប៉ាយ ល្មុត, គាំ រ៉េត, នួន យឿន ( អ្នកនិពន្ធសៀវភៅដំណើរឆ្ពោះទៅទិសខាងលិច), តោ ឈុន, សាយ បូរី, សាយ បូរាណ, រស់ ចន្ទ្រាបុត្រ (អ្នកនិពន្ធសៀវភៅសាធារណរដ្ឋខ្មែរ), លាង ហាប់អាន, ហៃល ស៊ុំផា, ដាញ់ សាង, ម៉ា ឡាយខេម និង សោម សុខ។

ដូច្នេះ អ្វីដែល លន់ ណុន សង្ឃឹមថា ការបង្កើតគណៈកម្មាធិការសាធារណរដ្ឋនេះ នឹងអាចកាច់បំបាក់ទ្រង់ សិរិមតៈ បាននោះ វាគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ ព្រោះ លន់ នល់ មិនចូលលេងល្បែងនយោបាយបែបនេះ ជាមួយប្អូនប្រុសគាត់ឡើយ។

ចាប់ពីពេលនោះមក លន់ ណុន ក៏បានចាប់ផ្តើមរៀបចំយុទ្ធសាស្ត្រថ្មីមួយទៀត។ ក្នុងនាមជាមេបញ្ជាការកងពលតូចថ្មើរជើងលេខ១៥នៃរបបសាធារណរដ្ឋខ្មែរ គាត់មិនត្រឹមតែបំពាក់គ្រឿងសព្វាវុធទំនើបៗ និងហ្វឹកហ្វឺនពលទាហានគាត់ ឱ្យចេះក្បួនយុទ្ធសាស្ត្រខ្លាំងក្លាប៉ុណ្ណោះទេ គឺគាត់ថែមទាំងបញ្ជាឱ្យពលទាហានរបស់គាត់ បំពេញបេសកកម្មប្រកបដោយគ្រោះថ្នាក់ក្នុងការកម្ចាត់ទ្រង់ សិរិមតៈ និងបានអូសទាញសិស្សនិស្សិត និងបញ្ញវន្ត ដែលស្រឡាញ់របបសាធារណរដ្ឋ ឱ្យមកប្រឡូកក្នុងល្បែងនយោបាយដ៏ស្មោកគ្រោករបស់គាត់ផងដែរ។

ជាមួយគ្នានោះ គាត់បានឱ្យ រស់ ចន្ទ្រាបុត្រ បង្កើតសមាគមមួយឈ្មោះថា

របត់នយោបាយ
សមាគមអ្នកសាធារណរដ្ឋនិយម និងឱ្យបង្កើតកាសែតមួយទៀតឈ្មោះថា លូតលាស់ ដែលចេញផ្សាយជាភាសាខ្មែរ ផង និងភាសាអង់គ្លេស ផង។

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧១ នាយឧត្តមសេនីយ៍ លន់ នល់ ក្នុងនាមជានាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ក៏បានប្រកាសរំសាយគណៈរដ្ឋមន្ត្រីរបស់គាត់ចោល។ ១២ថ្ងៃ ក្រោយមកទៀត គឺនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧១ គាត់បានប្រកាសសមាសភាពគណៈរដ្ឋមន្ត្រីថ្មីមួយទៀត រួមមាន៖ លន់ នល់ ជានាយករដ្ឋមន្ត្រី, ទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ជានាយករដ្ឋមន្ត្រីប្រតិភូ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ, អ៊ិន តាំ ឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកក្រសួងមហាផ្ទៃ សន្តិសុខ ធម្មការ សម្របសម្រួលកិច្ចការក្រសួងយុត្តិធម៌ កសិកម្ម សាធារណការ និងទេពកោសល្យជនបទ, សុក ឆុង ឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកក្រសួងហិរញ្ញវត្ថុ សម្របសម្រួលកិច្ចការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រៃសណីយ៍ និងទូរគមនាគមន៍, ហង្ស ធុនហាក់ ឧបនាយករដ្ឋមន្ត្រីទី៣ ទទួលបន្ទុកក្រសួងអភិវឌ្ឍន៍សហគមន៍ និងសម្របសម្រួល កិច្ចការក្រសួងសាធារណសុខាភិបាល ការងារ សង្គមកិច្ច និងអប់រំជាតិ, ទឹម ងួន ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការនាយករដ្ឋមន្ត្រី, កើត គីលឹម ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការបរទេស, ថៅ សេងអ៊ួ ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងសង្គមកិច្ច ការងារ និងមុខរបរ, ឡុង បូរ៉េត រដ្ឋមន្ត្រីក្រសួងឃោសនាការ, ស សុង រដ្ឋមន្ត្រីក្រសួងកសិកម្ម, ដាញ់ សាង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រាស្រ័យទំនាក់ទំនងជាមួយរដ្ឋសភា, ឃី តាំងលឹម រដ្ឋមន្ត្រីក្រសួងសាធារណការ និងទេពកោសល្យជនបទ, សូ សាត្ថា រដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល, ប៉ាន់ សុធី រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និង វប្បធម៌, ឃឹង ថៃលី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ពាណិជ្ជកម្ម និងផ្គត់ផ្គង់ការ និង ឈាង គីមសួរ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ការបង្កើតរដ្ឋាភិបាលថ្មីនេះ ធ្វើឱ្យ លន់ ណុន កាន់តែអាម៉ាស់ថែមទៀត ព្រោះព្រះអង្គម្ចាស់ សិរិមតៈ ដែលជាគូសត្រូវរបស់គាត់នោះ បានឡើងឋានៈពីឧបនាយករដ្ឋមន្ត្រីទៅជានាយករដ្ឋមន្ត្រីប្រតិភូ និងជារដ្ឋមន្ត្រីការពារជាតិទៀតផង។ ចំណែក លន់ ណុន

របត់នយោបាយ

នៅតែមានឋានន្តរសក្តិត្រឹមតែវរសេនីយ៍ទោ និងជាមេបញ្ជាការកងពលតូចថ្មើរជើងលេខ២១៥ដដែល។ ការតែងតាំងទ្រង់សិរិមតៈ ជានាយករដ្ឋមន្ត្រីប្រតិភូ ដែលតំណែងនេះមិនធ្លាប់មានពីមុនមកនោះ ប្រហែលជាដោយសារ លន់ នល់ មានជំងឺស្លាប់មួយចំហៀងខ្លួន មិនអាចបំពេញតួនាទីជានាយករដ្ឋមន្ត្រីឱ្យបានពេញលេញ ហើយគាត់ក៏មិនទុកចិត្តលើសមត្ថភាពឥស្សរជនណាម្នាក់ផ្សេងទៀត ក្រៅពីទ្រង់ សិរិមតៈ ជាមិត្តភក្តិជិតស្និទ្ធនោះដែរ ទើបគាត់បង្កើតតំណែងនាយករដ្ឋមន្ត្រីប្រតិភូនេះ ដើម្បីឱ្យទ្រង់សិរិមតៈ ដឹកនាំរដ្ឋាភិបាលដោយផ្ទាល់តែម្តង ឯរូបគាត់គ្រាន់តែឈរជាបង្គោល តែប៉ុណ្ណោះ។

# ៧.២៦ របប លន់ នល់ រស់បាន ដោយសារជំនួយអាមេរិក



**នាវាអាមេរិក ដឹកអាវុធ និងរថក្រោះ**M13 **មកដល់កំពង់ផែភ្នំពេញ**

ក្រោយថ្ងៃធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ចេញពីអំណាច រហូតដល់ដំណាច់ឆ្នាំ១៩៧០ សហរដ្ឋអាមេរិក បានផ្តល់ជំនួយយោធា គិតជាទឹកប្រាក់ ចំនួន៣៣លានដុល្លារអាមេរិក និងអាវុធយុទ្ធភណ្ឌជាច្រើនទៀត រួមមាន៖ កាំភ្លើងកាប៉ាប៊ីន (Carabine) ៣០០០០ដើម, កាំភ្លើងវែងធុន ហ្គារ៉ង់ អឹមអង (Garand M1)ចំនួន១២០០០ដើម, កាំភ្លើងធំម៉ាក Howitzer ៦ដើម, វិទ្យុទាក់ទង៤០០គ្រឿង ឧទ្ធម្ភាគចក្រ៦គ្រឿង, រថយន្តយោធាធុនធំ ៦០គ្រឿង និងឧបករណ៍គាំទ្រផ្នែកអាកាសមួយចំនួនទៀត។

នៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧១ សភាសហរដ្ឋអាមេរិក បានអនុម័តយល់ព្រមឱ្យរដ្ឋាភិបាលអាមេរិក ផ្តល់ជំនួយដល់របបសាធារណរដ្ឋខ្មែរ ផ្នែកយោធាគិតជាទឹកប្រាក់សរុបចំនួន៨៥លានដុល្លារអាមេរិក, ផ្នែកសេដ្ឋកិច្ច ចំនួន៧០លានដុល្លារអាមេរិក និងសម្រាប់ការចំណាយផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់របស់រដ្ឋាភិបាល សាធារណរដ្ឋខ្មែរ ចំនួន១០០លានដុល្លារអាមេរិក។ ជាមួយគ្នានោះដែរ រដ្ឋាភិបាលអាមេរិក យក

របត់នយោបាយ
នាវាល្បាតពីកំពង់ផែទីក្រុងព្រៃនគរ ចំនួន៨គ្រឿង មកប្រគល់ឱ្យកងនាវាចរណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បន្ថែមទៀត។

នៅយប់ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧១ កងកុម្ម៉ង់ដូពិសេសដាក់កុង ( Dac Cong) របស់កងទ័ពវៀតកុង-វៀតណាមខាងជើង ចំនួន១៤៧នាក់ បានឆ្លងកាត់ខ្សែត្រៀមទាហានយោធភូមិភាគពិសេស ដែលជាខ្សែក្រវាត់ការពារទីក្រុងភ្នំពេញ យ៉ាងសម្ងាត់បំផុត។ រួចពួកគេបានបំបែកគ្នាជា៦ក្រុម ដែលភាគច្រើនប្រដាប់ដោយកាំភ្លើងអាកា៤៧ ( AK-47 ) និងគ្រាប់រ៉ុក្កែតប្រឆាំងរថក្រោះអ៊ែរប៉េហ្សេ-៧ Rocket-Propelled Grenade7 ( RPG-7 )។ លុះវេលារំលងអធ្រាត្រឈានចូលថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧១ ពួកគេក៏ចាប់ផ្តើមបើកការវាយឆ្មក់យ៉ាងអង់អាចក្លាហានទៅលើអាកាសយានដ្ឋានពោធិ៍ចិនតុង។

ដំបូង ពួកគេបានបើកវាយប្រហារនៅក្បែរអាកាសយានដ្ឋានស៊ីវិល, មជ្ឈមណ្ឌលដឹកជញ្ជូនកងទ័ព និងឃ្លាំងគ្រាប់រំសេវមួយ។ បន្ទាប់មក ពួកគេបានកាត់របងលួសបន្លាសម្រុកចូលទៅក្នុងបរិវេណអាកាសយានដ្ឋានយោធា ដែលនៅជាប់អាកាសយានដ្ឋានស៊ីវិលនោះដែរ។

តាមរបាយការណ៍របស់កងទ័ពសាធារណរដ្ឋខ្មែរ និងអាមេរិក បានឱ្យដឹងថា នៅក្នុងការវាយប្រហារទៅលើអាកាសយានដ្ឋានពោធិ៍ចិនតុង នាយប់ថ្ងៃទី២១ ឈានចូលថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧១នោះ យន្តហោះសរុប ចំនួន៦៩គ្រឿង ត្រូវបានកងទ័ពវៀតកុង-វៀតណាមខាងជើង បំផ្លាញស្ទើរតែទាំងអស់។ ជាមួយគ្នានោះ មនុស្សចំនួន៣៩នាក់បានបាត់បង់ជីវិត និង១៧០នាក់ ផ្សេងទៀត រងរបួស។ តែក្នុងចំណោមអ្នកស្លាប់ និងរបួសនោះ ពុំមានអាកាសយានិកណាម្នាក់ទេ។

ដោយឡែក ខាងកងទ័ពវៀតកុង-វៀតណាមខាងជើង វិញ បានអះអាងថា ពួកគេស្លាប់៧នាក់ និង២នាក់ បាត់ខ្លួន។ តែប្រភពព័ត៌មានផ្សេងទៀតបានផ្សាយថា កងទ័ពវៀតកុង ចំនួន៤នាក់ ត្រូវបាញ់ស្លាប់ក្នុងការវាយឆ្មក់យប់នោះ និង១៥នាក់ទៀតត្រូវបានបាញ់ស្លាប់ នៅពេលពួកគេដកថយឆ្ពោះទៅថ្លង ស្រុកអមលាំង វិញ។ ក្រោយការវាយប្រហារនោះ អាមេរិក បានចាប់ផ្តើមផ្គត់ផ្គង់កងទ័ពអាកាសខ្មែរឡើងវិញយ៉ាង

របត់នយោបាយ
ឆាប់រហ័ស ជាមួយនឹងឧបករណ៍ថ្មីៗ ហើយសន្តិសុខនៅជុំវិញតំបន់អាកាសយានដ្ឋានពោធិ៍ចិនតុង ត្រូវបានរឹតបន្តឹង។



**យន្តហោះ និងឧទ្ធម្ភាគចក្រ ដែលពួកវៀតកុងចូលមកបំផ្លាញ**

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧១ នោះដែរ នៅទីក្រុងប៉េកាំង សម្តេចសីហនុ បានផ្ញើសារទូរលេខជាលើកទី១៦ ទៅជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយបានប្រកាសថា កងទ័ពរណសិរ្សរួបរួមជាតិ របស់ព្រះអង្គបានវាយរំដោះ និងកាន់កាប់ទឹកដីបាន២ភាគ៣នៃប្រទេសកម្ពុជា ហើយ និងកំពុងបើកការវាយប្រហារ ទៅលើទីក្រុងភ្នំពេញ ទៀតផង។

សារទូរលេខដដែល បានបន្តថា ដោយសារការរួបរួមសាមគ្គីជាមួយប្រជាជន លាវ និងវៀតណាមជាបងប្អូន រណសិរ្សរួបរួមជាតិកម្ពុជា នឹងទទួលជោគជ័យលើពួកសត្រូវ និងរុញច្រានពួកចក្រពត្តិអាមេរិក និងបរិវារឱ្យចេញអស់ពីឥណ្ឌូចិន ជាស្ថាពរជាក់ជាមិនខាន។ ពេលនោះដែរ វិទ្យុលួចលាក់របស់ពួកវៀតកុង-វៀតណាមខាងជើង ក៏បានធ្វើការផ្សព្វផ្សាយ ពីការវាយប្រហាររបស់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា នៅទីតាំងសមរភូមិនានា ដែលនៅជុំវិញទីក្រុងភ្នំពេញ ផងដែរ។ រដ្ឋាភិបាលក្រុងហាណូយ ក៏បានប្រកាសថា ខ្លួននឹងអនុវត្តតាមសេចក្តីថ្លែងការណ៍រួមរបស់សន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិន និងប្តេជ្ញាចិត្តបង្កើនការប្រយុទ្ធប្រឆាំងនឹងពួកឈ្លានពានអាមេរិក ព្រមទាំងប្តេជ្ញារក្សាសាមគ្គីភាព ជាមួយប្រជាជនកម្ពុជា ជាបងប្អូន ដើម្បីតស៊ូប្រយុទ្ធរហូតទទួលបាន

របត់នយោបាយ

ជ័យជម្នះទាំងស្រុង និងជាស្ថាពរ។

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧១ កាសែតឡឺម៉ុងដ៍ របស់បារាំង បានចុះផ្សាយថា ពាក់កណ្តាលនៃកងទ័ពវៀតណាមខាងត្បូង ដែលមានចំនួន៥៣០០នាក់ កំពុងធ្វើប្រតិបត្តិការសឹករួមគ្នាជាមួយកងទ័ពនៃរបបសាធារណរដ្ឋខ្មែរ នៅតាមបណ្តោយផ្លូវជាតិលេខ៤ ពីទីក្រុងភ្នំពេញ ទៅទីក្រុងកំពង់សោម ត្រូវបានដកថយទៅប្រទេសវៀតណាមខាងត្បូង វិញ។ ចំណែកកងទ័ពនៃរបបសាធារណរដ្ឋខ្មែរ វិញ ក៏ត្រូវបញ្ជាឱ្យដកថយមកការពារទីក្រុងភ្នំពេញ វិញដែរ។ បញ្ហានេះ បានបញ្ជាក់ច្បាស់ពីការខ្វះកម្លាំងទាហាននៃរបបសាធារណរដ្ឋខ្មែរ ដើម្បីធ្វើការទប់ទល់ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង និងកងទ័ពខ្មែរក្រហម។





**កងទ័ពវៀតណាមខាងត្បូង នៅផ្លូវជាតិលេខ៤**

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧១ រដ្ឋាភិបាលអាមេរិក បានផ្តល់ជំនួយរថក្រោះម៉ាកអឹម១១៣ (M113) ចំនួន២៥គ្រឿង ដោយដឹកតាមនាវាធុនធំពីកំពង់ផែក្រុងព្រៃនគរ ឡើងតាមទន្លេមេគង្គឆ្ពោះមកកំពង់ផែក្រុងភ្នំពេញ។ បន្ទាប់មកទៀត រដ្ឋាភិបាលអាមេរិក បានផ្តល់ជំនួយជាយន្តហោះចម្បាំងម៉ាកតេ.២៨ (T.28) ចំនួន៦គ្រឿងទៀត ដល់កងអាកាសចរណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ផងដែរ។

ជាមួយនឹងការផ្តល់ជំនួយខាងលើនេះដែរ សហរដ្ឋអាមេរិក ក៏បានបង្កើនចំនួនបុគ្គលិក ដែលបម្រើការងារនៅក្នុងស្ថានទូតរបស់ខ្លួនកាន់តែច្រើនឡើងៗ។ ក្នុងខែមេសា ឆ្នាំ១៩៧០ បុគ្គលិកស្ថានទូតអាមេរិក ប្រចាំនៅក្រុងភ្នំពេញ មានចំនួនតែ១១នាក់


រថក្រោះអាមេរិក ពេលមកកំពង់ផែភ្នំពេញ

ប៉ុណ្ណោះ។ លុះមកដល់ខែមីនា ឆ្នាំ១៩៧១ បានកើនឡើងដល់ចំនួន៩១នាក់ ហើយនៅក្នុងខែតុលា ឆ្នាំ១៩៧១ ដដែលនោះ បានកើនឡើងដល់១៣៧នាក់។ ចំណែក មន្ត្រីយោធាអាមេរិក ដែលបម្រើការងារនៅក្នុងប្រទេសកម្ពុជា វិញ នៅដើមឆ្នាំ១៩៧២ មានចំនួន៩៧នាក់ ក្នុងនោះ ៦២នាក់ ជាក្រុមបែងចែកសម្ភារសឹក។

ក្រៅពីជំនួយរបស់សហរដ្ឋអាមេរិក នៅក្នុងខែមិថុនា ឆ្នាំ១៩៧១ រដ្ឋាភិបាលអូស្ត្រាលី ដែលជាសម្ព័ន្ធមិត្ត បានផ្តល់ជំនួយដល់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ជាទឹកប្រាក់ចំនួន៥០០០០០ ដុល្លារអូស្ត្រាលី បន្ថែមទៀតពីលើការផ្តល់ឱ្យលើកមុនចំនួន៦០០០០០ដុល្លារអូស្ត្រាលី។ បន្ទាប់មកទៀត នៅក្នុងខែកញ្ញា ឆ្នាំ១៩៧១ រដ្ឋាភិបាល អូស្ត្រាលី បានផ្តល់ជំនួយជាសម្ភារយោធា គិតជាទឹកប្រាក់ចំនួន២០០០០០០ដុល្លារអូស្ត្រាលី បន្ថែមទៀត។ ជាមួយគ្នានោះ រដ្ឋាភិបាលអូស្ត្រាលី ក៏បានបញ្ជូនពួកយោធាចារ្យ (គ្រូបង្ហាត់ជំនាញខាងកងទ័ព) ឱ្យមកជួយបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រដល់ទាហានសាធារណរដ្ឋខ្មែរ នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនកងទ័ពរបស់សហរដ្ឋអាមេរិក នៅភូក តូយ (Phuc Toy) ក្នុងប្រទេសវៀតណាមខាងត្បូង ទៀតផង។ ក្រៅពីនេះ របបសាធារណរដ្ឋខ្មែរ ក៏បានទទួលជំនួយផ្សេងៗ ទៀត ពីប្រទេសនូវែលសេឡង់, ជប៉ុន, ម៉ាឡេស៊ី, និងថៃ ផងដែរ។

តាមរយៈការផ្តល់ជំនួយរបស់ភ្នាក់ងារអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ក្រសួងការពារជាតិអាមេរិក មានយុទ្ធសាស្ត្រពង្រីក និងពង្រឹងទាហានជើងគោករបបសាធារណរដ្ឋខ្មែរ ឱ្យបានចំនួន១៥ម៉ឺននាក់ និងបណ្តុះបណ្តាលទាហានឆត្រយោង១៥ម៉ឺននាក់ ទៀត ដោយបានរាប់រយនាក់ ឱ្យទៅហ្វឹកហាត់នៅសហរដ្ឋអាមេរិក, ឥណ្ឌូនេស៊ី, ថៃ, លាវ និងវៀតណាមខាងត្បូង។

របត់នយោបាយ

នៅចុងខែមីនា ឆ្នាំ១៩៧១ តុលាការសឹកនៅក្រុងភ្នំពេញ បើកសវនាកជំនុំជម្រះសំណុំរឿងរបស់ទ្រង់ នរោត្តម រណឫទ្ធិ, ទ្រង់ នរោត្តម នរទីបោ (នរ៉ាទីប៉ូ), ម្ចាស់ក្សត្រិយ៍ នរោត្តម បុទុមបុប្ផា ជាបុត្រាបុត្រីរបស់សម្តេចសីហនុ ពីបទផ្តល់ប្រាក់កាសក្នុងការបង្កើតចលនាមួយ ដើម្បីធ្វើវិទ្ធ្វេទកម្មនយោបាយប្រឆាំងរបបសាធារណរដ្ឋខ្មែរ តាមការឆ្លើយដាក់របស់ជនជាប់ចោទ១១នាក់ ដែលកម្លាំងសមត្ថកិច្ចចាប់ខ្លួនកាលពីប៉ុន្មានថ្ងៃមុន។ ជាមួយគ្នានោះ តុលាការសឹកបានចោទប្រកាន់ទ្រង់ នរោត្តម រណឫទ្ធិ, ទ្រង់ នរោត្តម នរទីបោ (នរ៉ាទីប៉ូ), ម្ចាស់ក្សត្រិយ៍ នរោត្តម បុទុមបុប្ផា ថា ជាអ្នកនៅពីក្រោយខ្នងការគប់គ្រាប់បែកចូលស្ថានទូតអាមេរិក កាលពីថ្ងៃអង្គារទី០១ ខែធ្នូ ឆ្នាំ១៩៧០ និងបំផ្ទុះគ្រាប់បែកនៅក្នុងរោងភាពយន្តបណ្តាលឱ្យមនុស្សស្លាប់ជាង២០នាក់។



**នរោត្តម បុទុមបុប្ផា, នរោត្តម នរទីបោ(នរ៉ាទីប៉ូ) និងនរោត្តម រណឫទ្ធិ**

នៅចំពោះមុខតុលាការសឹក ទ្រង់រណឫទ្ធិ បានឆ្លើយបដិសេធនូវការចោទប្រកាន់របស់ស្នងការរដ្ឋាភិបាល និងការឆ្លើយដាក់របស់ជនជាប់ចោទទាំង១១នាក់នោះដាច់អហង្ការ។

ទ្រង់រណឫទ្ធិ បញ្ជាក់ប្រាប់តុលាការថា ខ្លួនមិនដែលស្គាល់ជនទាំង១១នាក់នោះទេលើកលែងតែម្នាក់ជាកម្មករជាក់ស៊ីក្លូ ដែលតែងតែទៅដឹកចង្ហាន់របស់ទ្រង់យកទៅប្រគេនព្រះសង្ឃ នៅដំណាក់ម្ចាស់ក្សត្រិយ៍ កន្និដ្ឋា រស្មីសោភ័ណ។ ប៉ុន្តែការស្គាល់នេះគឺស្គាល់ដោយគ្រាន់តែបានឃើញមុខរាល់ថ្ងៃប៉ុណ្ណោះ តែមិនបានប្រាស្រ័យទាក់ទងអ្វី

របត់នយោបាយ

ឱ្យជិតស្និទ្ធទេ។

ចំពោះការឆ្លើយដាក់របស់ជនជាប់ចោទទាំង១១នាក់ ដែលថា ទ្រង់ជាអ្នកផ្ដើមគំនិត និងជាអ្នកផ្គត់ផ្គង់ក្នុងការធ្វើវិច្ឆេទកម្មនយោបាយនោះ ទ្រង់រណឫទ្ធិ បានឆ្លើយបដិសេធថា ទ្រង់មិនបានដឹងអ្វីទាល់តែសោះ។ ទ្រង់បានសម្អាងថា ចាប់តាំងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧០ មកម្ល៉េះ ក្រសួងសន្តិសុខជាតិបានចាត់ភ្នាក់ងារឱ្យទៅតាមដាន និងឃ្លាំមើលសកម្មភាពរបស់ទ្រង់ជាអចិន្ត្រៃយ៍ ដូច្នេះតាំងពីពេលនោះមកទ្រង់មានលទ្ធភាពឯណានឹងធ្វើបែបនេះកើត?



**ទិដ្ឋភាពស្ថានទូតអាមេរិក ក្រោយគប់គ្រាប់បែកចូល កាលពីថ្ងៃអង្គារទី០១ ខែធ្នូ ឆ្នាំ១៩៧០**

ទ្រង់រណឫទ្ធិ ឆ្លើយបដិសេធបន្តថា ចំណែកជនទាំង១១នាក់ ដែលឆ្លើយនៅចំពោះមុខប៉ូលិសថា ពួកគេបានប្រាស័យទាក់ទងជាមួយទ្រង់នៅផ្ទះរបស់ទ្រង់នោះ តើអាចធ្វើទៅកើតដែរឬទេ? បើភ្នាក់ងារសន្តិសុខនៅចាំយាមតាមដាន និងឃ្លាំមើលយ៉ាងមធ្យ័តបំផុតនោះ?។ ទោះបីយ៉ាងណា ក៏តុលាការសឹកបានកាត់ទោសឱ្យទ្រង់រណឫទ្ធិ និងទ្រង់នរទីបោ (នរ៉ាទីប៉ូ) ក្នុងម្នាក់ៗដាក់ពន្ធនាគារ៥ឆ្នាំដែរ។

លុះដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧១ កាសែតអេភី (AP) របស់សហរដ្ឋអាមេរិក បានចុះផ្សាយថា ព្រះរាជបុត្រាទាំងពីរ របស់សម្ដេចនរោត្តម សីហនុ គឺទ្រង់រណឫទ្ធិ អាយុ២៧ឆ្នាំ និងប្អូនប្រុសបង្កើតរបស់ទ្រង់ គឺព្រះអង្គម្ចាស់ នរទីបោ ជាអ្នកដែលត្រូវ

របត់នយោបាយ ស្នងរាជសម្បត្តិបន្តពីសម្តេចសីហនុ ត្រូវបានតុលាការសឹកនៅរាជធានីភ្នំពេញ សម្រេចដោះលែងវិញហើយនៅថ្ងៃនេះ ក្រោយពីរកមិនឃើញថា មានជាប់ពាក់ព័ន្ធក្នុងការវាយប្រហារភេរវកម្ម គប់គ្រាប់បែកចូលស្ថានទូតអាមេរិក កាលពីថ្ងៃអង្គារទី០១ ខែធ្នូ ឆ្នាំ១៩៧០ និងបំផ្ទុះគ្រាប់បែកនៅក្នុងរោងភាពយន្តបណ្តាលឱ្យមនុស្សស្លាប់ជាង២០នាក់នោះ។

មុនមានព្រឹត្តិការណ៍រដ្ឋប្រហារ ឆ្នាំ១៩៧០ មូលដ្ឋានកងទ័ពអាកាសសំខាន់មានទីតាំងនៅជាប់អាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង មានយន្តហោះទម្លាក់គ្រាប់បែកធុនតេ.២៨(T.28) ជាង១០គ្រឿង, ឧទ្ធម្ភាគចក្រជាង១០គ្រឿង, យន្តហោះដឹកជញ្ជូនធុនដេសេ (DC) ជាង១០គ្រឿង និងយន្តហោះឈ្លបយកការណ៍អិល.១៩ (L-19) ប្រហែល២-៣គ្រឿង ប៉ុណ្ណោះ។

ក្រោយពេលមានសង្គ្រាមប៉ុន្មានខែ សហរដ្ឋអាមេរិក ក៏បានផ្តល់ជំនួយជាយន្តហោះទម្លាក់គ្រាប់បែកធុន អេ.៣៧ (A37) និងយន្តហោះដឹកជញ្ជូនធុនធំ សេ-១៣០ (C.130) ជាច្រើនគ្រឿងទៀត។

នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧២ ប្រទេសអូស្ត្រាលី បានផ្តល់យន្តហោះដឹកជញ្ជូនសេ-៤៧ (C-47) ចំនួន៦គ្រឿង។ ជាមួយគ្នានោះអូស្ត្រាលី ក៏បានទទួលយកនិស្សិតអាកាសចរណ៍ខ្មែរ មួយចំនួនឱ្យទៅហ្វឹកហ្វឺននៅសាលាយោធាអូស្ត្រាលីផងដែរ។



**អូស្ត្រាលី បានផ្តល់យន្តហោះដឹកជញ្ជូនសេ-៤៧ (C-47) ចំនួន៦គ្រឿង**

របត់នយោបាយ

ក្រៅពីមូលដ្ឋានកងទ័ពអាកាសនៅពោធិ៍ចិនតុង របបសាធារណរដ្ឋខ្មែរ ក៏មានមូលដ្ឋានកងទ័ពអាកាសមួយទៀត នៅបែកចាន ខេត្តបាត់ដំបង។ ប៉ុន្តែ មូលដ្ឋានកងទ័ពអាកាសនៅបែកចាននោះ គ្រាន់តែជាមូលដ្ឋានបន្ទាប់បន្សំប៉ុណ្ណោះ។

ចំណែកកងទ័ពជើងទឹក មានមូលដ្ឋានសំខាន់ៗ២ គឺមួយនៅមាត់ទន្លេមេគង្គ ត្រង់មុំខាងត្បូងវត្តសិរីគៀនឃ្លាំង ជ្រោយចង្វា និងមួយកន្លែងទៀតនៅរាម ក្រុមកំពង់សោម។

កងទ័ពជើងទឹកនេះ មាននាវាចម្បាំងធុនធំ ដែលបន្សល់តាំងពីសង្គ្រាមលោកលើកទី២ ចំនួន២គ្រឿង, ស្រឡាងដឹកជញ្ជូនកងទ័ពជាង១០គ្រឿង និងនាវាវីដែតជាប្រភេទនាវាប្រដេញធុនតូច ចំនួនជាង២០គ្រឿង ប៉ុណ្ណោះ។ នាវាទាំងនេះបំពេញតួនាទីជាអ្នកអមការពារក្បួននាវាដឹកស្បៀង និងទំនិញផ្សេងៗតាមទន្លេមេគង្គ និងទន្លេសាប ពិសេសអមការពារនាវាធំៗ ដែលដឹកទំនិញឆ្លងកាត់ប្រទេសវៀតណាម ពីព្រំដែនក្អមសំណ ឡើងមកកំពង់ផែភ្នំពេញ។

ដើមឆ្នាំ១៩៧០ កងទ័ពជើងទឹក មានតែប្រមាណ២០០នាក់ ប៉ុណ្ណោះ។ នៅចុងឆ្នាំ១៩៧២ ចំនួនកងទ័ពជើងទឹកនេះ បានកើនឡើងដល់២០០០នាក់។

ដើម្បីបង្កើនចំនួនពលទាហានរបស់ខ្លួនឱ្យបានច្រើនថែមទៀត នាយអគ្គសេនាធិការកងយោធពលខេមរជាតិ បានអនុញ្ញាតឱ្យមន្ត្រីរាជការ, សាស្ត្រាចារ្យ, គ្រូបង្រៀននៅទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួនទៀត ចូលបម្រើក្នុងជួរកងទ័ពដោយស្ម័គ្រចិត្ត ហៅថា នាយទាហានអាស៊ីមីឡេ (Assimile) និងផ្តល់ឋានន្តរសក្តិសមស្របតាមតួនាទីមុខងារ របស់ពួកគេម្នាក់ៗផងដែរ។ អ៊ិន តាំ ជាប្រធានរដ្ឋសភា ចូលបម្រើក្នុងជួរកងទ័ពដោយស្ម័គ្រចិត្តទទួលបានឋានន្តរសក្តិជាឧត្តមសេនីយ៍ត្រី, ឱក សឿម ជាតំណាងរាស្ត្រមណ្ឌលសំរោង ខេត្តឧត្តរមានជ័យ, អ៊ិន យ៉ុង ជាតំណាងរាស្ត្រនៅមណ្ឌលគគីរសោម ខេត្តស្វាយរៀង ជាអតីតអ្នកចម្រៀងអាយ៉ៃដ៏ល្បីល្បាញម្នាក់ និងតំណាងរាស្ត្រមួយចំនួនទៀត ចូលបម្រើក្នុងជួរកងទ័ពដោយស្ម័គ្រចិត្តដែរនោះ ទទួលបានឋានន្តរសក្តិជាវរសេនីយ៍ត្រី (ស័ក្តិ៤)។ អ៊ិន យ៉ុង បានក្លាយជាមេបញ្ជាការកងវរសេនាតូចថ្មើរជើងលេខ២១៤ (214BC) នៅខេត្តស្វាយរៀង។ គាត់បានដឹកនាំពល

របត់នយោបាយ
ទាហានវាយប្រយុទ្ធស៊ីសាច់ហុតឈាមគ្នា ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង នៅសមរភូមិអូរសម្តី។

មុនឆ្នាំ១៩៧០ អ៊ិន យ៉ុង ជាតំណាងរាស្ត្រមណ្ឌលគគីរសោម ខេត្តស្វាយរៀង បានយកប្អូនប្រុសឈ្មោះ អ៊ិន យ៉េង មកធ្វើជាមួយមិត្តភក្តិម្នាក់ធ្វើការនៅវិទ្យុជាតិ។ ក្រោយមកតាមរយៈចម្រៀងមួយបទមានចំណងជើងថា ឈើកាច់បាភ្នំ អ៊ិន យ៉េង ក៏ចាប់ផ្តើមល្បីឈ្មោះតាំងពីពេលនោះមក។



**យុទ្ធនារី ជាទាហាន របបសាធារណរដ្ឋខ្មែរ**

ចំណែកសិស្ស និស្សិត ក៏ដូចគ្នាដែរ។ សិស្សសាលាណា ដែលមានសញ្ញាបត្រមធ្យមសិក្សាបត្របឋមភូមិ (ឌីប្លូម) ពេលចូលបម្រើក្នុងជួរកងទ័ពត្រូវទទួលឋានន្តរសក្តិជាពលបាលត្រី (ដោយមួយជាន់), សិស្សសាលាណាមានសញ្ញាបត្រមធ្យមសិក្សាបត្រភាគទី១ (បាក់អង) ទទួលបានឋានន្តរសក្តិជាព្រិន្ទបាល (អាត់ហ្សុយដង់), សិស្សសាលាណាមានសញ្ញាបត្រមធ្យមសិក្សាបត្រភាគ២ (បាក់ឌុប) ទទួលបានឋានន្តរសក្តិជាអនុសេនីយ៍ត្រី (សក្តិ១) ហើយនិស្សិតមានបរិញ្ញាបត្រ ទទួលបានឋានន្តរសក្តិចាប់

របត់នយោបាយ

ពីអនុសនីយ៍ទោ (ស័ក្តិ២) និងអនុសនីយ៍ឯក (សក្តិ៣)។ នៅក្នុងចំណោមសិស្ស និស្សិត ដែលបានចូលរួមធ្វើបាតុកម្មវាយកម្ទេចស្ថានទូតវៀតកុង និងវៀតណាមខាងជើង នៅទីក្រុងភ្នំពេញ ថ្ងៃទី១១ ខែមីនា និងធ្វើបាតុកម្មទាមទារឱ្យកមុខអ្នកលក់ទឹកដីឱ្យពួកវៀតកុង-វៀតណាមខាងជើង នៅមុខរដ្ឋសភា ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧០ នោះ មានភាគច្រើនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរទាហានរដ្ឋាភិបាល លន់ នល់។ តែក៏មានមួយចំនួនទៀត បានសម្រេចចិត្តរត់ចូលព្រៃម៉ាគី តាមការអំពាវនាវរបស់សម្តេចសីហនុ ដែរ។



**យុទ្ធនារី សាធារណរដ្ឋខ្មែរ បាញ់កាំភ្លើងយន្តM38 នៅសមរភូមិតាំងគោក (ចេនឡាទី២) ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧១**

---

# ៧.២៧ កងទ័ពវៀតកុង ចាប់អ្នកការសែតខ្មែរ និងបរទេស៦នាក់



**អ្នកស្រី ខេត វីប** ( Kete webb )

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ភ្លាម ភ្លើងសង្គ្រាមចាប់ផ្តើមកើតមានដំបូង គង់ វន បម្រើការងារជាអ្នកបកប្រែឱ្យអ្នកយកព័ត៌មានយូភីអាយ( UPI ) របស់សហរដ្ឋអាមេរិក ទទួលបានប្រាក់កម្រៃក្នុងមួយថ្ងៃ១៥ដុល្លារសហរដ្ឋអាមេរិក។ តែដោយសារនៅយប់មួយអ្នកយកព័ត៌មានយូភីអាយ( UPI ) ទទួលព័ត៌មានថា ពួកទាហាន លន់ នល់ បាញ់គ្រាប់ប្លោងសម្លាប់ជនជាតិវៀតណាម ក្នុងជំរំមួយនៅទីប្រជុំជនប្រសូត ក្នុងខេត្តស្វាយរៀង ព្រឹកឡើង អ្នកយកព័ត៌មានយូភីអាយ ( UPI ) នោះបាននាំគាត់ចុះទៅយកព័ត៌មានដល់កន្លែងកើតហេតុផ្ទាល់តែម្តង។

អ្នកយកព័ត៌មានអាមេរិករូបនេះបានឱ្យគាត់រាប់ចំនួនសាកសពជនជាតិវៀតណាម តើសរុបទាំងអស់មានចំនួនប៉ុន្មាន? ពេលនោះ គាត់ឃើញសាកសពជនជាតិវៀតណាម

របត់នយោបាយ

នៅដង្ហើមផ្ដិកៗនៅឡើយ ហើយសាកសពខ្លះត្រូវដាច់ជាពីរ ជាបីកំណាត់ ខ្លះទៀតពោះវៀនហើរទៅទើរនៅចុងឫស្សី។ គាត់រាប់បានជាង១០០ ស្រាប់តែមានអាការៈស្លុតរន្ធត់វិលមុខខ្លាំង ក៏ប្រាប់អ្នកយកព័ត៌មានអាមេរិក នោះថា ថ្ងៃនេះ គាត់មិនយកប្រាក់កម្រៃទេ ព្រោះគាត់មិនអាចស៊ូទ្រាំរាប់សាកសពទាំងនោះឱ្យអស់បានទេ។ អ្នកយកព័ត៌មានអាមេរិកនោះ ប្រាប់គាត់ថា មិនបញ្ហាទេ អ្នកឯងរកកន្លែងសម្រាកចុះ រួចអ្នកយកព័ត៌មានរូបនោះ ក៏ដើររាប់ខ្លួនឯងដោយជើងគាត់មានប្រឡាក់ឈាមដល់ក្បាលជង្គង់។ ដោយឡែក នៅកំពង់ចម្លងអ្នកលឿង គាត់ឃើញសាកសពជនជាតិវៀតណាម ជាច្រើនអណ្តែតទឹកហើមស្ពឹងៗពេញទន្លេ។ ឃើញដូច្នេះ គាត់មានការសង្វេគខ្លាំងណាស់ ព្រោះសាសន៍ឯងសាសន៍គេ ជាមនុស្សដូចតែគ្នា។

ជាមួយគ្នានោះដែរ អ្នកយកព័ត៌មានកាសែតយូភីអាយ តែងតែនាំគាត់ចុះទៅយកព័ត៌មានផ្ទាល់ដល់សមរភូមិវាយប្រយុទ្ធគ្នាក្តៅគគុក។ គាត់ខ្លាចមានគ្រោះថ្នាក់ដល់ជីវិត ធ្វើបានតែ៣ខែ គាត់ក៏សុំលាឈប់ រួចទៅធ្វើជាអ្នកបកប្រែឱ្យអង្គភាពយកព័ត៌មានជប៉ុនមួយ ឈ្មោះ នីហុង ដេនប៉ា (Nihon Denpa News) គឺជាអង្គភាពមួយដើរយកព័ត៌មានពីសង្គ្រាមនៅកម្ពុជា ទៅលក់ឱ្យកាសែត និងទូរទស្សន៍នៅតាមបណ្តាប្រទេសជឿនលឿន។

នៅក្នុងខែមិថុនា ឆ្នាំ១៩៧១ គង់ វន និងអ្នកកាសែតខ្មែរ និងបរទេសចំនួន៥នាក់ទៀត ក្នុងនោះរួមមាន៖ ១. អៀង ចារូន អ្នកយកព័ត៌មានកាសែតខ្មែរឯករាជ្យ, ២.អ្នកស្រី ខេត វេប (Kete webb) ជនជាតិអូស្ត្រាលី ជាអ្នកឆ្លើយឆ្លងព័ត៌មានយូភីអាយ (UPI), ៣. តូអ៊ីជី ស៊ុយហ្សូគី (Toichi Suzuki) ប្រធានទីភ្នាក់ងារព័ត៌មាន នីហុង ដេនប៉ា (Nihon Denpa News), ៤.មូន ហ្វេស អ្នកយកព័ត៌មានស៊ីប្រាក់កម្រៃតាមអត្ថបទ (អ្នកកាសែត Freeland) និង៥.ឈឹម សារ៉ាត អ្នកបកប្រែ បាននាំគ្នាចុះទៅយកព័ត៌មាននៅពេលកងទ័ពវៀតកុង-វៀតណាមខាងជើង សហការគ្នាជាមួយកងទ័ពខ្មែរក្រហមបើកការវាយប្រហារទាហានឆត្រយោង (ប៉ារ៉ា) ក្រោមបញ្ជាការរបស់វរសេនីយ៍ឯក ស្រី យ៉ា

របត់នយោបាយ
ដើម្បីកាត់ផ្តាច់ផ្លូវជាតិលេខ៤ ត្រង់ចំណុចផ្លូវបំបែកចូលភ្នំគិរីរម្យ ទៅភ្នំពេជ្រនិល។

គង់ វន បានឱ្យដឹងថា កាលនោះ កងទ័ពវៀតកុង-វៀតណាមខាងជើង និងកងទ័ពខ្មែរក្រហម វាយផ្តាច់ខ្សែត្រៀមពួកទាហានឆត្រយោង (ប៉ារ៉ា) ឱ្យដាច់ជាកង់ៗ និងបាញ់កាំងភ្លើងប្លោងជាច្រើន។



**គង់ វន ក្នុងវ័យ ៨៥ឆ្នាំ**

ដោយដឹងថា កងទ័ពវៀតកុង បានវាយកាត់ផ្តាច់កន្ទុយជួរទាហានដែលនៅខាងក្រោយ មិនអាចដើរវិលត្រឡប់មកក្រោយតាមផ្លូវជាតិលេខ៤ វិញបាន ពួកគាត់ក៏បាននាំគ្នាដើរចុះពីផ្លូវជាតិលេខ៤ គេចខ្លួនកាត់ព្រៃ ជួនក្រាបផងលូនផង សំដៅទៅទិសឦសានភ្នំពេជ្រនិល ដើម្បីវាងមករកផ្លូវជាតិលេខ៤វិញ។ តែពួកគាត់ដើរវង្វេងក្នុងព្រៃអស់មួយយប់ដាច់បាយដាច់ទឹក។

លុះព្រឹកឡើងភ្លឺ ស្រាប់តែឃើញកងទ័ពខ្មែរក្រហម មួយក្រុមលើកកាំភ្លើងអាកា.៤៧ ភ្ជង់គំរាមឱ្យលើកដៃឡើងលើ។ គាត់ដើរខាងមុខគេលើកដៃផង ខំនិយាយអង្វរកងទ័ពខ្មែរក្រហម ក្មេងៗ អាយុមិនលើសពី១៦ឆ្នាំ នោះផងថា លោកក្មួយ! ពួកយើងជាអ្នកកាសែតទេ សូមមេត្តាទុកជីវិតពួកយើងផង។ កងទ័ពខ្មែរក្រហម ម្នាក់ទំនងជាមេកង បានស្រែកសន្ធាប់ថា ពួកឯងមកយកការណ៍ឱ្យពួកអាមេរិក និងពួកអាយ៉ង

លន់ នល់ មែនទេ? ត្រៀមធ្វើស្នូលដី (ស្លាប់) ឱ្យហើយទៅ។ គាត់និយាយអង្វរបន្តថា ទេ! ពួកយើងមិនមែនជាអ្នកយកការណ៍ឱ្យពួកអាមេរិក និងពួកអាយ៉ង លន់ នល់ នោះទេ។

តូអ៊ីជី ស៊ុយហ្សូគី ប្រធានទីភ្នាក់ងារព័ត៌មាន នីហុង ដេនប៉ា លើកដៃសំពះ និងព្យាយាមនិយាយអង្វរជាភាសាអង់គ្លេស ដោយមានគាត់ ជួយបកប្រែជាភាសាខ្មែរថា ពួកយើងជាអ្នកកាសែតអព្យាក្រឹត មិនសម្លៀងទៅខាងណាទេ ពួកយើងមកទីនេះ ដើម្បីចង់បានព័ត៌មានពិតនៅលើសមរភូមិតែប៉ុណ្ណោះ។ អ្នកកាសែតស្រីឈ្មោះ ខេត វេប ប្រឹងនិយាយអង្វរថា ពួកយើងមិនមែនមកយកការណ៍អ្វីនោះទេ គឺពួកយើងមកដល់ទីនេះ ដោយសារតែពួកយើងនាំគ្នាគេចពីគ្រាប់កាំភ្លើងប្លោងតែប៉ុណ្ណោះ។



**ទាហានលន់ នល់ នាំគ្នារុញរថយន្តហ្ស៊ីប**
**ឡើងភ្នំគីរីរម្យ (២៦/០៧/១៩៧០)**

ទោះបីជាពួកគាត់ព្យាយាមអង្វរកយ៉ាងណា ក៏កងទ័ពខ្មែរក្រហម ក្មេងៗទាំងនោះមិនស្តាប់ដែរ។ ពួកគេដឹងតែម្យ៉ាង គឺនាំពួកគាត់យកទៅសម្លាប់ចោល។ បន្តិចក្រោយមក ក៏កងទ័ពវៀតកុង-វៀតណាមខាងជើង មួយក្រុម ស្លៀកពាក់ឯកសណ្ឋាន

ពណ៌ស្លឹកឈើ បានមកដល់។ ក្រោយពីសួរនាំរួច កងទ័ពវៀតកុង-វៀតណាមខាងជើង បានស្នើសុំពួកខ្មែរក្រហមក្មេងៗនោះ ឱ្យប្រគល់ពួកគាត់ ឱ្យទៅពួកគេដើម្បីចាត់ការបន្តទៀត។ ក្នុងចំណោមកងទ័ពវៀតកុង-វៀតណាមខាងជើង មួយក្រុមនោះ មានម្នាក់ជាខ្មែរកម្ពុជាក្រោម បានបញ្ជាឱ្យពួកគាត់ដោះស្បែកជើង និងយកខ្សែរលួសមកចងស្លាបសេកយ៉ាងតឹង រួចបណ្តើរពួកគាត់ឆ្ពោះទៅកាន់តំបន់ភ្នំគិរីរម្យ។

ពេលទៅជិតដល់ចង្កេះភ្នំ គាត់ស្រេកទឹកស្ទើរតែខះបំពង់ក។ លុះក្រឡេកឃើញប្រឡាយទឹកមួយ ក៏សុំកងទ័ពវៀតកុង ចុះផឹកទឹកសិន ពួកគេក៏យល់ព្រម។ តែរៀបនឹងឱនផឹកទឹកទៅហើយ ស្រាប់តែឃើញសាកសពទាហាន លន់ នល់ ស្លាប់គរជើងគ្នាក្នុងប្រឡាយនោះ គាត់លែងហ៊ានផឹកទឹកនោះ។ គាត់សន្និដ្ឋានថា សាកសពទាំងនេះជាទាហាននៅក្នុងកងពលតូចលេខ១៣ របស់ទ្រង់ ចន្ទរង្សី ប្រហែលជាបាក់ទ័ព ហើយត្រូវកងទ័ពវៀតកុង ចាប់បានយកមកបាញ់ទម្លាក់ចោលក្នុងប្រឡាយទឹកនេះ។

ពួកគាត់ត្រូវគេបណ្តើរកាត់ព្រៃ ដើរជាន់បន្លា មិនហ៊ានត្អូញត្អែរ មួយម៉ាត់។ ម៉្យាងខះបំពង់ក រកនិយាយមិនចង់រួច ម្នាក់ៗភិតភ័យ និងគិតក្នុងចិត្តថា កងទ័ពវៀតកុងបណ្តើរពួកគាត់យកទៅបាញ់ទម្លាក់ជ្រោះ ក៏មិនដឹង?។

គង់ វន បន្តថា ក្រោយពីត្រូវគេចងបណ្តើរជាខ្សែកាត់ព្រៃអស់រយៈពេល៦ម៉ោង គាត់បោះជំហានឈានជើងទៅមុខលែងរួច ក៏ឱនខ្សឹបប្រាប់ តូអ៊ីជី ស៊ុយហ៊្សូគី ជាមេគាត់ ដែលនៅខាងក្រោយគ្នានោះថា៖ នេះជាលើកទី១នៃជីវិតខ្ញុំ ដែលក្លាយជាឈ្លើយសឹកសង្គ្រាម ខ្ញុំសុំលាអ្នកទាំងអស់គ្នាហើយ ខ្ញុំទៅមុខលែងរួចហើយ ខ្ញុំនឹងឱ្យគេបាញ់សម្លាប់ខ្ញុំនៅទីនេះចុះ!។ តូអ៊ីជី ស៊ុយហ៊្សូគី ដែលបោះជំហានឈានជើងទៅមុខលែងចង់រួចដែរនោះ ប្រាប់គាត់ថា ពីមុនគាត់ធ្លាប់ទៅធ្វើការនៅប្រទេសវៀតណាមខាងជើង ដែរតាមដឹង ពួកហ្នឹងស្គាល់ច្បាប់ស្គាល់វិន័យ មិនចេះតែសម្លាប់មនុស្សផ្តេសផ្តាសទេ។ ម៉្យាងបើពួកគេចង់សម្លាប់ពួកយើង ពួកគេមិនមែនបណ្តើរយើងដល់ទៅ៦ម៉ោងអញ្ចឹងទេ គេមិនសម្លាប់យើងទេ ទ្រាំសិនទៅ...។ ពេលបណ្តើរពួកគាត់ទៅដល់ទីទួលមួយ

របត់នយោបាយ

ស្រាប់តែ អៀង ចារូន អ្នកយកព័ត៌មានឱ្យកាសែតខ្មែរឯករាជ្យ ជំពប់ជើងដួលបណ្ដាលឱ្យខ្សែចំណង ដែលពួកគេចងពួកគាត់មួយខ្សែនោះ ទាញពួកគាត់ឱ្យដួលផ្កាប់មុខទាំងអស់គ្នា។ គាត់នឹកស្មានថា គេច្រានឱ្យដួល ដើម្បីបាញ់សម្លាប់។

បន្ទាប់ពីបណ្ដើរទៅដល់ដើមស្រឡៅធំមួយ មានម្លប់ត្រជាក់ ដោយសារឃើញគាត់មានមាឌធំ សម្បុរខ្មៅ ពួកគេសង្ស័យថា ជាមេទាហាន លន់ នល់ គេបានស្រាយចំណងគាត់ឱ្យចេញពីជួរ រួចបណ្ដើរមកសួរចម្លើយមុនគេ។ មេបញ្ជាការវៀតណាមម្នាក់ស្លៀកពាក់ស៊ីវិល ចេះនិយាយភាសាខ្មែរស្ទាត់ ចាប់ផ្ដើមសួរគាត់ថា អ្នកឯងពាក់ស័ក្តិប៉ុន្មាន? គាត់ឆ្លើយថា ខ្ញុំគ្មានពាក់ស័ក្តិអ្វីទេ។ មេបញ្ជាការកងទ័ពវៀតកុង នោះ ក៏សួរគាត់បន្តថា ចុះពួកអ្នកឯងមករកអ្វីនៅទីនេះ? គាត់ឆ្លើយថា៖ ខ្ញុំជាអ្នកបកប្រែឱ្យជនជាតិជប៉ុន ជាប្រធានក្រុមព័ត៌មាន នីហុង ដេនប៉ា ដែលមកជាមួយគ្នានេះ បើអ្នកឯងមិនជឿខ្ញុំទេ អ្នកឯងចាំស្ដាប់តាមវិទ្យុចុះ យ៉ាងយូរពីរ ឬបីថ្ងៃទៀត គេច្បាស់ជាផ្សាយពីរឿងបាត់ខ្លួនពួកខ្ញុំទាំង៦នាក់ នេះហើយ។ ខ្ញុំមិនមែនជាទាហាន លន់ នល់ ទេ ខ្ញុំហ៊ានស្បថ...។ មេបញ្ជាការនោះប្រាប់ថា៖ កុំបាច់ស្បថអី ខ្ញុំមិនចូលចិត្តរឿងស្បថនេះទេ តែបើខ្ញុំស៊ើបទៅដឹងថា អ្នកឯងជាទាហានរបស់ ចន្ទរង្សី តើអ្នកឯងគិតយ៉ាងម៉េច? គាត់ឆ្លើយភ្លាមថា បាញ់ខ្ញុំចោលទៅចុះ ខ្ញុំមិនកុហកទេ។

មេបញ្ជាការនោះសួរគាត់បន្តថា អ្នកឯងនាំពួកកាសែតបរទេសទៅយកព័ត៌មាននៅសមរភូមិណាខ្លះ? គាត់ប្រាប់ថា គាត់នាំពួកកាសែតបរទេសទៅយកព័ត៌មាន តែនៅសមរភូមិណា ដែលកងទ័ពវៀតកុង វាយឈ្នះពួកទាហាន លន់ នល់ តែប៉ុណ្ណោះ។ (តាមពិត នៅសមរភូមិនោះ កងទ័ពវៀតកុងវាយឈ្នះពិតមែន ពួកទាហាន លន់ នល់ ស្លាប់ច្រើនណាស់)។ ចំណែកសមរភូមិណា ដែលពួកទាហាន លន់ នល់ វាយឈ្នះកងទ័ពវៀតកុង គាត់មិនហ៊ាននិយាយទេ។ លុះសួរចម្លើយរួច គេក៏បណ្ដើរគាត់យកទៅចងភ្ជាប់នៅក្នុងជួរដូចមុនវិញ ហើយស្រាយចំណងគ្នាគាត់ម្នាក់ទៀត យកចេញពីជួរ បណ្ដើរទៅសួរចម្លើយជាបន្តបន្ទាប់។ ក្នុងចំណោមពួកគាត់ មានម្នាក់ឈ្មោះ ឈឹម សារ៉ាត់ ជា

របត់នយោបាយ

អ្នកបកប្រែដូចគាត់ដែរ ភ័យខ្លាចស្លាប់ជាងគេ បានឆ្លើយកុហកថា ខ្លួនជាអ្នកបើករថយន្តឱ្យអ្នកកាសែត យូភីអាយ (UPI) តែអ្នកសួរចម្លើយនោះមិនសួរដេញដោលច្រើនទេ។

មេបញ្ជាការវៀតណាម ជាអ្នកសួរចម្លើយនោះ ប្រាប់គាត់ថា គេជាជនជាតិវៀតណាម តែបានមករស់នៅក្នុងទីក្រុងភ្នំពេញ និងបានរៀនភាសាខ្មែរ រយៈពេលប្រហែល១០ឆ្នាំ។



**រថក្រោះ**M113 **របស់កងពលលេខ១៣ ត្រូវវៀតកុងបាញ់កម្ទេច**

ចុងក្រោយពួកវៀតណាម បានឱ្យទឹកពួកគាត់ផឹកផ្ញើមបំពង់ក រួចបណ្ដើរចុះពីចង្កេះភ្នំគិរីរម្យ ក្រោមស្នូរគ្រាប់កាំភ្លើងធំ១១៥មិល្លីម៉ែត្រ របស់ទាហានរបស់ទ្រង់ ចន្ទរង្សី បាញ់ប្លោងចេញពីក្នុងបន្ទាយដោះកញ្ជរខាងកើត ទៅរកភ្នំគិរីរម្យ ឆ្លើយឆ្លងគ្នាជាមួយនឹងគ្រាប់កាំភ្លើងត្បាល់របស់កងទ័ពវៀតកុង និងខ្មែរក្រហម បាញ់តបតទៅវិញ។ ខាងទាហាន លន់ នល់ មានយន្តហោះតេ.២៨ (T.28) និងយន្តហោះអែហ្វ.១០៥ (F.105) យន្តហោះអែហ្វ.១១១(F.111) របស់អាមេរិក ជួយអន្តរាគមន៍ទម្លាក់គ្រាប់បែកលាន់កក្រើកមេឃ។ ជួនកាល មានគ្រាប់ប្លោងធ្លាក់មកក្បែរពួកគាត់ ពួកវៀតណាម ប្រានពួកគាត់ឱ្យចូលទៅក្នុងលេណដ្ឋាន។ ពួកគាត់នឹកស្មានថា ពួកគេនឹងបាញ់ពួកគាត់ឱ្យងាប់នៅក្នុងលេណដ្ឋាននោះជាមិនខាន។ តែតាមពិត គេប្រានពួកគាត់ឱ្យចូលទៅក្នុងលេណដ្ឋាន គឺដើម្បីបញ្ចៀសឱ្យផុតពីអម្បែងគ្រាប់ប្លោងសោះ។

របត់នយោបាយ

ទីបំផុត គេបណ្តើរពួកគាត់ទៅដល់ទីតាំងមួយទៀត ក៏ស្រាយចំណងចេញ និងឱ្យទទួលទានបាយជាមួយឆាសាច់ជ្រូកដាក់បន្លែស្ពៃ។ តែពេលលេបបាយចូលទៅគាត់ឈឺបំពង់កខ្លាំងណាស់ ព្រោះខានបានទទួលទានបាយពីរថ្ងៃមកហើយ។

បន្ទាប់មកទៀត គេក៏បណ្តើរពួកគាត់ពីកន្លែងមួយ ទៅកន្លែងមួយទៀត រហូតចូលទៅដល់ព្រៃដីសើមមួយ មានសត្វទាកចូលក្នុងខោខាំប្រដាប់បន្តពូជ ទម្រាំបេះវាចេញមកវិញ ភ័យជាងខ្លាចគ្រាប់កាំភ្លើងទៅទៀត។ លុះទៅដល់ព្រៃមួយកន្លែង ក្នុងស្រុកកំពង់សីលា អ្នកកាសែតស្រី ឈ្មោះ ខេត វេប ជនជាតិអូស្ត្រាលី ដេកឆ្ងាយពីប្រុសៗ ព្រោះគាត់មិនបានងូតទឹក១០ថ្ងៃ ជះក្លិនមិនល្អ ទើបមិនហ៊ានដេកនៅជិតប្រុសៗ។



**ទាហានលន់ នល់ បាក់ទ័ព រត់គេចខ្លួនពីពួកវៀតកុង មករកខ្មែរក្រៀមពួកគេវិញ**

គង់ វន បញ្ជាក់ថា បន្ទាប់មកទៀត គេបានបណ្តើរពួកគាត់កាត់ព្រៃឆ្ពោះទៅខាងកើតជ្រោះពេជ្រនិល អស់រយៈពេល៧យប់៧ថ្ងៃ ទើបទៅដល់រូងធំមួយនៅខាងក្រោមគុម្ពប្ញស្សីក្រាស់ ជាជំរំមេធំរបស់ពួកគេ។

របត់នយោបាយ

ថ្ងៃមួយ តូអ៊ីជី ស៊ុយហ៊្សូគី ប្រាប់ខ្ញុំថា គាត់មានរូបថតមួយសន្លឹក ថតជាមួយ ហូ ជីមិញ រួចគាដករូបថតនោះចេញពីមកបង្ហាញ ហើយប្រាប់ថា គាត់ធ្លាប់ទៅយកព័ត៌មាននៅក្រុងហាណូយ វៀតណាមខាងជើង ២ឆ្នាំ។ គាត់ (គង់ វន) ពិនិត្យរូបថតនោះទៅ ឃើញ តូអ៊ីជី ស៊ុយហ៊្សូគី ថតជាមួយ ហូ ជីមិញ មានពុកមាត់ស្រមូម មែន។ បន្ទាប់មក គាត់ក៏យករូបថតនោះ បង្ហាញមេបញ្ជាការកងទ័ពវៀតកុង។ មេបញ្ជាការនោះក៏យកទៅបាត់ ដោយមិនបានសួរនាំអ្វីឡើយ។ ចាប់ពីពេលនោះមក សភាពការណ៍ប្រែប្រួល ពួកគេមិនសូវសួរចម្លើយពួកគាត់ទៀតទេ។ ភាគច្រើន ពួកគេឱ្យគាត់ស្តាប់វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា វិទ្យុភ្នំពេញ និងវិទ្យុក្រុងប៉េកាំង ផ្សាយជាភាសាខ្មែរ។ តែឧទាហរណ៍ វិទ្យុភ្នំពេញ ផ្សាយថា ខាងទាហាន លន់ នល់ វាយឈ្នះ គាត់បកប្រែថា ខាងទាហាន លន់ នល់ មិនអាចទប់ទល់ជាមួយពួកវៀតកុងបានទេ។ ជាមួយគ្នានោះ គាត់ខ្សឹបប្រាប់អ្នកកាសែតបរទេសទាំងអស់នោះថា ពេលណាមានផ្សាយព័ត៌មានថា កងទ័ពវៀតកុង និងរណសិរ្សរួបរួមជាតិកម្ពុជា ទទួលជ័យជម្នះលើពួកទាហាន លន់ នល់ អ្នកឯងចេះតែនាំគ្នាអបអរសាទរទៅ បើមិនអញ្ចឹងទេ ពួកយើងមានបញ្ហាជាមិនខាន ទាំងអស់គ្នាក៏ធ្វើតាមគាត់។ មិនយូរប៉ុន្មាន មេបញ្ជាការកងទ័ពវៀតកុង ក៏លែងសួរចម្លើយពួកគាត់ទៀត និងឱ្យពួកគាត់ស្តាប់តែវិទ្យុ និងបកប្រែឱ្យពួកគេស្តាប់តែប៉ុណ្ណោះ។

លុះដល់ថ្ងៃទី២៣ នៃការចាប់ខ្លួន គេប្រាប់ពួកគាត់ថា មេបញ្ជាការភូមិភាគនិរតីទិសរបស់ខ្មែរក្រហម បានប្រជុំសម្រេចដោះលែងពួកគាត់ទាំង៦នាក់ ឱ្យទៅជួបជុំគ្រួសារវិញហើយ។ ពួកគេក៏បានជាំបាយឆាសាច់ជ្រូក និងមានបង្អែមផ្លែចេក ដាក់ឱ្យពួកគាត់ទទួលទាន ព្រមទាំងប្រគល់កញ្ចប់ស្បែកជើងកង់ឡាន អង្រឹង ក្រមា ឱ្យពួកគាត់ម្នាក់មួយកញ្ចប់ និងឱ្យពាក់ខោអាវ ដែលពួកគេចែកម្នាក់មួយសម្រាប់ រួចកងទ័ពវៀតណាម៤-៥នាក់ ក៏នាំពួកគាត់ចេញពីព្រៃធំ ឆ្លងកាត់ជ្រលងភ្នំ សំដៅទៅរកផ្លូវជាតិលេខ៤។

លុះមកដល់ជិតភ្នំត្រពាំងក្រឡឹង ពួកគេ ក៏ចាប់ដៃពួកគាត់ លាវិលត្រឡប់ទៅ

របត់នយោបាយ
វិញអស់។ គាត់ ក៏យកក្រណាត់សប្រវែងប្រហែល២ម៉ែត្រ របស់ស្ត្រីជាអ្នកកាសែតជនជាតិអូស្ត្រាលី មកចងជាមួយមែកឈើ លើកឡើងលើដើរតម្រង់ទៅរកខ្សែត្រៀមរបស់ទាហានទ្រង់ ចន្ទរង្សី។

ពេលដើរទៅដល់ខ្សែត្រៀម ពួកទាហានស្រែកសួរថា នរណាគេហ្នឹង? គាត់ស្រែកខ្លាំងៗតបទៅវិញថា៖ " ពួកខ្ញុំជាអ្នកកាសែត...! "។



**ភូមិភាគខ្មែរ-ជៀតណាមខាងជើង**

លុះចូលមកកាន់តែជិត ពួកទាហានកងពលលេខ១៣ របស់ទ្រង់ ចន្ទរង្សី ស្គាល់ពួកគាត់ច្បាស់ ព្រោះពួកគាត់ឧហ្សាហ៍ ចុះមកជួបទ្រង់ចន្ទរង្សី ដើម្បីយកព័ត៌មាននៅសមរភូមិក្នុងខេត្តកំពង់ស្ពឺ ញឹកញាប់ ពួកគេក៏នាំគ្នារត់មកទទួលដោយរីករាយរាក់ទាក់បំផុត។ ពួកគេបានបញ្ជូនពួកគាត់តាមរថយន្តហ្ស៊ីប២គ្រឿង ទៅទីបញ្ជាការកងពលលេខ១៣ នៅបន្ទាយដោះកញ្ជរ។ ទ្រង់ចន្ទរង្សី បានចេញមកទទួលស្វាគមន៍ពួកគាត់ដោយសោមនស្សរីករាយ និងរៀបចំបាយទឹកមានស្រា និងម្ហូបអាហារឆ្ងាញ់ៗឱ្យពួកខ្ញុំ

ទទួលទាន ហើយទ្រង់បានឱ្យប្រាក់ពួកគាត់ជាអ្នកកាសែតខ្មែរ ១ម៉ឺនរៀលទៀតផង។ ខេត វេប អ្នកឆ្លើយឆ្លងព័ត៌មាន យូភីអាយ (UPI) និងតូអ៊ីជី ស៊ុយហ្ស៊ូគី (Toichi Suzuki) ប្រធានទីភ្នាក់ងារព័ត៌មាន នីហុង ដេនប៉ា ក៏បានថ្លែងអំណរគុណ និងរៀបរាប់ពីការឈឺចាប់ទុក្ខលំបាករបស់ពួកគាត់រយៈពេល២៣ថ្ងៃ ដែលពួកវៀតកុង និងពួកខ្មែរក្រហម ចាប់បាននោះ ឱ្យទ្រង់ចន្ទរង្សី បានដឹងផងដែរ។



**ទ្រង់ ចន្ទរង្សី ជាមួយអ្នកការសែតបរទេស**

ទ្រង់ចន្ទរង្សី បានបញ្ជាក់ប្រាប់ពួកគាត់ថា ដោយសាររដ្ឋាភិបាលក្រុងភ្នំពេញព្យាយាមតវ៉ា ទៅរដ្ឋាភិបាលទីក្រុងហាណូយ ទើបមានការដោះលែងពួកគាត់មកវិញ និងបានផ្តាំផ្ញើថា ថ្ងៃក្រោយសូមកុំឱ្យពួកគាត់ ទៅយកព័ត៌មានដល់ខ្សែត្រៀមជួរមុខ ទៀតព្រោះសមរភូមិក្តៅសម្រាប់តែទាហានទេ បើអ្នកកាសែតហ៊ានចូលទៅដល់ គ្រោះថ្នាក់ណាស់ ខណៈនោះដែរ ក៏មានសារទូរលេខពីឧត្តមសេនីយ៍ សុស្តែន ហ្វែរណង់ដេស មេបញ្ជាការយោធភូមិភាគទី២ បញ្ជាឱ្យបញ្ជូនពួកគាត់ទៅទីក្រុងភ្នំពេញជាបន្ទាន់ ដើម្បីធ្វើសន្និសីទកាសែត។ មិនយូរប៉ុន្មាន ឧទ្ធម្ភាគចក្រយោធាមួយគ្រឿងក៏បានមកដឹកពួកគាត់ទៅចុះនៅអាកាសយានដ្ឋានពោធិ៍ចិនតុង និងដឹកបន្តតាមរថយន្តឆ្ពោះទៅ

របត់នយោបាយ

សណ្ឋាគារឡឺភ្នំ ដែលពីមុនជាសណ្ឋាគាររ៉ូយ៉ាល់។ ពេលទៅដល់សណ្ឋាគារឡឺភ្នំ ស្រាប់តែឃើញប្រពន្ធកូន ក្រុមគ្រួសារ និងមិត្តភក្តិពួកគាត់ជាច្រើននៅឈរចាំទទួល ទាំងទឹកភ្នែកគ្រេកអរ។

សម័យសង្គ្រាមក្នុងចន្លោះពីឆ្នាំ១៩៧០ ទៅឆ្នាំ១៩៧៥ អ្នកកាសែតបរទេស និងកម្ពុជា ប្រមាណ៣៧នាក់ ត្រូវបាត់បង់ជីវិត។ ជាមួយគ្នានោះ ក៏មានអ្នកកាសែតប្រមាណ៣៧នាក់ ទៀត រួមមាន អ្នកកាសែត អ្នកថតរូប និងអ្នកថតវីដេអូ មកពីប្រទេសជប៉ុន បារាំង សហរដ្ឋអាមេរិក អាល្លឺម៉ង់ ឥណ្ឌា លាវ អូស្ត្រាលី អូទ្រីស ស្វីស និងកម្ពុជា ផងដែរ ត្រូវបាត់ខ្លួន។

ចាប់ពីពេលនោះមក គង់ វន ក៏ឈប់ធ្វើការជាមួយ តូអ៊ីជី ស៊ុយហ្សូគី (Toichi Suzuki) ប្រធានក្រុមព័ត៌មាន នីហុង ដេនប៉ា (Nihon Denpa News)។ គាត់ទៅធ្វើការជាអ្នកយកព័ត៌មានឱ្យកាសែតជប៉ុន មួយទៀត គឺកាសែត ក្យូដូ (Kyodo News) មានស្នាក់ការនៅសណ្ឋាគារឡឺភ្នំ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលកងទ័ពខ្មែរក្រហម វាយដណ្តើមបានទីក្រុងភ្នំពេញ ពីរបបសាធារណរដ្ឋខ្មែរ។

គង់ វន ចាប់កំណើតនៅឆ្នាំ១៩៤៧ ក្នុងត្រកូលកសិករមួយនៅភូមិធ្វាង ឃុំប្រជាគុ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ក្នុងវ័យ១៧ឆ្នាំទៅហើយ គាត់មិនទាន់រៀនចប់សាលាបឋមសិក្សានៅឡើយ ក៏បានបោះបង់ការសិក្សា ទៅជួយកិច្ចការរកស៊ីម្តាយឪពុកវិញ។ គាត់បានឆ្លងកាត់ជីវិត ជាកម្មករចម្ការកៅស៊ូមេមត់ ជាកម្មករលីសែងនៅកំពង់ផែភ្នំពេញ និងជាកម្មករជាក់ស៊ីក្លូជាច្រើនឆ្នាំ។ តែគាត់ព្យាយាមខិតខំរៀនភាសាអង់គ្លេស រហូតបានក្លាយ ជាអ្នកបកប្រែ និងជាជំនួយការ ឱ្យពួកអ្នកកាសែតបរទេសល្បីៗ។ ក្រោយកងទ័ពខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពាញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលពួកវាជម្លៀសគាត់ និងក្រុមគ្រួសារដល់ស្រុកបាធាយ ខេត្តកំពង់ចាម គាត់ និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ៣នាក់ទៀត ត្រូវពួកវាចាប់យកទៅសម្លាប់ចោលនៅក្នុងព្រៃមួយ។ តែគាត់បានតដៃជាមួយពួកវា ហើយរត់រួចទាំងចំណាង និងបានគេចខ្លួនទៅ

របត់នយោបាយ

រស់នៅខេត្តព្រៃវែង ជាស្រុកកំណើត។

នៅឆ្នាំ១៩៨១ គាត់បានទៅរស់នៅក្នុងជំរំភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ហើយត្រូវនាយកសារព័ត៌មាន ក្យូដូ (Kyodo) ជាមេកោយចាស់របស់គាត់កាលសម័យរបបសាធារណរដ្ឋខ្មែរ ធានាឱ្យទៅរស់នៅប្រទេសជប៉ុន។ ក្រោយពីរស់នៅក្នុងប្រទេសជប៉ុន ប្រមាណ១៧ឆ្នាំ គាត់បានវិលត្រឡប់មកកម្ពុជា វិញ រួមចំណែកជួយអភិវឌ្ឍន៍ប្រទេសជាតិ ដោយបានកសាងអនុវិទ្យាល័យបន្ទាយចក្រី ពិសេសអនុវិទ្យាល័យ និងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន នៅក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង ព្រមទាំងបានជួយកូនចៅប្រជាពលរដ្ឋក្រីក្រជាច្រើន ឱ្យបានបន្តការសិក្សាដល់ថ្នាក់ឧត្តមសិក្សាទៀតផង។

# ៧.២៨ លន់ នល់ ឡើងជាសេនាប្រមុខ សិស្ស និស្សិតធ្វើបាតុកម្ម ប្រឆាំងទ្រង់ សិរិមតៈ





**សេនាប្រមុខលន់ នល់** **ក្បួនបាតុកម្មរបស់សិស្ស-និស្សិត**

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧១ លន់ នល់ ក៏បានបង្កើតគណៈកម្មាធិការមួយទៀត មានសមាជិករហូតដល់ទៅ១៩១រូប ដែលមកពីអង្គការ និងស្ថាប័នផ្សេងៗគ្នា ដើម្បីពិភាក្សាគ្នាសម្រេចថា តើត្រូវជ្រើសរើសយករបបប្រធានាធិបតីនិយម ឬរបបសភានិយម? ឬមួយរបបចម្រុះ មកដឹកនាំប្រទេស?

គណៈកម្មាធិការថ្មីនេះមានសមាជិកសំខាន់ៗរួមមាន៖ តំណាងរដ្ឋាភិបាលម្នាក់គឺ ប៉ាន់ សុធី រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងវប្បធម៌, ទីប្រឹក្សារដ្ឋាភិបាល ៣នាក់ គឺ ទ្រិញ វ៉ាញ ឌុក វ៉ាស៊ី និងកែវ ស្រណោះ, តំណាងសមាជិករដ្ឋសភា ៣រូប, តំណាងក្រុមប្រឹក្សាសាធារណរដ្ឋ (ពីមុនជាក្រុមប្រឹក្សាព្រះរាជាណាចក្រ) ៣រូប, រស់ ចន្ត្រាបុត្រ តំណាងសមាគមអ្នកសាធារណរដ្ឋនិយម, ប៉ូល លីតៃសួន តំណាងសមាគមអ្នកសារព័ត៌មានកម្ពុជា, អ៊ឹម យូហៃ តំណាងសមាគមសិស្សនិស្សិតបញ្ញវន្តខ្មែរ និងប៊ុណ្ណ ចន្ទម៉ុល ...ជាដើម។

ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៧១ សភាទាំង២ បានឯកភាពគ្នា តម្លើងឋានន្តរសក្តិ លន់ នល់ ពីនាយឧត្តមសេនីយ៍ ឱ្យទៅជាសេនាប្រមុខ (ផ្កាយ៦)។

ចាប់ពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧១ គណៈកម្មាធិការនេះ បានសម្រេចលើក

របត់នយោបាយ

យកប្រធានបទចំនួន៣ ដើម្បីដាក់ឱ្យអង្គប្រជុំធ្វើការពិភាក្សាគ្នា និងសម្រេចជ្រើសរើស។ តើត្រូវជ្រើសរើសយក របបគ្រប់គ្រងតាមបែបប្រធានាធិបតីនិយម គឺអំណាចទាំងអស់ត្រូវស្ថិតនៅលើប្រធានាធិបតី? ឬរបបសភានិយម គឺប្រធានាធិបតី និងរដ្ឋាភិបាលទទួលខុសត្រូវចំពោះ មុខសភា ឬមួយក៏គ្រប់គ្រងតាមបែបចម្រុះ គឺរបបប្រធានាធិបតីនិយមពាក់កណ្តាល និងរបបសភានិយមពាក់កណ្តាល?។





**លន់ នល់ ឡើងឋានន្តរសក្តិជាសេនាប្រមុខ**

ក្រោយពីធ្វើការពិភាក្សាគ្នាអស់រយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧១ មក ក្នុងចំណោមសមាជិកគណៈកម្មាធិការ ចំនួន១៩១រូប ដែលវត្តមានក្នុងអង្គប្រជុំ មានចំនួន១៣១រូប បានបោះឆ្នោតគាំទ្រឱ្យយករបបចម្រុះ គឺរបបប្រធានាធិបតីនិយមពាក់កណ្តាល និងសភានិយមពាក់កណ្តាល។ ចំនួន៥៧រូប បានបោះឆ្នោតគាំទ្រឱ្យយករបបប្រធានាធិបតីនិយម និងចំនួន៣រូប បានបោះឆ្នោតគាំទ្រឱ្យយករបបសភានិយម។ តាមរយៈលទ្ធផលនៃការបោះឆ្នោតនេះ គណៈកម្មាធិការបានសម្រេចជ្រើសរើសយករបបដឹកនាំចម្រុះ គឺពាក់កណ្តាលរបបប្រធានាធិបតីនិយម

របបនយោបាយ
និងពាក់កណ្ដាលរបបសភានិយម។ ប៉ុន្តែពួកគេ ឱ្យប្រធានាធិបតី មានអំណាចជាង សភាបន្តិច ក្នុងការសម្រេចកិច្ចការសំខាន់ៗរបស់ប្រទេសជាតិ។

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧១ គណៈកម្មាធិការនេះ ក៏បានបើកប្រជុំពិភាក្សាបន្តទៀត ដើម្បីអនុម័តពីការកំណត់ឱ្យរបបសាធារណរដ្ឋខ្មែរ ឱ្យមានសភាពីរ (រដ្ឋសភា និងព្រឹទ្ធសភា) ឬមានសភាតែមួយ។ ក្នុងចំណោមសមាជិក ដែលមានវត្តមានក្នុងអង្គប្រជុំ សរុបចំនួន១៥៦រូប មាន១២១សំឡេង បានបោះឆ្នោតគាំទ្រឱ្យមានសភាពីរ គឺរដ្ឋសភា និងព្រឹទ្ធសភា ហើយ៣២សំឡេងបានបោះឆ្នោតគាំទ្រឱ្យមានសភាតែមួយ គឺរដ្ឋសភា និង៣សំឡេង ទៀត ជាសន្លឹកឆ្នោតមិនបានការ។

ដោយមានសំឡេងគាំទ្រ២ភាគ៣ នៅក្នុងរដ្ឋសភា និងក្រុមប្រឹក្សាសាធារណរដ្ឋ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧១ ចេង ហេង ក្នុងនាមប្រមុខរដ្ឋនៃប្រទេសកម្ពុជា ចេញក្រឹត្យមួយប្រកាសបញ្ចប់អាណត្តិរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា ដែលកើតឡើងដោយការបោះឆ្នោតតាំងពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦ ប្រកាសឱ្យរដ្ឋសភា និងក្រុមប្រឹក្សាសាធារណរដ្ឋ (ក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា) នោះ ក្លាយទៅជាសភាធម្មនុញ្ញជាស្វ័យប្រវត្តិ ដើម្បីបង្កើតរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋខ្មែរ បន្តទៀត។

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧២ នៅក្នុងសន្និសីទកាសែតមួយ កែវ អន ជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (សាលាច្បាប់) បានធ្វើការរិះគន់វាយប្រហារទៅលើទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ដែលជានាយករដ្ឋមន្ត្រីប្រតិភូ និងជារដ្ឋមន្ត្រីការពារជាតិ ពីបញ្ហាពុករលួយ, បញ្ហាកិបកេងចំនួនកងទ័ព, បញ្ហាការបើកប្រាក់ខែឱ្យកងទ័ពមិនបានទៀងទាត់ និងបញ្ហាផ្សេងៗជាច្រើនទៀត ពិសេសទាមទារឱ្យទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ចុះចេញពីតំណែងទៀតផង។

បន្ទាប់មក ថ្ងៃទី២៦ ខែកុម្ភៈ ពាក្យសម្ដីរិះគន់វាយប្រហារទាំងប៉ុន្មានរបស់ កែវ អន ទៅលើទ្រង់ ស៊ីសុវត្ថិ សិរិមតៈ នៅក្នុងសន្និសីទនោះ ត្រូវបានគេយកទៅចុះផ្សាយស្ទើរតែទាំងស្រុងនៅ លើទំព័រកាសែតសង្គមសាធារណរដ្ឋ។ កាសែតសង្គមសាធារណរដ្ឋនេះ មាន លន់ ណុន ទើបនឹងឡើងឋានន្តរសក្តិជាវរសេនីយ៍ឯកថ្មីៗកាលពីខែមករា

របត់នយោបាយ
ឆ្នាំ១៩៧២ នៅពីក្រោយខ្នង ហើយ កែវ អន ជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (សាលាច្បាប់) នោះ ក៏ជាស្ថាបនិកម្នាក់របស់កាសែតសង្គម សាធារណរដ្ឋ នោះដែរ។



**កែវ អន**

មួយថ្ងៃក្រោយមកទៀត គឺថ្ងៃទី២៧ ខែកុម្ភៈ កាសែត "នគរធំ" របស់ សុទ្ធ ប៉ូលីន ដែលជាមិត្តភក្តិជិតស្និទ្ធរបស់វរសេនីយ៍ឯក លន់ ណុន ក៏បានចុះផ្សាយលិខិតចំហមួយ របស់ កែវ អន ដែលទាមទារឱ្យទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ចុះចេញពីតំណែងផងដែរ។

ដោយខឹងសម្បានឹង កែវ អន ដែលប្លើមធំហ៊ានប្រកាសទាមទារឱ្យទ្រង់ចុះចេញ ពីតំណែងនោះ ទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ក្នុងនាមនាយករដ្ឋមន្ត្រីប្រតិភូ ក៏បានសម្រេច ចេញក្រឹត្យដកតំណែងព្រឹទ្ធបុរសរបស់មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ពីលោក កែវ អន ដោយគ្មានបង្អែបង្អង់ឡើយ។

ពេលនោះដែរ ដោយមាន លន់ ណុន ជាប្អូនសេនាប្រមុខ លន់ នល់ នៅពី ក្រោយខ្នង ពួកនិស្សិតនៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅ បឹងត្របែក ក៏នាំគ្នាងើបឡើងធ្វើបាតុកម្មបះបោរប្រឆាំងនឹងទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ថា

របត់នយោបាយ

ជាអ្នកបំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមលទ្ធិប្រជាធិបតេយ្យ និងប្រព្រឹត្តអំពើពុករលួយ។

ពួកនិស្សិត បានចងបដានៅខ្លោងទ្វារមុខមហាវិទ្យាល័យច្បាប់ ដោយមានខ្លឹមសារថា៖ “ ហេតុអ្វីបានជាយើង មិនអាចបញ្ចេញមតិបាន? និងពាក្យស្លោកថា ត្រូវកាត់ដៃជើងពួកពុករលួយ...ជាដើម ”។

នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៧២ ចលនាធ្វើបាតុកម្មប្រឆាំងនឹងទ្រង់ សិរិមតៈ បានរីករាលដាលពីមហាវិទ្យាល័យមួយ ទៅមហាវិទ្យាល័យមួយ រហូតដល់វត្តអារាមផ្សេងៗទៀត ពិសេសនៅវត្តលង្កា ដែលមានភិក្ខុធម្មបាល ខៀវ ជុំ ជាព្រះសង្ឃជិតស្និទ្ធនឹង លន់ ណុន គង់នៅទីនោះ។

សិស្ស-និស្សិត និងព្រះសង្ឃជាច្រើន នាំគ្នាទាមទារឱ្យទ្រង់ សិរិមតៈ ចុះចេញពីតំណែង ដោយពួកគេចោទថា ទ្រង់នេះ ជាពួកសក្តិភូមិ ដូចស្តេចសីហនុ ដែរ។ ជាមួយគ្នានោះពួកគេបានសរសេរអក្សរធំៗ ជាភាសាបារាំងនៅលើបដាថា៖ “ Lon Nol Oui, Siri MaTak non ” បានន័យថា ពួកគេគាំទ្រតែ លន់ នល់ ប៉ុណ្ណោះ មិនគាំទ្រ សិរិមតៈ ទេ។ ឯបដាខ្លះទៀត បានសរសេរអក្សរជាភាសាខ្មែរថា “ អត់ឱនឱ្យពួកពុករលួយ គឺក្បត់ធនធានៈពលរដ្ឋ...ជាដើម ”។



**ទ្រង់ សិរិមតៈ និងសេនាប្រមុខលន់ នល់**

របត់នយោបាយ

អ្វីដែលគួរឱ្យអស់សំណើចដែរនោះ ពួកសិស្ស-និស្សិត បានលើកឡើងនូវពាក្យស្លោកមួយដែលមានន័យ ចំអកដល់មេដឹកនាំរបបសាធារណរដ្ឋខ្មែរ ទាំង៣នាក់ ថា៖ “ សង្ឃឹម លន់ នល់, លន់ នល់ ដើងបាក់ សង្ឃឹម សិរិមតៈ, សិរិមតៈ ចាត់ការដូចក្មេង សង្ឃឹម ចេង ហេង ដូចសង្ឃឹមផ្កាយលើមេឃ... ” ។

យប់ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧២ ទំនងជាមានការរងសម្ពាធពីសេនាប្រមុខ លន់ នល់ ផងដែរនោះ ចេង ហេង ដែលសភាទាំង២ បានសម្រេចឱ្យកាន់តំណែងជាប្រមុខរដ្ឋ រហូតដល់មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនោះ បានប្រកាសសុំលាលែងពីតំណែងជាសាធារណៈតាមវិទ្យុជាតិ ដោយលើកហេតុផលថា រូបគាត់គ្មានសមត្ថភាពក្នុងការបំពេញការងារជាប្រមុខរដ្ឋនោះទៅវិញ ហើយគាត់ប្រកាសថា មានតែសេនាប្រមុខ លន់ នល់ ដែលជាវីរបុរសនៃបដិវត្តន៍សាធារណរដ្ឋនិយមទេ ទើបអាចមានសមត្ថភាពដឹកនាំប្រទេសជាតិក្នុងកាលៈទេសៈដ៏លំបាកនេះបាន...។

ក្រោយពី ចេង ហេង ប្រកាសលាលែងពីតំណែងជាប្រមុខរដ្ឋ រយៈពេលតែ៣ម៉ោងប៉ុណ្ណោះ សេនាប្រមុខ លន់ នល់ ក៏បានប្រកាសតាមវិទ្យុជាតិដដែលនោះថា ភារកិច្ចបានតម្រូវឱ្យគាត់ទទួលយកនូវបេសកកម្មមួយនេះ (តំណែងប្រមុខរដ្ឋ) ដើម្បីសង្គ្រោះប្រទេសជាតិឱ្យរួចផុតពីគ្រោះមហន្តរាយ ដែលកំពុងតែប្រឈមនឹងការឈ្លានពានរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង។

សេនាប្រមុខ លន់ នល់ បានប្រកាសបន្តថា ក្នុងអំឡុងពេល២ឆ្នាំចុងក្រោយនេះ ពួកឈ្លានពានវៀតកុង-វៀតណាមខាងជើង បានបំផ្លិចបំផ្លាញប្រទេសកម្ពុជា យ៉ាងសាហាវឃោរឃៅបំផុត។ ប៉ុន្តែទាហានរបស់គាត់មិនរារែកក្នុងការវាយបកចំពោះពួកទមិឡតតសាសនាទាំងអស់នេះវិញទេ។

សេនាប្រមុខ លន់ នល់ ក៏បានបញ្ជាក់ថា ចាប់ពីពេលនេះទៅ គាត់បានសម្រេចចិត្តរំលាយសភាធម្មនុញ្ញចោល ហើយគាត់ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីសង្គ្រោះរបបសាធារណរដ្ឋខ្មែរ និងនាំមកនូវសុខសន្តិភាពជូនប្រជាពលរដ្ឋខ្មែរវិញ ព្រមទាំងដឹកនាំប្រទេសឆ្ពោះទៅរកភាពសម្បូរសប្បាយ និងមានសុភមង្គលដូចប្រទេសដទៃទៀត។

របត់នយោបាយ

មូលហេតុដែលសេនាប្រមុខ លន់ នល់ ប្រកាសរំលាយសភាធម្មនុញ្ញចោលនោះ មជ្ឈដ្ឋានខ្លះ បានលើកហេតុផលថា មកពីសភាធម្មនុញ្ញនោះ ចេះតែព្យាយាមបង្កើត មាត្រាមួយចំនួនដើម្បីកាត់បន្ថយអំណាចរបស់គាត់ និងពន្យារពេល មិនព្រមតាក់តែង ពង្រៀងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ នោះ ឱ្យបានឆាប់រហ័សតាមកាលកំណត់។

បន្ទាប់ពីប្រកាសរំលាយសភាធម្មនុញ្ញនោះចោល លន់ នល់ បានរៀបចំឱ្យមាន គណៈកម្មាធិការមួយ និងបានតែងតាំង ភឹង គុន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ភ្នំពេញ ជាប្រធានគណៈកម្មាធិការ ដើម្បីតាក់តែងពង្រាងរដ្ឋធម្មនុញ្ញថ្មីមួយទៀត។ ចាប់ពីពេលនោះមក សេនាប្រមុខ លន់ នល់ បានតាំងខ្លួនឯងជាប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ មុនពេលបង្កើតរដ្ឋធម្មនុញ្ញថ្មីនោះទៅទៀត។

ចំណែកទ្រង់ សិរិមតៈ វិញ ដោយសារធុញទ្រាន់នឹងសិស្ស-និស្សិតនាំគ្នាធ្វើ បាតុកម្មទាមទារឱ្យទ្រង់ចុះចេញពីតំណែងកាន់តែរីកធំទៅៗ នៅថ្ងៃទី១២ ខែមីនាឆ្នាំ ១៩៧២ ទ្រង់ក៏បានសម្រេចចិត្តយល់ព្រមចុះចេញពីតំណែងនាយករដ្ឋមន្ត្រីប្រតិភូនោះ ដែរ ប៉ុន្តែទោះបី ជាយ៉ាងនេះ ក៏ដោយ ក៏ពួកសិស្ស-និស្សិត ដែលមានវរសេនីយ៍ឯក លន់ ណុន នៅពីក្រោយខ្នងនោះ បានទាមទារឱ្យទ្រង់លាឈប់ពីឆាកនយោបាយទៀតផង។

ក្រោយពេលទ្រង់ សិរិមតៈ លាឈប់ពីតំណែងនាយករដ្ឋមន្ត្រីប្រតិភូ អស់រយៈ ពេល៨ថ្ងៃមក នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧២ រដ្ឋាភិបាលថ្មីមួយ ត្រូវបានប្រកាសជា ផ្លូវការ។ សមាសភាពរដ្ឋាភិបាលនោះ រួមមាន៖ អតីតមេដឹកនាំចលនាតស៊ូខ្មែរសេរី ស៊ឺង ង៉ុកថាញ់ ជារដ្ឋមន្ត្រីទី១ និងជារដ្ឋមន្ត្រីការបរទេស (ចាប់ពីពេលនោះ មករបប សាធារណរដ្ឋខ្មែរ ប្រើពាក្យរដ្ឋមន្ត្រីទី១ ជំនួសពាក្យនាយករដ្ឋមន្ត្រី), យ៉ែម សំបូរ (ធ្លាប់ជានាយករដ្ឋមន្ត្រីកាលពីឆ្នាំ១៩៤៩) ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងយុត្តិធម៌ សុខាភិបាលសុខមាលភាព និងអភិវឌ្ឍន៍ផលិតផលឱសថ, ម៉ៅ សាយ ទេសរដ្ឋមន្ត្រី អមទីស្តីការប្រធានាធិបតី, ឧត្តមសេនីយ៍ សក់ ស៊ុតសាខន ទេសរដ្ឋមន្ត្រីទទួលបន្ទុក ក្រសួងការពារជាតិ, ផ្លែក ឆាត ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងផែនការ ជំនួយបរទេស និងអភិវឌ្ឍន៍, ឧត្តមសេនីយ៍ ឋាប្បនា ងិន្ន ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួង មហាផ្ទៃ

របត់នយោបាយ

សន្តិសុខ ធម្មការ អតីតយុទ្ធជន និងទេសចរណ៍, ឡុង បូរ៉េត រដ្ឋមន្ត្រីក្រសួងឃោសនាការ, ថៅ សេងអ៊ួ រដ្ឋមន្ត្រីក្រសួងការងារសង្គមកិច្ច, ធន សុខុម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ធនធាន អណ្តូងរ៉ែ និងនេសាទសមុទ្រ, ហ៊ូ ហុង រដ្ឋមន្ត្រីក្រសួងសុខាភិបាលសុខមាលភាព និងអភិវឌ្ឍន៍ផលិតឱសថ, ឧត្តមសេនីយ៍ កង កេង (មិត្តភក្តិជិតស្និទ្ធនិងជាវេជ្ជបណ្ឌិតតាមមើលថែសុខភាពសេនាប្រមុខ លន់ នល់) ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, អ៊ុន ត្រមុច រដ្ឋមន្ត្រីទទួលបន្ទុកកំណែនទូទៅ, ស សុង រដ្ឋមន្ត្រីក្រសួងកសិកម្ម អភិវឌ្ឍន៍សហគមន៍ និងទេពកោសល្យជនបទ, ឃី តាំងលឹម រដ្ឋមន្ត្រីខាងតុបតែងលំនៅឋាន សាធារណការ ប្រៃសណីយ៍ និងទូរគមនាគមន៍, អ៊ិត ធុយ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, ថាច់ ជា (មនុស្សជំនិតរបស់ លន់ ណុន) ជារដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងវប្បធម៌ និងអ៊ុង សៀម រដ្ឋមន្ត្រីទទួលបន្ទុកគ្រប់គ្រងទីក្រុងភ្នំពេញ។

សឺង ង៉ុកថាញ់ រដ្ឋមន្ត្រីទី១ ជាអតីតមេដឹកនាំចលនាតស៊ូខ្មែរឥស្សរៈប្រឆាំងនឹងបារាំង តាំងពីដើមទសវត្សរ៍ ឆ្នាំ១៩៤០ មកម្ល៉េះ។ ពីឆ្នាំ១៩៤២មក គាត់បានរត់ទៅជ្រកកោននៅប្រទេសជប៉ុន។ ក្រោយពីកងទ័ពជប៉ុន ឡើងកាន់កាប់ប្រទេសកម្ពុជាជំនួសបារាំង ពីថ្ងៃទី១៨ សីហា ដល់ ១៦តុលា ១៩៥៤ គាត់ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី។ ក្រោយពីកងទ័ពបារាំង ចូលមកកាន់កាប់ប្រទេសកម្ពុជា វិញ គាត់ត្រូវបារាំង ចាប់យកទៅឃុំទុកនៅប្រទេសបារាំង ក្នុងខែតុលា ឆ្នាំ១៩៤៥ នោះដែរ។

នៅក្នុងខែតុលា ឆ្នាំ១៩៥១ សម្តេចសីហនុ បានស្នើសុំបារាំង ឱ្យសឺង ង៉ុកថាញ់វិលមកមាតុប្រទេសវិញ ដោយសន្យាថា គាត់មិនធ្វើនយោបាយប្រឆាំងនឹងបារាំងទៀតទេ។ ប៉ុន្តែ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៥២ គាត់បាននាំមន្ត្រីរាជការ សិស្ស និស្សិតមួយចំនួន រត់ទៅភ្នំដងរែក បង្កើតចលនាតស៊ូថ្មីមួយទៀត ឈ្មោះចលនាឥស្សរៈរួមខ្មែរបម្រើជាតិ ហៅកាត់ថា ប្រជាចលនា ដើម្បីប្រឆាំងនឹងបារាំង ព្រមទាំងសម្តេចសីហនុផងដែរ។ រហូតដល់ក្រោយរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គាត់បានត្រលប់ចូលមកក្នុងសង្គមជាតិ វិញ ដោយមានតួនាទីជាទីប្រឹក្សារដ្ឋាភិបាល លន់ នល់។




គួរកត់សម្គាល់ថា ក្រៅការឈប់ប្រើពាក្យនាយករដ្ឋមន្ត្រី ហើយយកពាក្យរដ្ឋមន្ត្រីទី១ ជំនួសវិញនោះ រដ្ឋាភិបាលថ្មីនេះ ក៏មិនឃើញមានតំណែងឧបនាយករដ្ឋមន្ត្រីដែរ គឺមានតែតំណែងទេសរដ្ឋមន្ត្រីចំនួន៥រូប និងតំណែងរដ្ឋមន្ត្រីចំនួន១១រូប ហើយចំណោមសមាសភាពរដ្ឋាភិបាលនេះ មានតែ ឃី តាំងលឹម ជារដ្ឋមន្ត្រីខាងតុបតែលំនៅឋានសាធារណការ ប្រៃសណីយ៍ និងទូរគមនាគមន៍ម្នាក់ប៉ុណ្ណោះ ដែលមានសំណាងខ្ពស់ជាងគេ ដោយគាត់មិនត្រឹមតែរួចផុត ពីការកាប់សម្លាប់របស់មេដឹកនាំខ្មែរក្រហម កាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានចេញទៅរស់នៅក្រៅប្រទេសប៉ុណ្ណោះទេ គឺរយៈពេល២៦ឆ្នាំ ក្រោយមកទៀត គាត់បានត្រលប់ពីបរទេសមកវិញ ហើយបានទទួលតំណែងជារដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូននៃរាជរដ្ឋាភិបាលអាណត្តិទី២ របស់ព្រះរាជាណាចក្រកម្ពុជាទី២ ឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៣ ទៀតផង។

# ៧.២៩ រដ្ឋាភិបាលប្រកាសចាប់ កុយ ប៊ុច និស្សិត និងសិស្សធ្វើបាតុកម្ម



**និស្សិត និងសិស្ស ហែក្បួនបាតុកម្ម**

ក្រោយពេលគណៈកម្មាធិការតាក់តែងពង្រាងរដ្ឋធម្មនុញ្ញ បានបំពេញតួនាទីរបស់ខ្លួនដោយជោគជ័យតាមបំណងប្រាថ្នារបស់សេនាប្រមុខ លន់ នល់ រួចហើយនោះ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧២ និស្សិតសាលាច្បាប់ដ៏ល្បីល្បាញម្នាក់ឈ្មោះ កុយ ប៊ុច (និស្សិតឆ្នាំទី៤) ត្រូវបានរដ្ឋាភិបាលជ្រើសរើសឱ្យទៅធ្វើជាវាគ្មិន ដើម្បីធ្វើការបកស្រាយពន្យល់នៅតាមកញ្ចក់ទូរទស្សន៍ពីខ្លឹមសារនៃពង្រាងរដ្ឋធម្មនុញ្ញ ដែលទើបតាក់តែងហើយថ្មីៗ និងត្រូវដាក់ឱ្យធ្វើប្រជាមតិនាពេលខាងមុខផងដែរ។ ប៉ុន្តែទន្ទឹមនឹងការពន្យល់បកស្រាយ ពីខ្លឹមសារ នៃពង្រាងរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋខ្មែរ នោះនិស្សិត កុយ ប៊ុច បែរជាឆ្លៀតឱកាសធ្វើការវាយប្រហាររិះគន់សេនាប្រមុខ លន់ នល់ ដោយប្រៀបប្រដូច លន់ នល់ នៅនឹងស្តេចយក្សម្នាក់ ឈ្មោះស្តេច អារុលមេឃ ដែលជាស្តេចកំណាចល្ងីល្ងើ មិនមានសមត្ថភាពក្នុងការដឹកនាំធ្វើសង្គ្រាមជាមួយគូសត្រូវទៅវិញ។

របត់នយោបាយ

ក្រោយពីបញ្ចប់ការវាយប្រហារ តាមផ្សាយផ្ទាល់មកពក្ញក់ទូរទស្សន៍នោះមក រដ្ឋមន្ត្រីទី១ សឹង ង៉ុកថាញ់ ក៏បានចេញបញ្ជាឱ្យកម្លាំងសមត្ថកិច្ចតាមចាប់និស្សិត កុយ ប៊ិច នោះភ្លាមៗដែរ។ ប៉ុន្តែ កុយ ប៊ិច បានរត់គេចខ្លួនចូលទៅនៅក្នុងមហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (សាលាច្បាប់) ដែលមានកម្លាំងកងកុម្មង់ដូ និស្សិតយាមប្រចាំការមហាវិទ្យាល័យនោះ ជួយការពារផងដែរ។

ស្អែកឡើងថ្ងៃទី២៤ ខែមេសា រដ្ឋាភិបាលក៏បានបញ្ជាកម្លាំងកងអាវុធហត្ថជាតិ (ប៉េអឹម) ដោយមានរថពាសដែក និងរថយន្តហ្សីបបំពាក់កាំភ្លើងយន្ត ឱ្យធ្វើការឡោម ព័ទ្ធមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងបំណងតាមរកចាប់ និស្សិត កុយ ប៊ិច ឱ្យបាន។ ប៉ុន្តែ កម្លាំងកងអាវុធហត្ថជាតិ មិនអាចចូលទៅចាប់ កុយ ប៊ិច ដែល នៅក្នុងមហាវិទ្យាល័យនោះ បានដោយងាយៗឡើយ ព្រោះពួកនិស្សិតជាកងកុម្មង់ដូ ដែលនៅខាងក្នុង ក៏មានអាវុធជាច្រើនត្រៀមរង់ចាំទប់ទល់ដែរ។

ពេលនោះដែរ អ៊ឹម យូហៃ ប្រធានសមាគមសិស្សនិស្សិតបញ្ញវន្តខ្មែរ ដែលមាន ទីស្នាក់ការនៅភូមិគ្រឹះមួយនៅត្រង់កែងផ្លូវម៉ៅសេទុង និងផ្លូវចូលទៅខាងក្រោយវិមាន រដ្ឋចម្ការមន "ផ្លូវ ហែម ចៀវ អតីតផ្លូវព្រះត្រសក់ផ្អែម" និងសន ថាត ជាប្រធាន សមាគមនិស្សិតមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានប្រកាសការពារ កុយ ប៊ិច ដោយបានអះអាងថា ការលើកឡើងរបស់ កុយ ប៊ិច នៅក្នុងវេទិកាពន្យល់បក ស្រាយខ្លឹមសារ រដ្ឋធម្មនុញ្ញនៅក្នុងកញ្ចក់ទូរទស្សន៍ កាលពីយប់ថ្ងៃទី២៣ ខែមេសានោះ គឺជាសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមបែបលទ្ធិប្រជាធិបតេយ្យ នៃរបបសាធារណរដ្ឋ ប៉ុណ្ណោះ ហើយមេដឹកនាំសមាគមសិស្សនិស្សិតបញ្ញវន្តទាំង២នាក់នេះ បានប្រកាស ឱ្យសិស្ស-និស្សិតនៅតាមវិទ្យាល័យ និងមហាវិទ្យាល័យនានាផ្សេងៗទៀត នាំគ្នាងើប ឡើងប្រឆាំងនឹងរដ្ឋាភិបាល សឹង ង៉ុកថាញ់ និងការពារ កុយ ប៊ិច ឱ្យបានខ្លាំងក្លាថែមទៀត។

ក្រោយពេលកម្លាំងសមត្ថកិច្ចប៉េអឹម ឡោមព័ទ្ធមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រ សេដ្ឋកិច្ច អស់រយៈពេល៤យប់៣ថ្ងៃនោះមក ពួកសិស្ស និស្សិតជាច្រើន ពាន់នាក់ ដែលមកពីវិទ្យាល័យ មហាវិទ្យាល័យនានា ក៏បាននាំគ្នាមកធ្វើបាតុកម្មឡោមព័ទ្ធ

របត់នយោបាយ

ក្រោយវិញដែរ ដោយស្រែកទាមទារឱ្យកម្លាំងសមត្ថកិច្ចប៉េអឹម ដកចេញឱ្យឆ្ងាយពីបរិវេណមហាវិទ្យាល័យវិញ។ នៅវេលាម៉ោង១០ព្រឹក ថ្ងៃទី២៧ ខែមេសា រថយន្តហ្ស៊ីប១គ្រឿងរបស់មេបញ្ជាការប៉េអឹមម្នាក់ ដែលមានក្រុមអង្គរក្សអង្គុយនៅខាងក្រោយផងនោះ បានបើកកាត់ហ្វូងបាតុករកំពុងឡោមព័ទ្ធពីក្រោយកម្លាំងប៉េអឹមនោះ សំដៅចូលទៅរកកម្លាំងប៉េអឹមជាកូនចៅរបស់ខ្លួន ដែលកំពុងឡោមព័ទ្ធនៅមុខខ្លោងទ្វារមហាវិទ្យាល័យ ស្រាប់តែមានបាតុករម្នាក់បានគប់ដុំថ្មទៅលើរថយន្តហ្ស៊ីបនោះ បណ្តាលឱ្យមេប៉េអឹមម្នាក់នោះ រងរបួសបែកក្បាលយ៉ាងធ្ងន់ ធ្វើឱ្យកម្លាំងប៉េអឹមស៊ូទ្រាំមិនបាន ក៏ធ្វើការបាញ់យ៉ាងសាហាវឃោរឃៅ ធ្វើឱ្យសិស្ស-និស្សិត ត្រូវស្លាប់ នឹងរបួស ហើយរត់ខ្ចាត់ខ្ចាយអស់។ តាមរបាយការណ៍ របស់អ្នកការសែតមួយចំនួនបានឱ្យដឹងថា មានសិស្ស-និស្សិត រងរបួសជាង២០នាក់ និងស្លាប់មួយចំនួន។

នៅរសៀលថ្ងៃដដែលនោះ អ៊ឹម យូហៃ ប្រធានសមាគមសិស្ស និស្សិត បញ្ញវន្តខ្មែរ ក៏បានប្រកាសឱ្យ សិស្ស និស្សិត មកពីគ្រឹះស្ថានសិក្សានៅក្នុងទីក្រុងភ្នំពេញ ទាំងអស់មកជួបជុំគ្នានៅវិមានឯករាជ្យ ដើម្បីធ្វើការថ្កោលទោស និងធ្វើបុណ្យឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធដល់ សិស្ស និស្សិត ដែលកម្លាំងប៉េអឹមបានបាញ់សម្លាប់ ហើយយកសាកសពទៅបោះចោលបាត់នោះផងដែរ។

សិស្ស និស្សិត៤-៥នាក់ ដែលរងរបួសស្រាលក្នុងហេតុការណ៍បាញ់ប្រហារកាលពីព្រឹកនោះ ក៏ត្រូវបានមេដឹកនាំសិស្ស និស្សិតដឹកចេញពីមន្ទីរពេទ្យ ដើម្បីឱ្យមកធ្វើសេចក្តីថ្លែងការណ៍ បញ្ជាក់ពីសកម្មភាពនៃការបាញ់រះនោះ នៅកន្លែងជួបជុំគ្នានៅវិមានឯករាជ្យនោះ ផងដែរ។ ទោះបី ពុំអាចរកសាកសពឃើញយ៉ាងណាក៏ដោយ ក៏មេដឹកនាំបាតុករ បានយកក្តារមឈូសទទេ២ មកតាំងនៅលើខឿនសងខាងជណ្តើរខាងជើងនៃវិមានឯករាជ្យនោះ និងបាននិមន្តព្រះសង្ឃមកឆាន់តាមប្រពៃណីព្រះពុទ្ធសាសនា ដើម្បីឧទ្ទិសកុសលដល់អ្នកដែលស្លាប់ ក្នុងការបាញ់ប្រហារនៅព្រឹកថ្ងៃទី២៧ មេសានោះដែរ។ ប៉ុន្តែគ្មានព្រះសង្ឃអង្គណាហ៊ាននិមន្តមកឆាន់ តាមការនិមន្តរបស់មេដឹកនាំធ្វើបាតុកម្ម នោះទេ ហើយព្រះសង្ឃបានឆ្លើយតបមកវិញថា រដ្ឋាភិបាលមិនអនុញ្ញាតឱ្យ

ព្រះអង្គនិមន្តមកឆាន់ ឬមកសូធ្យមន្ត នៅវិមានឯករាជ្យ នោះទេ។

បញ្ហានេះ ធ្វើឱ្យក្រុមបាតុករកាន់តែមានកំហឹងទៅលើ សឺង ង៉ុកថាញ់ ជារដ្ឋមន្ត្រីទី១ ដែលទើបនឹងឡើងកាន់តំណែង បានប៉ុន្មានថ្ងៃនោះថែមទៀត។ ពួកគេបានសរសេរបដាធំៗថា៖ “ មិនឱ្យព្រះសង្ឃនិមន្តមកឆាន់ គឺទមិឡផតសាសនា ” និងបានទុកចង្ហាន់ដែលនៅត្រៀបត្រានោះឱ្យជូរផ្អូម ដើម្បីជាព័ស្តុតាងបង្ហាញឱ្យអ្នកកាសែត និងមហាជនបានឃើញជាក់ស្តែងទៀតផង។

ចាប់ពីថ្ងៃដំបូង នៃការធ្វើបាតុកម្ម នៅវិមានឯករាជ្យនោះ កម្លាំងកុម្ម៉ង់ដូរបស់សិស្ស និស្សិត បានត្រៀមលក្ខណៈទប់ទល់នឹងការបង្ក្រាប របស់កម្លាំងសមត្ថកិច្ចប៉េអឹម ដោយនាំគ្នាដឹកជញ្ជូនដុំថ្មពីក្នុងវត្តលង្កា ដែលនៅក្បែរនោះ និងបានត្រៀមចម្ពាមកៅស៊ូ គ្រាប់ឃ្លី គ្រាប់ក្រួស ព្រមទាំងពាងដាក់ទឹកនោម បាវក្រចៅ ដាក់ពង្រាយជុំវិញបរិវេណវិមានឯករាជ្យ ព្រមទាំងចែកមើមខ្ទឹមសគ្រប់ៗគ្នា សម្រាប់ហិតការពារផ្សែងពុលរបស់កម្លាំងសមត្ថកិច្ចផងដែរ។

តែទីបំផុត រដ្ឋាភិបាល សឺង ង៉ុកថាញ់ មិនបានចាត់វិធានការបង្ក្រាប ឬវាយបណ្តេញពួកគេ ឱ្យចាកចេញពីបរិវេណវិមានឯករាជ្យ នោះទេ ដោយទុកឱ្យពួកគេធ្វើបាតុកម្មនៅទីនោះ តាមបំណងប្រាថ្នា។

នៅថ្ងៃបញ្ចប់នៃការធ្វើបាតុកម្ម តាំងក្ការមឈូសទទេ នៅវិមានឯករាជ្យរយៈពេល៧ថ្ងៃនោះ សិស្ស និស្សិត នាំគ្នាដង្ហែក្បួនយ៉ាងគគ្រឹកគគ្រេង ដោយមានសិស្សមកពីខេត្ត ជិតៗ ដូចជាខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ជាដើម មកចូលរួមផងដែរ។ ពេលនោះក៏មានសិស្ស និស្សិត៤-៥ នាក់ បានស្ម័គ្រចិត្តកោរសក់ ស្លៀកស ពាក់សដើរនាំមុខក្បួន ចេញពីវិមានឯករាជ្យ តាមមហាវិថីព្រះនរោត្តម “ មហាវិថី ៩ តុលា ” ទៅរមណីយដ្ឋានវត្តភ្នំ ដោយមានវង់ភ្លេងក្លងខែក សម្រាប់ដង្ហែសពនៅពីមុខផង។

បន្ទាប់ពីនោះប្រមាណ១០ម៉ែត្រ គឺ អ៊ុម យូហៃ ប្រធានសមាគម សិស្ស និស្សិតបញ្ញវន្តខ្មែរ ដែលស្លៀកសំពត់ស និងអាវស តែម្នាក់ឯង ហើយនៅខាងក្រោយគាត់ប្រហែល១០ម៉ែត្រដែរនោះ គឺជាក្បួនរបស់ សិស្ស និស្សិត យ៉ាងច្រើនកុះករ ដែលក្បាល

របត់នយោបាយ

ដឹកនាំក្បួនធ្វើដំណើរមកជិតដល់រមណីយដ្ឋានវត្តភ្នំទៅហើយ កន្ទុយក្បួននៅតែមិនទាន់ចេញផុតពីវិមានឯករាជ្យ ទៀត។

ក្បួនដង្ហែ ដោយគ្មានសាកសពរបស់ សិស្ស និស្សិត បានហែប្រទក្សិណវត្តភ្នំ កាត់តាមសួនច្បារខាងមុខបណ្ណាល័យជាតិ ឡើងតាមមហាវិថីព្រះមុនីវង្ស “ មហាវិថីប្រជាធិបតេយ្យ ” កាត់តាមមុខមហាវិទ្យាល័យវេជ្ជសាស្ត្រ រហូតទៅដល់ភ្លើងស្តុបពេទ្យចិន ក៏កាច់ទៅរកវិមានឯករាជ្យវិញ ដោយគ្មានការរំខានពីកម្លាំងសមត្ថកិច្ចឡើយ។

ពេលក្បួនហែដល់វិមានឯករាជ្យ វេលាព្រលប់ទៅហើយនោះ ពួកគេក៏បានធ្វើពិធីបូជាក្តារមឈូសទទេទាំងពីរ ដែលគេបានតម្កល់ទុកនៅទីនោះ៧ថ្ងៃមកហើយ។

ក្នុងព្រឹត្តិការណ៍បាញ់ប្រហារសិស្ស និស្សិត នៅមុខមហាវិទ្យាល័យនីតិសាស្ត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីថ្ងៃទី២៧ ខែមេសានោះ កាសែតនគរធំ បានចុះផ្សាយថា រថយន្តហ្ស៊ីប ដែលបើកកាត់ហ្វូងបាតុករ ចូលទៅខាងមុខមហាវិទ្យាល័យច្បាប់នោះ ជារថយន្តរបស់វរសេនីយ៍ត្រី ឧប គឹមអួន។ កាសែតនគរធំ បានសរសេរចោទប្រកាន់ថា វរសេនីយ៍ត្រី ឧប គឹមអួន ឱ្យកម្លាំងប៉េអឹម បាញ់ប្រហារទៅលើ សិស្ស និស្សិត នៅមុខសាលាច្បាប់នោះ តាមបញ្ជារបស់ទ្រង់ សិរិមតៈ។ កាសែតនគរធំបានសរសេរថា ទ្រង់ សិរិមតៈ បានសម្រេចចិត្តបែបនេះ ដើម្បីសងសឹក សិស្ស និស្សិត ដែលបានធ្វើបាតុកម្មបណ្តេញទ្រង់ឱ្យចុះចេញពីអំណាច ហើយថា ទ្រង់បានឆ្លៀតយកចំណេញ ពីការធ្វើបាតុកម្មដ៏ច្របូកច្របល់នោះ ទៀតផង។

តែវរសេនីយ៍ត្រី ឧប គឹមអួន មិនបានឆ្លើយបំភ្លឺការចោទប្រកាន់របស់កាសែតនគរធំ នោះវិញទេ។ វរសេនីយ៍ត្រី ឧប គឹមអួន ជាប្អូនប្រុសរបស់ ឧប គឹមអាង ជាអតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខ និងធម្មការ (ឆ្នាំ១៩៧០-៧១) និងជាដៃស្តាំរបស់ទ្រង់ សិរិមតៈ។

ក្រោយព្រឹត្តិការណ៍បាញ់ប្រហារ សិស្ស និស្សិត នៅមុខមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យ៉ាងសាហាវឃោរឃៅ នៅព្រឹកថ្ងៃទី២៧ ខែមេសានោះមក គណៈកម្មការសមាគមនិស្សិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

របត់នយោបាយ

បានសម្រេចឱ្យ កុយ ប៊ិច ចេញពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅស្នាក់នៅក្នុងបន្ទាយកងពលធំលេខ១ ដែលមានវរសេនីយ៍ឯក អ៊ិត សួង ជាមេបញ្ជាការ។ ម៉្យាង កុយ ប៊ិច និងវរសេនីយ៍ឯក អ៊ិត សួង ធ្លាប់ស្គាល់គ្នាច្បាស់ផងដែរ។ ទីតាំងបន្ទាយកងពលធំលេខ១ ឋិតនៅប៉ែកខាងកើត ធៀងខាងត្បូង ភ្លើងស្តុបបូកគោ (ទីតាំងស្ថានីយប្រេងកាល់តិច សព្វថ្ងៃ)។




**វរសេនីយ៍ឯក អ៊ិត សួង**

ថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧២ បានចេញសេចក្តីប្រកាសមួយថា៖ ខ្ញុំបាទឈ្មោះ កុយ ប៊ិច មានកូន៥នាក់ ជានិស្សិតមហាវិទ្យាល័យច្បាប់។ តាំងពីពេលខ្ញុំបានរត់គេចខ្លួនទៅនៅក្នុងមហាវិទ្យាល័យច្បាប់មក មានការលួចបាញ់ពីសំណាក់ជនមិនស្គាល់មុខ បណ្តាលឱ្យមានរបួសដល់កូនក្មេងខ្លះដែរ។ តែឥឡូវនេះ ខ្ញុំបានយល់ស្របតាមសេចក្តីសម្រេចរបស់គណៈកម្មការយុវជនខ្ញុំបានមកនៅក្នុងបន្ទាយចម្ការមន ជាមួយលោកស័ក្តិ៥ អ៊ិត សួង ដែលខ្ញុំធ្លាប់ស្គាល់គាត់ច្បាស់។ ពេលនេះ តាមរយៈបង អ៊ិត សួង ខ្ញុំបាទសុំសេចក្តីអនុគ្រោះពីសំណាក់រដ្ឋាភិបាល សូមមេត្តាឈប់ប្រកែប្រកាន់ខ្ញុំបាទ

របត់នយោបាយ

ពីរឿងដែលខ្ញុំបាទ បានរត់គេចខ្លួនទៅ នៅក្នុងមហាវិទ្យាល័យច្បាប់ បណ្តាលឱ្យមានការលួចបាញ់ប្រហារនោះ តទៅទៀត។

នៅពេលនោះ ក្នុងទឹកមុខញញឹមរីករាយ កុយ ប៊ុច បានសារភាពប្រាប់អ្នកយកព័ត៌មានកាសែតប្រយោជន៍ខ្មែរ ថា ក្រោយពីគាត់បានរត់គេចខ្លួន ចូលទៅនៅក្នុងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (សាលាច្បាប់) ដោយមានកម្លាំងកងកុម្ម៉ង់ដូ និស្សិតជាច្រើន ជួយការពារជុំវិញរបង មហាវិទ្យាល័យផងនោះ ឃើញថាសភាពការណ៍មានការច្របូកច្របល់ខ្លាំងឡើងៗ ក៏មានមនុស្សមិនស្គាល់មុខជាច្រើនចូលមកបន្លំខ្លួនធ្វើសកម្មភាពប្រឆាំងរដ្ឋាភិបាល រហូតដល់មានការបាញ់ប្រហារមកលើពួកសិស្ស និស្សិត បណ្តាលឱ្យរងរបួសជាង២០នាក់ និងស្លាប់មួយចំនួន។



លោក កុយ ប៊ុច បានស្គាល់ កំហុសរបស់ខ្លួន

ដើម្បីឆ្លើយតប នឹងការមន្ទិលសង្ស័យថាផ្ទេះផ្ទោះនៃមតិមហាជន យើងសូមលើកយករឿងពិតរបស់លោកកុយប៊ុចមកជម្រាប ដូចតទៅនេះ :

កាលពីម្សិលមិញ នៅវេលាម៉ោង១០កន្លះព្រឹក នាង ទូ វណ្ណា តំណាងសារពត៌មានរដ្ឋប្រយោជន៍ខ្មែរបានអញ្ជើញទៅជួប នឹងលោក កុយប៊ុច នៅឯទីបញ្ជាការយោធា

( តទៅទំព័រ៤១ )

និស្សិត កុយ ប៊ុច

## អ្នកការសែតសម័យសាធារណរដ្ឋខ្មែរ ចុះផ្សាយពីរឿង កុយ ប៊ុច ទទួលស្គាល់កំហុស

កុយ ប៊ុច បានសារភាពបន្តថា អ្វីដែលគាត់ថ្លែងនៅក្នុងទូរទស្សន៍កាលពីនៅថ្ងៃទី២៣ ខែមេសា នោះ គឺគាត់បាននិយាយជ្រុល បណ្តាលឱ្យប៉ះពាល់ដល់រដ្ឋាភិបាលមែន ហើយគាត់សុំទោសរដ្ឋាភិបាលថា ថ្ងៃក្រោយ គាត់លែងធ្វើរបៀបនេះទៀតហើយ ដើម្បី

របត់នយោបាយ

ចៀសវាងកុំឱ្យមាន ការប្រេះឆាក្នុងសង្គមជាតិយើង ក្នុងពេលដែលពួកវៀតកុង-យួនខាងជើង កំពុងចូលយាយីទឹកដីយើងដោយឥតត្រាប្រណី។ ឥឡូវនេះ គាត់កំពុងស្ថិតនៅជាមួយ វរសេនីយ៍ឯក អ៊ិត សួង នៅក្នុងបន្ទាយកងពលធំលេខ១ ដោយមិនមានការចាប់ចង ឬឃុំឃាំងអ្វីទេ។

ចាប់ពីពេលនោះមក យុវជនជា សិស្ស និស្សិត ត្រូវបែងចែកជា២-៣ក្រុម។ ក្រៅពីសមាគមសិស្ស និស្សិត បញ្ញវន្តខ្មែរ ដែលមាន អ៊ឹម យូហៃ ជាប្រធាន ដោយមាន លន់ ណុន នៅពីក្រោយខ្នងនោះ ក៏មានសមាគមយុវជនមួយទៀត ឈ្មោះសមាគមយុវជនខ្មែរប្រឆាំងកុម្មុយនិស្តឥណ្ឌូចិន ហៅកាត់ថា JKACI ( Jeunesse Khmer Anti Communists Indochine ) ដែលមានព្រះអង្គម្ចាស់ សិរិមតៈ នៅពីក្រោយខ្នងដែរ និងមានសមាគមយុវជនជាតិនិយម មួយផ្សេងទៀត។

---

# ៧.៣០ រដ្ឋធម្មនុញ្ញ នៃរបបសាធារណរដ្ឋខ្មែរ






នៅថ្ងៃទី៣០ មេសា ១៩៧២ ពង្រាងរដ្ឋធម្មនុញ្ញ នៃរបបសាធារណរដ្ឋខ្មែរ ត្រូវដាក់ឱ្យធ្វើប្រជាមតិ។ ប៉ុន្តែ ដោយសារពេលនោះ ប្រទេសកំពុងមានសង្គ្រាម ហើយរបបសាធារណរដ្ឋខ្មែរ កាន់កាប់ត្រួតត្រាទឹកដីមួយចំណែកតូច គឺមានតែទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួនប៉ុណ្ណោះ។ ដូច្នេះក្នុងចំណោមប្រជាពលរដ្ឋខ្មែរ សរុបប្រមាណ ៧លាននាក់ ការធ្វើប្រជាមតិនេះមានប្រជាពលរដ្ឋត្រឹមតែ១លាន៥សែននាក់ ប៉ុណ្ណោះ បានចូលរួម និងមានសំឡេងគាំទ្ររដ្ឋធម្មនុញ្ញនោះ៩៧ភាគរយ។ នេះបើតាមការប្រកាសលទ្ធផលរបស់គណៈកម្មាធិការរៀបចំការធ្វើប្រជាមតិ។

១០ថ្ងៃក្រោយមក គឺថ្ងៃទី១០ ឧសភា ប្រធានាធិបតី លន់ នល់ បានប្រកាសឱ្យប្រើប្រាស់រដ្ឋធម្មនុញ្ញថ្មីនេះជាផ្លូវការ ហើយទ្រង់ សិរិមតៈ ក៏ត្រូវបានតែងតាំងជាទីប្រឹក្សាប្រធានាធិបតី។

ខ្លឹមសាររដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២ មាន១១ជំពូក និង ១២១មាត្រា។ យើងសូមធ្វើការដកស្រង់នូវមាត្រាសំខាន់ៗមួយចំនួន របស់រដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋខ្មែរ ដូចមានខាងក្រោមនេះ៖

របត់នយោបាយ

## ជំពូកទី១. បទបញ្ញត្តិជាគ្រឹះ

**មាត្រា១-** ប្រទេសកម្ពុជា ជាសាធារណរដ្ឋ ឯករាជ្យ ប្រជាធិបតេយ្យ ហើយដែលនិយមប្រយោជន៍សង្គម។ ប្រទេសកម្ពុជា មិនអាចបែងចែកបានទេ។ ប្រទេសកម្ពុជាមានឈ្មោះថា សាធារណរដ្ឋខ្មែរ។

**មាត្រា២-** ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

**មាត្រា៣-** អំណាចគ្រប់យ៉ាងចេញមកពីប្រជារាស្ត្រ អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃបច្ចុប្បន្នរដ្ឋធម្មនុញ្ញ។

**មាត្រា៤-** ការបង្កើតគណបក្សនយោបាយ ធ្វើបានដោយសេរី។ ប៉ុន្តែ រដ្ឋឧបត្ថម្ភនូវការផ្តើមគំនិតទាំងឡាយ ដែលនាំឱ្យបន្ថយចំនួនគណបក្សនយោបាយ ឆ្ពោះទៅរករបបដែលមានគណបក្សតែពីរ។

## ជំពូកទី២. សិទ្ធិ និងករណីយកិច្ចនៃពលរដ្ឋ

**មាត្រា៧-** ពលរដ្ឋរាល់រូប មានសេរីភាពសម្តែង គំនិតរបស់ខ្លួន តាមវាចា តាមលាយល័ក្ខណ៍អក្សរ ឬតាមមធ្យោបាយ សម្រាប់ផ្សាយដទៃទៀត។ ក៏ប៉ុន្តែ ពលរដ្ឋត្រូវចៀសវាងកុំប្រើសិទ្ធិនេះ ដោយរំលោភ ហើយនឹងកុំធ្វើឱ្យខូចរបៀបរៀបរយសាធារណៈ។ ការប្រើសេរីភាពសារព័ត៌មាន មិនត្រូវប៉ះពាល់ដល់កិត្តិយសបុគ្គល សន្តិសុខជាតិ ឬទំនៀមទម្លាប់ល្អទេ។ របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់មួយ។

**មាត្រា១២-** សេរីភាពក្នុងការសរសេរលិខិតឆ្លើយឆ្លង លក្ខណៈអាថ៌កំបាំងនៃលិខិតព្រមទាំងការទាក់ទងឆ្លើយឆ្លង តាមរបៀបដទៃទៀត មិនអាចនរណារំលោភបានដាច់ខាត លុះត្រាណាតែមានច្បាប់ចែងខុសពីនេះ ហើយសម្រាប់តែម្តងម្កាល ដោយហេតុឧត្តមប្រយោជន៍នៃប្រទេសជាតិតម្រូវឱ្យធ្វើ។

**មាត្រា១៣-** ការនិរទេស និងការដកសញ្ជាតិខ្មែរ ដោយហេតុនយោបាយត្រូវហាមប្រាម។

**មាត្រា១៨-** រដ្ឋត្រូវខិតខំប្រយុទ្ធ បំបាត់ការចងការប្រាក់គ្រប់ប្រភេទ ដែលយកការប្រាក់លើសកម្រិតច្បាប់កំណត់។

របត់នយោបាយ

**មាត្រា២១-** ពលរដ្ឋម្នាក់ៗ ត្រូវបំពេញបរិចារកិច្ចទាហាន ជាកាតព្វកិច្ចក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់។

## ជំពូកទី៣. ប្រធានាធិបតីនៃសាធារណរដ្ឋ

**មាត្រា២៣-** ប្រធានាធិបតី នៃសាធារណរដ្ឋ ប្រើអំណាចនីតិប្រតិបត្តិ ដែលប្រជារាស្ត្រ ប្រគល់ជូនលោក។

**មាត្រា២៤-** ក្នុងអំឡុងអាណត្តិរបស់លោកប្រធានាធិបតីនៃសាធារណរដ្ឋ មានអនុប្រធានាធិបតីម្នាក់ ជួយធ្វើការ។ ប្រធានាធិបតីនៃសាធារណរដ្ឋ មានខុទ្ទកាល័យប្រតិបត្តិការមួយ និងក្រុមប្រឹក្សាសន្តិសុខមួយ។ ឯការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គការទាំងពីរនេះ ត្រូវកំណត់ក្នុងច្បាប់រៀបចំអង្គការមួយ។

ប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋ ត្រូវជ្រើសតាំងក្នុងសន្លឹកបញ្ជីជាមួយគ្នាសម្រាប់ប្រាំឆ្នាំ ដោយវិធីបោះឆ្នោតជាសាកល ដោយចំពោះ និងជាសម្ងាត់។

មុខងារប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋ មានវិសមិតភាព និងការកាន់កាប់វិជ្ជាជីវៈឧស្សាហកម្ម និងពាណិជ្ជកម្ម និងមុខងារសាធារណៈដទៃទៀត ឬ/និងមុខងារសមាជិករដ្ឋាភិបាល។

ប្រធានាធិបតី នៃសាធារណរដ្ឋ អាចឈរឈ្មោះឱ្យគេជ្រើសតាំងសាជាថ្មី បានតែម្តងប៉ុណ្ណោះ។

**មាត្រា២៥-** ពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះជាបេក្ខជនប្រធានាធិបតី ឬអនុប្រធានាធិបតីនៃសាធារណរដ្ឋបាន កាលណាបានបំពេញលក្ខខណ្ឌដូចតទៅនេះ៖

ក- មានសញ្ញាតិជាខ្មែរតាំងពីកំណើតរហូតមក

ខ- កើតពីមាតាបិតាមានសញ្ជាតិខ្មែរ

គ- មានសហព័ទ្ធសញ្ជាតិជាខ្មែរពីកំណើត បើសាមីខ្លួនភរិយា ឬស្វាមីពេញច្បាប់

ឃ- មានអាយុយ៉ាងតិច៤០ឆ្នាំ មកទល់ថ្ងៃបោះឆ្នោត

ង- ជាអ្នកមានសិទ្ធិបោះឆ្នោតហើយ ប្រកបលក្ខខណ្ឌដទៃទៀត ដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។

របត់នយោបាយ

**មាត្រា២៦-** បេក្ខជននៃសន្លឹកបញ្ជីណា ដែលបានទទួលភាគច្រើនដាច់ខាតនៃសន្លឹកឆ្នោតសម្តែងមតិ ត្រូវបានប្រកាសជាប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋ។

ក្នុងករណីដែលពុំបានភាគច្រើនដាច់ខាត នោះនឹងមានចាត់ការបោះឆ្នោតលើកទីពីរ នៅថ្ងៃទីប្រាំពីរ រាប់បន្ទាប់ពីថ្ងៃបោះឆ្នោតលើកទីមួយ។

នៅពេលបោះឆ្នោតលើកទីពីរ មានតែបេក្ខជននៃសន្លឹកបញ្ជីពីរ ដែលបានទទួលឆ្នោតច្រើនជាងគេ នាលើកទីមួយទេ ដែលអាចឈរឈ្មោះបាន។

ក្នុងការបោះឆ្នោតលើកទីពីរ បេក្ខជន នៃសន្លឹកឆ្នោតណា ដែលបានទទួលឆ្នោតច្រើនជាងគេ ត្រូវជ្រើសតាំងជាប្រធានាធិបតី និងអនុប្រធានាធិបតី។ ក្នុងករណីដែលមានសន្លឹកឆ្នោត មានចំនួនស្មើគ្នា សភាទាំងពីររួមប្រជុំដោយសមាជសភា ក្នុងរយៈវេលាប្រាំពីរថ្ងៃ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងសន្លឹកបញ្ជីមួយ ក្នុងចំណោមសន្លឹកបញ្ជីទាំងពីរខាងលើ ដោយយកតាមមតិភាគច្រើនដោយប្រៀប។

**មាត្រា២៧-** ការចាត់ចែងបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋត្រូវធ្វើក្នុងម្ភៃថ្ងៃយ៉ាងតិច និងសែសិបថ្ងៃយ៉ាងយូរ មុនពេលផុតអាណត្តិប្រធានាធិបតីក្នុងតំណែង។

ក្នុងករណីបោះឆ្នោតមិនកើត ដោយហេតុមានសង្គ្រាម ឬអសន្តិសុខខ្លាំង អាណត្តិប្រធានាធិបតី និងអនុប្រធានាធិបតី នៃសាធារណរដ្ឋ អាចបន្តបានម្តងមួយឆ្នាំៗ។ ការពិនិត្យពិច័យ អំពីភាពបោះឆ្នោតមិនកើត ព្រមទាំងការបន្តអាណត្តិនេះ ត្រូវសម្រេចដោយសភាទាំងពីរ រួមប្រជុំជាសមាជសភា បោះឆ្នោតយកមតិភាគច្រើនដាច់ខាត នៃសមាជិកសមាជសភា បន្ទាប់ពីបានពិគ្រោះនឹងតុលាការធម្មនុញ្ញ។

**មាត្រា២៨-** ច្បាប់រៀបចំអង្គការមួយត្រូវកម្រិតបែបបទ ជ្រើសតាំងប្រធានាធិបតី និងអនុប្រធានាធិបតី នៃសាធារណរដ្ឋ។

**មាត្រា២៩-** មុខងារប្រធានាធិបតី និងអនុប្រធានាធិបតី ចាប់ផ្តើមនៅថ្ងៃថ្លែង

របត់នយោបាយ

សច្ចាប្រណិធាន។ មុខងារនេះ ត្រូវផុតនៅម៉ោងដប់ពីរថ្ងៃត្រង់ នាថ្ងៃទី១៨ ខែមីនា បន្ទាប់ពីពេលផុតរយៈ៥ឆ្នាំបន្តបន្ទាប់គ្នា រាប់ពីពេលជាប់ឆ្នោត។

មុនចូលកាន់តំណែង ប្រធានាធិបតី នៃសាធារណរដ្ឋ ថ្លែងសច្ចាប្រណិធាននៅចំពោះមុខប្រជារាស្ត្រ ដោយមានសមាជិកអង្គការរដ្ឋនានា រួបរួមផង ជាសេចក្តីដូចតទៅ៖

“ ខ្ញុំតាំងសច្ចាជាឱឡារិកចំពោះមុខប្រជារាស្ត្រថា ខ្ញុំនឹងការពារមាតុភូមិ បំពេញដោយស្មោះស្ម័គ្រនូវភារៈប្រធានាធិបតីសាធារណរដ្ឋខ្មែរ គោរពធម្មនុញ្ញ ហើយបូជាខ្លួនខ្ញុំទាំងស្រុង ដើម្បីប្រយោជន៍ប្រជាពលរដ្ឋ និងប្រជាជាតិ ”។

**មាត្រា៣០-** ក្នុងករណីដែលប្រធានាធិបតីនៃសាធារណរដ្ឋ មានធុរៈម្តងម្កាល មុខងារប្រធានាធិបតី វៀរលែងតែមុខងារដែលមានចែងនៅមាត្រា៣៦, ៣៧, ៣៨, ៤១ និង៤២ចេញ ត្រូវអនុប្រធានាធិបតីនៃសាធារណរដ្ឋ កាន់កាប់ជំនួស។

**មាត្រា៣១-** ក្នុងករណីដែលតំណែងប្រធានាធិបតីនៃសាធារណរដ្ឋ នៅជាស្ថាពរ ទោះមកពីហេតុអ្វីក៏ដោយ ឬក្នុងករណីដែលមានការរារាំងជាស្ថាពរ ដែលតុលាការធម្មនុញ្ញបានប្រកាសយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកខ្លួន អនុប្រធានាធិបតីជំនួសប្រធានាធិបតី ដោយទទួលអំណាចទាំងអស់របស់ប្រធានាធិបតី។

ប៉ុន្តែ បើករណីនេះ កើតឡើងជាងដប់ពីរខែមុនពេលផុតអាណត្តិធម្មតានោះ នឹងត្រូវរៀបចំក្នុងរយៈពេលពីរខែយ៉ាងតិច និងបីខែយ៉ាងយូរ ឱ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីសម្រាប់អាណត្តិមួយថ្មី។

**មាត្រា៣២-** ក្នុងករណីដែលដោយហេតុដូចគ្នា និងហេតុដែលមានចែងនៅមាត្រា៣១ វាក្យខ័ណ្ឌទី១ អនុប្រធានាធិបតី ពុំអាចកាន់កាប់មុខងារប្រធានាធិបតីនៃសាធារណរដ្ឋបាន មុខងារនេះ ត្រូវធ្លាក់ទៅលើប្រធានព្រឹទ្ធសភា។ ប្រធានព្រឹទ្ធសភាត្រូវបង្គាប់ឱ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ក្នុងរយៈវេលាពីរខែយ៉ាងតិច ហើយបីខែយ៉ាងយូរ។ ក្នុងរយៈពេលនេះ មិនឱ្យមានការរម្លំរដ្ឋាភិបាល ឬមានការសើរើសមាសភាពនៃរដ្ឋាភិបាលទេ ហើយសភាជាតិ ក៏មិនអាចត្រូវរំលាយបានដែរ។

ក្នុងករណីបោះឆ្នោតមិនកើត ដូចចែងនៅមាត្រា២៧ វាក្យខ័ណ្ឌទី២ ដោយហេតុ

របត់នយោបាយ

មានសង្គ្រាម ឬមានអសន្តិសុខខ្លាំង សភាទាំងពីរនៃសហសភា និងក្រុមប្រឹក្សាសេន្យានុភាពរួមប្រជុំនៅមន្ទីរសភាជាតិ បោះឆ្នោតយកមតិភាគច្រើនដាច់ខាត ដែលចែងនៅវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ដើម្បីជ្រើសរើសប្រធានាធិបតីម្នាក់ ឱ្យបំពេញបង្គ្រប់រយៈពេលអាណត្តិប្រធានាធិបតីសាមីជន។

**មាត្រា៣៣-** ប្រធានាធិបតីនៃសាធារណរដ្ឋ តែងតាំងរដ្ឋមន្ត្រីទី១ និងសមាជិករដ្ឋាភិបាល តាមសេចក្តីស្នើពីរដ្ឋមន្ត្រីទី១។

ប្រធានាធិបតី នៃសាធារណរដ្ឋ អាចបញ្ឈប់សមាជិករដ្ឋាភិបាលមួយរូប ឬទាំងអស់គ្នាពីមុខងាររបស់ខ្លួនបាន។

**មាត្រា៣៤-** ប្រធានាធិបតីនៃសាធារណរដ្ឋ ដឹកនាំការពិភាក្សានៃគណៈរដ្ឋមន្ត្រី។ ក្នុងករណីមានធុរៈ ត្រូវអនុប្រធានាធិបតី ឬបើអនុប្រធានាធិបតីមានធុរៈដែរនោះ ត្រូវរដ្ឋមន្ត្រីទី១ បំពេញកិច្ចនេះជំនួស។

**មាត្រា៣៥-** ប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសឱ្យប្រើច្បាប់ និងចុះហត្ថលេខាលើក្រឹត្យ។ ច្បាប់ដែលសហសភា បានបញ្ចេញមតិយល់ព្រមជាស្ថាពររួចហើយ ត្រូវប្រកាសឱ្យប្រើក្នុង១៥ថ្ងៃ បន្ទាប់ពីពេលដែលប្រធានាធិបតីនៃសាធារណរដ្ឋបានទទួលច្បាប់នោះ មុនផុតរយៈពេលនេះ ប្រធានាធិបតី អាចសុំឱ្យសហសភាពិភាក្សាសាជាថ្មីនូវច្បាប់ ឬមាត្រាខ្លះនៃច្បាប់នោះ។ ការពិភាក្សានេះ ត្រូវធ្វើក្នុងរយៈពេលម្ភៃថ្ងៃយ៉ាងយូរ។

**មាត្រា៣៦-** ប្រធានាធិបតីនៃសាធារណរដ្ឋ តែងតាំងក្នុងមុខតំណែងស៊ីវិល និងទាហាន។ អ្នករដ្ឋការដែលត្រូវតែងតាំងដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី គឺៈ ឯកអគ្គរដ្ឋទូត និងប្រេសិតវិសាមញ្ញ, សមាជិកនៃក្រុមប្រឹក្សារដ្ឋ, អភិបាលខេត្ត, ឧត្តមសេនានីយ៍, សាកលវិទ្យាធិការ, នាយករដ្ឋការកណ្តាល និងសមាជិកនៃក្រុមប្រឹក្សាសេន្យានុភាព។ មុខតំណែងដទៃទៀត ដែលត្រូវតែងតាំងដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ព្រមទាំងលក្ខខណ្ឌដែលប្រធានាធិបតី នៃសាធារណរដ្ឋមានអំណាចតែងតាំងក្នុងនាមរបស់លោក ត្រូវមានរៀបរាប់ក្នុងច្បាប់រៀបចំអង្គការមួយ។

របត់នយោបាយ

**មាត្រា៣៧-** ប្រធានាធិបតីនៃសាធារណរដ្ឋ តែងតាំងឯកអគ្គរដ្ឋទូត និងប្រេសិតវិសាមញ្ញ ជាតំណាងសាធារណរដ្ឋខ្មែរនៅប្រទេសក្រៅ។ រីឯ ឯកអគ្គរដ្ឋទូត រាជទូត និងប្រេសិតវិសាមញ្ញបរទេស ត្រូវទទួលសារតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ។

**មាត្រា៣៨-** ប្រធានាធិបតីនៃសាធារណរដ្ឋ ចុះហត្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយឱ្យសច្ចាប័នលើឯកសារទាំងនេះ ដោយអាស្រ័យការអនុម័តនៃសហសភា។

**មាត្រា៣៩-** បន្ទាប់ពីបានពិគ្រោះ ជាមួយប្រធាននៃសភាទាំងពីរ ប្រធានាធិបតីបន្ទាន់ប៉ះពាល់លើស្ថាប័ននានា នៃសាធារណរដ្ឋ ដល់អាចប្រកាសនូវភាពអាសន្ន ឬវិក្រឹតិកាល ក្នុងករណីមានការគំរាមកំហែងធ្ងន់ និងជាឯករាជ្យជាតិ និងដល់បូរណភាពទឹកដីនៃសាធារណរដ្ឋ។ ប្រធានាធិបតី ត្រូវជូនដំណឹងនេះភ្លាមដល់ប្រជាជាតិតាមសារលិខិត។

ក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីពេលប្រកាសនូវភាពអាសន្ន ឬវិក្រឹតិកាលនោះ សហសភារួមប្រជុំជាសមាជសភា ដើម្បីឱ្យការយល់ព្រម ឬកែប្រែ វិធានការដែលបានបញ្ញត្តិ ឬបញ្ចប់វិធានការនោះ។

ក្នុងកំឡុងពេលពិសេសនេះ សភាជាតិមិនអាចត្រូវរំលាយបានទេ។

**មាត្រា៤០-** ប្រធានាធិបតីនៃសាធារណរដ្ឋ ជាមេបញ្ជាការជាន់ខ្ពស់បំផុតលើកម្លាំងទ័ពរបស់សាធារណរដ្ឋ។

លោកប្រកាសភាពមានសង្គ្រាម ឬប្រកាសថា ប្រជាជាតិស្ថិតក្នុងភយន្តរាយតាមសេចក្តីស្នើពីរដ្ឋាភិបាល ហើយក្រោយដែលមានការយល់ព្រមពីសភាទាំងពីរ រួមប្រជុំជាសមាជ។

**មាត្រា៤១-** ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រាស្រ័យជាមួយនឹងសភាទាំងពីរតាមសារលិខិត ហើយសារលិខិតនេះ មិនត្រូវយកមកពិភាក្សាទេ។ ប្រសិនបើសភាស្ថិតនៅក្នុងវិស្សមកាល សហសភាត្រូវរួមប្រជុំជាពិសេស ដើម្បីស្តាប់សារលិខិតនេះ។

**មាត្រា៤២-** ប្រធានាធិបតីនៃសាធារណរដ្ឋ ជាអ្នកផ្តល់គ្រឿងឥស្សរិយយសជាតិ។

របត់នយោបាយ

លោកមានសិទ្ធិលើកលែង និងបន្ធូរបន្ថយទោស។

## ជំពូកទី៤. រដ្ឋាភិបាល

**មាត្រា៤៣-** រដ្ឋមន្ត្រីទី១ និងសមាជិករដ្ឋាភិបាលទទួលខុសត្រូវចំពោះប្រធានាធិបតី នៃសាធារណរដ្ឋ ពីកិច្ចចាត់ការអនុវត្តនយោបាយរបស់រដ្ឋឱ្យបានសម្រេច។

**មាត្រា៤៤-** មុខងារនៃសមាជិករដ្ឋាភិបាល មានវិសមិតភាព នឹងការកាន់កាប់ វិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងការកាន់កាប់តំណែងក្នុងអង្គការ សាធារណៈណាមួយ។

## ជំពូកទី៥. សហសភា

**មាត្រា៤៦-** សហសភាមានសភាពីរ គឺសភាជាតិ និងព្រឹទ្ធសភា។ សភាជាតិ មានសមាជិកចំនួន៨០នាក់យ៉ាងតិច។ តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះ ឆ្នោតជាសាកល ដោយសម្ងាត់ និងដោយសន្លឹកឆ្នោតមួយ ដែលមាននាមតែមួយ សម្រាប់អាណត្តិ៤ឆ្នាំ។ តំណាងរាស្ត្រអាចឈរឈ្មោះឱ្យគេជ្រើសតាំងសាជាថ្មីបាន។

**មាត្រា៤៨-** ព្រឹទ្ធសភា មានសមាជិកចំនួនពី២៨ទៅ៤០នាក់។ ព្រឹទ្ធសភាជាអង្គ ការតំណាងភូមិភាគផ្សេងៗ នៃសាធារណរដ្ឋ និងអង្គការធំៗនៃរដ្ឋ។ សមាជិក ព្រឹទ្ធសភាត្រូវជ្រើសតាំងសម្រាប់ប្រាំមួយឆ្នាំ ដោយការបោះឆ្នោតជាសាកល ដោយមិន ចំពោះ ជាសម្ងាត់ និងដោយសន្លឹកឆ្នោតមួយ មាននាមតែមួយ ក្នុងបណ្ដាអ្នកមានសិទ្ធិ បោះឆ្នោតទាំងពីរភេទ ដែលមានអាយុយ៉ាងតិចសែសិបឆ្នាំគត់ មកទល់ថ្ងៃបោះឆ្នោត។ សមាជិកព្រឹទ្ធសភា សមាជិកសហសភា ណាក៏ដោយមិនអាចត្រូវគេចោទប្រកាន់តាម រកខ្លួន ចាប់ចង ឃុំឃាំង ឬកាត់ទោសដោយហេតុថា បានសម្ដែងយោបល់ ឬបញ្ចេញ មតិក្នុងការបំពេញមុខងាររបស់ខ្លួន។ សមាជិកសហសភាណា ក៏ដោយនឹងអាចត្រូវគេ ចោទប្រកាន់ ឬចាប់ចងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិមបាន លុះត្រាណាតែមានការ អនុញ្ញាតពីសភា ដែលខ្លួន ជាសមាជិក វៀរលែងតែក្នុងករណី បានប្រព្រឹត្តបទល្មើស ជាក់ស្ដែង ចេញ។ ក្នុងករណីទាំងអស់ ការឃុំឃាំង ឬការចោទប្រកាន់សមាជិកសភា ណាមួយត្រូវផ្អាក ប្រសិនបើមានសមាជិកបីភាគបួន (៣/៤) នៃសភាដែលជាសមាជិក

របត់នយោបាយ
បានបញ្ចេញមតិសុំឱ្យផ្អាក។

## ជំពូកទី៦. ការទាក់ទងរវាងសភា និងរដ្ឋាភិបាល

**មាត្រា៦៦-** អ្នកផ្តើមគំនិតបង្កើតច្បាប់ គឺរដ្ឋាភិបាលក៏បាន សមាជិកសភាក៏បាន ប៉ុន្តែ ការផ្តើមគំនិតខាងចំណាយសម្រាប់បុគ្គលិក ជាភារៈឯកឯងនៃរដ្ឋាភិបាល។

## ជំពូកទី៧. អំណាចតុលាការ

**មាត្រា៨១-** អំណាចតុលាការ ជាអំណាចប្រកបដោយឯករាជ្យភាព អំណាចតុលាការរក្សាការពារអនាគតិ។ អំណាចតុលាការ ការពារសិទ្ធិ និងសេរីភាពពលរដ្ឋ អំណាចនេះត្រូវប្រគល់ទៅតុលាការកំពូល និងទៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ ស្ថាប័នតុលាការនេះ រួមមាន៖ ក្រុមថៅក្រម, តុលាការកំពូល និងឧត្តមក្រុមប្រឹក្សាតុលាការ។

## ជំពូកទី៨. ស្ថាប័នដទៃទៀតរបស់សាធារណរដ្ឋ រួមមាន៖

តុលាការធម្មនុញ្ញ, តុលាការជាន់ខ្ពស់, ក្រុមប្រឹក្សារដ្ឋ, ក្រុមប្រឹក្សាជាតិខាងអប់រំ និងខាងវប្បធម៌, ក្រុមប្រឹក្សាសេនា្យនុភាព, ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច, អភិបាលរដ្ឋ និងកំណែនទូទៅ។

## ជំពូកទី៩. សមូហភាពដែនដី

**មាត្រា១១៤-** សមូហភាពដែនដី នៃសាធារណរដ្ឋគឺ សង្កាត់ ខេត្ត និងក្រុង។ សមូហ-ភាពទាំងនេះ នឹងត្រូវគ្រប់គ្រងខ្លួន តាមលក្ខខណ្ឌមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។

## ជំពូកទី១០. ការពិនិត្យ និងវិសោធនកម្ម

**មាត្រា១១៥-** ការផ្តើមគំនិតពិនិត្យ ឬវិសោធនកម្មនៃរដ្ឋធម្មនុញ្ញជាសិទ្ធិរដ្ឋាភិបាល ឬសមាជិកពាក់កណ្តាលនៃសភាណាមួយរបស់សហសភា។ ការផ្តើមគំនិតពិនិត្យ ឬវិសោធនកម្ម ធ្វើឡើងតាមច្បាប់មួយ ដែលអនុម័តតាមវិធីបោះឆ្នោតចំហ។ ត្រូវកម្រិតយកភាគច្រើនបីភាគបួន នៃសមាជិកសភានីមួយៗនៃសហសភា ហើយការប្រញាប់មិនអាចត្រូវប្រកាសបានឡើយ។

របត់នយោបាយ

**មាត្រា១១៦-** ការពិនិត្យ ឬវិសោធនកម្មណាក៏ដោយត្រូវហាមឃាត់ នៅពេលប្រធានាធិបតីនៃសាធារណរដ្ឋ មានធុរៈម្តងម្កាល។

**មាត្រា១១៧-** ការរើពិនិត្យណាក៏ដោយ ដែលមានគោលបំណងកែប្រែសណ្ឋានសាធារណរដ្ឋនៃប្រទេស ត្រូវហាម មិនឱ្យធ្វើឡើយ។

## ជំពូកទី១១. អន្តរប្បញ្ញត្តិ

ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ ប្រធានាធិបតី លន់ នល់ បានចេញបញ្ញត្តិលេខ ១៩/៧២-បស២ ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ដែលបានធ្វើប្រជាមតិនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ នោះជាផ្លូវការ និងប្រកាសថា រដ្ឋធម្មនុញ្ញនេះនឹងចូលជាធរមាន ចាប់ពីថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧២។

# ឯកសារយោង៖

1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola.
2. Le mal Cambodge Histoire D'une société traditionnelle Face à ses Leaders Politiques 1946-1987. par Marie Alexandrine Martin.
3. Pol Pot Frère Numéro Un. par Davidp - Chandler.
4. Les Lames du Cambodge L'histoire D'un Auto Genocide. par Elizabeth Becker.
5. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud.
6. Cambodge: Rêves et Réalités. par Vandy Kaonn.
7. Histoire du Cambodge 1863 - 1992. par Vandy Kaonn.
8. Cambodia: Year Zero by Francois Ponchaud
9. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.
10. When the War Was Over by Elizabeth Becker
11. How Pol Pot to come Power. By Ben Kiernan.
12. Wikipedia The free encyclopedia.
13. Wikipedia Org. wiki.
14. DP. Pedia org. page.
15. Wikiwand.
16. U.S. Embassy in Cambodia document.
17. Cold war international history Project.

18. The New York Times newspaper.
19. Times Magazine.
20. The Far Eastern Economic Review Magazine.
21. Le Figaro newspaper.
22. Le Monde newspaper.
23. Les Echos newspaper.
24. Le Parisien newspaper.
25. L' humanite newspaper.
26. Liberation newspaper.
27. Washington Post newspaper.
28. Pol Pot by Philip Short.
29. The Gate by Francois Bizot.
30. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.
31. My War with the CIA by Norodom Sihanouk.
32. War and Hope: The Case for Cambodia by Norodom Sihanouk.
33. Flying Tigers Over Cambodia by Larry Partridge.
34. The United States and Cambodia, 1870-1969 By Kenton Clymer.
35. L'histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge (THEATRE) (French Edition).
36. Souvenir doux et amers par Norodom Sihanouk.
37. គុកនយោបាយ ដោយ ប៊ុណ្ណ ចន្ទម៉ុល.

38. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.
39. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្ធី ទត់.
40. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា ដោយ ប៉ែន សុវណ្ណ និងនាង សារុន
41. Des racines dans lapierre par Sam raingsy
42. ខ្មែរអ្នកជាតិនិយម ដោយឡឹក សំអឿន ហៅផ្កាយព្រឹក
43. The one who was shot
44. ធ្វើពលីកម្មដើម្បីជាតិ ដោយ គង់ វន
45. Le Cambodge de Sihanouk by Richard Sola

----------------------------

# ជីវប្រវត្តិសង្ខេបរបស់អ្នកសិក្សាស្រាវជ្រាវ



**រូបថត ឆ្នាំ១៩៨៥**



**រូបថត បច្ចុប្បន្ន**

ឈ្មោះ **ឈឹម សេរីត្ហួន** កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ កើតនៅភូមិស្រម៉ជំ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ឪពុកឈ្មោះ **ឈឹម ប៉ាវ** មានស្រុកកំណើតនៅខេត្តព្រៃវែង មុខរបរជាអ្នកថែសួននៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ម្តាយឈ្មោះ **ទេព ឌុន** មានស្រុកកំណើតនៅខេត្តស្វាយរៀង មុខរបរជាមេផ្ទះ។ មានបង ៣នាក់ (ស្រី១ ប្រុស២) និងប្អូន ៣នាក់(ស្រី២ ប្រុស១)។

ឆ្នាំ១៩៦២ - ៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ នៅម្តុំខាងក្រោយសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រសព្វថ្ងៃ។

ឆ្នាំ១៩៦៣ - ៦៩ រៀននៅសាលាបឋមសិក្សាចង្ក្រានតាព្រហ្មមានជ័យ (វត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ)

ឆ្នាំ១៩៦៩ - ៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក)

ឆ្នាំ១៩៧៤ - ៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជានៅវិទ្យាល័យ កែវ សង់គីម (វិទ្យាល័យ១៨មីនា ១៩៧០ ឬវិទ្យាល័យព្រះយុគន្ធរ)។

**ប្រវត្តិការងារ ៖**

-ពីឆ្នាំ១៩៧៩ - ១៩៨៤ ជានាយកអប់រំឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៤ - ១៩៨៥ ជាអនុប្រធានការិយាល័យអប់រំស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៥ - ១៩៨៦ ជាប្រធានការិយាល័យឃោសនាការ វប្បធម៌ និងព័ត៌មាន ស្រុកមេសាង

-ពីឆ្នាំ១៩៨៦ -១៩៨៧ ជាលេខាបក្សឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៧ -១៩៩៣ ជាប្រធានមន្ទីរគណៈកម្មាធិការបក្សស្រុកមេសាង និងជាសមាជិកគណៈកម្មាធិការបក្សស្រុកមេសាង ខេត្តព្រៃវែង

-ដើមឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ ( UNTAC ) ប្រចាំស្រុកមេសាង ខេត្តព្រៃវែង

-ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ

-ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២២៖ ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយ វិចារណកថា បទបរិយាយ ឱ្យកាសែតចក្រវាឡ, កាសែតអរិយធម៌, កាសែតសំឡេងនិស្សិត, ទស្សនាវដ្ដី កងរាជអាវុធហត្ថរាជធានីភ្នំពេញ ។ ជានិពន្ធនាយកទស្សនាវដ្ដីអង្គរធំ, ជានិពន្ធនាយកទស្សនាវដ្ដីខេមរា, ជានិពន្ធនាយកទស្សនាវដ្ដីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្ដីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រ TVFB, ជានិពន្ធនាយកគេហទំព័រ KBN និងជាប្រធានផ្នែកព័ត៌មានជាតិ គេហទំព័រ SBM News និងជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្របត់នយោបាយ

-ឆ្នាំ២០២២ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ

-ឆ្នាំ២០២៣ ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

----------------------------

UNITED NATIONS
UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA (UNTAC)

NATIONS UNIES
AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE (APRONUC)

CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,
H. Prasad
Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93



សៀវភៅដែលមានចំណងជើងថា " **របត់នយោបាយ** " ត្រូវបានបោះពុម្ពជាសៀវភៅ តាំងពីភាគទី១ រហូតដល់ភាគទី៧នេះ ស្របតាមបំណងប្រាថ្នាប្រកបដោយគតិបណ្ឌិត និងមនសិការប្រវត្តិសាស្ត្រជាតិដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រដ៏ពិស្តារមួយ ឱ្យយុវជនសម័យបច្ចុប្បន្ននេះក៏ជាកូនចៅជំនាន់ក្រោយៗទៀត បានសិក្សាស្រាវជ្រាវត្រិះរិះពិចារណាពីព្រឹត្តិការណ៍នយោបាយសំខាន់ៗ ដែលកើតមានឡើងតាំងពីសម័យអណានិគមបារាំង មក។

ប្រសិនបើគ្មានការជួយឧបត្ថម្ភគាំទ្រពី **សម្តេចក្រឡាហោម** ទេនោះក៏គ្មានវត្តមានសៀវភៅប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់នេះដែរ។

ខ្ញុំបាទសូមលំឱនកាយគោរពថ្លែងអំណរគុណ និងសូមប្រសិទ្ធពរជ័យជូន **សម្តេចក្រឡាហោម ស ខេង** សូមមានសុខភាពល្អបរិបូណ៌ អាយុយឺនយូ បញ្ញាញាណភ្លឺថ្លា ទទួលបានមហាជោគជ័យគ្រប់ភារកិច្ច។

សូម **សម្តេច** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ

**ឈឹម សេរីត្នួន**